ឯកសារផ្តល់ព័ត៌មាន

ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រជាសាធារណៈលើកដំបូង

PESTECH

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

(ក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្មលេខ៖ ០០០០០៩៥៧)

(បង្កើតឡើងក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា)

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងចំនួនរហូតដល់ ៣.៩៤៥.០០០ ភាគហ៊ុនធម្មតាថ្មីរបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក ជាមួយនឹងការចុះបញ្ជីរបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក នៅក្នុងទីផ្សារគោលនៃផ្សារមូលបត្រកម្ពុជា។

ក្នុងតម្លៃ ៣.១២០ រៀល (០,៧៦ ដុល្លារអាមេរិក) ក្នុងមួយភាគហ៊ុន ដែលត្រូវបង់ឱ្យគ្រប់ចំនួននៅពេលដាក់ពាក្យស្នើសុំ។



ក្រុមហ៊ុនទីប្រឹក្សា និងធានាទិញមូលបត្រ

RHB

អ អេច ប៊ី ស៊ីយ្យូរីធី (ខេមបូឌា) ម.ក

វិនិយោគិនត្រូវបានណែនាំឱ្យអាន និងយល់អំពីខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាននេះ។ ប្រសិនបើមានចម្ងល់សូមធ្វើការប្រឹក្សាយោបល់ជាមួយអ្នកប្រឹក្សាយោបល់ជំនាញ។

សម្រាប់ព័ត៌មានអំពីកត្តាហានិភ័យទាំងឡាយដែលវិនិយោគិនគួរពិចារណា សូមអានកត្តាហានិភ័យក្នុងផ្នែកទី ៣ នៃឯកសារផ្តល់ព័ត៌មាននេះ។

ក្រុមហ៊ុន និងស្ថាប័នពាក់ព័ន្ធដែលបានរៀបចំឯកសារផ្តល់ព័ត៌មាននេះ នឹងត្រូវទទួលខុសត្រូវទៅលើព័ត៌មានដែលមាននៅក្នុងឯកសារនេះ

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

ឈ្មោះរបស់អ្នកតំណាងបោះផ្សាយលក់មូលបត្រ	:	Lim Pay Chuan (Paul Lim)		
អាសយដ្ឋាន	:	លេខ ៦ ផ្លូវ ៥៨៨ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា		
គេហទំព័រ	:	www.pestech.com.kh		
អ៊ីម៉ែល	:	info@pestech.com.my		
លេខទូរស័ព្ទ	:	+៨៥៥ ២៣ ៨៨២ ១០៥		
លេខទូរសារ	:	+៨៥៥ ២៣ ៨៨២ ១០៦		
លេខចុះបញ្ជីពាណិជ្ជកម្ម	:	០០០០០៩៥៧	កាលបរិច្ឆេទ	: ០៥ កុម្ភៈ ២០១០
អាជ្ញាបណ្ណចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	:	៣២៦ ឯនស/អសន	កាលបរិច្ឆេទ	: ២០ ធ្នូ ២០១៨

ការបោះផ្សាយលក់មូលបត្រកម្ពុជា

លេខវិញ្ញាបនបត្រចុះបញ្ជី	:	១៣៤/២០ ស.ម.ក/សាធារ
កាលបរិច្ឆេទចេញដោយគណៈកម្មការមូលបត្រកម្ពុជា	:	២៤ - មករា - ២០២០

ក្រុមហ៊ុនទីប្រឹក្សា និងធានាទិញមូលបត្រគ្រប់គ្រង : **អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក**

ឯកសារផ្តល់ព័ត៌មាននេះ និងឯកសារបន្ថែមនានាអាចរកបាននៅ៖

- ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក៖ លេខ៦ ផ្លូវ៥៨៨ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- ក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក៖ ជាន់ M OHK Tower ផ្លូវលេខ១១០ កែងនឹងផ្លូវលេខ៩៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក៖ ជាន់ទី១ OHK Tower ផ្លូវលេខ១១០ កែងនឹងផ្លូវលេខ៩៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទ ៖ ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២០

បុគ្គលដែលទទួលបន្ទុកក្នុងការឯកសារផ្តល់ព័ត៌មាន៖

ឈ្មោះ ៖ លោក អ៊ីវ រ៉ាណារិទ្ធ មុខងារ ៖ នាយកប្រតិបត្តិ
អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក

លេខទូរស័ព្ទ ៖ +៨៥៥ ២៣ ៩៦៩ ១៦១

អ៊ីម៉ែល ៖ ranarith.iv@rhbgroup.com

សេចក្តីជូនដំណឹងចំពោះវិនិយោគន

ក្រុមប្រឹក្សាភិបាល (តទៅនេះហៅថា "**ក្រុមប្រឹក្សា**") របស់ក្រុមហ៊ុនផេសថិក (ខេមបូឌា) ម.ក (តទៅនេះហៅថា "**ផេសថិក(ខេមបូឌា)**") បានអនុម័តលើឯកសារផ្តល់ព័ត៌មាននេះ ក្នុងគោលបំណងស្នើ/បោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (តទៅនេះហៅថា "**ការបោះផ្សាយលក់ជាសាធារណៈ**") ព្រមទាំងទទួលខុសត្រូវជារួម និងដោយឡែក លើភាពត្រឹមត្រូវនៃព័ត៌មាន ដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មាននេះ។ ក្រោយពីបានសួរបញ្ជាក់ និងផ្ទៀតផ្ទាត់ដោយផ្អែកលើការយល់ដឹង និងការយល់ឃើញរបស់ខ្លួន ក្រុមប្រឹក្សាសូមធានាថា មិនមានសេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឱ្យយល់ខុសនៅក្នុងឯកសារផ្តល់ព័ត៌មាននេះ ឬមិនមានការលាក់បាំងនូវព័ត៌មានពិតដ៏ទៃទៀតដែលបណ្តាលឱ្យសេចក្តីថ្លែងណាមួយនៅក្នុងឯកសារផ្តល់ព័ត៌មាននេះមានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុសនោះឡើយ។

គ.ម.ក បានផ្តល់ការអនុញ្ញាតលើសំណើរបស់ក្រុមហ៊ុន ក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ហើយឯកសារផ្តល់ព័ត៌មានជាច្បាប់ចម្លងភាសាខ្មែរ ត្រូវបានចុះបញ្ជី និងបានតម្កល់ទុកនៅ គ.ម.ក។ ការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានជាភាសាខ្មែរនេះ មិនមានន័យថា គ.ម.ក ផ្តល់អនុសាសន៍ឱ្យទិញមូលបត្របោះផ្សាយលក់ ឬទទួលខុសត្រូវលើភាពត្រឹមត្រូវនៃព័ត៌មាន យោបល់ ឬសេចក្តីថ្លែងដែលមានបង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មាននេះឡើយ។

គ.ម.ក មិនទទួលខុសត្រូវចំពោះព័ត៌មានដែលមិនបានផ្តល់ និងខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន ហើយក៏មិនបញ្ជាក់ពីភាពត្រឹមត្រូវ ឬភាពពេញលេញរបស់ឯកសារផ្តល់ព័ត៌មាននេះដែរ។ គ.ម.ក មិនទទួលខុសត្រូវចំពោះការខាតបង់ណាមួយដែលវិនិយោគិនអាចនឹងប្រឈមកើតចេញពីផ្នែកណាមួយ ឬទាំងស្រុងពីខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាននេះឡើយ។

វិនិយោគិនគួរពឹងផ្អែកលើការវាយតម្លៃផ្ទាល់ខ្លួន ទៅលើភាពត្រឹមត្រូវនិងហានិភ័យដែលពាក់ព័ន្ធនឹងសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដោយពិចារណាលើកត្តាផ្សេងៗមានជាអាទិ៍គោលបំណងនៃការវិនិយោគ ហានិភ័យ និងស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនជាដើម។ ប្រសិនបើវិនិយោគិនមានចម្ងល់ពាក់ព័ន្ធនឹងឯកសារផ្តល់ព័ត៌មាននេះ ឬស្ថិតក្នុងការពិចារណាក្នុងការវិនិយោគ វិនិយោគិនគួរធ្វើការប្រឹក្សាយោបល់ជាមួយក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ឬទីប្រឹក្សាជំនាញដទៃទៀត។

កាលបរិច្ឆេទ៖ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០២០

ហត្ថលេខា និងត្រា

ឧកញ៉ា Lim Pay Chuan

ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ

ការទទួលខុសត្រូវរបស់ក្រុមហ៊ុនឆ្មោះផ្សាយ ក្រុមហ៊ុនធានាទិញ និងអ្នកប្រឹក្សាយោបល់ដែលពាក់ព័ន្ធដទៃទៀត

ព័ត៌មាននៅក្នុងឯកសារផ្តល់ព័ត៌មាននេះត្រូវបានផ្តល់ដោយក្រុមប្រឹក្សាភិបាលក្រុមហ៊ុនផេសទិក (ខេមបូឌា) លើកលែងតែមានការលើកឡើងផ្សេងពីនេះអំពីប្រភពព័ត៌មាន។ បន្ទាប់ពីបានពិនិត្យឡើងវិញដោយយកចិត្តទុកដាក់ តាមការយល់ច្បាស់ និងជឿជាក់របស់ក្រុមហ៊ុនយើង ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនផេសទិក (ខេមបូឌា) បញ្ជាក់ថា រាល់ព័ត៌មានទាំងអស់នៃឯកសារផ្តល់ព័ត៌មាននេះគឺត្រឹមត្រូវ គ្មានការលុប ឬចំណុចដែលអាចភ័ណ្ឌច្រលំលើព័ត៌មាន ឬខ្វីមសារនៅក្នុងឯកសារផ្តល់ព័ត៌មាននេះឡើយ។

ក្រុមប្រឹក្សាភិបាល ក្រុមហ៊ុនផេសទិក (ខេមបូឌា) ទទួលខុសត្រូវទាំងស្រុង ជារួម ឬដោយឡែក លើភាពត្រឹមត្រូវ និងភាពពេញលេញនូវព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មាននេះ។ ក្រុមហ៊ុនធានាទិញបានខិតខំរិះរកមធ្យោបាយតាមការដែលអាចធ្វើបានដើម្បីធ្វើឲ្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និងពេញលេញនូវឯកសារផ្តល់ព័ត៌មាននេះ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនធានាទិញមិនមានទំនួលខុសត្រូវចំពោះភាពត្រឹមត្រូវ និងព័ត៌មានពេញលេញដែលមានក្នុងឯកសារផ្តល់ព័ត៌មាននេះឡើយ។

ព័ត៌មានទូទៅ

ឯកសារផ្តល់ព័ត៌មានជាភាសាខ្មែរនេះត្រូវបានចុះបញ្ជីនៅ គ.ម.ក។ ឯកសារផ្តល់ព័ត៌មានជាភាសាអង់គ្លេស និងការបកប្រែជាភាសាអង់គ្លេសដែលមាននៅក្នុងឯកសារនេះ គឺធ្វើឡើងក្នុងឆន្ទៈ និងគោលបំណងដើម្បីជាឯកសារយោងសុទ្ធសាធ។ លោកអ្នកបានទទួលស្គាល់ និងយល់ច្បាស់ថា រាល់ការបកប្រែរវាងភាសាទាំងពីរ ការបកប្រែចំពោះពាក្យជាក់លាក់ណាមួយ ឬឃ្លាណាមួយនៅក្នុងភាសាមួយ អាចមិនមានភាពច្បាស់លាស់ដើម្បីបង្ហាញអត្ថន័យពេញលេញនៃពាក្យ ឬឃ្លានៃភាសាមួយផ្សេងទៀត។ យើងខ្ញុំមិនទទួលយក ឬសន្មតយកនូវការទទួលខុសត្រូវ ឬកាតព្វកិច្ចណាមួយដែលកើតមានឡើងពាក់ព័ន្ធជាមួយនឹងហេតុការណ៍ដែលកើតឡើងដោយសារ ឬចេញពីភាពមិនច្បាស់លាស់ កង្វះខាត ឬការលុបចេញពីឯកសារផ្តល់ព័ត៌មានជាភាសាអង់គ្លេសធៀបជាមួយនឹងឯកសារផ្តល់ព័ត៌មានជាភាសាខ្មែរឡើយ។

លោកអ្នកគួរតែពឹងផ្អែកលើការវាយតម្លៃផ្ទាល់ខ្លួនក្នុងការប៉ាន់ស្មានពីហេតុការណ៍ និងហានិភ័យនៃការវិនិយោគជាមួយក្រុមហ៊ុនរបស់យើងខ្ញុំ។ ប្រសិនបើលោកអ្នកមានចម្ងល់អំពីវិធីសាស្ត្រនៃការវិនិយោគនេះ លោកអ្នកអាចពិគ្រោះយោបល់ជាមួយក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ឬទីប្រឹក្សាជំនាញដ៏ទៃទៀត។

ការចែកចាយ

ច្បាប់ចម្លងឯកសារផ្តល់ព័ត៌មានជាភាសាខ្មែរ និងភាសាអង់គ្លេសក៏អាចចូលមើល និងទាញយកបានពីគេហទំព័ររបស់ក្រុមហ៊ុនបោះផ្សាយ www.pestech.com.kh គេហទំព័ររបស់ក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក www.rhbgroup.com.kh និងតាមរយៈគេហទំព័ររបស់ភ្នាក់ងារលក់ដែលទទួលបានការតែងតាំង។ ឯកសារផ្តល់ព័ត៌មានជាទម្រង់អេឡិចត្រូនិច ក៏អាចផ្តល់ជូនដល់អនាគតវិនិយោគិន ឬបុគ្គលផ្សេងទៀតតាមរយៈអ៊ីម៉ែលទៅតាមការស្នើសុំ។

លោកអ្នកទទួលស្គាល់ថាឯកសារផ្តល់ព័ត៌មាននេះ និងខ្លឹមសារដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មាននេះ អាចនឹងត្រូវបានធ្វើការកែប្រែ ផ្លាស់ប្តូរ ឬ ធ្វើបច្ចុប្បន្នភាព ដោយមិនមានការជូនដំណឹង (១) នៅអំឡុងពេលដំណើរការផ្ទេរប្រព័ន្ធអេឡិចត្រូនិច (២) ស្របតាមច្បាប់ និងបញ្ញត្តិផ្សេងៗដែលមានជាធរមាន (៣) សម្រាប់គោលបំណងចុះបញ្ជីស្តាពរជាមួយនឹង គ.ម.ក ឬ (៤) តាមការសម្រេចចិត្តជាឯកច្ឆន្ទក្រោមសមត្ថកិច្ចត្រឹមត្រូវ។

ប្រសិនបើលោកអ្នកមានចម្ងល់អំពីសុពលភាព ឬសុចរិតភាព នៃឯកសារផ្តល់ព័ត៌មានតាមប្រព័ន្ធអេឡិចត្រូចនិច លោកអ្នកគួរធ្វើការស្នើសុំឯកសារផ្តល់ព័ត៌មានជាក្រដាស ឬជាការបោះពុម្ពចម្លងពីយើងខ្ញុំ ឬក្រុមហ៊ុនធានាទិញមូលបត្ររបស់យើងខ្ញុំ។ ប្រសិនបើមានភាពមិនស្របគ្នារវាងខ្លឹមសារនៃឯកសារផ្តល់ព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិច និងឯកសារផ្តល់ព័ត៌មានជាក្រដាស ឬជាការបោះពុម្ពចម្លង ខ្លឹមសារនៃឯកសារផ្តល់ព័ត៌មានជាក្រដាស ឬជាការបោះពុម្ពចម្លងដែលដូចគ្នាជាមួយនឹងច្បាប់ចម្លងឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីនៅ គ.ម.ក ត្រូវចាត់ទុកជាឯកសារបានការ។

រាល់ការយោងពាក់ព័ន្ធនឹងឯកសារផ្តល់ព័ត៌មាននេះ នៅគេហទំព័ររបស់តតិយជន (តទៅនេះហៅថា "គេហទំព័រតតិយជន") ដោយតំណភ្ជាប់គេហទំព័រ ឬតាមវិធីនៃការពិពណ៌នារបស់គេហទំព័រតតិយជន លោកអ្នកទទួលស្គាល់ និងយល់ស្របថា៖

- យើងខ្ញុំមិនទទួលខុសត្រូវ និងមិនមានការពាក់ព័ន្ធណាមួយជាមួយនឹងគេហទំព័រតតិយជនឡើយ។ ដោយហេតុនេះ យើងខ្ញុំមិនទទួលខុសត្រូវចំពោះឯកសារ ឬ ខ្លឹមសារ ឬ ទិន្នន័យនៃឯកសារ ឬ ឯកសារផ្សេងៗទៀតដែលផ្តល់ឱ្យនៅលើគេហទំព័រតតិយជនឡើយ។ លោកអ្នកទទួលខុសត្រូវផ្ទាល់ទៅលើហានិភ័យដែលពាក់ព័ន្ធទៅនឹងការចូល ឬប្រើប្រាស់គេហទំព័រតតិយជន។
- យើងខ្ញុំមិនទទួលខុសត្រូវលើគុណភាពផលិតផល ឬសេវាកម្មរបស់គេហទំព័រតតិយជនឡើយ ជាពិសេសក្នុងការបំពេញលក្ខខណ្ឌនៃការព្រមព្រៀងណាមួយជាមួយនឹងគេហទំព័រតតិយជន។ យើងខ្ញុំក៏មិនទទួលខុសត្រូវលើការបាត់បង់ ឬការខូចខាត ឬការខាតបង់ជាសាច់ប្រាក់ ដែលអាចកើតឡើងចំពោះលោកអ្នក ឬកើតចេញពីទំនាក់ទំនង ឬជាលទ្ធផល ដែលកើតចេញពីទំនាក់ទំនងជាមួយនឹង គេហទំព័រតតិយជន ឬការប្រើប្រាស់ ឬការពឹងផ្អែកទៅលើទិន្នន័យ ព័ត៌មាន ឯកសារ ឬ ឯកសារផ្សេងៗទៀតដែលផ្តល់ជូនដោយភាគីនោះឡើយ។

- ហើយរាល់ទិន្នន័យ ឯកសារផ្សេងៗ ដែលបានទាញយកពីគេហទំព័រតិយជន គឺធ្វើឡើងចេញពីការសម្រេចចិត្ត និងទទួលយកនូវហានិភ័យផ្ទាល់ខ្លួន។ យើងខ្ញុំគ្មានកាតព្វកិច្ច ការទទួលខុសត្រូវ ឬមានការណីយកិច្ច ចំពោះការខូចខាតដែលកើតមានឡើងលើប្រព័ន្ធកុំព្យូទ័ររបស់លោកអ្នក ឬការបាត់បង់ទិន្នន័យដែលចេញពីការទាញយកនូវទិន្នន័យ ឯកសារ ឬឯកសារផ្សេងៗទៀតពីគេហទំព័រតិយជនឡើយ។

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា

ការចែកចាយឯកសារផ្តល់ព័ត៌មាននេះ និងសំណើដាក់លក់ ព្រមទាំងការលក់មូលបត្រកម្មសិទ្ធិ អាចផ្ទុយនឹងច្បាប់នៅក្នុងដែនសមត្ថកិច្ចជាក់លាក់ណាមួយ។ វាជាកាតព្វកិច្ចផ្ទាល់របស់វិនិយោគិនក្នុងការពិនិត្យមើលការហាមឃាត់ដែលអាចនឹងអនុវត្តចំពោះឯកសារផ្តល់ព័ត៌មាននេះ និងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនៅក្នុងដែនសមត្ថកិច្ចដែលពាក់ព័ន្ធ។ ឯកសារផ្តល់ព័ត៌មាននេះមិនមានបង្កើតសំណើដាក់លក់មូលបត្រណាមួយ ឬសំណើដាក់លក់ផ្សេងទៀត ឬបញ្ចុះបញ្ចូលឱ្យទិញមូលបត្រណាមួយរបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) នៅក្នុងដែនសមត្ថកិច្ចណាមួយ ពីបុគ្គលណាម្នាក់ដែលមិនមានសិទ្ធិស្របច្បាប់ដើម្បីធ្វើការដាក់សំណើលក់មូលបត្រនៅក្នុងដែនសមត្ថកិច្ចនោះឡើយ។

បុគ្គលណាម្នាក់ដែលស្ថិតក្នុងដែនសមត្ថកិច្ចក្រៅពីព្រះរាជាណាចក្រកម្ពុជាដែលមិនមានការហាមឃាត់នូវការចែកចាយឯកសារផ្តល់ព័ត៌មាននេះ ឬការដាក់សំណើ ឬការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ត្រូវស្វែងរកការប្រឹក្សាយោបល់ជំនាញពាក់ព័ន្ធនឹងខ្លឹមសារនៃឯកសារនេះ ព្រមទាំងច្បាប់ពាក់ព័ន្ធ និងប្រព័ន្ធពន្ធដារក្នុងព្រះរាជាណាចក្រកម្ពុជា។

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា

ការបដ្ឋាញអំពីព័ត៌មាន

រាល់ការប្រើប្រាស់ពាក្យ "ក្រុមហ៊ុនយើង" ឬ "ក្រុមហ៊ុន ផេសថិក (ខេមបូឌា)" នៅក្នុងឯកសារផ្តល់ព័ត៌មាននេះគឺសំដៅដល់ក្រុមហ៊ុនផេសថិក (ខេមបូឌា) ម.ក ហើយរាល់ការប្រើប្រាស់សព្វនាម "សម្ព័ន្ធក្រុមហ៊ុនផេសថិក (ខេមបូឌា)" "សម្ព័ន្ធរបស់យើង" "យើង" "របស់យើង" "នៃយើង" និង "ខ្លួនយើង" គឺសំដៅដល់ក្រុមហ៊ុនយើង និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើងដោយឡែក ឬជារួមទៅតាមករណីនីមួយៗ។ លុះត្រាមានតម្រូវការផ្សេងក្នុងបរិបទ រាល់ការប្រើប្រាស់ពាក្យ "ថ្នាក់គ្រប់គ្រង" គឺសំដៅដល់នាយកប្រតិបត្តិរបស់ក្រុមហ៊ុន និងអ្នកគ្រប់គ្រងសំខាន់ៗនាកាលបរិច្ឆេទអនុវត្តចុងក្រោយ ហើយរាល់សេចក្តីថ្លែងការណ៍ដែលចេញពីថ្នាក់គ្រប់គ្រងយើង គឺស្របទៅតាមការជឿជាក់ ការរំពឹងទុក ការវាយតម្លៃ និងមតិយោបល់របស់យើង។

រាល់ការប្រើប្រាស់ពាក្យ "សម្ព័ន្ធក្រុមហ៊ុនផេសថិកអន្តរជាតិ" ឬ "PIB" គឺសំដៅដល់ ក្រុមហ៊ុន PESTECH International Berhad និងបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុននេះ។

រាល់ការប្រើប្រាស់ពាក្យ "គម្រោង" គឺសំដៅលើការងារវិស្វកម្ម លទ្ធកម្ម សាងសង់ និងដាក់ឱ្យប្រើប្រាស់អនុស្ថានីយ៍ (EPCC) ខ្សែបណ្តាញបញ្ជូន ក៏ដូចជាប្រព័ន្ធខ្សែកាបថាមពលបង្កប់ក្រោមដីសម្រាប់ការបញ្ជូន និងចែកចាយថាមពលអគ្គិសនី។

ភាពខុសគ្នាណាមួយនៅក្នុងតារាង រវាងចំនួនដែលបានរៀបរាប់ និងចំនួនសរុបនៅក្នុងឯកសារផ្តល់ព័ត៌មាននេះ គឺកើតចេញពីការបង្គត់។ ពាក្យអក្សរកាត់ និងពាក្យបំព្រួញ ដែលប្រើប្រាស់នៅក្នុងនេះ ត្រូវបានកំណត់អត្ថន័យនៅក្នុងផ្នែក "និយមន័យ" ហើយពាក្យបច្ចេកទេសដែលប្រើប្រាស់នៅទីនេះ ត្រូវបានកំណត់អត្ថន័យក្នុងផ្នែក "សន្ទានុក្រមនៃវាក្យស័ព្ទ" ដែលមាននៅផ្នែកបន្ទាប់។ ពាក្យបញ្ជាក់ពីឯកវចន: ត្រូវរួមបញ្ចូលទាំង ពហុវចន: និងផ្ទុយទៅវិញ ហើយពាក្យបញ្ជាក់ពីភេទប្រុស ត្រូវរួមបញ្ចូលទាំងភេទស្រី និងអភេទ និងផ្ទុយទៅវិញទៅតាមបរិបទ។ រាល់ការប្រើប្រាស់ពាក្យបុគ្គល គឺរួមបញ្ចូលទាំងរូបវន្តបុគ្គល ក្រុមហ៊ុន និងក្រុមហ៊ុនសាជីវកម្ម។

រាល់ការយោងផ្សេងៗនៅក្នុងឯកសារផ្តល់ព័ត៌មាននេះទៅនឹងការអនុម័តណាមួយ គឺសំដៅដល់ការយោងទៅដល់ការអនុម័តសម្រាប់ពេលកំពុងត្រូវបានធ្វើវិសោធនកម្ម ឬអនុម័តសារជាថ្មី។ រាល់ការយោងទៅនឹងពេលវេលាក្នុងឯកសារផ្តល់ព័ត៌មាននេះ គឺត្រូវយោងទៅតាមម៉ោងរបស់ព្រះរាជាណាចក្រកម្ពុជា លុះត្រាតែមានការកំណត់ផ្សេងក្រៅពីនេះ។

ឯកសារផ្តល់ព័ត៌មាននេះ រួមបញ្ចូលទិន្នន័យស្ថិតិដែលផ្តល់ឱ្យដោយថ្នាក់គ្រប់គ្រងរបស់យើង និងតតិយជនផ្សេងទៀត ព្រមទាំងឯកស្រង់ចេញពីការព្យាករណ៍របស់តតិយជនពាក់ព័ន្ធនឹងការរីកចម្រើន និងប្រតិបត្តិការរបស់ឧស្សាហកម្មដែលយើងដំណើរការ។ ទិន្នន័យនេះ ត្រូវបានយកចេញ ឬទាញយកពីព័ត៌មានដែលបោះផ្សាយចេញពីប្រភពឧស្សាហកម្ម និងចេញពីទិន្នន័យផ្ទៃក្នុងរបស់យើង។ ក្នុងករណីនីមួយៗ ប្រភពទិន្នន័យគឺត្រូវបានរៀបរាប់នៅក្នុងឯកសារផ្តល់ព័ត៌មាននេះ ក្នុងករណីគ្មានការបញ្ជាក់អំពីប្រភពទិន្នន័យ នោះអាចសន្មតបានថាទិន្នន័យនោះគឺមានប្រភពមកពីយើង។

ជាពិសេស ព័ត៌មានជាក់លាក់នៅក្នុងឯកសារផ្តល់ព័ត៌មាននេះ ត្រូវបានយកចេញ ឬ ដកស្រង់ចេញពីរបាយការណ៍ដែលរៀបចំឡើងដោយ ក្រុមហ៊ុន Smith Zander International Sdn Bhd ("Smith Zander") ដែលជាអាជីវកម្មឯករាជ្យ

និងជាក្រុមហ៊ុនប្រឹក្សាផ្នែកស្រាវជ្រាវទីផ្សារ។ យើងជឿជាក់ថាទិន្នន័យស្ថិតិ និងការព្យាករណ៍ដែលរៀបរាប់នៅក្នុងឯកសារផ្តល់ព័ត៌មាននេះ មានសារៈប្រយោជន៍ក្នុងការជួយលោកអ្នកឱ្យមានការយល់ដឹងអំពីនិន្នាការចម្បងនៅក្នុងឧស្សាហកម្មដែលយើងដំណើរការ។ ផ្ទុយទៅវិញ ទាំងក្រុមហ៊ុន ឬ ក្រុមហ៊ុនធានាទិញមូលបត្រមិនបានធ្វើការធ្វើទិន្នន័យនេះដាច់ដោយឡែកឡើយ។ ទាំងក្រុមហ៊ុន ឬ ក្រុមហ៊ុនធានាទិញមូលបត្រមិនបានអះអាងអំពីភាពត្រឹមត្រូវ ភាពជាក់លាក់ ឬ ភាពពេញលេញរបស់ទិន្នន័យនោះឡើយ។ ដូចគ្នាផងដែរ ការព្យាករណ៍ចេញពីតតិយជន ដែលដកស្រង់នៅក្នុងឯកសារផ្តល់ព័ត៌មាននេះ អាចមានភាពមិនច្បាស់លាស់ ដែលអាចធ្វើឱ្យទិន្នន័យជាក់ស្តែងមានការប្រែប្រួលខ្លាំងពីតួលេខដែលបានព្យាករ។ យើងមិនធានា តួលេខដែលបានព្យាករ នឹងទទួលបានលទ្ធផលដូចការរំពឹងទុកឡើយ។ លោកអ្នកមិនគួរទុកចិត្តហួសហេតុទៅលើទិន្នន័យស្ថិតិ និងការព្យាករណ៍របស់តតិយជនដែលដកស្រង់នៅក្នុងឯកសារផ្តល់ព័ត៌មាននេះឡើយ។

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា

សេចក្តីថ្លែងការណ៍ពីអនាគត

ឯកសារផ្តល់ព័ត៌មាននេះរួមបញ្ចូលសេចក្តីថ្លែងការណ៍ពីអនាគតដែលរួមមានការថ្លែងការណ៍ទាំងអស់ ក្រៅពីប្រាក្យការណ៍ប្រវត្តិសាស្ត្រ ដែលរួមមានជាអាទិ៍ ហេតុការណ៍ដែលទាក់ទងនឹងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យុទ្ធសាស្ត្រអាជីវកម្ម គម្រោង និងគោលដៅរបស់ថ្នាក់គ្រប់គ្រងរបស់យើងសម្រាប់ប្រតិបត្តិការនាពេលអនាគត។ សេចក្តីថ្លែងការណ៍ទាំងនេះ អាចកំណត់បានដោយការប្រើប្រាស់ពាក្យដែលមានភាពលម្អៀងទៅកាន់ការព្យាករណ៍ ឬពាក្យដែលមានការព្យាករណ៍ទុកដូចជា "អាចនឹង" "នឹង" "អាច" "ជឿជាក់ថា" "រំពឹងថា" "ប្រមើលមើលថា" "មានបំណង" "ប៉ាន់ស្មាន" "គ្រោង" "ព្យាករថា" ឬ ការប្រើប្រាស់ពាក្យដែលស្រដៀងនេះ។ ការប្រើប្រាស់សេចក្តីថ្លែងការណ៍ពីអនាគតបែបនេះ រួមបញ្ចូលទាំងហានិភ័យដែលដឹងមុន ឬមិនដឹងមុន ភាពមិនប្រាកដប្រជា និងកត្តាសំខាន់ៗផ្សេងទៀត ដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់ក្រុមហ៊ុន ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផល ប្រតិបត្តិការ ឬ សមិទ្ធផលជាក់ស្តែងដែលអាចមានភាពខុសគ្នាខ្លាំងពីលទ្ធផលនាពេលអនាគត ប្រតិបត្តិការ ឬ សមិទ្ធផលដែលបង្ហាញ ឬយល់ នៅក្នុងសេចក្តីថ្លែងការណ៍នាពេលអនាគតនេះ។ ដូចនេះ យើងមិនអាចធានាថា សេចក្តីថ្លែងការណ៍ពីអនាគតក្នុងឯកសារផ្តល់ព័ត៌មាននេះ នឹងអាចកើតមានឡើងតាមការរំពឹងទុកនោះឡើយ។

សេចក្តីថ្លែងការណ៍ពីអនាគតនេះ ពឹងផ្អែកលើការសន្មតជាច្រើនដែលពាក់ព័ន្ធទៅនឹងយុទ្ធសាស្ត្រអាជីវកម្មនាពេលបច្ចុប្បន្ន និងអនាគតរបស់ក្រុមហ៊ុន និងបរិយាកាសដែលក្រុមហ៊ុនកំពុងដំណើរការ។ កត្តាផ្សេងៗទៀតដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផល ការប្រតិបត្តិ ឬសមិទ្ធផលជាក់ស្តែងរបស់ក្រុមហ៊ុនដែលធ្វើឱ្យមានការប្រែប្រួលខ្លាំង រួមមានជាអាទិ៍ អ្វីដែលបានលើកឡើងក្នុងផ្នែកទី ៣-កត្តាហានិភ័យ ផ្នែកទី ៥-ព័ត៌មានក្រុមហ៊ុន និងផ្នែកទី ៧.៥-កិច្ចពិភាក្សាថ្នាក់គ្រប់គ្រង និងការវិភាគលក្ខខណ្ឌហិរញ្ញវត្ថុ និងលទ្ធផលនៃប្រតិបត្តិការក្រុមហ៊ុន ។

សេចក្តីថ្លែងការណ៍ពីអនាគតនេះ ពឹងផ្អែកទៅលើព័ត៌មានដែលយើងមាននាកាលបរិច្ឆេទនៃឯកសារផ្តល់ព័ត៌មាននេះ។ លើកលែងស្របតាមការតម្រូវរបស់ច្បាប់ យើងសូមធ្វើការប្រកាសបដិសេធរាល់កាតព្វកិច្ច ឬការសន្យា ក្នុងការផ្សព្វផ្សាយជាសាធារណៈអំពីការធ្វើបច្ចុប្បន្នភាព ឬការកែប្រែនូវសេចក្តីថ្លែងការណ៍ពីអនាគត ដែលមានក្នុងឯកសារផ្តល់ព័ត៌មាននេះ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរការរំពឹងទុករបស់យើង ឬការផ្លាស់ប្តូរនូវរាល់ព្រឹត្តិការណ៍ លក្ខខណ្ឌ ឬ កាលៈទេសៈដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ពីអនាគតនេះ។

លោកអ្នកត្រូវបានសន្មតថាបានអាន និងយល់អំពីការពិពណ៌នានូវការសន្មត និងភាពមិនប្រាកដប្រជាដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ពីអនាគតនេះ។

គម្រោងពេលរំពឹងទុកនៃការចោះផ្សាយ

ព្រឹត្តិការណ៍នឹងកើតមាននៅកាលបរិច្ឆេទដែលរំពឹងទុកដូចខាងក្រោម៖

ព្រឹត្តិការណ៍	កាលបរិច្ឆេទ និងម៉ោងដែលគ្រោងទុក
កាលបរិច្ឆេទចាប់ផ្តើមទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម	ម៉ោង ៨:00 ព្រឹក ២៧ កក្កដា ២0២0
កាលបរិច្ឆេទឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្ម	ម៉ោង ៤:៣0 ល្ងាច ៤ សីហា ២0២0
កាលបរិច្ឆេទជូនដំណឹងដល់អ្នកធ្វើបរិវិសកម្មទទួលជោគជ័យ	៧ សីហា ២0២0
កាលបរិច្ឆេទបែងចែកមូលបត្រដល់អ្នកដាក់ពាក្យស្នើសុំដែលទទួលបានជោគជ័យ	៧ សីហា ២0២0
កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រ	១២ សីហា ២0២0

ចំណាំ៖

ម៉ោងធ្វើការគឺរៀងរាល់ម៉ោង ៨ ព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់ និងចាប់ពីម៉ោង ១ ថ្ងៃត្រង់ រហូតដល់ម៉ោង ៤:៣0 ល្ងាច ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកបុណ្យជាតិនៃព្រះរាជាណាចក្រកម្ពុជា។

គម្រោងពេលរំពឹងទុកខាងលើនេះ អាចមានការប្រែប្រួលក្នុងករណីចាំបាច់ ដើម្បីជួយសម្រួលដល់ការអនុវត្តនីតិវិធី។ ការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មបន្តបើករហូតដល់ថ្ងៃទី៤ ខែសីហា ឆ្នាំ២0២0 ម៉ោង ៤:៣0 ល្ងាច។

ប្រសិនបើកាលបរិច្ឆេទនៃការឈប់ទទួលពាក្យស្នើសុំត្រូវបានពន្យារ និងបានជូនដំណឹង នោះកាលបរិច្ឆេទសម្រាប់ធ្វើការបែងចែក និងកាលបរិច្ឆេទសម្រាប់ការចុះបញ្ជីនឹងត្រូវពន្យារតាមនោះដែរ។ ក្រុមហ៊ុនផេសថិក (ខេមបូឌា) ត្រូវជូនដំណឹងដល់សាធារណៈជនតាមរយៈការចុះផ្សាយក្នុងកាសែតព័ត៌មានជាភាសាខ្មែរ និងភាសាអង់គ្លេសដែលទទួលស្គាល់ដោយ គ.ម.ក។

មាតិកា

សេចក្តីជូនដំណឹងចំពោះវិនិយោគិន ii

សេចក្តីថ្លែងមិនទទួលខុសត្រូវ iii

ការចែកចាយ Iv

សេចក្តីថ្លែងសម្រាប់វិនិយោគិននៅក្រៅព្រះរាជាណាចក្រកម្ពុជា vi

ការបង្ហាញអំពីព័ត៌មាន vii

សេចក្តីថ្លែងការណ៍ពីអនាគត ix

គម្រោងពេលវេលាពីងទុកនៃការបោះផ្សាយ x

មាតិកា xi

និយមន័យនៃអក្សរកាត់ xx

សន្ទានុក្រមនៃពាក្យបច្ចេកទេស xxviii

១. សេចក្តីសង្ខេបឯកសារផ្តល់ពត៌មាន 1

១.១. ទិដ្ឋភាពទូទៅរបស់ក្រុមហ៊ុន 1

១.២. អត្ថប្រយោជន៍ប្រកួតប្រជែង ផែនការអនាគត និងយុទ្ធសាស្ត្រធុរកិច្ច 3

១.២.១. អត្ថប្រយោជន៍ប្រកួតប្រជែង 3

១.២.២. ផែនការអនាគត និងយុទ្ធសាស្ត្រធុរកិច្ច 3

១.៣. អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក 4

១.៣.១. ភាគហ៊ុនិក 4

១.៣.២. អភិបាល 4

១.៣.៣. បុគ្គលិកជាន់ខ្ពស់ 4

១.៤. ព័ត៌មានអំពីប្រវត្តិហិរញ្ញវត្ថុ 5

១.៤.១. របាយការណ៍ប្រាក់ចំណូលលម្អិត 5

១.៤.២. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ 6

១.៥. កត្តាចាំបាច់ពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រកម្មសិទ្ធជាសាធារណៈ 8

១.៦. ការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ 9

១.៧. កត្តាហានិភ័យនានា 10

១.៨. គោលនយោបាយភាគលាភ 11

២. ការពិពណ៌នាអំពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ 12

២.១. ព័ត៌មានទូទៅរបស់ក្រុមហ៊ុន 12

២.២.	ព័ត៌មានស្តីពីក្រុមហ៊ុនធានាទិញមូលបត្រ	12
	២.២.១. ព័ត៌មានទូទៅរបស់ក្រុមហ៊ុនធានាទិញមូលបត្រ	12
	២.២.២. លក្ខខណ្ឌនៃកិច្ចព្រមព្រៀងធានាទិញមូលបត្រ	13
	២.២.៣. ផលប្រយោជន៍របស់ក្រុមហ៊ុនធានាទិញមូលបត្រ	15
២.៣.	ភាគរយនៃផាប់ប្លិកហ្វ្លត (PUBLIC FLOATS) និងឡុកអាប់ (LOCK-UP)	16
២.៤.	ព័ត៌មានអំពីក្រុមហ៊ុនផ្តល់សេវាកម្មសវនកម្ម និងសវនករឯករាជ្យ	17
	២.៤.១. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម	17
	២.៤.២. សវនករឯករាជ្យ	18
២.៥.	ព័ត៌មានអំពីមេធាវី	18
២.៦.	ព័ត៌មានអំពីអ្នកស្រាវជ្រាវទីផ្សារឯករាជ្យ	19
២.៧.	ការចំណាយទាំងអស់ពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ	19
២.៨.	ការពិព័ណ៌នាអំពីមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់	21
	២.៨.១. ការពិពណ៌នាអំពីលក្ខខណ្ឌនានាអំពីមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់	21
	២.៨.២. ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិ	21
២.៩.	ការកំណត់ពីតម្លៃមូលបត្រកម្មសិទ្ធិដែលបោះផ្សាយលក់	22
	២.៩.១. ព័ត៌មានអំពីប្រវត្តិហិរញ្ញវត្ថុរបស់ក្រុមហ៊ុន	22
	២.៩.២. ទ្រព្យសកម្មសុទ្ធរួមរបស់ក្រុមហ៊ុន	22
	២.៩.៣. ប្រវត្តិប្រតិបត្តិរបស់ក្រុមហ៊ុន	23
	២.៩.៤. ការរំពឹងទុក និងផែនការអនាគតរបស់ក្រុមហ៊ុន	23
	២.៩.៥. ស្ថានភាពទីផ្សារបច្ចុប្បន្ន	23
២.១០.	ទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (NET ASSETS PER SHARE) ប្រាក់ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ (EARNINGS PER SHARE) អនុបាតភីអ៊ី (P/E RATIO OR PRICE EARNINGS MULTIPLE PER SHARE) និងទិន្នផលភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (YIELD PER SHARE)	24
	២.១០.១. ទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ	25
	២.១០.២. ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ	26
	២.១០.៣. អនុបាតភីអ៊ី (P/E RATIO OR PRICE EARNINGS MULTIPLE PER SHARE) .	26
	២.១០.៤. ទិន្នផលភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ	26
២.១១.	ផែនការបែងចែកមូលបត្រកម្មសិទ្ធិ	27
២.១២.	ការប្រើសាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រសាធារណៈ	28

២.១៣.	គម្រោងវិនិយោគ	30
៣.	កត្តាហានិភ័យ	31
៣.១.	ហានិភ័យលើអត្រាការប្រាក់	32
	៣.១.១. ចលនាឡើងចុះនៃអត្រាការប្រាក់	32
៣.២.	ហានិភ័យលើអត្រាប្តូរប្រាក់	33
	៣.២.១. ចលនាឡើងចុះនៃអត្រាប្តូរប្រាក់	33
៣.៣.	ហានិភ័យលើឧស្សាហកម្ម ហានិភ័យទាក់ទងនឹងការប្រែប្រួលបរិបទជាតិ និងអន្តរជាតិ និងការកែប្រែប្រួលនៃច្បាប់ និងបទប្បញ្ញត្តិនានា	34
	៣.៣.១. ការពឹងផ្អែកលើតម្រូវការអគ្គិសនី	34
	៣.៣.២. ការប្រែប្រួលលក្ខខណ្ឌ នយោបាយ សង្គមកិច្ច និងបទប្បញ្ញត្តិក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសដ៏ទៃទៀតដែលក្រុមហ៊ុនអាចមានប្រតិបត្តិការ	35
៣.៤.	ហានិភ័យប្រតិបត្តិការ	37
	៣.៤.១. ហានិភ័យដែលកើតមានប្រចាំថ្ងៃ និងការធានារ៉ាប់រង	37
	៣.៤.២. លទ្ធផលផ្អែកតាមគម្រោង	38
	៣.៤.៣. ហានិភ័យនៃគម្រោង	39
	៣.៤.៤. ការពឹងផ្អែកលើ និងអលទ្ធភាពក្នុងការរក្សាទុក អភិបាលប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់	41
	៣.៤.៥. ការពឹងផ្អែកទៅលើតតិយជនក្នុងការផ្តល់សម្ភារៈ បង្គុំ និងផ្នែកផ្សេងៗក្នុងគម្រោងរបស់ក្រុមហ៊ុន	41
	៣.៤.៦ ហានិភ័យនៃការប្រើប្រាស់បច្ចេកទេសរបស់តតិយជន	42
	៣.៤.៧. ការពឹងផ្អែកលើអតិថិជនសំខាន់ៗ	43
	៣.៤.៨. ការពឹងផ្អែកលើអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការយល់ព្រម ពាក់ព័ន្ធនានាចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសកម្ពុជា	45
៣.៥.	ហានិភ័យមិនមែនប្រតិបត្តិការ	46
	៣.៥.១. កម្មសិទ្ធិ និងការគ្រប់គ្រងដោយម្ចាស់ភាគហ៊ុនដែលមានសិទ្ធិគ្រប់គ្រង	46
៣.៦.	ហានិភ័យហិរញ្ញវត្ថុ រួមបញ្ចូលទាំងហានិភ័យសន្ទនីយភាព និងហានិភ័យឥណទាន	46
	៣.៦.១. ហានិភ័យសន្ទនីយភាព	46
	៣.៦.២. ហានិភ័យឥណទាន	48
	៣.៦.៣. តម្រូវការដើមទុននាពេលអនាគតដែលទាមទារការធ្វើហិរញ្ញប្បទានបន្ថែម	49
៣.៧	ហានិភ័យលើបណ្តឹង និងការទទួលខុសត្រូវ	50
	៣.៧.១. ហានិភ័យលើបណ្តឹង	50

	៣.៧.២. វិវាទពន្ធដារ	51
៣.៨	ហានិភ័យពាក់ព័ន្ធនឹងការវិនិយោគលើមូលបត្រ	52
	៣.៨.១. សកម្មភាពជួញដូរដែលមានកម្រិតក្នុងផ្សារមូលបត្រកម្ពុជា	52
	៣.៨.២. កង្វះខាតទីផ្សារដែលមានស្រាប់សម្រាប់ភាគហ៊ុនរបស់ក្រុមហ៊ុន	53
	៣.៨.៣. បរាជ័យ ឬការពន្យាពេលនៃការចុះបញ្ជីលក់មូលបត្រ	54
៣.៩	ហានិភ័យដទៃទៀត	54
	៣.៩.១. ការផ្តល់ព័ត៌មានទាក់ទងនឹងសេចក្តីថ្លែងការណ៍ពីអនាគត	54
៤.	**ព័ត៌មានរបស់ក្រុមហ៊ុន**	**56**
៤.១.	ការពិពណ៌នាអំពីធុរកិច្ច	56
	៤.១.១. សាវតារបស់ក្រុមហ៊ុន	56
	៤.១.២. ការរៀបចំផ្ទៃក្នុងឡើងវិញ	58
	៤.១.៣. ប្រវត្តិរបស់ក្រុមហ៊ុន	59
	៤.១.៤. រចនាសម្ព័ន្ធក្រុមហ៊ុន	62
	៤.១.៥. អភិបាលកិច្ចសាជីវកម្ម	63
	ក. ក្រុមប្រឹក្សាភិបាលនិង គណៈកម្មាធិការ	63
	ខ. ការតែងតាំង និង/ឬការដកហូតអភិបាល និងតំណែងចំនេរ	63
	គ. កាលបរិច្ឆេទក្លាយជាអភិបាល និងកាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្នគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	63
	ឃ. តួនាទីរបស់ក្រុមប្រឹក្សាភិបាល	64
	ង. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល	65
	៤.១.៦. ផលិតផល និងសេវាកម្មចម្បង	68
	៤.១.៧. ឃុទ្ធសាស្ត្រធុរកិច្ចរួមទាំងស្ថានភាពប្រកួតប្រជែងទីផ្សារ និងផែនការនាពេលអនាគត	77
	៤.១.៨. បរិមាណលក់ផលិតផល ឬសេវាកម្មដែលមានចំនួនច្រើនជាង ១០% នៃចំណូលសរុបរបស់ក្រុមហ៊ុន	87
	៤.១.៩. ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនពាក់ព័ន្ធ ឬក្រុមហ៊ុនហួលឌីង និងផ្នែកសំខាន់ៗនៃធុរកិច្ចរបស់ក្រុមហ៊ុនទាំងនោះ	88
	៤.១.១០. វិធីសាស្ត្រទីផ្សារ និងការចែកចាយ	89
	៤.១.១១. វត្ថុធាតុដើម និងធនធានដាក់បញ្ចូលផ្សេងទៀត	90
	៤.១.១២. លក្ខខណ្ឌតម្រូវសម្រាប់ថាមពល ឧស្ម័ន និងទឹក ឬឧបករណ៍ប្រើប្រាស់ផ្សេងៗទៀត	91
	៤.១.១៣. អតិថិជនដែលទិញផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុនចាប់ពី ១០% ឡើងទៅ	92

	៤.១.១៤. អ្នកផ្គត់ផ្គង់ដែលផ្គត់ផ្គង់លើការទិញលក់របស់ក្រុមហ៊ុន ១០% ឬច្រើនជាងនេះ	92
	៤.១.១៥. ប្រកាសនីយបត្រតក្កកម្ម ម៉ាក ពាណិជ្ជនាម អាជ្ញាបណ្ណ និង/ឬកិច្ចព្រមព្រៀងផ្សេងទៀតលើសិទ្ធិកម្មសិទ្ធិបញ្ញា	93
	៤.១.១៦. ចំនួននិយោជិតពេញម៉ោង និងនិយោជិតសរុប	93
	៤.១.១៧. សក្តានុពលនៃសមត្ថភាពផលិត ឬសេវាកម្ម	93
	៤.១.១៨. ប្រតិបត្តិការជាមួយក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនដែលពាក់ព័ន្ធ	94
៤.២.	ផែនការប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ	96
	៤.២.១. របាយការណ៍ព្យាករណ៍ប្រាក់ចំណេញ	96
	៤.២.២. ការព្យាករណ៍ការផ្លាស់ប្តូរចំនួននិយោជិត	96
	៤.២.៣. ប្រភពដើមទុនខាងក្នុង និងខាងក្រៅ	96
	៤.២.៤. ការចំណាយដើមទុនចម្បង និងប្រភពហិរញ្ញវត្ថុដែលរំពឹងទុកសម្រាប់ការចំណាយនោះ	97
	៤.២.៥. ការផ្លាស់ប្តូរចម្បងលើប្រាក់ចំណូល តម្លៃនៃការលក់ ការចំណាយប្រតិបត្តិការផ្សេងទៀត និងប្រាក់ចំណេញសុទ្ធ	97
	៤.២.៦. ទិដ្ឋភាពតាមរដូវកាលនៃអាជីវកម្មរបស់ក្រុមហ៊ុន	97
	៤.២.៧. និន្នាការ ព្រឹត្តិការណ៍ ឬភាពមិនច្បាស់លាស់ណាមួយដែលបានដឹង	97
	៤.២.៨. ការផ្លាស់ប្តូរទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនដែលប្រើប្រាស់សម្រាប់សងបំណុល	98
	៤.២.៩. កម្ចីចម្បងៗ (Material Loan) រវាងក្រុមហ៊ុនហូលឌីង និងក្រុមហ៊ុនបុត្រសម្ព័ន្ធ	98
	៤.១.១០. បំណុលជាយថាហេតុ និងបំណុលកិច្ចសន្យានាពេលអនាគត	98
	៤.១.១១. អាករលើតម្លៃបន្ថែម ពន្ធលើប្រាក់ចំណេញ កាតព្វកិច្ចពន្ធគយ ឬបំណុលពន្ធដែលមិនបានទូទាត់ផ្សេងៗទៀត រួមទាំងបំណុលជាយថាហេតុណាមួយ	98
	៤.១.១២. ភតិសន្យាប្រតិបត្តិការ និងភតិសន្យាហិរញ្ញវត្ថុ	99
	៤.១.១៣. បទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងបុគ្គលិក រួមទាំងផលប្រយោជន៍ចូលនិវត្តន៍ដែលមិនពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធរបស់ក្រុមហ៊ុន	99
៤.៣.	ព័ត៌មានទាក់ទងនឹងទ្រព្យសកម្មរបស់ក្រុមហ៊ុន	99
	៤.៣.១. អចលនទ្រព្យ រោងចក្រនិងបរិក្ខា ទ្រព្យសម្បត្តិជីវសាស្ត្រ និងសិទ្ធិនៃកម្មសិទ្ធិបញ្ញា	99
	៤.៣.២. ការវាយតម្លៃលើទ្រព្យ និងការវាយតម្លៃឡើងវិញ (រាប់បញ្ចូលទាំងវិធីសាស្ត្រវាយតម្លៃ កាលបរិច្ឆេទនៃការវាយតម្លៃ ឈ្មោះអ្នកវាយតម្លៃឯករាជ្យ)	101
៥.	**ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន**	102
៥.១.	អភិបាល និងបុគ្គលិកជាន់ខ្ពស់	102

	៥.១.១. ជីវប្រវត្តិសង្ខេបដោយមានបញ្ជាក់អត្តសញ្ញាណ និងគុណវុឌ្ឍិរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់	102
	៥.១.២. បទពិសោធន៍ការងាររបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងរយៈពេលប្រាំ (៥) ឆ្នាំចុងក្រោយ	107
	៥.១.៣. កាលបរិច្ឆេទនៃការតែងតាំង និងកាលបរិច្ឆេទបញ្ចប់អាណត្តិ	115
	៥.១.៤. ប្រសិនបើអភិបាលណាម្នាក់ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិករ ក្រុមហ៊ុន ឬសហគ្រាសផ្សេងទៀត សូមបញ្ជាក់ឈ្មោះក្រុមហ៊ុន	115
	៥.១.៥. ទំនាក់ទំនងសាច់ញាតិ ក្នុងចំណោមអភិបាល ភាគហ៊ុនិក និងបុគ្គលិកជាន់ខ្ពស់ (ប្រសិនបើមាន) និងបញ្ជាក់ពីស្ថានភាពនៃទំនាក់ទំនង	119
	៥.១.៦. ការប្រកាសក្សัយធនរបស់អភិបាល ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនអប្បបរិមា ៥% នៃភាគហ៊ុនដែលបានបង់គ្រប់រួចរាល់	120
៥.២.	ការជាប់ពាក់ព័ន្ធរបស់អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ក្នុងដំណើរការផ្លូវច្បាប់ ក្នុងរយៈពេលប្រាំ (៥) ឆ្នាំចុងក្រោយ	120
៥.៣.	លាភការ ឬប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់	120
	៥.៣.១. ឈ្មោះ និងមុខតំណែងរបស់បុគ្គលិកទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតប្រាំ (៥) រូប ព្រមទាំងលាភការសរុប	120
	៥.៣.២. លាភការសរុបដែលបង់ឱ្យអភិបាលមិនប្រតិបត្តិ	121
	៥.៣.៣. លាភការសរុបដែលត្រូវបង់ឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់	121
	៥.៣.៤. លាភការសរុបដែលបានស្នើដើម្បីបង់ឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់សម្រាប់រយៈពេលមួយ (១) ឆ្នាំសារពើពន្ធខាងមុខ	121
	៥.៣.៥. កំណើនគួរឱ្យកត់សម្គាល់លើលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់អំឡុងពេលបច្ចុប្បន្ន និងឆ្នាំសារពើពន្ធខាងមុខ	122
៥.៤.	សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត	122
	៥.៤.១. សិទ្ធិទិញដែលបានផ្តល់ឱ្យទៅអភិបាល	122
	៥.៤.២. សិទ្ធិទិញដែលបានផ្តល់ឱ្យទៅបុគ្គលិកជាន់ខ្ពស់	122
	៥.៤.៣. សិទ្ធិទិញដែលបានផ្តល់ឱ្យទៅនិយោជិត	122
៥.៥	ការកាន់កាប់ភាគហ៊ុន	123
	៥.៥.១. អត្តសញ្ញាណភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិអប្បបរិមា ៥%	123
	៥.៥.២. អត្តសញ្ញាណអភិបាលដែលកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន	124

	៥.៥.៣. អត្តសញ្ញាណនិយោជិតទាំងប្រាំ (៥) ដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់ជាងគេ ដែលកាន់កាប់មូលបត្រកម្មសិទ្ធិក្នុងក្រុមហ៊ុន	125
៦.	**ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ**	126
៦.១.	ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ	126
៦.២.	ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ	126
៦.៣.	ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនអប្បបរិមា ៥% នៃភាគហ៊ុនដែលនៅសល់របស់ក្រុមហ៊ុនក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ	126
៦.៤.	ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនអប្បបរិមា ៥% នៃភាគហ៊ុនក្រុមហ៊ុនដែលកំពុងធ្វើចរាចរក្នុងទីផ្សារក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ	127
៦.៥.	ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុន ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហ្វូលឌីង ដែលទំនាក់ទំនងរវាងបុគ្គលទាំងនោះ កើតមានក្នុងពេលប្រតិបត្តិការ ឬការរៀបចំចាត់ចែងណាមួយដែលធ្វើឡើងដោយក្រុមហ៊ុនក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ	127
៦.៦.	ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលធ្លាប់ជាអភិបាល ឬបុគ្គលដែលជាប់ពាក់ព័ន្ធនឹងបុគ្គលដែលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុន ដែលទំនាក់ទំនងរវាងបុគ្គលទាំងនោះកើតមានក្នុងពេលប្រតិបត្តិការ ឬការរៀបចំចាត់ចែងណាមួយដែលធ្វើឡើងដោយក្រុមហ៊ុនក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ ...	129
៦.៧.	ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខដំណែងក្នុងសហគមន៍ ឬអង្គការមិនមែនស្វែងរកប្រាក់ចំណេញ ឬក្រុមហ៊ុនណាមួយផ្សេងក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ	129
៦.៨.	ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈសម្រាប់សេវាដែលខ្លួនបានផ្តល់តាមរយៈសហគ្រាសណាមួយដល់ក្រុមហ៊ុន ក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ	129
៧.	**ព័ត៌មានហិរញ្ញវត្ថុ**	130
៧.១.	អត្រាប្តូរប្រាក់	130
៧.២.	ព័ត៌មានស្តីពីប្រវត្តិហិរញ្ញវត្ថុ	131
	៧.២.១. របាយការណ៍ចំណេញ ឬខាត	131
	៧.២.២. របាយការណ៍ស្ថានហិរញ្ញវត្ថុ	132
៧.៣.	មូលធននីយកម្ម និងបំណុល	133
៧.៤.	កិច្ចពិភាក្សាថ្នាក់គ្រប់គ្រង និងការវិភាគលក្ខខណ្ឌហិរញ្ញវត្ថុ និងសមិទ្ធផលប្រតិបត្តិការក្រុមហ៊ុន ...	134
	៧.៤.១. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ	134
	៧.៤.២. ការពិនិត្យលើលទ្ធផលប្រតិបត្តិការ	134

៧.៤.៣.	កត្តាសំខាន់ដែលប៉ះពាល់លើប្រាក់ចំណេញ	143
៧.៥.	សន្ទនីយភាព និងប្រភពទុន	148
៧.៥.១.	ទុនបង្វិល	148
៧.៥.២.	ចលនាសាច់ប្រាក់	149
៧.៥.៣.	កម្ចី	150
៧.៥.៤.	ការល្មើសនឹងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការចាត់ចែងឥណទានកម្ចីធនាគារ	151
៧.៥.៥.	ប្រភេទឧបករណ៍ហិរញ្ញវត្ថុដែលបានប្រើប្រាស់	151
៧.៥.៦.	គោលនយោបាយ និងគោលបំណងក្នុងការគ្រប់គ្រងសាច់ប្រាក់	152
៧.៥.៧.	កតព្វកិច្ចសំខាន់ៗ	153
៧.៥.៨.	វិវាទ និងបំណុលជាយថាហេតុសំខាន់ៗ	153
៧.៥.៩.	អនុបាតហិរញ្ញវត្ថុសំខាន់ៗ	155
៧.៥.១០.	បំណុលអតិថិជន និងគណនីផ្សេងទៀត	157
៧.៥.១១.	សន្និធិ	157
៧.៥.១២.	ទ្រព្យសកម្មរយៈពេលវែង	157
៧.៥.១៣.	គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម	158
៧.៥.១៤.	ទឹកប្រាក់ជំពាក់ក្រុមហ៊ុនមេ និងភាគីពាក់ព័ន្ធ	159
៧.៥.១៥.	កិច្ចសន្យាសំខាន់ៗ	159
៧.៦.	ព័ត៌មាននិន្នាការ	161
៧.៧.	គោលនយោបាយភាគលាភ	162
៧.៨.	ការព្យាករណ៍ប្រាក់ចំណេញ	162
៧.៩.	ព័ត៌មានហិរញ្ញវត្ថុរួម	163
៧.១០.	ខ្នង់ក្រៅតារាងតុល្យការ	163
៨.	**របាយការណ៍របស់អភិបាល**	**164**
៩.	**របាយការណ៍គណនេយ្យ**	**166**
១០.	**ព័ត៌មានផ្សេងៗ**	**223**
១០.១.	សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងរយៈពេលពីរ(២)ឆ្នាំចុងក្រោយមុនពេលដាក់ពាក្យស្នើសុំ	223
១០.២.	របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករផ្ទៃក្នុងសម្រាប់រយៈពេលពីរ(២)ឆ្នាំចុងក្រោយ	224
១០.៣.	សេចក្តីសម្រេចរបស់ភាគហ៊ុនិកពីរ (២) ឆ្នាំចុងក្រោយមុនពេលដាក់ពាក្យស្នើសុំ	225
១០.៤.	របាយការណ៍ភាគលាភពីរ (២) ឆ្នាំចុងក្រោយ មុនពេលដាក់ពាក្យស្នើសុំ	225

១០.៥. របាយការណ៍ពាក់ព័ន្ធដំណើរការផ្លូវច្បាប់ពីរ (២) ឆ្នាំចុងក្រោយមុនពេលដាក់ពាក្យស្នើសុំ 225

១០.៦. តម្រូវការសម្រាប់ការអនុម័ត 226

១១. ការព្រមព្រៀងរបស់អ្នកជំនាញ 227

១២. ហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល នាយកប្រតិបត្តិ និងនាយកផ្នែកហិរញ្ញវត្ថុ 228

ឧបសម្ព័ន្ធ

១. ក្រមសីលធម៌វិជ្ជាជីវៈ

២. សេចក្តីសង្ខេបប្រតិបត្តិនៃរបាយការណ៍ស្រាវជ្រាវទីផ្សារឯករាជ្យ

៣. របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩

៤. របាយការណ៍ហិរញ្ញវត្ថុត្រួតពិនិត្យក្នុងគ្រាសម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

៥. លិខិតបញ្ជាក់ពីភាពត្រឹមត្រូវនៃព័ត៌មាន

និយមន័យនៃអក្សរកាត់

លុះត្រាតែបានកំណត់ផ្សេងពីនេះ និយមន័យខាងក្រោម ត្រូវបានប្រើប្រាស់ក្នុងឯកសារផ្តល់ព័ត៌មានដូចតទៅ៖

ការចុះបញ្ជីមូលបត្រកម្មសិទ្ធិ	:	សំដៅដល់ការចុះបញ្ជីផ្លូវការនៃមូលបត្រកម្មសិទ្ធិទាំងអស់របស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ចំនួន៧៤.៩៤៥.000 ភាគហ៊ុនលើទីផ្សារគោលនៃ ផ.ម.ក
ការបោះផ្សាយជាសាធារណៈ	:	សំដៅដល់ការបោះផ្សាយជាសាធារណៈនៃភាគហ៊ុនថ្មីចំនួនរហូតដល់ ៣.៩៤៥.000 ភាគហ៊ុន របស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ដែលតំណាងឱ្យ ៥.២៦% នៃដើមទុនទាំងអស់ដែលបានបោះ និងបង់រួចរាល់ទាំងស្រុងរបស់ក្រុមហ៊ុន តាមតម្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ស្របទៅតាមខ និងលក្ខខណ្ឌនៃឯកសារផ្តល់ព័ត៌មាននេះ
ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO)	:	សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង របស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា)
ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យ	:	ជាដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និង ថ្ងៃទី៣០ មិថុនា ឆ្នាំ២០១៩
ការរៀបចំផ្ទៃក្នុងឡើងវិញ	:	ជារួម ការរៀបចំផ្ទៃក្នុងឡើងវិញរបស់ក្រុមហ៊ុន ដែលពាក់ព័ន្ធនឹងការផ្ទេរភាគហ៊ុនរបស់យើងពី ក្រុមហ៊ុន PSB ទៅ ក្រុមហ៊ុន PIB ការបង្កើនដើមទុនដែលបានចុះបញ្ជីពី ៤ លានរៀល (ស្មើនឹង ១.000 ដុល្លារអាមេរិក) ទៅ ២៨,៤ ប៊ីលានរៀល (ស្មើ ៧,១ លានដុល្លារអាមេរិក) និងការផ្លាស់ប្តូរទម្រង់ក្រុមហ៊ុនពីសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលព័ត៌មានជាក់លាក់មានរៀបរាប់នៅក្នុងផ្នែក ៤.១.២ នៃឯកសារផ្តល់ព័ត៌មាននេះ។
កាលបរិច្ឆេទអនុវត្តចុងក្រោយ (LPD)	:	សំដៅដល់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ ជាកាលបរិច្ឆេទអនុវត្តចុងក្រោយបំផុតមុនពេលបោះពុម្ពឯកសារផ្តល់ព័ត៌មាន
កិច្ចព្រមព្រៀងធានាទិញមូលបត្រកម្មសិទ្ធិ	:	សំដៅដល់ កិច្ចព្រមព្រៀងធានាទិញមូលបត្រកម្មសិទ្ធិរវាង ក្រុមហ៊ុន ផេសថិក (ខេមបូឌា) និងក្រុមហ៊ុនធានាទិញមូលបត្រកម្មសិទ្ធិ ដើម្បីធានាទិញភាគហ៊ុនចំនួនរហូតដល់២.៦៣១.៥៧៩ ភាគហ៊ុន តាមរយៈការបោះផ្សាយលក់ជាសាធារណៈ
ក្រុមប្រឹក្សាភិបាល	:	ជាក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនផេសថិក (ខេមបូឌា)

និយមន័យនៃអក្សរកាត់ (ត)

ក្រុមហ៊ុន ដាយអ៊ីមុន ផៅវ៉ែរ	:	ក្រុមហ៊ុនដាយអ៊ីមុន ផៅវ៉ែរ លីមីធីត ជាក្រុមហ៊ុនដែលបង្កើតនិង មានទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលភាគហ៊ុនចំនួន ៦០% ត្រូវបានកាន់កាប់ដោយ ក្រុមហ៊ុន PESTECH Power Sdn Bhd ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងស្រុងរបស់ក្រុមហ៊ុន PIB។
ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ឬក្រុមហ៊ុន ឬក្រុមហ៊ុនបោះផ្សាយ	:	សំដៅដល់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក
ក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យួរីធី (ខេមបូឌា) ឬ ក្រុមហ៊ុនទីប្រឹក្សា និងធានាទិញមូលបត្រ	:	សំដៅដល់ក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យួរីធី (ខេមបូឌា) ម.ក
ក្រុមហ៊ុន អាឡិច ខបអ៊ីរេសិន	:	ក្រុមហ៊ុន អាឡិច ខបអ៊ីរេសិន ម.ក ពីមុនត្រូវបានស្គាល់ជា ក្រុមហ៊ុន អាឡិច ខបអ៊ីរេសិន ខូអិលធីឌី ជាក្រុមហ៊ុនបង្កើត និងមានទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន PIB	:	ក្រុមហ៊ុន PESTECH International Berhad ជាក្រុមហ៊ុនដែលបង្កើតឡើង និងមានទីស្នាក់ការនៅប្រទេសម៉ាឡេស៊ី និងជាក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្នុងបញ្ជីផ្លូវការរបស់ Bursa Malaysia Securities Berhad ជាផ្សារហ៊ុននៃប្រទេសម៉ាឡេស៊ី។ ក្រុមហ៊ុន PIB ក៏ជាក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនយើងដែរបន្ទាប់ពីបញ្ចប់ការរៀបចំផ្ទៃក្នុងឡើងវិញ
ក្រុមហ៊ុន PSB	:	សំដៅដល់ក្រុមហ៊ុន PESTECH Sdn Bhd ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងស្រុងរបស់ក្រុមហ៊ុន PIB និងជាក្រុមហ៊ុនដែលបានបង្កើត និងមានទីស្នាក់ការនៅក្នុងប្រទេសម៉ាឡេស៊ី
ក្រុមហ៊ុន Maschinenfabrik Reinhausen		ក្រុមហ៊ុន Maschinenfabrik Reinhausen GmbH ក្រុមហ៊ុនបង្កើត និងមានទីស្នាក់ការនៅក្នុងប្រទេសអាល្លឺម៉ង់
ក្រុមហ៊ុន Smith Zander	:	សំដៅដល់ក្រុមហ៊ុន Smith Zander International Sdn Bhd ជាក្រុមហ៊ុនស្រាវជ្រាវទីផ្សារឯករាជ្យ
ក្រុមហ៊ុន Schneitec		ក្រុមហ៊ុន Schneitec ឯ.ក ក្រុមហ៊ុនបង្កើត និងមានទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា

និយមន័យនៃអក្សរកាត់ (ត)

គណៈកម្មាធិការសវនកម្ម	:	ជាគណៈកម្មាធិការក្រុមប្រឹក្សា ដែលទទួលខុសត្រូវក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញរាល់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងត្រួតពិនិត្យផ្នែកខាងក្នុង និងខាងក្រៅ ព្រមទាំងធ្វើសវនកម្ម។
គ.ម.ក	:	សំដៅដល់គណៈកម្មការមូលបត្រកម្ពុជា
គម្រោង	:	ជារួមសំដៅដល់ គម្រោងភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ គម្រោងខេត្តកំពង់ចាម - ខេត្តក្រចេះ គម្រោងរោងចក្រអគ្គិសនីស្ទឹងតាតៃ - ប្រព័ន្ធបណ្តាញបញ្ជូនភ្នំពេញ គម្រោងខេត្តសៀមរាប - ខេត្តឧត្តរមានជ័យ និងគម្រោងអ្នខ្វារឬទៅតាមករណីនីមួយៗ
គម្រោងខេត្តកំពង់ចាម - ខេត្តក្រចេះ	:	គូសបន្លង់ វិស្វកម្ម ការធ្វើតេស្តសាកល្បង តម្លើង និង ដាក់ឱ្យប្រើប្រាស់ទីធ្លាភ្ជាប់ផ្តាច់ចរន្ត ទំហំ ២៣០គីឡូវ៉ុល ក្នុងអនុស្ថានីយ៍ដែលមានស្រាប់នៅខេត្តកំពង់ចាម អនុស្ថានីយ៍ថ្មីដែលមានចាមពល ២៣០/២២គីឡូវ៉ុល នៅខេត្តក្រចេះ និងភ្ជាប់បណ្តាញបញ្ជូនប្រវែង ១២៥ គីឡូម៉ែត ពីអនុស្ថានីយ៍ខេត្តកំពង់ចាម ដល់អនុស្ថានីយ៍ខេត្តក្រចេះ។
គម្រោងខេត្តសៀមរាប - ខេត្តឧត្តរមានជ័យ	:	គម្រោងនេះទាក់ទងនឹង៖ • ការសាងសង់ជាកញ្ចប់ (turnkey) នៃខ្សែបណ្តាញបញ្ជូនទ្វេប្រវែងប្រមាណ ៧៥ គីឡូម៉ែត្រ ± ៣ គីឡូម៉ែត្រ ពីខេត្តឧត្តរមានជ័យ ទៅខេត្តសៀមរាប • ការសាងសង់ជាកញ្ចប់ នៃអនុស្ថានីយ៍ខេត្តឧត្តរមានជ័យទំហំ ១១៥/២២ គីឡូវ៉ុល និង • ការសាងសង់ជាកញ្ចប់ នៃអនុស្ថានីយ៍បែកចានទំហំ ២៣០/២២គីឡូវ៉ុល គម្រោងបានបញ្ចប់នៅក្នុងខែធ្នូ ឆ្នាំ ២០១៩។

គម្រោង ភ្នំពេញខាងលិច - ខេត្តព្រះសីហនុ	:	គម្រោងរួមបញ្ចូល ការគូសបន្ទង់ វិស្វកម្ម ផ្គត់ផ្គង់ តម្លើង ធ្វើពិសោធ និងដាក់ឱ្យប្រើប្រាស់បណ្តាញបញ្ជូនថាមពលទំហំ ២៣០គីឡូវ៉ុល ពីភាគខាងលិចរាជធានីភ្នំពេញ - ខេត្តព្រះសីហនុ និងគម្រោងពង្រីកអនុស្ថានីយ៍ទំហំ ២៣០/១១៥/២២ គីឡូវ៉ុល ក្រោមកិច្ចសន្យាដើមរវាងក្រុមហ៊ុន ផេសថិក (ខេមបូឌា) និង ក្រុមហ៊ុន អាឡិច ខបភើរេសិន ដែលចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១៤។ តម្លៃកិច្ចសន្យានៃគម្រោងនេះត្រូវបានកែប្រែទៅចំនួន ១៤៧,៨ លានដុល្លារអាមេរិក។ ការងារបន្ថែមរួមមាន៖ • ការតម្លើងថាមពលបណ្តាញបញ្ជូនសៀគ្វីទ្វេរចរន្ត ២៣០ គីឡូវ៉ុល ពីស្ទឹងហាវ ទៅចំការលួង និង • ការតម្លើងថាមពលបណ្តាញបញ្ជូនសៀគ្វីទ្វេរចរន្ត ៥០០ គីឡូវ៉ុល ពីចំការលួង ទៅបែកចាន។ គម្រោងបានបញ្ចប់នៅក្នុងខែមករា ឆ្នាំ ២០២០។
គម្រោង អោងចក្រថាមពល អគ្គិសនីស្ទឹងតាតៃ - ប្រព័ន្ធ បណ្តាញបញ្ជូនភ្នំពេញ	:	គម្រោងនេះរួមបញ្ចូល៖ • គំនូសបន្ទង់ វិស្វកម្ម ផលិត តម្លើង សាកល្បង និងដាក់ឱ្យប្រើប្រាស់ បណ្តាញបញ្ជូនថាមពល ២៣០ គីឡូវ៉ុល ប្រម៉ាណ ២២០ គីឡូម៉ែត ពីអោងចក្រថាមពលអគ្គិសនីស្ទឹងតាតៃទៅរាជធានីភ្នំពេញ និង • ផ្គត់ផ្គង់ តម្លើង និងភ្ជាប់ខ្សែ (line bay) ទំហំ ២៣០ គីឡូវ៉ុលពីរខ្សែនៅទីធ្លាភ្ជាប់ផ្តាច់ចរន្ត នៃអោងចក្រថាមពលអគ្គិសនីស្ទឹងតាតៃ។ កិច្ចព្រមព្រៀងនេះត្រូវបានបង្កើតឡើងរវាង ក្រុមហ៊ុន ផេសថិក (ខេមបូឌា) និង ក្រុមហ៊ុន អាឡិច ខបភើរេសិន នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៧។ គម្រោងនេះគ្រោងបញ្ចប់ត្រឹមខែមេសា ឆ្នាំ២០២១។
គម្រោង Sarawak	:	សេវាកម្មគ្រប់គ្រងគម្រោងនិងសំណង់ស៊ីវិលសម្រាប់សាងសង់អនុស្ថានីយ៍ ២៧៥kV/៣២kV និង ១៣២kV/១១kV នៅក្នុងខេត្ត Sarawak នៃប្រទេសម៉ាឡេស៊ី
គម្រោងអូខ្វាវ	:	គម្រោងរួមបញ្ចូល ការគូសបន្ទង់ វិស្វកម្ម សាកល្បង តម្លើង និង ដាក់ឱ្យប្រើប្រាស់ទីធ្លាភ្ជាប់ផ្តាច់ចរន្ត នឹងការប្រគល់អនុស្ថានីយ៍អូខ្វាវ ទំហំ ២៣០/១១គីឡូវ៉ុល នៅខេត្តមណ្ឌលគីរី។ គម្រោងនេះគ្រោងបញ្ចប់រយៈពេល១២ខែ គិតចាប់ពីថ្ងៃ០១ ខែមិនា ឆ្នាំ២០២០។

និយមន័យនៃអក្សរកាត់ (ត)

ចំណូលក្នុងមួយឯកតាភាគហ៊ុន (EPS)	:	ជាចំណូលក្នុងមួយឯកតាភាគហ៊ុន
ចំណេញ (EBITDA)	:	ជាចំណូលមុនការប្រាក់ ពន្ធ និងរំលស់
ដំណាច់ការិយបរិច្ឆេទ (FYE)	:	ឆ្នាំហិរញ្ញវត្ថុត្រូវបានបញ្ចប់ ទៅតាមករណីនីមួយៗ
ដំណាច់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យ	:	ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ដល់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩
ដនស	:	សំដៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ដុល្លារអាមេរិក	:	សំដៅដល់រូបិយវត្ថុផ្លូវការរបស់សហរដ្ឋអាមេរិក
តម្លៃបោះផ្សាយលក់	:	ជាតម្លៃ ៣.១២០ រៀល (០,៧៦ ដុល្លារអាមេរិក) ក្នុងមួយឯកតាភាគហ៊ុនបោះផ្សាយលក់
ថ្ងៃបើកទីផ្សារ	:	សំដៅពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ដែលមិនមែនជាថ្ងៃឈប់សម្រាកបុណ្យជាតិ និងនៅពេលដែល ផ.ម.ក បើកដើម្បីចរាចរមូលបត្រកម្មសិទ្ធិ
ទម្រង់ពាក្យស្នើសុំ	:	ទម្រង់ពាក្យស្នើសុំបោះពុម្ពលើក្រដាសសម្រាប់ដាក់ពាក្យស្នើសុំទិញមូលបត្រកម្មសិទ្ធិ IPO
ធនាគារ អ អេច ប៊ី (ខេមបូឌា)	:	ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក
ប្រទេសកម្ពុជា	:	ព្រះរាជាណាចក្រកម្ពុជា
ប្រទេសឡាវ	:	សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
ប្រទេសអាល្លឺម៉ង់	:	សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់
បរិវិសកម្ម	:	ជាដំណើរការដែលប្រព្រឹត្តទៅក្រោមគោលការណ៍ណែនាំរបស់ គ.ម.ក ស្តីពីការកំណត់ផ្តែលក់មូលបត្រ និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ។
ផ.ម.ក	:	ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

និយមន័យនៃអក្សរកាត់ (ត)

ផលិតផល	:	ផលិតផលរបស់ក្រុមហ៊ុនរួមបញ្ចូលផលិតផលដែលផលិត និងបន្ថែមគុណប្រយោជន៍ដោយសម្ព័ន្ធក្រុមហ៊ុនផេសថិក រួចត្រូវបានចែកចាយដោយក្រុមហ៊ុនយើងខ្ញុំ ទៅកាន់តតីយជន (ភាគីទី៣) (ជាផលិតផលដែលមិនប្រើសម្រាប់គម្រោងរបស់ក្រុមហ៊ុន) មានដូចខាងក្រោម៖ (i) ផលិតគ្រឿងបរិក្ខារ និងបង្គុំប្រព័ន្ធថាមពលចុះពាណិជ្ជសញ្ញាដោយ សម្ព័ន្ធក្រុមហ៊ុនផេសថិក និង (ii) គ្រឿងបរិក្ខាររបស់តតីយជន (ភាគីទី៣) រួមបញ្ចូលជាមួយសេវាកម្មបន្ថែមគុណប្រយោជន៍ដោយសម្ព័ន្ធក្រុមហ៊ុនផេសថិក ដូចជា រូបសណ្ឋាន (configuration) (សរសេរកម្មវិធី និងវិស្វកម្ម) ការធ្វើតេស្តមុខងារ សេវាកម្មបន្ទាប់ពីការលក់ (ការគាំទ្រផ្នែកបច្ចេកទេស និងផលិតផល) និងការតម្លើងផលិតផល។
ពាក្យស្នើសុំ	:	ជាពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ IPO ដោយដាក់តាមទម្រង់ពាក្យស្នើសុំ
ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនធម្មតា ចំនួនច្រើនលើសលប់	:	ដូចមានចែងក្នុងគោលការណ៍ចុះបញ្ជីលក់មូលបត្រ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ សំដៅដល់ភាគហ៊ុនិក ឬក្រុមបុគ្គល ដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតចាប់ពី ៣០ ភាគរយឡើងទៅ ហើយដែលសិទ្ធិនោះអាចកើតឡើង ដោយផ្ទាល់ តាមរយៈការកាន់កាប់ភាគហ៊ុន ឬដោយប្រយោល
ភាគហ៊ុនបោះផ្សាយលក់	:	ភាគហ៊ុនថ្មីចំនួនរហូតដល់ ៣.៩៤៥.000 ភាគហ៊ុន នឹងត្រូវលក់ ក្នុងតម្លៃបោះផ្សាយលក់ ស្របទៅតាមការបោះផ្សាយជាសាធារណៈ
ភាគហ៊ុនរបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ឬ ភាគហ៊ុន	:	សំដៅដល់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតដែលមានតម្លៃចារឹកស្មើនឹង ៤00 រៀល (0.១ ដុល្លារអាមេរិក) នៅក្នុងក្រុមហ៊ុនផេសថិក (ខេមបូឌា)
មូលធនូបនីយកម្មទីផ្សារសរុប	:	សំដៅដល់តម្លៃទីផ្សារសរុបនៃភាគហ៊ុន ដែលបានបោះផ្សាយទាំងអស់ (share outstanding) របស់ក្រុមហ៊ុន។ មូលធនូបនីយកម្មសរុបអាចគណនា ដោយយកចំនួនភាគហ៊ុន ដែលបានបោះផ្សាយទាំងអស់របស់ក្រុមហ៊ុន គុណនឹងតម្លៃទីផ្សារបច្ចុប្បន្នក្នុងមួយឯកតាហ៊ុន
មូលបត្រកម្មសិទ្ធិ IPO	:	សំដៅដល់ភាគហ៊ុនបោះផ្សាយថ្មី ចំនួន ៣.៩៤៥.000 ភាគហ៊ុន

និយមន័យនៃអក្សរកាត់ (ត)

របាយការណ៍ស្រាវជ្រាវទីផ្សារឯករាជ្យ	:	ជារបាយការណ៍សិក្សាស្រាវជ្រាវទីផ្សារឯករាជ្យ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ចេញដោយក្រុមហ៊ុន Smith Zander International
វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ	:	សំដៅដល់រាល់វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ ផ.ម.ក រួមទាំងរាល់វិសោធនកម្ម និងការកែប្រែផ្សេងៗ
វិនិយោគិនសញ្ជាតិខ្មែរ	:	ជារូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលដែលមានភាគហ៊ុន ៥១% (ហាសិបមួយភាគរយ) ឡើងទៅកាន់កាប់ដោយរូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ
ស.រ.អ	:	សហរដ្ឋអាមេរិក
សម្ព័ន្ធក្រុមហ៊ុនផេសថិក (ខេមបូឌា)	:	ជាក្រុមហ៊ុនផេសថិក (ខេមបូឌា) និងបុត្រសម្ព័ន្ធ រួមគ្នា
សម្ព័ន្ធក្រុមហ៊ុនផេសថិកអន្តរជាតិ	:	ជាក្រុមហ៊ុន PIB និងបុត្រសម្ព័ន្ធ រួមគ្នា
សហវ	:	សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ឡុកអាប់	:	ស្របតាមប្រការ ១៩ នៃប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់ មូលបត្រកម្មសិទ្ធិ សម្រាប់រយៈពេលមួយ (១) ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទចុះបញ្ជីភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនធម្មតាចំនួនច្រើនលើសលប់ មិនអនុញ្ញាតឱ្យលក់ ឬផ្ទេរភាគហ៊ុនរបស់ខ្លួនក្នុងរយៈពេល ប្រាំមួយ (៦) ខែដំបូង និងអាចធ្វើការលក់ ឬផ្ទេរភាគហ៊ុនរបស់ខ្លួនក្នុងកម្រិតអតិបរមា ហាសិបភាគរយ (៥០%) សម្រាប់ប្រាំមួយ (៦) ខែបន្ទាប់។ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនធម្មតាចាប់ពី ១៥% ឡើងទៅ មិនឱ្យលក់ ឬផ្ទេរមូលបត្រកម្មសិទ្ធិ យ៉ាងហោចណាស់សម្រាប់រយៈពេលប្រាំមួយ (៦) ខែ បន្ទាប់ពីចុះបញ្ជីលក់មូលបត្រដំបូង ដោយយោងតាមមាត្រា១៧ នៃវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
អគ្គិសនីកម្ពុជា	:	អគ្គីសនីកម្ពុជា (Electricite Du Cambodge) ដែលជាសហគ្រាសរដ្ឋ
អតប	:	សំដៅដល់អាករលើតម្លៃបន្ថែម
O&M	:	ប្រតិបត្តិការ និងការថែទាំអនុស្ថានីយថាមពល និងខ្សែបញ្ជូន
អត្រាកំណើនប្រចាំឆ្នាំមធ្យម	:	អត្រាកំណើនប្រចាំឆ្នាំមធ្យម (Compound Annual Growth Rate)

និយមន័យនៃអក្សរកាត់ (ក)

អនុបាតភីអ៊ី (P/E)	:	សំដៅលើផលធៀបរវាងថ្លៃទីផ្សារក្នុងមួយឯកតាភាគហ៊ុននិងចំណូលនៃមួយឯកតាភាគហ៊ុន
អភិបាល	:	អភិបាលរបស់ក្រុមហ៊ុន ត្រូវកំណត់និយមន័យតាមរយៈប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនចុះបញ្ជីបោះផ្សាយលក់មូលបត្រ
ឯកសារផ្តល់ព័ត៌មាន	:	ជាឯកសារផ្តល់ព័ត៌មាន ដែលអធិប្បាយអំពីប្រវត្តិក្រុមហ៊ុន របាយការណ៍ហិរញ្ញវត្ថុ សាវតារបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ និងព័ត៌មានសំខាន់ៗដ៏ទៃទៀតដែលពាក់ព័ន្ធសម្រាប់វិនិយោគិន
EPCC	:	វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការតម្លើងសំដៅលើកាតព្វកិច្ចក្នុងការចាប់ផ្តើម បញ្ចប់ និងប្រគល់ជូនន្ទវគម្រោងទាំងស្រុង
Km	:	សំដៅលើខ្នាតរង្វាស់ចម្ងាយគិតជាគីឡូម៉ែត្រ
RM	:	ជារូបិយបណ្ណជាតិរបស់ប្រទេសម៉ាឡេស៊ី

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា

សន្ទានុក្រមនៃពាក្យបច្ចេកទេស

សន្ទានុក្រមនេះ មានពន្យល់អំពីពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងឯកសារផ្តល់ព័ត៌មានស្តីពីក្រុមហ៊ុន និងអ្នកជំនួរបស់ក្រុមហ៊ុន។ វាក្យស័ព្ទ និងអត្ថន័យរបស់ពាក្យទាំងនោះ អាចនឹងមិនឆ្លើយតបទៅនឹងការប្រើប្រាស់តាមស្តង់ដារឧស្សាហកម្ម និងការប្រើប្រាស់ត្រឹមត្រូវរបស់វា។

BCD (Binary Code Decimal)	:	សំដៅដល់ទសភាគប្រព័ន្ធគោលពីរ ជាវិធីសាស្ត្រក្នុងការសរសេរជាកូដឌីជីថលសម្រាប់លេខទសភាគពីរ ដែលលេខនីមួយៗតំណាងឱ្យលំដាប់ប្រព័ន្ធគោលរបស់វា។ នៅក្នុង BCD លេខមួយគឺជាការតំណាងដោយ៤ប៊ីត ដែលជាទូទៅ តំណាងឱ្យទសភាគពីលេខ 0 ទៅដល់លេខ ៩។
តង់ស្យុងខ្ពស់ខ្លាំង (Extra high voltage)	:	តង់ស្យុងខ្ពស់ខ្លាំង ឧទាហរណ៍ តង់ស្យុងលើស ២៣0 kV
Gwh	:	ជីហ្គាវ៉ាតម៉ោង គឺជាឯកតាថាមពលស្មើនឹង មួយពាន់លានវ៉ាត់ម៉ោង ឬមួយលានគីឡូវ៉ាត់ម៉ោង
តង់ស្យុងខ្ពស់ (High Voltage)	:	តង់ស្យុងខ្ពស់ ឧទាហរណ៍ តង់ស្យុងក្នុងចន្លោះ ១១ kV និង ២៣0 kV
គីឡូវ៉ុល (kV)	:	គីឡូវ៉ុល គឺជារង្វាស់នៃថាមពលដែលអាចចំរាញ់យកបានក្នុងចំហំពាន់ឯកតា នៅចំណុចណាមួយនៅក្នុងសៀគ្វីដែលពាក់ព័ន្ធទៅនឹងចំណុចយោងមួយ (ដី)
អំពែរមេហ្គាវ៉ុល (Megavolt ampere)	:	អំពែរមេហ្គាវ៉ុល គឺជារង្វាស់នៃថាមពលពិតនៅក្នុងឯកតាណាន ឧទាហរណ៍ ថាមពលអគ្គិសនីដែលប្រើប្រាស់ដោយឧបករណ៍អគ្គិសនី
ឧបករណ៍រ៉េស៊ីស្តង់កំណត់ភាពណឺតរបស់ដី (Neutral earthing resistor)	:	ឧបករណ៍រ៉េស៊ីស្តង់កំណត់ភាពណឺតរបស់ដី ប្រើប្រាស់ជាឧបករណ៍ថាមពលដើម្បីការពារឧបករណ៍បំលែងថាមពល ម៉ាស៊ីនភ្លើង និងរាល់ឧបករណ៍ពាក់ព័ន្ធដទៃទៀត ប្រឆាំងទៅនឹង កំហុសចរន្ត ដែលកើតចេញពីកំហុស 50/60Hz (short circuit) និងបាតុភូតអន្តរកាល (lighting switching operations)
RTU (Remote terminal unit)	:	ជាឧបករណ៍អគ្គិសនី microprocessor-controlled ដែលប្រសព្វវត្ថុក្នុងពិភពរូប (physical world) ទៅនឹងប្រព័ន្ធគ្រប់គ្រងចែកចាយ ឬ ប្រព័ន្ធ SCADA ដោយបញ្ជូនទិន្នន័យទូរលេខ (telemetry data) ទៅដល់ប្រព័ន្ធ និង/ឬ ផ្លាស់ប្តូររបៀបភ្ជាប់វត្ថុនោះតាមរយៈសារ ដែលទទួលបានពីប្រព័ន្ធ
SCADA (Supervisory control and data acquisition)	:	ជាទូទៅសំដៅដល់ប្រព័ន្ធគ្រប់គ្រងឧស្សាហកម្ម ឧ.ទ ប្រព័ន្ធកុំព្យូទ័រដែលត្រួតពិនិត្យនិងគ្រប់គ្រង ដំណើរការ ឧស្សាហកម្ម រចនាសម្ព័ន្ធ ឬ facility-based process

សន្ទានុក្រមនៃពាក្យបច្ចេកទេស (ត)

SIMS (Substation integration and monitoring system)	:	ជាដំណោះស្រាយជួយដល់ការត្រួតពិនិត្យពេញលេញ ឬការចូលទៅ ទិន្នន័យរបស់ឧបករណ៍អេឡិចត្រូនិកឆ្លាតវៃ (IED) ណាមួយដោយបង្កើត ផ្លូវចេញចូលដល់ IED តាមរយៈ software របស់ឧស្សាហករ

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា

១. សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន

ផ្នែកនេះគឺជាសេចក្តីសង្ខេបព័ត៌មានសំខាន់របស់ក្រុមហ៊ុន និងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុន ដែលបានដកស្រង់ពីអត្ថបទដើមទាំងស្រុងនៃឯកសារផ្តល់ព័ត៌មាននេះ។ លោកអ្នកគប្បីអាន និងយល់ ឱ្យបានច្បាស់ និងដោយប្រុងប្រយ័ត្នអំពីផ្នែកនេះ រួមជាមួយឯកសារផ្តល់ព័ត៌មានទាំងស្រុង មុនពេលសម្រេចវិនិយោគជាមួយក្រុមហ៊ុនយើង។

១.១. ទិដ្ឋភាពទូទៅរបស់ក្រុមហ៊ុន

ក្រុមហ៊ុនផេសថិក (ខេមបូឌា) ពីមុនមានឈ្មោះថា Tajri-Pestech JV Limited និង បានចុះបញ្ជីនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០ ជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតនៅព្រះរាជាណាចក្រកម្ពុជា ហើយក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការក្នុងឆ្នាំដដែល។ ក្រុមហ៊ុនបានអនុម័តប្រើឈ្មោះ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ឯ.ក ដែលជាឈ្មោះមុនរបស់ក្រុមហ៊ុននៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ ហើយប្រើប្រាស់ឈ្មោះនិងទម្រង់ក្រុមហ៊ុនបច្ចុប្បន្នរបស់យើងនៅក្រោយពេលដែលការកែប្រែរចនាសម្ព័ន្ធផ្ទៃក្នុង ដែលបានសម្រេចអនុម័តដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។ ក្រុមហ៊ុនយើង គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលត្រូវបានកាន់កាប់ទាំងស្រុងដោយក្រុមហ៊ុន PIB ដែលបានចុះបញ្ជី និងមានអាសយដ្ឋាននៅប្រទេសម៉ាឡេស៊ី ហើយបានចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោលនៃផ្សារភាគហ៊ុនប្រទេសម៉ាឡេស៊ី BURSA MALAYSIA SECURITIES BERHAD។

ក្រុមហ៊ុនយើង ជាក្រុមហ៊ុនបច្ចេកទេសថាមពលអគ្គិសនី។ ក្រុមហ៊ុនផ្តល់សេវាកម្មសំខាន់លើការ ផ្តល់ជូនវិស្វកម្មប្រព័ន្ធថាមពល និងដំណោះស្រាយបច្ចេកទេសសម្រាប់៖

- ការគូសប្តង់ លទ្ធកម្ម ការសាង់សង់ ការដំឡើង និងការដាក់ឱ្យប្រើប្រាស់នូវរអនុស្ថានីយ៍មានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង និងបណ្តាញបញ្ជូនអគ្គិសនីដែលមាន តង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ក៏ដូចជាប្រព័ន្ធថាមពលខ្សែកាបក្រោមដីសម្រាប់ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី និង
- ការជួញដូរបង្គុំ និងបរិក្ខារប្រព័ន្ធថាមពលដែលជាកម្មសិទ្ធិ និងមិនមែនកម្មសិទ្ធិ។

ក្រុមហ៊ុន PESTECH (Myanmar) Limited (“PESTECH (Myanmar)”) ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើងត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតបង្កើតឡើងក្រោមច្បាប់ក្រុមហ៊ុនរបស់ប្រទេសមីយ៉ាន់ម៉ា។ ក្រុមហ៊ុន PESTECH (Myanmar) ជាក្រុមហ៊ុនផ្តត់ផ្តង់វិស្វកម្មប្រព័ន្ធថាមពលចម្រុះ និងដំណោះស្រាយបច្ចេកទេសចម្រុះសម្រាប់ ការរចនា លទ្ធកម្ម ការសាងសង់ និងសេវាពាក់ពន្ធនឹងឧស្សាហកម្មអគ្គិសនី។

១. សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន (ត)

PESTECH Hinthar Corporation Limited ("PESTECH Hinthar") ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ (៦០%) ត្រូវបានបង្កើតឡើងនៅថ្ងៃទី ២៤ មិថុនា ឆ្នាំ២០១៩ ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតបង្កើតឡើងក្រោមច្បាប់ក្រុមហ៊ុនរបស់ប្រទេសមីយ៉ាន់ម៉ា។ PESTECH Hinthar ជាក្រុមហ៊ុនផ្គត់ផ្គង់វិស្វកម្មប្រព័ន្ធថាមពលទូលំទូលាយ ការសាងសង់ និងគួសប្តង់ ការដំឡើង និងសេវាពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យថាមពលអគ្គិសនី។

PESTECH Microgrid Corporation Limited ("PESTECH Microgrid") ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ (៩០%) ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៤ កុម្ភៈ ឆ្នាំ២០២០ ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតបង្កើតឡើងក្រោមច្បាប់ក្រុមហ៊ុនរបស់ប្រទេសមីយ៉ាន់ម៉ា។ PESTECH Microgrid ជាក្រុមហ៊ុនផ្គត់ផ្គង់វិស្វកម្មប្រព័ន្ធថាមពលខ្នាតតូច និងហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនីតាមបណ្តាជនបទរបស់របស់ប្រទេសមីយ៉ាន់ម៉ា។

ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងទំនិញ និងសេវាកម្មគោលរបស់ក្រុមហ៊ុន មានរៀបរាប់នៅផ្នែកទី៤.១.៦ នៃឯកសារផ្តល់ព័ត៌មាននេះ។

ដ្យាក្រាម*ខាងក្រោមនេះបង្ហាញពីរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន មុន និងបន្ទាប់ពីការរៀបចំផ្នែកក្នុងឡើងវិញ៖

រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនមុនពេលការរៀបចំផ្នែកក្នុងឡើងវិញ



រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនបន្ទាប់ពីការរៀបចំផ្នែកក្នុងឡើងវិញ



ចំណាំ៖

^ បង្ហាញអំពីចំណែកកម្មសិទ្ធិរបស់ក្រុមហ៊ុនមេក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

** ដ្យាក្រាមខាងលើពុំបានរួមបញ្ចូលក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់របស់ក្រុមហ៊ុន PIB ទេ*

១. សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន (ក)

១.២. អត្ថប្រយោជន៍ប្រកួតប្រជែង ផែនការអនាគត និង យុទ្ធសាស្ត្រធុរកិច្ច

១.២.១. អត្ថប្រយោជន៍ប្រកួតប្រជែង

ក្រុមហ៊ុនយើងមានចំណុចខ្លាំង និងអត្ថប្រយោជន៍ប្រកួតប្រជែងមួយចំនួន ដើម្បីទ្រទ្រង់ធុរកិច្ច និងការរីកចម្រើនរបស់ខ្លួន។ អត្ថប្រយោជន៍ប្រកួតប្រជែងសំខាន់ៗទាំងនោះរួមមាន៖

១. អាជីវកម្មរបស់ក្រុមហ៊ុនមានលក្ខណៈអំណោយផលដើម្បីទទួលបានផលប្រយោជន៍ពីកំណើនតម្រូវការអគ្គិសនីក្នុងប្រទេសកម្ពុជា

២. ក្រុមហ៊ុនមានជំនាញបច្ចេកទេសខាងវិស្វកម្មប្រព័ន្ធថាមពលអគ្គិសនីរឹងមាំ

៣. ក្រុមហ៊ុនមានសមាហរណកម្មគំរូអាជីវកម្មទូទាំងផ្នែកវិស្វកម្មប្រព័ន្ធថាមពលអគ្គិសនី បញ្ជូន និងចែកចាយថាមពលអគ្គិសនី

៤. ក្រុមហ៊ុនសង្កត់ធ្ងន់ទៅលើគុណភាពជាចម្បងសម្រាប់ការផ្តល់សេវាកម្មរបស់យើង និង

៥. ក្រុមហ៊ុនមានថ្នាក់គ្រប់គ្រងដែលមានបទពិសោធន៍ និងមានការប្តេជ្ញាខ្ពស់ យកចិត្តទុកដាក់ទៅលើការរីកចម្រើននៃធុរកិច្ចរបស់ក្រុមហ៊ុន។

១២..២. ផែនការអនាគត និងយុទ្ធសាស្ត្រធុរកិច្ច

ក្រុមហ៊ុនមានបំណងអនុវត្តយុទ្ធសាស្ត្រនានាដូចខាងក្រោម ដើម្បីជាផ្នែកមួយនៃផែនការអនាគតរបស់យើងដើម្បីអភិវឌ្ឍន៍ និងរក្សាកម្លាំងប្រកួតប្រជែង៖

១. ក្រុមហ៊ុនមានបំណងបន្តពង្រឹងជំហរទីផ្សាររបស់ខ្លួន ក្នុងផ្នែកបញ្ជូន និងចែកចាយថាមពលក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការថាមពលអគ្គិសនីដែលចេះតែកើនឡើង

២. ក្រុមហ៊ុនកំពុងធ្វើពិពិធកម្មសកម្មភាពវិស្វកម្មប្រព័ន្ធថាមពលអគ្គិសនី និងដំណោះស្រាយបច្ចេកទេស ដោយបញ្ចូលការងារប្រតិបត្តិការ និងតំហែទាំហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនី

៣. ក្រុមហ៊ុនមានបំណងបន្ថែមសកម្មភាពចែកចាយថាមពលអគ្គិសនី ដែលអាចបង្កើតចំណូលបន្ថែមសម្រាប់ក្រុមហ៊ុន

៤. ក្រុមហ៊ុនមានបំណងបន្តបង្កើនឱកាសទីផ្សារសម្រាប់ការបញ្ជូន និងចែកចាយថាមពលអគ្គិសនីក្នុងបណ្តាប្រទេសជិតខាង

៥. ក្រុមហ៊ុនមានបំណងបង្កើតមធ្យោបាយផលិតបង្គុំប្រព័ន្ធថាមពលអគ្គិសនី ដើម្បីធ្វើពិពិធកម្មចំណូលរបស់ខ្លួន និង

១. សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន (ក)



ខ. ក្រុមហ៊ុនមានបំណងស្វែងរកឱកាសក្នុងការចុះបញ្ជីលើកទីពីរ (secondary listing) នៅផ្សារភាគហ៊ុនប្រទេសថៃបន្ទាប់ពីបញ្ចប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនេះ។

ព័ត៌មានបន្ថែមស្តីពីអត្ថប្រយោជន៍ដែលមានលក្ខណៈប្រកួតប្រជែង ផែនការអនាគត និងយុទ្ធសាស្ត្រធុរកិច្ចរបស់ក្រុមហ៊ុនមានរៀបរាប់ក្នុងផ្នែកទី៤.១.៧ នៃឯកសារផ្តល់ព័ត៌មាននេះ។

១.៣. អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក

១.៣.១. ភាគហ៊ុនិក

មុនពេលការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ក្រុមហ៊ុនយើងគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលត្រូវបានកាន់កាប់ទាំងស្រុងដោយក្រុមហ៊ុន PIB។

១.៣.២. អភិបាល

ឈ្មោះ	មុខតំណែង
លោក Lim Pay Chuan (“Paul Lim”)	ប្រធានក្រុមប្រឹក្សាប្រតិបត្តិ
លោក Lim Ah Hock	អភិបាលប្រតិបត្តិ
លោក Han Fatt Juan	អភិបាលប្រតិបត្តិ/នាយកប្រតិបត្តិ
លោក Tan Pu Hooi (“Charles Tan ”)	អភិបាលប្រតិបត្តិ
ឯកឧត្តម ដាវ អានសាន	អភិបាលឯករាជ្យ

១.៣.៣. បុគ្គលិកជាន់ខ្ពស់

ឈ្មោះ	មុខតំណែង
លោក Han Fatt Juan	អភិបាលប្រត្តិបត្តិ/នាយកប្រត្តិបត្តិ
លោក Teh Bee Choo	ប្រធានផ្នែកហិរញ្ញវត្ថុ
កញ្ញា Tann Sochan	ប្រធានជាន់ខ្ពស់/លេខាធិការ
លោក N Saravanan Nadarajah	ប្រធានផ្នែកគម្រោងនិងការលេញផ្លែ
លោក Pablo T. Magpantay	ប្រធានផ្នែក O&M

ព័ត៌មានបន្ថែមស្តីអំពីភាគហ៊ុនិក អភិបាល បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន និងការកាន់កាប់ភាគហ៊ុនដោយផ្ទាល់ និងមិនផ្ទាល់របស់ពួកគេមានរៀបរាប់ក្នុងផ្នែកទី៥ នៃឯកសារផ្តល់ព័ត៌មាននេះ។



១. សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន (ត)

១.៤. ព័ត៌មានពីប្រវត្តិហិរញ្ញវត្ថុ

១.៤.១. របាយការណ៍ប្រាក់ចំណូលលម្អិត

តារាងខាងក្រោមជាសេចក្តីសង្ខេបរបាយការណ៍ចំណេញ ឬខាតរបស់ក្រុមហ៊ុន ដែលបានធ្វើសវនកម្មរួចរាល់សម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ វត្តមានរបាយការណ៍ចំណេញ ឬខាត គឺសម្រាប់តែគោលបំណងបង្ហាញតែប៉ុណ្ណោះ និងគប្បីអានជាមួយកំណត់ចំណាំ និងការសន្និដ្ឋានភ្ជាប់ជាមួយរបាយការណ៍គណនេយ្យករ ដែលមានកំណត់ក្នុងផ្នែកទី៩ នៃឯកសារផ្តល់ព័ត៌មាននេះ។

	ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨		ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ចំណូល	៧៧.១៥៧	៣១៣.៤៨៦	៥៦.៨២៧	២៣១.០៥៨
ថ្លៃដើមលក់ និងការសាងសង់	(៦២.៩៦៧)	(២៥៥.៨៣៤)	(៤៩.៧៧០)	(២០២.៣៦៥)
ចំណេញដុល	**១៤.១៩០**	**៥៧.៦៥២**	**៧.០៥៧**	**២៨.៦៩៣**
ចំណូលផ្សេងៗ	៧	២៩	១.៥២២	៦.១៨៧
ចំណាយលើប្រតិបត្តិការ	(៤.០៦៣)	(១៦.៥០៦)	(២.៧៨១)	(១១.៣០៦)
ចំណេញប្រតិបត្តិការ	**១០.១៣៤**	**៤១.១៧៥**	**៥.៧៩៨**	**២៣.៥៧៤**
ចំណូលហិរញ្ញប្បទាន	-	១	១២	៤៨
ចំណាយហិរញ្ញប្បទាន	(១៦៩)	(៦៨៨)	(៣.៤៦៧)	(១៤.០៩៤)
ចំណេញមុនគិតពន្ធ	**៩.៩៦៥**	**៤០.៤៨៨**	**២.៣៤៣**	**៩.៥២៨**
ការចំណាយពន្ធលើប្រាក់ចំណូល	(២.៣៨៤)	(៩.៦៨៤)	(៥៦៨)	(២.៣១០)
ចំណេញក្នុងគ្រា	**៧.៥៨១**	**៣០.៨០៤**	**១.៧៧៥**	**៧.២១៨**
ការខាត់បងតម្លៃលើលំហូរសាច់ប្រាក់	-	-	(១.៨២៤)	(៧.៤១៧)
លទ្ធផលចំណេញ ឬខាតលម្អិតប្រចាំឆ្នាំ	**៧.៥៨១**	**៣០.៨០៤**	**(៤៩)**	**(១៩៩)**
គំលាតចំណេញដុល (%)	១៨,៣៩	១៨,៣៩	១២,៤២	១២,៤២
គម្លាតប្រាក់ចំណេញមុនពេលគិតពន្ធ (%)	១២,៩២	១២,៩២	៤,១២	៤,១២

១.៤.២. ទ្រាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

តារាងខាងក្រោមជាសេចក្តីសង្ខេបរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលរាយនៅក្នុងសវនកម្មរួចរាល់ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គឺសម្រាប់តែគោលបំណងបង្ហាញតែប៉ុណ្ណោះ និងគប្បីអានជាមួយជាមួយកំណត់ចំណាំ និងការសន្និដ្ឋានភ្ជាប់ជាមួយរបាយការណ៍គណនេយ្យករ ដែលមានកំណត់ក្នុងផ្នែកទី៩ នៃឯកសារផ្តល់ព័ត៌មាននេះ។

	ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨		ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានពាន់រៀល
ទ្រព្យសកម្ម				
ទ្រព្យសកម្មរយៈពេលវែង				
ទ្រព្យសម្បត្តិ អាងចក្រ និងបរិក្ខារ	១.៩១៣	៧.៧៧១	២.២៤៧	៩.១៣៥
ទ្រព្យសកម្មអរូបីយ	-	-	៣	១២
ទ្រព្យសកម្មកិច្ចសន្យា	១៤៦.៥៨៧	៥៩៥.៥៨៣	១៧៣.០៥៩	៧០៣.៦៥៨
ទ្រព្យសកម្មរយៈពេលវែងសរុប	**១៤៨.៥០០**	**៦០៣.៣៥៤**	**១៧៥.៣០៩**	**៧២១.៨០៥**
ទ្រព្យសកម្មរយៈពេលខ្លី				
គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ	៨៤៦	៣.៤៣៦	១០.៨០៤	៤៣.៩២៨
ទ្រព្យសកម្មកិច្ចសន្យា	-	-	៦.០៤២	២៤.៥៦៥
ទឹកប្រាក់ភាគីសម្ព័ន្ធញាតិជំពាក់	-	-	១.៩៤៤	៧.៩០៧
សាច់ប្រាក់ និងសមតុល្យធនាគារ	២.០៨៤	៨.៤៦៩	១៣.០៥៦	៥៣.០៨៦
ទ្រព្យសកម្មរយៈពេលខ្លីសរុប	**២.៩៣០**	**១១.៩០៥**	**៣១.៨៤៦**	**១២៩.៤៨៦**
ទ្រព្យសកម្មសរុប	**១៥១.៤៣០**	**៦១៥.២៥៩**	**២០៧.១៥៥**	**៨៤២.២៩១**
មូលធន និងបំណុល				
មូលធន				
ដើមទុន	៧.១០០	២៨.៨៤៧	៧.១០០	២៨.៨៦៨
ដើមទុនបម្រុងទុក	៥២	២១១	(១.៧៧២)	(៧.២០៥)
ចំណេញរក្សាទុក	២០.៦៣១	៨៣.៨២៤	៨.៥៩៥	៣៤.៩៤៧

១. សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន (ត)

	ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨		ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានពាន់រៀល
មូលធនសរុប	**២៧.៧៨៣**	**១១២.៨៨២**	**១៣.៩២៣**	**៥៦.៦១០**
បំណុលរយៈពេលវែង				
ប្រាក់កម្ចី	១៩.៩៤៥	៨១.០៣៧	៩៥.៤០៧	៣៨៧.៩២៥
ឧបករណ៍និស្សន្ទ	-	-	១.៨២៤	៧.៤១៧
បំណុលរយៈពេលវែងសរុប	**១៩.៩៤៥**	**៨១.០៣៧**	**៩៧.២៣១**	**៣៩៥.៣៤២**
បំណុលរយៈពេលខ្លី				
គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង				
បំណុលផ្សេងៗ	៤៨.០០៥	១៩៥.០៤៣	៨.៣១៧	៣៣.៨១៨
ទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុនមេ	៥៦៥	២.២៩៦	៥៩.៥៥៨	២៤២.១៦២
ទឹកប្រាក់ដែលជំពាក់ភាគីសម្ព័ន្ធញាតិ	៤៩.៦៧៩	២០១.៨៤៦	២៣.០១៨	៩៣.៥៨៩
ប្រាក់កម្ចី	២.០៦៨	៨.៤០២	៤.១៨០	១៦.៩៩៧
ពន្ធលើប្រាក់ចំណូលត្រូវបង់	៣.៣៨៥	១៣.៧៥៣	៩២៨	៣.៧៧៣
បំណុលរយៈពេលខ្លីសរុប	**១០៣.៧០២**	**៤២១.៣៤០**	**៩៦.០០១**	**៣៩០.៣៣៩**
បំណុលសរុប	**១២៣.៦៤៧**	**៥០២.៣៧៧**	**១៩៣.២៣២**	**៧៨៥.៦៨១**
មូលធន និងបំណុលសរុប	**១៥១.៤៣០**	**៦១៥.២៥៩**	**២០៧.១៥៥**	**៨៤២.២៩១**

ព័ត៌មានបន្ថែមផ្សេងទៀតពាក់ព័ន្ធនឹងរបាយការណ៍បិរញ្ញវត្ថុរបស់យើង គឺមានសរសេរនៅក្នុងផ្នែកទី៧ នៃឯកសារផ្តល់ព័តមាននេះ។

១. សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន (ត)

១.៥. កត្តាចាំបាច់ពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈ

ស្ថិតិខាងក្រោមនេះដែលពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រកម្មសិទ្ធិសាធារណៈរបស់ក្រុមហ៊ុន ដកស្រង់ចេញពីសំណៅសរសេរទាំងមូលនៅក្នុងឯកសារផ្តល់ព័ត៌មាននេះ ហើយដែលគប្បីត្រូវអានភ្ជាប់ជាមួយនឹងសំណៅសរសេរនោះ។

	ចំនួនភាគហ៊ុន	លានដុល្លារអាមេរិក	លានរៀល
ដើមទុនដែលបានបោះផ្សាយ និងបង់រួចរាល់	៧១.000.000	៧,១0	២៨.៤00
ភាគហ៊ុនដែលនឹងធ្វើការបោះផ្សាយស្របតាមការបោះផ្សាយជាសាធារណៈ:	៣.៩៤៥.000	0,៣៩	១.៥៧៨
ដើមទុនពង្រីកដែលបានបោះផ្សាយ និងបង់រួចរាល់បន្ទាប់ពីចុះបញ្ជី	៧៤.៩៤៥.000	៧,៤៩	២៩.៩៧៨
តម្លៃបោះផ្សាយ (ដុល្លារអាមេរិក ខ្មែររៀល)	-	0,៧៦	៣.១២0
មូលធនទីផ្សារសរុប	-	៥0,៩0	២៣៣.៨២៨

ក្រុមហ៊ុនមានភាគហ៊ុនបោះផ្សាយតែមួយ (១) ចំណាត់ថ្នាក់ប៉ុណ្ណោះ គឺភាគហ៊ុនមានសិទ្ធិបោះឆ្នោត ក្នុងតម្លៃ ៤00 រៀល (0,១0 ដុល្លារអាមេរិក) ក្នុងមួយភាគហ៊ុន។ ភាគហ៊ុនបោះផ្សាយត្រូវចាត់ចំណាត់ថ្នាក់ ស្មើគ្នានឹងភាគហ៊ុនបោះផ្សាយដែលមានស្រាប់រួមមាន សិទ្ធិបោះឆ្នោត សិទ្ធិទទួលបានទ្រព្យសម្បត្តិដែលនៅសល់របស់ក្រុមហ៊ុននៅពេលរំលាយក្រុមហ៊ុន និងសិទ្ធិក្នុងការទទួលបានភាគលាភ និងការបែងចែកដែលនឹងត្រូវប្រកាសដែលត្រូវបង់ជូន ឬធ្វើឡើងនៅកាលបរិច្ឆេទ ឬបន្ទាប់ពីកាលបរិច្ឆេទនៃការបែងចែកនោះ។

តម្លៃបោះផ្សាយលក់គឺ ៣.១២0 រៀល (0,៧៦ ដុល្លារអាមេរិក) ដែលត្រូវបង់ទាំងស្រុងជាមួយពាក្យស្នើសុំដែលអាស្រ័យទៅលើលក្ខខណ្ឌនៃឯកសារផ្តល់ព័ត៌មាននេះ។

ចំនួនបរិវិសកម្មអប្បបរមាសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងនេះ នឹងមានចំនួនមួយរយ (១00) ភាគហ៊ុន ក៏ប៉ុន្តែប្រសិនបើចំនួនភាគហ៊ុនដែលបានគណនាជាមុនបែងចែកទៅវិនិយោគិនជោគជ័យមានចំនួនតិចជាង ១00 ភាគហ៊ុនចំនួនអប្បបរមានេះ មិនត្រូវរារាំងដល់វិនិយោគិនជោគជ័យនោះពីការធ្វើបរិវិសកម្មនូវចំនួនភាគហ៊ុនគណនាជាមុននោះឡើយ។

ព័ត៌មានបន្ថែមអំពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង មានរៀបរាប់នៅក្នុងផ្នែកទី២ នៃឯកសារផ្តល់ព័ត៌មាននេះ។

១. សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន (ត)

១.៦. ការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

ក្រុមហ៊ុនរំពឹងថា សាច់ប្រាក់ដុលដែលបានមកពីការបោះផ្សាយមូលបត្រជាសាធារណៈមានប្រមាណ ៣.០០ លានដុល្លារអាមេរិក ឬ ១២.៣០៨ លានរៀល ដោយផ្អែកលើតម្លៃបោះផ្សាយលក់ជាសាធារណៈ ៣.១២០ រៀល (០,៧៦ ដុល្លារអាមេរិក) ក្នុងមួយភាគហ៊ុន។ ក្រុមហ៊ុនត្រូវទទួលបានសាច់ប្រាក់នោះ ហើយត្រូវទទួលខុសត្រូវលើការចំណាយទាំងអស់ពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិសម្រាប់ដើមទុនដែលបានពង្រីក និងបង់រួចរាល់ទាំងអស់នៅ ផ.ម.ក។

ក្រុមហ៊ុនមានបំណងប្រើប្រាស់សាច់ប្រាក់ដូចខាងក្រោម៖

ល.រ	ព័ត៌មានលម្អិតអំពីការប្រើប្រាស់	តារាងពេលវេលារំពឹងទុកការប្រើប្រាស់ក្រោយការចុះបញ្ជី	ចំនួនពាន់ដុល្លារអាមេរិក	ភាគរយនៃប្រាក់ចំណូលសរុប %
១.	ហិរញ្ញប្បទានគម្រោងមានស្រាប់និងអនាគតរបស់ក្រុមហ៊ុន	ក្នុងរយៈពេល ១២ ខែ	២.០០០	៦៦.៧
២.	ទុនបង្វិល	ក្នុងរយៈពេល ១២ ខែ	៤៩១	១៦.៤
៣.	ការប៉ាន់ប្រមាណចំណាយលើការបោះផ្សាយ	ក្នុងរយៈពេល ៣ ខែ	៥០៧	១៦.៩
	ប្រាក់ចំណូលសរុប		**២.៩៩៨**	**១០០,០**

ព័ត៌មានបន្ថែមអំពីការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបានកំណត់នៅក្នុងផ្នែកទី ២.១២ នៃឯកសារផ្តល់ព័ត៌មាននេះ។

១. សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន (ត)

១.៧. កត្តាហានិភ័យនានា

មានកត្តាហានិភ័យមួយចំនួនដែលមានជាក់លាក់ចំពោះក្រុមហ៊ុនយើង និងខ្លះទៀតពាក់ព័ន្ធទៅនឹងទីផ្សារ ពាណិជ្ជកម្មទូទៅដែលអាចជះឥទ្ធិពលដល់ដំណើរការហិរញ្ញវត្ថុនាពេលអនាគតរបស់ក្រុមហ៊ុនផងដែរ។ មុនពេលធ្វើការសម្រេចចិត្តវិនិយោគ លោកអ្នកគួរតែពិចារណាឱ្យបានច្បាស់លាស់នូវហានិភ័យផ្សេងៗ និងកត្តាមួយចំនួនដែលមានរៀបរាប់ខាងក្រោម ព្រមទាំងបញ្ហាផ្សេងៗទៀតដែលមានក្នុងឯកសារផ្តល់ព័ត៌មាននេះផងដែរ។ លោកអ្នកគួរកត់សម្គាល់ថា បញ្ជីខាងក្រោមនេះមិនមែនជាបញ្ជីទាំងស្រុងស្តីពីហានិភ័យដែលក្រុមហ៊ុនជួបប្រទះ ឬហានិភ័យដែលអាចកើតឡើងនាពេលអនាគតទាំងអស់នោះឡើយ៖

ក. ការប្រែប្រួលនៃអត្រាការប្រាក់

ខ. ការប្រែប្រួលនៃអត្រាប្តូរប្រាក់

គ. ការពឹងផ្អែកលើតម្រូវការផ្គត់ផ្គង់អគ្គិសនី

ឃ. ការផ្លាស់ប្តូរលក្ខខណ្ឌសេដ្ឋកិច្ចនយោបាយ សង្គម និងបទប្បញ្ញត្តិក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសដទៃទៀត ដែលយើងអាចនឹងមានប្រតិបត្តិការជាមួយ

ង. ហានិភ័យប្រតិបត្តិការប្រចាំថ្ងៃ និងការធានារ៉ាប់រង

ច. លទ្ធផលពឹងផ្អែកលើគម្រោង

ឆ. ហានិភ័យពាក់ព័ន្ធនឹងគម្រោង

ជ. ការពឹងផ្អែក និងអសមត្ថភាពក្នុងការរក្សាបុគ្គលិកគ្រប់គ្រងសំខាន់ៗ

ឈ. ការពឹងផ្អែកទៅលើភាគីទីបីក្នុងការផ្គត់ផ្គង់គ្រឿងបរិក្ខារ គ្រឿងបង្គុំ និងផ្នែកផ្សេងៗទៀតសម្រាប់គម្រោងរបស់ក្រុមហ៊ុន

ញ. ហានិភ័យប្រើប្រាស់បច្ចេកទេសរបស់ភាគីទីបី

ដ. ការពឹងផ្អែកលើអតិថិជនធំៗ

ឋ. ការពឹងផ្អែកលើអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការព្រមព្រៀងនានា ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងប្រទេសកម្ពុជា

ឌ. ភាពជាកម្មសិទ្ធិ និងការគ្រប់គ្រងដោយភាគហ៊ុនិកដែលមានស្រាប់

ឍ. ហានិភ័យហិរញ្ញវត្ថុ រួមទាំងហានិភ័យសន្ទនីយភាព និងហានិភ័យឥណទាន និងតម្រូវការដើមទុននាពេលអនាគតដែលនឹងតម្រូវហិរញ្ញប្បទានបន្ថែម

ណ. ហានិភ័យវិវាទ និងបំណុលជាយថាហេតុ

ត. ហានិភ័យទាក់ទងនឹងការវិនិយោគលើមូលបត្រ

ថ. និងការផ្តល់ព័ត៌មានអំពីសេចក្តីថ្លែងការណ៍ពីអនាគត

ព័ត៌មានបន្ថែមអំពីកត្តាហានិភ័យនានាត្រូវបានកំណត់នៅក្នុងផ្នែកទី ៣ នៃឯកសារផ្តល់ព័ត៌មាននេះ។

១. សេចក្តីសង្ខេបឯកសារផ្តល់ព័ត៌មាន (ត)

១.៨. គោលនយោបាយភាគលាភ

វាគឺជាឆន្ទៈរបស់ក្រុមប្រឹក្សាភិបាលយើងក្នុងការអនុញ្ញាតឱ្យភាគហ៊ុនិកចូលរួមក្នុងការចំណេញរបស់ក្រុមហ៊ុនយើង ក៏ដូចជារក្សានូវភាគបំរុងគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍន៍នាពេលអនាគតរបស់ក្រុមហ៊ុនយើង។

លទ្ធភាពក្នុងការបែកចែកភាគលាភនាពេលអនាគតជូនម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន អាស្រ័យទៅតាមកត្តាផ្សេងៗរួមមានជាអាទិ៍ ប្រតិបត្តិការហិរញ្ញវត្ថុ តម្រូវការចលនាសាច់ប្រាក់ ប្រាក់ចំណេញរក្សាទុក តម្រូវការចំណាយដើមទុន និងកត្តាផ្សេងទៀតដែលក្រុមប្រឹក្សាភិបាលគិតថាពាក់ព័ន្ធ។

បន្ទាប់ពីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមានបំណងបង្កើតឱ្យមានជាស្ថិរភាព និងចិរភាពនៃគោលនយោបាយបែងចែកភាគលាភ ដើម្បីអនុញ្ញាតឱ្យភាគហ៊ុនិកនីមួយៗចូលរួមទទួលបានប្រាក់ចំណេញពីក្រុមហ៊ុន ខណៈពេលដែលខ្លួនកំពុងរក្សាវចនាសម្ព័ន្ធដើមទុនឱ្យបានប្រសើរ និងធានាឱ្យបានន្យូវមូលនិធិគ្រប់គ្រាន់សម្រាប់ការរីកចម្រើននាពេលអនាគត។

អាស្រ័យហេតុនេះ វាគឺជាចេតនារបស់យើងក្នុងការផ្តល់អនុសាសន៍ និងបែងចែកភាគលាភអប្បបរមាចំនួនសាមសិបភាគរយ (៣០,០០%) នៃប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធរបស់យើង ក្រោមលក្ខខណ្ឌដែលមានចែងខាងលើ។

ក្រុមហ៊ុនអាចពិចារណាទូទាត់នូវភាគលាភនោះក្នុងទម្រង់ជាសាច់ប្រាក់សុទ្ធ ជាភាគហ៊ុននៅក្នុងក្រុមហ៊ុនសម្រាប់ការវិនិយោគឡើងវិញ ឬរួមបញ្ចូលជម្រើសទាំងពីរខាងលើ។ នៅពេលដែលមានជម្រើស ភាគហ៊ុនិកមានសិទ្ធិជ្រើសរើសជាសាច់ប្រាក់ ភាគហ៊ុន ឬទាំងពីររួមគ្នា ដោយអនុលោមទៅតាមច្បាប់ និងគោលការណ៍ដែលមានក្នុងព្រះរាជាណាចក្រកម្ពុជា។

ទោះជាយ៉ាងណា ចេតនាក្នុងការណែនាំឱ្យមានការបែងចែកភាគលាភនេះ មិនមែនជាកាតព្វកិច្ចផ្លូវច្បាប់ចងភ្ជាប់ទៅនឹងក្រុមហ៊ុននោះឡើយ។ ដូចគ្នានេះដែរ កម្រិតនៃភាគលាភមិនគួរចាត់ទុកជាសូចនាករកំណត់អំពីគោលនយោបាយបែងចែកភាគលាភនាពេលអនាគតរបស់ក្រុមហ៊ុននោះឡើយ។ មិនមានការធានា មួយថាភាគលាភនឹងត្រូវបានបែងចែកនាពេលអនាគត ឬនៅពេលកំណត់ណាមួយនោះឡើយ។ ក្រុមហ៊ុនយកចិត្តទុកដាក់លើការបង្កើនប្រយោជន៍ជាអតិបរមាដល់ម្ចាស់ភាគហ៊ុន ក្នុងការពិចារណាកំណត់ពីការបែងចែកភាគលាភទៅតាមឆ្នាំហិរញ្ញវត្ថុបន្តបន្ទាប់។

វិនិយោគិនមិនគួរយកសេចក្តីថ្លែងការណ៍ខាងលើ ដើម្បីកំណត់ពីផលចំណេញជាក់ស្តែងនាពេលអនាគត ឬលទ្ធភាពក្នុងការបែងចែកភាគលាភរបស់ក្រុមហ៊ុននាពេលអនាគតឡើយ។

២. ការពិពណ៌នាអំពីសំណើច្មោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

២.១. ព័ត៌មានទូទៅរបស់ក្រុមហ៊ុន

ឈ្មោះក្រុមហ៊ុន	:	ក្រុមហ៊ុន ផេសទិក (ខេមបូឌា) ម.ក
អាសយដ្ឋាន	:	លេខ ៦ ផ្លូវ ៥៨៨ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ	:	www.pestech.com.kh
អ៊ីម៉ែល	:	info@pestech.com.kh
លេខទូរស័ព្ទ	:	+៨៥៥ ២៣ ៨៨២ ១០៥
លេខទូរសារ	:	+៨៥៥ ២៣ ៨៨២ ១០៦
លេខចុះបញ្ជីពាណិជ្ជកម្ម	:	០០០០០៩៥៧ កាលបរិច្ឆេទ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០
អាជ្ញាប័ណ្ណចេញដោយក្រសួងដែនដី នគរូបនីយកម្ម និងសំណង់	:	៣២៦ ប្រ.ដនស/អនស កាលបរិច្ឆេទ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨

២.២. ព័ត៌មានស្តីពីក្រុមហ៊ុនធានាធិញមូលបត្រ

២.២.១.ព័ត៌មានទូទៅរបស់ក្រុមហ៊ុនធានាធិញមូលបត្រ

ឈ្មោះក្រុមហ៊ុន	:	អ អេច ប៊ី ស៊ីយ្យូរឹធី (ខេមបូឌា) ម.ក
អាសយដ្ឋាន	:	ជាន់ M OHK Tower កាច់ជ្រុងផ្លូវលេខ១១០ & ៩៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ	:	www.rhbgroup.com.kh
អ៊ីម៉ែល	:	rhbsc.info@rhbgroup.com
លេខទូរស័ព្ទ	:	+៨៥៥ ២៣ ៩៦៩ ១៦១
លេខចុះបញ្ជីពាណិជ្ជកម្ម	:	០០០០៣២៩៥
- ចេញដោយ	:	ក្រសួងពាណិជ្ជកម្ម
- កាលបរិច្ឆេទចុះបញ្ជី	:	ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០
លេខអាជ្ញាប័ណ្ណចេញដោយ គ.ម.ក	:	០០៩ គ.ម.ក/កធ
- កាលបរិច្ឆេទលេខចុះបញ្ជី	:	ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៨

ព្រះរាជាណាចក្រកម្ពុជា ផេសទិក (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

២. ការពិភាក្សាអំពីសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

២.២.២. លក្ខខណ្ឌនៃកិច្ចព្រមព្រៀងធានាទិញមូលបត្រ

ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងធានាទិញមូលបត្រ ជាមួយនឹងក្រុមហ៊ុនធានាទិញមូលបត្រដើម្បីធានាទិញមូលបត្រចំនួន ២.៦៣១.៥៧៩ ភាគហ៊ុន ហើយក្រុមហ៊ុនធានាទិញមូលបត្រនឹងប្រែងប្រែងលក់អស់លទ្ធភាពរហូតដល់ចំនួន ១.៣១៣.៤២១ ភាគហ៊ុនទៀត ក្នុងតម្លៃបោះផ្សាយលក់។

កាតព្វកិច្ចនៃការធានាទិញមូលបត្ររបស់ក្រុមហ៊ុនធានាទិញមូលបត្រត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដ៏ជាក់លាក់សមស្របមួយមុននឹងចុះបញ្ជីផ្តល់ឯកសារព័ត៌មានជាមួយនឹង គ.ម.ក។

លក្ខខណ្ឌខាងក្រោមត្រូវបានស្រង់ចេញពីកិច្ចព្រមព្រៀងធានាទិញមូលបត្រ ក្រុមហ៊ុនធានាទិញមូលបត្រអាចផ្តល់ដំណឹងទៅកាន់ក្រុមហ៊ុនគ្រប់ពេលមុនកាលបរិច្ឆេទចុះបញ្ជី ការបញ្ចប់ ការលុបចោល និងដកការប្តេជ្ញាចិត្តក្នុងការធានាទិញមូលបត្រ ប្រសិនបើ៖

ក. មានការរំលោភបំពានដោយក្រុមហ៊ុននៅចំណុចណាមួយនៃការធានា កាតព្វកិច្ច ឬការទទួលខុសត្រូវដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង

ខ. ព័ត៌មានសំខាន់ដែលត្រូវបានដកយកដោយក្រុមហ៊ុន ពីក្រុមហ៊ុនធានាទិញមូលបត្រដែលតម្រូវឱ្យបង្ហាញស្របតាមកិច្ចព្រមព្រៀងដែលតាមគំនិតរបស់ក្រុមហ៊ុនធានាទិញមូលបត្រ ដែលមានការប៉ះពាល់ទៅនឹងព័ត៌មានសំខាន់ ឬប៉ះពាល់ដល់ជោគជ័យនៃការបោះផ្សាយជាសាធារណៈលើកដំបូង ឬការចែកចាយ ឬការលក់ភាគហ៊ុនរបស់ក្រុមហ៊ុនដែលស្របទៅតាមការបោះផ្សាយជាសាធារណៈលើកដំបូង។

គ. មានការលេចឡើង កើតឡើង ឬចូលជាធរមាននូវព្រឹត្តិការណ៍ ឬព្រឹត្តិការណ៍បន្តបន្ទាប់ដែលហួសពីការគ្រប់គ្រងដែលសមហេតុផលរបស់ក្រុមហ៊ុនធានាទិញមូលបត្រ និងដោយហេតុប្រធានសក្តិ (ដូចដែលបានកំណត់នៅខាងក្រោម) ដែលអាចមាន ឬអាចត្រូវបានរំពឹងថាមានការប៉ះពាល់អវិជ្ជមានដល់ព័ត៌មាន ឬទំនងជាមានប្រសិទ្ធិភាពដែលធ្វើឱ្យកាតព្វកិច្ចណាមួយដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះមិនអាចអនុវត្តបានសមស្របទៅតាមលក្ខខណ្ឌ។ “ប្រធានសក្តិ” មានន័យថាបុព្វហេតុដែលមិនអាចប៉ាន់ស្មានបាន និងលើសពីការគ្រប់គ្រងដែលភាគីបានប្រកាសថាជាប្រធានសក្តិដែលមិនអាចជៀសបាន ឬមិនអាចរារាំងបានដោយការមើលឃើញជាមុន ការរៀបចំគម្រោងផែនការ និងការអនុវត្តដែលមាន ប៉ុន្តែមិនកំណត់ត្រឹម៖

(១) សង្គ្រាម សកម្មភាពនៃសង្គ្រាម ការបំផ្លិចបំផ្លាញ អរិភាព ការឈ្លានពាន ការលុកលុយដោយកម្លាំងប្រដាប់អាវុធ សកម្មភាពអរិភាពនៃកងទ័ព ប្រទេសជាតិ ឬសត្រូវ សង្គ្រាមស៊ីវិល ឬភាពចលាចល ប្តន់ អរវកម្ម

(២) កុប្បកម្ម ការរើបឡើងប្រឆាំងនឹងរដ្ឋអំណាច ភាពវឹកវរស៊ីវិល ភាពច្របូកច្របល់ ឧទ្ទាមកម្ម ការរៀបចំប្រដាប់អាវុធប្រឆាំងនឹងរដ្ឋាភិបាល ការបះបោរ បដិវត្តន៍ យោធា ឬដណ្តើមអំណាច

(៣) គ្រោះមហន្តរាយធម្មជាតិ រួមទាំងប៉ុន្តែមិនកំណត់ចំពោះការរញ្ជួយដី ទឹកជំនន់ អគ្គិភ័យ ព្យុះ ព្យុះរន្ទះ ព្យុះសង្ឃរា ការផ្ទុះ គ្រោះថ្នាក់ ជំងឺរាតត្បាត ឬប្រធានសក្តិផ្សេងៗទៀត

ឃ. រាល់ការទាមទាររបស់រដ្ឋាភិបាល ឬការកើតឡើងផ្សេងៗនៃធម្មជាតិណាមួយដែលអាចមាន ឬទំនងជាមានការប៉ះពាល់អវិជ្ជមានដល់ព័ត៌មាន

ង. រាល់ការផ្លាស់ប្តូរអវិជ្ជមាននៃព័ត៌មានសំខាន់ក្នុងទីផ្សាររូបិយវត្ថុហិរញ្ញវត្ថុជាតិ ឬអន្តរជាតិ (រួមទាំងលក្ខខណ្ឌទីផ្សារភាគហ៊ុន និងអត្រាការប្រាក់) លក្ខខណ្ឌនយោបាយ ឬសេដ្ឋកិច្ច ការត្រួតពិនិត្យលើការដោះដូររូបិយវត្ថុ ឬអត្រាប្តូរប្រាក់ដែលតាមគំនិតរបស់ក្រុមហ៊ុនធានាទិញមូលបត្រអាចមាន ឬទំនងអាចជាមានផលប៉ះពាល់អវិជ្ជមានលើព័ត៌មាន ឬផលប៉ះពាល់អវិជ្ជមានលើព័ត៌មាន (មិនថានៅក្នុងទីផ្សារដំបូង ឬទាក់ទងនឹងការជួញដូរនៅទីផ្សារបន្ទាប់) លើតម្លៃ ឬតម្លៃភាគហ៊ុនរបស់ក្រុមហ៊ុន។

ច. ការជួញដូររបស់ក្រុមហ៊ុនមូលបត្រនៅក្នុងទីផ្សារមូលបត្រកម្ពុជាត្រូវបានពន្យា ឬទម្រង់ទូទៅត្រូវបានដាក់កំហិតក្នុងការជួញដូរ

ឆ. រាល់ច្បាប់ ឬបញ្ញត្តិថ្មី ឬមានវិសោធនកម្មទៅលើច្បាប់ បទបញ្ញត្តិ គោលការណ៍ណែនាំ គោលនយោបាយ ឬសេចក្តីសម្រេចនៅក្នុងដែនសមត្ថកិច្ចណាមួយដែលនៅក្នុងគំនិតរបស់ក្រុមហ៊ុនធានាទិញមូលបត្រអាចធ្វើបុរេនិវ្ថ័យចំពោះការចុះបញ្ជី ឬដែលអាចមាន ឬទំនងជាមានឥទ្ធិពលធ្វើឲ្យមិនអាចអនុវត្តបានដើម្បីអនុវត្តកិច្ចសន្យាទៅជាចំណែក និង/ឬផ្នែរភាគហ៊ុន ឬអនុវត្តកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងដែលមិនអាចអនុវត្តបានស្របទៅតាមលក្ខខណ្ឌ

ជ. ការដាក់ និង/ឬការផ្តល់ជូនជាសាធារណៈត្រូវបានបញ្ឈប់ឬពន្យាពេលដោយក្រុមហ៊ុនម្ចាស់ភាគហ៊ុនលក់ ឬអាជ្ញាធរដែលមានបទប្បញ្ញត្តិសម្រាប់ហេតុផលណាមួយ (លើកលែងតែការពន្យាពេលបែបនេះត្រូវបានយល់ព្រមដោយក្រុមហ៊ុនធានាទិញមូលបត្រ)

ឈ. ការចុះបញ្ជីមិនត្រូវធ្វើឡើងដោយកាលបរិច្ឆេទថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ឬកាលបរិច្ឆេទបន្តែមផ្សេងទៀតដែលអាចត្រូវបានយល់ស្របដោយក្រុមហ៊ុនធានាទិញមូលបត្រនោះទេ។

២. ការពិពណ៌នាអំពីសំណើច្មោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

ញ. រាល់ការចាប់ផ្តើមនៃនីតិវិធីច្បាប់ ឬសកម្មភាពណាមួយប្រឆាំងនឹងសមាជិកនៃសម្ព័ន្ធក្រុមហ៊ុន ឬអភិបាលណាមួយ ដែលមាននៅក្នុងគំនិតរបស់ក្រុមហ៊ុនធានាទិញមូលបត្រ អាចមាន ឬសមហេតុផលប៉ះពាល់ធំដុំ ឬនាំឱ្យមិនអាចអនុវត្តកិច្ចសន្យាដើម្បីបែងចែង និង/ឬការផ្ទេរភាគហ៊ុន

ញ. កិច្ចព្រមព្រៀងទិញត្រូវបានបញ្ចប់ ឬលុបចោលស្របទៅតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង។

២.២.៣. ផលប្រយោជន៍របស់ក្រុមហ៊ុនធានាទិញមូលបត្រ

ក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យួរីធី (ខេមបូឌា) ក្នុងតួនាទីជាទីប្រឹក្សា និងក្រុមហ៊ុនធានាទិញមូលបត្រសម្រាប់ការបោះផ្សាយលក់មូលបត្រ អះអាងថាមិនមានទំនាស់ផលប្រយោជន៍ណាមួយកើតឡើង ឬនឹងកើតឡើងពាក់ព័ន្ធនឹងតួនាទីរបស់ខ្លួនជាក្រុមហ៊ុនប្រមូលទិញសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងឡើយ។

ក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យួរីធី (ខេមបូឌា) និង/ឬ ក្រុមហ៊ុនពាក់ព័ន្ធរបស់ខ្លួន ("ក្រុមហ៊ុនសម្ព័ន្ធធនាគារ អ អេច ប៊ី") បង្កើតជាក្រុមហ៊ុនសម្ព័ន្ធហិរញ្ញវត្ថុចម្រុះមួយ និងអាចពង្រីកទំហំឥណទាន ឬធ្វើការទំនាក់ទំនងប្រតិបត្តិការធនាគារឯកជន ធនាគារពាណិជ្ជកម្ម និងធនាគារវិនិយោគរួមមាន ជាភ្នាក់ងារជើងសារ ជួញដូរមូលបត្រ គ្រប់គ្រងទ្រព្យ និងមូលនិធិ និងអាជីវកម្មសេវាកម្មជួញដូរឥណទានធ្វើឡើងជាធម្មតាជាមួយនឹងក្រុមហ៊ុនយើង និងបុគ្គលតំណាងរបស់ខ្លួន។ ក្រុមហ៊ុនណាមួយរបស់ក្រុមហ៊ុនសម្ព័ន្ធធនាគារ អ អេច ប៊ី អាចផ្តល់ឱ្យសេវាកម្មរបស់ខ្លួនសម្រាប់ ឬទំនាក់ទំនងក្នុងប្រតិបត្តិការនានា (លើផលប្រយោជន៍ផ្ទាល់ខ្លួន ឬផ្សេងពីនេះ) ជាមួយនឹងក្រុមហ៊ុនរបស់យើង និង/ឬក្រុមហ៊ុនពាក់ព័ន្ធមានតួនាទីរយៈពេលវែង ឬខ្លី និងអាចធ្វើការជួញដូរ ឬផ្សេងពីនេះ ប៉ះពាល់ដល់ប្រតិបត្តិការលើផលប្រយោជន៍ផ្ទាល់ខ្លួន ឬផ្សេងពីនេះរបស់អតិថិជនផ្សេងទៀតដែលកំពុងជាប់បំណុល ឬមូលបត្រកម្មសិទ្ធិ ឬឥណទានទំហំធំនៃក្រុមហ៊ុនរបស់យើង និង/ឬក្រុមហ៊ុនពាក់ព័ន្ធ។

ក្រុមហ៊ុនសម្ព័ន្ធធនាគារ អ អេច ប៊ី តាមរយៈ ធនាគារ អ អេច ប៊ី (ខេមបូឌា) នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧ បានផ្តល់ឥណទានវិបារូបចំនួន ៣,០០ លានដុល្លារអាមេរិក ទៅឱ្យក្រុមហ៊ុនផេសទិក (ខេមបូឌា) សម្រាប់គោលដៅដើមទុនការងារទូទៅ ("ចំនួនចំណាយលើសខ្នង់គណនី") ដែលចំនួនប្រមាណ ១,៩៩ លានដុល្លារអាមេរិក នៅមិនទាន់បានបង់គិតត្រឹមកាលបរិច្ឆេទថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០២០។

ក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យួរីធី (ខេមបូឌា) ដែលជាផ្នែកនៃក្រុមហ៊ុនសម្ព័ន្ធធនាគារ អ អេច ប៊ី បានបញ្ជាក់ថា ការផ្តល់ឥណទានខាងលើមិនអាចបង្ករជាទំនាស់ផលប្រយោជន៍ក្នុងតួនាទីខ្លួនជាក្រុមហ៊ុនធានាទិញពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងឡើយ ដោយហេតុថា:

២. ការពិពណ៌នាអំពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (គ)

(១) ចំនួនឥណទានសរុបមិនមានទំហំធំធេងឡើយបើប្រៀបជាមួយនឹងទ្រព្យសកម្មសុទ្ធ ប្រមាណ ២៥.៨ ពាន់លាន់ RM របស់ក្រុមហ៊ុនសម្ព័ន្ធធនាគារ អ អេច ប៊ី គិតត្រឹមកាលបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

(២) ឥណទានត្រូវបានផ្តល់ឱ្យដោយធនាគារ អ អេច ប៊ី (ខេមបូឌា) ក្នុងកិច្ចការអាជីវកម្មជាធម្មតា ហើយក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) មិនទទួលបានការប្រាក់ ឬផលប្រយោជន៍ណាមួយ សម្រាប់ផ្លៃឈ្នួលទទួលបានពាក់ព័ន្ធនឹងការតែងតាំងជាក្រុមហ៊ុនធានាទិញ ។

(៣) ក្រុមការងារទទួលខុសត្រូវលើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង របស់សម្ព័ន្ធធនាគារ អ អេច ប៊ី គឺឯករាជ្យពីក្រុមការងារដែលទទួលខុសត្រូវលើការងារឥណទាន

(៤) ហើយសកម្មភាពរបស់សម្ព័ន្ធធនាគារ អ អេច ប៊ី នៅក្នុងអាជីវកម្មធនាគាររបស់ខ្លួនត្រូវបានអនុឡោមតាមច្បាប់លើសេវាកម្មហិរញ្ញវត្ថុឆ្នាំ២០១៣ របស់ប្រទេសម៉ាឡេស៊ី និងការគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុងរបស់សម្ព័ន្ធធនាគារ អ អេច ប៊ី។

២.៣. ភាគរយនៃផាប់ប្លិកហ្ហ្ជូត (PUBLIC FLOATS) និងឡុកអាប់ (LOCK-UP)

ស្របទៅតាមប្រការ១៧ នៃប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ តារាងខាងក្រោមបញ្ជាក់ពីឡុកអាប់ និងភាគហ៊ុនហ្ហ្ជូតសេរីរបស់ក្រុមហ៊ុន៖

ប្រភេទភាគហ៊ុនិក		មុនពេលបោះផ្សាយ		ក្រោយពេលបោះផ្សាយ		រយៈពេលឡុកអាប់
		ចំនួនភាគហ៊ុន	%	ចំនួនភាគហ៊ុន	%	
ឡុកអាប់ (Lock-up)	ភាគហ៊ុនិកដែលកាន់កាប់ ភាគហ៊ុនធម្មតាច្រើនលើសលប់/ក្រុមហ៊ុន PIB	៧១.០០០.០០០	១០០%	៧១.០០០.០០០	៩៤,៧៤	មួយ (១) ឆ្នាំ ^
	សរុបបឋម	**៧១.០០០.០០០**	**១០០%**	**៧១.០០០.០០០**	**៩៤,៧៤**	
ហ្ហូតសេរី (Free Floats)	Masschinenfabrik Reinhausen	-	-	២.៦៣១.៥៧៩	៣,៥១	
	បុគ្គលិក/នាយក/សហការអាជីវកម្ម ដែលមានសិទ្ធិ	-	-	៦៥៧.៨៩៥	០,៨៨	
	វិនិយោគិនសាធារណៈ			៦៥៥.៥២៦	០,៨៧	

២. ការពិពណ៌នាអំពីសំណើរបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

សរុបបឋម	-	-	៣.៩៤៥.០០០	៥,២៦
សរុប	៧១.០០០.០០០	១០០%	៧៥.៩៤៥.០០០	១០០%

ចំណាំ៖

^ ស្របតាមប្រការ ១៧ នៃប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ក្រុមហ៊ុន PIB មានសិទ្ធិលក់ ឬផ្ទេរភាគហ៊ុនរបស់ខ្លួនក្នុងកម្រិតអតិបរិមាហាសិបភាគរយ (៥០%) សម្រាប់ប្រាំមួយ (៦) ខែបន្ទាប់ពីបោះផ្សាយ។

២.៤. ព័ត៌មានអំពីក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ

២.៤.១. ក្រុមហ៊ុនផ្តល់សេវាសវនកម្ម

ឈ្មោះក្រុមហ៊ុន	:	ប្រ្តេន សនថុន (ខេមបូឌា) លីមីធីត
អាសយដ្ឋាន	:	វិមានកាណាឌីយ៉ា ជាន់ទី២០ លេខ ៣១៥ វិថី ព្រះបាទអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ	:	www.grantthornton.com.kh
អ៊ីម៉ែល	:	info@kh.gt.com
លេខទូរស័ព្ទ	:	+៨៥៥ ២៣ ៩៦៦ ៥២០
លេខចុះបញ្ជីពាណិជ្ជកម្ម	:	០០០១៨៤១១
- ចេញដោយ	:	ក្រសួងពាណិជ្ជកម្ម
- កាលបរិច្ឆេទចុះបញ្ជី	:	ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១
លេខអាជ្ញាប័ណ្ណចេញដោយ គ.ម.ក	:	លេខ ០៦៥/១៧
- ចេញដោយ	:	គ.ម.ក
- កាលបរិច្ឆេទចេញ	:	ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧
លេខចុះបញ្ជីទទួលស្គាល់ដោយ គ.ម.ក	:	០០៦ គ.ម.ក./កស

២. ការពិពណ៌នាអំពីសំណើច្នោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

២.៤.២. សវនករឯករាជ្យ

ឈ្មោះសវនករឯករាជ្យ	:	Ronald Coronel Almera
អាសយដ្ឋាន	:	វិមានកាណាឌីយ៉ា ជាន់ទី ២០ លេខ ៣១៥ វិថី ព្រះបាទ អង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ. ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ	:	+៨៥៥ ២៣ ៩៦៦ ៥២០
អ៊ីម៉ែល	:	ronald.almera@kh.gt.com
លេខចុះបញ្ជីជាសមាជិកនៃ វ.គ.ស.ក (KICPAA)	:	លេខ ០០២០៨ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១
លេខចុះបញ្ជីទទួលស្គាល់ដោយ គ.ម.ក	:	០៣៨ គ.ម.ក./សឯ
កាលបរិច្ឆេទចុះបញ្ជី	:	ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥

២.៥. ព័ត៌មានអំពីមេធាវី

ឈ្មោះ	:	ការិយាល័យមេធាវី ភីវ៉ាយធី និង សហការី
អាសយដ្ឋាន	:	អគារ G មជ្ឈមណ្ឌលភ្នំពេញ ជាន់ទី០៥ បន្ទប់៥៨១ មហាវិថី សម្តេចសុធារស (៣) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
អ៊ីម៉ែល	:	potim@pyt.com.kh
លេខទូរស័ព្ទ	:	+៨៥៥ ៦៩ ៦៦២ ៨៨៨
លេខវិញ្ញាបនបត្រវិជ្ជាជីវៈ	:	LO២៧៤/១៥
- ចេញដោយ	:	គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- កាលបរិច្ឆេទ	:	ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២
លេខចុះបញ្ជីទទួលស្គាល់ដោយ គ.ម.ក	:	០០៨ គ.ម.ក./កម
- កាលបរិច្ឆេទ	:	ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩

២. ការពិពណ៌នាអំពីសំណើច្មោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

២.៦. ព័ត៌មានអំពីអ្នកស្រាវជ្រាវធីផ្សារឯកវាជ្យ

ឈ្មោះ	:	ក្រុមហ៊ុន Smith Zander International Sdn Bhd
អាសយដ្ឋាន	:	Suite 23-3, Level 23, Office Suite Menara 1MK, 1 Jalan Kiara Mont" Kiara, 50480 កូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី
អ៊ីម៉ែល	:	enquiries@smith-zander.com
លេខទូរស័ព្ទ	:	+៦០៣ ៦២១១ ២១២១

២.៧. ការចំណាយទាំងអស់ពាក់ព័ន្ធនឹងការច្មោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

សេចក្តីសង្ខេបអំពីការចំណាយ និងសោហ៊ុយទាំងអស់ពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ មានដូចខាងក្រោម៖

ការប៉ាន់ប្រមាណលើការចំណាយ	ចំណាំ	ដុល្លារអាមេរិក*	ពាន់រៀល
ចំណាយលើក្រុមហ៊ុនធានាទិញមូលបត្រ និងកម្រៃជើងសារ	១	២៥៩.៩៦៤	១.០៣៩.៨៥៦
ចំណាយលើការដាក់ជូន និងចុះបញ្ជីនៃឯកសារផ្តល់ព័ត៌មាន (ត.ម.ក)	២	៤.៥០០	១៨.០០០
ចំណាយលើការចុះបញ្ជី (ផ.ម.ក)	៣	១៦.៦៤៤	៦៦.៥៧៦
ចំណាយលើការបោះពុម្ព និងផ្សព្វផ្សាយ	៤	៣០.០០០	១២០.០០០
ចំណាយផ្នែកវិជ្ជាជីវៈ	៥	១៥២.៥០០	៦១០.០០០
ចំណាយផ្សេងៗ	៦	៤៣.១៥០	១៧២.៦០០
សរុប		**៥០៦.៧៥៨**	**២.០២៧.០៣២**

ចំណាំ៖

* *សម្រាប់គោលបំណងងាយស្រួលអាន ក្រុមហ៊ុនសន្មតអត្រាប្តូរប្រាក់ដូចខាងក្រោម៖*

- *១ ដុល្លារអាមេរិក ស្មើ ៤.០០០ រៀល*

១. ការចំណាយលើក្រុមហ៊ុនធានាទិញមូលបត្រ និងកម្រៃជើងសារ

ក្រុមហ៊ុនប៉ាន់ប្រមាណថា សោហ៊ុយ និងកម្រៃជើងសារដែលចំណាយលើក្រុមហ៊ុនធានាទិញមូលបត្រ មានប្រមាណ ២៥៩.៩៦៤ ដុល្លារអាមេរិក (១.០៤០ លានរៀល)។ សោហ៊ុយសរុបនឹងត្រូវកំណត់ដោយផ្អែកលើតម្លៃបោះផ្សាយមូលបត្រជាសាធារណៈ និងតម្លៃមូលបត្រកម្មសិទ្ធិចុងក្រោយ បន្ទាប់ពីទទួលបានសេចក្តីសម្រេចពី ត.ម.ក ទៅលើលក្ខខណ្ឌនៃការដាក់សំណើលក់របស់ក្រុមហ៊ុន។

២. ការចំណាយលើការដាក់ជូន និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

ក្រុមហ៊ុននឹងទូទាត់ការចំណាយចំនួន ១៨ លានរៀល (៤.៥០០ ដុល្លារអាមេរិក) សម្រាប់ការដាក់ជូន និងចុះបញ្ជីនូវឯកសារផ្តល់ព័ត៌មានទៅ គ.ម.ក។

៣. ការចំណាយលើការចុះបញ្ជី

ក្រុមហ៊ុននឹងទូទាត់ទៅ ធ.ម.ក នូវចំនួនទឹកប្រាក់ដូចខាងក្រោម៖

- ៤ លានរៀល (១.០០០ ដុល្លារអាមេរិក) សម្រាប់ការពិនិត្យមើលលើលទ្ធភាពអាចចុះបញ្ជី និង
- ប្រមាណ ៦២,៦ លានរៀល (១៥.៦៤៤ ដុល្លារអាមេរិក) សម្រាប់ការចំណាយលើការចុះបញ្ជីលើកដំបូង។ ចំនួនទឹកប្រាក់ជាក់ស្តែងនឹងត្រូវកំណត់បន្ទាប់ពីតម្លៃនៃការបោះផ្សាយលក់មូលបត្រត្រូវកំណត់រួចរាល់។

៤. ការចំណាយលើការបោះពុម្ព ផ្សព្វផ្សាយ ធ្វើដំណើរ និងបទបង្ហាញ៖

ក្រុមហ៊ុនប៉ាន់ប្រមាណថា ការចំណាយលើការបោះពុម្ពឯកសារផ្តល់ព័ត៌មាន និងទំរង់ពាក្យស្នើសុំមានចំនួនប្រមាណ ១០.០០០ ដុល្លារអាមេរិក (៤០ លានរៀល) ហើយចំណាយលើការផ្សព្វផ្សាយ ធ្វើដំណើរ និងបទបង្ហាញ នឹងមានចំនួនប្រមាណ ២០.០០០ ដុល្លារអាមេរិក (៨០ លានរៀល)។

៥. ការចំណាយផ្នែកវិជ្ជាជីវៈ

ការចំណាយផ្នែកវិជ្ជាជីវៈ រួមមានការចំណាយលើសេវាប្រឹក្សាផ្នែកច្បាប់ ចំណាយលើគណនេយ្យករចេញរបាយការណ៍គណនេយ្យ និងចំណាយលើការស្រាវជ្រាវទីផ្សារឯករាជ្យ។

៦. ការចំណាយផ្សេងៗ

ក្រុមហ៊ុនប៉ាន់ប្រមាណថា ការចំណាយផ្សេងៗ មានចំនួនប្រហែល ៤៣.១៥០ ដុល្លារអាមេរិក (១៧២,៦ លានរៀល) រួមបញ្ចូលទាំង៖

- ការចំណាយលើភ្នាក់ងារបញ្ជីកាមូលបត្រ៖ ១០.០០០ ដុល្លារអាមេរិក (៤០ លានរៀល)
- ការចំណាយលើការបកប្រែឯកសារផ្តល់ព័ត៌មាន៖ ៥.០០០ ដុល្លារអាមេរិក (២០ លានរៀល)
- ការចំណាយផ្សេងៗ និងការចំណាយនាពេលអនាគត៖ ២៨.១៥០ ដុល្លារអាមេរិក (១១២.៦ លានរៀល)

២. ការពិពណ៌នាអំពីសំណើច្នោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

២.៨. ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិដែលត្រូវច្នោះផ្សាយលក់

២.៨.១. ការពិពណ៌នាអំពីលក្ខខណ្ឌនានាអំពីមូលបត្រកម្មសិទ្ធិដែលត្រូវច្នោះផ្សាយលក់

ឈ្មោះមូលបត្រកម្មសិទ្ធិ	:	ភាគហ៊ុនធម្មតា
ប្រភេទមូលបត្រកម្មសិទ្ធិ	:	ភាគហ៊ុនធម្មតា
តម្លៃចារឹក	:	៤០០ រៀល (0,១0 ដុល្លារអាមេរិក)
តម្លៃបោះផ្សាយលក់	:	៣.១២0 រៀល (0,៧៦ ដុល្លារអាមេរិក)*
បរិមាណសរុបដែលដាក់ស្នើលក់	:	បោះផ្សាយជាសាធារណៈ ចំនួន ៣.៩៤៥.000 ភាគហ៊ុន
តម្លៃសរុបដែលដាក់ស្នើលក់	:	បោះផ្សាយជាសាធារណៈ ១២.៣0៨ លានរៀល (៣ លានដុល្លារអាមេរិក)
កាលបរិច្ឆេទចាប់ផ្តើមបរិវិសកម្ម	:	ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២0២0
កាលបរិច្ឆេទបញ្ចប់បរិវិសកម្ម	:	ថ្ងៃទី៤ ខែសីហា ឆ្នាំ២0២0

ចំណាំ៖

* *១ ដុល្លារអាមេរិក ស្មើ ៤.១0៨ រៀល យោងលើអត្រាប្តូរប្រាក់មធ្យមប្រចាំខែឧសភា ឆ្នាំ២0២0 របស់ធនាគារជាតិ នៃកម្ពុជា*

២.៨.២. ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិ

ក្រុមហ៊ុនមានប្រភេទភាគហ៊ុនតែមួយ (១) ប៉ុណ្ណោះ ដែលមានឈ្មោះថា ភាគហ៊ុនធម្មតា ក្នុងតម្លៃចារឹក ៤00 រៀល (0,១0 ដុល្លារអាមេរិក) ក្នុងមួយភាគហ៊ុន។ មូលបត្រកម្មសិទ្ធិបោះផ្សាយលក់ ត្រូវបានចាត់ថ្នាក់ស្មើនឹងភាគហ៊ុនបានបោះដែលមានស្រាប់របស់ក្រុមហ៊ុន ដែលរួមបញ្ចូល៖

- សិទ្ធិបោះឆ្នោត និងសិទ្ធិបញ្ចេញមតិរាល់ការប្រជុំភាគហ៊ុនិករបស់ក្រុមហ៊ុន
- សិទ្ធិផ្ទៀងផ្ទាត់ជាមួយបញ្ជីភាគហ៊ុនិក និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- សិទ្ធិទទួលបានទ្រព្យសម្បត្តិដែលនៅសល់របស់ក្រុមហ៊ុននៅពេលរំលាយក្រុមហ៊ុន និងសិទ្ធិលើការបែងចែក និងចែកចាយភាគលាភដែលអាចនឹងត្រូវប្រកាសទូទាត់ ឬធ្វើឡើងនៅកាលបរិច្ឆេទ ឬបន្ទាប់ពីកាលបរិច្ឆេទនៃការបែងចែក ឬការចែកចាយភាគលាភនោះ
- ភាគហ៊ុនិកនីមួយៗ ត្រូវមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាតរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង។

២. ការពិពណ៌នាអំពីសំណើរបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

២.ឆ. ការកំណត់ពីតម្លៃមូលបត្រកម្មសិទ្ធិដែលបោះផ្សាយលក់

មុនពេលបោះផ្សាយលក់មូលបត្រ ភាគហ៊ុនរបស់ក្រុមហ៊ុនមិនមាននៅលើទីផ្សារសាធារណៈឡើយ។ តម្លៃនៃការបោះផ្សាយលក់ ៣.១២០ រៀល (០,៧៦ ដុល្លារអាមេរិក) ក្នុងមួយភាគហ៊ុន ដែលត្រូវបានកំណត់និងព្រមព្រៀងដោយក្រុមប្រឹក្សាភិបាល និងក្រុមហ៊ុនធានាទិញមូលបត្រ បន្ទាប់ពីបានពិចារណាទៅលើកត្តានានាដូចខាងក្រោម។

២.ឆ.១ ព័ត៌មានអំពីប្រវត្តិហិរញ្ញវត្ថុរបស់ក្រុមហ៊ុន

ក្រុមហ៊ុនបានកត់ត្រាចំណូលប្រមាណ ៥៦,៨៣ លានដុល្លារអាមេរិក សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដែលតំណាងឱ្យការថយចុះចំនួន ២៦,៣% ពីចំនួន ៧៧,១៦ លានដុល្លារអាមេរិក សម្រាប់ឆ្នាំដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ចំណេញដុលរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ មានចំនួន ៧,១ លានដុល្លារអាមេរិក តំណាងឱ្យការថយចុះ ៥០,០% ពីដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ដែលមានចំនួន ១៤,១៩ លានដុល្លារអាមេរិក។

បន្ថែមពីនេះទៀត សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនយើងមានកំណត់ត្រាចំណេញក្នុងគ្រាចំនួនប្រហែល ១,៧៨ លានដុល្លារអាមេរិក តំណាងឱ្យការថយចុះចំនួន ៧៦,៦% លើដំណាច់ការិយបរិច្ឆេទឆ្នាំ២០១៨ ដែលមានចំនួន ៧,៥៨ លានដុល្លារអាមេរិក។

ព័ត៌មានបន្ថែមស្តីអំពីប្រវត្តិហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានរៀបរាប់នៅផ្នែកទី៧ នៃឯកសារផ្តល់ព័ត៌មាននេះ។

ផ្អែកតាមដើមទុនពង្រីកបោះផ្សាយនិងបង់រួចរាល់ បន្ទាប់ពីចុះបញ្ជីភាគហ៊ុនចំនួន ៧៤.៩៤៥.000 ចំណេញសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុន (pro forma net EPS) សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ មានចំនួន ០,០២៤ ដុល្លារអាមេរិក។

២.ឆ.២ ទ្រព្យសកម្មសុទ្ធរួមរបស់ក្រុមហ៊ុន

បន្ទាប់ពីមានការកែតម្រូវចេញពីចំណូលប្រាក់ ដែលបានមកពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ និងការប៉ាន់ប្រមាណទៅលើចំណាយលើការបោះផ្សាយលក់មូលបត្រ និងការរៀបចំផ្នែកក្នុងឡើងវិញ ទ្រព្យសកម្មសុទ្ធរួមក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុន (NA per Share) គិតត្រឹមការិយបរិបច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ (ផ្អែកលើដើមទុនពង្រីកដែលបានបោះផ្សាយ និងបង់រួចរាល់បន្ទាប់ពីចុះបញ្ជីភាគហ៊ុនចំនួន ៧៤.៩៤៥.000 ភាគហ៊ុន) នឹងមានតម្លៃ ០,២២ ដុល្លារអាមេរិក។

២. ការពិពណ៌នាអំពីសំណើច្នោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

ព័ត៌មានបន្ថែមស្តីអំពីទ្រព្យសកម្មសុទ្ធរួមរបស់ក្រុមហ៊ុនមានរៀបរាប់នៅផ្នែកទី ២.១០ នៃឯកសារផ្តល់ព័ត៌មាននេះ។

២.៩.៣. ប្រវត្តិប្រតិបត្តិការរបស់ក្រុមហ៊ុន

ប្រវត្តិប្រតិបត្តិការរបស់ក្រុមហ៊ុន និងប្រភេទធុរកិច្ចរបស់ក្រុមហ៊ុនមានរៀបរាប់នៅផ្នែកទី ៤ នៃឯកសារផ្តល់ព័ត៌មាននេះ។

២.៩.៤. ការរំពឹងទុក និងផែនការអនាគតរបស់ក្រុមហ៊ុន

ការរំពឹងទុកពីអនាគតក្នុងឧស្សាហកម្មដែលក្រុមហ៊ុនកំពុងដំណើរការ ផែនការយុទ្ធសាស្ត្រអនាគត និងការរំពឹងទុកនានា ដូចដែលមានពណ៌នានៅផ្នែកទី ៥.១.៧ នៃឯកសារផ្តល់ព័ត៌មាននេះ។

២.៩.៥. ស្ថានភាពទីផ្សារបច្ចុប្បន្ន

ស្ថានភាពទីផ្សារបច្ចុប្បន្ន រាប់ញ្ចូលទាំងនិន្នាការទីផ្សារបច្ចុប្បន្ន និងចេតនារបស់វិនិយោគិន។ លោកអ្នកគួរយល់ដឹងថា តម្លៃទីផ្សារនៃភាគហ៊ុនរបស់ក្រុមហ៊ុន បន្ទាប់ពីការចុះបញ្ជីនៅក្នុងទីផ្សារគោលរបស់ ផ.ម.ក គឺជាកម្មវត្ថុទៅនឹងកំលាំងចលករទីផ្សារ និងភាពមិនច្បាស់លាស់ផ្សេងៗ ដែលអាចប៉ះពាល់ដល់តម្លៃភាគហ៊ុនដែលចរាចរលក់នៅលើទីផ្សារ។ មុនពេលសម្រេចចិត្តវិនិយោគ លោកអ្នកគួរពិចារណាលើ កត្តាផ្សេងៗដែលមានរៀបរាប់ក្នុងឯកសារផ្តល់ពត៌មាននេះ រួមជាមួយនឹងកត្តាហានិភ័យ ដែលមានរៀបរាប់នៅផ្នែកទី ៣ នៃឯកសារផ្តល់ព័ត៌មាននេះ។

២. ការពិពណ៌នាអំពីសំណើច្នោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

២.១០. ទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (NET ASSETS PER SHARE) ប្រាក់ចំណេញក្នុងក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (EARNINGS PER SHARE) អនុបាតតម្លៃ (P/E RATIO OR PRICE EARINGS MULTIPLE PER SHARE) និងចំនួនផលតាតលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (YIELD PER SHARE)

របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ	៣០ មិថុនា ២០១៩ ពាន់ដុល្លារអាមេរិក
ទ្រព្យសកម្ម	
ទ្រព្យសកម្មរយៈពេលវែង	
ទ្រព្យសម្បត្តិ អាងចក្រ និងបរិក្ខារ	២.២៤៧
ទ្រព្យសកម្មអរូបីយ	៣
ទ្រព្យសកម្មកិច្ចសន្យា	១៧៣.០៥៩
ទ្រព្យសកម្មរយៈពេលវែងសរុប	១៧៥.៣០៩
ទ្រព្យសកម្មរយៈពេលខ្លី	
គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ	១០.៨០៤
ទ្រព្យសកម្មកិច្ចសន្យា	៦.០៤២
ទឹកប្រាក់ដែលភាគីសម្ព័ន្ធញាតិជំពាក់	១.៩៤៤
សាច់ប្រាក់ និងសមតុល្យធនាគារ	១៣.០៥៦
ទ្រព្យសកម្មរយៈពេលខ្លីសរុប	៣១.៨៤៦
ទ្រព្យសកម្មសរុប (ក)	**២០៧.១៥៥**
មូលធន និងបំណុល	
មូលធន	
ដើមទុន	៧.១០០
ដើមទុនបម្រុងទុក	(១.៧៧២)
ចំណេញរក្សារទុក	៨.៥៩៥
មូលធនសរុប	**១៣.៩២៣**
បំណុលរយៈពេលវែង	
ប្រាក់កម្ចី	៩៥.៤០៧
ឧបករណ៍និស្សន្ទ	១.៨២៤
បំណុលរយៈពេលវែងសរុប	**៩៧.២៣១**

២. ការពិពណ៌នាអំពីសំណើច្មោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ	៣០ មិថុនា ២០១៩ ពាន់ដុល្លារអាមេរិក
បំណុលរយៈពេលខ្លី	
គណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងៗ	៨.៣១៧
ទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុនមេ	៥៩.៥៥៨
ទឹកប្រាក់ដែលជំពាក់សម្ព័ន្ធញាតិ	២៣.០១៨
ប្រាក់កម្ចី	៤.១៨០
ចំណូលពន្ធលើប្រាក់ចំណូលត្រូវបង់	៩២៨
បំណុលរយៈពេលខ្លីសរុប	**៩៦.០០១**
បំណុលសរុប (ខ)	**១៩៣.២៣២**
មូលធន និងបំណុលសរុប	**២០៧.១៥៥**
ដើមទុនដែលបានបង្កើត និងបង់រួចរាល់មុនពេលបោះផ្សាយមូលបត្រ (គ) ('000)	៧១.០០០
ទ្រព្យសកម្មសុទ្ធ (ក-ខ)	១៣.៩២៣
ទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ក-ខ)/(គ)	០,២០
ដើមទុនដែលបានបង្កើត និងបង់រួចរាល់ក្រោយពេលបោះផ្សាយមូលបត្រ (ឃ) ('000)	៧៤.៩៤៥
ទ្រព្យសកម្មសុទ្ធកែតម្រូវសម្រាប់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការចំណាយទៅលើការបោះផ្សាយ (ង)	១៦.៤១៤
ទ្រព្យសកម្មសុទ្ធ ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ Pro forma (ង/ឃ)	០,២២

២.១០.១. ទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ

ទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ មានតម្លៃ ០,២០ ដុល្លារអាមេរិក ផ្អែកលើដើមទុនដែលបានបង្កើត និងបង់រួចរាល់ចំនួន ៧១.០០០.០០០ ភាគហ៊ុន មុនពេលកែតម្រូវសម្រាប់ការបោះផ្សាយមូលបត្រ។

បន្ទាប់ពីមានការរៀបចំផ្នែកក្នុងឡើងវិញ ការបោះផ្សាយភាគហ៊ុនថ្មីចំនួន ៣.៩៤៥.០០០ ភាគហ៊ុន តាមរយៈការបោះផ្សាយជាសាធារណៈទទួលបានជោគជ័យ និងបន្ទាប់ពីការកែតម្រូវសម្រាប់ការចំណាយលើការបោះផ្សាយភាគហ៊ុន ទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមូលបត្រកម្មសិទ្ធរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ (ផ្អែកលើដើមទុនដែលបានបង្កើត និងបង់រួចរាល់ចំនួន ៧៤.៩៤៥.០០០ ភាគហ៊ុន) នឹងមានតម្លៃ ០,២២ ដុល្លារអាមេរិក។

២.១០.២. ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ

	ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ពាន់ដុល្លារអាមេរិក
ចំណេញក្នុងឆ្នាំ (ក)	១.៧៧៥
ភាគលាភដែលបែងចែក (ខ)	-
(១) = (ក) – (ខ)	១.៧៧៥
ដើមទុនដែលបានបង្កើត និងបង់រួចរាល់ក្រោយពេលបោះផ្សាយមូលបត្រ ('000) (២)	៧៤.៩៤៥
ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ដុល្លារអាមេរិក) (១)/(២)	០,០២៤

២.១០.៣. អនុបាតតម្លៃ (P/E Ratio)

	ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដុល្លារអាមេរិក
តម្លៃបោះផ្សាយលក់ (១)	០,៧៦
ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (២)	០.០២៤
អនុបាតភីអ៊ី (P/E Ratio) (១)/(២)	៣១,៦៧

២.១០.៤. ទិន្នផលភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ

	ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដុល្លារអាមេរិក
ភាគលាភប្រចាំឆ្នាំមួយឯកតាមូលបត្រកម្មសិទ្ធិ (១)	*-
តម្លៃបោះផ្សាយលក់ (២)	០,៧៦
ទិន្នផលភាគលាភ (១)/(២)	**មិនមាន**

ចំណាំ៖

* *ក្រុមហ៊ុនមិនបានប្រកាសអំពីការបែងចែកភាគលាភសម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩*

២. ការពិពណ៌នាអំពីសំណើច្នោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

២.១១. ផែនការបែងចែកមូលបត្រកម្មសិទ្ធិ

ការបោះផ្សាយជាសាធារណៈនូវភាគហ៊ុនរបស់ក្រុមហ៊ុនសរុបចំនួន ៣.៩៤៥.០០០ តំណាងឱ្យ ៥,២៥% នៃ ដើមទុនដែលបានបង្កើត និងបង់រួចរាល់ ដែលរួមមានភាគហ៊ុនចំនួន ៣.៩៤៥.០០០ ជាភាគហ៊ុនថ្មី នៅតម្លៃ បោះផ្សាយ ៣.១២០ រៀល (០,៧៦ ដុល្លារអាមេរិក) ក្នុងមួយឯកតាភាគហ៊ុនបោះផ្សាយលក់ ត្រូវបង់ ទាំងស្រុងអំឡុងពេលដាក់ពាក្យ ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌនៃឯកសារផ្តល់ព័ត៌មាននេះ និងបន្ទាប់ពីទទួល បានជោគជ័យ នឹងត្រូវធ្វើការបែងចែកតាមទម្រង់ដូចខាងក្រោម៖

	ការបែងចែក	
ក្រុមវិនិយោគិន	**ភាគហ៊ុន**	**ភាគរយ (%)**
Maschinenfabrik Reinhausen [i]	២.៦៣១.៥៧៩	៦៦,៧
អភិបាល និយោជិត និងសហការអាជីវកម្ម ដែលមានសិទ្ធិ ឬបុគ្គលដែលបានរួមចំណែកធ្វើឱ្យក្រុមហ៊ុនទទួលបានភាពជោគជ័យ [ii]	៦៥៧.៨៩៥	១៦,៧
និងវិនិយោគិនដែលទទួលបានជោគជ័យក្នុងបរិវិសកម្ម [ii]	៦៥៥.៥២៦	១៦,៦
សរុប	**៣.៩៤៥.០០០**	**១០០,០**

ចំណាំ៖

(i) Maschinenfabrik Reinhausen ជាក្រុមហ៊ុននៅប្រទេសអាល្លឺម៉ង ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អេឡិចត្រូនិក ព្រមទាំងគ្រឿងបង្គុំ. អាជីវកម្មចម្បងរបស់ក្រុមហ៊ុនគឺគ្រប់គ្រង់បណ្តាញចែកចាយអគ្គីសនី។

(ii) ការបែងចែកភាគហ៊ុនជូនវិនិយោគិនសាធារណៈ: និយោជិត អភិបាល និងសហការអាជីវកម្ម ដែលមានសិទ្ធិ ឬបុគ្គលដែលបានរួមចំណែកធ្វើឱ្យក្រុមហ៊ុនទទួលបានភាពជោគជ័យនោះ អាចខុសពីការបែងចែកខាងលើ និងជាកម្មវត្ថុនៃលទ្ធផលចេញពីការធ្វើបរិវិសកម្ម។ ប្រសិនបើភាគហ៊ុនបោះផ្សាយដែលបានបម្រុងទុកសម្រាប់ និយោជិត អភិបាល និងសហការអាជីវកម្ម ដែលមានសិទ្ធិ ឬបុគ្គលដែលបានរួមចំណែកធ្វើឱ្យក្រុមហ៊ុនទទួលបានភាពជោគជ័យនោះ មិនត្រូវបានធ្វើបរិវិសកម្មអស់ ភាគហ៊ុនដែលនៅសល់អាចនឹងត្រូវបានបែងចែកទៅឱ្យវិនិយោគិនសាធារណៈ។ ផ្ទុយមកវិញ ប្រសិនបើភាគហ៊ុនបោះផ្សាយដែលបានបម្រុងទុកសម្រាប់ វិនិយោគិនសាធារណៈ មិនត្រូវបានធ្វើបរិវិសកម្មអស់ ភាគហ៊ុនដែលនៅសល់អាចនឹងត្រូវបានបែងចែកទៅឱ្យនិយោជិត អភិបាល និងសហការអាជីវកម្ម ដែលមានសិទ្ធិ ឬបុគ្គលដែលបានរួមចំណែកធ្វើឱ្យក្រុមហ៊ុនទទួលបានភាពជោគជ័យនោះ។ ក្នុងករណីការធ្វើបរិវិសកម្មមានតម្រូវការលើសលុបសម្រាប់ចំណែកដែលលើបម្រុងទុកសម្រាប់វិនិយោគិនសាធារណៈស្របពេលភាគហ៊ុនដែលបានបែងចែកទៅឱ្យ និយោជិត អភិបាល និងសហការអាជីវកម្ម ដែលមានសិទ្ធិ ឬបុគ្គលដែលបានរួមចំណែកធ្វើឱ្យក្រុមហ៊ុនទទួលបានភាពជោគជ័យនោះ ត្រូវបានធ្វើបរិវិសកម្មអស់នោះ ភាគហ៊ុនដែលលើបម្រុងទុកសម្រាប់វិនិយោគិនសាធារណៈ នឹងត្រូវបានបែងចែកតាមមូលដ្ឋានសមាមាត្រ។ ប្រសិនបើបន្ទាប់ពីមានការបែងចែកសារជាថ្មី ភាគហ៊ុនដែលត្រូវបានបម្រុងទុកសម្រាប់ និយោជិត អភិបាល និងសហការអាជីវកម្មដែលមានសិទ្ធិ ឬបុគ្គលដែលបានរួមចំណែកធ្វើឱ្យក្រុមហ៊ុនទទួលបានភាពជោគជ័យនោះ និងវិនិយោគិនសាធារណៈ មិនត្រូវបានធ្វើបរិវិសកម្មអស់ នោះភាគហ៊ុនដែលនៅសល់នឹងមិនត្រូវបានបោះផ្សាយទេ។

២. ការពិពណ៌នាអំពីសំណើផ្តោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

២.១២ ការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការផ្តោះផ្សាយលក់មូលបត្រជាសាធារណៈ

ក្រុមហ៊ុនរំពឹងថា សាច់ប្រាក់ដុលដែលបានមកពីការបោះផ្សាយមូលបត្រជាសាធារណៈ មានប្រមាណ ៣,០០ លានដុល្លារអាមេរិក ឬ ១២.៣០៨ លានរៀល ដោយផ្អែកលើតម្លៃនៃការបោះផ្សាយមូលបត្រជាសាធារណៈ ៣.១២០ រៀល (០,៧៦ ដុល្លារអាមេរិក) ក្នុងមួយភាគហ៊ុន។ ក្រុមហ៊ុនត្រូវទទួលបានសាច់ប្រាក់នោះ ហើយត្រូវទទួលខុសត្រូវលើការចំណាយទាំងអស់ពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

ក្រុមហ៊ុនមានបំណងប្រើប្រាស់សាច់ប្រាក់ដុលតាមការបែងចែកខាងក្រោម៖

ល.រ	ព័ត៌មានលម្អិតអំពីការប្រើប្រាស់	រយៈពេលរំពឹងទុកសម្រាប់ការប្រើប្រាស់បន្ទាប់ពីការចុះបញ្ជី	ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក	ភាគរយនៃសាច់ប្រាក់ដុល (%)
១.	ហិរញ្ញប្បទានគម្រោងមានស្រាប់និងអនាគតរបស់ក្រុមហ៊ុន	ក្នុងរយៈពេល ១២ ខែ	២.០០០	៦៦,៧
២.	ទុនបង្វិល	ក្នុងរយៈពេល ១២ ខែ	៤៩១	១៦,៤
៣.	ការប៉ាន់ប្រមាណចំណាយលើការបោះផ្សាយ	ក្នុងរយៈពេល ៣ ខែ	៥០៧	១៦,៩
	សាច់ប្រាក់ដុលសរុប		**២.៩៩៨**	**១០០,០**

១. ហិរញ្ញប្បទានគម្រោងនាពេលអនាគត

ក្រុមហ៊ុនមានបំណងបែងចែកសាច់ប្រាក់ប្រមាណ ២,០០ លានដុល្លារអាមេរិក ពីសាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយមូលបត្រជាសាធារណៈ សម្រាប់ចំណាយទៅលើគម្រោងនាពេលអនាគត ដែលរួមបញ្ចូលទាំងការងារបឋមរបស់គម្រោងដូចជា ការគូសបង្គង់អនុស្ថានីយ៍ និងខ្សែបណ្តាញបញ្ជូន ការទិញសម្ភារៈនិងគ្រឿងបរិក្ខារ ការងារសាងសង់និងតម្លើង ក៏ដូចជាថ្លៃសេវាកម្លាំងពលកម្មផងដែរ។ បច្ចុប្បន្នក្រុមហ៊ុនកំពុងដេញថ្លៃគម្រោងពាក់ព័ន្ធនឹងការដាក់បង្កប់ខ្សែកាបក្រោមដីដែលមានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង អនុស្ថានីយ៍ដែលមានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង និងខ្សែបណ្តាញបញ្ជូន ប៉ុន្តែលទ្ធផលមិនទាន់ទទួលបានការសម្រេចពីអតិថិជននៅឡើយ។ រាល់មូលនិធិដែលនៅសល់ពីការប្រើប្រាស់សម្រាប់ហិរញ្ញប្បទានសម្រាប់គម្រោងនាពេលអនាគតនឹងត្រូវយកមកប្រើប្រាស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការទុនបង្វិលរបស់ក្រុមហ៊ុនយើង។

ផ្ទុយមកវិញ ប្រសិនបើការបែងចែកសាច់ប្រាក់ដែលបានមកពីការបោះផ្សាយមូលបត្រសាធារណៈ

២. ការពិភាក្សាអំពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ (ត)

មិនគ្រប់គ្រាន់ សម្រាប់ហិរញ្ញប្បទានគម្រោងនាពេលអនាគត ការខ្វះខាតនោះនឹងត្រូវបង្គ្រប់ដោយមូលនិធិផ្ទៃក្នុង ទុនបង្វិល ឥណទានពីអ្នកផ្គត់ផ្គង់ និង/ឬ កម្ចី/ហិរញ្ញប្បទាន។

ក្រុមហ៊ុននឹងបន្តស្វែងរកមូលនិធិពីស្ថាប័នហិរញ្ញវត្ថុនានា ដើម្បីទ្រទ្រង់ការវិនិយោគនៅក្នុងគម្រោងរបស់ខ្លួន។

២. ទុនបង្វិល

ក្រុមហ៊ុនបានកំណត់ទុកសាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយមូលបត្រជាសាធារណៈ ប្រមាណ ០,៤៩ លានដុល្លារអាមេរិក ដើម្បីប្រើប្រាស់ទៅលើប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន ដែលរួមមានជាអាទិ៍ ការចំណាយលើបុគ្គលិក និងការថែទាំយានយន្ត និងធ្វើឱ្យប្រសើរឡើងនៃសម្ភារៈការិយាល័យ និងប្រព័ន្ធព័ត៌មានវិទ្យា ដូចមានរៀបរាប់ខាងក្រោម៖

- ពង្រីកកម្លាំងពលកម្មដើម្បីឆ្លើយតបនឹងការរីកចម្រើនអាជីវកម្មរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនរំពឹងថានឹងពង្រីកកម្លាំងពលកម្មរបស់ខ្លួន រួមមាន និយោជិតធ្វើការជាប់លាប់ពី ៥៩ នាក់ ទៅ ៦៤ នាក់ និងនិយោជិតតាមកិច្ចសន្យាពី៤៣ នាក់ ទៅ ៥៣ នាក់ ដែលភាគច្រើននឹងធ្វើការពាក់ព័ន្ធនឹងគម្រោងក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត
- ការចំណាយលើការថែទាំ ចំណាយលើផ្ទៃសាំងនិងប្រេងម៉ាស៊ូត ដើម្បីប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ និង
- ធ្វើឱ្យប្រសើរឡើងនូវសម្ភារៈប្រើប្រាស់ក្នុងការិយាល័យ និងប្រព័ន្ធព័ត៌មានវិទ្យា ដែលរួមមានទាំងការចំណាយលើការថែទាំ និងគ្រប់គ្រង។

៣. ការប៉ាន់ប្រមាណចំណាយក្នុងការបោះផ្សាយមូលបត្រជាសាធារណៈលើកដំបូង

ការប៉ាន់ប្រមាណលើចំណាយក្នុងការបោះផ្សាយប្រមាណ ០,៥១ លានដុល្លារអាមេរិក ត្រូវបានរៀបរាប់នៅផ្នែកទី ២.៧ នៃឯកសារផ្តល់ព័ត៌មាននេះ។

ប្រសិនបើការចំណាយជាក់ស្តែងខ្ពស់ជាការប៉ាន់ស្មាន ចំនួនដែលខ្វះនឹងត្រូវផ្តល់ជូនតាមរយៈទុនបង្វិល។ ផ្ទុយមកវិញ ប្រសិនបើការចំណាយជាក់ស្តែងទាបជាងការប៉ាន់ស្មាន ចំនួនដែលលើសនឹងត្រូវយកមកប្រើប្រាស់សម្រាប់តម្រូវការទុនបង្វិលរបស់ក្រុមហ៊ុនវិញ។

២. ការពិពណ៌នាអំពីសំណើច្មោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ: (ត)

ក្រុមហ៊ុនគ្រោងនឹងយកសាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយមូលបត្រជាសាធារណៈ ឬសមតុល្យទឹកប្រាក់របស់ក្រុមហ៊ុន ដែលមានក្នុងនោះ ដាក់បញ្ចើនៅធនាគារ ឬស្ថាប័នហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ក្នុងទម្រង់ជាមូលនិធិ/ឧបករណ៍ ដែលអាចជួញដូរបានដែលមានការប្រាក់ មុនពេលយកមកប្រើប្រាស់សម្រាប់គោលបំណងដែលមានបង្ហាញខាងលើ។

២.១៣ គម្រោងវនិយោគ

មិនមាន។

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា

៣. កត្តាហានិភ័យ

ការវិនិយោគលើមូលបត្រកម្មសិទ្ធិ គឺជាការវិនិយោគដែលមានហានិភ័យខ្ពស់។ លោកអ្នកគួរពិចារណា ដោយយកចិត្តទុកដាក់រាល់ព័ត៌មានទាំងអស់នៅក្នុងឯកសារផ្តល់ព័ត៌មាននេះ ហើយជាពិសេសអាល់ហានិភ័យ ដូចមានបញ្ជាក់ក្នុងផ្នែកនេះ មុននឹងធ្វើការវិនិយោគលើភាគហ៊ុនរបស់ក្រុមហ៊ុន។ លោកអ្នកគួរស្វែងរកការប្រឹក្សាយោបល់ដោយត្រឹមត្រូវពីភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ឬពីក្រុមហ៊ុនទីប្រឹក្សាវិនិយោគដែលមានអាជ្ញាបណ្ណ។

លោកអ្នក គប្បីអានផ្នែកដែលមានចំណងជើងថា "ផ្នែកទី៣ កត្តាហានិភ័យ" និងផ្នែកបន្តបន្ទាប់ទៀតដូចជា "ផ្នែកទី៤ ព័ត៌មានរបស់ក្រុមហ៊ុន" និង "ផ្នែកទី៧ ព័ត៌មានហិរញ្ញវត្ថុ" រួមជាមួយនឹងព័ត៌មានហិរញ្ញវត្ថុ និងស្ថិតិទាំងអស់ ដែលមានក្នុងឯកសារផ្តល់ព័ត៌មាននេះ។

ប្រសិនបើមានហានិភ័យណាមួយដូចខាងក្រោមកើតឡើង ក្រុមហ៊ុនអាចនឹងជួបផលប៉ះពាល់ធ្ងន់ធ្ងរលើស្ថានភាពអាជីវកម្ម ឬហិរញ្ញវត្ថុ ដែលអាចធ្វើឱ្យមានការធ្លាក់ចុះតម្លៃភាគហ៊ុនរបស់ក្រុមហ៊ុន ហើយលោកអ្នកអាចខាតបង់ការវិនិយោគរបស់លោកអ្នកមួយផ្នែក ឬទាំងអស់។

ហានិភ័យដែលបានរៀបរាប់នៅក្នុងផ្នែកនេះ មិនមែនជាហានិភ័យទាំងអស់ ដែលក្រុមហ៊ុនកំពុងជួបប្រទះ ឬអាចនឹងកើតឡើងក្នុងពេលអនាគតឡើយ។ អាជីវកម្មរបស់ក្រុមហ៊ុនក៏អាចទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរ ដោយសារកត្តាផ្សេងៗទៀត ដែលក្រុមហ៊ុនមិនបានដឹងក្នុងពេលនេះ ឬមិនគិតថាវាជាឧបសគ្គធ្ងន់ធ្ងរចំពោះអាជីវកម្មរបស់ក្រុមហ៊ុន។ លុះត្រាតែមានការបញ្ជាក់ក្នុងកត្តាហានិភ័យដូចបានរៀបរាប់នៅក្នុងផ្នែកនេះ ក្រុមហ៊ុនមិនមានកាតព្វកិច្ចរៀបរាប់ ឬបញ្ជាក់បន្ថែមលើ ភាពជាក់លាក់នៃផលប៉ះពាល់ដែលកើតចេញពីហានិភ័យដូចបានរៀបរាប់ខាងលើនោះទេ។

សូមបញ្ជាក់ថា អវត្តមាននៃការពណ៌នា និង/ឬការបញ្ជៀសហានិភ័យ ពាក់ព័ន្ធនឹងកត្តាហានិភ័យណាមួយ មិនមែនជាការមើលរំលងនោះទេ។ ការបញ្ជៀសហានិភ័យមិនអាចធ្វើទៅបាន ឬមិនមានវិធានការណាមួយត្រូវបានអនុវត្តដើម្បីបញ្ជៀសហានិភ័យឡើយពាក់ព័ន្ធនឹងកត្តាហានិភ័យនានាដូចខាងក្រោម។

៣. កត្តាហានិភ័យ (ត)

៣.១. ហានិភ័យលើអត្រាការប្រាក់

៣.១.១. ចលនាឡើងចុះនៃអត្រាការប្រាក់

ក. ការវិភាគ

ហានិភ័យលើអត្រាការប្រាក់ សំដៅលើហានិភ័យកើតចេញពីចលនាឡើងចុះនៃអត្រាការប្រាក់នាពេលអនាគត ដែលអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ចំណាយ និងចំណូលរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនមានលទ្ធភាពក្នុងការពង្រីកប្រត្តិបត្តិការអាជីវកម្ម គឺត្រូវពឹងផ្អែកទៅលើលទ្ធភាពក្នុងការទទួលហិរញ្ញប្បទានគ្រប់គ្រាន់ ដែលបានមកពីកម្ចីពីខាងក្រៅ ឬការបន្តែមដើមទុន ឬបានមកពីសាច់ប្រាក់ដែលបានមកពីអាជីវកម្មផ្ទៃក្នុងជាដើម។

គិតត្រឹមដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនជាប់បំណុលចំនួន ៩៩.៦ លានដុល្លាអាមេរិក ដែលរួមមាន ឥណទានវិបារូប ឥណទានទុនបង្វិល Murabahah facilities និង syndicated financing facilitating។ ការកើនឡើងនៃប្រាក់កម្ចី និង/ឬ ការកើនឡើងដោយមិនបានរំពឹងទុកនូវអត្រាការប្រាក់ ជាលទ្ធផលនឹងមានការកើនឡើងនូវចំណាយការប្រាក់ ដែលអាចនឹងមានផលប៉ះពាល់លើចំណូលរបស់ក្រុមហ៊ុន និងកាតព្វកិច្ចទៅលើការសងបំណុលត្រលប់ទៅវិញរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនក៏អាចប្រឈមផងដែរទៅនឹងហានិភ័យលើអត្រាការប្រាក់ សម្រាប់ចំណូលជាការប្រាក់ដែលបានមកពីការដាក់ប្រាក់បញ្ញើរយៈពេលខ្លី។ ការទម្លាក់អត្រាការប្រាក់ អាចធ្វើឱ្យប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

តារាងខាងក្រោមបង្ហាញពីភាពប្រែប្រួលនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនទៅនឹងការផ្លាស់ប្តូរប្រាក់ចំណេញសមហេតុផលក្នុងអត្រាការប្រាក់ ±0,២៥%

ពាន់ដុល្លារអាមេរិក	+0,២៥%	-0,២៥%
គិតត្រឹមដំណាច់ការិយបរិច្ឆេទ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	(២៤៨)	២៤៨
គិតត្រឹមដំណាច់ការិយបរិច្ឆេទ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨	(៥៥)	៥៥

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

ទោះបីមិនមានផលប៉ះពាល់ធ្ងន់ធ្ងរណាមួយកើតឡើងដោយចលនាឡើងចុះនៃអត្រាការប្រាក់នៅក្នុងប្រវត្តិប្រាក់ចំណេញរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ មិនមានការធានាថាក្រុមហ៊ុននឹងមិនត្រូវបានប៉ះពាល់ដោយការចលនាឡើងចុះនៃអត្រាការប្រាក់នាពេលអនាគតនោះឡើយ។

ក្រុមហ៊ុនមានកិច្ចសន្យាប្តូរអត្រាការប្រាក់ (Interest Rate Swaps) ដើម្បីការពារហានិភ័យរបស់ក្រុមហ៊ុនចំពោះការបង្ហាញនៃហានិភ័យនៃអត្រាការប្រាក់លើប្រាក់កម្ចីរបស់ក្រុមហ៊ុនអប្បបរមាចំនួន ២៥ លានដុល្លារអាមេរិក។ កិច្ចសន្យាប្តូរអត្រាការប្រាក់អនុញ្ញាតឲ្យក្រុមហ៊ុនបង្កើនប្រាក់កម្ចីក្នុងអត្រាអណ្តែត ហើយប្តូរទៅអត្រាថេរ។

លើសពីនេះទៅទៀត ថ្នាក់គ្រប់គ្រងក្រុមហ៊ុននឹងបន្តវាយតម្លៃដោយយកចិត្តទុកដាក់លើហានិភ័យអត្រាការប្រាក់ និងកំណត់ពីតម្រូវការប្រាក់ការចុះកិច្ចសន្យាការពារហានិភ័យអត្រាការប្រាក់នាពេលអនាគត។

៣.២. ហានិភ័យលើអត្រាប្តូរប្រាក់

៣.២.១ .ចលនាឡើងចុះនៃអត្រាប្តូរប្រាក់

ក. ការវិភាគ

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជាគឺប្រាក់រៀល។ ក៏ប៉ុន្តែ ក្រុមហ៊ុនអនុវត្តប្រតិបត្តិការអាជីវកម្ម និងកត់ត្រាបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនជាប្រាក់ដុល្លារអាមេរិក។ គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនបានកំណត់យកប្រាក់ដុល្លារអាមេរិក ធ្វើជារូបិយប័ណ្ណប្រតិបត្តិការរបស់ក្រុមហ៊ុន។ ហេតុនេះ ហានិភ័យលើអត្រាប្រាក់រូបិយប័ណ្ណបរទេសរបស់ ក្រុមហ៊ុនកើតឡើងពីប្រតិបត្តិការដែលប្រើប្រាស់រូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក។

សម្រាប់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យ ចំណូលសរុប និងការបញ្ចាទិញ ត្រូវបានកំណត់ជាប្រាក់ដុល្លារអាមេរិក។

ការប្រឈមរបស់ក្រុមហ៊ុនចំពោះហានិភ័យប្តូរប្រាក់បរទេសកើតឡើងពីចំនួនទឹកប្រាក់ដែលបានមកពីក្រុមហ៊ុនមេ និងភាគីដែលពាក់ព័ន្ធប្រមាណ ៥៩,៦ លានដុល្លារអាមេរិក និង ១,១ លានដុល្លារអាមេរិក ដែលត្រូវបានកំណត់ជាប្រាក់ដុល្លារអាមេរិក។ តារាងខាងក្រោមបង្ហាញពីរំញោចប្រាក់ចំណេញរបស់ក្រុមហ៊ុនយើងសម្រាប់ឆ្នាំសារពើពន្ធថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដល់ទៅ ±៥,០០% ការផ្លាស់ប្តូរជាប្រាក់រីងហ្គីត៖

រឹងហ្គីត/ដុល្លារអាមេរិក	ពាន់ដុល្លារអាមេរិក
ភាពខ្លាំង	(៣.០៣៥)
ភាពខ្សោយ	៣.០៣៥

ខ. **ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ឈៀសហានិភ័យ**

ក្រុមប្រឹក្សាភិបាលយើងយល់ឃើញថា ហានិភ័យអត្រាប្តូរប្រាក់ មិនមែនជាបញ្ហាធំដល់អាជីវកម្មរបស់ក្រុមហ៊ុនយើងឡើយរហូតមកដល់ពេលនេះ។ ដូច្នេះក្រុមហ៊ុនយើងមិនបានចូលរួមក្នុងប្រតិបត្តិការការពារហានិភ័យអត្រាប្តូរប្រាក់ទេ (currency hedging transaction) ដោយហេតុថា ការជួញដូររបស់ក្រុមហ៊ុនភាគច្រើនធ្វើឡើងជាប្រាក់ដុល្លារអាមេរិក។ ហេតុនេះ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន មិនមានជំនឿថាហានិភ័យលើអត្រាប្តូរប្រាក់មានភាពធ្ងន់ធ្ងរចំពោះអាជីវកម្មរបស់ក្រុមហ៊ុនឡើយ។ បន្ថែមពីនេះ គណៈគ្រប់គ្រងរបស់ក្រុមហ៊ុន មានបទពិសោធន៍ជាច្រើនក្នុងការទិញសម្ភារៈ និង/ឬឧបករណ៍ ហើយត្រួតពិនិត្យជា បចាំលើស្ថានភាពទីផ្សារសម្រាប់តម្លៃនៃសម្ភារៈ និង/ឬឧបករណ៍នានា ដើម្បីធានាការប្រឈមទៅនឹង ចលនាអត្រាប្តូរប្រាក់បរទេសក្នុងកម្រិតទាបបំផុត។

ផ្ទុយពីការលើកឡើងខាងលើ មិនមានការធានាណាមួយថា ចលនាឡើងចុះនៃអត្រាប្តូរប្រាក់នាពេលអនាគត នឹងមិនប៉ះពាល់ជាអវិជ្ជមានលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

៣.៣. ហានិភ័យលើខ្សែសង្វាក់ផ្គត់ផ្គង់ ហានិភ័យទាក់ទងនឹងការប្រែប្រួលបរិមាណជាតិ និងអន្តរជាតិ និងការប្រែប្រួលនៃច្បាប់ និងបទប្បញ្ញត្តិនានា

៣.៣.១. ការពឹងផ្អែកលើតម្រូវការអគ្គិសនី

ក. **ការវិភាគ**

ក្រុមហ៊ុនពឹងផ្អែកលើតម្រូវការក្នុងតំបន់ សម្រាប់ការផ្គត់ផ្គង់អគ្គិសនីដើម្បីបង្កើនតម្រូវការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម និងនគរូបនីយកម្ម។ អតិថិជនរបស់ក្រុមហ៊ុនភាគច្រើនគឺជាក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនី និងឧស្សាហកម្ម និងសម្បទានិកហោដ្ឋារចនាសម្ព័ន្ធថាមពលដែលផ្តល់សន្យានៃការសាងសង់ជាកញ្ចប់នៃហោដ្ឋារចនាសម្ព័ន្ធអគ្គិសនី។ ការសាងសង់នូវហោដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានទំនុកចិត្ត និងមានសុវត្ថិភាព គឺជាធាតុគន្លឹះមូលដ្ឋាននៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ប្រទេស។

ហេតុដូច្នេះ សកម្មភាពអាជីវកម្មរបស់យើងត្រូវបានចងភ្ជាប់យ៉ាងជិតស្និតទៅនឹងសន្ទុះនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមក្នុងតំបន់ ដែលពឹងផ្អែកទៅលើសេចក្តីប្រាថ្នារបស់ជាតិសាសន៍នីមួយៗ។

ភាពយឺតយ៉ាវនៃការពង្រីកបន្ថែម ឬការធ្វើឱ្យប្រសើរឡើង នៃហេដ្ឋារចនាសម្ព័ន្ធចាំបាច់ក្នុងតំបន់ ដែលកើតចេញពីផលអវិជ្ជមាននៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម នឹងមានឥទ្ធិពលដោយផ្ទាល់លើប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន និងផែនការនាពេលអនាគតរបស់ក្រុមហ៊ុន។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

នៅក្នុងប្រទេសភាគច្រើន ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍនៅក្នុងតំបន់ តែងតែមានតម្រូវការអគ្គិសនីស្របពេលនឹងការលូតលាស់ នៃសេដ្ឋកិច្ច និងសក្ដានុពលធ្វើឱ្យប្រសើរឡើង នៃការទទួលបានថាមពលអគ្គិសនីប្រើប្រាស់ជាទូទៅ។ ក្រុមហ៊ុន Smith Zander បានប៉ាន់ប្រមាណថា តម្រូវការក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងប្រទេសកម្ពុជាតែមួយនឹងកើនឡើងពី ៨.៦៤៩,៩៨ ជីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០១៨ ដល់ ១២.០១៩,៧៥ ជីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០២០ ក្នុងអត្រាកំណើនប្រចាំឆ្នាំសរុប ១៧,៨៨%។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនគិតថា តម្រូវការអគ្គិសនី ការពង្រីក និងការធ្វើឱ្យប្រសើរឡើងនៅក្នុងតំបន់ នឹងបន្តកើនឡើងជាបន្តបន្ទាប់រហូតដល់ឆ្នាំ២០៣០ ផ្អែកទៅលើរបាយការណ៍ផ្សេងៗអំពីតម្រូវការអគ្គិសនីសម្រាប់តំបន់ ។

៣.៣.២ ការប្រែប្រួលលក្ខខណ្ឌ នយោបាយ សង្គមកិច្ច និងបទប្បញ្ញត្តិក្នុងប្រទេសកម្ពុជា និងបណ្ដាប្រទេសដទៃទៀតដែលក្រុមហ៊ុន អាចមានប្រតិបត្តិការ

ក. ការវិភាគ

ក្រុមហ៊ុនងាយនឹងទទួលរងអំពីការប្រែប្រួលលក្ខខណ្ឌ នយោបាយ និងបទប្បញ្ញត្តិក្នុងប្រទេសកម្ពុជា និងបណ្ដាប្រទេសដទៃទៀតដែល ក្រុមហ៊ុនអាចមានប្រតិបត្តិការនាពេលអនាគត។ ស្ថានភាពអវិជ្ជមាននៅក្នុងប្រទេសទាំងនោះអាចបង្ករការរាំងស្ទះធ្ងន់ធ្ងរលើសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន ហើយអាចប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុ និងប្រាក់ចំណេញរបស់ក្រុមហ៊ុន។ ស្ថានភាពទាំងនេះរួមមានជាអាទិ៍ ស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់និងសកលលោកនាពេលបច្ចុប្បន្ន អតិផរណា ស្ថានភាពឥណទាន ស្ថានភាពដឹកនាំនយោបាយ បទប្បញ្ញត្តិនិងគោលនយោបាយរបស់រដ្ឋាភិបាល ហានិភ័យសង្គ្រាម វិធីសាស្ត្រគណនាពន្ធ ជាតូបនីយកម្ម អស្សាមិករណ៍ ការចរចារឡើងវិញ ឬការរំលាយកិច្ចសន្យាដែលមានស្រាប់។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

ក្រុមហ៊ុនបានប្រើប្រាស់យន្តការបង្ការ ដោយស្វែងយល់បច្ចុប្បន្នភាព វឌ្ឍនៈភាពសេដ្ឋកិច្ច នយោបាយ សង្គម និងបទប្បញ្ញត្តិក្នុងប្រទេសកម្ពុជា និងការអភិវឌ្ឍនៅក្នុងបណ្ដាប្រទេស

ដទៃទៀត ដែលក្រុមហ៊ុនអាចមានប្រតិបត្តិការនាពេលអនាគត។ ទោះបីក្រុមហ៊ុននឹងប្រើប្រាស់វិធានការឱ្យមានប្រសិទ្ធភាព ដូចជាការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រុងប្រយ័ត្ន និងនីតិវិធីប្រតិបត្តិការឱ្យមានប្រសិទ្ធភាព ក្រុមហ៊ុនមិនធានាថាផលអវិជ្ជមាននៃកត្តានយោបាយ សេដ្ឋកិច្ច សង្គម និងបទប្បញ្ញត្តិផ្សេងៗ នឹងមិនបង្កឱ្យមានផលប៉ះពាល់ដល់ដំណើរការរបស់ក្រុមហ៊ុនឡើយ។ ចំពោះគម្រោងជាក់លាក់នានា ការធានាលើហានិភ័យនយោបាយនឹងត្រូវបានប្រើប្រាស់ក្នុងគោលបំណងកាត់បន្ថយហានិភ័យ។

ប៉ុន្តែ ចរិកលក្ខណៈរបស់អាជីវកម្ម និងយុទ្ធសាស្ត្ររបស់យើង មិនតម្រូវឱ្យយើងវិនិយោគច្រើនលើទ្រព្យសកម្មរយៈពេលវែង ដើម្បីទទួលបានអាជីវកម្មនោះឡើយ។ ហេតុដូចនេះ យើងហាក់មិនទទួលរងនូវឥទ្ធិពលអវិជ្ជមាននៃនយោបាយ សេដ្ឋកិច្ច សង្គម និងគោលការណ៍ផ្សេងៗ ដោយយើងជឿជាក់ថាយើងអាចសម្របទៅនឹងការផ្លាស់ប្តូរនោះ ដោយក្រុមហ៊ុនយើងមានតម្រូវការដើមទុនទាប។

បន្ថែមពីលើនេះ បរិយាកាសអាជីវកម្ម និង បរិយាកាសវិនិយោគល្អជា លក្ខខណ្ឌចាំបាច់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីបន្តទាក់ទាញការវិនិយោគនិងសកម្មភាពសាងសង់ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី។

គិតមកត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនរបស់យើងមិនបានជួបប្រទះនូវបញ្ហាមិនល្អណាមួយដែលកើតឡើងពីការប្រែប្រួល ស្ថានភាពសេដ្ឋកិច្ច នយោបាយ សង្គម និងបទប្បញ្ញត្តិនៅក្នុងតំបន់ទេ លើកលែងតែការផ្ទុះឡើងនៃវីរុស Covid-19 នៅដើមឆ្នាំ ២០២០ ដែលអាចនាំអោយមានផលប៉ះពាល់ដូចខាងក្រោម៖

(i) ការពន្យាពេលជាបណ្តោះអាសន្នចំពោះគម្រោងផ្គត់ផ្គង់អគ្គិសនី (រួមមានការសាងសង់រោងចក្រថាមពល អនុស្ថានីយ ប្រព័ន្ធបញ្ជូននិងចែកចាយអគ្គិសនី) ដោយសារតែការរឹតត្បិតការធ្វើដំណើរអ្នកជំនាញ/ដៃគូចូលក្នុងប្រទេសកម្ពុជា ក៏ដូចជាការពន្យារពេលក្នុងការផ្គត់ផ្គង់ពីអ្នកផ្គត់ផ្គង់នៅបរទេសសម្រាប់គម្រោងផ្គត់ផ្គង់អគ្គិសនី និង

(ii) ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជាយោងតាមធនាគារអភិវឌ្ឍន៍អាស៊ីដែលអាចបង្កហានិភ័យដល់គម្រោងផ្គត់ផ្គង់អគ្គិសនីខ្នាតធំ។

ទោះជាយ៉ាងនេះក្តី តម្រូវការអគ្គិសនីនៅកម្ពុជានឹងនៅតែរឹងមាំក្នុងរយៈពេលវែងព្រោះវាជាកត្តាចាំបាច់ដើម្បីគាំទ្រដល់ការរីកចម្រើន និងការអភិវឌ្ឍប្រទេសជាតិ ហេតុដូចនេះហើយវានឹងបន្តជំរុញកំណើនអ្នកផ្គត់ផ្គង់ ក្នុងវិស័យអគ្គិសនី។ ក្នុងនាមអ្នកផ្គត់ផ្គង់មួយក្នុងវិស័យផ្គត់ផ្គង់ថាមពលអគ្គីសនីនេះ យើងខ្ញុំរំពឹងថា ក្រុមហ៊ុន ផេសថិក (ខេមបូឌា) នឹងជះឥទ្ធិពលវិជ្ជមានក្នុងរយៈពេលវែងទៅលើវិស័យផ្គត់ផ្គង់អគ្គិសនីនេះ។

៣.៤. ហានិភ័យប្រតិបត្តិការ

៣.៤.១. ហានិភ័យដែលកើតមានប្រចាំថ្ងៃ និងការធានារ៉ាប់រង

ក. **ការវិភាគ**

ដោយហេតុថា ក្រុមហ៊ុនយើងប្រតិបត្តិការក្នុងឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនី នោះសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនងាយនឹងទទួលរងហានិភ័យ។ ហានិភ័យដែលកើតមានប្រចាំថ្ងៃ រួមមានហានិភ័យគ្រោះថ្នាក់ ការអាក់ខាននៃការផ្គត់ផ្គង់លើធាតុសំខាន់ៗ ការអាក់ខានក្នុងការផ្គត់ផ្គង់ទឹកភ្លើង រួមទាំងអគ្គិភ័យ ទឹកជំនន់ និង/ឬ គ្រោះធម្មជាតិផ្សេងៗ ដែលអាចបង្កការរាំងស្ទះ ឬពន្យារពេលក្នុងការអនុវត្តគម្រោងរបស់ក្រុមហ៊ុន ហើយអាចបង្កការខូចខាតទៅលើសម្ភារៈ និងឧបករណ៍នានា ដែលអាចនាំឱ្យប៉ះពាល់ដល់ដំណើរការអាជីវកម្ម។ លើសពីនេះទៀត ដោយសារគម្រោងរបស់ក្រុមហ៊ុន រួមមានការប្រើប្រាស់ឧបករណ៍ និងគ្រឿងម៉ាស៊ីនធុនធ្ងន់ យើងអាចជួបប្រទះគ្រោះថ្នាក់ ឬឧបទ្ទវហេតុ នៅក្នុងការដ្ឋាននៃគម្រោងផងដែរ។

ខ. **ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ**

ក្រុមហ៊ុនខិតខំកាត់បន្ថយហានិភ័យខាងលើតាមរយៈវិធានការបង្ការហានិភ័យដូចខាងក្រោម៖

(១) ក្រុមហ៊ុនបានទិញធានារ៉ាប់រងបង្ការគ្រោះថ្នាក់ផ្ទាល់ខ្លួនសម្រាប់បុគ្គលិកទាំងអស់របស់ក្រុមហ៊ុន។

(២) ក្រុមហ៊ុនធានាថា ការដ្ឋាននៃគម្រោងបានបំពេញតាមលក្ខខណ្ឌសុវត្ថិភាពដូចមានចែងក្នុងអាជ្ញាប័ណ្ណពាក់ព័ន្ធនានា ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច និងវិធានផ្ទៃក្នុងរបស់ក្រុមហ៊ុនដែលបានអនុម័ត។

(៣) ក្រុមហ៊ុនបានបង្កើតនីតិវិធីអនុវត្តគម្រោងផ្ទៃក្នុង និងការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ដើម្បីធានាប្រតិបត្តិការអាជីវកម្មមានប្រសិទ្ធិភាព។

(៤) ការហ្វឹកហាត់ និងណែនាំផ្ទៃក្នុងអំពីលក្ខខណ្ឌសុវត្ថិភាព និងរបៀបប្រើប្រាស់ឧបករណ៍ផ្សេងៗដោយត្រឹមត្រូវ ត្រូវបានរៀបចំឡើងដើម្បីធានាថា និយោជិតរបស់ក្រុមហ៊ុន បានឆ្លងកាត់ការហ្វឹកហាត់គ្រប់គ្រាន់ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់នៅក្នុងទីតាំងគម្រោង។ និង

(៥) ក្រុមហ៊ុនស្វែងរកការធានាលើសម្ភារៈ ដែលផ្គត់ផ្គង់ដោយអ្នកផ្គត់ផ្គង់របស់ក្រុមហ៊ុនស្របទៅតាមការតម្រូវរបស់គម្រោង ហើយសម្ភារៈត្រូវមានការធានាត្រឹមត្រូវ។

រាល់គម្រោងទាំងអស់របស់ក្រុមហ៊ុនមានធានារ៉ាប់រងគ្រប់គ្រាន់ ដើម្បីធានាលើការខូចខាត និងគ្រោះថ្នាក់ចម្បងផ្សេងៗ។

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនមិនធ្លាប់បានរងផលប៉ះពាល់ដោយព្រឹត្តការណ៍ណាមួយឡើយ រួមមានហានិភ័យដូចជា រៃគ្រោះធម្មជាតិ បាតុកម្ម កុបកម្ម ឬហានិភ័យប្រតិបត្តិការណាមួយឡើយ។

៣.៤.២. លទ្ធផលផ្អែកតាមគម្រោង

ក. ការវិភាគ

លទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុនអាស្រ័យលើគម្រោង។ សម្រាប់ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ គម្រោងទាំងនោះ បានចូលរួមយ៉ាងសំខាន់លើប្រាក់ចំណេញរបស់ក្រុមហ៊ុន។ គម្រោងរបស់ក្រុមហ៊ុន បានចូលរួមចំណែកប្រហែល ៩៩,៩% និង ៨៧,៤% លើប្រាក់ចំណេញសរុបសម្រាប់ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និង ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៩។ សម្រាប់ព័ត៌មានបន្ថែមលើ គម្រោងដែលបានបញ្ចប់ និងកំពុងបន្តអនុវត្ត សូមពិនិត្យមើលផ្នែកទី ៤.១.៦ នៃឯកសារផ្តល់ព័ត៌មាននេះ។

លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការទទួលបានកិច្ចសន្យាថ្មីៗនាពេលអនាគត គឺពឹងផ្អែកទៅលើកត្តានានាដែលរួមមានជាអាទិ៍ គោលនយោបាយរដ្ឋាភិបាល និងស្ថានភាពសេដ្ឋកិច្ចទូទៅ តម្រូវការនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ និងការផ្លាស់ប្តូរនានាក្នុងស្ថានភាពអាជីវកម្ម និងឥណទានទូទៅទាំងក្នុងស្រុកនិងក្រៅស្រុក។ ហេតុនេះ លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនអាចត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ក្នុងករណីដែលក្រុមហ៊ុនមិនអាចធានាបាននូវការបញ្ជាទិញគ្រប់គ្រាន់សម្រាប់គម្រោងរបស់ក្រុមហ៊ុន។ បន្ថែមពីនេះទៀត ប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងដំណាច់ការិយបរិច្ឆេទជាក់លាក់ណាមួយអាចពឹងផ្អែកយ៉ាងខ្លាំងទៅលើគម្រោងតែមួយ និងដំណាក់កាលនៃការអនុវត្តគម្រោងនោះ។ ឧទាហរណ៍ សម្រាប់ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ចំណូលបានមកពីគម្រោង ភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ មានចំនួនប្រហែល ៥០,១% នៃចំណូលសរុបប្រចាំឆ្នាំ។ ខណៈដែលក្រុមហ៊ុនមិនរំពឹងទុកអំពីស្ថានភាពបែបនេះអាចកើតមានឡើងជារៀងរហូតក៏ដោយ ប៉ុន្តែគ្មានការធានាណាមួយថាការពឹងផ្អែកបែបនេះនឹងមិនកើតឡើងនាពេលអនាគតនោះឡើយ។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

ក្រុមហ៊ុនបានប្រើប្រាស់វិធានការចាំបាច់នានា ក្នុងការបង្កើនអតិថិជនក្នុងតំបន់ ឲ្យបានទូលំទូលាយ ដោយសារសេវាកម្ម និងផលិតផលរបស់ក្រុមហ៊ុនយើងមានតម្រូវការស្រដៀងគ្នា

គ្រប់ប្រទេសក្នុងតំបន់។ ក្រុមហ៊ុនយើង ព្យាយាមធានានូវភាពពេញចិត្តខ្ពស់របស់អតិថិជន ធានារក្សា និងទទួលបានអតិថិជនថ្មី ដោយ៖

(១) ផ្តល់សេវាកម្ម ឬដំណោះស្រាយ ដ៏ល្អប្រសើរបន្ថែម ជូនអតិថិជនរបស់ក្រុមហ៊ុន តាមរយៈឧបករណ៍ធ្វើតេស្តរបស់ក្រុមហ៊ុន សម្រាប់ការដាក់ឱ្យដំណើរការអនុស្ថានីយ៍ និង

(២) ផ្តល់ដំណោះស្រាយដ៏សមរម្យដល់អតិថិជន ដោយផ្ទាល់ និងធានាថាអតិថិជនពេញចិត្តនឹងគុណភាព និងសេវាកម្មនៃគម្រោង របស់ក្រុមហ៊ុន និង ការអនុវត្តដោយទៀងទាត់ទាន់ពេលវេលា។

បន្ថែមពីលើនេះ តម្រូវការសម្រាប់ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់មានសន្ទុះល្បឿន និងផ្តល់នូវឱកាសល្អសម្រាប់ក្រុមហ៊ុនយើងក្នុងការបំពេញនូវការបញ្ជារកក់។

បន្ថែមពីលើនេះទៅទៀត ក្រុមហ៊ុនយើងបានទទួលនូវកិច្ចសន្យា O&M ដែលធានានូវចំណូលសម្រាប់ក្រុមហ៊ុនយើងសម្រាប់រយៈពេល ២៥ ឆ្នាំបន្តទៀត។

៣.៤.៣. ហានិភ័យនៃគម្រោង

ក. ការវិភាគ

ដូចបានរៀបរាប់នៅ ផ្នែកទី៣.៤.២ ខាងលើ ចំណូលរបស់ក្រុមហ៊ុន គឺទទួលបានមួយភាគធំចេញពីគម្រោង ដែលធ្វើឡើងក្នុងទម្រង់ជាកិច្ចសន្យា ដែលជាកម្មវត្ថុទៅនឹងការអនុវត្តន៍ចេញពី ខ និងលក្ខខណ្ឌនៃកិច្ចសន្យានោះ។ ប្រសិនបើ គម្រោងរបស់ក្រុមហ៊ុនត្រូវបានពន្យារពេល ដោយសារមូលហេតុណាមួយដែលក្រុមហ៊ុនត្រូវទទួលខុសត្រូវតាមកិច្ចសន្យា ជាពិសេសចំណុចដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវទទួលខុសចំពោះការខូចខាតជាក់ស្តែង ដែលកើតចេញពីការពន្យាពេល ឬបញ្ចប់នោះ។ ដូច្នេះហើយ ការពន្យារពេលណាមួយ អាចប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបញ្ចប់គម្រោង និងគោលដៅចំណូល ព្រមទាំងផែនការអាជីវកម្មរបស់ក្រុមហ៊ុនអំឡុងពេលជាក់លាក់ណាមួយ។ ឧបសគ្គប្រឈមក្នុងការអនុវត្តគម្រោង អាចបណ្តាលឱ្យមានការកើនឡើងនៃបន្ទុកចំណាយ។ ការវិវឌ្ឍនៃស្ថានភាពបែបនេះ អាចបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានដល់អាជីវកម្ម ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលនៃប្រតិបត្តិការនានារបស់ក្រុមហ៊ុន។

ក្រៅពីចំណុចខាងលើ គម្រោងរបស់ក្រុមហ៊ុនអាចត្រូវបានលុបចោល ពន្យារពេល ឬរៀបចំកាលវិភាគឡើងវិញ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ ប្រាក់ចំណេញរបស់ក្រុមហ៊ុន។ ជាងនេះ

ទៅទៀត ការបញ្ឈប់គម្រោងសំខាន់នានា នឹងនាំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ចំណូលរបស់ក្រុមហ៊ុននាពេលអនាគត។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ឈៀសហានិភ័យ

សម្រាប់ស្ថានភាពនានាដែលក្រុមហ៊ុនមិនអាចគ្រប់គ្រងបាន ដូចជាស្ថានភាពធាតុអាកាសមិនល្អ និង/ឬទឹកជំនន់ ការពន្យារពេលទាំងនេះ នឹងត្រូវបានផ្តល់ជាការអនុគ្រោះដោយអតិថិជនតាមរយៈ ការពន្យារពេលក្នុងពេលបញ្ចប់គម្រោង។ លើសពីនេះទៀត ក្រោមបញ្ញត្តិនៃកិច្ចសន្យា ភាគច្រើនជាមួយនឹងអតិថិជនរបស់ក្រុមហ៊ុន អតិថិជនអាចធ្វើការស្នើសុំផ្លាស់ប្តូរលើលក្ខខណ្ឌកិច្ចសន្យា ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ឥតគ្រោងទុកណាមួយ ដែលប៉ះពាល់ដល់គម្រោង។ កិច្ចសន្យារបស់ក្រុមហ៊ុនចែងថា ការចំណាយ និងរយៈពេលបន្ថែមដោយផ្តាល់កើតឡើងពីការប្រែប្រួលនេះ ត្រូវបានអនុញ្ញាត។

គ្រប់គម្រោងរបស់ក្រុមហ៊ុន គឺពឹងផ្អែកទៅលើកិច្ចសន្យា។ វាល់ការលុបចោល និងបញ្ឈប់គម្រោង ត្រូវអនុលោមតាម ខ និងលក្ខខណ្ឌនៃកិច្ចសន្យា។ ជាទូទៅ ការទាមទារបង់ប្រាក់លើកិច្ចការណាមួយដែលកើតមានឡើងមុនពេលលុបចោល ឬបញ្ឈប់កិច្ចសន្យា នឹងត្រូវបានអនុញ្ញាតតាមកិច្ចសន្យា។

បន្ថែមពីលើនេះ ក្រុមហ៊ុននឹងស្វែងរកនូវការប្រឹក្សាច្បាប់មុនពេលចុះកិច្ចសន្យាដើម្បីការពារផលប្រយោជន៍របស់ក្រុមហ៊ុន។

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនបានបង់ប្រាក់ ឬទទួលខុសត្រូវលើសំណងការខូចខាតជាក់ស្តែងណាមួយលើការបញ្ឈប់ ពន្យារពេល ឬរៀបចំកាលវិភាគឡើងវិញ ក្នុងអំឡុងការិយបរិច្ឆេទក្រោមការត្រួតពិនិត្យនោះឡើយ។

៣.៤.៤. ការពឹងផ្អែកលើ និងអលទ្ធភាពក្នុងការរក្សាទុក អតថាលប្រតិបត្ត និងបុគ្គលិកជាន់ខ្ពស់

ក. ការវិភាគ

ក្រុមហ៊ុនយើងជឿជាក់ថា ភាពជោគជ័យជាបន្តបន្ទាប់របស់ក្រុមហ៊ុន ពឹងផ្អែកសំខាន់ទៅលើសមត្ថភាព លទ្ធភាព និងការខិតខំប្រឹងប្រែងរបស់ អភិបាលប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន ក្នុងការធ្វើទីផ្សារលើសេវាកម្ម និងផលិតផលដើម្បីភាពរីកចម្រើនអាជីវកម្ម។ ក្រុមហ៊ុនយើងត្រូវបានដឹកនាំដោយអភិបាលដែលមានបទពិសោធន៍ និងគ្រប់គ្រងដោយក្រុមការងារបុគ្គលិកជាន់ខ្ពស់ដែលមានសមត្ថភាព ដែលមានបទពិសោធន៍និងចំណេះដឹងជាច្រើននៅក្នុងវិស័យឧស្សាហកម្ម។

ការបាត់បង់អភិបាល និងថ្នាក់គ្រប់គ្រងសំខាន់ៗរបស់ក្រុមហ៊ុន អាចប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការអនុវត្តសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាព។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ទទួលស្គាល់សារៈសំខាន់លើសមត្ថភាពទាក់ទាញ និងរក្សាទុកអភិបាលប្រតិបត្តិ និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន តាមរយៈការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស ដែលរួមមាន កញ្ចប់ប្រាក់លើកទឹកចិត្តសមរម្យ ផែនការអ្នកបន្តវេនតួនាទីសំខាន់ៗ។

បន្ថែមពីនេះទៀត ក្រុមហ៊ុនបានអនុម័តការគ្រប់គ្រងនិរន្តរភាពអាជីវកម្ម ដើម្បីជៀសវាងការរអាក់រអួលអាជីវកម្ម។

ទោះយ៉ាងណាក៏ដោយ មិនមានការធានាទេថា យន្តការខាងលើនឹងទទួលបានជោគជ័យក្នុងការទាក់ទាញ និងរក្សាទុកអភិបាលប្រតិបត្តិ បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនឡើយ។ វាល់ការបាត់បង់អភិបាលប្រតិបត្តិ ឬបុគ្គលិកជាន់ខ្ពស់នឹងមានផលប៉ះពាល់តែមួយរយៈពេលខ្លីដល់អាជីវកម្មប៉ុណ្ណោះ។

៣.៤.៥. ការពឹងផ្អែកទៅលើតតយជន ក្នុងការផ្តល់សម្ភារៈ បង្គុំ និងផ្នែកផ្សេងៗ ក្នុងគម្រោងរបស់ក្រុមហ៊ុន

ក. ការវិភាគ

ក្រុមហ៊ុនយើងពឹងផ្អែកលើ ក្រុមហ៊ុន PSB ក្នុងការផ្គត់ផ្គង់បរិក្ខារដូចជា ទូរភ្ជាប់ផ្តាច់ចរន្ត និងបំប្លែងអគ្គិសនីសម្រាប់គម្រោង និងផលិតផលមកឱ្យក្រុមហ៊ុន។ ក្រុមហ៊ុនក៏ពឹងផ្អែកលើក្រុមហ៊ុន PSB ដើម្បីធ្វើការបញ្ជាទិញពីអ្នកផលិតដទៃ ដើម្បីផលិតបំណែកលោហៈក្នុងការបម្រើ

ឱ្យគម្រោងរបស់ក្រុមហ៊ុន។ សម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ការបញ្ចាទិញពីក្រុមហ៊ុន PSB មានចំនួនប្រមាណ ១៣,៦ លានដុល្លារអាមេរិក និង ៣៦,៥ លានដុល្លារអាមេរិក ស្មើនឹង ២១,៦% និង ៧៣,៣% នៃផ្នែកដើមលក់ និងតម្លើងក្នុងឆ្នាំហិរញ្ញវត្ថុនោះ។ ជាងនេះទៅទៀត ក្រុមហ៊ុន PSB ក៏ពឹងផ្អែកលើអោងចក្រផលិតដទៃ (ភាគីទីបី) សម្រាប់គ្រឿងបង្គុំ ដូចជាឧបករណ៍រឺឡេ ឧបករណ៍បំប្លែងចរន្ត ឧបករណ៍បំប្លែងតង់ស្យុង និងទូរភ្ជាប់ផ្តាច់ចរន្ត សម្រាប់ផលិតផលរបស់ខ្លួន និងសម្រាប់ផ្គត់ផ្គង់ដល់ក្រុមហ៊ុនយើង។ អាជីវកម្មរបស់ក្រុមហ៊ុន អាចទទួលផលប៉ះពាល់ធ្ងន់ធ្ងរ ប្រសិនបើ ក្រុមហ៊ុន PSB មិនអាចផ្គត់ផ្គង់ និងធានាការផ្គត់ផ្គង់រាល់គ្រឿងបង្គុំ និងឧបករណ៍ដូចរៀបរាប់ពីខាងដើមសម្រាប់គម្រោងរបស់ក្រុមហ៊ុន។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការកាត់បញ្ឈៀសហានិភ័យ

ក្រុមហ៊ុនមានបំណងទទួលយកការផ្គត់ផ្គង់សម្ភារ និងបរិក្ខារដោយផ្ទាល់ពីភាគីខាងក្រៅបន្តិចម្តងៗបន្ទាប់ពីការបោះផ្សាយជាសាធារណៈនេះ។ ការគ្រប់គ្រង និងប្រាស្រ័យទាក់ទងជាមួយអ្នកផ្គត់ផ្គង់នេះនឹងត្រូវបានធ្វើឡើងដោយផ្ទាល់ពីក្រុមហ៊ុនយើង។
គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនធ្លាប់ជួប ឧបសគ្គណាមួយក្នុងការទិញគ្រឿងបរិក្ខារពីក្រុមហ៊ុន PSB ឬអ្នកផ្គត់ផ្គង់ដទៃផ្សេងទៀត ដើម្បីបម្រើឱ្យគម្រោងឡើយ។

៣.៤.៦. ហានិភ័យនៃការប្រើប្រាស់បច្ចេកទេសរបស់តតិយជន

ក. ការវិភាគ

អំឡុងពេលអនុវត្តគម្រោង ក្រុមហ៊ុនត្រូវការប្រើប្រាស់សម្ភារៈ ឬទំនិញរបស់តតិយជន។ ប្រសិនបើសម្ភារៈ ឬទំនិញទាំងនោះមិនដំណើរការប្រក្រតី ក្រុមហ៊ុនត្រូវការស្នើសុំជំនួយបច្ចេកទេសពីអ្នកផលិតដើម្បីដោះស្រាយបញ្ហា។ ទោះបីជាផលិតករជាទូទៅមាន ក្រុមអ្នកជំនាញសម្រាប់ជួយដោះស្រាយក្នុងកាលៈទេសៈនេះក៏ដោយ ក៏ក្រុមហ៊ុនមិនអាចធានាបានថាជំនួយទាំងនោះអាចត្រូវបានផ្តល់ឱ្យទាន់ពេលវេលា និងមានប្រសិទ្ធិភាពគ្រប់ពេលវេលានោះឡើយ។

ខ. **ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ**

ក្រុមហ៊ុនអាចនឹងធានាថាគ្រឿងបង្គុំ ឬគ្រឿងបរិក្ខារនានារបស់តតិយជន ត្រូវបានផ្គត់ផ្គង់ដោយអ្នកផ្គត់ផ្គង់ដែលមានកេរ្តិ៍ឈ្មោះជាមួយនឹងបទពិសោធន៍យូរអង្វែង ពាក់ព័ន្ធនឹងភាពដែលអាចទុកចិត្តបានលើគ្រឿងបរិក្ខារ ឬផលិតផលរបស់ពួកគេ ដើម្បីកាត់បន្ថយហានិភ័យនៃកំហុសផ្នែកបរិក្ខាររបស់តតិយជន។ បន្ថែមពីលើនេះថ្នាក់គ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់របស់ក្រុមហ៊ុនយើង តម្រូវឱ្យមានការចុះឈ្មោះអ្នកផ្គត់ផ្គង់ ការតាមដានវឌ្ឍនភាព និងការការត្រួតពិនិត្យរោងចក្រដើម្បីធានានូវគុណភាពនៃផលិតផល និងការដឹកជញ្ជូនទាន់ពេលវេលា។

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនធ្លាប់ឆ្លងកាត់ការពន្យារពេលណាមួយលើគម្រោង ដែលកើតឡើងដោយសារបញ្ហាគ្រឿងបរិក្ខារ ឬផលិតផលរបស់តតិយជនឡើយ។

៣.៤.៧. ការពឹងផ្អែកលើអតថិជនសំខាន់ៗ

ក. **ការវិភាគ**

ដោយហេតុថា ចំណូលរបស់ក្រុមហ៊ុនមួយភាគធំទទួលបានមកពីគម្រោង ក្រុមហ៊ុនអាចពឹងផ្អែកលើគម្រោង និងអតិថិជនជាក់លាក់មួយចំនួន ក្នុងអំឡុងពេលជាក់លាក់ណាមួយ។ អំឡុងដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ អតិថិជនសំខាន់របស់ក្រុមហ៊ុនយើងមាន ក្រុមហ៊ុន អាឡិច ខបអើរេសិន និងក្រុមហ៊ុន Schneitec ដែលរួមចំណែកចំនួន ៥៧,៨% និង២៥,៤% នៃចំណូលសរុបរបស់ក្រុមហ៊ុនយើងបន្តបន្ទាប់សម្រាប់ដំណាច់ការិយបរិច្ឆេទក្នុងឆ្នាំ។

សម្រាប់ព័ត៌មានបន្ថែមស្តីអំពី គម្រោងបច្ចុប្បន្នរបស់ក្រុមហ៊ុន មាននៅផ្នែកទី ៤.១.៦ នៃឯកសារផ្តល់ព័ត៌មាននេះ។

ខ: ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

ការពឹងផ្អែកលើ ក្រុមហ៊ុន អាឡិច ខបភើរេសិន និងក្រុមហ៊ុន Schneitec គឺសម្រាប់តែរយៈពេលកិច្ចសន្យាលើគម្រោងភ្នំពេញខាងលិច - ខេត្តព្រះសីហនុ និង គម្រោងអោងចក្រថាមពលអគ្គិសនីស្ទឹងតាតៃ - ប្រព័ន្ធបណ្តាញបញ្ជូនភ្នំពេញ និងគម្រោងខេត្តសៀមរាប - ខេត្តឧត្តរមានជ័យតែប៉ុណ្ណោះ។ ខណៈពេលដែលក្រុមហ៊ុនមិនរំពឹងថា ការពឹងផ្អែកលើអតិថិជនជាក់លាក់ណាមួយច្រើនដែលនោះ វាគឺជាលក្ខណៈនៃអាជីវកម្មរបស់ក្រុមហ៊ុនដែលក្រុមហ៊ុនអាចពឹងផ្អែកលើអតិថិជនជាក់លាក់ណាមួយ ក្នុងកំឡុងពេលវេលាណាមួយនាពេលអនាគត។ ការបាត់បង់អតិថិជនណាមួយ ដោយគ្មានការជំនួសមកវិញ នឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនគិតថាហានិភ័យទាំងនេះអាចកាត់បន្ថយបានដល់កម្រិតជាក់លាក់មួយដោយ៖

១. ក្រុមហ៊ុនយើងមានទំនាក់ទំនងអាជីវកម្មជាមួយ ក្រុមហ៊ុន អាឡិច ខបភើរេសិន តាំងពីឆ្នាំ២០១៤ នៅពេលដែលក្រុមហ៊ុនធ្វើកិច្ចសន្យាគម្រោងភាគខាងលិចរាជធានីភ្នំពេញ-ខេត្តព្រះសីហនុ និងកិច្ចសន្យាកែសម្រួលលក្ខខណ្ឌជាក់លាក់មួយចំនួននៃគម្រោងខាងដើម ជាលទ្ធផលមានការកែប្រែតម្លៃនៃកិច្ចសន្យាទៅជា ១៤៧,៨ លានដុល្លារអាមេរិក។

ឃោងតាមទំនាក់ទំនង និងភាពជឿជាក់របស់ក្រុមហ៊ុនក្នុងការធ្វើជំនួញ ជាមួយក្រុមហ៊ុន អាឡិច ខបភើរេសិន មកទល់ពេលបច្ចុប្បន្ន ក្រុមហ៊ុនបានបន្តចុះកិច្ចសន្យាថ្មីជាមួយ ក្រុមហ៊ុន អាឡិច ខបភើរេសិន នាថ្ងៃទី០៦ មេសា ឆ្នាំ២០១៧ សម្រាប់គម្រោងអោងចក្រវារីអគ្គិសនី ស្ទឹងតាតៃ-ប្រព័ន្ធបណ្តាញបញ្ជូន រាជធានីភ្នំពេញ។ ព័ត៌មានលំអិតបន្ថែមរបស់គម្រោងដែលបានរៀបរាប់ខាងដើម មានក្នុងផ្នែកទី ៤.១.៦ នៃឯកសារផ្តល់ព័ត៌មាននេះ។

២. បទពិសោធន៍របស់ក្រុមហ៊ុនដែលបានផ្តល់ដំណោះស្រាយ និងគុណភាពនៃសេវាកម្មដ៏ល្អប្រសើរ បានធានាការរក្សាទុក និងការទាក់ទាញអតិថិជនថ្មី និង

៣. ដោយបានធានាការចុះកិច្ចសន្យាបន្ថែមពីអតិថិជនផ្សេងទៀត និងបំពេញបន្ថែមការងារគម្រោង ក្រុមហ៊ុនមានលទ្ធភាពកាត់បន្ថយការពឹងផ្អែករបស់ខ្លួន ទៅលើអតិថិជនជាក់លាក់ណាមួយនាពេលអនាគត។

បន្ថែមពីនេះទៀត ក្រុមហ៊ុនបានរក្សា និងបន្តបំពេញតម្រូវការរបស់អតិថិជន ដោយសម្របសម្រួលការងារទៅតាមតម្រូវការរបស់ពួកគេ ដើម្បីធ្វើឱ្យសេវាកម្មរបស់ក្រុមហ៊ុនកាន់តែប្រសើរឡើង។ ទោះបីមានការខិតខំប្រឹងប្រែងរបស់ក្រុមហ៊ុនក្នុងការស្វែងយល់អំពីអតិថិជនយ៉ាងណាក៏ដោយ ក៏មិនអាចធានាបានថាប្រតិបត្តិការ និងដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុននឹងមិនរងផលប៉ះពាល់អវិជ្ជមានពីការពឹងផ្អែករបស់ក្រុមហ៊ុនទៅលើអតិថិជនសំខាន់ៗណាមួយឡើយ។

៣.៤.៨ ការពឹងផ្អែកលើអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការយល់ព្រម ពាក់ព័ន្ធនានាចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសកម្ពុជា

ក. ការវិភាគ

អាជ្ញាធរមានសមត្ថកិច្ចក្នុងប្រទេសដែលយើងកំពុងមានប្រតិបត្តិការ តម្រូវឱ្យក្រុមហ៊ុនមានអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការយល់ព្រមនានាដែលពាក់ព័ន្ធដើម្បីធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ការប្រែប្រួលណាមួយនៃច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយរដ្ឋាភិបាល អាចនាំឱ្យប៉ះពាល់ដល់ដំណើរការប្រតិបត្តិការរបស់ក្រុមហ៊ុន។ រាល់ការសម្រេចណាមួយរបស់រដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងការផ្តល់ និងបន្តអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតរបស់ក្រុមហ៊ុន អាចនឹងរាំងស្ទះដល់ដំណើរការ និងមានផលប៉ះពាល់ធ្ងន់ធ្ងរលើអាជីវកម្ម និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ ទោះបីជាក្រុមហ៊ុន ទទួលបានអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងការយល់ព្រមនានារួចហើយក៏ដោយ ក៏ក្រុមហ៊ុននៅតែស្ថិតក្រោមការត្រួតពិនិត្យស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ហើយការអនុវត្តបែបនេះអាចមានការប្រែប្រួលជារឿយៗ។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

ក្រុមហ៊ុននឹងបន្តការអនុវត្តស្របតាមច្បាប់ និងបទប្បញ្ញត្តិក្នុងប្រទេសដែលយើងកំពុងមានប្រតិបត្តិការ ដោយធានាថាក្រុមហ៊ុននឹងពិនិត្យមើលបទប្បញ្ញត្តិ និងលក្ខខណ្ឌ នានាដែលមាន និងរាល់សេចក្តីបង្គាប់ផ្សេងៗជាប្រចាំ។ ទោះជាយ៉ាងណាក៏ដោយ ក៏ក្រុមហ៊ុនមិនអាចធានាបានឡើយថាការខិតខំប្រឹងប្រែងរបស់ក្រុមហ៊ុនគឺគ្រប់គ្រាន់ សម្រាប់កាត់បន្ថយហានិភ័យទាំងនេះឡើយ។

៣. កត្តាហានិភ័យ (ត)

៣.៥. ហានិភ័យមិនមែនប្រតិបត្តិការ

៣.៥.១ កម្មសិទ្ធិ និងការគ្រប់គ្រងដោយម្ចាស់ភាគហ៊ុនដែលមានសិទ្ធិគ្រប់គ្រង

ក. **ការវិភាគ**

បន្ទាប់ពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុនយើង ក្រុមហ៊ុន PIB នឹងបន្តកាន់កាប់ភាគហ៊ុនភាគច្រើនរបស់ក្រុមហ៊ុន។ ជាលទ្ធផល ក្រុមហ៊ុន PIB នឹងបន្តគ្រប់គ្រងអាជីវកម្ម និង/ឬ មានឥទ្ធិពលយ៉ាងមានប្រសិទ្ធិភាព លើលទ្ធផលនៃបញ្ហា ដែលតម្រូវឱ្យមានការបោះឆ្នោតដោយម្ចាស់ភាគហ៊ុន។

ខ. **ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ**

ក្រុមហ៊ុនបានតែងតាំងអភិបាលឯករាជ្យមួយរូប និងបានបង្កើតគណៈកម្មាធិការសវនកម្មមួយ ដើម្បីធានាថារាល់ការជួញដូរជាមួយភាគីពាក់ព័ន្ធនាពេលអនាគត ត្រូវបានធ្វើឡើងដោយស្មើភាព និង/ឬ ក្រោមលក្ខខណ្ឌពាណិជ្ជកម្មទូទៅមួយ ដែលមិនលំអៀងទៅរកភាគីពាក់ព័ន្ធ ហើយមិនប៉ះពាល់ដល់ផលប្រយោជន៍ម្ចាស់ភាគហ៊ុនភាគតិចរបស់ក្រុមហ៊ុនឡើយ។ ការបង្កើតគណៈកម្មាធិការសវនកម្ម គឺវិពីងថានឹងសម្រួលឱ្យមានការគ្រប់គ្រងល្អ និងបង្កើនតម្លាភាពកាន់តែប្រសើរឡើង។ ក្នុងករណីប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធណាមួយដែលប៉ះពាល់ដល់ផលប្រយោជន៍ម្ចាស់ភាគហ៊ុនដែលមានសិទ្ធិគ្រប់គ្រងនោះ ម្ចាស់ភាគហ៊ុនដែលមានសិទ្ធិគ្រប់គ្រង នឹងអាចត្រូវបានហាមឃាត់មិនឱ្យបោះឆ្នោតស្របតាមច្បាប់ និង/ឬ តាមរយៈគោលការណ៍ពាក់ព័ន្ធ។ បន្ថែមពីលើនេះ ក្រុមហ៊ុនជឿជាក់ថា ម្ចាស់ភាគហ៊ុនដែលមានសិទ្ធិគ្រប់គ្រងនឹងយកផលប្រយោជន៍ក្រុមហ៊ុនជាធំ។

៣.៦. ហានិភ័យហិរញ្ញវត្ថុ រួមបញ្ចូលទាំងហានិភ័យសន្ទនីយភាព និងហានិភ័យឥណទាន

៣.៦.១ ហានិភ័យសន្ទនីយភាព

ក. **ការវិភាគ**

ហានិភ័យសន្ទនីយភាព គឺជាហានិភ័យដែលក្រុមហ៊ុននឹងជួបប្រទះការលំបាកក្នុងការកៀរគរប្រាក់ដើម្បីបំពេញកាតព្វកិច្ចបង់ប្រាក់ក្នុងរយៈពេលខ្លី។

ក្រុមហ៊ុនប្រឈមនឹងហានិភ័យសន្ទនីយភាព ដោយហេតុថា ជាទូទៅក្រុមហ៊ុនពន្យារយៈពេលឥណទានជូនអតិថិជន ហើយក្នុងករណីមួយចំនួន ក្រុមហ៊ុនទទួលបានការបង់ប្រាក់ក្រោយពីរយៈពេលសាងសង់។ ក្នុងករណីនេះ ក្រុមហ៊ុនអាចប្រឈមនឹងហានិភ័យសន្ទនីយភាព ប្រសិនបើក្រុមហ៊ុនមិនអាចផ្គត់ផ្គង់ប្រាក់ចំណាយសាងសង់ និងទិញគ្រឿងយន្ត និងសម្ភារៈសម្រាប់ប្រើប្រាស់នៅក្នុងគម្រោងបាន។ ឧទាហរណ៍ សម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ប្រាក់ដែលត្រូវបង់ពីអតិថិជនលើកិច្ចសន្យាមានចំនួន ១៧៩,១ លានដុល្លារអាមេរិក។ លក្ខខណ្ឌបង់ប្រាក់នេះស្របតាមកិច្ចសន្យា ធ្វើឡើងដោយក្រុមហ៊ុនជាមួយនឹងអតិថិជន។

ម្យ៉ាងវិញទៀត ក្រុមហ៊ុនពឹងផ្អែកលើ ក្រុមហ៊ុន PIB និងបុត្រសម្ពន្ធ័ផ្សេងទៀតដែលនៅក្នុងសម្ព័ន្ធក្រុមហ៊ុនផេសថិក ក្នុងការពន្យារយៈពេលបុរេប្រទានដល់ក្រុមហ៊ុនទៅលើការទិញឧបករណ៍ និងសម្ភារៈប្រើប្រាស់ក្នុងគម្រោង ដើម្បីបំពេញតម្រូវការទុនបង្វិលរបស់ក្រុមហ៊ុន។ ទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុន PIB និងភាគីដែលពាក់ព័ន្ធមានចំនួន ៥០,២ លានដុល្លារអាមេរិក និង ៨២,៦ លានដុល្លារអាមេរិក សម្រាប់ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុន PIB នឹងចាប់ផ្តើមគិតការប្រាក់ចំនួន ៤,៥0% ក្នុងមួយឆ្នាំ ទៅលើទឹកប្រាក់ដែលដល់កំណត់បង់ជូនក្រុមហ៊ុន PIB បន្ទាប់ពីក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិរួចរាល់។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

ក្រុមហ៊ុនព្យាយាមរក្សាសាច់ប្រាក់ និងសាច់ប្រាក់សមមូល គ្រប់គ្រាន់សម្រាប់បំពេញតម្រូវការទុនបង្វិល បន្ទាប់ពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ហើយក្រុមហ៊ុនក៏បានរក្សាទំនាក់ទំនងល្អជាមួយស្ថាប័នហិរញ្ញវត្ថុដែរ។

គោលនយោបាយរបស់ក្រុមហ៊ុន គឺត្រួតពិនិត្យយ៉ាងទៀងទាត់នូវតម្រូវការសាច់ប្រាក់បច្ចុប្បន្ន និងតាមការរំពឹងទុក ដើម្បីធានាការរក្សាបាននូវធនធានគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការសាច់ប្រាក់ទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែង។

បន្ថែមពីនេះទៀត ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជឿជាក់ថា ក្រុមហ៊ុន PIB នឹងបន្តពន្យារយៈពេលបុរេប្រទានដល់ក្រុមហ៊ុនបន្ថែមទៀត សម្រាប់ផ្គត់ផ្គង់សម្ភារៈ និងគ្រឿងបរិក្ខារផ្សេងៗ។ សម្ព័ន្ធក្រុមហ៊ុនផេសថិក ប្តេជ្ញាបន្តផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនដើម្បីបំពេញតាមការប្តេជ្ញាក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុរយៈពេលខ្លី ដែលដល់កំណត់សម្រាប់រយៈពេល១២ខែ គិតចាប់ពីកាលបរិច្ឆេទនៃឯកសារផ្តល់ព័ត៌មាននេះ និងបន្តបន្ថែមទៀតប្រសិនបើចាំបាច់។

ក្រុមហ៊ុននឹងខិតខំប្រឹងប្រែងធ្វើឱ្យមានតុល្យភាពនៃគម្រោង ដែលមានការទូទាត់ប្រាក់រយៈពេលវែង និងគម្រោងដែលមានការទូទាត់ប្រាក់រយៈពេលខ្លី ដើម្បីកាត់បន្ថយបន្ទុកសន្ទនីយភាពលើក្រុមហ៊ុន។

សម្រាប់ព័ត៌មានបន្ថែម លើចំនួនប្រាក់ដែលត្រូវបង់ឱ្យក្រុមហ៊ុន PIB សូមមើល ផ្នែកទី ៧.៥.១ នៃឯកសារផ្តល់ព័ត៌មាននេះ។

៣.៦.២ ហានិភ័យឥណទាន

ក. ការវិភាគ

ក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទាន ដោយហេតុថាជាធម្មតា ក្រុមហ៊ុនចេញវិក្កយបត្រទូទាត់ប្រាក់ទៅឱ្យអតិថិជន ផ្អែកលើដំណាក់កាលនៃការអនុវត្តគម្រោង ឬលក្ខខណ្ឌបង់ប្រាក់ដូចមានចែងក្នុងកិច្ចសន្យាជាមួយអតិថិជន។ លក្ខខណ្ឌបង់ប្រាក់ជាធម្មតាត្រូវបានចរចារវាងគូភាគីនៃកិច្ចសន្យា។

ផលប៉ះពាល់អវិជ្ជមានលើស្ថានភាពសេដ្ឋកិច្ច ឬបញ្ហាផ្នែកហិរញ្ញវត្ថុរបស់អតិថិជនអាចជះឥទ្ធិពលដល់លទ្ធភាពបង់កំរៃសេវាកម្ម ឬបំពេញកាតព្វកិច្ចតាមកិច្ចសន្យា ឬបង្ករការពន្យារពេលបង់ប្រាក់ ឬបំពេញកាតព្វកិច្ចទាំងនោះ។ ក្រុមហ៊ុនពឹងផ្អែកលើអតិថិជនក្នុងការទូទាត់ប្រាក់ទាន់ពេលវេលា។

ក្រុមហ៊ុនមិនធ្លាប់មានបញ្ហាធ្ងន់ធ្ងរណាមួយក្នុងការប្រមូលប្រាក់ ឬបំណុលខូចសម្រាប់ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ឡើយ ទោះជាយ៉ាងណាក្រុមហ៊ុនមិនអាចធានាបានទេថា ក្រុមហ៊ុននឹងមិនជួបប្រទះបញ្ហាបំណុលខូច ឬបញ្ហាទូទាត់ប្រាក់ណាមួយនាពេលអនាគតឡើយ។ ប្រសិនបើក្រុមហ៊ុនជួបប្រទះការពន្យារពេល ឬផលលំបាកណាមួយក្នុងការប្រមូលប្រាក់ពីអតិថិជន ស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់ក្រុមហ៊ុន អាចនឹងរងឥទ្ធិពលអវិជ្ជមានផងដែរ។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនគិតថារបៀបរបបក្នុងការចេញវិក្កយបត្រ គឺធ្វើតាមស្តង់ដារនៃឧស្សាហកម្មនេះ។ អតិថិជនភាគច្រើន ឬអតិថិជនចុងក្រោយរបស់យើង គឺជាក្រុមហ៊ុនរដ្ឋ ហើយយើងក៏បានទទួលបានការបង់ប្រាក់យ៉ាងទៀងទាត់ផងដែរ។

បន្ថែមពីនេះ សម្រាប់ប្រទេសកម្ពុជា បន្ទាប់ពីធ្វើការតំឡើងបណ្តាញចែកចាយ និង/ឬ អនុស្ថានីយ៍ អតិថិជនរបស់ក្រុមហ៊ុននឹងទទួលបានការបង់ប្រាក់ពីអគ្គិសនីកម្ពុជា តាមកិច្ចព្រមព្រៀងសម្បទានពីអគ្គិសនីកម្ពុជា។ ដើម្បីកាត់បន្ថយហានិភ័យផ្នែកឥណទានពីអតិថិជន ក្រុម

ហ៊ុនបានធ្វើការចរចារលើលក្ខខណ្ឌ នៃការបង់ប្រាក់ដោយផ្ទាល់ជាមួយនឹងអគ្គិសនីកម្ពុជា នៅក្នុងគម្រោងជាក់លាក់មួយចំនួន។ ដូច្នេះហើយ ក្រុមហ៊ុនមានទំនុកចិត្តលើ ឥណទានល្អរបស់អគ្គិសនីកម្ពុជា ដែលជាក្រុមហ៊ុនរបស់រដ្ឋ ផ្តត់ផ្តង់អគ្គិសនីលើមួយផ្នែកធំក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុនយើងមិនបានដឹងនោះទេ ថាតើអគ្គិសនីកម្ពុជា ធ្លាប់អាក់ខានបំពេញកាតព្វកិច្ចបង់ប្រាក់របស់ខ្លួនឬយ៉ាងណា។

ជាទូទៅ ក្រុមហ៊ុននឹងផ្តល់រយៈពេលឥណទានវែងដល់អតិថិជនរបស់យើងនៅពេលដែលក្រុមហ៊ុនយើងទទួលបានការរៀបចំបង់ប្រាក់ដោយផ្ទាល់ពីអតិថិជនចុងក្រោយ ដែលជាទូទៅគឺជាក្រុមហ៊ុនអគ្គិសនីរដ្ឋ។

៣.៦.៣ តម្រូវការដើមទុនសាពេលអនាគតដែលទាមទារការធ្វើហិរញ្ញប្បទានបន្ថែម

ក. ការវិភាគ

ក្រុមហ៊ុនអាចមានតម្រូវការគៀរគរមូលនិធិបន្ថែមនាពេលអនាគត តាមរយៈហិរញ្ញប្បទានឯកជន ឬសាធារណៈ ដើម្បីទ្រទ្រង់ការរីកចម្រើនរបស់ក្រុមហ៊ុន ការទិញយកក្រុមហ៊ុនដទៃ ដើម្បីតបនឹងសម្ពាធប្រកួតប្រជែង និង/ឬ ការទិញយកអាជីវកម្ម និងបច្ចេកវិទ្យាបំពេញបន្ថែម។ ក្នុងករណីដែលត្រូវការមូលនិធិបន្ថែម មិនមានការធានាទេថា មូលនិធិបន្ថែមនេះអាចទទួលបានក្នុងលក្ខខណ្ឌល្អឡើយ។ បន្ថែមពីនេះ ការធ្វើហិរញ្ញប្បទានបំណុលណាមួយដែលមានលក្ខខណ្ឌរឹតត្បិត អាចនឹងរឹតត្បិតភាពបត់បែនលើប្រតិបត្តិការរបស់ក្រុមហ៊ុន។ ប្រសិនបើ មូលនិធិបន្ថែមត្រូវបានគៀរគរតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ឬឧបករណ៍ពាក់ព័ន្ធនឹងមូលបត្រកម្មសិទ្ធិ ប្រាក់ចំណេញក្នុងមួយភាគហ៊ុននឹងត្រូវកាត់បន្ថយ ហើយម្ចាស់ភាគហ៊ុន អាចនឹងជួបប្រទះការថយចុះនៃការកាន់កាប់ភាគហ៊ុន នៅក្នុងក្រុមហ៊ុន។ បន្ថែមពីលើនេះ មូលបត្រកម្មសិទ្ធិ ឬឧបករណ៍ពាក់ព័ន្ធនឹងមូលបត្រកម្មសិទ្ធិនោះអាចទទួលបានសិទ្ធិ ជម្រើស ឬសិទ្ធិបុរិមា ច្រើនជាងភាគហ៊ុនដែលមានស្រាប់។ ការមិនអាចទទួលបាននូវមូលនិធិដែលមានលក្ខខណ្ឌធូរស្រាល អាចមានផលប៉ះពាល់អវិជ្ជមានលើអាជីវកម្ម ការប្រកួតប្រជែង និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ខ. **ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ**

ក្រុមហ៊ុនរក្សាទំនាក់ទំនងល្អជាមួយនឹងស្ថាប័នហិរញ្ញវត្ថុ ហើយក្រុមប្រឹក្សាភិបាលគិតថា ក្នុងករណីមានតម្រូវការ ក្រុមហ៊ុនមានលទ្ធភាពក្នុងការទទួលបានសេវាធនាគារជាមួយស្ថាប័នទាំងនោះ។ បន្ថែមពីលើនេះ ក្រុមហ៊ុនរំពឹងថាភាគច្រើននៃលក្ខខណ្ឌហិរញ្ញប្បទានបំណុល របស់ក្រុមហ៊ុននាពេលអនាគត គឺពាក់ព័ន្ធនឹងគម្រោងដែលមានប្រភពទុទាត់សងត្រឹមត្រូវច្បាស់លាស់។

បន្ទាប់ពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង ក្រុមហ៊ុននឹងមានឧបករណ៍គៀរគរមូលធនផ្សេងៗ ដើម្បីបំពេញតម្រូវការមូលធនក្នុងគម្រោងរបស់ក្រុមហ៊ុននាពេលអនាគត។

៣.៧. ហានិភ័យលើបណ្តឹង និងការទទួលខុសត្រូវ

៣.៧.១ ហានិភ័យលើបណ្តឹង

ក. **ការវិភាគ**

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនធ្លាប់មានពាក់ព័ន្ធនឹងបណ្តឹងណាមួយឡើយក្នុងប្រទេសកម្ពុជា។ ប៉ុន្តែ ក្រុមហ៊ុនអាចមានហានិភ័យលើបណ្តឹង និងការអនុវត្តបទប្បញ្ញត្តិផ្សេងៗ នៅក្នុងការអនុវត្តប្រតិបត្តិការអាជីវកម្មរបស់ខ្លួន ជាពិសេសការបំពានកិច្ចព្រមព្រៀងណាមួយនៃកិច្ចសន្យា លក្ខខណ្ឌបរិស្ថាន និងសំណង់ពន្ធដារ និងច្បាប់ការងារពាក់ព័ន្ធនឹងគម្រោង។

រាល់បណ្តឹង ឬការអនុវត្តបទប្បញ្ញត្តិនានា អាចធ្វើឱ្យក្រុមហ៊ុនអាប់ឱនកេរ្តិ៍ឈ្មោះ និងប្រឈមមុខនឹងការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ រាំងស្ទះដល់ប្រភពចំណូល និងការយកចិត្តទុកដាក់គ្រប់គ្រងទៅលើសកម្មភាពអាជីវកម្មប្រចាំថ្ងៃ ហើយអាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ខ. **ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ**

ក្រុមហ៊ុនមិនប្រឈមនឹងបណ្តឹងណាមួយ ដែលអាចមានឥទ្ធិពលអវិជ្ជមានលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។ ក្រុមហ៊ុនតែងតែខិតខំប្រឹងប្រែងអនុវត្តអាជីវកម្ម ដោយអនុលោមតាមច្បាប់ជាធរមាន និងការអនុវត្តល្អៗនានា នៅក្នុងឧស្សាហកម្មរបស់ក្រុមហ៊ុន។

៣.៧.២ ទទាទពន្ធដារ

ក. ការវិភាគ

នាឆ្នាំ២០១១ អគ្គនាយកដ្ឋានពន្ធដារ បានចេញសេចក្តីជូនដំណឹងមួយអំពីការកំណត់ពន្ធឡើងវិញលើក្រុមហ៊ុនបន្ទាប់ពីការធ្វើសវនកម្មពន្ធដារមានកម្រិត ដែលមានចំនួន ៥៤៦.៩៧១ ដុល្លារអាមេរិក (ស្មើនឹងចំនួន ២.២២២ លានរៀល) ដើម្បីទាមទារប្រាក់ពន្ធលើប្រាក់ចំណេញ និងអាករលើតម្លៃបន្ថែម ដែលបានចោទថាមិនបានប្រកាសសម្រាប់រយៈពេលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១១ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១១។

នាឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារ បានចេញសេចក្តីជូនដំណឹងមួយអំពីការកំណត់ពន្ធឡើងវិញលើក្រុមហ៊ុនបន្ទាប់ពីការធ្វើសវនកម្មពន្ធដារមានកម្រិត ដែលមានចំនួន ៤៩០.៩១២ ដុល្លារអាមេរិក (ស្មើនឹងចំនួន ១.៩៩៥ លានរៀល) ដើម្បីទាមទារប្រាក់ពន្ធលើប្រាក់ចំណេញ និងពន្ធអាករលើតម្លៃបន្ថែមដែលបានចោទថាមិនបានប្រកាសសម្រាប់រយៈពេលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ ដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣។

នាឆ្នាំ២០១៧ អគ្គនាយកដ្ឋានពន្ធដារ បានចេញសេចក្តីជូនដំណឹងមួយអំពីការកំណត់ពន្ធឡើងវិញលើក្រុមហ៊ុនបន្ទាប់ពីការធ្វើសវនកម្មពន្ធដារពេញលេញ ក្នុងឆ្នាំសារពើពន្ធ ២០១០ ដែលមានចំនួន ២៦៧.៩៥៦ ដុល្លារអាមេរិក (ស្មើនឹងចំនួន ១.០៨៨ លានរៀល) ដើម្បីទាមទារប្រាក់ពន្ធលើប្រាក់ចំណេញ អាករលើតម្លៃបន្ថែម និងពន្ធកាត់ទុក ដែលបានចោទថាមិនបានប្រកាសក្នុងឆ្នាំសារពើពន្ធ។

អគ្គនាយកដ្ឋានពន្ធដារ បានធ្វើសវនកម្មពន្ធដារលម្អិតពេញលេញលើក្រុមហ៊ុន ក្នុងឆ្នាំសារពើពន្ធ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៦។ គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ការកំណត់ពន្ធឡើងវិញចុងក្រោយសម្រាប់រយៈពេល មិនទាន់ទទួលបានសេចក្តីជូនដំណឹងឡើយ។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

ក្រុមហ៊ុនបានឆ្លើយតបដោយដាក់លិខិតតវ៉ាទៅកាន់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីតវ៉ានឹងការកំណត់ពន្ធឡើងវិញដែលមានការភាន់ច្រឡំនេះ។ ថ្នាក់គ្រប់គ្រងយើងយល់ឃើញថាការកំណត់ពន្ធឡើងវិញខាងលើ មិនមានមូលដ្ឋានច្បាស់លាស់ និងមិនត្រឹមត្រូវ ហើយប្រូបាបដែលក្រុមហ៊ុន តម្រូវក្នុងការទូទាត់ការវាយតម្លៃពន្ធនោះមានតិចបំផុត។ គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ការតវ៉ានេះនៅមានបន្តនៅឡើយ។

ផ្ទុយពីការរៀបរាប់ខាងលើ យោងទៅលើអនុក្រឹតលេខ០១ អនក្រ. បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រកម្ពុជា នឹងទទួលបានការលើកទឹកចិត្ត រួមមាន ការអនុគ្រោះបំណុលពន្ធពីអតីតកាល ការកាត់បន្ថយពន្ធលើប្រាក់ចំណូល ពន្ធកាត់ទុក អាករលើតំលៃបន្ថែម អាករពិសេសលើទំនិញ និងសេវាកម្មមួយចំនួន អាករស្នាក់នៅ និងអាករបំភ្លឺផ្លូវ ចាប់ពីកាលបរិច្ឆេទ N-៣ (ឆ្នាំ N ជាឆ្នាំដែលក្រុមហ៊ុនធ្វើការបោះផ្សាយលក់មូលបត្រជាលើកដំបូង)។

ក្រុមហ៊ុនកំពុងបន្តចរចារជាមួយនឹងអគ្គនាយកដ្ឋានពន្ធដារ ដើម្បីឈានដល់ការទូទាត់មួយដែលស្របតាមច្បាប់ពន្ធនៃព្រះរាជាណាចក្រកម្ពុជា។ រាល់ការទូទាត់ដល់អគ្គនាយកដ្ឋានពន្ធដារពាក់ព័ន្ធនឹងករណីនេះ នឹងប៉ះពាល់ដល់ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ឆ្នាំណាមួយ។

៣.៨. ហានិភ័យពាក់ព័ន្ធនឹងការវនិយោគលើមូលបត្រ

៣.៨.១. សកម្មភាពជួញដូរដែលមានកម្រិតក្នុងផ្សារមូលបត្រកម្ពុជា

ក. ការវិភាគ

ផ្សារមូលបត្រកម្ពុជា គឺជាទីផ្សារភាគហ៊ុនថ្មីមួយ ហើយការចូលរួមរបស់ វិនិយោគិននៅមានកម្រិតនៅឡើយ។ ដូច្នេះហើយ សកម្មភាពជួញដូរ ភាគហ៊ុនរបស់ក្រុមហ៊ុនដទៃ និងភាគហ៊ុនរបស់ក្រុមហ៊ុនយើង នាកាលបរិច្ឆេទជាក់លាក់ ឬនៅក្នុងអំឡុងពេលណាមួយអាចនៅមានកម្រិត ។ ហេតុនេះ វិនិយោគិនអាចនឹងមិនអាចធ្វើការជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុន ទៅតាមចំនួន និងតម្លៃដែលខ្លួនចង់បានឡើយ។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ផ្សារមូលបត្រកម្ពុជា បានធ្វើប្រតិបត្តិការអស់រយៈពេលប្រាំបួន (០៩) ឆ្នាំ ហើយមានការពង្រីកបន្ថែម សន្សឹមៗនៃចំនួនក្រុមហ៊ុនដែលបានចុះបញ្ជី និងចំនួនវិនិយោគិនសាធារណៈ។ ក្រុមហ៊ុនសង្កេតឃើញថាការជួញដូរនៅក្នុងទីផ្សារនឹងប្រសើរឡើងជាបន្តបន្ទាប់ នៅពេលក្រុមហ៊ុនកាន់តែច្រើនចូលរួមក្នុងផ្សារមូលបត្រកម្ពុជា ដែលនឹងទាក់ទាញវិនិយោគិនកាន់តែច្រើនឱ្យចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា។

ក្រុមហ៊ុននឹងស្វែងរកការបង្កើតនូវមុខងារទំនាក់ទំនង ជាមួយនឹងវិនិយោគិនឱ្យបានល្អ ដើម្បីធានាបានការចែកចាយព័ត៌មានដ៏មានប្រសិទ្ធិភាព ទៅកាន់វិនិយោគិនសាធារណៈ និងការយល់ដឹងរបស់គេពីក្រុមហ៊ុន ក៏ដូចជាភាគហ៊ុនរបស់ក្រុមហ៊ុនដែរ។

បន្ថែមពីលើនេះ ក្រុមហ៊ុននឹងស្វែងរកឱកាសបោះផ្សាយលើកទីពីរ (secondary listing) លើផ្សារភាគហ៊ុនប្រទេសថៃបន្ទាប់ពីការបោះផ្សាយនេះ ដើម្បីពង្រីកចំនួនវិនិយោគិន និងលើកស្ទួយសកម្មភាពជួញដូរភាគហ៊ុនក្រុមហ៊ុនយើង។

ទោះបីដូចបានរៀបរាប់ខាងលើក៏ដោយ ក៏គ្មានការធានានោះទេ ដែលថាភាគហ៊ុនរបស់ក្រុមហ៊ុននឹងតែងតែត្រូវបានជួញដូរយ៉ាងសកម្ម នៅក្នុងទីផ្សារ។

៣.៨.២. កង្វះខាតទីផ្សារដែលមានស្រាប់សម្រាប់ភាគហ៊ុនរបស់ក្រុមហ៊ុន

ក. ការវិភាគ

នៅមុនការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គ្មានទីផ្សារសាធារណៈសម្រាប់លក់ភាគហ៊ុនរបស់ក្រុមហ៊ុនទេ។ ដូច្នេះហើយ ទោះមានការចុះបញ្ជីលក់មូលបត្រក៏ដោយ ក៏គ្មានការធានាដែលថាទីផ្សារភាគហ៊ុនរបស់ក្រុមហ៊ុននឹងត្រូវបានជួញដូរយ៉ាងសកម្ម ឬបើទោះជួញដូរយ៉ាងសកម្ម ក៏មិនប្រាកដដែរថាការជួញដូរនោះនឹងមានចីរភាព។ តម្លៃបោះផ្សាយ ត្រូវបានកំណត់ដោយពិចារណាលើកត្តាជាច្រើន ហើយ ក្រុមហ៊ុនគិតថាកត្តាមួយចំនួន អាចបង្កឱ្យតម្លៃភាគហ៊ុនរបស់ក្រុមហ៊ុនមានការ ប្រែប្រួល។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

គ្មានការធានាទេថា តម្លៃទីផ្សារនៃភាគហ៊ុនរបស់ក្រុមហ៊ុននឹងមិនធ្លាក់ចុះក្រោមតម្លៃនាពេលបោះផ្សាយឡើយ។ កត្តាមួយចំនួនដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន អាចធ្វើឱ្យតម្លៃភាគហ៊ុនរបស់ក្រុមហ៊ុនធ្លាក់ចុះ រួមមានជាអាទិ៍ ការលក់មួយចំនួនធំនៃភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងទីផ្សារសាធារណៈនាពេលអនាគត ការផ្សព្វផ្សាយពីការវិវឌ្ឍពាក់ព័ន្ធនឹងអាជីវកម្មក្រុមហ៊ុន ការប្រែប្រួលនៃលទ្ធផលប្រតិបត្តិការក្រុមហ៊ុន លក្ខខណ្ឌឧស្សាហកម្មទូទៅ ឬស្ថានភាពនៃសេដ្ឋកិច្ចពិភពលោក។

៣.៨.៣. បរាជ័យ ឬការពន្យារពេលនៃការចុះបញ្ជីលក់មូលបត្រ

ក. **ការវិភាគ**

ការកើតឡើងនៃព្រឹត្តិការណ៍ណាមួយខាងក្រោម អាចបង្កឱ្យមានការពន្យារពេល ឬបរាជ័យក្នុងការចុះបញ្ជីលក់មូលបត្ររបស់ក្រុមហ៊ុន៖

១. គ.ម.ក និង/ឬ ផ.ម.ក អាចមិនយល់ព្រមលើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លើកដំបូង។

២. ក្រុមហ៊ុនធានាទិញមូលបត្រ អនុវត្តសិទ្ធិស្របតាមកិច្ចព្រមព្រៀងធានាទិញមូលបត្រដោយរួចផុតពីកាតព្វកិច្ចនានាដែលខ្លួនមាន។

ខ. **ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ឈៀសហានិភ័យ**

ក្រុមប្រឹក្សាភិបាល និងក្រុមហ៊ុនធានាទិញមូលបត្រ នឹងខិតខំប្រឹងប្រែងស្នើសុំការអនុញ្ញាតពី គ.ម.ក និង ផ.ម.ក សម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុន និងធានាថាក្រុមហ៊ុនអាចបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ក្រុមហ៊ុនដោយជោគជ័យ។

ក្នុងករណីបរាជ័យក្នុងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក ក្រុមហ៊ុននឹងធ្វើការប្រកាសលុបចោលភ្លាមនូវឯកសារផ្តល់ព័ត៌មាន តាមរយៈសារព័ត៌មាន ដែលទទួលស្គាល់ដោយអគ្គនាយកនៃគ.ម.ក។ រាល់ទឹកប្រាក់ទាំងឡាយដែល លោកអ្នកបានបង់អំឡុងពេលការដាក់ពាក្យត្រូវបានទទួលស្គាល់ នឹងត្រូវសងវិញទាំងស្រុងដោយមិនមានការប្រាក់ ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃប្រកាសលុបចោលនោះ។

៣.៩. ហានិភ័យដទៃទៀត

៣.៩.១. ការផ្តល់ព័ត៌មានចាក់ចងនឹងសេចក្តីថ្លែងការណ៍ពីអនាគត

ក. **ការវិភាគ**

ឯកសារផ្តល់ព័ត៌មាននេះមានផ្ទុកសេចក្តីថ្លែងការណ៍ពីអនាគតដែលផ្អែកលើទិន្នន័យអតីតកាល ដែលអាចនឹងមិនធ្លុះបញ្ចាំងអំពីប្រតិបត្តិការក្រុមហ៊ុននាពេលអនាគតឡើយ ក្រៅពីនេះគឺជាការព្យាករណ៍លើបរិបទដែលជាកម្មវត្ថុនៃភាពមិនច្បាស់លាស់ និងកត្តាពាក់ព័ន្ធនានា។ សេចក្តីថ្លែងការណ៍ពីអនាគតនេះ រួមមានហានិភ័យដែលបានដឹង និងមិនបានដឹង ភាពមិនច្បាស់លាស់ និងកត្តាដទៃទៀតដែលអាចបង្កឱ្យលទ្ធផលប្រតិបត្តិការ ឬសមិទ្ធផល

ជាក់ស្តែង មានលក្ខណៈខុសគ្នាច្រើនពីលទ្ធផលប្រតិបត្តិការ ឬសមិទ្ធផលនាពេលអនាគត ដូចបានបញ្ជាក់ ឬស្តែងឡើងចេញពីសេចក្តីថ្លែងការណ៍ពីអនាគតទាំងនោះ។

សេចក្តីថ្លែងការណ៍ពីអនាគតទាំងនោះ ផ្អែកលើការសន្មត់ជាច្រើន ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រអាជីវកម្មក្នុងពេលបច្ចុប្បន្ន និងអនាគត មជ្ឈដ្ឋានដែលយុទ្ធសាស្ត្រអាជីវកម្មបច្ចុប្បន្ន និងអនាគតត្រូវបានបង្កើត និងមជ្ឈដ្ឋានប្រតិបត្តិការនាពេលអនាគតរបស់ក្រុមហ៊ុន។

ខ. ទស្សនៈរបស់ថ្នាក់គ្រប់គ្រង និងការបញ្ជៀសហានិភ័យ

ទោះបីក្រុមហ៊ុនគិតថា ការរំពឹងទុកដូចបានឆ្លុះបញ្ចាំងក្នុងសេចក្តីថ្លែងការណ៍ពីអនាគតទាំងនោះ មានលក្ខខណៈសមហេតុផលនាពេលនេះ ក៏ដោយ ក៏ក្រុមហ៊ុនមិនអាចធានាបានទេថាការរំពឹងទុកទាំងនោះគឺត្រឹមត្រូវជាក់លាក់នោះដែរ។ តើសេចក្តីថ្លែងការណ៍ទាំងនេះត្រូវបានបញ្ជាក់ថាត្រឹមត្រូវ ឬយ៉ាងណា គឺពឹងផ្អែកទៅលើកត្តាជាច្រើនដែលអាចមានឥទ្ធិពលលើអាជីវកម្ម និងប្រតិបត្តិការរបស់ក្រុមហ៊ុន។

ពាក់ព័ន្ធនឹងភាពមិនច្បាស់លាស់ទាំងនេះ ការបញ្ចូលនូវសេចក្តីថ្លែងការណ៍ពីអនាគតនៅក្នុងឯកសារផ្តល់ព័ត៌មាននេះ មិនគួរត្រូវបានចាត់ទុកថាជាការអះអាង ឬការធានា ដោយក្រុមហ៊ុន ឬក្រុមហ៊ុនធានាទិញមូលបត្រ ទៅលើផែនការរបស់ក្រុមហ៊ុន និងគោលដៅអាជីវកម្មរបស់ក្រុមហ៊ុនថានឹងបានទទួលជោគជ័យឡើយ

៤. ព័ត៌មានរបស់ក្រុមហ៊ុន

៤.១. ការពិពណ៌នាអំពីចុះកច្ច

៤.១.១. សាខតារបស់ក្រុមហ៊ុន

ក្រុមហ៊ុនផេសថិក (ខេមបូឌា) ពីមុនមានឈ្មោះថា Tajri-Pestech JV Limited និងបានចុះបញ្ជីនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០ ជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតនៅព្រះរាជាណាចក្រកម្ពុជា ហើយក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការក្នុងឆ្នាំដដែល។ ក្រុមហ៊ុនបានអនុម័តប្រើឈ្មោះផេសថិក (ខេមបូឌា) ឯ.ក ដែលជាឈ្មោះមុនរបស់ក្រុមហ៊ុន នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ ហើយប្រើប្រាស់ឈ្មោះ និងទម្រង់ក្រុមហ៊ុនបច្ចុប្បន្នរបស់យើង នៅពេលដែលការកែប្រែរចនាសម្ព័ន្ធផ្ទៃក្នុងសម្រេចអនុម័តដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។ ក្រុមហ៊ុនយើង គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលត្រូវបានកាន់កាប់ទាំងស្រុងដោយក្រុមហ៊ុន PIB ដែលបានចុះបញ្ជី និងមានអាសយដ្ឋាននៅប្រទេសម៉ាឡេស៊ី ហើយបានចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោលនៃផ្សារភាគហ៊ុនប្រទេសម៉ាឡេស៊ី Bursa Malaysia Securities Berhad។

ក្រុមហ៊ុនយើង ជាក្រុមហ៊ុនបច្ចេកទេសថាមពលអគ្គិសនី។ ក្រុមហ៊ុនផ្តល់សេវាកម្មចំបងលើការផ្តល់ជូននូវវិស្វកម្មប្រព័ន្ធថាមពល និងដំណោះស្រាយ បច្ចេកទេសសម្រាប់៖

- ការគួសបង្ហិ លទ្ធកម្ម ការសាងសង់ ការដំឡើង និងការដាក់ឱ្យប្រើប្រាស់នូវអនុស្ថានីយ៍មានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង និងបណ្តាញបញ្ជូនអគ្គិសនីដែលមានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ក៏ដូចជាប្រព័ន្ធថាមពលខ្សែកាបក្រោមដីសម្រាប់ការបញ្ជូន និងការចែកចាយអគ្គិសនី និង
- ការជួញដូរបង្គុំ និងបរិក្ខារប្រព័ន្ធថាមពលដែលមាន និងមិនមានបំពាក់ពាណិជ្ជសញ្ញា ។

ក្រុមហ៊ុន PESTECH (Myanmar) ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតបង្កើតឡើងក្រោមច្បាប់ក្រុមហ៊ុនរបស់ប្រទេសមីយ៉ាន់ម៉ា។ ក្រុមហ៊ុន PESTECH (Myanmar) ជាក្រុមហ៊ុនផ្តត់ផ្គង់វិស្វកម្មប្រព័ន្ធថាមពលចម្រុះ និងដំណោះស្រាយបច្ចេកទេសចម្រុះសម្រាប់ ការរចនា លទ្ធកម្ម ការសាងសង់ និងសេវាពាក់ពន្ធនឹងឧស្សាហកម្មអគ្គិសនី។

PESTECH Hinthar ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ (60%) ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតបង្កើតឡើងក្រោមច្បាប់ក្រុមហ៊ុនរបស់ប្រទេសមីយ៉ាន់ម៉ា។ PESTECH Hinthar ជាក្រុមហ៊ុនផ្តត់ផ្គង់វិស្វកម្មប្រពន័ន្ធថាមពលទូលំទូលាយ ការសាងសង់ និងគួសបង្ហិ ការដំឡើង និងសេវាពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យថាមពលអគ្គិសនី។

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

PESTECH Microgrid ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ (90%) ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតបង្កើតឡើងក្រោមច្បាប់ក្រុមហ៊ុនរបស់ប្រទេសមីយ៉ាន់ម៉ា។ PESTECH Microgrid ជាក្រុមហ៊ុនផ្តត់ផ្តង់វិស្វកម្មប្រព័ន្ធថាមពលខ្នាតតូច និងហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនីតាមបណ្តាជនបទរបស់របស់ប្រទេសមីយ៉ាន់ម៉ា។

ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងទំនិញ និងសេវាកម្មគោលរបស់ក្រុមហ៊ុន មានរៀបរាប់នៅផ្នែកទី ៤.១.៦ នៃឯកសារផ្តល់ព័ត៌មាននេះ។

រូបក្រាម*ខាងក្រោមនេះបង្ហាញពីរចនាសម្ព័ន្ធរបស់ក្រុមហ៊ុនពីមុន និងបច្ចុប្បន្ន៖

រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនមុនពេលការរៀបចំផ្នែកក្នុងឡើងវិញ



រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនបន្ទាប់ពីការរៀបចំផ្នែកក្នុងឡើងវិញ



ចំណាំ៖

^ *បញ្ជាក់ពីកម្មសិទ្ធិលើភាគហ៊ុនរបស់ក្រុមហ៊ុនមេដែលមានដៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ*

* *ការបង្ហាញខាងលើពុំបានរួមបញ្ចូលក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់របស់ក្រុមហ៊ុន PIB ទេ*

៤.១.២. ការរៀបចំផ្នែកក្នុងឡើងវិញ

ដោយភ្ជាប់ជាមួយ និងជាផ្នែកសំខាន់នៅក្នុងការចុះបញ្ជីលក់មូលបត្ររបស់ក្រុមហ៊ុនយើង ក្រុមហ៊ុនបានអនុវត្ត និងបញ្ចប់ការរៀបចំផ្នែកក្នុងឡើងវិញដូចខាងក្រោម៖

ក. ការផ្ទេរភាគហ៊ុន

ភាគហ៊ុនទាំងអស់របស់ក្រុមហ៊ុន ដែលកាន់កាប់ដោយក្រុមហ៊ុន PSB ត្រូវបានផ្ទេរទៅឱ្យ ក្រុមហ៊ុន PIB មានតម្លៃតំណាងចំនួន ១.000 ដុល្លារអាមេរិក នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨។ ជាលទ្ធផលនៃការផ្ទេរភាគហ៊ុន ក្រុមហ៊ុន PIB បានក្លាយជាក្រុមហ៊ុនហូលឌីងកាន់កាប់ផ្តាល់លើក្រុមហ៊ុនយើង។

ខ. ការបង្កើនដើមទុនបោះផ្សាយ និងបង់រួចរាល់

ដើមទុនបោះផ្សាយនិងបង់រួចរាល់ បានកើនឡើងពី ៤ លានរៀល ឬស្មើនឹង ១.000 ដុល្លារអាមេរិក តំណាងឱ្យ១.000 ភាគហ៊ុនដែលមានតម្លៃចារឹកស្មើនឹង ៤.000 រៀល ឬស្មើនឹង ១,00 ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន ទៅជា ២៨,៤ ពាន់លានរៀល ឬស្មើនឹង ៧,១ លានដុល្លារអាមេរិក ដែលតំណាងដោយ ៧១ លានភាគហ៊ុន ដែលមានតម្លៃចារឹកស្មើនឹង ៤00 រៀល ឬស្មើនឹង 0,១0 ដុល្លារ អាមេរិកក្នុងមួយភាគហ៊ុន។

ការបង្កើនភាគហ៊ុននេះធ្វើឡើងតាមរយៈការបំបែកភាគហ៊ុនពី ១.000 ភាគហ៊ុន មានតម្លៃចារឹក ១,00 ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុនទៅជា ១0.000 ភាគហ៊ុន មានតម្លៃចារឹក 0,១0 ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន និងធ្វើមូលធននីយកម្មប្រមាណ ៧,១ លានដុល្លារអាមេរិក រួមមានទឹកប្រាក់ជំពាក់ទៅក្រុមហ៊ុន PIB ចំនួន ៥លានដុល្លារអាមេរិក និងប្រាក់ចំណេញដែលរក្សាទុកចំនួនប្រមាណ ២,១ លានដុល្លារអាមេរិក ទៅជាដើមទុន ដែលតំណាងឱ្យភាគហ៊ុនប្រមាណ ៧១ លានភាគហ៊ុនមានតម្លៃចារឹក 0,១0 ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន។

គ. ការផ្លាស់ប្តូរទម្រង់ច្បាប់របស់ក្រុមហ៊ុន

ទម្រង់របស់ក្រុមហ៊ុនត្រូវបានផ្លាស់ប្តូរពីក្រុមហ៊ុនឯកបុគ្គលទទួលខុសត្រូវមានកម្រិតទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។

ការរៀបចំផ្នែកក្នុងឡើងវិញត្រូវបានអនុញ្ញាតដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។

៤.១.៣. ប្រវត្តិរបស់ក្រុមហ៊ុន

ក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្មនៅខែកុម្ភៈ ឆ្នាំ២០១០ នៅពេលដែលក្រុមហ៊ុនបានចុះកិច្ចសន្យាមួយពាក់ព័ន្ធនឹងការសាងសង់អនុស្ថានីយ៍ដែលមានតង់ស្យុងខ្ពស់ និងការតភ្ជាប់បណ្តាញបញ្ជូនដែលមានតង់ស្យុងខ្ពស់ រវាងបណ្តាញបញ្ជូនអគ្គិសនីភាគខាងជើងរាជធានីភ្នំពេញ ទៅខេត្តកំពង់ចាមនៅក្នុងព្រះរាជាណាចក្រកម្ពុជា (គម្រោងរាជធានីភ្នំពេញភាគខាងជើង - ខេត្តកំពង់ចាម) ពីក្រុមហ៊ុន ខេមបូឌាន ត្រែនមីសិន លីមីធីត (Cambodian Transmission Limited)។ គម្រោងនេះរួមបញ្ចូលទាំងការគូសបន្ទង់ ការសាងសង់ ការសាកល្បង និងការដាក់ឱ្យប្រើប្រាស់ខ្សែបណ្តាញបញ្ជូនអគ្គិសនីប្រវែង ១១០ គីឡូម៉ែត្រ * មានតង់ស្យុង ២៣០ គីឡូវ៉ុល ដែលមានខ្សែបញ្ជូននៃសៀគ្វីចំនួនពីរ ពីរាជធានីភ្នំពេញទៅខេត្តកំពង់ចាម រួមជាមួយនឹងបរិក្ខារសម្រាប់អនុស្ថានីយ៍ពីរ (០២) និងការធ្វើឱ្យដំណើរការកាន់តែប្រសើរឡើង។

កំណត់សម្គាល់៖

* *ចម្ងាយពិតប្រាកដនៃខ្សែបណ្តាញបញ្ជូនអគ្គិសនីរបស់គម្រោងពីរាជធានីភ្នំពេញភាគខាងជើង ទៅខេត្តកំពង់ចាម បានបញ្ចប់ត្រឹមចម្ងាយ ៩៧,១៨ គីឡូម៉ែត្រ។ ការវាស់វែងសម្រាប់ការសាងសង់ខ្សែបណ្តាញបញ្ជូនចាមពលអគ្គិសនី ជាទូទៅខុសគ្នាទៅនឹងប្រវែងមានកំណត់ក្នុងគម្រោងដើម ដោយសារតែមានភាពខុសគ្នាក្នុងការប្រើប្រាស់ផ្លូវជាក់ស្តែង។*

ក្រុមហ៊ុនបានបញ្ចប់ និងប្រគល់គម្រោងរាជធានីភ្នំពេញភាគខាងជើង - ខេត្តកំពង់ចាម ទៅឱ្យម្ចាស់គម្រោងគឺក្រុមហ៊ុន ខេមបូឌាន ត្រែនមីសិន លីមីធីត ដោយជោគជ័យនៅក្នុងខែឧសភា ឆ្នាំ២០១៣។ គម្រោងនេះបានបង្ហាញពីព្រឹត្តិការណ៍សំខាន់មួយរបស់ក្រុមហ៊ុនយើង ដោយក្រុមហ៊ុនបានបញ្ចប់គម្រោងប្រាំបី (០៨) ខែមុនកាលកំណត់។

បន្ថែមពីនេះទៀត នៅខែមិនា ឆ្នាំ២០១២ ក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយនឹងក្រុមហ៊ុនអគ្គិសនីកម្ពុជា ពាក់ព័ន្ធនឹងការសាងសង់ខ្សែបណ្តាញបញ្ជូនដែលមានតង់ស្យុង ១១៥ គីឡូវ៉ុល តភ្ជាប់ពីអនុស្ថានីយ៍របស់ក្រុមហ៊ុន ខេមបូឌាន ផៅវែរ ប្រ៊ីត ("CPG") មានតង់ស្យុង ២៣០/១១៥ គីឡូវ៉ុល ទៅកាន់អនុស្ថានីយ៍របស់ក្រុមហ៊ុន ខេមបូឌា ផៅវែរ ត្រែនមីសិន ឡាញ ("CPTL") មានតង់ស្យុង ១១៥/២២ គីឡូវ៉ុលនៅខេត្តបាត់ដំបងដែលមានប្រវែង ០,៩៧ គីឡូម៉ែតក្នុងតម្លៃ ២២៣.៤០៧ ដុល្លារអាមេរិក (គម្រោងខេត្តបាត់ដំបង)។ គម្រោងនេះពាក់ព័ន្ធទៅនឹងការគូសបន្ទង់ វិស្វកម្ម ការផ្គត់ផ្គង់សម្ភារៈ និងការតម្លើងខ្សែបណ្តាញបញ្ជូនអគ្គិសនី។ ក្រុមហ៊ុនបានបញ្ចប់គម្រោងនេះជាស្ថាពរនៅខែសីហា ឆ្នាំ ២០១២។

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

នៅឆ្នាំ២០១៤ ក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយនឹងក្រុមហ៊ុន អាឡិច ដែលជាក្រុមហ៊ុនផ្តល់សេវាកម្មច្រើនប្រភេទនៅកម្ពុជា។ កិច្ចសន្យានេះពាក់ព័ន្ធនឹងការគូសប្តង់ វិស្វកម្ម ការតម្លើង ការសាកល្បង និងការដាក់ឱ្យប្រើប្រាស់នូវគម្រោងរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ៖

- ខ្សែបញ្ជូនរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ ដែលមានតង់ស្យុង២៣០ គីឡូវ៉ុល និង
- គម្រោងពង្រីកអនុស្ថានីយ៍មានតង់ស្យុង ២៣០/១១៥/២២គីឡូវ៉ុល។

គម្រោងនេះពាក់ព័ន្ធនឹងការសាងសង់ខ្សែបណ្តាញបញ្ជូនមួយមានប្រវែងប្រហែល ១៩០ គីឡូម៉ែត្រ ដែលបញ្ជូនអគ្គិសនីពីអោងចក្រផលិតថាមពលនៅខេត្តព្រះសីហនុទៅរាជធានីភ្នំពេញ។ គម្រោងនេះពាក់ព័ន្ធនឹងការធ្វើឱ្យប្រសើរឡើងនូវអនុស្ថានីយ៍ដែលមានស្រាប់នៅស្ទឹងហាវ ជាមួយច្រកភ្ជាប់បណ្តាញ (outgoing transmission bay) ថ្មីចំនួនពីរ (០២) ដែលមានតង់ស្យុង២៣០គីឡូវ៉ុល ហើយត្រូវភ្ជាប់ទៅអនុស្ថានីយ៍រាជធានីភ្នំពេញភាគខាងលិចនៅក្នុងរាជធានីភ្នំពេញ តាមរយៈខ្សែបណ្តាញបញ្ជូនថ្មីដែលមានតង់ស្យុង២៣០ គីឡូវ៉ុល ដែលនឹងត្រូវសាងសង់ក្នុងគម្រោងនេះ។

នៅខែឧសភា ឆ្នាំ២០១៥ ក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយនឹងក្រុមហ៊ុន ដាយអ៊ីមុិន ផៅវ៉ែរ ដើម្បីអនុវត្តគម្រោងខេត្តកំពង់ចាម - ខេត្តក្រចេះ។ គម្រោងនេះពាក់ព័ន្ធ នឹងការគូសប្តង់ វិស្វកម្ម ការសាកល្បង ការតម្លើង និងការដាក់ឱ្យប្រើប្រាស់ទីធ្លាភ្ជាប់ផ្តាច់ចរន្តដែលមានតង់ស្យុង២៣០ គីឡូវ៉ុល ក្នុងអនុស្ថានីយ៍ដែលមានស្រាប់នៅខេត្តកំពង់ចាម និងអនុស្ថានីយ៍ថ្មីដែលមានតង់ស្យុង ២៣០/២២ គីឡូវ៉ុលនៅខេត្តក្រចេះ និងការតភ្ជាប់ខ្សែបណ្តាញបញ្ជូនមួយមានប្រវែង១២៥គីឡូម៉ែត្រ ពីអនុស្ថានីយ៍ខេត្តកំពង់ចាម ទៅអនុស្ថានីយ៍ខេត្តក្រចេះ។ ក្រុមហ៊ុនបានបញ្ចប់ដោយជោគជ័យគម្រោងនេះនៅខែវិច្ឆិកា ឆ្នាំ២០១៧។

បន្ថែមពីនេះទៅទៀត នៅឆ្នាំដដែលនេះ ក្រុមហ៊ុនបានបញ្ចប់គម្រោងមួយនៅ រដ្ឋ Sarawak នៃប្រទេសម៉ាឡេស៊ី ដែលក្រុមហ៊ុនបានផ្តល់សេវាកម្មលើការគ្រប់គ្រងគម្រោង និងការគ្រប់គ្រងសំណង់ស៊ីវិល សម្រាប់ការសាងសង់អនុស្ថានីយ៍ដែលមានតង់ស្យុង ២៧៥/៣២គីឡូវ៉ុល និង ១៣២/១១គីឡូវ៉ុល (គម្រោង Sarawak)។ គម្រោងនេះគឺជាកិច្ចសន្យាម៉ៅការបន្តរបស់ក្រុមហ៊ុន PSB ក្នុងតម្លៃ៣២០.០០០ ដុល្លារអាមេរិក។

ក្រោយមក នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ការកែប្រែកិច្ចសន្យា ត្រូវបានធ្វើឡើងមុនកាលកំណត់ជាមួយនឹងក្រុមហ៊ុនអាឡិច ដើម្បីធ្វើឱ្យប្រសើរឡើងនូវលក្ខណៈរបស់គម្រោងរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ។ តាមរយៈការធ្វើវិសោធនកម្មកិច្ចសន្យានេះ ការធ្វើឱ្យប្រសើរឡើងនូវការងាររួមមាន ការគូសប្តង់ វិស្វកម្ម ការសាកល្បង ការតម្លើង និងការដាក់ឱ្យប្រើប្រាស់៖

- សៀគ្វីពីរសម្រាប់ខ្សែបណ្តាញបញ្ជូនមានតង់ស្យុង២៣០គីឡូវ៉ុល ប្រវែងប្រហែល ៥០ គីឡូម៉ែត្រ ពីអនុស្ថានីយ៍ស្ទឹងហាវទៅចំការលួង និង
- សៀគ្វីពីរសម្រាប់ខ្សែបណ្តាញបញ្ជូនមានតង់ស្យុង ៥០០ គីឡូវ៉ុលមានប្រវែងប្រហែល ១៤០គីឡូម៉ែត្រពីអនុស្ថានីយ៍ចំការលួង ទៅអនុស្ថានីយ៍ដែលទើបស្នើសុំថ្មីនៅបែកចាន។

គម្រោងនេះបានបញ្ចប់នៅខែកុងខែមករា ឆ្នាំ២០២០។

ជាងនេះទៅទៀតនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងថ្មីមួយទៀតដែលមានតម្លៃប្រមាណ១០០,២លានដុល្លារអាមេរិកជាមួយនឹងក្រុមហ៊ុន អាឡិច សម្រាប់គម្រោងរោងចក្រវារីអគ្គិសនីស្ទឹងតាតៃ - ប្រព័ន្ធបញ្ជូនអគ្គិសនីរាជធានីភ្នំពេញ។ គម្រោងនេះទាក់ទងនឹង៖

- ការគូសប្តង់ វិស្វកម្ម ការតម្លើង ការសាកល្បង និងការដាក់ឱ្យប្រើប្រាស់ខ្សែបណ្តាញបញ្ជូនមានតង់ស្យុង២៣០គីឡូវ៉ុល មានប្រវែងប្រហែល២២០ គីឡូម៉ែត្រពីរោងចក្រវារីអគ្គិសនីស្ទឹងតាតៃទៅអនុស្ថានីយ៍ដែលទើបស្នើសុំថ្មីនៅបែកចានក្នុងរាជធានីភ្នំពេញ និង
- ការផ្តត់ផ្តង់ ការតម្លើង និងការតភ្ជាប់បង្គោលបណ្តាញបញ្ជូនចេញចំនួនពីរ (០២) ដែលមានតង់ស្យុង២៣០ គីឡូវ៉ុលនៅទីធ្លាភ្ជាប់ផ្តាច់ចរន្ត នៃរោងចក្រវារីអគ្គិសនីស្ទឹងតាតៃ។

គម្រោងនេះគ្រោងនឹងបញ្ចប់នៅខែមេសា ឆ្នាំ២០២១។

នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ យើងបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន Schneitec សម្រាប់គម្រោងខេត្តសៀមរាប - ខេត្តឧត្តរមានជ័យ ដែលកិច្ចសន្យាមានតម្លៃ ២៦ លានដុល្លារអាមេរិក។ គម្រោងនេះទាក់ទងនឹងការអភិវឌ្ឍបណ្តាញបញ្ជូនទំហំ ១១៥ គីឡូវ៉ុល ពីខេត្តសៀមរាប ទៅខេត្តឧត្តរមានជ័យ អនុស្ថានីយ៍ខេត្តឧត្តរមានជ័យទំហំ ១១៥ គីឡូវ៉ុល/២២ គីឡូវ៉ុល និងអនុស្ថានីយ៍បែកចានទំហំ ២៣០ គីឡូវ៉ុល/ ២២ គីឡូវ៉ុល។

គម្រោងត្រូវបាន បញ្ចប់ក្នុងខែធ្នូ ឆ្នាំ២០១៩។

នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ យើងបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនអគ្គិសនីកម្ពុជា សម្រាប់គម្រោងដែលកិច្ចសន្យាមានតម្លៃ ៧,៤៩ លានដុល្លារអាមេរិក។ គម្រោងនេះទាក់ទងនឹងការផ្គត់ផ្គង់ TACSR បណ្តាញបញ្ជូនទំហំ ២៣០ គីឡូវ៉ុល ពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍ចំការហ្លួង។

គម្រោងនេះត្រូវបាន បញ្ចប់ក្នុងខែសីហា ឆ្នាំ២០១៩។

នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០ យើងបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន Renaissance Minerals (Cambodia) Ltd. សម្រាប់គម្រោងដែលកិច្ចសន្យាមានតម្លៃ ៧,៣០ លានដុល្លារអាមេរិក។ គម្រោងនេះទាក់ទងនឹង ការគូសប្តង់ វិស្វកម្ម ការតម្លើង ការសាកល្បង និងការដាក់ឱ្យ

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

ប្រើប្រាស់ខ្សែបណ្តាញបញ្ជូនមានតង់ស្យុង ២៣០/១១ គីឡូវ៉ុល សម្រាប់អនុស្ថានីយ៉ារួចរាវ ខេត្តមណ្ឌលគីរី។ គម្រោងនេះគ្រោងនឹងបញ្ចប់ក្នុងរយៈពេល១២ ខែចាប់តាំងពីថ្ងៃចាប់ផ្តើមសាងសង់។

៤.១.៤. រចនាសម្ព័ន្ធក្រុមហ៊ុន

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ប្រតិបត្តិការក្រោមការទទួលខុសត្រូវ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ នាយកប្រតិបត្តិជាមួយនឹងប្រធានផ្នែកចូលរួមក្នុងការដឹកនាំ និងត្រួតពិនិត្យនូវប្រតិបត្តិការប្រចាំថ្ងៃ និងការគ្រប់គ្រងក្រុមហ៊ុន។



ព័ត៌មានអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនយើងមាននៅក្នុងផ្នែកទី ៥ នៃឯកសារផ្តល់ព័ត៌មាន។

៤.១.៥. អនុលោមកច្ចសាជីវកម្មរបស់ក្រុមហ៊ុន

ក. ក្រុមប្រឹក្សាភិបាលនិង គណៈកម្មាធិការ

ដូចបានចែងនៅក្នុងមាត្រា ១៧ ក្នុងលក្ខន្តិក:របស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ថ្ងៃទី១១ ខែ សីហា ឆ្នាំ២០១៨ នៃផ្នែករបស់ក្រុមប្រឹក្សាភិបាលចែងថា៖ ក្រុមប្រឹក្សាភិបាល (ដោយមិនគិតពីអភិបាលឆ្លាស់វេន) ត្រូវមានអភិបាលមិនតិចជាងប្រាំ (០៥) រូប និងមិនច្រើនជាងដប់ប្រាំ (១៥) រូប។ អភិបាលមិនចាំបាច់ជាម្ចាស់ភាគហ៊ុនឡើយ នៅពេលត្រូវបានតម្រូវដោយ គ.ម.ក. អភិបាលនឹងមិនត្រូវបានតែងតាំងឡើយ ប្រសិនបើគាត់មិនអាចបំពេញបានតាមលក្ខខណ្ឌតម្រូវ និងគុណវុឌ្ឍិដែលបានកំណត់ដោយ គ.ម.ក. និងអនុលោមតាមប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយ បន្ទាប់ពីការចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក។

ក្រុមប្រឹក្សាភិបាល ក្រុមហ៊ុនត្រូវមានអភិបាលឯករាជ្យយ៉ាងតិចមួយភាគប្រាំ (១/៥) ឬចំនួនផ្សេងទៀតដែលតម្រូវដោយច្បាប់ ឬបទបញ្ញត្តិ។

ខ. ការតែងតាំង និង/ឬការដកហូតអភិបាល និងតំណែងទំនេរ

អភិបាលត្រូវតែជ្រើសតាំងដោយសេចក្តីសម្រេចធម្មតារបស់ម្ចាស់ភាគហ៊ុន។ ប្រសិនបើមិនមានការចែងផ្សេងពីនេះដោយសេចក្តីសម្រេច អភិបាលម្នាក់ៗនិងត្រូវបានជ្រើសតាំងសម្រាប់អាណត្តិពីរឆ្នាំ និងអាចត្រូវបានជ្រើសតាំងជាថ្មី។ ក្រុមម្ចាស់ភាគហ៊ុនអាចដកហូតតំណែងអភិបាលរូបណាក៏បាន នៅពេលណាក៏បាន តាមរយៈសេចក្តីសម្រេចធម្មតា។ ប្រសិនបើតំណែងទំនេរកើតឡើងនៅក្នុងក្រុមប្រឹក្សាភិបាលនៅមុនពេលផុតអាណត្តិរបស់អភិបាលម្នាក់ ដោយសារតែការដកហូតតំណែងឬដោយហេតុផលផ្សេងទៀត ក្រុមម្ចាស់ភាគហ៊ុនត្រូវជ្រើសតាំងអភិបាលម្នាក់ទៀតដើម្បីបំពេញតំណែងទំនេរនោះសម្រាប់អណត្តិដែលនៅសល់របស់អភិបាលដែលចាកចេញពីតំណែងនោះ។

គ. បញ្ជីសមាជិកក្រុមប្រឹក្សាភិបាលបច្ចុប្បន្ន

ល.រ	ឈ្មោះ	មុខតំណែង	កាលបរិច្ឆេទតាយជាអភិបាល	កាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន
១.	លោក Lim Pay Chuan	ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ	ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០១០	មិនមានកាលកំណត់
២.	លោក Lim Ah Hock	អភិបាលប្រតិបត្តិ	ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០១០	មិនមានកាលកំណត់
៣.	លោក Han Fatt Juan	អភិបាលប្រតិបត្តិ/នាយកប្រតិបត្តិ	ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨	មិនមានកាលកំណត់

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

ល.រ	ឈ្មោះ	មុខតំណែង	កាលបរិច្ឆេទតាយជា អភិបាល	កាលបរិច្ឆេទបញ្ចប់ អាណត្តិបច្ចុប្បន្ន
៤.	លោក Tan Pu Hooi	អភិបាលប្រតិបត្តិ	ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨	មិនមានកំណត់ពេលវេលា
៥.	ឯកឧត្តម ដាវ អានសាន	អភិបាលឯករាជ្យ	ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០១៨	ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០២៣

ឃ. តួនាទីរបស់ក្រុមប្រឹក្សាភិបាល

ទំនួលខុសត្រូវចម្បងរបស់ក្រុមប្រឹក្សាភិបាល ដោយផ្អែកលើការវាយតម្លៃដែលបានកំណត់ទុកជាមុន រួមទាំងការផ្តល់ទិសដៅយុទ្ធសាស្ត្រដល់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) កំណត់តំបន់ហានិភ័យសំខាន់ៗ និងសូចនាករប្រតិបត្តិការសំខាន់ៗនៃអាជីវកម្មរបស់ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) តាមដាន ការសម្រេចចិត្តលើការវិនិយោគ ពិចារណាលើបញ្ហាហិរញ្ញវត្ថុសំខាន់ៗ និងពិនិត្យមើលលើការអនុវត្តរបស់ថ្នាក់គ្រប់គ្រងទៅលើផែនការអាជីវកម្ម ថវិការ និងស្តង់ដារឧស្សាហកម្ម។

ក្រុមប្រឹក្សាភិបាលមានការទទួលខុសត្រូវយ៉ាងជាក់លាក់ ចំពោះការដឹកនាំបុគ្គលិករបស់ក្រុមហ៊ុន និងការបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវលើផ្នែកមានដូចខាងក្រោម៖

(ក) រក្សាការគ្រប់គ្រងឱ្យបានពេញលេញ និងមានប្រសិទ្ធភាពលើក្រុមហ៊ុន និងត្រួតពិនិត្យថ្នាក់គ្រប់គ្រងក្នុងការអនុវត្តផែនការ និងយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាភិបាល

(ខ) ធានាថាប្រព័ន្ធគោលនយោបាយទូលំទូលាយ និងនីតិវិធីមានដំណើរការ

(គ) កំណត់ និងត្រួតពិនិត្យទ្រង់ទ្រាយមិនមែនហិរញ្ញវត្ថុ ដែលទាក់ទងនឹងអាជីវកម្ម

(ឃ) ធានាឱ្យមានអាកប្បកិរិយាប្រកបដោយក្រមសីលធម៌ និងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគោលការណ៍សវនកម្ម និងគណនេយ្យ និងឯកសារគ្រប់គ្រងដោយផ្ទាល់ និងក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុន

(ង) ខិតខំអនុវត្តសកម្មភាពលើសពីការតម្រូវ និងកម្រិតអប្បបរមា ប្រៀបធៀបលទ្ធផលការងារទៅនឹងស្តង់ដារអនុវត្តល្អកម្រិតអន្តរជាតិ និងមិនត្រឹមតែអនុលោមក្នុងការអនុវត្តនោះទេ ប៉ុន្តែថែមទាំងត្រូវឱ្យមើលឃើញថាបានអនុលោមតាម

(ច) កំណត់កម្រិតនៃភាពសំខាន់ រក្សាសិទ្ធិអំណាចជាក់លាក់ដល់ក្រុមប្រឹក្សាភិបាល និងផ្តល់សិទ្ធិអំណាចផ្សេងៗដោយមានលិខិតអនុញ្ញាតជាចាំបាច់ជាលាយលក្ខណ៍អក្សរដល់ថ្នាក់

គ្រប់គ្រង និងបង្កើតយន្តការប្រកបដោយប្រសិទ្ធិភាពដែលធានានូវការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលសម្រាប់ការអនុវត្តតួនាទីនៃផ្នែកគ្រប់គ្រង

(ឆ) ធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវចំពោះភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន

(ជ) ត្រូវដឹង និងប្តេជ្ញាចិត្តចំពោះគោលការណ៍គ្រឹះនៃអភិបាលកិច្ចល្អ ហើយការអនុលោមតាមគោលការណ៍គ្រឹះនៃអភិបាលកិច្ចអាជីវកម្ម ត្រូវបានពិនិត្យជាប្រចាំ និង

(ឈ) ពិនិត្យ អនុម័ត សម្រេចលើនីតិវិធី គោលនយោបាយ លក្ខណៈវិនិច្ឆ័យ យន្តការ អនុសាសន៍នានា ដែលគណៈកម្មាធិការទាំងអស់បានរាយការណ៍ជូនក្រុមប្រឹក្សាភិបាល។

ង. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវបានអនុញ្ញាតក្នុងការបង្កើតគណៈកម្មាធិការ និងគណៈកម្មាធិការរបស់ក្រុមប្រឹក្សាត្រូវបានបង្កើតឡើងដោយអនុលោមតាមប្រកាសរបស់ គ.ម.ក ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។ គណៈកម្មាធិការជួយសម្រួលការសម្រេចចិត្តប្រកបដោយប្រសិទ្ធិភាព ដើម្បីជួយក្រុមប្រឹក្សាភិបាលក្នុងការអនុវត្តភារកិច្ច សិទ្ធិ និងអំណាចរបស់ខ្លួន។ ការប្រគល់សិទ្ធិអំណាចដល់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ឬគណៈគ្រប់គ្រងមិនធ្វើឱ្យក្រុមប្រឹក្សាភិបាលរួចផុតពីការទទួលខុសត្រូវរបស់ខ្លួនឡើយ។

ក្រុមប្រឹក្សាភិបាលមានត្រូវមានគណៈកម្មាធិការចំនួនបី (០៣) ដែលមានរៀបរាប់នៅក្នុងប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្ម សម្រាប់ក្រុមហ៊ុនបោះផ្សាយជាសាធារណៈ ដែលមានគណៈកម្មាធិការសវនកម្ម គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការតែងតាំង និងលាភការ។

ង.១. គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្មត្រូវមានសមាជិកយ៉ាងហោចណាស់ បី (០៣) នាក់ ហើយមានប្រធានជាអភិបាលឯករាជ្យមួយរូប។ យ៉ាងហោចណាស់សមាជិក ម្នាក់ គឺជាអ្នកជំនាញហិរញ្ញវត្ថុ ហើយសមាជិកដទៃទៀតយកល្អបំផុតគួរតែមានប្រវត្តិការងារ និង សិក្ខាខាងគណនេយ្យ និងហិរញ្ញវត្ថុ។

ប្រធាន	សមាជិក	កិច្ចប្រជុំ
ឯកឧត្តម ដាវ អានសាន អភិបាលឯករាជ្យ	លោក Lim Pay Chuan ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ លោក Tan Pu Hooi អភិបាល	យ៉ាងហោចណាស់ម្តង រៀងរាល់បី (០៣) ខែ

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្មនឹងត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល ដែលរួមមានតួនាទី និងភារកិច្ចដូចខាងក្រោមនេះ៖

(i) ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុទាំងអស់

(ii) ត្រួតពិនិត្យការគ្រប់គ្រងផ្ទៃក្នុង

(iii) ត្រួតពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង

(iv) ត្រួតពិនិត្យការធ្វើសវនកម្មពីខាងក្រៅ និង

(v) ធ្វើរបាយការណ៍អំពីសកម្មភាពរបស់គណៈកម្មាធិការដាក់ជូនក្រុមប្រឹក្សាភិបាល ។

សវនកម្មផ្ទៃក្នុង

ក្រុមប្រឹក្សាភិបាលបានតែងតាំងក្រុមហ៊ុន HT & P Partners ជាអ្នកផ្តល់សេវាកម្មសវនកម្មផ្ទៃក្នុងសម្រាប់ក្រុមហ៊ុនចាប់តាំងពីថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨។ ក្រុមហ៊ុន HT & P Partner ទទួលខុសត្រូវចំពោះគណៈកម្មាធិការសវនកម្ម និងក្រុមប្រឹក្សាភិបាល។

ការទទួលខុសត្រូវរបស់សវនកម្មផ្ទៃក្នុងរួមមាន ការបង្កើតផែនការសវនកម្ម និងការត្រួតពិនិត្យសវនកម្មផ្ទៃក្នុងរបស់ដំណើរការអាជីវកម្មសំខាន់ៗរបស់ក្រុមហ៊ុន និងការត្រួតពិនិត្យដែលពាក់ព័ន្ធដោយធ្វើដូចខាងក្រោម៖

(i) ស្វែងយល់ និងវាយតម្លៃតាមរយៈការពិនិត្យឡើងវិញនូវឯកសារសំភាសន៍ជាមួយអ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវផ្ទាល់ និងអនុវត្តនីតិវិធីជាជំហានៗ ដំណើរការអាជីវកម្ម និងការគ្រប់គ្រងអាជីវកម្មដែលពាក់ព័ន្ធ ឈរលើទស្សនវិស័យការគ្រប់គ្រងហានិភ័យលើនៃវដ្តនៃដំណើរការទាំងមូល

(ii) ពិនិត្យ និងវាយតម្លៃភាពគ្រប់គ្រាន់នៃឯកសារនិងនីតិវិធីដែលត្រូវចងក្រងជាឯកសារ។

(iii) អនុវត្តការវាយតម្លៃអំពីប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចុប្បន្ន

(iv) ត្រួតពិនិត្យសវនកម្មផ្ទៃក្នុង ដោយផ្អែកលើគំរូនៃដំណើរការអាជីវកម្មសំខាន់ៗដើម្បីវាយតម្លៃភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង

(v) កំណត់ភាពទន់ខ្សោយ/ខ្វះខាតនៃការគ្រប់គ្រងក្នុងដំណើរការសំខាន់ៗ

(vi) កំណត់ដំណើរការដែលត្រូវការកែលម្អ និងការពិនិត្យឡើងវិញ

(vii) ផ្តល់នូវអនុសាសន៍សម្រាប់ការកែលម្អ។

ង.២. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ត្រូវមានសមាជិកយ៉ាងតិចណាស់ បី (០៣) រូប និងមានប្រធានជាអភិបាលឯករាជ្យមួយ (០១) រូប។ យ៉ាងហោចណាស់សមាជិកម្នាក់ មានជំនាញខាងការគ្រប់គ្រងហិរញ្ញវត្ថុ និងហានិភ័យ។ តារាងខាងក្រោមបង្ហាញពីសមាសភាពនៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យ៖

ប្រធាន	សមាជិក	កិច្ចប្រជុំ
ឯកឧត្តម ដាវ អានសាន អភិបាលឯករាជ្យ	លោក Lim Pay Chuan ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ លោក Han Fatt Juan អភិបាលប្រតិបត្តិ	យ៉ាងហោចណាស់ម្តង រៀងរាល់ បី (០៣) ខែ

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការនេះ នឹងត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល ដែលរួមមានតួនាទី និងភារកិច្ចដូចខាងក្រោមនេះ៖

(i) ការវិភាគហានិភ័យដែលរួមមាន៖ ការពណ៌នាអំពីហានិភ័យ ការកំណត់ហានិភ័យ ការប៉ាន់ប្រមាណហានិភ័យ
(ii) ការវាយតម្លៃហានិភ័យ
(iii) របាយការណ៍អំពីហានិភ័យ
(iv) ការដោះស្រាយហានិភ័យ និង
(v) ការតាមដានហានិភ័យ។

ង.៣. គណៈកម្មាធិការលាភការ និងចាត់តាំង

ក្នុងករណីមានគណៈកម្មាធិការលាភការ និងចាត់តាំង គណៈកម្មាធិការនេះត្រូវមានសមាជិកយ៉ាងហោចណាស់ បី (០៣) រូប ដែលដឹកនាំដោយអភិបាល មួយ (០១) រូប ជាអភិបាលមិនប្រតិបត្តិ។

ដឹកនាំដោយ	សមាជិក	កិច្ចប្រជុំ
ឯកឧត្តម ដាវ អានសាន អភិបាលឯករាជ្យ	លោក Lim Ah Hock អភិបាល លោក Tan Pu Hooi អភិបាល	យ៉ាងហោចណាស់ម្តងរៀងរាល់ មួយ (០១) ឆ្នាំ

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការនេះនឹងត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល ដែលរួមមានតួនាទី និងភារកិច្ចដូចខាងក្រោមនេះ៖



១) ការត្រួតពិនិត្យ និងការវាយតម្លៃអំពីគុណវុឌ្ឍិរបស់បេក្ខជនសម្រាប់តំណែងអភិបាល ឬមន្ត្រីជាន់ខ្ពស់ដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល

២) ការកំណត់ ឬការពិនិត្យមើលឡើងវិញ និងការផ្តល់អនុសាសន៍អំពីការបង់អត្ថប្រយោជន៍ និងលាភការរបស់អភិបាល និងមន្ត្រីជាន់ខ្ពស់ផងដែរ

៣) ពិនិត្យ និងបច្ចុប្បន្នកម្មលើយន្តការ និងការវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល អភិបាល និងគណៈកម្មាធិការនានាយ៉ាងហោចណាស់ ១ (មួយ) ដងក្នុង ១ (មួយ) ឆ្នាំ។

៤.១.៦. ផលិតផល និងសេវាកម្មចម្បង

ក. ផលិតផល និងសេវាកម្មចម្បងរបស់ក្រុមហ៊ុន

ក្រុមហ៊ុនយើងជាក្រុមហ៊ុនបច្ចេកទេសថាមពលអគ្គិសនី។ ក្រុមហ៊ុនផ្តល់សេវាកម្មចម្បងលើការផ្តល់ជូននូវដំណោះស្រាយវិស្វកម្ម ប្រព័ន្ធថាមពល និងបច្ចេកវិទ្យាពេញលេញសម្រាប់៖

(i) **ការគូសប្លង់ លទ្ធកម្ម ការសាងសង់ ការតម្លើង និងការដាក់ឱ្យប្រើប្រាស់នូវអនុស្ថានីយ៍ដែលមានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង បណ្តាញបញ្ជូនដែលមានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ក៏ដូចជាប្រព័ន្ធខ្សែថាមពលក្រោមដី សម្រាប់ការបញ្ជូន និងចែកចាយអគ្គិសនី**

ក្រុមហ៊ុនផ្តល់សេវាកម្មចម្បងលើការផ្តល់ជូននូវដំណោះស្រាយបច្ចេកទេស និងវិស្វកម្មប្រព័ន្ធថាមពល សម្រាប់ការបញ្ជូន និងការចែកចាយអគ្គិសនី នៅតំបន់ឥណ្ឌូចិន។ ជាផ្នែកនៃដំណោះស្រាយបច្ចេកទេស និងវិស្វកម្មប្រព័ន្ធថាមពល ក្រុមហ៊ុនផ្តល់ជូននូវសេវាកម្មដូចខាងក្រោម៖

- ការគូសប្លង់នៃអនុស្ថានីយ៍អគ្គិសនីខាងក្នុង និងខាងក្រៅ ការសាងសង់រចនាសម្ព័ន្ធ និងសំណង់ស៊ីវិលសម្រាប់អនុស្ថានីយ៍មានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ខ្សែបណ្តាញបញ្ជូនដែលមានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង និងប្រព័ន្ធថាមពលខ្សែកាបក្រោមដី
- ការគ្រប់គ្រងគម្រោង ការសាងសង់ ការតម្លើង និងការដាក់ឱ្យប្រើប្រាស់នូវអនុស្ថានីយ៍មានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ខ្សែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង និងប្រព័ន្ធថាមពលខ្សែកាបក្រោមដី
- ការរៀបចំឧបករណ៍ម៉ាស់ដី ឧបករណ៍ចម្លងអគ្គិសនី ឧបករណ៍វាស់ចរន្ត និងឧបករណ៍តភ្ជាប់
- ការគូសប្លង់ប្រព័ន្ធគោល និងបម្រុង រួមទាំងការគណនា និងផ្ទៀងផ្ទាត់



- ការគូសប្លង់ប្រព័ន្ធការពារ ត្រួតពិនិត្យ និងទំនាក់ទំនង និងការអនុវត្ត
- ការអនុវត្តប្រព័ន្ធ SCADA។

ក្រុមហ៊ុនទទួលបានគម្រោងតាមរយៈការដាក់តម្លៃ និងការស្នើសុំដាក់តម្លៃពីអតិថិជនានាពេលអនាគត។ គម្រោងធម្មតាសម្រាប់ការងារសាងសង់អនុស្ថានីយ៍មានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ខ្សែបណ្តាញបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ឬប្រព័ន្ធខ្សែកាបក្រោមដី សំដៅលើគម្រោងដែលរួមបញ្ចូលការគូសប្លង់វិស្វកម្ម លទ្ធកម្ម ការសាងសង់ ការផ្គត់ផ្គង់ ការតម្លើង ការសាកល្បង និងការដាក់ឱ្យប្រើប្រាស់រចនាសម្ព័ន្ធ និងបរិក្ខារដែលពាក់ព័ន្ធ។ ការអនុវត្តគម្រោងទាំងនេះ គឺផ្អែកលើនីតិវិធីក្នុងសៀវភៅណែនាំការគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន។ សង្ខេបសេចក្តីមក ដំណើរការពាក់ព័ន្ធនឹងគម្រោងមានបង្ហាញដូចខាងក្រោម៖

ដំណាក់កាល	ដំណើរការ
ផែនការ និងលទ្ធកម្ម	ក្នុងដំណាក់កាលរៀបចំផែនការ ក្រុមហ៊ុនពិភាក្សាពីលក្ខខណ្ឌតម្រូវ និងតម្រូវការចាំបាច់របស់អតិថិជន នៅពេលគ្រោងប្លង់ប្រព័ន្ធនៃគម្រោង។ ក្រុមហ៊ុនពិចារណាទៅលើថវិការបស់អតិថិជន កាលវិភាគ តម្រូវការជាក់លាក់ ទំហំដី ទីតាំង និងកត្តា/ឧបសគ្គ ផ្សេងទៀត។ វិស្វកររបស់ក្រុមហ៊ុននឹងរៀបចំគំនូសប្លង់នៃគម្រោង ដែលអាចទុកចិត្តបាន និងតម្លៃសមរម្យ ខណៈពេលដែលអនុញ្ញាតឱ្យមានការពង្រីកប្រសិនបើមានភាពចាំបាច់។ គំនូសប្លង់នឹងបង្ហាញពីរចនាសម្ព័ន្ធនៃគម្រោង ដូចជាបណ្តុំទីធ្លាភ្ជាប់ផ្តាច់ចរន្ត ប្រព័ន្ធឧបករណ៍ម៉ាស់ដី ប្លង់ខ្សែកាប និងការការពារផ្លេះបាញ់ ក៏ដូចជា ប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធការពារ និងប្រព័ន្ធទំនាក់ទំនងរួមបញ្ចូលគ្នា។ ដោយមានការសហការជាមួយក្រុមហ៊ុន PSB ក្រុមហ៊ុនយើងទទួលខុសត្រូវលើការងារវិស្វកម្ម និងគូសប្លង់នៃគម្រោង ស្របតាមតម្រូវការរបស់គម្រោង។ នៅពេលគំនូសប្លង់ត្រូវបានអនុម័ត និងយកមកប្រើសម្រាប់ការសាងសង់ ក្រុមការងារនឹងធ្វើលទ្ធកម្មសម្ភារៈដែលតម្រូវ។ សម្ភារៈទាំងនេះ អាចជាបង្គុំ និងគ្រឿងបរិក្ខារប្រព័ន្ធថាមពល ដែលផលិតដោយសម្ព័ន្ធក្រុមហ៊ុន ផេសថិក។ ក្រុមហ៊ុនអាចទទួលបានធនធានសម្ភារៈពីរោងចក្រផលិត ឬអ្នកផ្គត់ផ្គង់ ជាតតីយជន។

ដំណាក់កាល	ដំណើរការ
ការសាងសង់ និងការតម្លើងគ្រឿងបរិក្ខារ	ដោយផ្អែកលើគំនូសបង្ហាញដែលមានការយល់ព្រមពីអតិថិជន ក្រុមការងាររបស់ក្រុមហ៊ុនយើងនឹងរៀបចំតម្លើងប្លង់ដែលបានគ្រោង។ សម្ភារៈនឹងត្រូវបញ្ជូនទៅការដ្ឋាន ហើយក្រុមការងារនឹងចាប់ផ្តើមការសាងសង់ និងតម្លើងបរិក្ខារ ដោយផ្អែកលើគម្រោងប្លង់ដែលមានការយល់ព្រមពីអតិថិជន។ ការតម្លើងបរិក្ខារនឹងចាប់ផ្តើមបន្ទាប់ពីការបំពេញចប់សព្វគ្រប់នៃការងារសំណង់ស៊ីវិល។
ការធ្វើតេស្តសាកល្បង និងការត្រួតពិនិត្យលម្អិត	នៅពេលគ្រឿងបរិក្ខារត្រូវបានតម្លើងរួចរាល់ ក្រុមការងារពិនិត្យភាពរឹងមាំ និងធ្វើតេស្តសាកល្បង ឬអ្នកធ្វើតេស្តសាកល្បងជាតិយជន នឹងធ្វើតេស្តសាកល្បងទៅលើបរិក្ខារនៅក្នុងការដ្ឋាន។ ការត្រួតពិនិត្យលម្អិត នឹងត្រូវចាប់ផ្តើមបន្ទាប់ពីការធ្វើតេស្តសាកល្បងបានបំពេញចប់សព្វគ្រប់ និងជោគជ័យ។
ការបញ្ចប់គម្រោង និងការប្រគល់	ដោយផ្អែកលើការបំពេញចប់សព្វគ្រប់នៃគម្រោង វិញ្ញាបនបត្របញ្ចប់គម្រោងនឹងត្រូវចេញដោយអតិថិជន។

(ii) ការជួញដូរបង្គុំ និងបរិក្ខារនៃប្រព័ន្ធថាមពលដែលមាន និងមិនមានបំពាក់ពាណិជ្ជសញ្ញារបស់ក្រុមហ៊ុន

ក្រុមហ៊ុនជួញដូរបង្គុំ និងគ្រឿងបរិក្ខារប្រព័ន្ធថាមពលដែលមាន និងមិនមានបំពាក់ពាណិជ្ជសញ្ញារបស់ក្រុមហ៊ុននៅប្រទេសកម្ពុជា។ បង្គុំ និងគ្រឿងបរិក្ខារប្រព័ន្ធថាមពលខ្លះ ត្រូវបានផលិតដោយសម្ព័ន្ធក្រុមហ៊ុនផេសទិក។

សម្ព័ន្ធក្រុមហ៊ុនផេសទិក គឺជាម្ចាស់ទៅលើក្រុមហ៊ុនសាខាដែលបានចុះបញ្ជីម៉ាកដូចជា PESTECH, COPS, D-Switch, PROCOM និង RETCOMS សម្រាប់បង្គុំ និងគ្រឿងបរិក្ខារប្រព័ន្ធថាមពលប្រើប្រាស់សម្រាប់ការត្រួតពិនិត្យ តាមដាន និងការពារអនុស្ថានីយ៍ដែលត្រូវបានផលិតដោយសម្ព័ន្ធក្រុមហ៊ុនផេសទិក នៅប្រទេសម៉ាឡេស៊ី។

វិសាលភាពនៃបង្គុំ និងបរិក្ខារនៃការត្រួតពិនិត្យប្រព័ន្ធថាមពលរបស់ក្រុមហ៊ុន រួមមាន៖

- ឧបករណ៍បង្ហាញទិន្នន័យចូល binary code decimal (“BCD”);
- ឧបករណ៍ត្រួតពិនិត្យ និងការពារ
- ឧបករណ៍ផ្តាច់តង់ស្យុងខ្ពស់

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

- ទូរវីឡេ ការពារ និង ទូរគមនាគមន៍ (Telecommunication and teleprotection panels)
- ឧបករណ៍រំសុីស្តីរកំណត់ភាពណឹតរបស់ដី (“NER”)
- ឧបករណ៍បញ្ជាពីចម្ងាយ (“RTU”)
- ប្រព័ន្ធត្រួតពិនិត្យ និងតាមដានអនុស្ថានីយ៍ (“SIMS”)
- ឧបករណ៍ប្រកាសអាសន្ន និង
- ឧបករណ៍រាស់សញ្ញាអាណាឡូកទៅឌីជីថល (“ADM”)

ផលិតផល	ស្នាកសញ្ញា	ការពណ៌នា	រូបភាព
ឧបករណ៍បម្លែង BCD និង ឧបករណ៍បង្ហាញទិន្នន័យចូល BCD	PESTECH	ឧបករណ៍បង្ហាញ BCD ត្រូវបានរចនាឡើងដើម្បីបម្លែងសញ្ញា binary ពីឧបករណ៍ BCD ទៅជាតួលេខ។ តួនាទីរបស់ឧបករណ៍បម្លែង BCD គឺ បម្លែងដោយផ្ទាល់នៃខ្នាតវុំល ទៅសញ្ញា binary និងសមត្ថភាពផលិតសញ្ញាបង្ហាញពី ០ ទៅ ១៩។	
ឧបករណ៍ត្រួតពិនិត្យ និងការពារ	COPS	COPS គឺជាគ្រឿងត្រួតពិនិត្យ ការពារ និងតាមដាន ដែលមានសមត្ថភាពបញ្ជាពីចម្ងាយលើប្រតិបត្តិការនៃបរិក្ខារគោលដែលមានតង់ស្យុងខ្ពស់ និងប្រព័ន្ធការពារនៅក្នុងអនុស្ថានីយ៍។	
ឧបករណ៍ផ្តាច់អគ្គិសនីសម្រាប់តង់ស្យុងខ្ពស់	D-Switch	កុងតាក់ផ្តាច់ (D-switch) ត្រូវបានប្រើនៅក្នុងឧបករណ៍ប្រើប្រាស់ថាមពលដើម្បីផ្តាច់ឧបករណ៍ពីប្រភពថាមពល ឬដី។ ឧបករណ៍ផ្តាច់អគ្គិសនីនេះ មានតួនាទីពិសេសដែលមានប៉ូល ៣ និងមាន ៣ ដំណាក់កាលផ្តេក ឬបញ្ឈរអាស្រ័យលើតម្រូវការរបស់អតិថិជន។	

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

ផលិតផល	ស្លាកសញ្ញា	ការពណ៌នា	រូបភាព
ទូរវីឡេ ការពារ និង ទូរគមនាគមន៍ (Telecommunication and teleprotection panels)	RETCOMS	បន្ទះឧបករណ៍ទំនាក់ទំនង និងការពារពីចម្ងាយ បានបញ្ចូល នូវឧបករណ៍ទំនាក់ទំនង និងការពារក្នុងឧបករណ៍តែមួយ ដោយរួមបញ្ចូលការធ្វើសមកាលកម្មនៃសញ្ញាឌីជីថលតាមបានានុក្រម ផ្សព្វផ្សាយបណ្តាញ (transmission media) ផលិតផលចម្រុះ (multip-lexer) និងផលិតផលការពារពីចម្ងាយនៅក្នុងបន្ទះឧបករណ៍តែមួយ។	
ឧបករណ៍រែស៊ីស្តីរកំណត់ភាពណឺតរបស់ដី (Neutral earthing resistor)	RES	ឧបករណ៍រែស៊ីស្តីរកំណត់ភាពណឺត របស់ដី ការពារបរិក្ខារថាមពលប្រឆាំងនឹងកំហុសចរន្ត ដោយការកម្រិតចរន្តអគ្គិសនីក្រោមដី ទៅកម្រិតណាមួយដើម្បីទប់ស្កាត់ការខូចខាត។	
ឧបករណ៍បញ្ជាពីចម្ងាយ (Remote terminal unit)	PROCOM	ដើម្បីភ្ជាប់ទំនាក់ទំនងបរិក្ខារបស់អនុស្ថានីយ៍ ជាមួយមជ្ឈមណ្ឌលបញ្ជាពីចម្ងាយ ក្រោមការអនុវត្តប្រព័ន្ធ SCADA។	
ប្រព័ន្ធត្រួតពិនិត្យអនុស្ថានីយ៍ និងតាមដាន (Supervisory control and data acquisition)	WACS	សម្រួលការត្រួតពិនិត្យ និងការបញ្ជាពេញលេញពីចម្ងាយ ទៅកាន់មូលដ្ឋានទិន្នន័យនៃឧបករណ៍អេឡិចត្រូនិចឆ្លាតវៃផ្សេងៗ (intelligent electronic devices) តាមរយៈកម្មវិធីកុំព្យូទ័រក្រោមកម្មសិទ្ធិរបស់អ្នកផលិត។	
ឧបករណ៍ប្រកាសអាសន្ន (Alarm Annunciation Panel)	PESTECH	ឧបករណ៍ប្រើប្រាស់សម្រាប់ជូនដំណឹងដល់ប្រតិបត្តិករ អំពីលក្ខខណ្ឌនានាក្នុងរោងចក្រដែលកើតមកពីព្រឹត្តិការណ៍មិនប្រក្រតី ឬលក្ខខណ្ឌដែលប្រើប្រាស់សញ្ញាជាសម្គេង។	

ព្រះរាជាណាចក្រកម្ពុជា
ផេសទិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ផលិតផល	ស្លាកសញ្ញា	ការពណ៌នា	រូបភាព
ឧបករណ៍វាស់សញ្ញា អាណាឡូកទៅឌីជីថល	PESTECH	ឧបករណ៍នេះមានតួនាទីបម្លែងសញ្ញា ចរន្តពី ឧបករណ៍ផ្លាស់ប្តូរ និងបង្ហាញនៅលើឧបករណ៍បង្ហាញដែលមានពីរផ្នែក និងអាចផ្តល់នូវទីតាំងឧបករណ៍ (tap position) ពី ១០-២០។	

(iii) O&M

ក្រៅពីការគូសប្លង់ លទ្ធកម្ម ការសាង់សង់ ការតម្លើង (EPCC) ក្រុមហ៊ុនផេសថេក (ខេមបូឌា) ក៏បានបង្កើតសេវា O&M។

អតិថិជនរបស់ ផេសថិក (ខេមបូឌា) ជាអ្នកកាន់កាប់សម្បទានភាគច្រើនដែលទទួលកិច្ចសន្យាដើម្បីសាងសង់ ប្រតិបត្តិការ និងផ្ទេរ (BOT) និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយថាមពល មិនចូលរួមក្នុងសកម្មភាពបច្ចេកទេស និងសកម្មភាពខាងក្រៅពាក់ព័ន្ធនឹងការកសាងហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយនោះទេ។

ជាទូទៅ អ្នកទទួលសិទ្ធិសម្បទានទាំងនោះជួលក្រុមហ៊ុនយើងសម្រាប់ផ្តល់សេវាជាកញ្ចប់ដើម្បីធ្វើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចផ្តល់សេវាប្រតិបត្តិការ និងការថែរទាំអនុស្ថានីយ៍ថាមពល និងខ្សែបញ្ជូន នៅពេលហេដ្ឋារចនាសម្ព័ន្ធបញ្ជូនត្រូវបានដាក់ឱ្យដំណើរការ។

ក្រុមហ៊ុនផេសថេក (ខេមបូឌា) បានចុះកិច្ចសន្យា O&M សរុប ១១៧,៣ លានដុល្លាអាមេរិក សម្រាប់ប្រព័ន្ធបណ្តាញបញ្ជូនថាមពលអគ្គិសនីមានដូចខាងក្រោម៖

- ប្រព័ន្ធបណ្តាញបញ្ជូនថាមពលអគ្គិសនីខេត្តកំពង់ចាម - ខេត្តក្រចេះ
- ប្រព័ន្ធបណ្តាញបញ្ជូនថាមពលអគ្គិសនីរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ
- គម្រោងស្ទឹងតាតៃ - រាជធានីភ្នំពេញ

ប្រាក់ចំណូលសម្រាប់គម្រោងទាំងបី (៣) នៃកិច្ចសន្យា O&M មានចំនួនប្រមាណ ៤,៦៩ លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ និងរយៈពេល២៥ឆ្នាំ។

ក្រុមហ៊ុនមានគោលបំណងណែនាំការអនុវត្តស្តង់ដារ O&M ក្នុងប្រទេសកម្ពុជា និងមានផែនការអនុវត្តសេវាកម្ម O&M សម្រាប់ហេដ្ឋារចនាសម្ព័ន្ធបណ្តាញបញ្ជូនដែលមានស្រាប់

និងដែលនឹងសាងសង់នាពេលអនាគត នៅពេលដែលវាបានបង្កើតសមត្ថភាព និងសេដ្ឋកិច្ច
មាត្រដ្ឋានរបស់ខ្លួន។

ខ. ព័ត៌មានលម្អិតស្តីពីគម្រោងពីមុន និងកំពុងបន្តរបស់ក្រុមហ៊ុន

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនសម្រេចបានគម្រោងដូចខាងក្រោម៖

វិសាលភាពនៃគម្រោង	អតិថិជន	រយៈពេលគម្រោង	តម្លៃគម្រោង លានដុល្លារអាមេរិក
គម្រោងខេត្តបាត់ដំបង	អគ្គិសនីកម្ពុជា	ចាប់ផ្តើមនៅខែមីនា ឆ្នាំ២០១២ និង បានបញ្ចប់នៅខែសីហា ឆ្នាំ២០១២	០,២
គម្រោងរាជធានីភ្នំពេញភាគខាងជើង –ខេត្តកំពង់ចាម	ក្រុមហ៊ុនខេមបូឌានថ្មែនមីសិន	ចាប់ផ្តើមនៅខែកុម្ភៈ ឆ្នាំ២០១០ និង បានបញ្ចប់នៅខែឧសភា ឆ្នាំ២០១៣	៤,៥
គម្រោង Sarawak	ក្រុមហ៊ុន PSB	ចាប់ផ្តើមនៅខែឧសភា ឆ្នាំ២០១៥ និងបានបញ្ចប់នៅខែ កក្កដា ឆ្នាំ២០១៥	០,៣
គម្រោងខេត្តកំពង់ចាម – ខេត្តក្រចេះ	ក្រុមហ៊ុន ដាយអឺម៉ុន ផៅវែរ	ចាប់ផ្តើមនៅខែឧសភា ឆ្នាំ២០១៥ និងបានបញ្ចប់នៅខែវិច្ឆិកា ឆ្នាំ២០១៧	១៧,២
គម្រោងរាជធានីភ្នំពេញភាគខាងលិច -ខេត្តព្រះសីហនុ	ក្រុមហ៊ុនអាឡិច	ចាប់ផ្តើមនៅខែ មេសា ឆ្នាំ២០១៥ និងបានបញ្ចប់នៅខែ មករា ឆ្នាំ២០២០	១៤៧,៨
គម្រោងខេត្តសៀមរាប -ខេត្តឧត្តរមានជ័យ	ក្រុមហ៊ុន Schneitec	ចាប់ផ្តើមនៅខែ មករា ឆ្នាំ២០១៨ និងបានបញ្ចប់នៅខែធ្នូ ឆ្នាំ២០១៩	២៦,០
ផ្គត់ផ្គង់ TACSR ២៣០ គីឡូវ៉ុលបណ្តាញបញ្ជូន កំរិតខ្ពស់ ពីអនុស្ថានីយ៍ស្ទឹងហាវ ទៅកាន់អនុស្ថានីយ៍ចំការលួង	អគ្គិសនីកម្ពុជា	ចាប់ផ្តើមនៅខែ មេសា ឆ្នាំ២០១៩ និងបានបញ្ចប់នៅខែកញ្ញា ឆ្នាំ២០១៩	៧,៥

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

ក្រុមហ៊ុនបានចូលរួមក្នុងគម្រោងរបៀបកំពុងមាន គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ នៅក្នុងប្រទេសកម្ពុជាដូចខាងក្រោម៖

គម្រោង	អតិថិជន	រយៈពេលសាងសង់	តម្លៃគម្រោង លានដុល្លារអាមេរិក	វិធីសាស្ត្របង់ប្រាក់
គម្រោងស្ថានីយ៍វារីអគ្គិសនីស្ទឹងតាតៃ ប្រព័ន្ធបណ្តាញថាមពល រាជធានីភ្នំពេញ	ក្រុមហ៊ុនអាទ្យិច	ចាប់ផ្តើមនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២០ និងបញ្ចប់នៅថ្ងៃ៣០ ខែមេសា ឆ្នាំ២០២២	១០០,២១	ការបង់ជាប្រចាំខែក្នុងរយៈពេលប្រាំបី(០៨)ឆ្នាំ ចាប់ពីឆ្នាំទីមួយ(០១) នៃប្រតិបត្តិការពាណិជ្ជកម្មលើប្រព័ន្ធបណ្តាញថាមពលអគ្គិសនី
គម្រោងអូខ្វាវ	ក្រុមហ៊ុន *Renaissance Minerals (Cambodia) Ltd.*	ចាប់ផ្តើមនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០២០ និងបញ្ចប់នៅថ្ងៃ៣០ ខែ មេសា ឆ្នាំ២០២២	៧,៣	បង់មុន៣០% និងចំនួនដែលនៅសល់ ត្រូវទូទាត់ទៅតាមតំណាក់កាល

ក្រៅពីគម្រោងខាងលើ ក្រុមហ៊ុនមានកិច្ចសន្យា O&M ដូចខាងក្រោម៖

កិច្ចសន្យា	គម្រោង	រយៈពេល	តម្លៃកិច្ចសន្យា លានដុល្លារអាមេរិក
កិច្ចសន្យាប្រតិបត្តិការ និងការថែរទាំអនុស្ថានីយ៍ថាមពល និងខ្សែបញ្ជូន	1) ប្រព័ន្ធបណ្តាញបញ្ជូនថាមពលអគ្គិសនីខេត្តកំពង់ចាម - ខេត្តក្រចេះ 2) ប្រព័ន្ធបណ្តាញបញ្ជូនថាមពលអគ្គិសនីរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ 3) គម្រោងស្ទឹងតាតៃ - រាជធានីភ្នំពេញ	បន្ទាប់ពីបញ្ចប់ការសាងសង់រយៈពេល ២៥ ឆ្នាំ នៃគម្រោងនីមួយៗ	១១៧,៣

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

គម្រោងពីមុន និងកំពុងមាននៅក្នុងប្រទេសកម្ពុជារបស់ក្រុមហ៊ុន មានព័ត៌មាននៅក្នុងផែនទីខាងក្រោម៖



គ. ព័ត៌មានលម្អិតនៃទីផ្សាររបស់ក្រុមហ៊ុន (ទីផ្សារក្នុងស្រុក ឬអន្តរជាតិ)

សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និងថ្ងៃទី៣០ ខមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនប្រតិបត្តិការអាជីវកម្មចម្បងនៅកម្ពុជា ដូច្នេះចំណូលរបស់ក្រុមហ៊ុនបានមកពីប្រតិបត្តិការក្នុងប្រទេសកម្ពុជាតែមួយប៉ុណ្ណោះ។

៤.១.៧. យុទ្ធសាស្ត្រចុះកិច្ចរួមជាំងស្ថានភាពប្រកួតប្រជែងទីផ្សារ និងផែនការនាពេលអនាគត

ក. ឧត្តមភាពប្រកួតប្រជែង

(i) ក្រុមហ៊ុនមានមូលដ្ឋានល្អដើម្បីទទួលបានផលប្រយោជន៍ពីកំណើនតម្រូវការប្រើប្រាស់ អគ្គិសនីនៅកម្ពុជា។

តម្រូវការអគ្គិសនី កើនឡើងពី ២.៥៧២,៧៤ ជីកាវ៉ាត់ម៉ោង នៅឆ្នាំ២០១១ ទៅ ៨.៦៤៩,៩៨ ជីកាវ៉ាត់ម៉ោង នៅឆ្នាំ២០១៨ ដែលស្មើនឹង ១៨,៩១% នៃ អត្រាកំណើនប្រចាំឆ្នាំ។ ក្រុមហ៊ុន Smith Zander បានព្យាករណ៍ថាតម្រូវការអគ្គិសនីនៅកម្ពុជាកើនឡើងពី ៨.៦៤៩,៩៨ ជីកាវ៉ាត់ម៉ោង នៅឆ្នាំ២០១៨ ទៅ ១២.០១៩,៧៥ ជីកាវ៉ាត់ម៉ោង នៅឆ្នាំ២០២០ ដែលស្មើនឹង ១៧,៨៨% នៃ អត្រាកំណើនប្រចាំឆ្នាំ។

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសពីឆន្ទៈក្នុងការពង្រឹងប្រព័ន្ធបញ្ជូនអគ្គិសនីនៅកម្ពុជា ពីឆ្នាំ២០០១ ទៅ២០២០។ តាមរយៈគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជា មានគោលបំណងពង្រឹងប្រព័ន្ធបញ្ជូនអគ្គិសនីនៅកម្ពុជា ដោយមេគុណលើសពី ២០ ដង ពី ១២០ គីឡូម៉ែត្រនៅឆ្នាំ២០០១ ទៅ ២.៥៨២ គីឡូម៉ែត្រ នៅឆ្នាំ២០២០។

បន្ថែមពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅពង្រឹកផែនការយុទ្ធសាស្ត្រពង្រឹកអគ្គិសនីនៅជនបទ ជាមួយគោលដៅធានាថា ភូមិទាំងអស់នៅក្នុងប្រទេសអាចទទួលបានអគ្គិសនីប្រើប្រាស់ ត្រឹមឆ្នាំ២០២០ រួមទាំងការភ្ជាប់ប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនីខ្នាតតូច និងប្រព័ន្ធបណ្តាញបញ្ជូនក្រៅបណ្តាញអគ្គិសនី និង ៧០% នៃលំនៅដ្ឋានទាំងអស់ទទួលបានការប្រើប្រាស់អគ្គិសនីត្រឹមឆ្នាំ២០៣០។ ចុងក្រោយ ធនាគារពិភពលោកគាំទ្រទៅលើគម្រោងចំនួនពីរ (២) មានឈ្មោះថា គម្រោងពង្រឹក និងចែកចាយអគ្គិសនីជនបទ និងគម្រោងជួញដូរថាមពលនៅក្នុងអនុតំបន់មេគង្គ។

ប្រភពពី៖ របាយការណ៍ស្រាវជ្រាវទីផ្សារឯករាជ្យដោយ Smith Zander

ក្រុមហ៊ុនទទួលបានផលប្រយោជន៍ពីកំណើនតម្រូវការប្រើប្រាស់អគ្គិសនីនៅ កម្ពុជា និងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអភិវឌ្ឍន៍អត្រាភ្ជាប់អគ្គិសនីនៅក្នុងប្រទេស។ ក្នុងចម្ងាយ ២.៥៨២ គីឡូម៉ែត្រ នៃខ្សែបណ្តាញបញ្ជូនថាមពលដែលបាននឹងកំពុងសង់នៅកម្ពុជា ក្រុមហ៊ុនយើងទទួលសិទ្ធិសាងសង់ចំនួនសរុប ៧២១ គីឡូម៉ែត្រ គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ៖

- ១១០ គីឡូម៉ែត្រ សម្រាប់គម្រោងរាជធានីភ្នំពេញភាគខាងជើង - ខេត្តកំពង់ចាម
- ០១ គីឡូម៉ែត្រ សម្រាប់គម្រោងខេត្តបាត់ដំបង
- ១៩០ គីឡូម៉ែត្រសម្រាប់គម្រោងរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ
- ១២៥ គីឡូម៉ែត្រ សម្រាប់គម្រោងខេត្តកំពង់ចាម - ខេត្តក្រចេះ
- ២២០ គីឡូម៉ែត្រ សម្រាប់គម្រោងរោងចក្រវារីអគ្គិសនីស្ទឹងតាតៃ - ប្រព័ន្ធបញ្ជូនអគ្គិសនីរាជធានីភ្នំពេញ។
- ៧៥ គីឡូម៉ែត្រ សម្រាប់គម្រោងខេត្តសៀមរាប - ខេត្តឧត្តរមានជ័យ។

(ii) **ក្រុមហ៊ុនមានជំនាញបច្ចេកទេសច្បាស់លាស់នៅក្នុងការធ្វើវិស្វកម្មប្រព័ន្ធថាមពល**

ក្រុមហ៊ុនមានភស្តុតាងបង្ហាញពីបទពិសោធន៍ នៅក្នុងវិស័យវិស្វកម្មបច្ចេកទេសថាមពល និងប្រព័ន្ធថាមពល តាមរយៈចំណេះដឹងនិងបទពិសោធន៍ការងាររបស់គណៈគ្រប់គ្រងជាច្រើនឆ្នាំ។ ទាំងអស់នេះពិតជាចាំបាច់ណាស់សម្រាប់វិស័យវិស្វកម្មប្រព័ន្ធថាមពល ដែលជាវិស័យដែលទាមទាបច្ចេកទេស និងជំនាញខ្ពស់ តម្រូវឱ្យមានចំណេះដឹង និងជំនាញជាក់លាក់ក្នុងវិស្វកម្មអគ្គិសនី និងមេកានិក។ ភាពស្មុគស្មាញនៃការងារនេះ ជារនាំងសម្រាប់អ្នកវិនិយោគថ្មីក្នុងវិស័យនេះ។

ក្រុមហ៊ុនពឹងផ្អែកលើបុគ្គលិកបច្ចេកទេសសំខាន់ៗ ដើម្បីអាចទទួលបាន និងអនុវត្តគម្រោងវិស្វកម្មប្រព័ន្ធថាមពលនៅកម្ពុជា។ ព័ត៌មានស្តីពីសាវតារ និងបទពិសោធន៍របស់គណៈគ្រប់គ្រងក្រុមហ៊ុន មានរៀបរាប់នៅផ្នែកទី៥ នៃឯកសារផ្តល់ព័ត៌មាននេះ។

ក្រុមហ៊ុនយើងបានអភិវឌ្ឍជំនាញបច្ចេកទេសជាក់លាក់ដែលត្រូវការដើម្បីអនុវត្តសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន នៅក្នុងវិស័យនៃការគូសបង្គប់ទីធ្លាភ្ជាប់ផ្តាច់ចរន្តអគ្គិសនី ប្តង់អនុស្ថានីយ៍ បន្ទុកចរន្ត ក៏ដូចជាការព្រាង ការតម្លើង និងការបំពាក់បរិក្ខារនៅក្នុងបណ្តុំឧបករណ៍អគ្គិសនី និងអនុស្ថានីយ៍។

ការងារនេះធ្វើឱ្យក្រុមហ៊ុនមានការអភិវឌ្ឍសមត្ថភាព និងជំនាញចូលទៅលើសកម្មភាពធុរកិច្ចរបស់ក្រុមហ៊ុន រួមមាន៖

- ការគូសបង្គប់ដាក់ទីតាំងបង្គោលទម្រ

- ការគូសប្តង់ អភិវឌ្ឍ និងរៀបចំផែនការអនុស្ថានីយ៍ក្នុង និងក្រៅ
- ការផ្គត់ផ្គង់ ការចែកចាយ និងការតម្លើងឧបករណ៍តម្លើងថាមពល ការងារ និង ការត្រួតពិនិត្យប្រព័ន្ធ ឧបករណ៍សម្រាប់ប្តូរ ឧបករណ៍សម្រាប់ជំនួយ និងឧបករណ៍ ពាក់ព័ន្ធនឹងការងារស៊ីវិល សម្រាប់បញ្ជូន និងចែកចាយបណ្តាញ ខ្សែបណ្តាញ និង អនុស្ថានីយ៍
- ការគូសប្តង់ ការតម្លើង និងការផ្គត់ផ្គង់ប្រព័ន្ធទំនាក់ទំនង ប្រព័ន្ធការពារ និងត្រួត ពិនិត្យ និង
- គម្រោងពង្រីកបន្ថែមនៃអនុស្ថានីយ៍។

(iii) ក្រុមហ៊ុនមានគំរូអាជីវកម្មជាកញ្ចប់ ជុំវិញវិស្វកម្មប្រព័ន្ធថាមពល បណ្តាញបញ្ជូន និងចែក ចាយ

ក្រុមហ៊ុនផ្តល់ជូននូវសេវាកម្ម ដែលមានវិសាលភាពទូលំទូលាយលើវិស្វកម្មប្រព័ន្ធថាមពល បណ្តាញបញ្ជូន និងចែកចាយថាមពលអគ្គិសនី ចាប់ពីការរៀបចំគម្រោង រហូតដល់ដល់ការ ត្រួតពិនិត្យលម្អិតទៅលើអនុស្ថានីយ៍ដែលមានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ទៅលើ បណ្តាញ បញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង និងប្រព័ន្ធខ្សែកាបក្រោមដី។ ក្រុមហ៊ុនគាំពារការគូសប្តង់ ការងារសំណង់ ការតម្លើង និងការត្រួតពិនិត្យលម្អិត ជាមួយ នឹងផលិតផលបំពេញបន្ថែម ដែលត្រូវបានគូសប្តង់ និងផលិតដោយសម្ព័ន្ធក្រុមហ៊ុន ផេសថិក ដែលរួមបញ្ចូលទាំងផលិតផលប្រព័ន្ធត្រួតពិនិត្យ និងការពារ ផលិតផល RTU ឧបករណ៍ផ្តាច់តង់ស្យុងខ្ពស់ ប្រព័ន្ធតាមដានអនុស្ថានីយ៍ និងប្រព័ន្ធទូរគមនាគមន៍ ដែល មានម៉ាក COPS, PROCOM, D-Switch, WACS និង RETCOMS។

ក្រុមការងាររបស់ក្រុមហ៊ុន ធ្វើការងារគូសប្តង់វិស្វកម្មប្រព័ន្ធថាមពល និងដំណោះស្រាយ បច្ចេកទេសសម្រាប់អនុស្ថានីយ៍ ខ្សែបណ្តាញ និងខ្សែបង្កប់ក្រោមដី។ វិស្វករទាំងនេះ ធ្វើការ យ៉ាងជិតស្និទ្ធជាមួយអតិថិជនរបស់ក្រុមហ៊ុន ដើម្បីអភិវឌ្ឍគម្រោង ដោយផ្អែកលើតម្រូវ ការជាក់លាក់ពីអតិថិជន ដូចជាថវិកា កាលវិភាគ ផ្ទៃដី និងទីតាំង។ ផ្អែកលើតម្រូវការ និង ព័ត៌មានលម្អិតរបស់អតិថិជន ក្រុមវិស្វកររនេះនឹង រៀបចំគម្រោង ដែលអាចជឿទុកចិត្តបាន និងដែលមានតម្លៃសមរម្យ ព្រមទាំងអាចពង្រីកសមត្ថភាពរបស់អនុស្ថានីយ៍នោះបានពេល មានការចាំបាច់។ ការគូសប្តង់ក៏ដាក់ចេញផងដែរនូវ ប្តង់បណ្តុំឧបករណ៍អគ្គិសនី ឧបករណ៍ ត្រួតពិនិត្យ ម៉ាស់ដី រចនាសម្ព័ន្ធខ្សែកាប និងការពាររន្ទះបាញ់ ដ៏ដូចជាប្រព័ន្ធត្រួតពិនិត្យ ការពារ និងទំនាក់ទំនង។





បន្ថែមពីនេះ ក្រុមហ៊ុនទទួលធ្វើការងារសាងសង់អនុស្ថានីយ៍ ខ្សែបណ្តាញ និងខ្សែបង្កប់ក្រោមដី ដោយផ្តើមចេញពីសមត្ថភាពផ្នែករចនា ការងារសំណង់ស៊ីវិល ក៏ដូចជាជំនាញវិស្វកម្មផ្នែកមេកានិក និងអគ្គិសនី ដើម្បីសាងសង់អនុស្ថានីយ៍ ខ្សែបណ្តាញបញ្ជូន និងខ្សែបង្កប់ក្រោមដី។ គិតត្រឹមការបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមានបុគ្គលិក១០៩ នាក់ធ្វើការក្នុងគម្រោងដែលមានសមត្ថភាពគ្រប់គ្រងកម្មករប្រហែល៥០នាក់ សម្រាប់ការងារសំណង់ស៊ីវិល និងការងារតម្លើង។

ក្រុមហ៊ុនក៏ទទួលធ្វើការងារតម្លើង និងដាក់ឱ្យដំណើរការ ដែលក្រុមការងាររបស់ក្រុមហ៊ុន នឹងធ្វើតេស្តលើសម្ភារៈនៅក្នុងការដ្ឋាន ដើម្បីធានាថាសម្ភារៈទាំងនោះមានលក្ខណៈសមស្របតាមស្តង់ដាររបស់ក្រុមហ៊ុន។ នៅពេលបរិក្ខារត្រូវបានធ្វើតេស្តសាកល្បងអនុវត្តដោយជោគជ័យ ការដាក់ឱ្យដំណើរការនឹងត្រូវធ្វើឡើង ហើយគម្រោងនឹងត្រូវប្រគល់ទៅឱ្យអតិថិជន។

គំរូធុរកិច្ចជាកញ្ចប់របស់ក្រុមហ៊ុន អនុញ្ញាតឱ្យក្រុមហ៊ុនត្រួតពិនិត្យលើគុណភាពតម្លៃ និងកាលវិភាគរបស់គម្រោង ដែលអាចជួយក្រុមហ៊ុនក្នុងការធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពនៃគម្រោងទាំងមូល កាត់បន្ថយការចំណាយផ្សេងៗ និងធានាការបញ្ចប់គម្រោងទាន់ពេលដើម្បីធានា និងបង្កើនប្រាក់ចំណេញរបស់ក្រុមហ៊ុន។

(iv) **ក្រុមហ៊ុនសង្កត់ធ្ងន់ទៅលើគុណភាពជាគន្លឹះក្នុងការផ្តល់សេវាកម្ម**

ក្រុមហ៊ុនសង្កត់ធ្ងន់លើការគ្រប់គ្រងគុណភាព ដើម្បីធានាថាគម្រោងរបស់ក្រុមហ៊ុនត្រូវមានគុណភាពស្របតាមបទប្បញ្ញត្តិដែលពាក់ព័ន្ធ និងដើម្បីរក្សាកេរ្តឹ៍ឈ្មោះ និងជំហរក្នុងទីផ្សារ។ ចាប់តាំងពីការចាប់ផ្តើមធុរកិច្ច ក្រុមហ៊ុនបានអនុម័តការអនុវត្តល្អនៃការគ្រប់គ្រងគុណភាព ដែលអភិវឌ្ឍដោយសម្ព័ន្ធក្រុមហ៊ុនផេសទិក។

ដើម្បីសម្រេច និងរក្សាបាននូវវត្ថុបំណងនៃគោលនយោបាយគុណភាព ថ្នាក់គ្រប់គ្រងរបស់ក្រុមហ៊ុនបានបង្កើតនូវគោលដៅគុណភាពដែលត្រូវត្រួតពិនិត្យឡើងវិញ ជាប្រចាំដូចខាងក្រោម៖

- សម្រេចថាគ្មានកំហុសចំពោះគំនូរដែលដាក់ជូន និងដើម្បីការយល់ស្របពីអតិថិជន និង
- សម្រេចការងារឱ្យបានយ៉ាងហោចណាស់ ៩៩,៩% តាមកាលបរិច្ឆេទកំណត់ដោយអតិថិជន។

ជាលទ្ធផល គម្រោងពីមុនរបស់ក្រុមហ៊ុន ត្រូវបានផ្តល់ជូនយ៉ាងត្រឹមត្រូវស្របតាមកាលបរិច្ឆេទ និងគោលដៅគុណភាព ដូចដែលបានកំណត់ដោយក្រុមហ៊ុន។



ក្រុមហ៊ុនដាក់វិធានសុវត្ថិភាព គ្រប់ដំណាក់កាលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ដើម្បីកាត់បន្ថយលទ្ធភាពគ្រោះថ្នាក់ការងារ និងរបួសការងារ។ លើសពីនេះក្រុមហ៊ុនខិតខំដើម្បីធានាសុវត្ថិភាពសម្រាប់សាធារណៈតាមរយៈការពិចារណា និងសម្រេចចិត្តយ៉ាងប្រុងប្រយ័ត្នក្នុងអំឡុងពេលអនុវត្តវិធានធានាសុវត្ថិភាព។ ក្រុមហ៊ុនសង្កត់ធ្ងន់ទៅលើគុណភាពនៃការចែកចាយសេវាកម្ម ដែលអនុញ្ញាតឱ្យក្រុមហ៊ុនទទួលបានលទ្ធផលល្អនៅកម្ពុជា ជាទីផ្សារដែលក្រុមហ៊ុនទទួលបានកិច្ចសន្យាបញ្ជូន និងចែកចាយថាមពលចំបងៗតាំងពីកាលចាប់ផ្តើមធុរកិច្ច។

(v) **ក្រុមហ៊ុនមានថ្នាក់គ្រប់គ្រងដែលមានបទពិសោធន៍ និងមុះមុតដោយសង្កត់ធ្ងន់លើការរីកចម្រើននៃធុរកិច្ចរបស់ក្រុមហ៊ុន**

ក្រុមហ៊ុនត្រូវបានដឹកនាំដោយថ្នាក់គ្រប់គ្រងមានសមត្ថភាពខ្ពស់ ជាមួយបទពិសោធន៍ច្បាស់លាស់ នៅក្នុងផ្នែករចនាប្រព័ន្ធ វិស្វកម្ម និងហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពល និងចែកចាយ។ ក្រុមហ៊ុនយើងត្រូវបានដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល លោក Lim Pay Chuan និងនាយកប្រតិបត្តិ លោក Han Fatt Juan។

- លោក Lim Pay Chuan បានបញ្ចប់ការសិក្សាបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រវិស្វកម្ម អគ្គិសនី (Summa cum Laude) ពីសកលវិទ្យាល័យ Mississippi (ស.រ.អ) នៅឆ្នាំ ១៩៩៣។ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែក វិស្វកម្ម (អគ្គិសនី) ពីសកលវិទ្យាល័យ Cornell (ស.រ.អ) នៅឆ្នាំ ១៩៩៤។ លោក Lim Pay Chuan មានបទពិសោធន៍ផ្នែកវិស្វកម្មបញ្ជូន និងចែកចាយថាមពលអគ្គិសនីជាង ២៦ ឆ្នាំ។ លោកក៏ជា អភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិនៃសម្ព័ន្ធក្រុមហ៊ុន PIB ផងដែរ។
- លោក Han Fatt Juan បានបញ្ចប់ការសិក្សាបរិញ្ញបត្រវិទ្យាសាស្ត្រវិស្វកម្មសំណង់ស៊ីវិលពី សកលវិទ្យាល័យ South Dakota State (ស.រ.អ) នៅឆ្នាំ ១៩៩០។ ក្រោយមកលោកបានទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រក្នុងការគ្រប់គ្រងនៅឆ្នាំ១៩៩២ ពីសកលវិទ្យាល័យដដែល។ លោក Han Fatt Juan មានបទពិសោធន៍ផ្នែកវិស្វកម្មបញ្ជូន និងចែកចាយថាមពលអគ្គិសនីជាង ២៨ ឆ្នាំ។ មុននេះ លោកក៏ជានាយកគ្រប់គ្រងទូទៅនៃផ្នែក ខ្សែបណ្តាញ ថាមពល និងខ្សែកាប របស់សក្រុមហ៊ុន PIB ផងដែរ។

លោក Lim Pay Chuan និង Han Fatt Juan ត្រូវបានគាំទ្រដោយបុគ្គលិកគ្រប់គ្រងសំខាន់ៗដូចខាងក្រោម៖

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

អ្នកគ្រប់គ្រងសំខាន់ៗ	តំណែង	គុណវុឌ្ឍិនៃការសិក្សា	ការងារពាក់ព័ន្ធ
លោកស្រី Teh Bee Choo	នាយកផ្នែកហិរញ្ញវត្ថុ	• ១៩៨៦ បរិញ្ញាបត្រធុរកិច្ចផ្នែកគណនេយ្យពីវិទ្យាស្ថាន Swinburne Institute of Technology ប្រទេសអូស្ត្រាលី • ១៩៩០ គុណវុឌ្ឍិជំនាញ ពីវិទ្យាស្ថាន Institute of Chartered Accountants, Australia	៣៤ ឆ្នាំ
កញ្ញា Tann Sochan	ប្រធានជាន់ខ្ពស់/ លេខាធិការ	• ២០០៧ បរិញ្ញាបត្ររដ្ឋបាលធុរកិច្ច ជំនាញការគ្រប់គ្រងធុរកិច្ច ពីសកលវិទ្យាល័យកម្ពុជា • ២០១១ បរិញ្ញាបត្រជាន់ខ្ពស់រដ្ឋបាលធុរកិច្ច ជំនាញការគ្រប់គ្រងធុរកិច្ចពីសកលវិទ្យាល័យកម្ពុជា	១៧ ឆ្នាំ
លោក N Saravanan Nadarajah	ប្រធានផ្នែកគម្រោង និងការដេញថ្លៃ	• ២០០១ បរិញ្ញាបត្រវិស្វកម្ម ជំនាញវិស្វកម្មថាមពលអគ្គិសនី (កិត្តិយស) ពីសកលវិទ្យាល័យបច្ចេកទេសនៅប្រទេសម៉ាឡេស៊ី	២៣ ឆ្នាំ
លោក Pablo T. Magpantay	ប្រធានផ្នែក O&M	• ២០០៣ បរិញ្ញាបត្រវិទ្យាសាស្ត្រ ជំនាញវិស្វកម្មអគ្គិសនីពីសាកលវិទ្យាល័យ Batangas ប្រទេសហ្វីលីពីន • ១៩៨៥ បរិញ្ញាបត្រវិទ្យាសាស្ត្រ ជំនាញការសិក្សាលើឧស្សាហកម្ម ពីសកលវិទ្យាល័យ Batangas State University ពីមុនឈ្មោះ PBMIT ប្រទេសហ្វីលីពីន	២១ ឆ្នាំ

ថ្នាក់គ្រប់គ្រងរបស់ក្រុមហ៊ុន បានចូលរួមចំណែកយ៉ាងធំធេងចំពោះភាពជោគជ័យរបស់ក្រុមហ៊ុន និងមានបទពិសោធន៍ ចំណេះដឹង និងជំនាញ ចាំបាច់នៅក្នុងឧស្សាហកម្មនេះ ដើម្បីការរីកចម្រើនយ៉ាងមានប្រសិទ្ធិភាពនៃធុរកិច្ចរបស់ក្រុមហ៊ុនបន្តទៅទៀត។

ខ. ផែនការនាពេលអនាគត និងយុទ្ធសាស្ត្រធុរកិច្ច

(i) ក្រុមហ៊ុនមានឆន្ទៈបន្តលើកកំពស់ជំហរទីផ្សាររបស់ក្រុមហ៊ុននៅក្នុងវិស័យបញ្ជូន និងចែកចាយថាមពលនៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការកើនឡើងនៃតម្រូវការថាមពល

ក្រុមហ៊ុនមានផែនការពង្រឹងជំហរទីផ្សាររបស់ខ្លួននៅក្នុងវិស័យបញ្ជូន និងចែកចាយថាមពលនៅកម្ពុជាបន្ថែមទៀត ដោយធានាឱ្យបាននូវការរីកចម្រើនជានិរន្តន៍នៃប្រតិបត្តិការរបស់ក្រុមហ៊ុន ជាមួយនឹងបំណងបង្កើនទីផ្សារទាំងមូលរបស់ក្រុមហ៊ុន។

កម្ពុជាគឺជាប្រទេសកំពុងអភិវឌ្ឍ ដែលមានកំណើនផលិតផលក្នុងស្រុកសរុបខ្ពស់ (ផ.ស.ស) និងទីផ្សារថាមពលដែលកំពុងរីកចម្រើន។ ក្រុមហ៊ុនជឿជាក់ថា គម្លាតតម្រូវការ - ការផ្គត់ផ្គង់ថាមពលនៅកម្ពុជាបច្ចុប្បន្ន រួមគ្នាជាមួយការកើនឡើង នៃការវិនិយោគលើវិស័យថាមពល ផ្តល់នូវបរិយាកាសល្អសមស្របសម្រាប់ក្រុមហ៊ុនដែលមានសមត្ថភាព និងកម្លាំងហិរញ្ញវត្ថុអាចរីកលូតលាស់។

យោងតាមក្រុមហ៊ុន Smith Zander តម្រូវការថាមពលនៅកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើងពី ៨.៦៤៩,៩៨ ជីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០១៨ ដល់ ១២.០១៩,៧៥ ជីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០២០ ដែលស្មើនឹងអត្រាកំណើនមធ្យមប្រចាំឆ្នាំ ប្រមាណ ១៧,៨៨% ដោយផ្អែកលើកំណើនសេដ្ឋកិច្ចរយៈពេលវែង។ ជាងនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសអំពីគម្រោងអភិវឌ្ឍន៍ជាតិជាច្រើន ដើម្បីពង្រឹងប្រព័ន្ធដឹកជញ្ជូនក្នុងស្រុក និងបង្កើនអត្រាប្រើប្រាស់អគ្គិសនីនៅក្នុងប្រទេសកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជាមានគោលបំណងពង្រឹងប្រព័ន្ធបញ្ជូននៅកម្ពុជាដោយ មេគុណ ២០ ដង ពី១២០ គីឡូម៉ែត្រនៅឆ្នាំ២០០១ ដល់ ២.៥៨២ គីឡូម៉ែត្រនៅឆ្នាំ២០២០ ក៏ដូចជាដើម្បីពង្រីកយុទ្ធសាស្ត្របង្កើនអត្រាភ្ជាប់អគ្គិសនីនៅតាមជនបទ ក្នុងគោលដៅធានាថាភូមិទាំងអស់នៅក្នុងប្រទេស នឹងទទួលបានការប្រើប្រាស់អគ្គិសនីនៅត្រឹមឆ្នាំ ២០២០ ដែលរួមបញ្ចូលទាំងការទទួលបានការភ្ជាប់អគ្គិសនីខ្នាតតូច និងអគ្គិសនីក្រៅបណ្តាញ ហើយគ្រួសារប្រមាណ ៧០% នឹងមានអគ្គិសនីនៅត្រឹមឆ្នាំ២០៣០។ នៅចុងឆ្នាំ២០១៨ ខ្សែបញ្ជូនសរុបក្នុងប្រទេសកម្ពុជា មានប្រវែង២.០៣១,០៤ គីឡូម៉ែត្រ។



បរិយាកាសទីផ្សារអំណោយផល រួមបញ្ចូលទាំងប្រវត្តិការងារដែលអាចជឿទុកចិត្ត បានរបស់ក្រុមហ៊ុន បង្កើតលទ្ធភាពឱ្យក្រុមហ៊ុនពង្រីកអាជីវកម្មរបស់ខ្លួននៅកម្ពុជា។ ក្រុមហ៊ុនមានបំណងចាប់យកឱកាស ដែលកើតចេញពីគម្រោងអភិវឌ្ឍន៍ថ្នាក់ជាតិផ្សេងៗ ដើម្បីពង្រីកវិសាលភាពទីផ្សារក្នុងស្រុករបស់ក្រុមហ៊ុននៅប្រទេសកម្ពុជា។ លក្ខខណ្ឌអនាគតជាទូទៅនៅក្នុងប្រទេសកម្ពុជានឹងអាចឱ្យក្រុមហ៊ុនពង្រីកធុរកិច្ច និងពង្រីងជំហររបស់ខ្លួនសម្រាប់ទីផ្សារបញ្ជូន និងចែកចាយថាមពលក្នុងស្រុក។

(ii) **ក្រុមហ៊ុនធ្វើពិពិធកម្មវិស្វកម្មប្រព័ន្ធថាមពលរបស់ក្រុមហ៊ុន និងដំណោះស្រាយបច្ចេកទេសដោយរួមបញ្ចូលហេដ្ឋារចនាសម្ព័ន្ធថាមពល O&M**

អ្នកកាន់កាប់សម្បទានភាគច្រើន ដែលបានទទួលកិច្ចសន្យាដើម្បីសាងសង់ ធ្វើប្រតិបត្តិការ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយថាមពល មិនចូលរួមក្នុងសកម្មភាពបច្ចេកទេស និងសកម្មភាពខាងក្រៅពាក់ព័ន្ធនឹងការកសាងហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយថាមពលនោះទេ។ ដូចនេះ អ្នកកាន់កាប់សម្បទានទាំងនោះជួលក្រុមហ៊ុនយើងសម្រាប់ផ្តល់សេវាជាកញ្ចប់ (turnkey) រួមបញ្ចូល ការរចនា លទ្ធកម្ម ការសាងសង់ ការតម្លើង និងការដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីរួមមាន អនុស្ថានីយ៍ ខ្សែបញ្ជូន និងប្រព័ន្ធខ្សែកាបក្រោមដី សម្រាប់បញ្ជូន និងចែកចាយអគ្គិសនី។

ក្រុមហ៊ុនក៏បានអភិវឌ្ឍសមត្ថភាពក្នុងO&M។ ដូចនេះ វាជាឱកាសរបស់ក្រុមហ៊ុនដើម្បីបន្តផ្តល់សេវា O&M ថាមពល និង/ឬ អ្នកកាន់កាប់សម្បទាន ក្នុងអំឡុងពេលសម្បទាននៃហេដ្ឋារចនាសម្ព័ន្ធថាមពល និងមុនពេលដែលហេដ្ឋារចនាសម្ព័ន្ធថាមពល O&M នោះ ត្រូវផ្ទេរទៅឱ្យអគ្គិសនីកម្ពុជាវិញ។

យើងទទួលបានកិច្ចសន្យាពីក្រុមហ៊ុន អាឡិច ខបភើរេសិន និងដាយអឺមុិន ផៅវ័រ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨ និងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ រៀងគ្នាដើម្បីផ្តល់សេវា O&M សម្រាប់គម្រោងរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ គម្រោងរោងចក្រវារីអគ្គិសនីស្ទឹងតាតៃ - ប្រព័ន្ធបណ្តាញបញ្ជូនរាជធានីភ្នំពេញ និងគម្រោងខេត្តកំពង់ចាម - ខេត្តក្រចេះ។ ជាផ្នែកមួយនៃកិច្ចព្រមព្រៀងផងដែរ ផេសថេក (ខេមបូឌា) នឹងផ្តល់ O&M សម្រាប់គម្រោងទាំងបីលើរយៈពេល ២៥ ឆ្នាំ ចាប់ផ្តើមពីឆ្នាំដំបូងនៃប្រតិបត្តិការអាជីវកម្មរបស់ប្រព័ន្ធបណ្តាញបញ្ជូនថាមពលអគ្គិសនីនីមួយៗ។



(iii) **ក្រុមហ៊ុនមានបំណងធ្វើអាជីវកម្មលើការចែកចាយថាមពលដែលនឹងបង្កើតប្រាក់ចំណូលបន្ថែមសម្រាប់ក្រុមហ៊ុន**

ក្រុមហ៊ុនមានបំណងពង្រីងជំហរទីផ្សាររបស់ខ្លួននៅកម្ពុជា ដោយទិញកាន់កាប់ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីដែលមានស្រាប់ ដើម្បីក្រុមហ៊ុនអាចធ្វើសកម្មភាពចែកចាយថាមពល។ ការចែកចាយថាមពលគឺជាដំណាក់កាលចុងក្រោយក្នុងការផ្គត់ផ្គង់អគ្គិសនី ដែលហេដ្ឋារចនា សម្ព័ន្ធចែកចាយអគ្គិសនី ចែកចាយ ថាមពលពីប្រព័ន្ធបញ្ជូនទៅកាន់អ្នកប្រើប្រាស់តាមលំនៅដ្ឋាន អាជីវកម្ម និងឧស្សាហកម្ម។ ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនី ត្រូវបានគេស្គាល់ផងដែរថាជាបណ្តាញចែកចាយដែលរួមមានខ្សែចែកចាយអគ្គិសនី។ នៅកម្ពុជា ខ្សែបណ្តាញចែកចាយអគ្គិសនី ត្រូវបានដំណើរការដោយឯកជនតាមរយៈសម្បទានការសាងសង់ ប្រតិបត្តិការ និងផ្ទេរ ដែលផ្តល់សិទ្ធិដោយអគ្គិសនីកម្ពុជា។

(iv) **ក្រុមហ៊ុនមានបំណងពង្រីកអាជីវកម្ម ក្នុងវិស័យបញ្ជូន និងចែកចាយថាមពលលើទីផ្សារនៃប្រទេសជិតខាង**

ក្រុមហ៊ុនមានបំណងពង្រីកវត្តមានភូមិសាស្ត្ររបស់ខ្លួន ទៅកាន់បណ្តាប្រទេសកំពុងអភិវឌ្ឍដទៃទៀតនៅក្នុងតំបន់តណ្ឌចិនដែលមានតម្រូវការអភិវឌ្ឍន៍ កែលម្អ និងលើកកម្ពស់ការបញ្ជូន និងចែកចាយអគ្គិសនី។ ដោយសារប្រព័ន្ធនៃការបញ្ជូន និងចែកចាយអគ្គិសនីប្រកបដោយប្រសិទ្ធភាព និងគួរឱ្យទុកចិត្ត ជាតម្រូវការចាំបាច់សម្រាប់សង្គមសម័យទំនើប ទើបបង្កើតឱ្យមានឱកាសសម្រាប់ក្រុមហ៊ុនក្នុងការពង្រីកវិសាលភាពរបស់ខ្លួន និងនាំយកជំនាញរបស់ខ្លួនទៅប្រទេសទាំងនោះ។

ក្នុងផែនការពង្រីកវត្តមានរបស់ក្រុមហ៊ុនទៅកាន់ទីផ្សារថ្មី ក្រុមហ៊ុនមានគម្រោងពង្រីកអាជីវកម្មនៅប្រទេសឡាវ និងប្រទេសមីយ៉ាន់ម៉ា ដែលកំពុងមានតម្រូវការអគ្គិសនីកើនឡើង និងដែលជំរុញឱ្យមានតម្រូវការថ្មី និង/ឬធ្វើឱ្យប្រសើរឡើងលើហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការផលិត សម្រាប់បញ្ជូន និងចែកចាយអគ្គិសនី។ ជាពិសេសស្ថានីយ៍វារីអគ្គិសនី ត្រូវបានគេសាងសង់នៅប្រទេសឡាវដើម្បីផ្គត់ផ្គង់អគ្គិសនីដល់ប្រទេសជិតខាងរបស់ខ្លួន។

ជាលទ្ធផល នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ យើងបានបង្កើតក្រុមហ៊ុន PESTECH (Myanmar) ដែលជាក្រុមហ៊ុនសម្ព័ន្ធរបស់យើង ហើយនេះសរបញ្ជាក់ឱ្យឃើញពីការបោះជំហានរបស់យើងចូលក្នុងទីផ្សារប្រទេសមីយ៉ាន់ម៉ា និងអនុញ្ញាតឱ្យយើងចាប់ផ្តើមចូលរួមក្នុងការដេញថ្លៃជាសាធារណៈ និងចរចាយកកិច្ចសន្យានានាក្នុង

ប្រទេសនេះ។ យើងបានបង្កើតក្រុមហ៊ុន PESTECH Hinthar ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន PESTECH (Myanmar) នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ជាមួយក្រុមហ៊ុនមីយ៉ាន់ម៉ា ដើម្បីពង្រឹងវត្តមាននៅក្នុងទីផ្សារប្រទេសមីយ៉ាន់ម៉ា។ ក្រោយមកទៀតនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ យើងបានបង្កើតក្រុមហ៊ុន PESTECH Microgrid ក្នុងគោលបំណងផ្តល់នូវសេវាប្រព័ន្ធថាមពលខ្នាតតូច និងហេដ្ឋារចនាសម្ព័ន្ធថាមពល នៅតាមបណ្តាជនបទរបស់ប្រទេសមីយ៉ាន់ម៉ា។

ក្រុមហ៊ុននឹងទាញផលចំណេញពីវត្តមាន និងធនធានរបស់ខ្លួននៅប្រទេសកម្ពុជា ដើម្បីពង្រីកចូលទៅក្នុងទីផ្សារទាំងនោះ។ ក្រុមហ៊ុនជឿជាក់ថា ខ្លួនអាចទាញផលប្រយោជន៍ពីកត្តានានាដូចជា ភាពដូចគ្នានៃការអនុវត្តធុរកិច្ច និងភាពស្រដៀងគ្នានៃវប្បធម៌នៅក្នុងតំបន់ឥណ្ឌូចិន បន្ថែមលើភាពខ្លាំងនៃការប្រកួតប្រជែងរបស់ខ្លួន ដើម្បីទទួលជោគជ័យនៅក្នុងប្រទេសទាំងនោះ។

(v) **ក្រុមហ៊ុនមានបំណងបង្កើតរោងចក្រផលិតសម្ភារៈបរិក្ខារ សម្រាប់បង្គុំប្រព័ន្ធថាមពល ដើម្បីធ្វើពិពិធកម្មលំហូរចំណូលរបស់ខ្លួន**

ខណៈពេលក្រុមហ៊ុនមានការលូតលាស់ និងរីកចម្រើន ក្រុមហ៊ុនមានបំណងអភិវឌ្ឍជំនាញផលិតកម្មសម្ភារៈបរិក្ខារ និងបង្កើតរោងចក្រផលិតបង្គុំ និងបរិក្ខារប្រព័ន្ធថាមពល ដើម្បីធ្វើពិពិធកម្មប្រភពចំណូលរបស់ក្រុមហ៊ុន។ លើសពីនេះទៀត វានឹងធ្វើឱ្យមានការពង្រីកប្រភេទផលិតផលដែលស្ថិតក្រោមម៉ាក PESTECH ម៉ាកCOPS ម៉ាក PROCOM និងម៉ាក RETCOMS ដែលប្រើប្រាស់សម្រាប់ការត្រួតពិនិត្យតាមដាន និងការពារអនុស្ថានីយ៍ថាមពលអគ្គិសនី។

ក្រុមហ៊ុនរំពឹងថាទាញផលប្រយោជន៍ពីកិច្ចសហការផ្នែកបច្ចេកទេស និងភាពជាដៃគូបច្ចុប្បន្នរបស់សម្ព័ន្ធក្រុមហ៊ុនផេសថិក ជាមួយនឹងក្រុមហ៊ុនអន្តរជាតិផ្សេងៗនៅក្នុងឧស្សាហកម្មនេះ ក៏ដូចជាដៃគូបច្ចេកវិទ្យាដែលមានសក្តានុពលជាមួយក្រុមហ៊ុនធំៗ ដទៃទៀតនាពេលអនាគត។ ក្រុមហ៊ុនជឿជាក់ថាចំណេះដឹង និងចំណេះធ្វើលើបច្ចេកវិទ្យា ដែលបានពីដៃគូរអាជីវកម្មរបស់ខ្លួន នឹងជួយពង្រីក និងលើកកំពស់ផលិតផលរបស់ខ្លួនជាមួយនឹងការនាំមកនូវផលិតផលថ្មីនៅក្នុងវិស្វកម្ម ការគូសប្លង់ការផលិត ការតំឡើង និងការដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយអគ្គិសនី។

(vi) **ក្រុមហ៊ុនយើងមានបំណងស្វែងរកឱកាសចុះបញ្ជីលើកទីពីរ (secondary listing) ក្នុងផ្សារភាគហ៊ុនប្រទេសថៃ**

យើងមានបំណងស្វែងរកឱកាសចុះបញ្ជីលើកទីពីរក្នុងផ្សារភាគហ៊ុនប្រទេសថៃ បន្ទាប់ពីការបោះផ្សាយនេះ ដោយត្រូវអនុលោមតាមវិធាន និងប៉ទបញ្ញត្តិនៃផ្សារភាគហ៊ុនប្រទេសថៃ។ ការចុះបញ្ជីលើកទីពីរនេះ នឹងរួមបញ្ចូលការចុះបញ្ជីនូវមូលបត្រកម្មសិទ្ធិទាំងអស់របស់ក្រុមហ៊ុនយើងដែលមានស្រាប់នៅផ្សារមូលបត្រកម្ពុជា។ ការចុះបញ្ជីលើកទីពីរ នឹងពង្រីកមូលដ្ឋានវិនិយោគិនរបស់ក្រុមហ៊ុនយើង ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសកម្មភាពជួញដូរលើភាគហ៊ុនរបស់ក្រុមហ៊ុនយើង។

៤.១.៨. បរិមាណលក់ផលិតផល ឬសេវាកម្ម ដែលមានចំនួនច្រើនជាង ១០% នៃចំណូលសរុបរបស់ក្រុមហ៊ុន

	ដំណាច់ការិយបរិច្ឆេទ នៅថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០១៨		ដំណាច់ការិយបរិច្ឆេទ នៅថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០១៩	
ផលិតផល ឬសេវាកម្ម	**ពាន់ដុល្លារអាមេរិក**	**%**	**ពាន់ដុល្លារអាមេរិក**	**%**
គម្រោង	៧៧.១៣២	៩៩,៩	៤៩.៦៥០	៨៧,៤
ផលិតផល	២៥	~(១)	៧.១៧៧	១២,៦
សរុប	**៧៧.១៥៧**	**១០០**	**៥៦.៨២៧**	**១០០**

ចំណាំ៖

(១) តិចជាង០.១% ដែលតិចតួចពេក

ព័ត៌មានបន្ថែមអំពីគម្រោង និងផលិតផលរបស់ក្រុមហ៊ុន មានរៀបរាប់នៅក្នុងផ្នែកទី ៤.១.៦ នៃឯកសារផ្តល់ព័ត៌មាននេះ។

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

៤.១.៩. ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនពាក់ព័ន្ធ ឬក្រុមហ៊ុនហូលឌីង និងផ្នែកសំខាន់ៗនៃធុរកិច្ចរបស់ក្រុមហ៊ុនទាំងនោះ

លេខ	ឈ្មោះ	ប្រភេទនៃទំនាក់ទំនង	ផ្នែកសំខាន់ៗនៃធុរកិច្ច	កាលបរិច្ឆេទចុះបញ្ជីអាជីវកម្ម
១	ក្រុមហ៊ុន PIB	ក្រុមហ៊ុនហូលឌីង	ការកាន់កាប់ការវិនិយោគ និងការផ្តល់ជូននូវ សេវាកម្មគ្រប់គ្រង។ក្រុមហ៊ុនបុត្រ សម្ព័ន្ធនានារបស់ក្រុមហ៊ុន PIB ធ្វើសកម្មភាពចម្បងលើ ការផលិតបង្កុំប្រព័ន្ធ ថាមពល ការប្រតិបត្តិហេដ្ឋារចនាសម្ព័ន្ធ បញ្ជូនថាមពល តាមរយៈ ការសម្បទានលើការសាងសង់ ប្រតិបត្តិការ និងផ្ទេរ (BOT) និងផ្តល់ជូននូវសេវាកម្មរួមបញ្ចូលគ្នាសម្រាប់ការងារវិស្វកម្ម ផ្គត់ផ្គង់ សំណង់ និងការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពល និងតំណាក់អគ្គិសនីផ្សេងៗ។	ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ (បង្កើត និងមានអាសយដ្ឋាននៅប្រទេសម៉ាឡេស៊ី)
២	PESTECH (Myanmar)	បុត្រសម្ព័ន្ធ	វិស្វកម្មប្រព័ន្ធថាមពលទូលំទូលាយ ការសាងសង់ និងគួសបង្គំ ការដំឡើង និង សេវាពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យថាមពលអគ្គិសនី	ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ (បង្កើតឡើង និងមានអាសយដ្ឋាននៅប្រទេសមីយ៉ាន់ម៉ា)
៣	PESTECH Hinthar	បុត្រសម្ព័ន្ធរបស់ PESTECH (Myanmar)	វិស្វកម្មប្រពន័ន្ធថាមពលទូលំទូលាយ ការសាងសង់ និងគួសបង្គំ ការដំឡើង និងសេវាពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យថាមពលអគ្គិសនី	ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ (បង្កើតឡើង និងមានអាស័យដ្ឋាននៅប្រទេសមីយ៉ាន់ម៉ា)
៤.	PESTECH Microgrid	បុត្រសម្ព័ន្ធរបស់ PESTECH Hinthar	ផ្គត់ផ្គង់វិស្វកម្មប្រព័ន្ធថាមពលខ្នាតតូច និងហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនីតាមបណ្តាជនបទរបស់របស់ប្រទេសមីយ៉ាន់ម៉ា។	ថ្ងៃទី១៤ ខែកុម្ភះ ឆ្នាំ២០២០ (បង្កើតឡើង និងមានអាស័យដ្ឋាននៅប្រទេសមីយ៉ាន់ម៉ា)

៤.១.១០. ទិដ្ឋភាពទីផ្សារ និងការចែកចាយ

ការខិតខំប្រឹងប្រែងអភិវឌ្ឍធុរកិច្ច ទីផ្សារ និងការលក់ផលិតផលរបស់ក្រុមហ៊ុន ត្រូវបានដឹកនាំដោយលោក Han Fatt Juan ជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន ដែលមានបទពិសោធន៍រយៈពេល ២៨ឆ្នាំ ក្នុងវិស័យវិស្វកម្មបញ្ជូន និងចែកចាយថាមពល។ លោកត្រូវបានទទួលជំនួយការងារពីលោក N Saravanan Nadarajah ជាប្រធានផ្នែកគម្រោង និងផ្នែកលក់របស់ក្រុមហ៊ុន។

លោក Han Fatt Juan និងលោក N Saravanan Nadarajah បានចូលរួមធ្វើវាល់សកម្មភាពអភិវឌ្ឍទីផ្សារ និងការលក់នានារបស់ក្រុមហ៊ុន។ ក្រុមហ៊ុនប្រើប្រាស់បណ្តាញលក់ផ្សេងៗដើម្បីទទួលបានគម្រោង ក៏ដូចជាដើម្បីលើកកម្ពស់ការយល់ដឹងអំពីសេវាកម្មរបស់ក្រុមហ៊ុន។

(ក) ការដេញថ្លៃ

ក្រុមហ៊ុនធ្វើការដេញថ្លៃគម្រោងនានាពីស្ថាប័នឯកជន និងស្ថាប័នរដ្ឋាភិបាល តាមរយៈការដាក់សំណើដេញថ្លៃទៅភាគីពាក់ព័ន្ធនានា។ សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃសម្រាប់គម្រោងនានាត្រូវបានធ្វើឡើងតាមរយៈវិធីសាស្ត្រផ្សេងៗ រួមមានសារព័ត៌មាន និងគេហទំព័រពាក់ព័ន្ធផ្សេងៗ។ ក្រុមហ៊ុនក៏ទទួលបានលិខិតអញ្ជើញដេញថ្លៃពីក្រុមហ៊ុននានា ដើម្បីចេញនូវការដាក់ថ្លៃសម្រាប់គម្រោងនានាផងដែរ។ នៅពេលដែលក្រុមហ៊ុនបានកំណត់ថាក្រុមហ៊ុនមានកំណត់ត្រាបទពិសោធន៍ និងធនធានគ្រប់គ្រាន់ក្នុងការបំពេញលក្ខណៈប៉ារ៉ាម៉ែត្រ និងលក្ខខណ្ឌតម្រូវនៃគម្រោងហើយនោះ ក្រុមហ៊ុននឹងដាក់ជូននូវការដេញថ្លៃ និងការដាក់ថ្លៃរបស់ក្រុមហ៊ុន។

ជាធម្មតាមានដំណាក់កាលពីរ (០២) នៅក្នុងដំណើរការវាយតម្លៃនៃការដេញថ្លៃ។ ដំណាក់កាលដំបូង (ដំណាក់ទី ១) គឺជាដំណាក់កាលវាយតម្លៃបច្ចេកទេស ដែលបេក្ខជនត្រូវបានគេវាយតម្លៃដោយផ្អែកលើកំណត់ត្រាបទពិសោធន៍ សមត្ថភាពហិរញ្ញវត្ថុ បទពិសោធន៍ និងធនធាន។ នៅពេលដែលបេក្ខជនមានសមត្ថភាពត្រូវបានជ្រើសរើស ពួកគេនឹងបន្តទៅដំណាក់កាលទីពីរ (ដំណាក់កាលទី ២) ដែលជាដំណាក់កាលអាជីវកម្ម។ នៅក្នុងដំណាក់កាលនេះ បេក្ខជនដែលត្រូវបានគេចាត់ទុកថាមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការងារនឹងត្រូវប្រកួតប្រជែងដោយផ្អែកលើយុទ្ធសាស្ត្រនៃការកំណត់ថ្លៃ។

(ខ) ការណែនាំ

ក្រុមហ៊ុនទទួលបាននូវឱកាសអាជីវកម្មថ្មីៗ តាមរយៈការណែនាំពីក្រុមហ៊ុននានាដែលក្រុមហ៊ុនបានធ្វើការជាមួយ។ ក្រុមហ៊ុនទទួលបានការណែនាំសម្រាប់គម្រោងថ្មីៗពីអតិថិជនចាស់ និងអតិថិជនបច្ចុប្បន្ន ពីអ្នកពិគ្រោះយោបល់ខាងក្រៅ និងសហការី

អាជីវកម្មដទៃទៀត ដោយសារកំណត់ត្រាបទពិសោធន៍ និងសេវាកម្មដែលមានគុណភាពរបស់ខ្លួន។

(គ) ការស្នើសុំឱ្យដាក់សំណើ

តាមរយៈបទពិសោធនរបស់ក្រុមហ៊ុននៅក្នុងឧស្សាហកម្មនេះ ក្រុមហ៊ុនក៏ទទួលបានឱកាសអាជីវកម្ម តាមរយៈការអញ្ជើញឱ្យដាក់សំណើ។ ការស្នើសុំសំណើទាំងនោះជាទូទៅពាក់ព័ន្ធនឹងគម្រោងដែលមានតម្រូវការពិសេសជាក់លាក់ ដូចជាគម្រោងមានរយៈពេលរហ័ស គម្រោងដែលតម្រូវឱ្យមានជំនាញពិសេស និងគម្រោងរចនាខុសពីធម្មតា។

(ឃ) បទបង្ហាញបច្ចេកទេស និងការបណ្តុះបណ្តាល

ដោយសហការជាមួយក្រុមហ៊ុន PSB ក្រុមហ៊ុនយើងធ្វើបទបង្ហាញបច្ចេកទេស និងវគ្គបណ្តុះបណ្តាលជាទៀងទាត់ដល់អតិថិជនរបស់ក្រុមហ៊ុន ដើម្បីធ្វើឱ្យអតិថិជនទាំងនោះទទួលបាននូវបច្ចុប្បន្នភាពអំពីប្រភេទបច្ចេកវិទ្យាដែលក្រុមហ៊ុនអាចផ្តល់ជូន ក៏ដូចជាដើម្បីផ្សព្វផ្សាយសេវាកម្មដែលមាននៅក្នុងឧស្សាហកម្មនេះ។

៤.១.១១. ទត្ថុធាតុដើម និងធនធានដាក់បញ្ចូលផ្សេងទៀត

សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ការទិញសំខាន់របស់ក្រុមហ៊ុនសម្រាប់គម្រោង និងផលិតផល មានដូចខាងក្រោម៖

			ការទិញ	
			លានដុល្លារអាមេរិក	
			ការិយបរិច្ឆេទ	ការិយបរិច្ឆេទថ្ងៃទី
			ថ្ងៃទី៣០ ខែមិថុនា	៣០ ខែមិថុនា
លេខ	វត្ថុធាតុដើម និងធនធានដាក់បញ្ចូលផ្សេងទៀត	ឈ្មោះអ្នកផ្គត់ផ្គង់	ឆ្នាំ២០១៨	ឆ្នាំ២០១៩
១	គ្រឿងបង្គុំប្រព័ន្ធថាមពល និងសម្ភារ: និងបរិក្ខារនៃបណ្តាញបញ្ជូនសម្រាប់គម្រោង និងផលិតផលរបស់ក្រុមហ៊ុន	ក្រុមហ៊ុន PSB	១៣,៦	៣៦,៥
២	កិច្ចសន្យាបន្តនៃការងារសំណង់ស៊ីវិលសម្រាប់គម្រោងរបស់ក្រុមហ៊ុន	ក្រុមហ៊ុនផារ័ត្ន វឌ្ឍន: អ៊ី & ស៊ី	១,៥	៤,២
៣	តម្លៃកិច្ចសន្យា	ក្រុមហ៊ុន Enersol Co. Ltd.	២,០	៣៨,៧

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

៤	តម្លៃកិច្ចសន្យា	ក្រុមហ៊ុន PESTECH Transmission Sdn Bhd	-	១,១

៤.១.១២. លក្ខខណ្ឌតម្រូវសម្រាប់ថាមពល ខ្វស្ម័ន និងទឹក ឬខ្វបកអណ៍ប្រើប្រាស់ផ្សេងៗទៀត

លេខ	ធនធានដាក់បញ្ចូល	ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ពាន់ដុល្លារអាមេរិក	ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ពាន់ដុល្លារអាមេរិក
១	ប្រេងឥន្ធនៈ និងម៉ាស៊ូត	១៣១,០	៧៨,១
២	អគ្គិសនី និងទឹក	១៩,៥	២១,២

៤.១.១៣. អតថិជនដែលទិញផលិតផល ឬសេវាកម្មរបស់ក្រុមហ៊ុនចាប់ពី ១០% ឡើងទៅ

អតិថិជនសំខាន់ៗរបស់ក្រុមហ៊ុន (មានន័យថាអតិថិជនទាំងឡាយណាដែលរួមចំណែកដាច់ដោយឡែកពីគ្នានូវ ១០% ឬច្រើនជាងនេះនៃប្រាក់ចំណូល សរុបរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យ) មានដូចខាងក្រោម៖

លេខ	ឈ្មោះអតិថិជន	ប្រភេទផលិតផល ឬសេវាកម្ម	រយៈពេលនៃកិច្ចសន្យា	ចំណូល លានដុល្លារអាមេរិក ដំណាច់ការិយបរិច្ឆេទ ៣០ មិថុនា ២០១៨	ចំណូល លានដុល្លារអាមេរិក ដំណាច់ការិយបរិច្ឆេទ ៣០ មិថុនា ២០១៩
១	ក្រុមហ៊ុន អាឡិចខបភើរេសិន	គម្រោង(១)	ខែមេសា ឆ្នាំ២០១៥ ដល់ខែមករា ឆ្នាំ ២០២០	៥០,៤	២៨,៥
		គម្រោង(២)	ខែមេសា ឆ្នាំ២០១៧ ដល់ខែមេសា ឆ្នាំ ២០២១	១៥,៣	៤,៣
២	ក្រុមហ៊ុន ដាយអឹមុិនផៅវ៉រ	គម្រោង(៣) និង O&M	ខែឧសភា ឆ្នាំ២០១៥ ដល់ខែវិច្ឆិកា ឆ្នាំ ២០១៧	២,៥	២,៤

៣	ក្រុមហ៊ុន Schneitec	គម្រោង[៤]	ខែមករា ឆ្នាំ២០១៨ ដល់ខែធ្នូ ឆ្នាំ២០១៩	៩,៥	១៤,៤
៤	អគ្គីសនីកម្ពុជា	ផ្គង់ផ្គង់សម្ភារ	ខែមេសា ឆ្នាំ២០១៩ ដល់ខែកញ្ញា ឆ្នាំ ២០២០	-	៧,២

ចំណាំ៖

(១) សម្រាប់គម្រោងរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ

(២) សម្រាប់គម្រោងស្ថានីយ៍វារីអគ្គិសនីស្ទឹងតាតៃ - ប្រព័ន្ធបណ្តាញចាយពលអគ្គិសនីរាជធានីភ្នំពេញ

(៣) សម្រាប់គម្រោងខេត្តកំពង់ចាម - ខេត្តក្រចេះ

(៤) សម្រាប់គម្រោងខេត្តសៀមរាប - ខេត្តឧត្តរមានជ័យ

ព័ត៌មានលម្អិតបន្ថែមស្តីពីការពឹងផ្អែករបស់ក្រុមហ៊ុនទៅលើអតិថិជនធំៗ មានរៀបរាប់នៅផ្នែកទី ៣.៤.៧ នៃឯកសារផ្តល់ព័ត៌មាននេះ។

៤.១.១.៤.អ្នកផ្គត់ផ្គង់ដែលផ្គត់ផ្គង់លើការទិញលក់របស់ក្រុមហ៊ុន ១០% ឬច្រើនជាងនេះ

អ្នកផ្គត់ផ្គង់ធំៗរបស់ក្រុមហ៊ុន (មានដូចជា អ្នកផ្គត់ផ្គង់ដែលរួមចំណែកក្នុងការទិញសរុបរបស់ក្រុមហ៊ុនចំនួន ១០% ឬច្រើនជាងនេះ សម្រាប់ឆ្នាំហិរញ្ញវត្ថុដែលស្ថិតក្រោមការត្រួតពិនិត្យ) មានដូចខាងក្រោម៖

លេខ	ឈ្មោះអ្នកផ្គត់ផ្គង់	ប្រភេទផលិតផល ឬសេវាកម្ម	ការទិញ លានដុល្លារអាមេរិក ដំណាច់ការិយបរិច្ឆេទ ៣០ មិថុនា ២០១៨	ដំណាច់ការិយបរិច្ឆេទ ៣០ មិថុនា ២០១៩	រយៈពេលនៃកិច្ចសន្យា
១	ក្រុមហ៊ុន PSB	ផ្គត់ផ្គង់សម្ភារ:	១៣,៦	៣៦,៥	គ្មាន
២	ក្រុមហ៊ុន ផារ័ត្ន វឌ្ឍន: អ៊ី & ស៊ី	សេវាកម្មសំណង់ស៊ីវិល	១,៥	៤,២	គ្មាន
៣	ក្រុមហ៊ុន Enersol Co., Ltd.	ផ្គត់ផ្គង់សម្ភារ:	១,៩	៣៨,៧	គ្មាន

៤	ក្រុមហ៊ុន PESTECH Transmission Sdn Bhd	ផ្គត់ផ្គង់សម្ភារៈ	១២ ឆ្នាំ

ព័ត៌មានបន្ថែមស្តីពីការពឹងផ្អែករបស់ក្រុមហ៊ុន ទៅលើក្រុមហ៊ុនសម្ព័ន្ធ PIB មានរៀបរាប់នៅផ្នែកទី ៧.៥.១ នៃឯកសារផ្តល់ព័ត៌មាននេះ។

៤.១.១៥. ប្រកាសនីយបត្រកក្កកម្ម ម៉ាក ពាណិជ្ជនាម អាជ្ញាបណ្ណ និង ម្ភកច្ចព្រមព្រៀង ផ្សេងទៀតលើសិទ្ធិកម្មសិទ្ធិបញ្ញា

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនមានស្លាកសញ្ញា ប្រកាសនីយបត្រកក្កកម្ម ពាណិជ្ជនាម អាជ្ញាបណ្ណ កិច្ចព្រមព្រៀងកម្រៃជើងសារ និងកម្មសិទ្ធិបញ្ញាដទៃទៀតសម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនឡើយ។

៤.១.១៦. ចំនួននិយោជិតពេញម៉ោង និងនិយោជិតសរុប

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមានកម្លាំងពលកម្មសរុបចំនួន ១០៩ នាក់ ធ្វើការពេញម៉ោង ដែលក្នុងនោះមាន ៦២ នាក់ ជានិយោជិតក្នុងស្រុក និង ៤៧ នាក់ ទៀតជានិយោជិតបរទេស។

តារាងខាងក្រោមបង្ហាញអំពីគុណវុឌ្ឍិរបស់និយោជិតក្រុមហ៊ុនត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ៖

គុណវុឌ្ឍិ/ប្រភេទសញ្ញាបត្រ	ចំនួននិយោជិត
បរិញ្ញាបត្រជាន់ខ្ពស់	១០
បរិញ្ញាបត្រ	៣៥
មធ្យមសិក្សាទុតិយភូមិ	៤
វិញ្ញាបនបត្រ	៨
សរុប	**៥៧**

៤.១.១៧. សក្ការទុពលនៃសមត្ថភាពផលិត ឬសេវាកម្ម

សេវាកម្មរបស់ក្រុមហ៊ុនចម្បងគឺផ្តល់ជូនតាមរយៈមូលដ្ឋាននៃកិច្ចសន្យា សម្រាប់ការគូសប្តង់ លទ្ធកម្ម ការសាងសង់ ការតម្លើង និងការដាក់ឱ្យដំណើរការអនុស្ថានីយ៍ដែលមានតង់ស្យុងខ្ពស់និងតង់ស្យុងខ្ពស់ខ្លាំង បណ្តាញបញ្ជូនមានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គិសនីក្រោមដីម្រាប់បញ្ជូន និងចែកចាយអគ្គិសនី។ រយៈពេលដើម្បីបញ្ចប់គម្រោងមួយ ពីដំណាក់កាលគូសប្តង់រហូតដល់ដំណាក់កាលដាក់ឱ្យដំណើរការ និងប្រគល់ជូនទៅអតិថិជន អាចប្រែប្រួលពី

ប្រាំមួយ (៦) ខែ រហូតដល់ពីរ ឬបីឆ្នាំ។ រយៈពេលបញ្ចប់គម្រោង អាស្រ័យទៅលើវិសាលភាពការងារដែលត្រូវធ្វើ និងតម្រូវការ ព្រមទាំងលក្ខខណ្ឌជាក់លាក់របស់អតិថិជន។

បច្ចុប្បន្នក្រុមហ៊ុនមិនត្រូវបានកម្រិតសមត្ថភាពក្នុងការទទួលយកកិច្ចសន្យាបន្ថែមលើការគូសប្លង់ លទ្ធកម្ម ការសាងសង់ ការតម្លើង និងការដាក់ឱ្យដំណើរការអនុស្ថានីយ៍ដែលមានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង បណ្តាញបញ្ជូនដែលមានតង់ស្យុងខ្ពស់ និងមានតង់ស្យុងខ្ពស់ខ្លាំង ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គិសនីក្រោមដីសម្រាប់បញ្ជូន និងចែកចាយអគ្គិសនីឡើយ។ ទាំងនេះដោយសារក្រុមហ៊ុនអាចស្វែងរកការគាំទ្រផ្នែកបច្ចេកទេសជំនាញពីសម្ព័ន្ធក្រុមហ៊ុនផេសថិក ទៅតាមករណីនីមួយៗ។

៤.១.១៨. ប្រតិបត្តិការជាមួយក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនដែលពាក់ព័ន្ធ

ក្រៅពីការរៀបរាប់ខាងក្រោម ក្រុមហ៊ុនមិនមានបង្កើត ឬត្រៀមបង្កើតទំនាក់ទំនងប្រតិបត្តិការនាពេលបច្ចុប្បន្ន ឬប្រតិបត្តិការដែលបានដាក់ស្នើ ពីសំណាក់ភាគីពាក់ព័ន្ធ សម្រាប់ឆ្នាំហិរញ្ញវត្ថុ ពីរ (២) ឆ្នាំចុងក្រោយ មុនកាលបរិច្ឆេទនៃឯកសារផ្តល់ព័ត៌មាននេះឡើយ៖

លេខ	ភាគីប្រតិបត្តិការ	ទំនាក់ទំនង	ប្រតិបត្តិការ	ការិយបរិច្ឆេទ ៣០ មិថុនា ២០១៨ ពាន់ដុល្លារអាមេរិក	ការិយបរិច្ឆេទ ៣០ មិថុនា ២០១៩ ពាន់ដុល្លារអាមេរិក
១.	ក្រុមហ៊ុន ដាយអឺមុិន ផៅវ័រ	ជាក្រុមហ៊ុនដែលមានអភិបាលមានផលប្រយោជន៍ដោយប្រយោល ឬតាមរយៈ	ការផ្តត់ផ្គង់សេវាទាក់ទងនឹងការគូសប្លង់ ការសាងសង់ ការសាកល្បង និងការដាក់ឱ្យប្រើប្រាស់គម្រោងប្រព័ន្ធចែកចាយដែលមានកំលាំងអគ្គិសនី ២៣០គីឡូវ៉ុល ពីខេត្តកំពង់ចាម - ខេត្តក្រចេះ	២.៤៧១	២.៤០៦
២.	ក្រុមហ៊ុន PESTECH Power Sdn Bhd	ជាក្រុមហ៊ុនដែលមានអភិបាលមានផលប្រយោជន៍ដោយប្រយោល ឬតាមរយៈ	ការទូទាត់មុន	-	១.២៧០

៤. ព័ត៌មានរបស់ក្រុមហ៊ុន (ត)

៣.	ក្រុមហ៊ុន PIB[1]	ជាក្រុមហ៊ុនដែលមានអភិបាលមានផលប្រយោជន៍ដោយប្រយោល ឬតាមរយៈ:	ការទិញលក់ផលិតផល និងបរិក្ខារសម្រាប់គម្រោងរបស់ក្រុមហ៊ុន	១៣.៦០៧	៣៦.៥០១
៤.	ក្រុមហ៊ុន Enersol Co., Ltd	ជាក្រុមហ៊ុនដែលមានអភិបាលដែលមានប្រយោជន៍ដោយប្រយោល ឬតាមរយៈ:	ការជាវផលិតផល និងបរិក្ខារសម្រាប់គម្រោង	១.៩៧៣	៣៨.៧២៤
៥.	ក្រុមហ៊ុន PESTECH Energy Sdn (ពីមុនមានឈ្មោះថា Xcell ATS (M) Sdn Bhd)	ជាក្រុមហ៊ុនដែលមានអភិបាលដែលមានប្រយោជន៍ដោយប្រយោល ឬតាមរយៈ:	ការជាវផលិតផល	៩	-
៦.	ក្រុមហ៊ុន PESTECH Transmission Sdn	ជាក្រុមហ៊ុនដែលមានអភិបាលដែលមានប្រយោជន៍ដោយប្រយោល ឬតាមរយៈ:	ការជាវផលិតផល និងបរិក្ខារសម្រាប់គម្រោង	-	១.១៤១
៧.	PIB	ជាក្រុមហ៊ុនដែលមានអភិបាលដែលមានប្រយោជន៍ដោយប្រយោល ឬតាមរយៈ:	ការគ្រប់គ្រងផ្នែកសេវា	៥៣៣	៣០១

ចំណាំ៖

[1] ជាក្រុមហ៊ុនហួលមឹងមុនរបស់ក្រុមហ៊ុន មុនពេលធ្វើការរៀបចំផ្នែកក្នុងឡើងវិញ

៤.២. ផែនការប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ

៤.២.១. រដ្ឋាយការណ៍ព្យាករណ៍ប្រាក់ចំណេញ

ក្រុមហ៊ុនយើងបានទទួលការអនុញ្ញាតពី គ.ម.ក ក្នុងការមិនបង្ហាញរបាយការណ៍ព្យាករណ៍ប្រាក់ចំណេញ។

៤.២.២. ការព្យាករណ៍ការផ្លាស់ប្តូរចំនួននិយោជិត

ក្រុមហ៊ុនមិនរំពឹងថាមានការផ្លាស់ប្តូរជាចម្បងចំពោះចំនួននិយោជិតសម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឡើយ។

៤.២.៣. ប្រភពដើមទុនខាងក្នុង និងខាងក្រៅ

តារាងខាងក្រោម បង្ហាញពីប្រភពដើមទុនទាំងខាងក្នុង និងខាងក្រៅរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ៖

	ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ពាន់ដុល្លារអាមេរិក	ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ពាន់ដុល្លារអាមេរិក
ប្រភពដើមទុនខាងក្នុង		
ដើមទុន	៧.១០០	៧.១០០
ដើមទុនបម្រុងទុក	៥២	(១.៧៧២)
ចំណេញរក្សាទុក	២០.៦៣១	៨.៥៩៥
សរុប	**២៧.៧៨៣**	**១៣.៩២៣**
ប្រភពដើមទុនខាងក្រៅ		
ទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុនមេ	៥៦៥	៥៩.៥៥៨
ទឹកប្រាក់ដែលជំពាក់ភាគីសម្ព័ន្ធញាតិ	៤៩.៦៧៩	២៣.០១៨
ប្រាក់កម្ចី	២២.០១៣	៩៩.៥៨៧
សរុបបឋម	**៧២.២៥៧**	**១៨២.១៦៣**
សរុប	**១០០.០៤០**	**១៩៦.០៨៦**

៤.២.៤. ការចំណាយដើមទុនចម្បង និងប្រភពហិរញ្ញវត្ថុដែលពឹងទុកសម្រាប់ការចំណាយនោះ

ក្រុមហ៊ុនមិនរំពឹងថា នឹងមានការចំណាយដើមទុនជាចម្បងណាមួយ សម្រាប់រំណាចការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ឡើយ។

៤.២.៥. ការផ្លាស់ប្តូរចម្បងលើប្រាក់ចំណូល តម្លៃនៃការលក់ ការចំណាយប្រតិបត្តិការផ្សេងទៀត និងប្រាក់ចំណេញសុទ្ធ

តារាងខាងក្រោមបង្ហាញ ការផ្លាស់ប្តូរចម្បងលើប្រាក់ចំណូល តម្លៃនៃការលក់ ការចំណាយប្រតិបត្តិការផ្សេងទៀត និងប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន ។ តារាងខាងក្រោម គួរត្រូវអានរួមគ្នាជាមួយនឹង "កិច្ចពិភាក្សាថ្នាក់គ្រប់គ្រង និងការវិភាគលក្ខខណ្ឌហិរញ្ញវត្ថុ និងសមិទ្ធផលប្រតិបត្តិការក្រុមហ៊ុន" ដែលមាននៅក្នុងផ្នែកទី៧.៤ នៃឯកសារផ្តល់ព័ត៌មាននេះ។

	ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ពាន់ដុល្លារអាមេរិក	ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ពាន់ដុល្លារអាមេរិក	ការប្រែប្រួល ពាន់ដុល្លារអាមេរិក	ការប្រែប្រួល %
ចំនួល	៧៣.១៥៧	៥៦.៨២៧	(២០.៣៣០)	(២៦,៣)
ថ្លៃដើមពីការលក់ និងការសាងសង់	៦២.៩៦៧	៤៩.៧៧០	(១៣.១៩៧)	(២១,០)
ចំណាយប្រត្តិបត្តការ	៤.០៦៣	២.៧៨១	(១.២៨២)	(៣១,៦)
ចំណេញក្នុងគ្រា	**៧.៥៨១**	**១.៧៧៥**	**(៥.៨០៦)**	**(៧៦,៦)**

៤.២.៦. ទិដ្ឋភាពតាមរដូវកាលនៃអាជីវកម្មរបស់ក្រុមហ៊ុន

ធុរកិច្ចរបស់ក្រុមហ៊ុនមិនធ្លាប់មានបទពិសោធន៍ ផ្លាស់ប្តូរតាមរដូវកាលនោះទេ។

៤.២.៧. និន្នាការ ព្រឹត្តការណ៍ ឬភាពមិនច្បាស់លាស់ណាមួយដែលបានដឹង

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ប្រតិបត្តិការរបស់ក្រុមហ៊ុនមិនត្រូវបាន ឬរំពឹងថានឹងទទួលរងផលប៉ះពាល់ពី និន្នាការនៃភាពមិនច្បាស់លាស់ តម្រូវការ ការប្តេជ្ញាចិត្ត ឬព្រឹត្តិការណ៍ ដែលអាចមានផលពាល់ធ្ងន់ធ្ងរលើលទ្ធផលហិរញ្ញវត្ថុ ស្ថានភាព និងប្រតិបត្តិការរបស់ក្រុមហ៊ុន ក្រៅពីដូចដែលបានពិភាក្សាក្នុងផ្នែកកិច្ចពិភាក្សា និងការវិភាគរបស់ថ្នាក់គ្រប់គ្រងស្តីពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលនៃប្រតិបត្តិការក្រុមហ៊ុន ដូចមានរៀបរាប់នៅផ្នែកទី ៧.៤ នៃឯកសារផ្តល់ព័ត៌មាននេះឡើយ។

៤.២.៨. ការផ្លាស់ប្តូរទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនដែលប្រើប្រាស់សម្រាប់សងបំណុល

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនរំពឹងថាមានការផ្លាស់ប្តូរទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនណាមួយ ដែលនឹងត្រូវបានប្រើសម្រាប់ការសងបំណុលរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឡើយ។

៤.២.៩. កម្ចីចម្បងៗ (Material Loan) រវាងក្រុមហ៊ុនហូលឌីង និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបានបញ្ជាក់យ៉ាងមុតមាំថា មិនមានប្រាក់កម្ចីដែលមិនទាន់សងដែលបានផ្តល់ឱ្យរវាងក្រុមហ៊ុនមេ និងសម្ព័ន្ធញ្ញាតិរបស់ក្រុមហ៊ុនដល់ជាប្រយោជន៍របស់ភាគីពាក់ព័ន្ធ សម្រាប់ដំណាច់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ។

៤.២.១០. បំណុលជាយថាហេតុ និងបំណុលកិច្ចសន្យានាពេលអនាគត

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ លើកលែងដូចមានបង្ហាញក្នុងផ្នែកទី ៧.៥.៨ ស្តីអំពីបំណុលជាយថាហេតុ ក្នុងឯកសារបង្ហាញព័ត៌មាននេះ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន មិនបានដឹងអំពីបំណុលកិច្ចសន្យា ឬបំណុលជាយថាហេតុណាមួយ កើតចេញពីក្រុមហ៊ុនដែលក្នុងករណីមានការអនុវត្តអាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះឡើយ។

៤.២.១១. អាករលើតំលៃបន្ថែម ពន្ធលើប្រាក់ចំណេញ ភាគទ្រកិច្ចពន្ធគយ ឬបំណុលពន្ធដែលមិនច្បាស់ទូទាត់ ផ្សេងៗទៀត រួមទាំងបំណុល ជាយថាហេតុណាមួយ

លើកលែងដូចមានបង្ហាញនៅក្នុងផ្នែកទី ៧.៥.៨ ស្តីអំពីបំណុលជាយថាហេតុ ដែលមានរៀបរាប់ក្នុងឯកសារបង្ហាញព័ត៌មាននេះ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមិនបានដឹងថាមានបំណុលពន្ធផ្សេងទៀតដែលមិនទាន់បានទូទាត់គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយនោះឡើយ។

៤.២.១២. តតសន្យាប្រតបត្តការនិងតតសន្យាហិរញ្ញវត្ថុ

ក្រៅពីដូចបង្ហាញតាមរយៈតារាងខាងក្រោម ក្រុមហ៊ុនមិនមានភតិប្រតិបត្តិការនិងភតិសន្យាហិរញ្ញវត្ថុដទៃទៀតនោះទេ។

	ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៨ ពាន់ដុល្លារអាមេរិក	ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៩ ពាន់ដុល្លារអាមេរិក
ក្នុងរយៈពេលមួយ(០១)ឆ្នាំ	៥៦	៥៦
ក្នុងរយៈពេលពីរ(០២) ទៅប្រាំ (០៥) ឆ្នាំ	៧៤	១៣
សរុប	១៣០	៦៩

៤.២.១៣. បទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងបុគ្គលិក រួមទាំងផលប្រយោជន៍ចូលនិវត្តន៍ដែលមិនពាក់ព័ន្ធនឹងការចោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ ក្រុមហ៊ុន

ក្រុមហ៊ុនផ្តល់ជូននូវកម្មវិធីផ្តល់អត្ថប្រយោជន៍ ដែលអនុលោមតាមបទបញ្ញត្តិក្នុងស្រុក និងដែលមានការប្រកួតប្រជែងជាមួយនឹងការអនុវត្តលើទីផ្សារ។ អត្ថប្រយោជន៍ទាំងនេះ រួមមានការឈប់សម្រាកប្រចាំឆ្នាំ និងការឈប់សម្រាកផ្សេងៗទៀត អត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រ ការទូទាត់សំណង និងសមាជិកភាពដល់សង្គមវិជ្ជាជីវៈ។

អនុលោមទៅតាមបញ្ញត្តិរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃប្រទេសកម្ពុជា ក្រុមហ៊ុនឹងផ្តល់ប្រាក់ឧបត្ថម្ភដល់និយោជិត ដែលមានសិទ្ធិទទួលបានមូលនិធិជាតិសន្តិសុខសង្គម។

ក្រៅពីអត្ថប្រយោជន៍ និងប្រាក់ឧបត្ថម្ភខាងលើ ក្រុមហ៊ុនមិនមាន ប្រាក់សោធន ប្រាក់សោធននិវត្តន៍ ឬអត្ថប្រយោជន៍ស្រដៀងគ្នាសម្រាប់និយោជិតរបស់ក្រុមហ៊ុនឡើយ។

៤.៣. ព័ត៌មានពាក់ព័ន្ធនឹងទ្រព្យសកម្មរបស់ក្រុមហ៊ុន

៤.៣.១. អចលនទ្រព្យ រោងចក្រនិងបរិក្ខារ ទ្រព្យសម្បត្តិជីវសាស្ត្រ និងសិទ្ធិនៃកម្មសិទ្ធិបញ្ញា

ក. ការពិពណ៌នាអំពីទ្រព្យសម្បត្តិ និងបរិក្ខារ

(i) ការពិពណ៌នាអំពីអចលនទ្រព្យ

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនមានអចលនទ្រព្យទេ។

(ii) **ការពិពណ៌នាអំពីអោងចក្រ**

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនមានអោងចក្រទេ។

(iii) **ការពិពណ៌នាអំពីគ្រឿងបរិក្ខារ**

សេចក្តីសង្ខេបអំពីគ្រឿងបរិក្ខារ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

ការពិពណ៌នា	តម្លៃដើម ជាន់ដុល្លារអាមេរិក	ថ្ងៃចុងគ្រា ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ជាន់ដុល្លារអាមេរិក
បរិក្ខារ	៣.១៨៧	១.៩៧៥
ម៉ូតូ រថយន្ត	៥២៥	២៥៧
គ្រឿងសង្ហារឹម	៣១	៦
បរិក្ខារកុំព្យូទ័រ	២៤	៩
សរុប	**៣.៧៦៧**	**២.២៤៧**

(iv) **ការវាយតម្លៃលើទ្រព្យសម្បត្តិ និងបរិក្ខារ**

ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមានភាគច្រើនជាបរិក្ខារ ហើយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនគិតថា ការវាយតម្លៃឡើងវិញលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនគឺមិនមានភាពចាំបាច់នោះទេ។ ក្រុមហ៊ុនបានអនុវត្តយកតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិរបស់កម្ពុជា ហើយទ្រព្យសម្បត្តិ និងបរិក្ខាររបស់ក្រុមហ៊ុនត្រូវបានវាយតម្លៃតាមថ្លៃដើម ដោយដកចេញនូវរំលោះបង្គរ និងការខាតបង់លើការខូចខាត។

(v) **ទ្រព្យសម្បត្តិ និងបរិក្ខារដែលដាក់ក្រោមកិច្ចធានា**

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនមានទ្រព្យសម្បត្តិ និងបរិក្ខារដែលដាក់ក្រោមកិច្ចធានានោះឡើយ។

ខ **ការពិពណ៌នាអំពីទ្រព្យសម្បត្តិជីវសាស្ត្រ**

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនមានទ្រព្យសម្បត្តិជីវសាស្ត្រឡើយ។

គ. **កម្មសិទ្ធិបញ្ញា**

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនមានកម្មសិទ្ធិបញ្ញាណាមួយឡើយ។

៤.៣.២. ការវាយតម្លៃលើទ្រព្យ និងការវាយតម្លៃឡើងវិញ (រាប់បញ្ចូលទាំងវិធីសាស្ត្រវាយតម្លៃ កាលបរិច្ឆេទនៃការវាយតំលៃ ឈ្មោះ អ្នកវាយតម្លៃឯករាជ្យ)

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនបានធ្វើការវាយតម្លៃឡើងវិញពីទ្រព្យសម្បត្តិ និងបរិក្ខាររបស់ខ្លួនទេ។ ទ្រព្យសម្បត្តិ និងបរិក្ខាររបស់ក្រុមហ៊ុនត្រូវបានវាយតម្លៃតាមថ្លៃដើម ដោយដកចេញនូវចំណាយរំលោះបង្គរ និងការខាតបង់លើការខូចខាត ៕

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា

៥. ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន

៥.១. អភិបាល និងបុគ្គលិកជាន់ខ្ពស់

៥.១.១. ជីវប្រវត្តិសង្ខេបដោយមានបញ្ជាក់អត្តសញ្ញាណ និងគុណវុឌ្ឍិរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

ក. ជីវប្រវត្តិសង្ខេបរបស់អភិបាល

ល.រ	ឈ្មោះ	មុខតំណែង	សញ្ជាតិ	ថ្ងៃខែឆ្នាំកំណើត	ការសិក្សា និងបទពិសោធន៍ការងារ
១.	លោក Lim Pay Chuan	ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ	ម៉ាឡេស៊ី	ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧០	• ឆ្នាំ១៩៩៣៖ បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ជំនាញវិស្វកម្មអគ្គិសនី ពីសាកលវិទ្យាល័យ Mississippi ស.រ.អ (Summa Cum Laude) • ឆ្នាំ១៩៩៤៖ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិស្វកម្ម (អគ្គិសនី) ពីសាកលវិទ្យាល័យ Cornell ស.រ.អ • ជំនាញគ្រប់គ្រងគម្រោង (Certified Project Management Professional) នៅវិទ្យាស្ថានគ្រប់គ្រងគម្រោងចាប់ពីឆ្នាំ២០១១ • សមាជិកជាន់ខ្ពស់ (Fellow member) វិទ្យាស្ថានវិស្វកររនៃប្រទេសម៉ាឡេស៊ីចាប់ពីឆ្នាំ ២០១៧ (ជាសមាជិកចាប់ពីឆ្នាំ២០០៥) • វិស្វករជំនាញ ដោយមានវិញ្ញាបនបត្រអនុវត្ត នៅគណៈវិស្វកររនៃប្រទេសម៉ាឡេស៊ីចាប់ពីឆ្នាំ២០០៧ • សមាជិកស្តាប់នវិស្វករអាស៊ានចាប់ពីឆ្នាំ២០១៦ • សមាជិកគណៈវិស្វករកម្ពុជាចាប់ពីឆ្នាំ២០១៧ • ចុះបញ្ជីក្រោម Asia Pacific Economic Cooperation Register

៥. ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ត)

ល.រ	ឈ្មោះ	មុខតំណែង	សញ្ជាតិ	ថ្ងៃខែឆ្នាំកំណើត	ការសិក្សា និងបទពិសោធន៍ការងារ
					ជាវិស្វករជំនាញអន្តរជាតិនៅស្ថាប័នវិស្វករជំនាញ និង ASEAN Engineering Register ចាប់ពីឆ្នាំ២០១៧
២.	លោក Lim Ah Hock	អភិបាល	ម៉ាឡេស៊ី	ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៥២	• ឆ្នាំ១៩៧៨៖ បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ជំនាញវិស្វកម្មមេកានិក (ចំណាត់ថ្នាក់លេខមួយ) ពីសាកលវិទ្យាល័យ Stathclyde ក្រុង Glasgow ប្រទេសអង់គ្លេស • ជាសមាជិកនៃ Institute of Engineers ប្រទេសម៉ាឡេស៊ីចាប់ពីឆ្នាំ ១៩៨១។
៣.	លោក Han Fatt Juan	អភិបាលប្រតិបត្តិ/ នាយកប្រតិបត្តិ	ម៉ាឡេស៊ី	ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៦៥	• ឆ្នាំ១៩៩០៖ បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រជំនាញវិស្វកម្មសំណង់ស៊ីវិល ពីសាកលវិទ្យាល័យរដ្ឋ South Dakota ស.រ.អ • ឆ្នាំ១៩៩២៖ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រជំនាញការគ្រប់គ្រង ពីសាកលវិទ្យាល័យរដ្ឋ South Dakota ស.រ.អ
៤.	លោក Tan Pu Hooi	អភិបាល	ម៉ាឡេស៊ី	ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧១	• ឆ្នាំ១៩៩៥៖ បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រជំនាញហិរញ្ញវត្ថុធុរកិច្ច ពីសាកលវិទ្យាល័យ Kansas រដ្ឋ Kansas ស.រ.អ • ឆ្នាំ១៩៩៦៖ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងពាណិជ្ជកម្ម (កិត្តិយស) ហិរញ្ញវត្ថុ និងការវិនិយោគ ពីសាកលវិទ្យាល័យ Washburn រដ្ឋ Kansas ស.រ.អ • គុណវុឌ្ឍិផ្នែកហិរញ្ញវត្ថុអភិបាលកិច្ចចេញដោយ Institute of Chartered Accountants ប្រទេសអង់គ្លេស និងវែល (ICAEW) ចាប់ពីឆ្នាំ២០០៨

៥. ព័ត៌មានពាក់ព័ន្ធនឹងអតថ្ថាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ត)

ល.រ	ឈ្មោះ	មុខតំណែង	សញ្ជាតិ	ថ្ងៃខែឆ្នាំកំណើត	ការសិក្សា និងបទពិសោធន៍ការងារ
៥.	ឯកឧត្តម ងាវ អាន សាន	អភិបាលឯករាជ្យ	ខ្មែរ	ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៩	• ឆ្នាំ២០០០៖ បរិញ្ញាបត្រផ្នែកគ្រប់គ្រងអាជីវកម្ម (ផ្នែកគ្រប់គ្រង) ពីសាកលវិទ្យាល័យជាតិកម្ពុជា • ឆ្នាំ២០០១៖ បរិញ្ញាបត្រផ្នែកច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច • ឆ្នាំ ២០០៣៖ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច ពីរាជបណ្ឌិត្យសភាកម្ពុជា • ឆ្នាំ ២០០៩៖ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគោលនយោបាយសេដ្ឋកិច្ច ពី Center for Development Economics, Williams College, Massachusetts ស.រ.អ

៥. ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ក)

ខ. ជីវប្រវត្តិសង្ខេបរបស់បុគ្គលិកជាន់ខ្ពស់

ល.រ	ឈ្មោះ	មុខតំណែង	សញ្ជាតិ	ថ្ងៃខែឆ្នាំកំណើត	ការសិក្សា និងបទពិសោធន៍ការងារ
១.	លោក Han Fatt Juan	អភិបាល ប្រតិបត្តិ/ នាយកប្រតិបត្តិ	ម៉ាឡេស៊ី	ថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៦៥	• ឆ្នាំ១៩៩០៖ បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រជំនាញវិស្វកម្មសំណង់ស៊ីវិល ពីសកលវិទ្យាល័យរដ្ឋ South Dakota ស.រ.អ • ឆ្នាំ១៩៩២៖ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រជំនាញការគ្រប់គ្រង ពីសកលវិទ្យាល័យរដ្ឋ South Dakota ស.រ.អ
២.	លោកស្រី Teh Bee Choo	នាយកផ្នែក ហិរញ្ញវត្ថុ	ម៉ាឡេស៊ី	ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៦៣	• ឆ្នាំ១៩៨៦៖ បរិញ្ញាបត្រផ្នែកធុរកិច្ចជំនាញគណនេយ្យ និងដំណើរការទិន្នន័យ ពីវិទ្យាស្ថានបច្ចេកវិទ្យា Swinburne ប្រទេសអូស្ត្រាលី • សមាជិក Institute of Chartered Accountants ប្រទេសអូស្ត្រាលី ចាប់ពីឆ្នាំ១៩៩០ • សមាជិក Malaysian Institute of Accountants ចាប់ពីឆ្នាំ១៩៩៣
៣.	កញ្ញា Tann Sochan	ប្រធានជាន់ខ្ពស់/ លេខាធិការ	ខ្មែរ	ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៨៥	• ឆ្នាំ២០០៧៖ បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យកម្ពុជា • ឆ្នាំ២០១១៖ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យកម្ពុជា

៥. ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ត)

ល.រ	ឈ្មោះ	មុខតំណែង	សញ្ជាតិ	ថ្ងៃខែឆ្នាំកំណើត	ការសិក្សា និងបទពិសោធន៍ការងារ
៤.	លោក N Saravanan Nadarajah	ប្រធានផ្នែកលក់ និងដេញថ្លៃ	ម៉ាឡេស៊ី	ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧៥	• ឆ្នាំ១៩៩៦៖ សញ្ញាបត្រជំនាញវិស្វកម្មអគ្គិសនី (ចាមពល) ពីសាកលវិទ្យាល័យបច្ចេកវិទ្យាម៉ាឡេស៊ី ក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី • ឆ្នាំ២០០១៖បរិញ្ញាបត្រផ្នែកវិស្វកម្មជំនាញវិស្វកម្មចាមពលអគ្គិសនី (កិត្តិយស) ពីសាកលវិទ្យាល័យបច្ចេកវិទ្យាម៉ាឡេស៊ី ក្រុង Johor ប្រទេសម៉ាឡេស៊ី
៥.	លោក Pablo T. Magpantay	ប្រធានផ្នែក O&M	ហ្វីលីពីន	ថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៦៣	• ឆ្នាំ១៩៨៥៖ បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រជំនាញអប់រំឧស្សាហកម្ម ពីសាកលវិទ្យាល័យ Batangas ពីមុនមានឈ្មោះថា PBMIT ប្រទេសហ្វីលីពីន • ឆ្នាំ២០០៣៖ បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រជំនាញវិស្វកម្មអគ្គិសនី ពីសាកលវិទ្យាល័យ Batangas ប្រទេសហ្វីលីពីន

៥.១.២. បទពិសោធន៍ការងាររបស់អគ្គាល និងបុគ្គលិកជាន់ខ្ពស់ក្នុងរយៈពេលប្រាំ (៥) ឆ្នាំចុងក្រោយ

(ក) លោក Lim Pay Chuan

លោក Lim Pay Chuan សញ្ជាតិម៉ាឡេស៊ី អាយុ៥០ឆ្នាំ ជាប្រធានក្រុមប្រឹក្សាភិបាល។ លោកត្រូវបានតែងតាំងនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០។ បច្ចុប្បន្ន លោកគឺជា Executive Director និងជានាយកប្រតិបត្តិ ("CEO") របស់ក្រុមហ៊ុន PIB។

នៅឆ្នាំ១៩៩៤ លោកបានចាប់ផ្តើមវិជ្ជាជីវៈជាមួយនឹងក្រុមហ៊ុន Motorola Malaysia Sdn Bhd ក្នុងនាមជាវិស្វកររចនលិតផលម្នាក់។ បន្ទាប់មកនៅឆ្នាំ១៩៩៥ លោកបានចូលរួមជាមួយនឹងក្រុមហ៊ុន Toprank Corporation Sdn Bhd (បច្ចុប្បន្នដែលគេស្គាល់ថាជា ក្រុមហ៊ុន Toshiba Transmission & Distribution System Asia Sdn Bhd) ក្នុងនាមជាវិស្វករគម្រោង ដែលនៅទីនោះលោកត្រូវបានតម្លើងជាប្រធានគម្រោងនៅឆ្នាំ ១៩៩៧ និងបន្ត បន្ទាប់ក្លាយជាជំនួយការនាយកគ្រប់គ្រងទូទៅនៅឆ្នាំ១៩៩៨។ នៅឆ្នាំ២០០០ លោកបានចូលរួមជាមួយក្រុមហ៊ុន PSB ក្នុងតួនាទីជាប្រធានគ្រប់គ្រងទូទៅ និងត្រូវបានតម្លើងជានាយកប្រតិបត្តិ ក្នុងឆ្នាំ២០០៨។

លោក Lim Pay Chuan បានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរីកចម្រើន និងអភិវឌ្ឍន៍របស់សម្ព័ន្ធក្រុមហ៊ុនផេសថិក ដោយចាប់ផ្តើមពីក្រុមហ៊ុនខ្នាតតូច រហូតក្លាយជាក្រុមហ៊ុនបច្ចេកវិទ្យាថាមពលអគ្គិសនី នៅក្នុងវិស័យអាជីវកម្មចែកចាយ និងបញ្ជូនថាមពល ជាមួយនឹងប្រតិបត្តិការនៅក្នុងប្រទេសម៉ាឡេស៊ី និងបណ្តាប្រទេសជាច្រើនទៀត។ លោកបានដឹកនាំសម្ព័ន្ធក្រុមហ៊ុនផេសថិក ឱ្យមានវត្តមាននៅលើទឹកដីនៃប្រទេសប្រ៊ុយណេ ប៉ាពួហ្គីណេស៊ី ប្រទេសកម្ពុជា ប្រទេសមីយ៉ាន់ម៉ា ប្រទេសចិន និងប្រទេសស្រីលង្កា និងបន្តយ៉ាងសកម្មក្នុងការរកធុរកិច្ចថ្មីទាំងក្នុងទីផ្សារក្នុងស្រុក និងបរទេស។

លោកជាបុគ្គលសំខាន់ក្នុងការបង្កើតឱ្យមានការអភិវឌ្ឍន៍ផលិតផល និងវិស្វកម្ម ដោយធ្វើឱ្យសម្ព័ន្ធក្រុមហ៊ុនផេសថិក មានសមត្ថភាពក្នុងការរចនាផ្នែកទូរគមនាគមន៍ SCADA ការការពារ និងការត្រួតពិនិត្យ ការរចនាប្រព័ន្ធគោល ការសាងសង់បណ្តាញបញ្ជូនថាមពល និងខ្សែកាបក្រោមដី។ នៅឆ្នាំ២០១៤ ផ្នែកផលិតថាមពល និងការចែកចាយថាមពលតាមផ្លូវដែក ត្រូវបានបង្កើតឡើងសម្រាប់ធ្វើការលើប្រព័ន្ធថាមពលស្វ័យប្រវត្តិ និងសេវាអគ្គិសនីសម្រាប់រោងចក្រថាមពល និងឧស្សាហកម្មផ្លូវដែក។

លោក បានទទួលនូវពានរង្វាន់សហគ្រិនឆ្នើមប្រចាំឆ្នាំ២០១០ ផ្តល់ដោយ Enterprise Asia នៅឆ្នាំ២០១០ សម្រាប់ឆន្ទៈ និងភាពជាអ្នកដឹកនាំរបស់លោកក្នុងការដឹកនាំសម្ពន្ធក្រុមហ៊ុន ផេសទិក រហូតបានក្លាយជាតួអង្គមួយដ៏សំខាន់ក្នុងអាជីវកម្ម ចែកចាយ និងបញ្ជូនថាមពលនៅក្នុងប្រទេសម៉ាឡេស៊ី និងបណ្តាប្រទេសដ៏ទៃទៀត។

បច្ចុប្បន្ន លោកបានចូលជាសមាជិកជាន់ខ្ពស់ នៃវិទ្យាស្ថានវិស្វករប្រទេសម៉ាឡេស៊ី ដែលលោកជាសមាជិកតាំងពីឆ្នាំ២០០៥។ លោកក៏ជាវិស្វករជំនាញនៃគណៈវិស្វករម៉ាឡេស៊ីចាប់តាំងពីឆ្នាំ២០០៧ ក្នុងផ្នែកវិស្វកម្មអគ្គិសនី។ ចាប់ពីឆ្នាំ២០១១ លោកបានទទួលគុណវុឌ្ឍិជំនាញផ្នែកគ្រប់គ្រងគម្រោងពីវិទ្យាស្ថានគ្រប់គ្រងគម្រោង ជាសមាគមវិជ្ជាជីវៈពិភពលោកផ្តល់នូវការបញ្ជាក់ដល់អ្នកជំនាញផ្នែកគ្រប់គ្រងគម្រោង ដែលមានទីស្នាក់ការនៅ ស.រ.អ និងមានការិយាល័យនៅគ្រប់តំបន់ទូទាំងសកលលោក។ លោកត្រូវបានចុះបញ្ជីជា ASEAN Chartered Professional Engineer ចាប់ពីឆ្នាំ២០១៦។ ក្នុងឆ្នាំ២០១៧ លោកត្រូវបានចុះបញ្ជីក្រោម The Asia Pacific Economic Co-operation Register និង The International Register of Professional Engineer និង the ASEAN Engineering Register។

(២) លោក Lim Ah Hock

លោក Lim Ah Hock សញ្ជាតិម៉ាឡេស៊ី អាយុ៦៨ ឆ្នាំ ជា Executive Director របស់ក្រុមហ៊ុន។ លោកត្រូវបានតែងតាំងនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០។ បច្ចុប្បន្ន លោកជាប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិរបស់ក្រុមហ៊ុន PIB។

នៅឆ្នាំ១៩៧៨ លោកបានទទួលបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រជំនាញវិស្វកម្មមេកានិក (ជ័យលាភីលេខមួយ) ពីសាកលវិទ្យាល័យ Strathclyde ក្រុង Glasgow ប្រទេសអង់គ្លេស។ លោកជាសមាជិកនៃវិទ្យាស្ថានវិស្វករប្រទេសម៉ាឡេស៊ីចាប់តាំងពីឆ្នាំ១៩៨១។

នៅឆ្នាំ១៩៧៩ លោកបានចាប់ផ្តើមវិជ្ជាជីវៈជាសាស្ត្រាចារ្យនៅសាលាបច្ចេកទេស Ngee Ann នៅប្រទេសសិង្ហបុរី (នៅឆ្នាំ១៩៨២ ត្រូវបានប្តូរឈ្មោះជាសាលាពហុបច្ចេកទេស Ngee Ann) ដោយលោកបានទទួលបន្ទុកបង្រៀនមុខវិជ្ជា ទែម៉ូឌីណាមិច និងមេកានិចរាវ (thermodynamics and fluid mechanics)។ នៅឆ្នាំ១៩៨០ លោកបានចូលរួមជាមួយក្រុមហ៊ុន Mechmar Kejuruteraan Sdn Bhd ("Mechmar") ក្នុងនាមជាវិស្វកររសេវាកម្ម ដែលនៅទីនោះលោកគ្រប់គ្រងលើផ្នែកសេវាកម្ម និងការផ្តល់សេវាកម្មក្រោយលក់ និងការជួសជុលម៉ាស៊ីនកម្តៅធំៗ។ បន្ទាប់មកទៀត លោកបានចាកចេញពីក្រុមហ៊ុន Mechmar នៅឆ្នាំ១៩៨៤ និងបានចូលរួមជាមួយនឹងក្រុមហ៊ុន Sing Mah Pressure

Vessels Co. ក្នុងនាមជាប្រធានសាខាអំឡុងឆ្នាំ១៩៨៤ និងឆ្នាំ១៩៨៩ ដែលនៅទីនោះលោកទទួលបន្ទុកក្នុងការលក់ទាំងស្រុងនៅភាគខាងត្បូង រហូតដល់វិស័យឧស្សាហកម្មចម្រាញ់ដូងប្រេង ចំណីអាហារ និងឧស្សាហកម្មឈើ ក៏ដូចជាឧស្សាហកម្មទាំងឡាយដែលមាននៅភាគខាងត្បូងឧបទ្វីប Sabah និង Sarawak ប្រទេសម៉ាឡេស៊ី។ នៅឆ្នាំ១៩៨៩ លោកបានក្លាយជាអភិបាលនៃក្រុមហ៊ុន VESTECH Engineering Sdn Bhd រហូតដល់បច្ចុប្បន្ន។

នៅឆ្នាំ១៩៩១ លោកបានបង្កើតក្រុមហ៊ុន PIB នៅ Johor Bahru ប្រទេសម៉ាឡេស៊ី។ មកទល់បច្ចុប្បន្ន តួនាទីរបស់លោកនៅក្នុងសម្ព័ន្ធក្រុមហ៊ុនផេសថិក គឺទទួលបន្ទុកផែនការអភិវឌ្ឍអាជីវកម្មធំៗ តម្រង់ទិសដៅអភិវឌ្ឍម៉ាក្រអាជីវកម្មជាមួយនាយកប្រតិបត្តិ ត្រួតពិនិត្យមើលស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពរបស់សម្ព័ន្ធក្រុមហ៊ុនផេសថិក ដែលរួមមាន ផ្តល់ការណែនាំក្នុងការគ្រប់គ្រង និងដឹកនាំបុគ្គលិក។

(ញ) **លោក Han Fatt Juan**

លោក Han Fatt Juan សញ្ជាតិម៉ាឡេស៊ី អាយុ៥៥ឆ្នាំ ជាអភិបាលប្រតិបត្តិ និងនាយកប្រតិបត្តិ របស់ក្រុមហ៊ុន។ លោកបានចូលរួមជាមួយក្រុមហ៊ុន PSB ក្នុងឆ្នាំ២០០៩ ហើយបានក្លាយជានាយកប្រតិបត្តិនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥។ លោកទទួលបន្ទុកក្នុងការសម្រេចឱ្យបាននូវគោលដៅចំណូល និងចំណេញរបស់ក្រុមហ៊ុន ឱ្យស្របតាមគម្រោងអាជីវកម្មរបស់ក្រុមហ៊ុន និងធានាឱ្យបានថាក្រុមហ៊ុនមានគោលដៅ ផែនការ និងថវិកាដែលតម្រូវដើម្បីសម្រេចគោលដៅហិរញ្ញវត្ថុ និងប្រតិបត្តិការរយៈពេលខ្លី និងរយៈពេលវែងដូចដែលបានកំណត់ទុកក្នុងផែនការអាជីវកម្មក្រុមហ៊ុន។

នៅឆ្នាំ១៩៨៥ លោកបានចាប់ផ្តើមវិជ្ជាជីវៈជាអ្នកត្រួតពិនិត្យការដ្ឋាននៅក្រុមហ៊ុន Metral Villar Sdn Bhd ដោយទទួលបន្ទុកក្នុងការត្រួតពិនិត្យមើល និងសម្របសម្រួលសកម្មភាពរបស់កម្មករទាក់ទងនឹងការដឹកជញ្ជូន និងការណាយស៊ីម៉ង់។ នៅឆ្នាំ១៩៨៨ លោកបានចាកចេញពីក្រុមហ៊ុន ដើម្បីបន្តការសិក្សានៅសាកលវិទ្យាល័យ South Dakota State ស.រ.អ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រ សំណង់ស៊ីវិលពីសាកលវិទ្យាល័យ South Dakota State ស.រ.អ ក្នុងឆ្នាំ១៩៩០។ ក្រោយមកគាត់បានទទួលបរិញ្ញាប័ត្រជាន់ខ្ពស់ ផ្នែកវិទ្យាសាស្ត្រគ្រប់គ្រង ក្នុងឆ្នាំ១៩៩២ ពីសាកលវិទ្យាល័យខាងលើ។ អំឡុងពេលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅទីនោះ លោកបានបំពេញការងារជាជំនួយការបង្រៀននៅសាកលវិទ្យាល័យ South Dakota State ស.រ.អ។ នៅឆ្នាំ១៩៩២ លោកបានចូលរួមជាមួយក្រុមហ៊ុន Zafas Sdn Bhd ក្នុងនាមជាវិស្វកររការដ្ឋាន និងបានចំណាយពេលនៅទីនោះអស់រយៈពេល១៧ឆ្នាំ រហូតដល់ឆ្នាំ២០០៩ ត្រូវបានតម្លើងជានាយកគម្រោង។ អំឡុងពេលបំពេញការងារ លោកបានចូលរួមក្នុងគម្រោងជាច្រើនរួមមាន ការងារតម្លើងខ្សែ

ខ្សែកាបក្រោមដី និងខ្សែបណ្តាញបញ្ជូនថាមពល ឆ្លងកាត់ប្រទេសម៉ាឡេស៊ី និងប្រទេសប្រ៊ុយណេ។

នៅឆ្នាំ២០០៩ លោកបានចូលរួមជាមួយក្រុមហ៊ុនសម្ព័ន្ធផេសថិក ក្នុងតួនាទីជាប្រធានគម្រោង និងត្រូវបានតម្លើងជាប្រធានគ្រប់គ្រងទូទៅ នៅក្នុងគម្រោងយុទ្ធសាស្ត្រ (ការអភិវឌ្ឍន៍អាជីវកម្ម) នៅឆ្នាំ២០១១ ហើយក្រោយមកក្លាយជាប្រធានគ្រប់គ្រងទូទៅ ផ្នែកបណ្តាញថាមពល និងខ្សែកាបរបស់សម្ព័ន្ធក្រុមហ៊ុនផេសថិក។ ក្នុងនាមជាប្រធានគ្រប់គ្រងទូទៅផ្នែកបណ្តាញថាមពល និងខ្សែកាប ក្រុមរបស់លោកទទួលបន្ទុកការងារកិច្ចសន្យា EPCC ដែលគ្របដណ្តប់លើដំណើរការគ្រប់គ្រងគម្រោង ការផ្គត់ផ្គង់គ្រឿងបរិក្ខារ ដំណើរការការដ្ឋានសំណង់ និងការតម្លើងបណ្តាញបញ្ជូនថាមពល និងខ្សែកាបក្រោមដី។

(៤) ឯកឧត្តម ដាវ អានសាន

ឯកឧត្តម ដាវ អានសាន សញ្ជាតិខ្មែរ អាយុ៣៩ ឆ្នាំ ជាអភិបាលឯករាជ្យរបស់ក្រុមហ៊ុនយើង។ ឯកឧត្តមជាសារការី និងជាអនុប្រធានប្រចាំមន្ទីរសារការីសេដ្ឋាវិទូ ចាប់ពីឆ្នាំ២០១៤ មកម្ល៉េះ។ ឯកឧត្តមមានបទពិសោធន៍ការងារលើសពី១០ ឆ្នាំក្នុងវិស័យច្បាប់ នយោបាយ សង្គម និងសេដ្ឋកិច្ច។ ឯកឧត្តមមានឯកទេសខាងគម្រោង និងហិរញ្ញវត្ថុសាជីវកម្ម។ មុនពេលចូលរួមជាមួយមន្ទីរសារការីសេដ្ឋាវិទូ ឯកឧត្តមជាអ្នកអនុវត្តច្បាប់នៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣។ មុនពេលចូលរួមជាមួយ អ.វ.ត.ក ឯកឧត្តមជាអ្នកផ្តល់ប្រឹក្សា និងអ្នកស្រាវជ្រាវនៅស្ថានទូតសាធារណរដ្ឋកូរ៉េប្រចាំប្រទេសកម្ពុជា និងនៅស្ថាប័នស្រាវជ្រាវសាធារណៈនៃរដ្ឋាភិបាលកម្ពុជា ក្នុងវិស័យផ្នែកច្បាប់ ឥស្សរិយសេដ្ឋកិច្ច ពាណិជ្ជកម្មឆ្លងដែន និងផ្នែកអាជីវកម្ម (Business Enabling Environment)។ ឯកឧត្តមក៏ជាសាស្ត្រាចារ្យក្នុងសាកលវិទ្យាល័យឯកជន និងរដ្ឋក្នុងរាជធានីភ្នំពេញផងដែរ គឺចាប់ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០១៣។

ឯកឧត្តម ដាវ អានសាន ជាទីប្រឹក្សារបស់**សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមក៏ជាសមាជិកនៃគណកម្មការ កណ្តាលនៃសហភាពសហព័ន្ធកម្ពុជា ជាអង្គការមិនមែនរដ្ឋាភិបាលដែលដឹកនាំដោយ **ឯកឧត្តម ហ៊ុន ម៉ានី** ដែលជាសមាជិកនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

ឯកឧត្តម ដាវ អានសាន ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ចនិយោបាយពី Williams College, Massachusetts ស.រ.អ ក្នុងឆ្នាំ២០០៩ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ចពីរាជបណ្ឌិត្យសភាកម្ពុជាក្នុងឆ្នាំ២០០៣។

ឯកឧត្តមចេះភាសារខ្មែរ អង់គ្លេស និងបារាំង។

(៥) **លោក Tan Pu Hooi**

លោក Tan Pu Hooi សញ្ជាតិម៉ាឡេស៊ី អាយុ៤៩ឆ្នាំ មានតួនាទីជាអភិបាលប្រតិបត្តិរបស់ក្រុមហ៊ុន។ លោកបានចូលរួមជាមួយក្រុមហ៊ុន PIB នៅក្នុងខែកញ្ញា ឆ្នាំ២០១៥ ក្នុងផ្នែកអភិវឌ្ឍអាជីវកម្ម។ លោកទទួលបន្ទុកផ្នែករៀបចំ និងអនុវត្តកិច្ចការអាជីវកម្មផ្សេងៗ មានដូចជា ការបោះផ្សាយលក់មូលត្រជាសាធារណៈលើកដំបូង ការបោះភាគហ៊ុនបន្ថែម (Bonus Issue) ការបំបែកភាគហ៊ុន ផែនការផ្តល់ភាគហ៊ុន ព្រមទាំងរៀបចំ និងអនុវត្តសកម្មភាពគៀរគរមូលធន។

ចាប់តាំងពីឆ្នាំ១៩៩៧ លោកមានបទពិសោធន៍លើផ្នែកហិរញ្ញវត្ថុសាជីវកម្មយ៉ាងទូលំទូលាយ ដោយលោកបានធ្វើការជាមួយនឹងធនាគារវិនិយោគនៅប្រទេសម៉ាឡេស៊ី និងជាសហ-ស្ថាបនិកនៃក្រុមហ៊ុនប្រឹក្សាហិរញ្ញវត្ថុសាជីវកម្មមួយ ដែលទទួលស្គាល់ដោយគណៈកម្មការមូលបត្រនៃប្រទេសម៉ាឡេស៊ី។

លោកទទួលបានគុណវុឌ្ឍិផ្នែកហិរញ្ញវត្ថុសាជីវកម្ម ដែលទទួលស្គាល់ដោយ Institute of Chartered Accountants នៅប្រទេសអង់គ្លេស និងវែល (ICAEW) និងជាសមាជិក Financial Planning Association នៃប្រទេសម៉ាឡេស៊ី ("FPAM")។

(៦) **លោកស្រី Teh Bee Choo**

លោកស្រី Teh Bee Choo សញ្ជាតិម៉ាឡេស៊ី អាយុ៥៧ឆ្នាំ មានតួនាទីជានាយកផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនយើង និងរបស់ក្រុមហ៊ុន PIB។ លោកស្រីបានទទួលបរិញ្ញាបត្រផ្នែកអាជីវកម្មជំនាញគណនេយ្យជាមួយដំណើរការទិន្នន័យពីវិទ្យាស្ថានបច្ចេកវិទ្យា Swinburne Institute of Technology នៅឆ្នាំ១៩៨៦។ លោកស្រីជាសមាជិកានៃ Institute of Chartered Accountants Australia ចាប់ពីឆ្នាំ១៩៩០ និងជាសមាជិកានៃ Malaysian Institute of Accountants ចាប់ពីឆ្នាំ១៩៩៣។

លោកស្រីបានចាប់ផ្តើមវិជ្ជាជីវៈរបស់ខ្លួននៅឆ្នាំ១៩៨៦ ក្នុងតួនាទីជាសវនករ (Junior Audit cum Tax Executive) នៅក្រុមហ៊ុន Shrapnel Accountants & Advisory Pty. Ltd ប្រទេសអូស្ត្រាលី និងក្រោយមកត្រូវបានតម្លើងជាប្រធានផ្នែក មុនពេលចាកចេញ

ប្រុះរាជាណាចក្រកម្ពុជា ផេសធិក (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

ពីក្រុមហ៊ុននៅឆ្នាំ១៩៩៣ ហើយបានចូលរួមជាមួយក្រុមហ៊ុន Samsung Corning (Malaysia) Sdn Bhd ក្នុងតួនាទីជាគណនេយ្យករ។

បន្ទាប់មកទៀត លោកស្រីបានចូលរួមជាមួយក្រុមហ៊ុន A&L Corporate Management Sdn Bhd ដែលជាក្រុមហ៊ុនផ្តល់សេវាលេខាធិការ និងពន្ធដារ ក្នុងតួនាទីជា ប្រធានផ្នែកនៅឆ្នាំដដែល និងចាកចេញពីក្រុមហ៊ុននៅឆ្នាំ១៩៩៥។ ក្រោយមក លោកស្រីបានប្តូរទៅកាន់ក្រុមហ៊ុន Toprank Corporation Sdn Bhd (ដែលបច្ចុប្បន្នត្រូវបានគេស្គាល់ថាជាក្រុមហ៊ុន Toshiba Transmission & Distribution System Asia Sdn Bhd) ក្នុងតួនាទីជាគណនេយ្យកររបស់ក្រុមហ៊ុន ដោយបានបម្រើការងារនៅទីនោះអស់រយៈពេល ៨ ឆ្នាំ។

នៅឆ្នាំ២០០៣ លោកស្រីបានបង្កើតក្រុមហ៊ុនផ្ទាល់ខ្លួនមួយ មានឈ្មោះថា BCT Advisory Sdn Bhd ដែលផ្តល់សេវាកម្មផ្នែកគ្រប់គ្រងសាជីវកម្ម ដោយលោកស្រីជាអ្នកគ្រប់គ្រងផ្ទាល់អស់រយៈពេលបួន (៤) ឆ្នាំ។ ក្នុងឆ្នាំ២០០៧ លោកស្រីបានចូលរួមជាមួយក្រុមហ៊ុន Multi Purpose Holding Bhd ក្នុងនាមជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ។ ក្រោយមកលោកស្រីបានចូលរួមជាមួយសម្ព័ន្ធក្រុមហ៊ុនផេសថិក ក្នុងតួនាទីជានាយកផ្នែកហិរញ្ញវត្ថុនៅឆ្នាំ២០០៨ រហូតមកដល់សព្វថ្ងៃ។

(៧) កញ្ញា Tann Sochan

កញ្ញា Tann Sochan សញ្ជាតិខ្មែរ អាយុ៣៥ឆ្នាំ ជាប្រធានជាន់ខ្ពស់/លេខាធិការរបស់ក្រុមហ៊ុន។ កញ្ញាចូលរួមជាមួយក្រុមហ៊ុននៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០។ កញ្ញាទទួលបន្ទុកការងារអៀបចំ និងអនុវត្តយុទ្ធសាស្ត្រអាជីវកម្ម និងត្រួតពិនិត្យទៅលើប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុន។

កញ្ញាបានចាប់ផ្តើមវិជ្ជាជីវៈ ជាបាហុនិការបស់ក្រុមហ៊ុនអង្គរអ៊ែរវេរ ចន្លោះឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨។ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០០៩ កញ្ញាបានចូលរួម ក្រុមហ៊ុនមេធាវី David Chanaiwa & Associates ក្នុងតួនាទីជំនួយការការិយាល័យ ទទួលបន្ទុកការងារស្រាវជ្រាវ ផ្ទៀងផ្ទាត់ព័ត៌មាន និងរៀបចំឯកសារច្បាប់ព្រមទាំងធ្វើកំណត់ត្រាកិច្ចប្រជុំ។

នៅឆ្នាំ២០១០ កញ្ញាបានចូលរួមជាមួយក្រុមហ៊ុនយើងក្នុងនាមជាមន្ត្រីប្រតិបត្តិ ទទួលបន្ទុកការងាររដ្ឋបាល ដូចជាការរៀបចំរាល់ខ្នង់ចំណាយ។ ក្នុងឆ្នាំ២០១១ កញ្ញាត្រូវបានតម្លើងជាអ្នកសម្របសម្រួលផ្នែកគម្រោង និងទីផ្សារ គ្រប់គ្រងការទិញសម្ភារៈសម្រាប់ការដ្ឋាន និងសម្របសម្រួលការចាត់ចែងការងារបុគ្គលិករវាងក្រុមហ៊ុន PIB អ្នកម៉ៅការបន្ត និងក្រុមហ៊ុនយើង។ កញ្ញាត្រូវបានតម្លើងជាប្រធានជាន់ខ្ពស់នៅឆ្នាំ២០១៤ បន្ទាប់ពីបានបញ្ចប់

គម្រោង ភ្នំពេញភាគខាងជើង - ខេត្តកំពង់ចាម រហូតដល់បច្ចុប្បន្ន។ កញ្ញាមានបទពិសោធន៍ជាងប្រាំមួយ (៦) ឆ្នាំ លើការងារប្រតិបត្តិការរបស់ក្រុមហ៊ុន និងគម្រោងរបស់ក្រុមហ៊ុន។

(៨) លោក N Saravanan Nadarajah ("Saravanan")

លោក Saravanan សញ្ជាតិម៉ាឡេស៊ី អាយុ៤៥ឆ្នាំ ជាប្រធានផ្នែកគម្រោង និងវេជ្ជផ្នែរបស់ក្រុមហ៊ុន។ លោកបានចូលរួមជាមួយយើងក្នុងនាមជាប្រធានផ្នែកគម្រោង និងការលក់នៅខែមីនា ឆ្នាំ២០១០។ លោកទទួលបន្ទុកផ្នែកអនុវត្ត និងសម្របសម្រួលការងារវិស្វកម្ម និងការងារសាងសង់ពាក់ព័ន្ធនឹងគម្រោងរបស់ក្រុមហ៊ុន។ លោកទទួលបន្ទុកអនុវត្តគម្រោងភ្នំពេញខាងលិច-ព្រះសីហនុ គម្រោងកំពង់ចាម-ក្រចេះ និងគម្រោងរោងចក្រអគ្គិសនីស្ទឹងតាតៃ-ប្រព័ន្ធបញ្ជូនភ្នំពេញ។

លោកបានចាប់ផ្តើមវិជ្ជាជីវៈជាជំនួយការបច្ចេកទេសនៅក្រុមហ៊ុន Tenaga Nasional Berhad ប្រទេសម៉ាឡេស៊ី ចន្លោះឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៩ ដែលនៅទីនោះលោកបានជួយក្នុងការរៀបចំសំណើ និងការងារវិស្វកម្ម ព្រមទាំងអនុវត្តកិច្ចព្រមព្រៀងនានា។

ចាប់ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០១ លោកបានបន្តការសិក្សារវិស្វកររអគ្គីសនី នៅសាកលវិទ្យាល័យបច្ចេកវិទ្យាម៉ាឡេស៊ី បន្ទាប់ពីបញ្ចប់ការសិក្សារលោកបានចូលរួមជាមួយក្រុមហ៊ុន Paremba Kentz MEPC Sdn Bhd ប្រទេសម៉ាឡេស៊ី ក្នុងតួនាទីជាវិស្វកររអគ្គិសនីទទួលបន្ទុកការងារតម្លើង សាកល្បង និងដាក់ដំណើការជាមុននូវគ្រឿងបរិក្ខារទៅរោងចក្រគីមីឥន្ធន:ចាប់ពីឆ្នាំ២០០១ ដល់ឆ្នាំ២០០២។

ចាប់ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០១០ លោកបានចូលរួមជាមួយក្រុមហ៊ុន TNB Engineering Corporation Sdn Bhd ប្រទេសម៉ាឡេស៊ី ក្នុងតួនាទីជាប្រធានគម្រោង សម្រាប់ការអភិវឌ្ឍគម្រោងបណ្តាញបញ្ជូនចាមពល២៧៥ គីឡូវ៉ុល និង១៣២ គីឡូវ៉ុល។ ក្នុងអំឡុងពេលនោះលោកក៏បានចូលរួមក្នុងការគ្រប់គ្រងគម្រោងខ្សែកាបក្រោមដីរួមមាន ការរៀបចំសំណើ ការបើកការដេញថ្លៃ ការងារវិស្វកម្ម និងការសាកល្បងនៅការដ្ឋាន។

នៅឆ្នាំ២០១០ លោកបានចូលរួមជាមួយក្រុមហ៊ុនយើង ក្នុងនាមជាប្រធានផ្នែកគម្រោង និងការលក់ ដែលលោកបានចូលរួមក្នុងការសាងសង់អនុស្ថានីយ៍ពីរ (២) ដែលមានចាមពល ២៣០/១១៥/២២គីឡូវ៉ុល និងបណ្តាញបញ្ជូនចាមពល២៣០ គីឡូវ៉ុល ប្រវែង ៩៨គីឡូម៉ែត្រ។

(៩) លោក Pablo T. Magpantay

លោក Pablo T. Magpantay សញ្ជាតិហ្វីលីពីន អាយុ៥៧ឆ្នាំ ជាប្រធានផ្នែក O&M របស់ក្រុមហ៊ុន។ លោកបានចូលរួមជាមួយក្រុមហ៊ុននៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧។ បច្ចុប្បន្ន

លោកទទួលបន្ទុកការងារប្រតិបត្តិការ និងថែទាំប្រចាំថ្ងៃទៅលើអនុស្ថានីយ៍ និងបណ្តាញបញ្ជូនថាមពលដែលក្រុមហ៊ុនទទួលបន្ទុកផ្គត់ផ្គង់សេវាកម្មទាំងនោះ។ លោកក៏ទទួលបន្ទុកធ្វើការអភិវឌ្ឍន៍ និងធានានូវការអនុវត្តប្រកបដោយប្រសិទ្ធិភាព និងអនុលោមភាពទៅតាមគោលនយោបាយ O&M សម្រាប់អនុស្ថានីយ៍ និងបណ្តាញបញ្ជូនផងដែរ។

លោកបានចាប់ផ្តើមវិជ្ជាជីវៈរបស់ខ្លួននៅឆ្នាំ១៩៨៥ ជាមួយក្រុមហ៊ុន CMI Contractor, Inc ក្នុងតួនាទីជាអ្នកបច្ចេកទេសអគ្គិសនី ដែលនៅទីនោះលោកបានចូលរួមក្នុងក្រុមការងារចំហុយប្រេងឆៅ និងក្រុមការងារបំបែកសារធាតុរាវកាតាលីករ នៃគម្រោងស្តារឡើងវិញនៅក្នុងរោងចក្រចម្រាញ់ប្រេងកាល់តិចនៅ Batangas ប្រទេសហ្វីលីពីន។ ក្រោយមកទៀត លោកបានចូលរួមជាមួយក្រុមហ៊ុនប្រេងឥន្ធនៈជាតិហ្វីលីពីន ក្នុងនាមជាអ្នកបច្ចេកទេសអគ្គិសនីនៅឆ្នាំ១៩៨៩ ដែលនៅទីនោះលោកបានចូលរួមក្នុងការអនុវត្តប្តង់ប្រព័ន្ធអគ្គិសនី និងការតម្លើងការិយាល័យនៅការដ្ឋានគម្រោងរោងចក្រថាមពល Geothermal Bacon - Manito ដែលមានថាមពល ១១០ មេកាវ៉ាត់ នៅ Sorsogon តំបន់ Bicol Region នៃប្រទេសហ្វីលីពីន។

ចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៤ លោកធ្វើជាសាស្ត្រាចារ្យផ្នែកបច្ចេកវិទ្យាអគ្គិសនីនៅសាកលវិទ្យាល័យរដ្ឋ Batangas នៃប្រទេសហ្វីលីពីន លោកបានបង្រៀនមុខវិជ្ជាផ្សេងៗទាក់ទងនឹងអគ្គិសនី។

នៅឆ្នាំ២០០៤ លោកបានចូលរួមជាមួយក្រុមហ៊ុន Hyundai Consortium ក្នុងតួនាទីជាវិស្វករអគ្គិសនី ដែលនៅទីនោះលោកបានចូលរួមក្នុងការសាងសង់គម្រោងចែកចាយថាមពល២២/0.៤គីឡូវ៉ុល នៅខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា។

ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៧ លោកធ្វើជាអ្នកត្រួតពិនិត្យគុណភាព នៅក្រុមហ៊ុន Atlantic, Gulf & Pacific Company of Manila, Inc. សម្រាប់ការតម្លើងគ្រឿងបរិក្ខារអគ្គិសនី និងសម្ភារៈសម្រាប់គម្រោងមួយនៅ San Roque Bauan Batangas ប្រទេសហ្វីលីពីន។

ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៨ លោកបម្រើការជាវិស្វករគម្រោងជាមួយក្រុមហ៊ុន Danway Electrical & Mechanical Engineering នៅសហភាពអារ៉ាប់រួម ក្នុងការសាងសង់អាកាសយានដ្ឋានអន្តរជាតិឌូបៃ។

មុនពេលចូលរួមជាមួយក្រុមហ៊ុន លោកធ្លាប់បម្រើការនៅក្រុមហ៊ុន ខេមបូឌាន ទ្រែនមីសិន លីមីធីត ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន លីឌឺ ខេមបូឌា លីមីធីត ចាប់ពីឆ្នាំ ២០០៧ ដល់ខែឧសភា ឆ្នាំ២០១៧ ដោយទទួលបន្ទុកក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងលើ

គម្រោងបញ្ជូនថាមពល ២៣០/១១៥/២២ គីឡូវ៉ុល នៅរាជធានីភ្នំពេញ និងគ្រប់គ្រងលើ O&M អនុស្ថានីយ៍ GSKC កំពង់ចាម ដែលមានកម្លាំង ២៣០/១១៥/២២គីឡូវ៉ុល។

៥.១.៣. កាលបរិច្ឆេទការតែងតាំង និងការបញ្ចប់អាណត្តបច្ចុប្បន្ន

ល.រ	ឈ្មោះ	កាលបរិច្ឆេទក្លាយជា អភិបាល	កាលបរិច្ឆេទបញ្ចប់អាណត្តិ បច្ចុប្បន្ន
១.	លោក Lim Pay Chuan	ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០	មិនមានកាលកំណត់
២.	លោក Lim Ah Hock	ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១០	មិនមានកាលកំណត់
៣.	លោក Han Fatt Juan	ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨	មិនមានកាលកំណត់
៤.	លោក Tan Pu Hooi	ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨	មិនមានកាលកំណត់
៥.	ឯកឧត្តម ងាវ អានសាន	ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨	ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣

៥.១.៤. ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិករ ក្រុមហ៊ុនឬសហគ្រាសផ្សេងទៀត សូមបញ្ជាក់ឈ្មោះក្រុមហ៊ុន

លើកលែងមានបង្ហាញតាមតារាងខាងក្រោម អភិបាលនិងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនទាំងអស់គឺជានិយោជិតជាប់ឈប់របស់ក្រុមហ៊ុន និងមិនជាប់ពាក់ព័ន្ធជាមួយប្រតិបត្តិការអាជីវកម្ម/សាជីវកម្មផ្សេងឡើយ ដោយគិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ៖

ល.រ.	ឈ្មោះអភិបាល	ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ	តួនាទី	ភាគហ៊ុនិក
១.	Lim Ah Hock	PIB	ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ	✓
		Astoria Solar Farm Sdn Bhd	អភិបាល	-
		PSB	អភិបាល	-
		PESTECH Power Sdn Bhd	អភិបាល	-
		PESTECH (Sarawak) Sdn Bhd	អភិបាល	-
		PESTECH Transmission Sdn Bhd	អភិបាល	-
		PESTECH Technology Sdn Bhd	អភិបាល	-
		PESTECH Energy Sdn Bhd	អភិបាល	-
		PESTECH Solutions Sdn Bhd	អភិបាល	-
		PESTECH Power One Sdn Bhd	អភិបាល	-

៥. ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ត)

ល.រ.	ឈ្មោះអភិបាល	ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ	តួនាទី	ភាគហ៊ុនិក
		PESTECH Power Two Sdn Bhd	អភិបាល	-
		PESTECH REI Sdn Bhd	អភិបាល	-
		Fornix Sdn Bhd	អភិបាល	-
		Forward Metal Works Sdn Bhd	អភិបាល	-
		CRSE Sdn. Bhd.	អភិបាល	-
		PESTECH Engineering Technology China Co., Ltd	អភិបាល	-
		Diamond Power Limited	អភិបាល	-
		Enersol Co., Ltd	អភិបាល	-
		PESTECH Hinthar Corporation Limited	អភិបាល	-
		PESTECH System Siam Ltd	អភិបាល	✓
		ODM Power Line Company Limited	អភិបាល	-
		Fornix Biotech Sdn Bhd	អភិបាល	✓
		Fornix Foodstuffs Sdn Bhd	អភិបាល	-
		Fornix Capital Sdn Bhd	អភិបាល	✓
		Asiapac Machineries Sdn Bhd	អភិបាល	-
		Vestech Engineering Sdn Bhd	អភិបាល	✓
		Batu Sawar Sdn. Bhd	អភិបាល	✓
២.	Lim Pay Chuan	PIB	អភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិ	✓
		Astoria Solar Farm Sdn Bhd	អភិបាល	-
		PSB	អភិបាល	-
		PESTECH Power Sdn Bhd	អភិបាល	-
		PESTECH (Sarawak) Sdn Bhd	អភិបាល	-
		PESTECH Transmission Sdn Bhd	អភិបាល	-
		PESTECH Technology Sdn Bhd	អភិបាល	-
		PESTECH Energy Sdn Bhd	អភិបាល	-

PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

៥. ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ត)

ល.រ.	ឈ្មោះអភិបាល	ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ	តួនាទី	ភាគហ៊ុនិក
		PESTECH Solutions Sdn Bhd	អភិបាល	-
		PESTECH Power One Sdn Bhd	អភិបាល	-
		PESTECH Power Two Sdn Bhd	អភិបាល	-
		PESTECH REI Sdn Bhd	អភិបាល	-
		CRSE Sdn. Bhd.	អភិបាល	-
		Fornix Sdn Bhd	អភិបាល	-
		Forward Metal Works Sdn Bhd	អភិបាល	-
		PESTECH (PNG) Ltd	អភិបាល	-
		PESTECH Corporation	អភិបាល	✓
		Diamond Power Limited	អភិបាល	-
		Enersol Co., Ltd.	អភិបាល	-
		PESTECH Transmission Ltd	អភិបាល	-
		PESTECH (Myanmar) Limited	អភិបាល	-
		PESTECH Hinthar Corporation Limited	អភិបាល	-
		PESTECH System Siam Ltd	អភិបាល	✓
		PESTECH Vietnam Company Limited	អភិបាល	-
		PESTECH Microgrid Company Limited	អភិបាល	-
		ODM Power Line Company Limited	អភិបាល	-
		PESTECH (Brunei) Sdn Bhd	អភិបាល	-
		Fornix Biotech Sdn Bhd	អភិបាល	✓
		Fornix Foodstuffs Sdn Bhd	អភិបាល	-
		Fornix Capital Sdn Bhd	អភិបាល	✓
		Asiapac Machineries Sdn Bhd	អភិបាល	-
		Imbiss Sdn Bhd	អភិបាល	✓
		Mercula Sdn Bhd	អភិបាល	✓
		Wylis Corporation Sdn Bhd	អភិបាល	✓

៥. ព័ត៌មានពាក់ព័ន្ធនឹងអតីតបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ត)

ល.រ.	ឈ្មោះអភិបាល	ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ	តួនាទី	ភាគហ៊ុនិក
		Wylis Sdn Bhd	អភិបាល	✓
		Asiapac Builders Sdn Bhd	អភិបាល	-
		BETSOL Sdn Bhd	អភិបាល	✓
		BETSOL (Sarawak) Sdn Bhd	អភិបាល	✓
		BETSOL International Sdn Bhd	អភិបាល	✓
		Riviera Wylis Sdn Bhd	អភិបាល	✓
		PC Wylis Sdn Bhd	អភិបាល	✓
		JAP Wylis Sdn Bhd	អភិបាល	✓
		De Aroma Imbiss Co., Ltd	អភិបាល	✓
		Enlightyx Sdn Bhd	អភិបាល	✓
		Copious Alliance Co., Ltd.	អភិបាល	✓
		Sustainable Energy Resources Co., Ltd.	អភិបាល	✓
៣.	Han Fatt Juan	De Aroma Imbiss Co., Ltd	អភិបាល	✓
		Imbiss Sdn Bhd	អភិបាល	✓
		PESTECH Transmission Ltd	អភិបាល	-
		PESTECH (Myanmar) Limited	អភិបាល	-
		PESTECH Hinthar Corporation Limited	អភិបាល	-
៤.	Tan Pu Hooi	PESTECH (PNG) Ltd.	អភិបាល	-
		Diamond Power Limited	អភិបាល	-
		PESTECH System Siam Ltd	អភិបាល	-
		Fornix Biotech Sdn Bhd	អភិបាល	✓
		Fornix Foodstuffs Sdn Bhd	អភិបាល	-
		PESTECH Corporation	អភិបាល	✓
		ODM Power Line Company Limited	អភិបាល	-
		Copious Alliance Co., Ltd.	អភិបាល	✓

៥. ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ត)

ល.រ.	ឈ្មោះអភិបាល	ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ	តួនាទី	ភាគហ៊ុនិក
		Sustainable Energy Resources Co., Ltd.	អភិបាល	✓
៥.	Dav Ansan	Sethavitou Notary	ដៃគូ និងសារការីសាធារណៈ	✓
		Propey Microfinance Plc.	អភិបាល	✓
		Sustainable Energy Resources Co., Ltd.	អភិបាល	✓

ការចូលរួមរបស់អភិបាលប្រតិបត្តិយើងក្នុងអាជីវកម្ម និងសារជីវកម្មក្រៅពីសម្ព័ន្ធក្រុមហ៊ុនផេសទិក មិនតម្រូវឱ្យពួកគេមានការចូលរួមជាប្រចាំនោះឡើយ ដោយសារអាជីវកម្ម/សាជីវកម្មទាំងនោះ ត្រូវបានគ្រប់គ្រងដោយប្រធានផ្នែក ក៏ដូចជាបុគ្គលិកជាន់ខ្ពស់ដែលពោរពេញដោយសមត្ថភាព និងបទពិសោធន៍។ ដូច្នេះការចូលរួមរបស់ពួកគេ នឹងមិនធ្វើឱ្យប៉ះពាល់ដល់ការរួមចំណែកក្នុងក្រុមហ៊ុន ឬសមត្ថភាពក្នុងការបំពេញមុខងារជាអភិបាលរបស់ក្រុមហ៊ុននោះឡើយ។

៥.១.៥. ទំនាក់ទំនងសាច់ញាតិ ក្នុងចំណោមអភិបាល ភាគហ៊ុនិក និង បុគ្គលិកជាន់ខ្ពស់ (ប្រសិនបើមាន) និង បញ្ជាក់ពីស្ថានភាពនៃទំនាក់ទំនង

លើកលែងមានបង្ហាញក្នុងតារាងខាងក្រោម មិនមានទំនាក់ទំនងសាច់ញាតិ រវាង ឬក្នុងចំណោមអភិបាល ភាគហ៊ុនិក និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុន និងអ្នកបង្កើតទេសនោះឡើយ៖

ឈ្មោះ	មុខតំណែង	ឈ្មោះរបស់សាច់ញាតិ	តំណែងរបស់សាច់ញាតិ	ទំនាក់ទំនង
លោក Lim Pay Chuan	ប្រធានក្រុមប្រឹក្សាប្រតិបត្តិ	លោក Lim Ah Hock	អភិបាលប្រតិបត្តិ	លោក Lim Pay Chuan គឺជាកូនរបស់លោក Lim Ah Hock

៥. ព័ត៌មានពាក់ព័ន្ធនឹងអតឡាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ត)

៥.១.៦. ការប្រកាសក្ស័យធនរបស់អតឡាល ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនអប្បបរមា ៥% នៃភាគហ៊ុនដែលឡានបង់គ្រប់រួចរាល់

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ មិនមានអភិបាល ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនអប្បបរមា ៥% នៃភាគហ៊ុនដែលបានបង់គ្រប់រួចរាល់ បានប្រកាសក្ស័យធនក្នុងរយៈពេលប្រាំ (៥) ឆ្នាំចុងក្រោយនោះឡើយ។

៥.២. ការជាប់ពាក់ព័ន្ធរបស់អតឡាល និងបុគ្គលិកជាន់ខ្ពស់ ក្នុងដំណើរការផ្លូវច្បាប់ ក្នុងរយៈពេលប្រាំ (៥) ឆ្នាំចុងក្រោយ

មិនមានអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនធ្លាប់ ឬកំពុងជាប់ពាក់ព័ន្ធនឹងករណីណាមួយដូចខាងក្រោមទោះស្ថិតនៅក្នុង ឬនៅក្រៅដែនសមត្ថកិច្ចព្រះរាជាណាចក្រកម្ពុជា៖

(១) បណ្តឹងក្ស័យធន ធ្វើឡើងដោយ ឬប្រឆាំងនឹង រាល់ក្រុមហ៊ុន ដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់របស់ក្រុមហ៊ុន ធ្លាប់ធ្វើជាអភិបាល មន្ត្រី ឬជាសហកម្មសិទ្ធិការរបស់ក្រុមហ៊ុននោះ អំឡុងពេលក្ស័យធនក្នុងរយៈពេលប្រាំ (៥) ឆ្នាំចុងក្រោយ

(២) ការផ្តន្ទាទោសព្រហ្មទណ្ឌ ឬបណ្តឹងព្រហ្មទណ្ឌដែលមិនទាន់សម្រេចប្រឆាំងនឹងអភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនយើង

(៣) សេចក្តីសម្រេច ឬដីកាបណ្តោះអាសន្ន/អចិន្ត្រៃយ៍ ចេញពីយុត្តាធិការតុលាការមានសមត្ថកិច្ចណាមួយប្រឆាំងនឹងអភិបាល ឬបុគ្គលិកជាន់ខ្ពស់ដោយបង្គាប់ រារាំង បញ្ឈប់ ឬកម្រិតការចូលរួមក្នុងសកម្មភាពអាជីវកម្ម ឬសកម្មភាពជួញដូរមូលបត្រ និង

(៤) សេចក្តីសម្រេចរបស់ គ.ម.ក គណៈកម្មការមូលបត្របរទេស ឬនិយ័តករដទៃទៀត លើការបញ្ឈប់ ឬកម្រិតការចូលរួមរបស់អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនយើង ក្នុងសកម្មភាពអាជីវកម្ម សកម្មភាពជួញដូរមូលបត្រកម្មសិទ្ធិ ឬសកម្មភាពធនាគារ។

៥.៣. លាភការ ឬប្រាក់បំណាច់របស់អតឡាល និងបុគ្គលិកជាន់ខ្ពស់

៥.៣.១. ឈ្មោះ និងមុខតំណែងរបស់បុគ្គលិកទទួលឡាន ប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតប្រាំ (៥) រូបព្រមទាំង លាភការសរុប

លាភការ និងអត្ថប្រយោជន៍សរុបដែលត្រូវបង់ទៅឱ្យបុគ្គលិកទទួលបាន ប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតប្រាំ (៥) រូបរបស់ក្រុមហ៊ុន អំឡុងដំណាច់ការិយបរិច្ឆេទថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៨ និងដំណាច់ការិយបរិច្ឆេទថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៩៖

ក្រុះរាជាណាចក្រកម្ពុជា ផេសទិក (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

៥. ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ត)

ល.រ.	ឈ្មោះ	មុខតំណែង	លាភការសរុប ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ដុល្លារអាមេរិក	លាភការសរុប ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដុល្លារអាមេរិក
១.	លោក Han Fatt Juan	នាយកប្រតិបត្តិ	២៦៨.២៧២	២៦៨.២៧៣
២.	លោក Yaddehige Shirley Manoj Krishantha Perera	ប្រធានគម្រោង		
៣.	លោក Samaraj Mohan	Chief of Tower and Stringing		
៤.	លោក Chee Jean Thai	វិស្វកម្មសំណង់ស៊ីវិល		
៥.	លោក Thlang Kompheak	ជំនួយការប្រធាន		

៥.៣.២.លាភការសរុបដែលបង់ឱ្យអភិបាលមិនប្រតិបត្តិ

សម្រាប់ដំណាច់ការិយបរិច្ឆេទអនុវត្តចុងក្រោយ លាភការសរុបដែលត្រូវបង់ឱ្យអភិបាលមិនប្រតិបត្តិមានចំនួន ៣០.០០០ ដុល្លារអាមេរិក។ មិនមានការផ្លាស់ប្តូរលាភការសរុបដែលត្រូវបង់ឱ្យអភិបាលមិនប្រតិបត្តិសម្រាប់ដំណាច់ការិយបរិច្ឆេទអនុវត្តចុងក្រោយនោះទេ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។

៥.៣.៣.លាភការសរុបដែលត្រូវបង់ឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់

សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ លាភការសរុបដែលត្រូវបង់ឱ្យអភិបាលនិងបុគ្គលិកជាន់ខ្ពស់មានចំនួន ៣៧០.៩៣២ ដុល្លារអាមេរិក។ មិនមានការផ្លាស់ប្តូរលាភការសរុបដែលត្រូវបង់ឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩នោះទេ ប្រៀបធៀបនឹងដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។

៥.៣.៤.លាភការសរុបដែលបានស្នើដើម្បីបង់ឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់សម្រាប់រយៈពេលមួយ (១) ឆ្នាំសារពើពន្ធខាងមុន

លាភការសរុបសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ត្រូវបានប៉ាន់ប្រមាណប្រហែល ៣៧០.៩៣២ ដុល្លារអាមេរិក។

៥.៣.៥.កំណើនគួរឱ្យកត់សម្គាល់លើលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និង បុគ្គលិកជាន់ខ្ពស់អំឡុងពេលបច្ចុប្បន្ន និងឆ្នាំសារពើពន្ធខាងមុខ

ក្រៅពីការតម្លើងប្រាក់បៀវត្សន៍នៅក្នុងសកម្មភាពអាជីវកម្មធម្មតារបស់ក្រុមហ៊ុន យើងមិនមានការរំពឹងថានឹងមានកំណើនគួរឱ្យកត់សម្គាល់លើលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

៥.៤. សិទ្ធិទិញមូលបត្រកម្មសិទ្ធិ ដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

៥.៤.១. សិទ្ធិទិញដែលបានបានផ្តល់ឱ្យទៅអភិបាល

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ មិនមានសិទ្ធិទិញមូលបត្រកម្មសិទ្ធិ (Stock Option) ផ្តល់ទៅឱ្យអភិបាលនោះឡើយ។

៥.៤.២.សិទ្ធិទិញដែលបានបានផ្តល់ឱ្យទៅបុគ្គលិកជាន់ខ្ពស់

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ មិនមានសិទ្ធិទិញមូលបត្រកម្មសិទ្ធិ (Stock Option) ផ្តល់ទៅឱ្យបុគ្គលិកជាន់ខ្ពស់នោះឡើយ។

៥.៤.៣.សិទ្ធិទិញដែលបានផ្តល់ឱ្យទៅនិយោជិត

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ មិនមានសិទ្ធិទិញមូលបត្រកម្មសិទ្ធិ (Stock Option) ផ្តល់ទៅឱ្យនិយោជិតនោះឡើយ។

៥. ព័ត៌មានពាក់ព័ន្ធនឹងអតិថិជន បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ត)

៥.៥. ការកាន់កាប់ភាគហ៊ុន

៥.៥.១. អត្តសញ្ញាណភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិអប្បបរិមា ៥%

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយអត្ថប្រយោជន៍ផ្តាល់ និងមិនផ្តាល់របស់ភាគហ៊ុនិកដែលកាន់កាប់មូលបត្រកម្មសិទ្ធិយ៉ាងតិច ៥% នៅក្នុងក្រុមហ៊ុនមានដូចខាងក្រោម៖

			ផ្តាល់		មិនផ្តាល់	
ល.រ.	ឈ្មោះ	អាសយដ្ឋានចុះបញ្ជី	ចំនួនមូលបត្រកម្មសិទ្ធិ	%	ចំនួនមូលបត្រកម្មសិទ្ធិ	%
១	ក្រុមហ៊ុន PIB	ជាន់ទី៧ Menara Milenium, Jalan Damanlela, Pusat Bandar Damansara, Damansara Heights, 50490 ក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី	៧១.០០០.០០០	១០០	-	-
២	លោក Lim Ah Hock	លេខ២៧A, Jalan Permas 1/5, Bandar Baru Permas Jaya, 81750 Masai, Johor, ប្រទេសម៉ាឡេស៊ី	-	-	២៣.៦៩២.៧០០ (១)	៣៣,៣៧០
៣	លោក Lim Pay Chuan	លេខ ៣៥៦ Jalan Yong Pak Kian, Ujong Pasir 75075 ម៉ាឡាកា ប្រទេសម៉ាឡេស៊ី	-	-	១៥.១១០.៩៣០ (២)	២១,២៨៣

ចំណាំ៖

(១) ការកាន់កាប់ភាគហ៊ុនដោយប្រយោលរបស់គាត់នៅក្នុងក្រុមហ៊ុន ផេសទិក (ខេមបូឌា) កើតចេញពីអត្ថប្រយោជន៍មូលបត្រដែលមានប្រសិទ្ធិភាពក្នុងក្រុមហ៊ុន PIB ក្នុងចំនួន ៣៣,៣៧០% ។

(២) ការកាន់កាប់ភាគហ៊ុនដោយប្រយោលរបស់គាត់នៅក្នុងក្រុមហ៊ុន ផេសទិក (ខេមបូឌា) កើតចេញពីអត្ថប្រយោជន៍មូលបត្រដែលមានប្រសិទ្ធិភាពក្នុងក្រុមហ៊ុន PIB ក្នុងចំនួន ២១,២៨៣% ។

៥.៥.២.អត្តសញ្ញាណអតថាលដែលកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ អត្ថប្រយោជន៍ផ្តាល់ និងមិនផ្តាល់របស់អភិបាលនៅក្នុងក្រុមហ៊ុនរបស់យើង មានដូចខាងក្រោម៖

			ផ្តាល់		មិនផ្តាល់	
ល.រ.	ឈ្មោះ	អាសយដ្ឋានចុះបញ្ជី	ចំនួនមូលបត្រកម្មសិទ្ធិ	%	ចំនួនមូលបត្រកម្មសិទ្ធិ	%
១	លោក Lim Ah Hock	No. 27A, Jalan Permas 1/5, Bandar Baru Permas Jaya, 81750 Masai, Johor, Malaysia	-	-	២៣.៦៩២.៧០០ (១)	៣៣,៣៧០
២	លោក Lim Pay Chuan	No. 346, Jalan Yong Pak Kian, Ujong Pasir, 75050 Melaka, Malaysia	-	-	១៥.១១០.៩៣០ (២)	២១,២៨៣
៣	លោក Han Fatt Juan	31, Jalan SL 7/18, Bandar Sg. Long, 43200 Kajang, Selangor Darul Ehsan, Malaysia	-	-	៣៨១.២៧០ (៣)	០,៥៣៧
៤	លោក Tan Pu Hooi	No. 71, Janlan PJU 1A/1C, Ara Damansara, 47301, Petaling Jaya, Selangor, Malaysia	-		៦៥៦.០៤០ (៤)	០,៩២៤

ចំណាំ៖

(១) ការកាន់កាប់ភាគហ៊ុនដោយប្រយោលរបស់គាត់នៅក្នុងក្រុមហ៊ុន ផេសថិក (ខេមបូឌា) កើតចេញពីអត្ថប្រយោជន៍មូលបត្រដែលមានប្រសិទ្ធិភាពក្នុងក្រុមហ៊ុន PIB ក្នុងចំនួន ៣៣,៣៧០% ។

(២) ការកាន់កាប់ភាគហ៊ុនដោយប្រយោលរបស់គាត់នៅក្នុងក្រុមហ៊ុន ផេសថិក (ខេមបូឌា) កើតចេញពីអត្ថប្រយោជន៍មូលបត្រដែលមានប្រសិទ្ធិភាពក្នុងក្រុមហ៊ុន PIB ក្នុងចំនួន ២១,២៨៣% ។

(៣) ការកាន់កាប់ភាគហ៊ុនដោយប្រយោលរបស់គាត់នៅក្នុងក្រុមហ៊ុន ផេសថិក (ខេមបូឌា) កើតចេញពីអត្ថប្រយោជន៍មូលបត្រដែលមានប្រសិទ្ធិភាពក្នុងក្រុមហ៊ុន PIB ក្នុងចំនួន ០,៥៣៧% ។

(៤) ការកាន់កាប់ភាគហ៊ុនដោយប្រយោលរបស់គាត់នៅក្នុងក្រុមហ៊ុន ផេសថិក (ខេមបូឌា) កើតចេញពីអត្ថប្រយោជន៍មូលបត្រដែលមានប្រសិទ្ធិភាពក្នុងក្រុមហ៊ុន PIB ក្នុងចំនួន ០,៩២៤% ។

៥. ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិករបស់ក្រុមហ៊ុន (ត)

៥.៥.៣.អត្ថសញ្ញាណនិយោជិតទាំងប្រាំ (៥) ដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់ជាងគេដែលកាន់កាប់មូលបត្រកម្មសិទ្ធិក្នុងក្រុមហ៊ុន

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ អត្ថប្រយោជន៍ផ្តាល់ និងមិនផ្តាល់របស់និយោជិតទាំងប្រាំ (៥) នៅក្នុងក្រុមហ៊ុនយើងមានដូចខាងក្រោម៖

			ផ្តាល់		មិនផ្តាល់	
ល.រ.	ឈ្មោះ	មុខតំណែង	ចំនួនមូលបត្រកម្មសិទ្ធិ	%	ចំនួនមូលបត្រកម្មសិទ្ធិ	%
១	លោក Han Fatt Juan	អភិបាលប្រតិបត្តិ/ នាយកប្រតិបត្តិ	-	-	៣៨១.២៧០ (១)	០,៥៣៧
២	លោក Yaddehige Shirley Manoj Krishanha Perera	ប្រធានគម្រោង	-	-	២.១៣០ (២)	០,០០៣
៣	លោក Loch Chansothear	ប្រធានគម្រោង	-	-	១.៤២០ (៣)	០,០០២
៤	លោក Samaraj Mohan	Chief of Tower & Stringing	-	-	២.១៣០ (៤)	០,០០៣
៥	លោក Chee Jean Thai	វិស្វកម្មសំណង់ ស៊ីវិល	-	-	៧១០ (៥)	០,០០១

ចំណាំ៖

(១) ការកាន់កាប់ភាគហ៊ុនដោយប្រយោលរបស់គាត់នៅក្នុងក្រុមហ៊ុន ផេសថិក (ខេមបូឌា) កើតចេញពីអត្ថប្រយោជន៍មូលបត្រដែលមានប្រសិទ្ធិភាពក្នុងក្រុមហ៊ុន PIB ក្នុងចំនួន ០,៥៣៧% ។

(២) ការកាន់កាប់ភាគហ៊ុនដោយប្រយោលរបស់គាត់នៅក្នុងក្រុមហ៊ុន ផេសថិក (ខេមបូឌា) កើតចេញពីអត្ថប្រយោជន៍មូលបត្រដែលមានប្រសិទ្ធិភាពក្នុងក្រុមហ៊ុន PIB ក្នុងចំនួន ០,០០៣% ។

(៣) ការកាន់កាប់ភាគហ៊ុនដោយប្រយោលរបស់គាត់នៅក្នុងក្រុមហ៊ុន ផេសថិក (ខេមបូឌា) កើតចេញពីអត្ថប្រយោជន៍មូលបត្រដែលមានប្រសិទ្ធិភាពក្នុងក្រុមហ៊ុន PIB ក្នុងចំនួន ០,០០២% ។

(៤) ការកាន់កាប់ភាគហ៊ុនដោយប្រយោលរបស់គាត់នៅក្នុងក្រុមហ៊ុន ផេសថិក (ខេមបូឌា) កើតចេញពីអត្ថប្រយោជន៍មូលបត្រដែលមានប្រសិទ្ធិភាពក្នុងក្រុមហ៊ុន PIB ក្នុងចំនួន ០,០០៣% ។

(៥) ការកាន់កាប់ភាគហ៊ុនដោយប្រយោលរបស់គាត់នៅក្នុងក្រុមហ៊ុន ផេសថិក (ខេមបូឌា) កើតចេញពីអត្ថប្រយោជន៍មូលបត្រដែលមានប្រសិទ្ធិភាពក្នុងក្រុមហ៊ុន PIB ក្នុងចំនួន ០,០០១% ។

៦. ជំនាក់ជំនួច និងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ

៦.១. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ

លើកលែងមានបង្ហាញខាងក្រោម មិនមានប្រតិបត្តិការដែលមានស្រាប់ ឬដែលបានស្នើ ដែលបានធ្វើ ឬនឹងធ្វើឡើងជាមួយភាគហ៊ុនិក អំឡុងការិយបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ៖

ឈ្មោះភាគហ៊ុនិក	ប្រភេទប្រតិបត្តិការ	ការកាន់កាប់ភាគហ៊ុន		តម្លៃប្រតិបត្តិការពាន់ដុល្លារអាមេរិក	
		ផ្ទាល់(%)	ប្រយោល(%)	ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨	ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩
ក្រុមហ៊ុន PSB	ផ្គត់ផ្គង់សម្ភារៈ	១០០*		១៣.៦០៧	៣៦.៥០១
ក្រុមហ៊ុន PIB	កម្រៃនៃការគ្រប់គ្រង	១០០		៥៣៣	៣០១

ចំណាំ៖

* ការបង្ហាញថាភាគហ៊ុនកម្មសិទ្ធិរបស់ក្រុមហ៊ុន PSB នៅក្នុងក្រុមហ៊ុនយើង មុនពេលមានការរៀបចំរចនាសម្ព័ន្ធឡើងវិញ

៦.២. ប្រតិបត្តិការសំខាន់ៗជាមួយអគ្គាល ឬ បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនក្នុងរយៈពេលពីរ (២) ឆ្នាំ ចុងក្រោយ

មិនមានប្រតិបត្តិការដែលមានស្រាប់ ឬដែលបានស្នើ ដែលបានធ្វើ ឬនឹងធ្វើឡើងជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនយើង អំឡុងកាលបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ។

៦.៣. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនអប្បបរិមា ៥% នៃភាគហ៊ុនដែលនៅសល់របស់ក្រុមហ៊ុនក្នុងរយៈពេល ២ឆ្នាំចុងក្រោយ

លើកលែងមានបង្ហាញខាងក្រោម មិនមានប្រតិបត្តិការដែលមានស្រាប់ ឬដែលបានស្នើ ដែលបានធ្វើ ឬនឹងធ្វើឡើងជាមួយភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនអប្បបរិមា ៥% នៃភាគហ៊ុនដែលនៅសល់អំឡុងកាលបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ។

៦. ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ (ត)

		ការកាន់កាប់ភាគហ៊ុន		តម្លៃប្រតិបត្តិការ ពាន់ដុល្លារអាមេរិក	
ឈ្មោះភាគហ៊ុនិក	ប្រភេទប្រតិបត្តិការ	ផ្ទាល់(%)	ប្រយោល(%)	ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨	ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩
ក្រុមហ៊ុន PSB	ផ្តត់ផ្តង់សម្ភារៈ	១០០*	-	១៣.៦០៧	៣៦.៥០១
ក្រុមហ៊ុន PIB	កម្រៃនៃការគ្រប់គ្រង	១០០	-	៥៣៣	៣០១

ចំណាំ៖

* ការបង្ហាញថាភាគហ៊ុនកម្មសិទ្ធិរបស់ក្រុមហ៊ុន PSB នៅក្នុងក្រុមហ៊ុនយើង មុនពេលមានការរៀបចំរចនាសម្ព័ន្ធឡើងវិញ

៦.៤. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនអប្បបរិមា ៥% នៃភាគហ៊ុនក្រុមហ៊ុនដែលកំពុងធ្វើចរាចរក្នុងទីផ្សារក្នុងរយៈពេល២ឆ្នាំចុងក្រោយ

មិនមានប្រតិបត្តិការដែលមានស្រាប់ ឬដែលបានស្នើ ដែលបានធ្វើ ឬនឹងធ្វើឡើងជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនអប្បបរិមា ៥% នៃភាគហ៊ុនដែលនៅសល់អំឡុងការិយបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ។

៦.៥. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុន ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ ក្រុមហ៊ុនហួលឌីង ដែលទំនាក់ទំនងរវាងបុគ្គលទាំងនោះកើតមានក្នុងពេលប្រតិបត្តិការ ឬ ការរៀបចំចាត់ចែងណាមួយដែលធ្វើឡើងដោយក្រុមហ៊ុនក្នុងរយៈពេល ២ឆ្នាំចុងក្រោយ

លើកលែងមានបង្ហាញខាងក្រោម មិនមានប្រតិបត្តិការដែលមានស្រាប់ ឬដែលបានស្នើ ដែលបានធ្វើ ឬនឹងធ្វើឡើងជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុន ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហួលឌីងប្រតិបត្តិប្រតិបត្តិអំឡុងការិយបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ។

៦. ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ (ត)

ដៃគូសហការ	លក្ខណៈទំនាក់ទំនង	ប្រភេទប្រតិបត្តិការ	តម្លៃប្រតិបត្តិការ ពាន់ដុល្លារអាមេរិក ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨	ការិយបរិច្ឆេទថ្ងៃទី៣០ខែ មិថុនា ឆ្នាំ២០១៩
ក្រុមហ៊ុន ដាយអ៊ីម៉ុន ផៅវែរ	ជាក្រុមហ៊ុនដែលមានអភិបាលមានផលប្រយោជន៍តាមរយៈក្រុមហ៊ុន PIB	ការផ្គត់ផ្គង់សេវាកម្មពាក់ព័ន្ធនឹងការការគូសបន្ទង់ ការសាងសង់ ការសាកល្បង និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបញ្ជូនចាមពលដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល ពីកំពង់ចាម - ក្រចេះ	២.១៨៤	-
		សេវាថែទាំ និងប្រតិបត្តិការ	២៨៧	២.៤០៦
ក្រុមហ៊ុន Enersol Co., Ltd	ជាក្រុមហ៊ុនដែលមានអភិបាលមានផលប្រយោជន៍ តាមរយៈក្រុមហ៊ុន PIB	ការទិញផលិតផល និងសម្ភារៈសម្រាប់គម្រោងរបស់យើង	១.៩៧៣	៣៨.៧២៤
ក្រុមហ៊ុន PESTECH Energy Sdn Bhd (ពីមុនជាក្រុមហ៊ុន Xcell ATS (M) Sdn Bhd)	ជាក្រុមហ៊ុនដែលមានអភិបាលមានផលប្រយោជន៍ តាមរយៈក្រុមហ៊ុន PIB	ការទិញផលិតផល និងសម្ភារៈសម្រាប់គំរោងរបស់យើង	៩	-
ក្រុមហ៊ុន PESTECH Transmission Sdn Bhd	ជាក្រុមហ៊ុនដែលមានអភិបាលមានផលប្រយោជន៍ តាមរយៈក្រុមហ៊ុន PIB	តម្លៃកិច្ចសន្យា	-	១.១៤១

៦.៦. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលធ្លាប់ជាអភិបាល ឬ បុគ្គលដែលជាប់ពាក់ព័ន្ធនឹងបុគ្គលដែលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុន ដែលទំនាក់ទំនងរវាងបុគ្គលទាំងនោះកើតមានក្នុងពេលប្រតិបត្តិការអាជីវកម្មក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ

មិនមានប្រតិបត្តិការដែលមានស្រាប់ ឬដែលបានស្នើ ដែលបានធ្វើ ឬនឹងធ្វើឡើងជាមួយបុគ្គលដែលធ្លាប់ជាអភិបាល ឬ បុគ្គលដែលជាប់ពាក់ព័ន្ធនឹងបុគ្គលដែលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុនយើងដែលទំនាក់ទំនងរវាងបុគ្គលទាំងនោះកើតមានក្នុងពេលប្រតិបត្តិអាជីវកម្ម អំឡុងការិយបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ។

៦.៧. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខដំណែងក្នុងសហគមន៍ ឬ អង្គការមិនស្វែងរកប្រាក់ចំណេញ ឬ ក្រុមហ៊ុនណាមួយផ្សេងក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ

មិនមានប្រតិបត្តិការដែលមានស្រាប់ ឬដែលបានស្នើ ដែលបានធ្វើ ឬនឹងធ្វើឡើងជាមួយអភិបាលដែលកាន់មុខដំណែងក្នុងសហគមន៍ ឬ អង្គការមិនស្វែងរកប្រាក់ចំណេញ ឬ ក្រុមហ៊ុនណាមួយផ្សេងទៀត ប្រតិបត្តិអំឡុងការិយបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ។

៦.៨. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬ កម្រៃឧជ្ជាជីវៈសម្រាប់ សេវាដែលខ្លួនបានផ្តល់តាមរយៈសហគ្រាសណាមួយដល់ក្រុមហ៊ុន ក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយ

មិនមានប្រតិបត្តិការដែលមានស្រាប់ ឬដែលបានស្នើ ដែលបានធ្វើ ឬនឹងធ្វើឡើងជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈសម្រាប់សេវាដែលខ្លួនបានផ្តល់តាមរយៈសហគ្រាសណាមួយដល់ក្រុមហ៊ុនប្រតិបត្តិអំឡុងការិយបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ៕

៧. ព័ត៌មានព័ត៌មានបរិញ្ញាបត្រ

៧.១ អត្រាប្តូរប្រាក់

រូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជាគឺប្រាក់រៀល។

ប្រតិបត្តិការធ្វើឡើងជារូបិយប័ណ្ណបរទេសក្រៅពីដុល្លារអាមេរិក ត្រូវប្តូរជាដុល្លារអាមេរិកតាមវិធាននៃអត្រាប្តូរប្រាក់បរទេសស្របតាមមកាលបរិច្ឆេទនៃប្រតិបត្តិការ។ ទ្រព្យសកម្ម និងបំណុលជារូបិយវត្ថុដែលត្រូវយកជារូបិយប័ណ្ណផ្សេងពីដុល្លារអាមេរិក នៅកាលបរិច្ឆេទរបាយការណ៍ ត្រូវប្តូរជារូបិយប័ណ្ណដុល្លារអាមេរិកតាមអត្រានៃវិធានប្តូរប្រាក់នៅកាលបរិច្ឆេទនោះ។ ភាពខុសគ្នានៃអត្រាប្តូរប្រាក់ដែលកើតចេញពីការប្តូរប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលចម្រុះ។

ការប្តូរប្រាក់ពីដុល្លារអាមេរិកទៅជាប្រាក់រៀល ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលសម្រាប់តែគោលបំណងបំពេញលក្ខខណ្ឌតម្រូវស្របតាមច្បាប់ស្តីពីគណនេយ្យ សហគ្រាស សវនកម្ម គណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យនៅកម្ពុជា និងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម (ខែមេសា ឆ្នាំ ២០១៦) និងត្រូវបានធ្វើឡើងដោយប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការ ក្នុងអត្រា ១,០០ ដុល្លារអាមេរិកស្មើនឹង ៤.០៦៦ រៀល ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និង ១,០០ ដុល្លារអាមេរិក ស្មើនឹង ៤.០៦៣ រៀល ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ស្របតាមការចុះផ្សាយរបស់អគ្គនាយកដ្ឋានពន្ធដារ។ ដំណើរការនៃការប្តូរប្រាក់នេះ មិនត្រូវបានចាត់ទុកជាការសន្មត់ថាប្រាក់ដុល្លារអាមេរិក ត្រូវបាន ឬអាចត្រូវបាន ឬនាពេលអនាគត ត្រូវប្តូរទៅជាប្រាក់រៀលក្នុងអត្រាជាក់លាក់ ឬអត្រាប្តូរប្រាក់ផ្សេងពីនេះឡើយ។

៧. ព័ត៌មានព័ត៌មានហិរញ្ញវត្ថុ (ត)

៧.២. ព័ត៌មានស្តីពីប្រវត្តិហិរញ្ញវត្ថុ

ទិន្នន័យស្តីពីប្រវត្តិហិរញ្ញវត្ថុខាងក្រោមសម្រាប់ដំណាច់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យត្រូវបានស្រង់ចេញពីរបាយការណ៍គណនេយ្យរបស់ក្រុមហ៊ុនយើង ដែលមាននៅផ្នែកទី៩ នៃឯកសារផ្តល់ព័ត៌មាននេះ។

ទិន្នន័យស្តីពីប្រវត្តិហិរញ្ញវត្ថុខាងក្រោម គួរត្រូវអានរួមគ្នាជាមួយនឹង "កិច្ចពិភាក្សាផ្នាក់គ្រប់គ្រង និងការវិភាគលក្ខខណ្ឌហិរញ្ញវត្ថុ និងសមិទ្ធផលប្រតិបត្តិការក្រុមហ៊ុន" ដែលមាននៅក្នុងផ្នែកទី៧.៤ និង របាយការណ៍គណនេយ្យរបស់ក្រុមហ៊ុនយើងដែលមាននៅក្នុងផ្នែកទី៩ នៃឯកសារផ្តល់ព័ត៌មាននេះ។

៧.២.១.ចរាយការណ៍ចំណេញ ឬខាត

តារាងខាងក្រោមជាសេចក្តីសង្ខេបនៃរបាយការណ៍ចំណេញ ឬខាតរបស់ក្រុមហ៊ុន ដែលបានធ្វើសវនកម្មរួចរាល់សម្រាប់ដំណាច់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យ៖

	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨		ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ចំណូល	៧៧.១៥៧	៣១៣.៤៨៦	៥៦.៨២៧	២៣១.០៥៨
ថ្លៃដើមពីការលក់ និងសាងសង់	(៦២.៩៦៧)	(២៥៥.៨៣៤)	(៤៩.៧៧០)	(២០២.៣៦៥)
ចំណេញដុល	**១៤.១៩០**	**៥៧.៦៥២**	**៧.០៥៧**	**២៨.៦៩៣**
ចំណូលផ្សេងៗ	៧	២៩	១.៥២២	៦.១៨៧
ចំណាយប្រតិបត្តិការ	(៤.០៦៣)	(១៦.៥០៦)	(២.៧៨១)	(១១.៣០៦)
ចំណេញប្រតិបត្តិការ	**១០.១៣៤**	**៤១.១៧៥**	**៥.៧៩៨**	**២៣.៥៧៤**
ចំណូលហិរញ្ញប្បទាន	-	១	១២	៤៨
ចំណាយហិរញ្ញប្បទាន	(១៦៩)	(៦៨៨)	(៣.៤៦៧)	(១៤.០៩៤)
ចំណេញមុនគិតពន្ធ	**៩.៩៦៥**	**៤០.៤៨៨**	**២.៣៤៣**	**៩.៥២៨**
ការចំណាយពន្ធលើប្រាក់ចំណូល	(២.៣៨៤)	(៩.៦៨៤)	(៥៦៨)	(២.៣១០)
ចំណេញក្នុងឆ្នាំ	**៧.៥៨១**	**៣០.៨០៤**	**១.៧៧៥**	**៧.២១៨**
ការខាត់បង់តម្លៃលើលំហូរសាច់ប្រាក់	-	-	(១.៨២៤)	(៧.៤១៧)
លទ្ធផលចំណេញ ឬខាតលម្អិតសរុបប្រចាំឆ្នាំ	**៧.៥៨១**	**៣០.៨០៤**	**(៤៩)**	**(១៩៩)**
គំលាតចំណេញដុល (%)	១៨,៣៩	១៨,៣៩	១២,៤២	១២,៤២

៧. ព័ត៌មានព័ត៌មានហិរញ្ញវត្ថុ (ត)

	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨		ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
គំលាតប្រាក់ចំណេញមុនគិតពន្ធ (%)	១២,៩២	១២,៩២	៤,១២	៤,១២

៧.២.២. របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

តារាងខាងក្រោមជាសេចក្តីសង្ខេបរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលបានធ្វើសវនកម្មរួចរាល់ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩៖

	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨		ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ទ្រព្យសកម្ម				
ទ្រព្យសកម្មរយៈពេលវែង				
ទ្រព្យសម្បត្តិ អាងចក្រនិងបរិក្ខារ	១.៩១៣	៧.៧៧១	២.២៤៧	៩.១៣៥
ទ្រព្យសកម្មអរូបី	-	-	៣	១២
ទ្រព្យសកម្មកិច្ចសន្យា	១៤៦.៥៨៧	៥៩៥.៥៨៣	១៧៣.០៥៩	៧០៣.៦៥៨
ទ្រព្យសកម្មរយៈពេលវែងសរុប	**១៤៨.៥០០**	**៦០៣.៣៥៤**	**១៧៥.៣០៩**	**៧១២.៨០៥**
ទ្រព្យសកម្មរយៈពេលខ្លី				
គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ	៨៤៦	៣.៤៣៦	១០.៨០៤	៤៣.៩២៨
ទ្រព្យតាមកិច្ចសន្យា	-	-	៦.០៤២	២៤.៥៦៥
ទឹកប្រាក់ភាគីសម្ព័ន្ធញាតិជិតាក់	-	-	១.៩៤៤	៧.៩០៧
សាច់ប្រាក់ និងសមតុល្យធនាគារ	២.០៨៤	៨.៤៦៩	១៣.០៥៦	៥៣.០៨៦
ទ្រព្យសកម្មរយៈពេលខ្លីសរុប	**២.៩៣០**	**១១.៩០៥**	**៣១.៨៤៦**	**១២៩.៤៨៦**
ទ្រព្យសកម្មសរុប	**១៥១.៤៣០**	**៦១៥.២៥៩**	**២០៧.១៥៥**	**៨៤២.២៩១**
មូលធន និងបំណុល				
មូលធន				
ដើមទុន	៧.១០០	២៨.៨៤៧	៧.១០០	២៨.៨៦៨
ដើមទុនបម្រុងទុក	៥២	២១១	(១.៧៧២)	(៧.២០៥)
ចំណេញរក្សាទុក	២០.៦៣១	៨៣.៨២៤	៨.៥៩៥	៣៤.៩៤៧

៧. ព័ត៌មានព័ត៌មានហិរញ្ញវត្ថុ (ត)

	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨		ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
មូលធនសរុប	**២៧.៧៨៣**	**១១២.៨៨២**	**១៣.៩២៣**	**៥៦.៦១០**
បំណុលរយៈពេលវែង				
ប្រាក់កម្ចី	១៩.៩៤៥	៨១.០៣៧	៩៥.៤០៧	៣៨៧.៩២៥
ឧបករណ៍និស្សន្ទ	-	-	១.៨២៤	៧.៤១៧
បំណុលរយៈពេលវែងសរុប	**១៩.៩៤៥**	**៨១.០៣៧**	**៩៧.២៣១**	**៣៩៥.៣៤២**
បំណុលរយៈពេលខ្លី				
គណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងៗ	៤៨.០០៥	១៩៥.០៤៣	៨.៣១៧	៣៣.៨១៨
ទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុនមេ	៥៦៥	២.២៩៦	៥៩.៥៥៨	២៤២.១៦២
ទឹកប្រាក់ដែលជំពាក់សម្ព័ន្ធញាតិ	៤៩.៦៧៩	២០១.៨៤៦	២៣.០១៨	៩៣.៥៨៩
ប្រាក់កម្ចី	២.០៦៨	៨.៤០២	៤.១៨០	១៦.៩៩៧
ពន្ធលើប្រាក់ចំណូលត្រូវបង់	៣.៣៨៥	១៣.៧៥៣	៩២៨	៣.៧៧៣
បំណុលរយៈពេលខ្លីសរុប	**១០៣.៧០២**	**៤២១.៣៤០**	**៩៦.០០១**	**៣៩០.៣៣៩**
បំណុលសរុប	**១២៣.៦៤៧**	**៥០២.៣៧៧**	**១៩៣.២៣២**	**៧៨៥.៦៨១**
មូលធន និងបំណុលសរុប	**១៥១.៤៣០**	**៦១៥.២៥៩**	**២០៧.១៥៥**	**៨៤២.២៩១**

៧.៣. មូលធនឥយកម្ម និងបំណុល

តារាងខាងក្រោមជាសេចក្តីសង្ខេបអំពីសាច់ប្រាក់និងសាច់ប្រាក់សមមូល ក៏ដូចជាមូលធនឥយកម្មនិងបំណុលរបស់ក្រុមហ៊ុន៖

ក) ផ្អែកលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលបានធ្វើសវនកម្មត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩

ខ) និងដូចដែលបានកែសម្រួលប្រាក់ទទួលបានពីការបោះផ្សាយមូលបត្រជាសាធារណៈ និងការចំណាយលើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដូចដែលមានកំណត់នៅផ្នែកទី ២.១២ នៃឯកសារផ្តល់ព័ត៌មាននេះ។

៧. ព័ត៌មានព័ត៌មានហិរញ្ញវត្ថុ (ក)

	ធ្វើសវនកម្ម ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	បានធ្វើបន្ទាប់ពីការបោះផ្សាយលក់ មូលបត្រជាសាធារណៈ និងចំណាយ លើការបោះផ្សាយលក់មូលបត្រ កម្មសិទ្ធិជាសាធារណៈ
	ពាន់ដុល្លារអាមេរិក	ពាន់ដុល្លារអាមេរិក
បំណុល		
រយៈពេលខ្លី (ដល់កំណត់សងក្នុងរយៈពេល ១២ខែ)	៤.១៨០	៤.១៨០
រយៈពេលវែង (ដល់កំណត់សងបន្ទាប់ពី១២ ខែ)	៩៥.៤០៧	៩៥.៤០៧
(ក) បំណុលសរុប	**៩៩.៥៨៧**	**៩៩.៥៨៧**
មូលធននីយកម្ម		
មូលធនសរុប	១៣.៩២៣	១៦.៤១៤
(ខ) មូលធននីយកម្មសរុប	១៣.៩២៣	១៦.៤១៤
មូលធន និងបំណុលសរុប (ក) + (ខ)	**១១៣.៥១០**	**១១៦.០០១**

៧.៤. កថាពិភាក្សាថ្នាក់គ្រប់គ្រង និងការវិភាគលក្ខខណ្ឌហិរញ្ញវត្ថុ និងសមិទ្ធផលប្រតិបត្តិការក្រុមហ៊ុន

កិច្ចពិភាក្សាថ្នាក់គ្រប់គ្រងនិងការវិភាគលក្ខខណ្ឌហិរញ្ញវត្ថុ និងសមិទ្ធផលប្រតិបត្តិការក្រុមហ៊ុនខាងក្រោម គួរអានដោយផ្ទៀងផ្ទាត់ជាមួយ របាយការណ៍ចំណេញឬខាត ដូចមានរៀបរាប់នៅផ្នែកទី៧.២.១ និង របាយការណ៍គណនេយ្យ នៅផ្នែកទី៩ នៃឯកសារផ្តល់ព័ត៌មាននេះ។

កិច្ចពិភាក្សានិងការវិភាគនេះមានផ្ទុកទិន្នន័យដែលយកចេញពីរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម រួចរាល់ ក៏ដូចជាសេចក្តីថ្លែងការណ៍ពីអនាគតដែលពាក់ព័ន្ធនឹងហានិភ័យ និងភាពមិនច្បាស់លាស់ផ្សេងៗ។ លទ្ធផលអាចខុសឆ្ងាយពីការរំពឹងទុកក្នុងសេចក្តីថ្លែងការណ៍ពីអនាគត។ កត្តាដែលអាចបណ្តាលឱ្យលទ្ធផលនាពេលអនាគត មានភាពខុសឆ្ងាយពីការរំពឹងទុកក្នុងសេចក្តីថ្លែងការណ៍ពីអនាគត រួមមានជាអាទិ៍ កត្តាដែលពិភាក្សាខាងក្រោម និងនៅផ្នែកណាផ្សេងទៀតនៃឯកសារផ្តល់ព័ត៌មាននេះ ជាពិសេសក្នុងផ្នែកកត្តាហានិភ័យដែលមាននៅផ្នែកទី៣ នៃឯកសារផ្តល់ព័ត៌មាននេះ។

៧.៤.១. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

ក្រុមហ៊ុនយើងត្រូវបានបង្កើតឡើងនៅឆ្នាំ២០១០ ក្នុងនាមជាក្រុមហ៊ុនបច្ចេកវិទ្យាថាមពលអគ្គិសនីទូលំទូលាយ។ ក្រុមហ៊ុនផ្តល់សេវាកម្មចម្បង លើការផ្គត់ផ្គង់វិស្វកម្មប្រព័ន្ធថាមពលទូលំទូលាយ និងដំណោះស្រាយ បច្ចេកវិទ្យាសម្រាប់ការគូសប្លង់ លទ្ធកម្ម ការសាង់សង់ ការដំឡើង និងការដាក់ឱ្យប្រើប្រាស់អនុស្ថានីយ៍ដែលមានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង និងបណ្តាញបញ្ជូនដែលមាន

តង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ក៏ដូចជាប្រព័ន្ធខ្សែភ្លើងក្រោមដីសម្រាប់ការបញ្ជូននិងចែកចាយអគ្គិសនី។ ក្រុមហ៊ុនក៏មានផ្តល់សេវាកម្មចែកចាយបង្គុំប្រព័ន្ធថាមពល និងគ្រឿងបរិក្ខារដែលផលិតដោយក្រុមហ៊ុនសម្ព័ន្ធផេសថិក។

សូមមើលផ្នែកទី ៤.១ នៃឯកសារផ្តល់ព័ត៌មាននេះសម្រាប់ស្ថានភាពលម្អិតនៃធុរកិច្ចរបស់ក្រុមហ៊ុន។

ក. ចំណូល

ប្រភពចំណូលរបស់ក្រុមហ៊ុនកើតចេញពីពីរប្រភពចម្បងគឺការអនុវត្តគម្រោង និងការចែកចាយផលិតផល។

បច្ចុប្បន្នគម្រោងរួមចំណែកយ៉ាងសំខាន់ទៅលើចំណូលរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនប្រើប្រាស់វិធីសាស្ត្របញ្ចប់តាមភាគរយដើម្បីកំណត់ពីចំណូល និងថ្លៃដើមពីការលក់និងសាងសង់ ដែលទទួលស្គាល់អំឡុងពេលកិច្ចសន្យា ដោយប្រៀបធៀបសមាមាត្រនៃថ្លៃដើមដែលបានចំណាយមកទល់ពេលបច្ចុប្បន្ន ទៅនឹងតម្លៃសន្មតសរុបរបស់កិច្ចសន្យា។ នៅពេលលទ្ធផលនៃកិច្ចសន្យាសាងសង់ អាចប៉ាន់ស្មានបានជាក់លាក់ ចំណូលដែលបានពីកិច្ចសន្យា និងថ្លៃដើមនៃកិច្ចសន្យាត្រូវបានទទួលស្គាល់នៅអំឡុងពេល អនុវត្តកិច្ចសន្យាជាចំណូល និងចំណាយដោយយោងទៅតាមភាគរយនៃការបំពេញកាតព្វកិច្ចក្នុងកិច្ចសន្យានៅចុងបញ្ចប់នៃរយៈពេលដែលត្រូវរាយការណ៍។ ភាគរយនៃការបំពេញកាតព្វកិច្ច គឺត្រូវបានបញ្ជាក់ដោយគូភាគីនៃកិច្ចសន្យាជាទូទៅដោយអ្នកគ្រប់គ្រងគម្រោងរបស់ក្រុមហ៊ុន និងវិស្វកររបស់អតិថិជន។

គម្រោងរបស់ក្រុមហ៊ុន ក៏មានបញ្ចូលទាំងផលិតផលដែលប្រើប្រាស់ក្នុងការអនុវត្តគម្រោងរបស់ក្រុមហ៊ុនផងដែរ។

ផលិតផលរបស់ក្រុមហ៊ុនរួមបញ្ចូលផលិតផលដែលផលិត និងតម្លៃបន្ថែម (value added) ដោយសម្ព័ន្ធក្រុមហ៊ុនផេសថិក រួចត្រូវបានចែកចាយដោយក្រុមហ៊ុនយើងទៅឱ្យតតិយជន (ភាគីទី៣) (ពោលគឺផលិតផលដែលមិនត្រូវបានប្រើសម្រាប់គម្រោងរបស់ក្រុមហ៊ុនយើង) មានដូចខាងក្រោម៖

(i) សម្ព័ន្ធក្រុមហ៊ុនផេសថិក ផលិតគ្រឿងបរិក្ខារ និងបង្គុំប្រព័ន្ធថាមពល

(ii) និងគ្រឿងបរិក្ខាររបស់តតិយជន (ភាគីទី៣) រួមបញ្ចូលជាមួយសេវាកម្មតម្លៃបន្ថែមដោយក្រុមហ៊ុនសម្ព័ន្ធផេសថិក។ ឧទាហរណ៍ រូបសណ្ឋាន (configuration) (សរសេរកម្មវិធី និងវិស្វកម្ម) ការធ្វើតេស្តមុខងារ សេវាកម្មបន្ទាប់ពីការលក់ (ការគាំទ្រផ្នែកបច្ចេកទេស និងផលិតផល) និងការតម្លើង

ផលិតផល។

ការលក់ផលិតផលរបស់ក្រុមហ៊ុនជូនដល់តតិយជន (ភាគីទី៣) ត្រូវបាន ប្រើប្រាស់ជាទូទៅសម្រាប់ការតម្លើងអនុស្ថានីយ៍ និងបណ្តាញបញ្ជូនក្នុងគម្រោងដែលទទួលយកដោយតតិយជន (ភាគីទី៣)។ ដោយសារតែលក្ខណៈលម្អិត និងគម្រោងថវិកាសម្រាប់គម្រោងនីមួយៗមានលក្ខណៈខុសគ្នា ផលិតផលរបស់ក្រុមហ៊ុនត្រូវរៀបចំ និងធ្វើតាមការតម្រូវខុសៗគ្នារបស់អតិថិជន។

ខ. ការវិភាគតាមផ្នែក

សម្រាប់ដំណាច់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យ ចំណូលគម្រោងរបស់ក្រុមហ៊ុនកើតចេញពីកិច្ចសន្យានានាដូចខាងក្រោម៖

គម្រោងរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ

គម្រោងនេះរួមបញ្ចូល ការគូសប្តង់ វិស្វកម្ម ផ្គត់ផ្គង់ តម្លើង សាកល្បង និងការផ្តល់បណ្តាញបញ្ជូនដែលមានកំលាំងអគ្គិសនី ២៣០គីឡូវ៉ុល ពីរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ និងគម្រោងពង្រីកអនុស្ថានីយ៍ដែលមានកំលាំង២៣០/១១៥/២២គីឡូវ៉ុល។ កិច្ចព្រមព្រៀងត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៤ ជាមួយក្រុមហ៊ុនអាឡិច ដែលកិច្ចសន្យាមានតម្លៃស្មើនឹង ៨៦,០៦៥ លានដុល្លារអាមេរិក។

នៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ក្រុមហ៊ុនបានចុះហត្ថលេខា ធ្វើវិសោធនកម្មលើ កិច្ចសន្យាខាងលើជាមួយក្រុមហ៊ុនអាឡិច ដើម្បីបន្ថែមលក្ខណៈនៃគម្រោងពីរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ ដោយធ្វើការកែប្រែតម្លៃកិច្ចសន្យាមកចំនួន ១៤៧,៨ លានដុល្លារអាមេរិក។ ការធ្វើឱ្យប្រសើរឡើងដោយបន្ថែមលក្ខណៈទាំងនោះរួមមាន៖

ក. តម្លើងបណ្តាញបញ្ជូនសៀគ្វីស្នូននៃកំលាំង២៣០ គីឡូវ៉ុលពីអនុស្ថានីយ៍ស្ទឹងហាវទៅចំការលួង និង

ខ. តម្លើងបណ្តាញបញ្ជូនសៀគ្វីស្នូននៃកំលាំង៥០០ គីឡូវ៉ុលពីអនុស្ថានីយ៍ចំការលួង ទៅបៃកចាន។

គម្រោងពីរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុដែលត្រូវបានធ្វើឱ្យប្រសើរឡើងនេះ បានបញ្ចប់ក្នុងខែមករា ឆ្នាំ២០២០។

គម្រោងខេត្តកំពង់ចាម - ក្រចេះ

គម្រោងនេះរួមបញ្ចូល ការគូសបន្ទង់ សាងសង់ សាកល្បង និងដាក់ឱ្យប្រើប្រាស់គម្រោងប្រព័ន្ធចែកចាយដែលមានកំលាំងអគ្គិសនី២៣០ គីឡូវ៉ុល ពីខេត្តកំពង់ចាម - ខេត្តក្រចេះ។ នៅក្នុងឆ្នាំ២០១៥ កិច្ចព្រមព្រៀងដែលមានតម្លៃ ១៧,២៣ លានដុល្លារអាមេរិក ត្រូវបានបង្កើតឡើងជាមួយក្រុមហ៊ុនដាយអ៊ីមុនផៅវ៉ែរ ។ កិច្ចសន្យានេះពាក់ព័ន្ធទៅនឹងការងារពលកម្មក្នុងគម្រោងដែលរួមបញ្ចូល ការគូសបន្ទង់ ការសាកល្បងរោងចក្រ ការដឹកជញ្ជូនសម្រាប់សាងសង់បណ្តាញបញ្ជូន និងអនុស្ថានីយ៍។

គម្រោងនេះត្រូវបានបញ្ចប់នៅខែតុលា ឆ្នាំ២០១៧ គឺមួយខែមុនកាលកំណត់នៅខែវិច្ឆិកា ឆ្នាំ២០១៧។

គម្រោងបណ្តាញបញ្ជូនថាមពលស្ថានីយ៍វារីអគ្គិសនីស្ទឹងតាតៃ- ភ្នំពេញ

គម្រោងនេះត្រូវបានចុះកិច្ចព្រមព្រៀងនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ រវាងក្រុមហ៊ុន និងក្រុមហ៊ុនអាឡិច ដែលមានតម្លៃ ១០០,២ លានដុល្លារអាមេរិក។ គម្រោងនេះរួមបញ្ចូល៖

(i) ការគូសបន្ទង់ វិស្វកម្ម ការតម្លើង ការសាកល្បង និងការដាក់ឱ្យប្រើប្រាស់គម្រោងប្រព័ន្ធចែកចាយដែលមានកំលាំងអគ្គិសនី ២៣០ គីឡូវ៉ុល ប្រវែងប្រមាណ២៣០ គីឡូម៉ែត្រពីស្ថានីយ៍វារីអគ្គិសនីស្ទឹងតាតៃ - ភ្នំពេញ

(ii) និងការផ្តត់ផ្តង់ ការតម្លើង និងការតភ្ជាប់បង្គោលបណ្តាញថាមពលអគ្គិសនី២៣០ គីឡូវ៉ុលចំនួនពីរ (០២) នៅទីធ្លាភ្ជាប់ផ្តាច់ចរន្តនៃស្ថានីយ៍វារីអគ្គិសនីស្ទឹងតាតៃ។

គម្រោងនេះគ្រោងនឹងបញ្ចប់នៅត្រឹមខែមេសា ឆ្នាំ២០២១។

គម្រោងខេត្តសៀមរាប - ឧត្តរមានជ័យ

គម្រោងនេះត្រូវបានចុះកិច្ចព្រមព្រៀងនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ រវាងក្រុមហ៊ុន និងក្រុមហ៊ុន Schneitec ដែលមានតម្លៃ ២៦ លានដុល្លារអាមេរិក។ គម្រោងនេះរួមបញ្ចូល៖

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

(i) សាងសង់ប្រព័ន្ធចែកចាយដែលមានសៀគ្វីស្មុនប្រអែង ប្រមាណ ៧៥ + 3 គីឡូម៉ែត្រ ពីសៀមរាប - ឧត្តរមានជ័យ

(ii) សាងសង់អនុស្ថានីយ៍ ឧត្តរមានជ័យថាមពលអគ្គិសនី១១៥/ ២៣០គីឡូវ៉ុល

(iii) សាងសង់អនុស្ថានីយ៍បែកចានថាមពលអគ្គិសនី២៣០/២២ គីឡូវ៉ុល

គម្រោងនេះបានបញ្ចប់នៅក្នុងខែធ្នូ ឆ្នាំ២០១៩។

តារាងខាងក្រោមបង្ហាញពី ការបំបែកចំណូលរបស់ក្រុមហ៊ុនទៅតាមផ្នែកដូចខាងក្រោម៖

	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨		ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	
ផ្នែក	**ពាន់ដុល្លាអាមេរិក**	**%**	**ពាន់ដុល្លាអាមេរិក**	**%**
គម្រោង	៧៧.១៣២	១០០,០	៤៩.៦៥០	៨៧,៤
ផលិតផល	២៥	០,០	៧.១៧៧	១២,៦
សរុប	**៧៧.១៥៧**	**១០០,០**	**៥៦.៨២៧**	**១០០,០**

គ. ថ្លៃដើមនៃការលក់ និងការសាងសង់

ដើមនៃការលក់ និងការសាងសង់របស់គម្រោង រួមមានកិច្ចការសំណង់ស៊ីវិល និងវិស្វកម្ម ថ្លៃ សម្ភារៈ និងគ្រឿងបរិក្ខារសម្រាប់ការសាងសង់ និងការតម្លើងអនុស្ថានីយ៍ និងបណ្តាញបញ្ជូនអគ្គិសនី សោហ៊ុយលើកម្លាំងពលកម្ម សោហ៊ុយនៃមធ្យោបាយធ្វើដំណើរ សោហ៊ុយនៃការជួលម៉ាស៊ីន និងសោហ៊ុយផ្សេងៗទៀត។ ការចំណាយលើកិច្ចសន្យា គឺធ្វើឡើងផ្អែកទៅតាមភាគរយនៃដំណាក់កាលបញ្ចប់នីមួយៗ។

ថ្លៃដើមផលិតផលរបស់ក្រុមហ៊ុនមានរួមបញ្ចូលតម្លៃសម្ភារៈទិញពីក្រុមហ៊ុន PSB រួមបញ្ចូលទាំងការដឹកជញ្ជូន ធានារ៉ាប់រង និងមធ្យោបាយធ្វើដំណើរ និងតម្លៃផ្សេងៗទៀតដែលពាក់ព័ន្ធ។

តារាងខាងក្រោមបង្ហាញពី ការបែងចែកថ្លៃដើមទៅតាមផ្នែកដូចខាងក្រោម៖

ផ្នែក	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨		ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	
	ពាន់ដុល្លារអាមេរិក	%	ពាន់ដុល្លារអាមេរិក	%
ថ្លៃដើមនៃការសាងសង់	៦២.៩៤៥	១០០,០	៤២.៨៨០	៨៦,២
ថ្លៃដើមនៃការលក់	២២	០,០	៦.៨៩០	១៣,៨
សរុប	**៦២.៩៦៧**	**១០០,០**	**៤៩.៧៧០**	**១០០,០**

ឃ. ចំណេញដុល

តារាងខាងក្រោមបង្ហាញអំពីការវិភាគរបស់ក្រុមហ៊ុនទៅលើចំណេញដុលសម្រាប់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យដូចខាងក្រោម៖

ផ្នែក	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨		ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩	
	ពាន់ដុល្លារអាមេរិក	%	ពាន់ដុល្លារអាមេរិក	%
គម្រោង	១៤.១៨៧	១០០,០	៦,៧៧០	៩៥,៩
ផលិតផល	៣	០,០	២៨៧	៤,១
សរុប	**១៤.១៩០**	**១០០,០**	**៧,០៥៧**	**១០០,០**

ង. គំលាតចំណេញដុល

តារាងខាងក្រោមបង្ហាញអំពីការវិភាគរបស់ក្រុមហ៊ុនទៅលើគំលាតចំណេញដុលសម្រាប់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យដូចខាងក្រោម៖

ផ្នែក	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩
	%	%
គម្រោង	១៨,៤	១៣,៦
ផលិតផល	១២,០	៤,០
សរុប	**១៨,៤**	**១២,៤**

ច. **ចំណាយប្រតិបត្តិការសរុប**

ចំណាយប្រតិបត្តិការសរុបរបស់ក្រុមហ៊ុនជាចម្បងរួមមានសោហ៊ុយដីកជញ្ជូន ចំណាយលើបុគ្គលិករួមមាន ប្រាក់បៀវត្ស ប្រាក់រង្វាន់ និងសុខមាលភាពបុគ្គលិក ផ្តែឈ្នួលការិយាល័យ និងការចំណាយលើការថែទាំ វំណេះទ្រព្យ និងបរិក្ខារ កម្រៃវិជ្ជាជីវៈ និងសោហ៊ុយរដ្ឋបាល ផ្សេងៗទៀត។

ចំណាយប្រតិបត្តិការសរុបសម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ មាន ៤,១លានដុល្លារអាមេរិក និងដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ មាន ២,៨ លានដុល្លារអាមេរិក។

ឆ. ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ៖ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) លេខ ១៥ ចំណូលពីកិច្ចសន្យាជាមួយអតិថិជន

នាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨ ក្រុមហ៊ុនបានអនុលោមទៅតាមការណែនាំថ្មីសម្រាប់ទទួលស្គាល់ប្រាក់ចំណូលពីកិច្ចសន្យាជាមួយអតិថិជន។ ស្តង់ដារថ្មីបានអនុវត្តតាមក្រោយដោយគ្មានការរីតបន្តឹង ដោយមានប្រសិទ្ធិភាពកើនឡើងនៃការអនុវត្តដែលត្រូវបានគេទទួលស្គាល់ថាជាការណែនាំកែតម្រូវ CIFRS លេខ១៥ ត្រូវបានអនុវត្តចំពោះកិច្ចសន្យាដែលមិនត្រូវបានបញ្ចប់ត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៨។

ការអនុវត្ត CIFRS ១៥ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨ ផលប៉ះពាល់ចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានដូចខាងក្រោម៖

	របាយការណ៍កន្លងមក នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ពាន់ដុល្លារអាមេរិក	ប្រសិទ្ធភាពនៃការអនុម័ត CIFRS 15 ពាន់ដុល្លារអាមេរិក	ថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១៨ ពាន់ដុល្លារអាមេរិក
ទ្រព្យសកម្មរយៈពេលវែង			
កិច្ចសន្យា	១៤៦.៥៨៧	(១៣.៨១១)	១៣២.៧៧៦
ប្រាក់ចំណេញរក្សាទុក	២០.៦៣១	(១៣.៨១១)	៦.៨២០

៧. ព័ត៌មានព័ត៌មានហិរញ្ញវត្ថុ (ត)

៧.៤.២. ការពិនិត្យលើលទ្ធផលប្រតិបត្តិការ

ក. ចំណូល

ចំណូល	ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ជាន់ដុល្លារអាមេរិក	ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ជាន់ដុល្លារអាមេរិក	បម្រែបម្រួល %
គម្រោង	៧៧.១៣២	៤៩.៦៥០	(៣៥,៦)
ផលិតផល	២៥	៧.១៧៧	២៨.៦០៨
សរុប	**៧៧.១៥៧**	**៥៦.៨២៧**	**(២៦,៣)**

ចំណូលសរុបបានថយចុះចំនួន២៦,៣% ដែលមានប្រមាណ ៥៦,៨ លានដុល្លារអាមេរិកសម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ពី៧៧,២ លានដុល្លារអាមេរិកសម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ការធ្លាក់ចុះចំណូលចម្បងទៅលើក្រុមហ៊ុនដោយសារការធ្លាក់ចុះនៃចំណូលពីគម្រោង និងការទូទាត់ដោយផ្នែកតាមរយៈការកើនចំណូលបានមកពីផលិតផលរបស់ក្រុមហ៊ុន។

ចំណូលបានមកពីគម្រោងនៅដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ថយចុះប្រហែលចំនួន ២៧.៥ លានដុល្លារអាមេរិក ឬ៣៥,៦% ទៅ៤៩,៦ លានដុល្លារអាមេរិក ប្រៀបធៀបទៅនឹងដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ដែលបានកត់ត្រាចំណូលប្រមាណ៧៧,១ លានដុល្លារអាមេរិក។

ការធ្លាក់ចុះនៃចំណូលពីគម្រោងដោយសារតែ ភាគរយទាបនៃការងារដែលបានបញ្ចប់សម្រាប់ រាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ និងគម្រោងសៀមរាប - ឧត្តរមានជ័យប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនីរាជធានីភ្នំពេញ សម្រាប់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ បើប្រៀបធៀបនឹងការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ បន្ថែមពីនេះទៅទៀត ការធ្លាក់ចុះនៃចំណូលគឺមួយផ្នែកដោយសារតែក្រុមហ៊ុនបានអនុវត្តស្តង់ដាគណនេយ្យថ្មី CIFRS ១៥ ដែលធ្វើអោយចំណូលថយចុះក្នុងការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ថយចុះរហូតដល់ ប្រមាណ៣,៦៧ លានដុល្លារអាមេរិក។

គម្រោងដែលរួមចំណែកចំណូលនៅអំឡុងដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ មាន គម្រោងរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ មានប្រមាណ ២៨,៥ លានដុល្លារអាមេរិក និងគម្រោងស្ថានីយ៍វារីអគ្គិសនីស្ទឹងតាតៃ - ប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនីរាជធានីភ្នំពេញមានប្រមាណ ៤,៣៥ លានដុល្លារអាមេរិក និងគម្រោងឧត្តរមានជ័យប្រមាណ ១៤,៤ លានដុល្លារអាមេរិក។

ព័ត៌មានលម្អិតពាក់ព័ន្ធនឹងគម្រោងរបស់ក្រុមហ៊ុន មានរៀបរាប់នៅផ្នែកទី ៥.១.ខ នៃឯកសារផ្តល់ព័ត៌មាននេះ។

សម្រាប់ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ចំណូលរបស់ក្រុមហ៊ុនបានពីការលក់ផលិតផលទៅឱ្យតតីយជន (ភាគីទី៣) ជាពិសេសទៅដល់អ្នកម៉ៅការបន្ត មានទឹកប្រាក់ចំនួន៧,២ លានដុល្លារអាមេរិក ស្មើនឹងការកើនឡើង៣៥.៩០០% ពីដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ដែលមាន០,០២ លានដុល្លារអាមេរិក។ ជាធម្មតាក្រុមហ៊ុនផ្តត់ផ្គង់ផលិតផលទៅកាន់តតិយជន (ភាគីទី៣) តាមរយៈកិច្ចព្រមព្រៀង ដូចនេះចំណូលរបស់ក្រុមហ៊ុនប្រែប្រួលគ្រប់ពេល។

ខ. ចំណេញដុល និងគំលាតចំណេញដុល

សម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនបានកត់ត្រាចំណេញដុលប្រមាណ៧,១ លានដុល្លារអាមេរិក ថយចុះ ៥០,០% ពី ១៤,២ លានដុល្លារអាមេរិកនៅដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ការថយចុះលើប្រាក់ចំណេញដុលនៅដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ អាស្រ័យជាចម្បងដោយសារចំណូលពីគម្រោងរបស់ក្រុមហ៊ុនមានការថយចុះ ។

សម្រាប់នៅដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ បានថយចុះ១២,៤% ពី ១៨,៤% ក្នុងដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ កម្រិតចំណេញដុលនិងគំលាតចំណេញដុលនៅដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ គឺដោយសារតែប្រាក់ថយចុះ ការអនុវត្ត CIRFRS ១៥ របស់ក្រុមហ៊ុនដែលនាំឱ្យ ចំណេញដុលមានការធ្លាក់ចុះប្រមាណ ៣,៦៧ លានដុល្លារអាមេរិក។

ព័ត៌មានលម្អិតពាក់ព័ន្ធនឹងការប៉ះពាល់នៃការអនុវត្ត CIFTRS ១៥ របស់ក្រុមហ៊ុន មានរៀបរាប់នៅផ្នែកទី៧.៤.១ ឆ នៃឯកសារផ្តល់ព័ត៌មាននេះ។

គ. ចំណាយប្រតិបត្តិការសរុប

ការចំណាយលើប្រតិបត្តិការសរុបរបស់ក្រុមហ៊ុនមានចំនួន ២,៨ លានដុល្លារអាមេរិក តំណាងឱ្យការធ្លាក់ចុះស្មើនឹង ៣១,៧% ពី ៤,១ លានដុល្លារអាមេរិក សម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ការថយចុះនេះនៃការចំណាយក្នុងការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ គឺបណ្តាលមកពីការទទួលស្គាល់ការខាតអត្រាប្តូរប្រាក់ប្រមាណជា ១,៨ លានដុល្លារអាមេរិកដែលបានកត់ទុកក្នុងការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។

ឃ. ប្រាក់ចំណេញមុនគិតពន្ធ

សម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនទទួលបានប្រាក់ចំណេញមុនគិតពន្ធចំនួន ២,៣៤ លានដុល្លារអាមេរិក ដែលការថយចុះចំនួន ៧៦,៥% ធៀបនឹងឆ្នាំមុន។

គំលាតចំណេញមុនគិតពន្ធថយចុះពី១២,៩% ក្នុងការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៨ មក៤,១% ក្នុងការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ការថយចុះនៃចំណេញមុនគិតពន្ធ និងគំលាតចំណេញមុនគិតពន្ធ គឺដោយសារតែចំណូលថយចុះ ចំណេញដុលថយចុះ និងគំលាតចំណេញដុលថយចុះ ក្នុងការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។

ង. ចំណេញក្នុងគ្រា

សម្រាប់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនបានកត់ត្រាប្រាក់ចំណេញក្នុងគ្រាប្រមាណ ១,៨ លានដុល្លារអាមេរិក ថយចុះចំនួន ៧៦,៦% ធៀបនឹងការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ដែលមានចំនួន ៧,៦ លានដុល្លារអាមេរិក។ ការថយចុះនៃចំណេញក្នុងគ្រាសម្រាប់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដោយសារតែចំណូល និងគម្លាតចំណេញដុលទាបជាងមុន។

៧.៤.៣. កត្តាសំខាន់ដែលប៉ះពាល់លើប្រាក់ចំណេញ

ផ្អែកតាមប្រវត្តិនៃការិយបរិច្ឆេទក្រោមការត្រួតពិនិត្យរបស់ក្រុមហ៊ុន ដែលរួមមានការវិភាគតាមផ្នែកទៅលើចំណូល និងប្រាក់ចំណេញ ក្រុមប្រឹក្សាភិបាលបានសង្កេតឃើញកត្តាចម្បងៗ ដែលអាចប៉ះពាល់ដល់ចំណូលរបស់ក្រុមហ៊ុនដូចខាងក្រោម៖

ក. តម្រូវការ និងការផ្គត់ផ្គង់អគ្គិសនី

i. ទស្សនវិស័យល្អលើវិស័យឧស្សាហកម្មសម្រាប់ការរៀបចំប្រព័ន្ធវិស្វកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឧស្សាហកម្មបញ្ជូន និងចែកចាយថាមពលក្នុងប្រទេសកម្ពុជា ដែលក្រុមហ៊ុនកំពុងដំណើរការ ក៏ដូចជានៅក្នុងប្រទេសឡាវ និងមីយ៉ាន់ម៉ា ជាប្រទេសដែលក្រុមហ៊ុនមានបំណងចង់បណ្តាក់ទុន ដូចមានរៀបរាប់នៅផ្នែកទី៤.១.៧ នៃឯកសារផ្តល់ព័ត៌មាននេះ។ គួរកត់សម្គាល់ថាអគ្គិសនីជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍ និងទំនើបភាវូបនីយកម្មក្នុងប្រទេស។ ទស្សនៈនេះអាចឃើញកាន់តែច្បាស់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសមីយ៉ាន់ម៉ា ដែលចាំបាច់ត្រូវការការអភិវឌ្ឍន៍ រីកចម្រើន និងបង្កើតប្រព័ន្ធបញ្ជូន និងចែកចាយថាមពលអគ្គិសនីដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលកើនឡើងសម្រាប់ការប្រើប្រាស់ និងឧស្សាហកម្ម។

ii. គិតត្រឹមដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ កិច្ចសន្យាដែលមានកិច្ច ធានាដែលមិនទាន់បង់របស់ក្រុមហ៊ុនមានចំនួន ៧១,១៤ លានដុល្លារអាមេរិក រួមមាន កិច្ចសន្យាដែលមិនទាន់បង់នៃគម្រោងរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ គម្រោងស្តានីយ៍វារីអគ្គិសនីស្ទឹងតាតៃ - ប្រព័ន្ធបណ្តាញអគ្គិសនីរាជធានីភ្នំពេញ គម្រោងខេត្តសៀមរាប - ឧត្តរមានជ័យ ។

iii. ការបន្ត ខិតខំប្រឹងប្រែងផ្នែកលក់ និងទីផ្សាររបស់ក្រុមហ៊ុន ដើម្បីទទួលបានគម្រោង និងការបញ្ជារទិញថ្មីៗ ស្របគ្នាទៅនឹងគម្រោងនាពេលអនាគតរបស់ក្រុមហ៊ុនក្នុងការ លើកកម្ពស់វត្តមានរបស់ក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជា និងពង្រីកអាជីវកម្មរបស់ ក្រុមហ៊ុនទៅបណ្តាប្រទេសដទៃទៀតក្នុងតំបន់ដូចជាប្រទេសឡាវ និងមីយ៉ាន់ម៉ា ដែល មានតម្រូវការអភិវឌ្ឍន៍ ការធ្វើឱ្យប្រសើរឡើង និងការសាងសង់បណ្តាញបញ្ជូន និង ចែកចាយថាមពលអគ្គិសនី។

iv. ដោយមានភាពជោគជ័យនៅក្នុងការបញ្ចប់គម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា ក្រុមហ៊ុនបានពង្រឹងកិត្តិនាមរបស់ខ្លួនយ៉ាងខ្លាំង ដែលបានជួយទាក់ទាញគម្រោងបន្ថែម ទៀតសម្រាប់ក្រុមហ៊ុននាពេលអនាគត។ ក្រុមហ៊ុននឹងបង្កើនអនុភាពលើការប្រកួត ប្រជែង ដើម្បីទាក់ទាញការងារបន្ថែមនៅក្នុងប្រទេសកម្ពុជា និងនៅបណ្តាទីផ្សារ បរទេសដទៃទៀត។

ខ. ការប្រែប្រួលតម្លៃសម្ភារៈ:

តម្លៃបរិក្ខារ និងបង្គុំប្រព័ន្ធអគ្គិសនី ("គ្រឿងបរិក្ខារ") ដែលជាផ្នែកសំខាន់ក្នុងការ កំណត់ផ្លែដើមនៃការលក់របស់ក្រុមហ៊ុន គឺពឹងផ្អែកទៅលើតម្លៃទីផ្សារដែលកំណត់ ដោយអ្នកផ្គត់ផ្គង់ ដែលតម្លៃទាំងនោះមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន ឡើយ។ ផ្ទុយមកវិញ ក្រុមហ៊ុនជឿជាក់ថា ក្រុមហ៊ុនមានសមត្ថភាពគ្រប់គ្រងតម្លៃ គ្រឿងបរិក្ខារជាមួយនឹងជម្រើសអ្នកផ្គត់ផ្គង់ជាច្រើន ដែលជឿទុកចិត្តបាន ដែល ក្រុមហ៊ុនអាចទទួលបានគ្រឿងបរិក្ខារនៅក្នុងតម្លៃប្រកួតប្រជែង។

ក្រុមហ៊ុន PSB គឺជាអ្នកផ្គត់ផ្គង់គ្រឿងបរិក្ខារដ៏ធំរបស់ក្រុមហ៊ុនយើងសម្រាប់ប្រើ ប្រាស់ក្នុងគម្រោងថាមពលអគ្គិសនីជាច្រើនក្នុងប្រទេសកម្ពុជា។ ដោយមានអ្នក ជំនាញខាងបច្ចេកទេស និងអ្នកជំនាញក្នុងការអនុវត្តគម្រោង ក្រុមហ៊ុន PSB អាច ផ្តោតសំខានទៅលើវិស្វកម្ម និងការអភិវឌ្ឍន៍ និងការពង្រីកមូលដ្ឋានផលិតគ្រឿង បរិក្ខាររបស់ខ្លួន។ ក្រុមហ៊ុន PSB អាចគ្រប់គ្រងលើតម្លៃមួយផ្នែកនៃគ្រឿងបរិក្ខារ តាមរយៈការផលិតផលិតផលគ្រឿងបរិក្ខារផ្ទាល់ខ្លួន ដែលអនុញ្ញាតឱ្យក្រុមហ៊ុនយើង

អាចគ្រប់គ្រងល្អជាងមុន ទៅលើគំលាតចំណេញរបស់គម្រោង ប្រសិនបើក្រុមហ៊ុន យើងបញ្ចាទិញផ្ទាល់ពីក្រុមហ៊ុន PSB។

គ្រឿងបង្គុំថាមពលអគ្គិសនី គ្រឿងបរិក្ខារ និងសម្ភារៈផ្សេងទៀតសម្រាប់ការបញ្ជូនថាមពល និងអនុស្ថានីយ៍ ត្រូវបានបញ្ជាទិញដោយក្រុមហ៊ុន PSB ពីអ្នកផ្គត់ផ្គង់ផ្សេងៗ ពីបណ្តាប្រទេសចិន ប្រទេសថៃ និងអឺរ៉ុប។

បន្ថែមពីនេះទៅទៀត ក្រុមហ៊ុនបានកាត់បន្ថយការប្រែប្រួលនៃតម្លៃគ្រឿងបរិក្ខារដោយធ្វើលទ្ធកម្មក្នុងអំឡុងពេលសមស្របណាមួយជាមុន ដោយផ្អែកលើលក្ខណៈលម្អិតនៃកិច្ចសន្យា និងតម្រូវការនៃគម្រោង។ ហេតុដូច្នោះ វាល់ការកើនឡើងនៃតម្លៃគ្រឿងបរិក្ខារក្នុងពេលបន្តបន្ទាប់ មិនធ្វើឱ្យប៉ះពាល់ដល់តម្លៃដើមសរុបរបស់គម្រោងឡើយ។

គ. ការវិភាគលើពន្ធ

យោងតាមច្បាប់ស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា២០% នៃប្រាក់ចំណេញជាប់ពន្ធ។ ក្រៅពីពន្ធលើប្រាក់ចំណេញក្រុមហ៊ុនក៏ត្រូវជាប់ពន្ធអប្បបរមាផ្សេងទៀតផងដែរ។ ពន្ធអប្បបរមាសំដៅដល់បំណុលពន្ធប្រចាំឆ្នាំស្មើនឹង១% នៃផលរបរ រួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម និងដោយមិនគិតលើប្រាក់ចំណេញ ឬខាតរបស់ក្រុមហ៊ុន។

លិខិតប្រកាសពន្ធរបស់ក្រុមហ៊ុន គឺជាកម្មវត្ថុនៃការត្រួតពិនិត្យពីអាជ្ញាធរពន្ធដារ។ ដោយសារការអនុវត្តច្បាប់ពន្ធដារ និងបទប្បញ្ញត្តិផ្សេងៗ ទៅលើប្រភេទប្រតិបត្តិការផ្សេងគ្នាងាយនឹងមានការបកស្រាយផ្សេងគ្នា ចំនួនទឹកប្រាក់ដែលបានកត់ត្រាចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចមានការផ្លាស់ប្តូរនាពេលអនាគតតាមការកំណត់ចុងក្រោយរបស់អាជ្ញាធរពន្ធ។

ផ្ទុយពីការបរិយាយខាងលើ យោងទៅលើអនុក្រឹតលេខ ០១ អនក្រ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ក្រុមហ៊ុនអាចនឹងទទួលបានការកាត់បន្ថយ ៥០% នៃពន្ធលើប្រាក់ចំណេញក្នុងកំឡុងពេល៣ឆ្នាំក្រោយចុះបញ្ជីក្នុងទីផ្សារមូលបត្រ។

ឃ. កត្តាដោយឡែក និងវិសាមញ្ញ

រហូតមកដល់កាលបរិច្ឆេទអនុវត្តចុងក្រោយ មិនមានកត្តាដោយឡែកនិងវិសាមញ្ញណាមួយកើតមានឡើងដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលបន្ទាប់ពី ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០១៩ ឡើយ។

ង. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

សម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនរក ចំណូលបានប្រមាណជាង ៥៦,៨ លានដុល្លារអាមេរិក ដែលបានថយចុះ ២៩,៣% ពី ៧៧,២ លានដុល្លារអាមេរិក ក្នុងដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៨។ កត្តាដែលចូលរួមធ្វើឱ្យមានការថយចុះប្រាក់ចំណូលត្រូវបានពិភាក្សាក្នុង ផ្នែកទី៧.៤.២ នៃឯកសារផ្តល់ព័ត៌មាននេះ។

ច. ផលប៉ះពាល់នៃការប្តូរប្រាក់ អត្រាការប្រាក់ និងផ្លែចំនិញ (Commodity)

i. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់

ចំណូលពីការលក់និងការទិញរបស់ក្រុមហ៊ុនត្រូវបានកំណត់យកជាប្រាក់ ដុល្លារអាមេរិក។ បន្ថែមពីនេះទៅទៀតក្រុមហ៊ុនមិនទាន់បានធ្វើប្រតិបត្តិ ការការពារហានិភ័យ (hedging) អត្រាប្តូរប្រាក់ឡើយសម្រាប់ដំណាច់ ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យ ដោយសារប្រតិបត្តិការរបស់ក្រុមហ៊ុន ភាគច្រើនធ្វើឡើងជាប្រ ក់ដុល្លារអាមេរិក។

ព័ត៌មានបន្ថែមស្តីពីហានិភ័យនៃការប្តូរប្រាក់ ត្រូវបានកំណត់នៅផ្នែក ទី ៣.២.១ នៃឯកសារផ្តល់ព័ត៌មាននេះ។

ii. ផលប៉ះពាល់នៃអត្រាការប្រាក់

សម្រាប់ដំណាច់ការិយបរិច្ឆេទក្រុមហ៊ុនមិនមានខ្ចី ឬមានជាប់បំណុលដែល មានការប្រាក់ឡើយ ហេតុដូច្នេះ ក្រុមហ៊ុនមិនមានទទួលរងនូវផលប៉ះពាល់ពី អត្រាការប្រាក់ឡើយ។

ក្រុមហ៊ុននឹងទទួលរង់ពីផលប៉ះពាល់នូវការផ្លាស់ប្តូរនៃអត្រាការប្រាក់តាម រយៈអត្រាប្រែប្រួលនៃកម្ចីរបស់ធនាគារ។ ខាងក្រោមគឺជាការបង្ហាញពីអត្រា ការប្រាក់ នៃអត្រាការប្រាក់ចម្បងនានា ដែលក្រុមហ៊ុននឹងត្រូវសង់ត្រលប់ គិត ត្រឹមដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩៖

	ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ពាន់ដុល្លារអាមេរិក
អត្រាផ្លូតនៃឧបករណ៍បំណុលហិរញ្ញវត្ថុ	
ប្រាក់កម្ចី	៩៩,៦
បំណុលហិរញ្ញវត្ថុ	**៩៩,៦**

តារាងខាងក្រោមបង្ហាញពីការប្រែប្រួលទៅលើ (ការខាត)/ចំណេញ ពីការផ្លាស់ប្តូរនៃអត្រាការប្រាក់ចន្លោះ +/- ០,២៥%។ ការប្រែប្រួលដែលអាចទទួលយកបានដោយផ្អែកទៅលើការអង្កេតស្ថានភាពទីផ្សារបច្ចុប្បន្ន។ ការគណនាការប្រែប្រួលដោយផ្អែកទៅលើការប្រែប្រួលជាមធ្យមនៃកំឡុងពេលនីមួយៗ និងការប្រែប្រួលឧបករណ៍ហិរិញ្ញវត្ថុនានានាដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ការប្រែប្រួលដទែទៀតស្ថិតនៅថេរ៖

	(ការខាត)/ចំណេញសម្រាប់ក្រុមហ៊ុន នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ពាន់ដុល្លារអាមេរិក
អត្រាការប្រាក់កើនឡើងត្រឹម០,២៥%	(២៤៨)
អត្រាការប្រាក់ថយចុះត្រឹម០,២៥%	២៤៨

ព័ត៌មានបន្ថែមស្តីពីហានិភ័យអត្រាការប្រាក់ ដូចដែលមានកំណត់នៅផ្នែក ៣.១.១ នៃឯកសារផ្តល់ព័ត៌មាន។

iii. ផលប៉ះពាល់នៃថ្លៃទំនិញ (commodity)

មិនមានផលប៉ះពាល់ធ្ងន់ធ្ងរណាមួយនៃថ្លៃទំនិញទៅលើលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យ។

អ. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ធ្ងន់ធ្ងរណាមួយនៃអតិផរណាទៅលើលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យ។

ជ. គោលនយោបាយរបស់រាជរដ្ឋាភិបាល សេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ

ហានិភ័យពាក់ព័ន្ធនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល សេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ ឬកត្តាដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន មានរៀបរាប់នៅផ្នែកទី៣.៣.២ និងផ្នែកទី៣.៤.៨ នៃឯកសារផ្តល់ព័ត៌មាននេះ។

មិនមានការផ្លាស់ប្តូរគោលនយោបាយរបស់រាជរដ្ឋាភិបាល សេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ ឬកត្តាផ្សេងទៀត ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ។

ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទក្រោមការត្រួតពិនិត្យឡើយ។

ប្រុះរាជាណាចក្រកម្ពុជា
ផេសទិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

៧. ព័ត៌មានព័ត៌មានហិរញ្ញវត្ថុ (ត)

ដូចដែលបានបង្ហាញខាងលើ រួមទាំងកិច្ចពិភាក្សាថ្នាក់គ្រប់គ្រង និងការវិភាគលក្ខខណ្ឌហិរញ្ញវត្ថុ និងលទ្ធផលនៃប្រតិបត្តិការក្រុមហ៊ុន និងផ្នែកទី៣ និងទី៤ នៃឯកសារផ្តល់ព័ត៌មាននេះ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនជឿជាក់ថា លើកលែងតែកាល:ទេស:ដែលមិនអាចស្មានទុនជាមុនបាន ; មិនមាននិន្នាការណាផ្សេង ស្ថានភាពមិនច្បាស់លាស់ ការទាមទារ ការប្តេជ្ញាចិត្ត ឬព្រឹត្តិការណ៍ណាមួយ ដែលអាចផ្តល់ផលប៉ះពាល់ជាវិជ្ជមាន ឬអវិជ្ជមានធ្ងន់ធ្ងរទៅលើលទ្ធផលហិរញ្ញវត្ថុ ស្ថានភាព និងប្រតិបត្តិការរបស់ក្រុមហ៊ុន ឬដែលអាចធ្វើឱ្យព័ត៌មានហិរញ្ញវត្ថុដែលបានបង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មាននេះ មិនអាចចង្អុលបង្ហាញអំពីលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយនាពេលអនាគត។

៧.៥. សន្ទនីយភាព និងប្រភពទុន

៧.៥.១. ទុនបង្វិល

ទុនបង្វិលរបស់ក្រុមហ៊ុន ត្រូវបានផ្តល់តាមរយៈសាច់ប្រាក់ដែលបានមកពីសកម្មភាពនានានៃប្រតិបត្តិការរបស់ក្រុមហ៊ុន ឥណទេយ្យបន្ថែមពីអ្នកផ្គត់ផ្គង់របស់ក្រុមហ៊ុន ការគាំទ្រផ្នែកហិរញ្ញវត្ថុដែលបានមកពីក្រុមហ៊ុន PIB ក៏ដូចជាសាច់ប្រាក់ និងសាច់ប្រាក់សមមូលដែលមានស្រាប់។

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនមានទ្រព្យសកម្មរយៈពេលខ្លីប្រមាណ ៣១,៨ លានដុល្លារអាមេរិក និងបំណុលរយៈពេលខ្លីប្រមាណ ៩៦,០ លានដុល្លារអាមេរិក ដែលស្មើនឹងទុនបង្វិលអវិជ្ជមានប្រមាណ ៦៤,២ លានដុល្លារអាមេរិក និងមានអនុបាតបច្ចុប្បន្នប្រមាណ ០,៣៣ ដង។

ក្រុមហ៊ុនពឹងផ្អែកទៅលើការគាំទ្រផ្នែកហិរញ្ញវត្ថុពីក្រុមហ៊ុន PIB និងក្រុមហ៊ុនផ្សេងទៀតដែលពាក់ព័ន្ធ ក្នុងការផ្តល់ទុនបង្វិលក្នុងទម្រង់ជាបុរេប្រទាន។ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ទឹកប្រាក់សរុបដែលជំពាក់ក្រុមហ៊ុន PIB មានចំនួន ៥៩,៦ លានដុល្លារអាមេរិក និងជំពាក់ក្រុមហ៊ុនពាក់ព័ន្ធចំនួន ២៣ លានដុល្លារអាមេរិក ដែលកើតចេញចម្បងពីការជាវសម្ភារៈ និងគ្រឿងបរិក្ខារក្នុងដំណើរការគម្រោង។ ស្ថានភាពទុនបង្វិលរបស់ក្រុមហ៊ុននឹងរីកចម្រើននៅពេលដែលក្រុមហ៊ុនចាប់ផ្តើមទទួលការទូទាត់សាច់ប្រាក់ ពីគម្រោងរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ និងគម្រោងស្តានីយ៍វារីអគ្គិសនីស្ទឹងតាតៃ - ប្រព័ន្ធបណ្តាញអគ្គិសនីរាជធានីភ្នំពេញ និងគម្រោងខេត្តសៀមរាប - ខេត្តឧត្តរមានជ័យ បន្ទាប់ពីបានបញ្ចប់គម្រោងខាងលើនេះ។

ទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុន PIB និងភាគីផ្សេងទៀតដែលពាក់ព័ន្ធ មិនមានការដាក់ទ្រព្យដើម្បីធានាគ្មានការប្រាក់ និងអាចសងបានតាមតម្រូវការ។ ក្រុមហ៊ុន PIB ប្តេជ្ញាក្នុងការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ក្រុមហ៊ុនយ៉ាងតិចបំផុតដប់ពីរ (១២) ខែ រាប់ចាប់ពីកាលបរិច្ឆេទនៃឯកសារផ្តល់ព័ត៌មាននេះ និងអាចពន្យារពេលទៅតាមការតម្រូវ។ ទោះជាយ៉ាងណា ក្រុមហ៊ុន PIB នឹងចាប់ផ្តើម

កំណត់ការប្រាក់ចំនួន ៤,៥0% ក្នុងមួយឆ្នាំដល់ក្រុមហ៊ុនយើងទៅលើទឹកប្រាក់ ដែលជំពាក់ក្រុមហ៊ុន PIB បន្ទាប់ពីធ្វើការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

៧.៥.២ ចលនាសាច់ប្រាក់

ខាងក្រោមនេះជាតារាងសង្ខេបនៃចលនាសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣0 ខែមិថុនា ឆ្នាំ២0១៩៖

	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣0 ខែមិថុនា ឆ្នាំ២0១៩ ពាន់ដុល្លារអាមេរិក
សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ	(៦៣.១២៥)
សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ	(៧១១)
សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពហិរញ្ញប្បទាន	៧២.៩៣៦
បម្រែបម្រួលសុទ្ធ និងសាច់ប្រាក់សមមូល	**៩.១00**
សាច់ប្រាក់ និងសាច់ប្រាក់សមមូល ដើមឆ្នាំ	៥៦៣
សាច់ប្រាក់ និងសាច់ប្រាក់សមមូល ចុងឆ្នាំ	**៩.៦៦៣**

ក. ចលនាសាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ

អំឡុងដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣0 ខែមិថុនា ឆ្នាំ២0១៩ ក្រុមហ៊ុនបានកត់ត្រាទុកប្រាក់ចំណេញប្រតិបត្តិការមុនពេលទុនបង្វិលមានការផ្លាស់ប្តូរប្រមាណជា ៤,៧ លានដុល្លារអាមេរិក។ បន្ទាប់ពីគិតបញ្ចូលបម្រែបម្រួលទុនបង្វិល និងការចំណាយពន្ធលើប្រាក់ចំណូល សាច់ប្រាក់សុទ្ធរបស់ក្រុមហ៊ុនដែលត្រូវបានប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការមានប្រមាណ ៦៣,១ លានដុល្លារអាមេរិក។ ការកើនឡើងទុនបង្វិលសម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣0 ខែមិថុនា ឆ្នាំ ២0១៩ បណ្តាលមកពីកត្តាធំៗដូចខាងក្រោម៖

i. ការកើនឡើងនៃទឹកប្រាក់ដែលអតិថិជនជំពាក់ តាមរយៈកិច្ចសន្យាដែលមានចំនួន៤៦,៣ លានដុល្លារអាមេរិក ជាចម្បងទៅលើគម្រោងភ្នំពេញភាគខាងលិច - ព្រះសីហនុ គម្រោងវារីអគ្គីសនីស្ទឹងតាតៃ និងគម្រោងបណ្តាញរាជធានីភ្នំពេញ

ii. ការកើនឡើងបំណុលអតិថិជន និងគណនីផ្សេងៗចំនួន ១0,0 លានដុល្លារអាមេរិក

iii. ការកើនឡើងទឹកប្រាក់ជំពាក់ទៅភាគីពាក់ព័ន្ធចំនួន ២៧,១ លានដុល្លារអាមេរិក ជាចម្បងមកពីការផ្តែជាវសម្ភារៈ និងគ្រឿងបរិក្ខារដើម្បីប្រើប្រាស់ក្នុងគម្រោងរបស់ក្រុមហ៊ុន

iv. ការកើនឡើងទឹកប្រាក់ជំពាក់ទៅក្រុមហ៊ុនហូលឌីងចំនួន ៥៩,០ លានដុល្លារអាមេរិក

v. និងការថយចុះបំណុលពាណិជ្ជកម្ម និងគណនីផ្សេងៗចំនួន ៤០,២ លានដុល្លារអាមេរិក។

ខ. ចលនាសាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ

សម្រាប់ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ចលនាសាច់ប្រាក់របស់ក្រុមហ៊ុនប្រើប្រាស់ក្នុងសកម្មភាពវិនិយោគកើនឡើងដល់ ០,៧ លានដុល្លារអាមេរិក ដែលកើតឡើងចម្បងពីការជាវគ្រឿងបរិក្ខារអោងចក្រ យានយន្ត គ្រឿងសង្ហារឹម សម្ភារៈតែងលម្អ និងកុំព្យូទ័រ។

គ. ចលនាសាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពហិរញ្ញប្បទាន

អំឡុងដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ចលនាសាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទានមានចំនួន៧២,៩ លានដុល្លារអាមេរិក ដែលបានមកពីប្រាក់កម្ចីនៅក្នុងឆ្នាំ ។

៧.៥.៣. ប្រាក់កម្ចី

តារាងខាងក្រោមដែលបង្ហាញពីប្រាក់កម្ចីរបស់ក្រុមហ៊ុនគិតត្រឹមដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩៖

	ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩
ប្រាក់កម្ចី	**ពាន់ដុល្លារអាមេរិក**
ទ្រព្យសកម្មរយៈពេលខ្លី	
ឥណទានវិបារូបណ៍	២.៦៨១
ឥណទានបង្វិល	១.៤៩៩
ទ្រព្យសកម្មរយៈពេលវែង	
Murabahah facility	៤៥.៤០៧
Syndicated financing facilities	៥០.០០០
សរុប	**៩៩.៥៨៧**

៧.៥.៤. ការល្មើសនឹងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងការចាត់ចែងឥណទានកម្ចី ធនាគារ

អំឡុងការិយបរិច្ឆេទក្រោមការត្រួតពិនិត្យ ក្រុមហ៊ុនមិនបានល្មើសនឹងលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ឬការព្រមព្រៀងណាមួយពាក់ព័ន្ធនឹងការចាត់ចែងឥណទាន ឬឥណទានធនាគារ ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុ ឬប្រតិបត្តិការធុរកិច្ច ឬការវិនិយោគពីសំណាក់ភាគហ៊ុនិករបស់ក្រុមហ៊ុនឡើយ។

៧.៥.៥. ប្រភេទឧបករណ៍ហិរញ្ញវត្ថុដែលបានប្រើប្រាស់

តារាងខាងក្រោមបង្ហាញពីទ្រព្យសកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលត្រូវបានចែកជាកម្ចី និងបំណុលគណនីអតិថិជន និងបំណុលហិរញ្ញវត្ថុ ដែលត្រូវចែកជាបំណុលដទៃទៀតគិតទៅតាមតម្លៃរំលស់៖

ទ្រព្យសកម្មហិរញ្ញវត្ថុ - កម្ចី និងគណនីអតិថិជន	ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ពាន់ដុល្លារអាមេរិក	ដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ពាន់ដុល្លារអាមេរិក
គណនីអតិថិជន និងគណនីទទួលផ្សេងៗ	៤៨	៧.៩១២
ទ្រព្យសកម្មកិច្ចសន្យា	១៤៦.៥៨៧	១៧៩.១០១
សាច់ប្រាក់ និងសមតុល្យធនាគារ	២.០៨៤	១៣.០៥៦
ទឹកប្រាក់ភាគីសម្ព័ន្ធញ្ញាតិជំពាក់	-	១.៩៤៤
សរុប	**១៤៨.៧១៩**	**២០២.០១៣**
បំណុលហិរញ្ញវត្ថុ - បំណុលដទៃទៀត		
គណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងៗ	៤៨.០០៥	៨.៣១៧
ទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុនមេ	៥៦៥	៥៩.៥៥៨
ទឹកប្រាក់ជំពាក់ភាគីសម្ព័ន្ធញ្ញាតិ	៤៩.៦៧៩	២៣.០១៨
ប្រាក់កម្ចី	២២.០១៣	៩៩.៥៨៧
ឧបករណ៍និស្សន្ទ	-	១.៨២៤
សរុប	**១២០.២៦២**	**១៩២.៣០៤**

៧.៥.៦ គោលនយោបាយ និងគោលបំណងក្នុងការគ្រប់គ្រងសាច់ប្រាក់

ក្រុមហ៊ុនទទួលផលប៉ះពាល់ពីហានិភ័យហិរញ្ញវត្ថុ ដែលកើតចេញពីប្រតិបត្តិការ និងការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ។ ក្រុមហ៊ុនបានបង្កើតគោលនយោបាយគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ដើម្បីធានាថាមានធនធានគ្រប់គ្រាន់ដើម្បីធ្វើការអភិវឌ្ឍធុរកិច្ចរបស់ក្រុមហ៊ុន ជាមួយនឹងការគ្រប់គ្រងហានិភ័យឥណទាន ហានិភ័យសន្ទនីយភាព ហានិភ័យរូបិយប័ណ្ណបរទេស និងហានិភ័យអត្រាការប្រាក់។ គោលនយោបាយរបស់ក្រុមហ៊ុន និងកត្តាហានិភ័យហិរញ្ញវត្ថុសំខាន់ៗដែលក្រុមហ៊ុនប្រឈមមានដូចខាងក្រោម៖

ក. ហានិភ័យឥណទាន

ហានិភ័យឥណទានសំដៅដល់ហានិភ័យហិរញ្ញវត្ថុ ប្រសិនបើអតិថិជនខកខានក្នុងការបំពេញកាតព្វកិច្ចតាមកិច្ចសន្យារបស់ខ្លួន។

ដើម្បីកាត់បន្ថយការប្រឈមទៅនឹងហានិភ័យឥណទាន ក្រុមហ៊ុនបានពិនិត្យមើលប្រវត្តិរបស់ភាគីម្ខាងទៀតមុនពេលចុះកិច្ចសន្យា ឬប្រតិបត្តិការជាមួយអតិថិជនរបស់ខ្លួន។

ក្រុមហ៊ុនមានគោលការណ៍ឥណទានផ្ទាល់ខ្លួន ដោយប្រើប្រាស់ការវិភាគប្រកបដោយបទពិសោធន៍របស់ខ្លួន ដើម្បីត្រួតពិនិត្យមើលគុណភាពឥណទាននៃបំណុលអតិថិជនរបស់ក្រុមហ៊ុន។

ការសិក្សាបន្ថែមលើហានិភ័យឥណទានមាននៅក្នុងផ្នែកទី៣.៦.២ នៃឯកសារព័ត៌មាននេះ។

ខ. ហានិភ័យសន្ទនីយភាព

ហានិភ័យសន្ទនីយភាព សំដៅលើហានិភ័យដែលក្រុមហ៊ុននឹងជួបប្រទះក្នុងការកៀរគរមូលនិធិដើម្បីឆ្លើយតបទៅនឹងកាតព្វកិច្ចក្នុងការបង់ប្រាក់ក្នុងរយៈពេលខ្លី។ ការប្រឈមរបស់ក្រុមហ៊ុនទៅនឹងហានិភ័យសន្ទនីយភាពកើតមានចម្បងចេញពីបំណុលពាណិជ្ជកម្ម និងគណនីផ្សេងៗ ព្រមទាំងទឹកប្រាក់ដែលជំពាក់ភាគីពាក់ព័ន្ធ។

ដើម្បីកាត់បន្ថយការប្រឈមទៅនឹងហានិភ័យសន្ទនីយភាព ក្រុមហ៊ុនមានគោលការណ៍ផ្ទាល់ខ្លួន ដើម្បីត្រួតពិនិត្យជាប្រចាំនូវតម្រូវការសន្ទនីយភាពរយៈពេលខ្លី និងនាពេលអនាគត ដើម្បីធានាថាក្រុមហ៊ុនបានរក្សាទុកនូវទុនបម្រុងគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការសន្ទនីយភាពនៅក្នុងរយៈពេលខ្លី និងរយៈពេលវែង។

ការសិក្សាបន្ថែមលើហានិភ័យសន្ទនីយភាពមាននៅក្នុងផ្នែកទី៣.៦.១ នៃឯកសារព័ត៌មាននេះ។

គ. ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់សំដៅដល់ហានិភ័យ ចលនាឡើងចុះលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនដែលជាលទ្ធផលនៃបម្រែបម្រួលអត្រាការប្រាក់នៅលើទីផ្សារ។

ការសិក្សាបន្ថែមលើហានិភ័យអត្រាការប្រាក់មាននៅក្នុង ផ្នែកទី ៣.១.១ នៃឯកសារផ្តល់ព័ត៌មាននេះ។

ឃ. ហានិភ័យរូបិយបណ្ណបរទេស

ហានិភ័យរូបិយបណ្ណបរទេស កើតចេញពីប្រតិបត្តិការដែលធ្វើឡើងដោយប្រើប្រាស់រូបិយបណ្ណបរទេស។

ការប្រឈមរបស់ក្រុមហ៊ុនទៅនឹងហានិភ័យរូបិយបណ្ណបរទេសមានកម្រិតទាបនៅឡើយ ដោយសារក្រុមហ៊ុនធ្វើប្រតិបត្តិការពាណិជ្ជកម្មជាប្រាក់ដុល្លារអាមេរិក។

ការសិក្សាបន្ថែមលើហានិភ័យរូបិយបណ្ណបរទេសមាននៅក្នុងផ្នែកទី ៣.២.១ នៃឯកសារព័ត៌មាននេះ។

៧.៥.៧. ភាគឭកច្ចសំខាន់ៗ

ក្រុមហ៊ុនប្តេជ្ញាចិត្តក្នុងការទិញធានារ៉ាប់រងហានិភ័យនយោបាយសម្រាប់រយៈដប់ (១០) ឆ្នាំ សម្រាប់ការសាងសង់គម្រោងវារីអគ្គិសនីស្ទឹងតាតៃ - ភ្នំពេញ ក្នុងចំនួនទឹកប្រាក់ប្រមាណ ៤,៩៧ ដុល្លារអាមេរិក ដើម្បីធានាប្រាក់កម្ចី ដូចដែលបានបង្ហាញក្នុងផ្នែកទី ៧.៥.៣ និងផ្នែកទី ៩ (កំណត់សម្គាល់ទី ១៤) នៃឯកសារព័ត៌មាននេះ។

៧.៥.៨. ទំនាស និងបំណុលជាយថាហេតុសំខាន់ៗ

ក. វិវាទសំខាន់ៗ

គិតត្រឹមកាលបរិច្ឆេទអនុវត្តន៍ចុងក្រោយ ក្រុមហ៊ុនពុំមានពាក់ព័ន្ធក្នុងវិវាទ និង/ឬ មជ្ឈិតការសំខាន់ណាមួយឡើយ ទោះជាក្នុងនាមជាដើមបណ្តឹង ឬចុងចម្លើយ ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរណាមួយលើស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន ហើយក៏មិនមានព័ត៌មានណាមួយ ដែលក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនបានដឹងពាក់ព័ន្ធនឹងនីតិវិធីណាមួយដែលកំពុងប្រព្រឹត្តទៅ ឬនឹងកើតមាន ឬមានអង្គហេតុណាមួយដែលអាចបណ្តាលឱ្យមានដំណើរការនីតិវិធីតុលាការដែលមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុ ឬធុរកិច្ចរបស់ក្រុមហ៊ុនឡើយ។

ខ. បំណុលជាយថាហេតុ

ក្នុងឆ្នាំ២០១១ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងមួយស្តីពីការកំណត់ពន្ធឡើងវិញបន្ទាប់ពីការធ្វើសនវកម្មពន្ធដារមានកម្រិតលើក្រុមហ៊ុនមានចំនួន ៥៤៦.៩៧១ ដុល្លារអាមេរិក (២.២២២ លានរៀល) ដើម្បីទាមទារឱ្យមានការបង់ពន្ធលើប្រាក់រំដោះពន្ធលើប្រាក់ចំណេញ និងអាករលើតម្លៃបន្ថែមដែលចោទថាមិនបានប្រកាសនៅចន្លោះថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១១។

នៅឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងមួយស្តីពីការកំណត់ពន្ធឡើងវិញ ដើម្បីទាមទារឱ្យមានការបង់ពន្ធលើប្រាក់រំដោះពន្ធលើប្រាក់ចំណេញ និងអាករលើតម្លៃបន្ថែមមានចំនួន៤៩០.៩១២ ដុល្លារអាមេរិក (១.៩៩៥លានរៀល) ដែលចោទថាមិនបានប្រកាសនៅចន្លោះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ ទៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣។

នៅឆ្នាំ២០១៧ អគ្គនាយដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងមួយស្តីពីការកំណត់ពន្ធឡើងវិញ ដើម្បីទាមទារឱ្យមានការបង់ពន្ធលើប្រាក់រំដោះពន្ធលើប្រាក់ចំណេញ អាករលើតម្លៃបន្ថែម និងពន្ធកាត់ទុកលើសេវា១៤% មានចំនួន២៦៧.៩៥៦ដុល្លារអាមេរិក (១.០៨៩លានរៀល) ដែលចោទថាមិនបានប្រកាសសម្រាប់ការធ្វើសវនកម្មពន្ធដារចម្រុះឆ្នាំ២០១០។

អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មពន្ធដារពេញលេញលើក្រុមហ៊ុនសម្រាប់ឆ្នាំសារពើពន្ធចាប់ពីឆ្នាំ២០១១ ដល់ ឆ្នាំ២០១៦។ គិតមកត្រឹមការិយបរិច្ឆេទអនុវត្តចុងក្រោយ ការកំណត់ពន្ធឡើងវិញចុងក្រោយសម្រាប់រយៈពេលនោះមិនទាន់បានបង្ហាញនៅឡើយ។

ជាការឆ្លើយតប ក្រុមហ៊ុនបានដាក់លិខិតជំទាស់ទៅកាន់អគ្គនាយកដ្ឋានពន្ធដារចំពោះការកំណត់ពន្ធឡើងវិញដែលមិនសមហេតុផលនោះ។ ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនចាត់ទុកលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញខាងលើនេះមិនមានមូលដ្ឋាន និងគ្មានសម្ពាង ដែលត្រូវឱ្យក្រុមហ៊ុនធ្វើការទូទាត់ពន្ធ។ គិតត្រឹមថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ ការតវ៉ានៅកំពុងបន្ត។

ទោះបីជាមានដូចរៀបរាប់ខាងលើក៏ដោយ យោងទៅលើអនុក្រឹតលេខ០១ អនក្រ. បក ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលទទួលបានការអនុញ្ញាតពី គ.ម.ក និងបានចុះបញ្ជីជួញដូរមូលបត្រនៅផ.ម.ក នឹងទទួលបានការលើកទឹកចិត្ត រួមមានការអនុគ្រោះបំណុលពន្ធពីអតីតកាល ការកាត់បន្ថយពន្ធលើប្រាក់ចំណូល ពន្ធកាត់ទុកអាករលើតំលៃបន្ថែម អាករពិសេសលើទំនិញ និងសេវាកម្មមួយចំនួន អាករស្នាក់នៅ និងអាករបំភ្លឺផ្លូវ ចាប់ពីកាលបរិច្ឆេទ N-៣ (ឆ្នាំ N ជាឆ្នាំដែលក្រុមហ៊ុនធ្វើការបោះផ្សាយលក់មូលបត្រជាលើកដំបូង)។

លើកលែងដូចមានរៀបរាប់ខាងលើ និងគិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមិនមានដំណឹងអំពីបំណុលជាយថាហេតុដែលបន្ទាប់ពីអនុវត្ត អាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុ និងអាជីវកម្មរបស់ក្រុមហ៊ុនឡើយ។

៧. ព័ត៌មានព័ត៌មានហិរញ្ញវត្ថុ (ត)

៧.៥.៩. អនុបាតហិរញ្ញវត្ថុសំខាន់ៗ

អនុបាតហិរញ្ញវត្ថុសំខាន់ៗរបស់ក្រុមហ៊ុនមានដូចតទៅ៖

បរិយាយ		ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ពាន់ដុល្លារអាមេរិក	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ពាន់ដុល្លារអាមេរិក
១	**អនុបាតសាធនភាព(១)/(២)**	**១៨,៣%**	**៦,៧%**
	(១) មូលនិធិផ្តាល់សុទ្ធ	២៧.៧៨៣	១៣.៩២៣
	(២) ទ្រព្យសកម្មសរុប (តម្លៃសុទ្ធក្រោយពេលដកចេញនូវសំវិធានធននិងការរំលស់)	១៥១.៤៣០	២០៧.១៥៥
២	**អនុបាតសន្ទនីយភាព**		
២.១	**អនុបាតចរន្ត(១)/(២)**	**២,៨%**	**៣៣,២%**
	(១) ទ្រព្យសកម្មរយៈពេលខ្លី	២.៩៣០	៣១.៨៤៦
	(២) បំណុលរយៈពេលខ្លី	១០៣.៧០២	៩៦.០០១
២.២	**អនុបាតចរន្តឈ្មឹន(១)/(២)**	**២,៨%**	**៣៣,២%**
	(១) ទ្រព្យសកម្មរយៈពេលខ្លី - សន្និធិ	២.៩៣០	៣១.៨៤៦
	(២) បំណុលរយៈពេលខ្លី	១០៣.៧០២	៩៦.០០១
៣	**អនុបាតចំណេញ**		
៣.១	**ចំណេញក្នុងឆ្នាំក្នុងមួយឯកតាទ្រព្យសកម្ម(១)/(២)**	**៥,០%**	**០,៩%**
	(១) ចំណេញក្នុងឆ្នាំ	៧.៥៨១	១.៧៧៥
	(២) ទ្រព្យសកម្មសរុប	១៥១.៤៣០	២០៧.១៥៥
៣.២	**ចំណេញក្នុងឆ្នាំក្នុងមួយឯកតាមូលធន(១)/(២)**	**២៧,៣%**	**១២,៧%**
	(១) ចំណេញក្នុងឆ្នាំ-ភាគលាភបែងចែកឱ្យភាគហ៊ុនបុរិមា	៧.៥៨១	១.៧៧៥
	(២) មូលធន	២៧.៧៨៣	១៣.៩២៣
៣.៣	**គំលាតចំណេញដុល (១)/(២)**	**១៨,៤%**	**១២,៤%**
	(១) ចំណេញដុល	១៤.១៩០	៧.០៥៧
	(២) ចំណូល	៧៧.១៥៧	៥៦.៨២៧
៣.៤	**គំលាតចំណេញសុទ្ធ (១)/(២)**	**៩,៨%**	**៣,១%**
	(១) ចំណេញក្នុងឆ្នាំ	៧.៥៨១	១.៧៧៥
	(២) ចំណូល	៧៧.១៥៧	៥៦.៨២៧
៣.៥	**ចំណេញសុទ្ធក្នុងឆ្នាំក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (១)/(២) (គិតជាសេនដុល្លារអាមេរិក)**	**១០,១**	**២,៤**

៧. ព័ត៌មានព័ត៌មានហិរញ្ញវត្ថុ (ត)

	បរិយាយ	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ ពាន់ដុល្លារអាមេរិក	ដំណាច់ការិយបរិច្ឆេទនៅ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ពាន់ដុល្លារអាមេរិក
	(១) ចំណេញក្នុងឆ្នាំ និងការប្រាក់ - ភាគលាភបែងចែកឱ្យភាគហ៊ុនបុរិមា	៧.៥៨១	១.៧៧៥
	(២) ចំនួនមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងចរាចរលើទីផ្សារ[១](លាន)	៧៤,៩	៧៤,៩
៤	**អនុបាតសកម្មភាព**		
៤.១	**អនុបាតជុំបង្វិលទ្រព្យសម្បត្តិ(១)/(២)**	**៥១,០%**	**២៧,៤%**
	(១) ចំណូល	៧៧.១៥៧	៥៦.៨២៧
	(២) ទ្រព្យសកម្មសរុប	១៥១.៤៣០	២០៧.១៥៥
៤.២	**អនុបាតជុំបង្វិលឥណទេយ្យពាណិជ្ជកម្ម (១)/(២)**	**២.១**	**០,៩**
	(១) ឥណទានបានពីការលក់[២]	២៥	៧.១៧៧
	(២) គណនីផ្សេងទៀត[៣]	១២	៧.៨៨៣
៤.៣	**អនុបាតជុំបង្វិលបំណុលពាណិជ្ជកម្ម[៣] (១)/(២)**	**០,០៣**	**៤,៧**
	(១) ការទិញ[៤]	២១,៦	៦.៨៩០
	(២) បំណុលពាណិជ្ជកម្ម	៨១៤,៧	១.៤៦៣
៤.៤	**អនុបាតជុំបង្វិលសន្និធិ (១)/(២)**	**គ្មាន**	**គ្មាន**
	(១) ការលក់	៧៧.១៥៧	៥៦.៨២៧
	(២) សន្និធិ	-	-
៥	**អនុបាតវិភាគរចនាសម្ព័ន្ធទុន**		
៥.១	**អនុបាតលទ្ធភាពបង់ការប្រាក់ (១)/(២)**	**៥៩,៩៦**	**១,៦៧**
	(១) ចំណេញមុនគិតការប្រាក់ និងពន្ធ	១០.១៣៤	៥.៧៩៨
	(២) ចំណាយហិរញ្ញប្បទាន	១៦៩	៣.៤៦៧
៥.២	**អនុបាតបំណុលធៀបនឹងមូលធន (១)/(២)**	**០,៧៩**	**៧,១៥**
	(១) បំណុលសរុប[៥]	២២.០១៣	៩៩.៥៨៧
	(២) មូលធន	២៧.៧៨៣	១៣.៩២៣

ចំណាំ៖

(១) ផ្អែកលើដើមទុនដែលបង្កើត និងបានបង់រួចចំនួន៧៤.៩៤៥.០០០ ហ៊ុនដែលក្នុងមួយហ៊ុនមានតម្លៃចារឹក ០,១០ ដុល្លារអាមេរិក។

(២) មិនរាប់បញ្ចូលចំណូលពីគម្រោងរបស់ក្រុមហ៊ុននោះទេ។

(៣) បំណុលទាក់ទងនឹងការលក់ផលិតផលរបស់ក្រុមហ៊ុន។

(៤) ការជាវទាក់ទងនឹងការលក់ផលិតផលតែប៉ុណ្ណោះ។

(៥) បំណុលដែលមានការប្រាក់ប៉ុណ្ណោះ។

៧.៥.១០. គណនីអតថិជន និងគណនីត្រូវទទួលផ្សេងៗ

គិតត្រឹមការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗរបស់ក្រុមហ៊ុនមានចំនួន១០,៨០ លានដុល្លារអាមេរិក ស្មើនឹងកំនើន ១.១៧៧% គឺ០.៨៥ លានដុល្លារអាមេរិកនៅដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ កំណើនបំណុលអតិថិជន និងគណនីផ្សេងទៀត ជាចម្បងមកពីការកើនឡើងនូវការបង់មុនទៅកាន់អ្នកផ្គត់ផ្គង់ពីចំនួន០,០១ លានដុល្លារអាមេរិក គិតត្រឹមដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ មកត្រឹម៧,៨៨ លានដុល្លារអាមេរិក គិតត្រឹមដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។

រយៈពេលកំណត់សងធម្មតាដែលក្រុមហ៊ុនផ្តល់ឱ្យអតិថិជនគឺនៅចន្លោះពី ៣០ថ្ងៃ ទៅ ៩០ថ្ងៃ។ រយៈពេលផ្សេងទៀត ត្រូវបានកំណត់ និងឯកភាពទៅតាមករណីនីមួយៗ បន្ទាប់ពីធ្វើការពិចារណាទៅលើសាវតារ និងប្រវត្តិកម្ចីរបស់អតិថិជន និងការការប្រមូលបំណុលពីមុន និងទំនាក់ទំនងក្រុមហ៊ុនជាមួយអតិថិជន។

៧.៥.១១. សន្និធិ

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ក្រុមហ៊ុនមិនមានសន្និធិទេ។

សម្ភារៈ និងគ្រឿងបរិក្ខារដែលទិញសម្រាប់ប្រើប្រាស់ក្នុងគម្រោងរបស់ក្រុមហ៊ុនគឺសន្មត់ជាការចំណាយរបស់គម្រោងភ្លាមៗ បន្ទាប់ពីបានបញ្ចូលទៅកាន់ឃ្លាំងរក្សាទុក ឬការដ្ឋានគម្រោង។ វិធីសាស្ត្រនៃការសន្មត់ពីការរៀបចំការចំណាយរបស់គម្រោងនេះ គឺធ្វើឡើងស្របតាមការអនុវត្តក្នុងឧស្សាហកម្ម។

បន្ថែមពីលើនេះ ផលិតផលរបស់ក្រុមហ៊ុនត្រូវបាននាំចូល និងចែកចាយទៅកាន់អតិថិជនដោយផ្ទាល់ទៅតាមតម្រូវការកំណត់ទុកជាមុន និងការបញ្ជាទិញ។ ដូចនេះក្រុមហ៊ុនមិនមានសន្និធិណាមួយសម្រាប់ធ្វើការចែកចាយផលិតផលរបស់ក្រុមហ៊ុនឡើយ។

ក្រុមហ៊ុនជឿជាក់ថាការចំណាយ និងហានិភ័យលើសន្និធិអាចត្រូវបានកាត់បន្ថយតាមរយៈការដាក់ចេញនូវការអនុវត្តនេះ។

៧.៥.១២. ទ្រព្យសកម្មរយៈពេលវែង

ក. ទ្រព្យសម្បត្តិ រោងចក្រ និងគ្រឿងបរិក្ខារ (“PPE”)

ទ្រព្យសម្បត្តិ រោងចក្រ និងគ្រឿងបរិក្ខាររបស់ក្រុមហ៊ុនរួមមានគ្រឿងបរិក្ខារោងចក្រ យានយន្ត កុំព្យូទ័រ គ្រឿងសង្ហារឹម និងគ្រឿងលម្អផ្សេងៗ។ នៅដំណាច់ការិយបរិច្ឆេទ

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ មានតម្លៃសុទ្ធប្រមាណ ១,៩១ លានដុល្លារអាមេរិក រហ៊ីយ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ មានទ្រព្យសម្បត្តិ និងគ្រឿងបរិក្ខាររបស់ក្រុមហ៊ុន ចំនួនប្រមាណ២,២៥ លានដុល្លារអាមេរិក។ ការកើនឡើងនៃទ្រព្យសម្បត្តិ រោងចក្រនិងគ្រឿងបរិក្ខាររបស់ក្រុមហ៊ុនគិតត្រឹមដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ គឺភាគច្រើនបណ្តាលមកពីការជាវគ្រឿងបរិក្ខារអោងចក្រ យានយន្ត និងកុំព្យូទ័រ។

ខ. ទ្រព្យសកម្មកិច្ចសន្យា

ទ្រព្យសកម្មកិច្ចសន្យារួមមាន ថ្លៃដើមដែលកើតពីកិច្ចសន្យារហូតបច្ចុប្បន្នជាមួយប្រាក់ចំណេញដែលអាចបែងចែក និងការកាត់កងទៅនឹងការចេញវិក្កយបត្រតាមដំណាក់កាលរបស់គម្រោង។

រយៈពេលកំណត់បង់ប្រាក់នៃកិច្ចសន្យានីមួយៗ ឧទាហរណ៍ ការចេញវិក្កយប័ត្រតាមដំណាក់កាល គឺអាស្រ័យទៅតាមការព្រមព្រៀងក្នុងកិច្ចសន្យារវាងក្រុមហ៊ុន និងអតិថិជន។

សូមមើលផ្នែកទី៧.៤.១ នៃឯកសារព័ត៌មាននេះ សម្រាប់ព័ត៌មានលើគោលនយោបាយទទួលស្គាល់ចំណូល។

គិតត្រឹមដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ទ្រព្យសកម្មកិច្ចសន្យាមានប្រមាណ ១៧៩.១ លានដុល្លារអាមេរិក ស្មើនឹងកំនើន២២.២% ពី១៤៦.៦ លានដុល្លារអាមេរិក នៅដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ការកើនឡើងទ្រព្យសកម្មកិច្ចសន្យាកើតឡើងមកពីចំណូលសន្ធត់ពីគម្រោងរាជធានីភ្នំពេញភាគខាងលិច - ខេត្តព្រះសីហនុ វារីអគ្គីសនីស្ទឹងតាតៃ និងបណ្តាញអគ្គីសនីរាជធានីភ្នំពេញ និងគម្រោងខេត្តសៀមរាប - ខេត្តឧត្តរមានជ័យ នៅដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។

សូមមើលផ្នែកទី៣.៦.២ នៃឯកសារព័ត៌មាននេះ សម្រាប់ព័ត៌មានលើហានិភ័យឥណទានដែលទាក់ទងនឹងគម្រោងរបស់ក្រុមហ៊ុន។

៧.៥.១៣. គណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងៗ

គិតត្រឹមដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ គណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងៗរបស់ក្រុមហ៊ុនកើនឡើងដល់៨,៣ លានដុល្លារអាមេរិក ស្មើនឹងការថយចុះ៨២,៧% ពី៤៨,០ លានដុល្លារអាមេរិក នៅដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។ ការថយចុះគណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងៗ របស់ក្រុមហ៊ុននៅដំណាច់ការិយបរិច្ឆេទនៅថ្ងៃទី៣០

ខែមិថុនា ឆ្នាំ២០១៩ ជាចម្បងកើតពីការថយចុះសំវិធានធនគម្រោងរបស់ក្រុមហ៊ុនដែលមានចំនួន ៤១,១ លានដុល្លារអាមេរិក នៅការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។

៧.៥.១៤. ទឹកប្រាក់ជំពាក់ក្រុមហ៊ុនមេ និងភាគីពាក់ព័ន្ធ

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុនមេ ឬក្រុមហ៊ុន PIB មានប្រមាណ៥៩,៦ លានដុល្លារអាមេរិក និងភាគីពាក់ព័ន្ធមានប្រមាណ២៣,០ លានដុល្លារអាមេរិក។ ទឹកប្រាក់ជំពាក់ទាំងនោះកើតឡើងពីការទិញសម្ភារៈ និងគ្រឿងបរិក្ខាផ្សេងៗសម្រាប់ការសាងសង់គម្រោងរបស់ក្រុមហ៊ុន។ ទឹកប្រាក់ជំពាក់ក្រុមហ៊ុន PIB និងភាគីពាក់ព័ន្ធមិនមានទ្រព្យដាក់ធានា គ្មានការប្រាក់ និងអាចបង់តាមការទាមទារ។ ទោះជាយ៉ាងណា ក្រុមហ៊ុន PIB នឹងចាប់ផ្តើមកំណត់ការប្រាក់ទៅលើទឹកប្រាក់ដែលក្រុមហ៊ុនជំពាក់បន្ទាប់ពីធ្វើការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

សូមមើលផ្នែកទី៣.៦.១ នៃឯកសារព័ត៌មាននេះសម្រាប់ព័ត៌មានលម្អិតលើទឹកប្រាក់ដែលត្រូវបង់ទៅក្រុមហ៊ុន PIB និងភាគីពាក់ព័ន្ធ។

៧.៥.១៥. កិច្ចសន្យាសំខាន់ៗ

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រៅពីកិច្ចសន្យាដែលបានចុះក្នុងដំណើរការសកម្មភាពអាជីវកម្មជាធម្មតាពាក់ព័ន្ធនឹងគម្រោង ដែលបានបង្ហាញក្នុងផ្នែកទី៤.១.៥ នៃឯកសារព័ត៌មាននេះ ក្រុមហ៊ុនមិនមានចុះកិច្ចសន្យាសំខាន់ណាមួយដទៃទៀតនោះឡើយ។

(i) កិច្ចព្រមព្រៀងចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ ២០១៧ រវាងអគ្គិសនីកម្ពុជា ក្រុមហ៊ុនអាឡិច និងក្រុមហ៊ុនផ្តល់សិទ្ធិ និងណែនាំឱ្យអគ្គិសនីកម្ពុជាទូទាត់ប្រាក់សរុបចំនួន ១៤១,៩ លានដុល្លារអាមេរិក ក្នុងរយៈពេល (៨) ឆ្នាំដោយចាប់ផ្តើមពីឆ្នាំដំបូងនៃកាលបរិច្ឆេទប្រតិបត្តិការពាណិជ្ជកម្មនៃគម្រោង ភ្នំពេញខាងលិច - ក្រុងព្រះសីហនុ ដល់ក្រុមហ៊ុន។

(ii) កិច្ចព្រមព្រៀងចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៧ រវាងអគ្គិសនីកម្ពុជា ក្រុមហ៊ុនអាឡិច និងក្រុមហ៊ុន ផ្តល់សិទ្ធិ និងណែនាំឱ្យអគ្គិសនីកម្ពុជាទូទាត់ប្រាក់សរុបចំនួន ៩៧,២ លានដុល្លារអាមេរិកក្នុងរយៈពេល (៨) ឆ្នាំដោយចាប់ផ្តើមពីឆ្នាំដំបូងនៃកាលបរិច្ឆេទប្រតិបត្តិការពាណិជ្ជកម្មនៃគម្រោងវារីអគ្គិសនីស្ទឹងតាតៃ - គម្រោងប្រព័ន្ធបញ្ជូនភ្នំពេញទៅក្រុមហ៊ុន។

(iii) នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងជាមួយធនាគារ អ អេច ប៊ី (ខេមបូឌា) ដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតចុះបញ្ជីស្របតាម

ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់កម្ចីធនាគារដែលមានទំហំទឹកប្រាក់ចំនួន៣ លានដុល្លារអាមេរិក។

(iv) នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងជាមួយធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី ("ស៊ីអាយអិមប៊ី") ដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់កម្ចីធនាគាររួមមាន ឥណទានវិបារូប និងឥណទានទុនបង្វិលចំនួន០,១ លានដុល្លារអាមេរិក និងចំនួន១,១ លានដុល្លារអាមេរិក។

(v) កិច្ចព្រមព្រៀង O&M ចុះថ្ងៃទី ១២ ខែមករាឆ្នាំ ២០១៨ រវាង ក្រុមហ៊ុនអាឡិច និងក្រុមហ៊ុន ទាក់ទងទៅនឹង O&M នៃ ភ្នំពេញខាងលិច-ក្រុងព្រះសីហនុ និងរោងចក្រវារីអគ្គិសនីស្ទឹងតាតៃ - គម្រោងប្រព័ន្ធបញ្ជូនអគ្គិសនីភ្នំពេញ។

(vi) កិច្ចព្រមព្រៀង O&M ចុះថ្ងៃទី ២៣ ខែកុម្ភះ ឆ្នាំ២០១៨ រវាងក្រុមហ៊ុន Diamond Power និងក្រុមហ៊ុន ទាក់ទងនឹង O&M នៃគម្រោងកំពង់ចាម - ក្រចេះ។

(vii) នៅថ្ងៃទី០៨ ខែកុម្ភះ ឆ្នាំ២០១៨ ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងកម្ចី Murabahah ជាមួយធនាគារ OCBC AL-A-MIN BANK BERHAD ("OCBC") ដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតចុះបញ្ជីស្របតាមច្បាប់នៃប្រទេសម៉ាឡេស៊ី និង ជាមួយធនាគារ ស៊ីអាយ អិមប៊ី ភីអិលស៊ី ("ស៊ីអាយអិមប៊ី") ដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតចុះបញ្ជីស្របតាមច្បាប់នៃ ប្រទេសម៉ាឡេស៊ី សម្រាប់កម្ចីធនាគាររួម ដែលផ្តល់ដោយ Oversea-Chinese Banking Corporation Limited, Labuan Branch និងCIMB Bank Berhad, Labuan Offshore Branch ដែលរួមមាន ចំនួន៥០ លានដុល្លារអាមេរិក Islamic term financing facilities និងចំនួន៣ លានដុល្លារអាមេរិក ជការធានាពីធនាគារ។

(viii) កិច្ចព្រមព្រៀងចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ២០១៨ រវាងអគ្គិសនីកម្ពុជា ក្រុមហ៊ុន Schneitec Energy Co. , Ltd ("Schneitec Energy") និងក្រុមហ៊ុនដែលក្រុមហ៊ុន Schneitec Energy អនុញ្ញាត និងណែនាំអគ្គិសនីកម្ពុជាឱ្យទូទាត់ប្រាក់សរុបចំនួន ២៦ លានដុល្លារអាមេរិក ក្នុងរយៈពេល (៤) ឆ្នាំចាប់ផ្តើមពីឆ្នាំដំបូងនៃកាលបរិច្ឆេទប្រតិបត្តិការពាណិជ្ជកម្មនៃគម្រោងសៀមរាប - ឧត្តរមានជ័យ ទៅក្រុមហ៊ុន។

(ix) នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ និងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ក្រុមហ៊ុនបានចុះកិច្ចសន្យាប្តូរអត្រាការប្រាក់ ("IRS") ដើម្បីការពារហានិភ័យរបស់ក្រុមហ៊ុនចំពោះហានិភ័យអត្រាការប្រាក់លើប្រាក់កម្ចីរបស់ខ្លួន។ IRS ផ្តល់សិទ្ធិឱ្យក្រុមហ៊ុន ទទួលបានកម្ចីក្នុងអត្រាការ

ព្រះរាជាណាចក្រកម្ពុជា
ផេសទិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ប្រាក់ប្រែប្រួល ហើយក្រុមហ៊ុនបង់ការប្រាក់តាមអត្រាការប្រាក់ថេរ ដូច្នេះក្រុមហ៊ុនអាច បង្កើនប្រាក់កម្ចីក្នុងអត្រាការប្រាក់ប្រែប្រួល ហើយបង់អត្រាការប្រាក់ថេរ។

(x) លិខិតផ្តល់ជូនពីធនាគារស៊ីអាយអិមប៊ីភីអិលស៊ី ចុះថ្ងៃទី១២ ខែកុម្ភៈឆ្នាំ ២០១៩ សម្រាប់សំភារៈបន្ថែមចំនួន ៣,៨ លានដុល្លារអាមេរិក ដែលរួមមានឥណទានវិបារូបចំនួន ១00,000 ដុល្លារអាមេរិក និង ឥណទាន (Revolving Credit) ចំនួន ៣,៤ លានដុល្លារអាមេរិក និងការធានាពីធនាគារចំនួន១,៥ លានដុល្លារអាមេរិក។

(xi) កិច្ចព្រមព្រៀងចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៩ រវាងធនាគារអាយស៊ីប៊ីស៊ី លីមីតធីត សាខាភ្នំពេញ (អាយស៊ីប៊ីស៊ីភ្នំពេញ) និង ICBC Berhad សម្រាប់ប្រាក់កម្ចីមានកាលកំណត់ និងមានទ្រព្យធានាចំនួន ៥0 លានដុល្លារអាមេរិក ដែលត្រូវបានផ្តល់ដោយធនាគារអាយស៊ីប៊ីស៊ី ភ្នំពេញ និង ICBC Berhad ដល់ក្រុមហ៊ុន។

(xii) កិច្ចសន្យាផ្គត់ផ្គង់ខ្សែកាប" TACSR" សម្រាប់បញ្ជូនអគ្គិសនី ២៣0kV ពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍ចំការលួងក្នុងតម្លៃលក់ ៧,៤៩ លានដុល្លារអាមេរិក ប្រតិបត្តិការរវាងក្រុមហ៊ុន និងអគ្គិសនីកម្ពុជានៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ ហើយខ្សែកាបត្រូវផ្គត់ផ្គង់ក្នុងរយៈពេល ៦ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខា។

(xiii) លិខិតអនុញ្ញាតពីធនាគារហុងលីអុង (ខេមបូឌា) ម.ក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៩ ដោយផ្តល់ជូនកម្ចី ២ ប្រភេទដល់ក្រុមហ៊ុន៖ (i) ប្រាក់កម្ចី ៩,៥ លានដុល្លារអាមេរិក និង (ii) ប្រាក់កម្ចី ១0.៣១0 លានរៀល ដែលកម្ចីនីមួយៗសម្រាប់រយៈពេល៥ឆ្នាំ រាប់បញ្ចូលទាំងរយៈពេលអនុគ្រោះមួយឆ្នាំ ឬការទូទាត់ចុងក្រោយបំផុតនៅខែមេសា ឆ្នាំ២0២0 ជាមួយនឹងការសងរំលោះ ៤៨ ខែ។

(xiv) នៅថ្ងៃទី១៤ ខែមិនា ឆ្នាំ២0២0 យើងបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន Renaissance Minerals (Cambodia) Ltd. សម្រាប់គម្រោងដែលកិច្ចសន្យាមានតម្លៃ ៧,៣0 លានដុល្លារអាមេរិក។ គម្រោងនេះទាក់ទងនឹង ការគូសប្តង់ វិស្វកម្ម ការតម្លើង ការសាកល្បង និងការដាក់ឱ្យប្រើប្រាស់ខ្សែបណ្តាញបញ្ជូនមានតង់ស្យុង ២៣0/១១ គីឡូវ៉ុល សម្រាប់អនុស្ថានីយ៍អូខ្វាវ ខេត្តមណ្ឌលគីរី។

៧.៦. ព័ត៌មានឥន្ធនការ

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ប្រតិបត្តិការរបស់ក្រុមហ៊ុនមិនធ្លាប់បាន ឬមិនរំពឹងថានឹងមានផលប៉ះពាល់ពីនិន្នាការ ភាពមិនជាក់លាក់ តម្រូវការ ការសន្យា ឬព្រឹត្តិការណ៍ណាមួយដែលអាចមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើផ្នែកហិរញ្ញវត្ថុ ស្ថានភាព និងប្រតិបត្តិការរបស់ក្រុមហ៊ុន ក្រៅពីចំណុចដែលបានលើកឡើងនៅផ្នែកកិច្ចពិភាក្សាថ្នាក់ដឹកនាំ និងការវាយតម្លៃ និងលទ្ធផលនៃប្រតិបត្តិការដូចមាននៅក្នុងផ្នែកទី៧.៤ នៃឯកសារព័ត៌មាននេះឡើយ។

៧. ព័ត៌មានព័ត៌មានហិរញ្ញវត្ថុ (ត)

៧.៧. គោលនយោបាយភាគលាភ

ជាបំណងរបស់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដែលអនុញ្ញាតឱ្យភាគហ៊ុនិកចូលរួមក្នុងចំណេញរួមរបស់ក្រុមហ៊ុន ក៏ដូចជាទុកភាគបម្រុងដើម្បីការរីកចម្រើននាពេលអនាគតរបស់ក្រុមហ៊ុន។

លទ្ធភាពក្នុងការបែកចែកភាគលាភនាពេលអនាគតជូនភាគហ៊ុនិករបស់ក្រុមហ៊ុន អាស្រ័យទៅតាមកត្តាផ្សេងៗ រួមមានជាអាទិ៍ ប្រតិបត្តិការហិរញ្ញវត្ថុ តម្រូវការចលនាសាច់ប្រាក់ ប្រាក់ចំណេញរក្សាទុក តម្រូវការចំណាយដើមទុន និងកត្តាផ្សេងទៀតដែលក្រុមប្រឹក្សាភិបាលគិតថាពាក់ព័ន្ធ។

បន្ទាប់ពីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមានបំណងបង្កើតឱ្យមានជាស្ថេរភាព និងចីរភាពនៃគោលនយោបាយបែកចែកភាគលាភ ដើម្បីអនុញ្ញាតឱ្យភាគហ៊ុនិកនីមួយៗ ចូលរួមទទួលបានប្រាក់ចំណេញពីក្រុមហ៊ុន ខណៈពេលដែលខ្លួនកំពុងរក្សាចនាសម្ព័ន្ធដើមទុនឱ្យបានប្រសើរ និងធានាឱ្យបាននូវមូលនិធិគ្រប់គ្រាន់សម្រាប់ការរីកចម្រើននាពេលអនាគត។

ក្នុងន័យនេះ យើងមានបំណងផ្តល់និងបែងចែងភាគលាភអប្បបរមាចំនួនសាមសិបភាគរយ (៣០,០០%) នៃចំណាញក្នុងគ្រារបស់យើង ដោយត្រូវអនុវត្តតាមលក្ខខណ្ឌដូចបានកំណត់ពីខាងដើម។

ក្រុមហ៊ុនអាចពិចារណាផ្តល់ភាគលាភនោះក្នុងទម្រង់ជាសាច់ប្រាក់សុទ្ធ ជាភាគហ៊ុននៅក្នុងក្រុមហ៊ុនសម្រាប់ការវិនិយោគឡើងវិញ ឬជាការរួមបញ្ចូលទាំងពីរ។ នៅពេលដែលមានជម្រើស ម្ចាស់ភាគហ៊ុន អាចជ្រើសរើសយកជាសាច់ប្រាក់ ជាភាគហ៊ុន ឬរួមបញ្ចូលទាំងពីរ ស្របទៅតាមច្បាប់និងគោលការដែលមានក្នុងព្រះរាជាណាចក្រកម្ពុជា។

ផ្ទុយពីអ្វីដែលបានរៀបរាប់ពីខាងដើម លោកអ្នកគួរកត់សំគាល់ថា ចេតនាស្នើបែងចែកភាគលាភមិនគួរត្រូវបានចាត់ទុកជាកាតព្វកិច្ចផ្លូវច្បាប់មកលើក្រុមហ៊ុនឡើយ។ ដូចគ្នានេះដែរ កម្រិតនៃភាគលាភមិនគួរចាត់ទុកជាសូចនាករកំណត់អំពីគោលនយោបាយបែងចែកភាគលាភនាពេលអនាគតរបស់ក្រុមហ៊ុននោះឡើយ។ មិនមានការធានាណាមួយថា ភាគលាភនឹងត្រូវបានបែងចែកនាពេលអនាគត ឬនៅពេលកំណត់ណាមួយនោះឡើយ។ ក្រុមហ៊ុននឹងធ្វើការពិចារណាក្នុងការបង្កើនជាអតិបរិមានូវតម្លៃរបស់ភាគហ៊ុនិកក្នុងពេលកំណត់ពីការបែងចែកភាគលាភទៅតាមឆ្នាំសារពើពន្ធបន្តបន្ទាប់។

មិនគួរយកសេចក្តីថ្លែងការណ៍ខាងលើ ដើម្បីកំណត់ពីផលចំណេញជាក់ស្តែងនាពេលអនាគត ឬលទ្ធភាពក្នុងការបែងចែកភាគលាភរបស់ក្រុមហ៊ុនឡើយ។

៧.៨. ការព្យាករណ៍ប្រាក់ចំណេញ

ក្រុមហ៊ុនយើងបានទទួលការអនុញ្ញាតពី គ.ម.ក ក្នុងការមិនបង្ហាញរបាយការណ៍ព្យាករណ៍ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

៧. ព័ត៌មានព័ត៌មានហិរញ្ញវត្ថុ (ក)

៧.៩. ព័ត៌មានហិរញ្ញវត្ថុរួម

គ្មាន

៧.១០. ខ្ចប់ក្រៅតារាងតុល្យការ

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនពុំមានខ្ចង់ក្រៅតារាងតុល្យការនោះទេ៕

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា

៨. រង្វាយការណ៍របស់អគ្គាល

PESTECH

ផេសថិក (ខេមបូឌា) ម.ក
ការិយាល័យចុះបញ្ជី៖
ផ្ទះលេខ ៦ ផ្លូវលេខ ៥៨៨
សង្កាត់បឹងកក់២ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ភាគហ៊ុនិក
ផេសថិក (ខេមបូឌា) ម.ក

គោរពជូន

តំណាងឱ្យក្រុមប្រឹក្សាភិបាលរបស់ ក្រុមហ៊ុន **ផេសថិក (ខេមបូឌា) ម.ក** ("**ផេសថិក (ខេមបូឌា)**") ("**ក្រុមប្រឹក្សា**") បន្ទាប់ពីមានការសាកសួរពីក្រុមប្រឹក្សា ខ្ញុំសូមរាយការណ៍ថា សម្រាប់អំឡុងពេលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដែលជាកាលបរិច្ឆេទបង្កើតរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មចុងក្រោយរបស់ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) មកដល់កាលបរិច្ឆេទនៃរបាយការណ៍នេះដែលជាកាលបរិច្ឆេទមិនលើសពី៣០ថ្ងៃ មុនថ្ងៃបោះផ្សាយឯកសារបង្ហាញព័ត៌មាននេះ៖

១. យោងតាមការយល់ឃើញរបស់ក្រុមប្រឹក្សា ធុរកិច្ចរបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ត្រូវបានគ្រប់គ្រងរក្សាយ៉ាងសមរម្យ។

២. យោងតាមការយល់ឃើញរបស់ក្រុមប្រឹក្សា មិនមានព្រឹត្តិការណ៍ណាមួយបានកើតឡើងចាប់ពីកាលបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មចុងក្រោយរបស់ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ដែលបានជះឥទ្ធិពលអវិជ្ជមានដល់ការជួញដូរ ឬតម្លៃនៃទ្រព្យសកម្មរបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ឡើយ។

៣. ទ្រព្យសកម្មរយៈពេលខ្លីរបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ដែលមានរៀបរាប់ក្នុងបញ្ជី ជាតម្លៃសមស្របទៅតាមដំណើរការធម្មតានៃអាជីវកម្ម។

៤. លើកលែងមានបង្ហាញក្នុងឯកសារពត៌មាននេះ មិនមានបំណុលជាយថាហេតុណាមួយ ដែលកើតចេញពីការធានា ឬការសន្យារបស់ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ឡើយ។

៥. មិនមានការខកខាន ឬព្រឹត្តការណ៍ណាមួយដែលបណ្តាលឱ្យមានការខកខាន ក្នុងការទូទាត់ការប្រាក់ និង/ឬ ប្រាក់ដើម សម្រាប់កម្ចីណាមួយ ចាប់តាំងពីកាលបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មចុងក្រោយរបស់ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ឡើយ។

ផេសថិក (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

៨. ទ្រាយការណ៍របស់អតឡាល (ត)

៦. លើកលែងមានបង្ហាញក្នុងឯកសារពត៌មាននេះ មិនមានការផ្ទាស់ប្តូរសំខាន់ណាមួយលើទុនបំរុង ឬភាពមិនប្រក្រតីណាមួយ ដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុន ផេសទិក (ខេមបូឌា) ចាប់តាំងពីកាលបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មចុងក្រោយរបស់ក្រុមហ៊ុន ផេសទិក (ខេមបូឌា) ឡើយ ។

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា

Grant Thornton

ប្រេន សនជុន ប្រគុមប្បនា) លីមីតធីត
ជាន់ទី២០ អាគារ ណាល់ ធីយ៉ា
៣១៨ ផ្លូវព្រះ ម៉ុនីវង្ស
កែងមហាវិថីព្រះ ម៉ុនីវង្ស
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

ក្រុមប្រឹក្សាភិបាល
ផេសថិក (ខេមបូឌា) លីមីតធីត
ផ្ទះលេខ ៦ ផ្លូវលេខ ៥៨៨
សង្កាត់បឹងកក់២ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ផេសថិក (ខេមបូឌា) លីមីតធីត ហៅកាត់ថា ("ក្រុមហ៊ុន")
របាយការណ៍គណនេយ្យ ហៅកាត់ថា ("របាយការណ៍")

សេចក្តីផ្តើម

ខាក្រោមនេះជារបាយការណ៍របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ក្រុមហ៊ុនផេសថិក (ខេមបូឌា) លីមីតធីត ហៅកាត់ថា ("ក្រុមហ៊ុន") និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ហៅកាត់ថា("សម្ព័ន្ធក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៨ និង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ("ការិយហិរញ្ញវត្ថុដែលទាក់ទង") និងរបាយការណ៍លទ្ធផលរបាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ចុងការិយបរិច្ឆេទនិងកំណត់សម្គាល់ដែលរួមមានសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ ព្រមទាំងការពន្យល់កំណត់សម្គាល់ផ្សេងៗ ("ព័ត៌មានហិរញ្ញវត្ថុ") សម្រាប់ដាក់បញ្ចូលទៅក្នុងឯកសារលាតត្រដាងព័ត៌មាន ("ឯកសារលាតត្រដាងព័ត៌មាន") ទាក់ទងនឹងការចុះបញ្ជីដំបូងនៃភាគហ៊ុនរបស់ក្រុមហ៊ុននៅលើមូលប័ត្រកម្ពុជា("ជ.ម.ក") និងមិនគួរត្រូវបានផ្អែកទៅលើព័ត៌មានទាំងនោះសម្រាប់គោលបំណងផ្សេងឡើយ។

មតិសវនកម្ម

តាមមតិរបស់យើងខ្ញុំ ព័ត៌មានហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន នាកាលបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ និង ២០១៩ រួមបញ្ចូលលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ចុងការិយបរិច្ឆេទ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងការសង្ស័យដែលមានវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏ៈ

ក) កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃព័ត៌មានហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គង រៀបចំនិងអនុវត្តនិតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្រប ដើម្បីគាំទ្រជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើង។ ហានិភ័យដែលមិនអាចរកឃើញ

ដោយការរាយការណ៍ខុសជាសារវ៉ន្ត ដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសផ្តុងដោយអចេតនា ដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬ ការលើសលប់ទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

ខ) ធ្វើការស្វែងយល់អំពីការគ្រប់គ្រង់ផ្ទៃក្នុង ដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនិតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធិភាពគ្រប់គ្រង់ផ្ទៃក្នុងរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។

គ) ធ្វើការវាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រង។

ឃ) សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់គណៈគ្រប់គ្រង លើមូលដ្ឋាននិរន្តភាពគណនេយ្យ ផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវ៉ន្ត បានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឲ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពក្នុងការបន្តនិរន្តភាពរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន។ ប្រសិនបើយើងសន្និដ្ឋានថាភាពមិនប្រាកដប្រជា ជាសារវ៉ន្តនឹងកើតមានឡើង យើង តម្រូវឲ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើង ទៅនឹងការលាតត្រដាងនៅក្នុងព័ត៌មានហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់ពួកយើង គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើង។ ក៏ប៉ុន្តែស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឲ្យ សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តភាពបាន។

ង) វាយតម្លៃការបង្ហាញទូទៅ ទម្រង់ និងអត្ថន័យរបស់ព័ត៌មានហិរញ្ញវត្ថុរួមបញ្ចូលទាំងការលាតត្រដាងនានាថាតើព័ត៌មានហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

ច) ទទួលភស្តុតាងសវនកម្មចំពោះព័ត៌មានហិរញ្ញវត្ថុឬសកម្មភាពអាជីវកម្មរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនត្រឹមត្រូវ និងគ្រប់គ្រាន់ ដើម្បីបញ្ចេញមតិយោបល់ទៅលើ របាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំទទួលខុសត្រូវចំពោះការចាត់ចែង ការគ្រប់គ្រង និងការអនុវត្ត សវនកម្ម។ យើងខ្ញុំទទួលខុសត្រូវតែទៅលើមតិយោបល់សវនកម្មរបស់យើងតែប៉ុណ្ណោះ។

យើងប្រាស្រ័យទាក់ទងជាមួយនឹងគណៈគ្រប់គ្រងទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបបគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតធំៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

ក្រុះរាជាណាចក្រកម្ពុជា
ផេសទិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

Grant Thornton

យើងខ្ញុំក៏ផ្តល់ជូនគណៈគ្រប់គ្រងនូវសេចក្តីថ្លែងការណ៍ ដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការ
ក្រមសីលធម៌ ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងពួកគាត់នូវរាល់
ផ្សេងៗដែលនឹងគិតថាសមហេតុផលលើឯករាជ្យភាពរបស់យើងខ្ញុំ និងការការពារដែលអាចមាន។

Grant Thornton

ប្រ៊ុនសនថុន លីមីតធីត (ខេមបូឌា)
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩

គណនេយ្យករជំនាញនិងសវនករប្រតិស្រុត
សមាជិកភាពប្រ៊ុន សនថុន អន្តរជាតិ។ ប្រ៊ុន សនថុន អន្តរជាតិ និង សមាជិកគឺមិនមែនជាដៃគូរពាណិជ្ជកម្មទូទាំង
សកលលោកទេ។រាល់សេវាកម្មនានាត្រូវបានផ្តល់ឃ្លាំងឯករាជ្យដោយសមាជិកនីមួយៗ។

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន

	សំគាល់	ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩		ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨	
		ដុល្លារអាមេរិក	ពាន់រៀល (សំគាល់ ៤.២)	ដុល្លារ	ពាន់រៀល (សំគាល់ ៤.២)
ទ្រព្យសកម្ម					
ទ្រព្យសកម្មរយៈពេលវែង					
ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ	៨	២.២៨៦.៦៧៨	៩.១៣៨.៩៧៦	១.៩១២.៥៣៧	៧.៧៧០.៦៣៨
ទ្រព្យសកម្មអរូបិយ		៣.០៦៩	១២.៤៧៩	-	-
ទ្រព្យសកម្មកិច្ចសន្យា	៩	១៧៣.០៥៩.០៣៨	៧០៣.៦៥៨.០៣២	១៨៦.៥៨៧.០៤៨	៥៩៥.៥៨៣.១៧៦
ទ្រព្យសកម្មរយៈពេលវែង		**១៧៥.៣០៨.៧៧៧**	**៧១២.៨០៥.៤៨៧**	**១៨៨.៤៩៩.៥៨៥**	**៦០៣.៣៥៣.៨១៨**
ទ្រព្យសកម្មរយៈពេលខ្លី					
គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ	១០	១០.៨០៣.៧៧៨	៤៣.៩២៨.១៤៥	៨៤៥.៨០៨	៣.៤៣៦.៥១៨
ទ្រព្យសកម្មកិច្ចសន្យា	៩	៦.០៤១.៦៦៧	២៤.៥៦៥.៤១៨	-	-
ទឹកប្រាក់ដែលភាគីសម្ព័ន្ធញាតិជំពាក់	២១	១.៩៨៤.៤៧៤	៧.៩០៦.២៣១	-	-
សាច់ប្រាក់ និងសមតុល្យធនាគារ	១១	១៣.០៥៥.៩៧៩	៥៣.០៨៥.៦១១	២.០៨៤.៣១០	៨.៤៦៨.៥៩១
ទ្រព្យសកម្មរយៈពេលខ្លី		៣១.៨៨៥.៨៩៤	១២៩.៨៨៥.៤០៥	២.៩៣០.១១៨	១១.៩០៥.០៦៩
ទ្រព្យសកម្មសរុប		**២០៧.១៩៤.៦៧១**	**៨៨២.២៩០.៨៩២**	**១៩១.៤២៩.៧០៣**	**៦១៥.២៩៨.៨៨៣**
មូលធន និងបំណុល					
មូលធន					
ដើមទុន	១២.១	៧.១០០.០០០	២៨.៨៦៨.៦០០	៧.១០០.០០០	២៨.៨៨៧.៣០០
ដើមទុនបម្រុងទុក	១២.២	(១.៧៧២.០៩១)	(៧.២០៥.១៩៩)	៥២.០៨៤	២១១.៤៥៤
ចំណេញរក្សាទុក		៨.៥៩៤.៩១៧	៣៤.៩៨៦.៩៣៣	២០.៦៣០.៨២៧	៨៣.៨២៣.០៥០
មូលធនសរុប		**១៣.៩២២.៨៦៦**	**៥៦.៦១០.៣៧៨**	**២៧.៧៨២.៨៧១**	**១១២.៨៩១.៨០៤**
បំណុល					
បំណុលរយៈពេលវែង					
ប្រាក់កម្ចី	១៤	៩៥.៤០៦.៩៧០	៣៨៧.៩២៤.៧៤០	១៩.៩៤៥.០០០	៨១.០៣៦.៥៣៥
ឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍	១៥	១.៨២៤.០៩៥	៧.៤១៦.៧៧០	-	-
បំណុលរយៈពេលវែងសរុប		**៩៧.២៣១.០៦៥**	**៣៩៥.៣៤១.៩១០**	**១៩.៩៤៥.០០០**	**៨១.០៣៦.៥៣៥**
បំណុលរយៈពេលខ្លី					
គណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងៗ	១៣	៨.៣១៧.២១៩	៣៣.៨១៧.៨១២	៨៨.០០៤.៧៤២	១៩៥.០៤៣.២៦៧
ទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុនមេ	២១	៥៩.៥៥៧.៨២៤	២៤២.១៦២.១១២	៥៦៥.០៤២	២.២៩៥.៧៦៦
ទឹកប្រាក់ដែលជំពាក់ទៅភាគីសម្ព័ន្ធញាតិ	២១	២៣.០១៧.៥៧៨	៩៣.៥៨៩.៤៧២	៤៩.៦៧៩.០៩៩	២០១.៨៤៦.១៧៩
ប្រាក់កម្ចី	១៤	៤.១៨០.២៨២	១៦.៩៩៧.០២៧	២.០៦៧.៩២៩	៨.៤០១.៩៩៦
ពន្ធលើប្រាក់ចំណូលត្រូវបង់		៩២៧.៨៣៧	៣.៧៧២.៥៨៥	៣.៣៨៥.០២០	១៣.៧៥៣.៣៣៦
បំណុលរយៈពេលខ្លីសរុប		**៩៦.០០០.៧៨០**	**៣៩០.៣៣៩.០០៨**	**១០៣.៧០១.៨៣២**	**៤២១.៣៤០.៥៤៤**
បំណុលសរុប		**១៩៣.២៣១.៨០៥**	**៧៨៥.៦៨០.៥១៨**	**១២៣.៦៤៦.៨៣២**	**៥០២.៣៧៧.០៧៩**
មូលធន និងបំណុលសរុប		**២០៧.១៥៤.៦៧១**	**៨៨២.២៩០.៨៩២**	**១៩១.៤២៩.៧០៣**	**៦១៥.២៩៨.៨៨៣**

បាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន

	សំគាល់	ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩		ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨	
		ដុល្លារអាមេរិក	ពាន់រៀល (សំគាល់ ៤.២)	ដុល្លារអាមេរិក	ពាន់រៀល (សំគាល់ ៤.២)
ទ្រព្យសកម្ម					
ទ្រព្យសកម្មរយៈពេលវែង					
ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ	៧	២៥.០០០	១០១.៦៥០	២៥.០០០	១០១.៥៧៥
ទ្រព្យសកម្មអរូបិយ	៨	២.២៤៦.៦៧៤	៩.១៣៤.៩៧៦	១.៩១២.៥៣៧	៧.៧៧០.៦៣៨
ទ្រព្យសកម្មកិច្ចសន្យា		៣.០៦៩	១២.៤៧៩	-	-
ទ្រព្យសកម្មរយៈពេលវែង	៩	១៧៣.០៥៩.០៣៤	៧០៣.៦៥៨.០៣២	១៤៦.៥៨៧.០៤៨	៥៩៥.៥៨៣.១៧៦
ទ្រព្យសកម្ម		១៧៥.៣៣៣.៧៧៧	៧១២.៩០៧.១៣៧	១៤៨.៥២៤.៥៨៥	៦០៣.៤៥៥.៣៨៩
ទ្រព្យសកម្មរយៈពេលខ្លី					
គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ	១០	១០.៨០៣.៧៧៤	៤៣.៩២៨.១៤៥	៨៤៥.៨០៨	៣.៤៣៦.៥១៨
ទ្រព្យសកម្មកិច្ចសន្យា	៩	៦.០៤១.៦៦៧	២៤.៥៦៥.៤១៨	-	-
ទឹកប្រាក់ដែលភាគីសម្ព័ន្ធញ្ញាតិជំពាក់	២១	១.៩៤៤.៤៧៤	៧.៩០៦.២៣១	-	-
ទឹកប្រាក់ដែលក្រុមហ៊ុនកូនជំពាក់	២១	១.០១០	៤.១០៧	១.០០០	៤.០៦៣
សាច់ប្រាក់ និងសមតុល្យធនាគារ	១១	១៣.០៣៩.៨៧១	៥៣.០២០.១១៥	២.០៥៨.៤២៩	៨.៣៦៣.៣៩៧
ទ្រព្យសកម្មរយៈពេលខ្លី		៣១.៨៣០.៧៩៦	១២៩.៤២៤.០១៦	២.៩០៥.២៣៧	១១.៨០៣.៩៧៨
ទ្រព្យសកម្មសរុប		២០៧.១៦៤.៥៧៣	៨៤២.៣៣១.១៥៣	១៥១.៤២៩.៨២២	៦១៥.២៥៩.៣៦៧
មូលធន និងបំណុល					
មូលធន					
ដើមទុន	១២.១	៧.១០០.០០០	២៨.៨៦៨.៦០០	៧.១០០.០០០	២៨.៨៤៧.៣០០
ដើមទុនបម្រុងទុក	១២.២	(១.៧៧២.០៥១)	(៧.២០៥.១៥៩)	៥២.០៤៤	២១១.៤៥៤
ចំណេញរក្សាទុក		៨.៦០៧.៤៥១	៣៤.៩៩៧.៨៩៦	២០.៦៣០.៩៤៦	៨៣.៨២៣.៥៣៤
មូលធនសរុប		១៣.៩៣៥.៤០០	៥៦.៦៦១.៣៣៧	២៧.៧៨២.៩៩០	១១២.៨៨២.២៨៨
បំណុលរយៈពេលវែង					
ប្រាក់កម្ចី	១៤	៩៥.៤០៦.៩៧០	៣៨៧.៩២៤.៧៤០	១៩.៩៤៥.០០០	៨១.០៣៦.៥៣៥
ឧបករណ៍ហិរញ្ញវត្ថុនិទស្សន	១៥	១.៨២៤.០៩៥	៧.៤១៦.៧៧០	-	-
បំណុលរយៈពេលវែងសរុប		៩៧.២៣១.០៦៥	៣៩៥.៣៤១.៥១០	១៩.៩៤៥.០០០	៨១.០៣៦.៥៣៥
បំណុល					
បំណុលរយៈពេលខ្លី					
គណនីអ្នកផ្គត់ផ្គង់ និងបំណុលផ្សេងៗ	១៣	៨.៣១៤.៥៨៧	៣៣.៨០៧.១១០	៤៨.០០៤.៧៤២	១៩៥.០៤៣.២៦៧
ទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុនមេ	២១	៥៩.៥៥៧.៨២៤	២៤២.១៦២.១១២	៥៦៥.០៤២	២.២៩៥.៧៦៦
ទឹកប្រាក់ដែលជំពាក់ទៅភាគីសម្ព័ន្ធញ្ញាតិ	២១	២៣.០១៧.៥៧៨	៩៣.៥៨៩.៤៧២	៤៩.៦៧៩.០៩៩	២០១.៨៤៦.១៧៩
ប្រាក់កម្ចី	១៤	៤.១៨០.២៨២	១៦.៩៩៧.០២៧	២.០៦៧.៩២៩	៨.៤០១.៩៩៦
ពន្ធលើប្រាក់ចំណូលត្រូវបង់		៩២៧.៨៣៧	៣.៧៧២.៥៨៥	៣.៣៨៥.០២០	១៣.៧៥៣.៣៣៦
បំណុលរយៈពេលខ្លីសរុប		៩៥.៩៩៨.១០៨	៣៩០.៣២៨.៣០៦	១០៣.៧០១.៨៣២	៤២១.៣៤០.៥៤៤
បំណុលសរុប		១៩៣.២២៩.១៧៣	៧៨៥.៦៦៩.៨១៦	១២៣.៦៤៦.៨៣២	៥០២.៣៧៧.០៧៩
មូលធន និងបំណុលសរុប		២០៧.១៦៤.៥៧៣	៨៤២.៣៣១.១៥៣	១៥១.៤២៩.៨២២	៦១៥.២៥៩.៣៦៧

តារាងខាងក្រោមបង្ហាញពីចំនួនតំរូវការនិងតម្លៃសមរម្យនៃទ្រព្យសកម្មនិងបំណុលហិរញ្ញវត្ថុរួមទាំងកម្រិតរបស់ពួកគេនៅក្នុងហានានុក្រមតម្លៃសមរម្យ។ វាមិនរាប់បញ្ចូលព័ត៌មានតម្លៃសមរម្យសម្រាប់ទ្រព្រយសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ មិនត្រូវបានវាស់តាមតម្លៃសមរម្យប្រសិនបើតម្លៃយោងគឺជាការប៉ាន់ប្រមាណសមហតុផល តម្លៃសមរម្យ។

កំរិតខុសគ្នាត្រូវបានកំណត់ដូចតទៅ:

- តម្លៃដែលបានដកស្រង់ (មិនសមហេតុផល) នៅក្នុងទីផ្សារសកម្មសម្រាប់ទ្រព្យសម្បត្តិឬបំណុលដែលបានកំណត់ (កម្រិត ១)។
- ធាតុចូលក្រៅពីតម្លៃដែលបានដកស្រង់រាប់បញ្ចូលក្នុងកម្រិតទី ១ ដែលអាចសង្កេតបានសម្រាប់ទ្រព្យសកម្មឬការទទួលខុសត្រូវដោយផ្ទាល់ឬដោយប្រយោល (កម្រិត ២)។
- ធាតុចូលសម្រាប់ទ្រព្យសម្បត្តិឬការទទួលខុសត្រូវដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន (កម្រិត ៣) ។

			សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន		
បំណុលហិរញ្ញវត្ថុ	តម្លៃយោង	កំរិត ១	កំរិត ១	កំរិត ១	Total
ឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍	-	-	១.៨២៤.០៩៥	-	១.៨២៤.០៩៥
	-	-	១.៨២៤.០៩៥	-	១.៨២៤.០៩៥

តម្លៃសមរម្យនៃឧបករណ៍ហិរញ្ញវត្ថុដែលបានជួញដូរនៅក្នុងទីផ្សារសកម្មគឺផ្អែកលើតម្លៃទីផ្សារដែលបានដកស្រង់នៅកាលបរិច្ឆេទរាយការណ៍។ ទីផ្សារត្រូវបានចាត់ទុកថាសកម្មប្រសិនបើតម្លៃដកស្រង់អាចរកបានយ៉ាងឆាប់រហ័សនិងទៀងទាត់ពីការផ្លាស់ប្តូរអ្នកចែកចៀសញ្ញកណ្តាលក្រុមឧស្សាហកម្មសេវាកម្មកំណត់តម្លៃឬទីភ្នាក់ងារកំណត់ហើយតម្លៃទាំងនោះតំណាងឱ្យប្រតិបត្តិការទីផ្សារជាក់ស្តែងនិងទៀងទាត់ដែលផ្អែកលើប្រវែងដៃ។ ឧបករណ៍ទាំងនេះត្រូវបានបញ្ចូលក្នុងកម្រិតទី ១។

តម្លៃសមរម្យនៃឧបករណ៍ហិរញ្ញវត្ថុដែលមិនត្រូវបានជួញដូរនៅក្នុងទីផ្សារសកម្ម (ឧទាហរណ៍៖ ឧបករណ៍ហិរញ្ញវត្ថុហួសប្រមាណ) ត្រូវបានកំណត់ដោយការប្រើប្រាស់បច្ចេកទេសវាយតម្លៃ។ បច្ចេកទេសវាយតម្លៃទាំងនេះបង្កើនការប្រើប្រាស់ទិន្នន័យទីផ្សារដែលអាចសង្កេតបាននៅកន្លែងដែលមានហើយពឹងផ្អែកតិចតួចតាមដែលអាចធ្វើទៅបានតាមការប៉ាន់ស្មានជាក់លាក់របស់អង្គភាព។ ប្រសិនបើធាតុចូលសំខាន់ៗទាំងអស់តម្រូវឱ្យមានតម្លៃសមរម្យឧបករណ៍អាចត្រូវបានគេសង្កេតឃើញឧបករណ៍នេះត្រូវបានបញ្ចូលក្នុងកម្រិតទី ២។

ប្រសិនបើធាតុបញ្ចូលសំខាន់មួយឬច្រើនមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាននោះឧបករណ៍ត្រូវបានបញ្ចូលក្នុងកម្រិតទី ៣។

ការផ្លាស់ប្តូរអត្រាការប្រាក់សមរម្យដែលត្រូវបានគណនាជាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតដែលបានប៉ាន់ស្មានផ្អែកលើខ្សែកោងទិន្នផលដែលអាចសង្កេតបាន។

២៦ យថាភាព និងកិច្ចសន្យានៃតតិសន្យា

(ក) កិច្ចសន្យាមូលធន

	សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន			
	ថ្ងៃទី៣០ មិថុនា ឆ្នាំ២០១៩		ថ្ងៃទី៣០ មិថុនា ឆ្នាំ២០១៨	
	ដុល្លារអាមេរិក	ពាន់រៀល (សំគាល់ ៤.២)	ដុល្លារអាមេរិក	ពាន់រៀល (សំគាល់ ៤.២)
សិទ្ធិនិងកិច្ចសន្យាសម្រាប់៖				
ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ	១៥០.៥៦២	៦១២.១៨៥	-	-

(ខ) កិច្ចសន្យាធានារ៉ាប់រង

ក្រុមហ៊ុនបានទិញធានារ៉ាប់រងហានិភ័យ រយៈពេល ១០ ឆ្នាំសម្រាប់គម្រោងសាងសង់ប្រព័ន្ធថាមពលអគ្គីសនីស្ទឹងតាតែប្រវែង ២៣០ គីឡូវ៉ាត់ក្នុងទឹកប្រាក់សរុបចំនួន ៤.៩៦៨.៦០០ ដុល្លារអាមេរិកដើម្បីធានាដល់ទីតាំងដូចដែលបានបង្ហាញនៅក្នុងកំណត់សំគាល់ថ្ងៃទី ១៤គ។ គិតត្រឹមថ្ងៃទី ៣០ ខែមិថុនាឆ្នាំ ២០១៩ ចំនួនទឹកប្រាក់ដែលមិនទាន់បង់មានចំនួន ៤.២១៦.៧៦២ ដុល្លារអាមេរិក។

(គ) កិច្ចសន្យាជួលរយៈពេលខ្លី

ក្រុមហ៊ុនជួលការិយាល័យរបស់ខ្លួនក្រោមកិច្ចសន្យាជួលប្រតិបត្តិការដែលមិនអាចលុបចោលបាន។ តារាងទូទាត់ភតិសន្យាអប្បបរមានាពេលអនាគតមានដូចខាងក្រោម:

	សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុន			
	ថ្ងៃទី៣០ មិថុនា ឆ្នាំ២០១៩		ថ្ងៃទី៣០ មិថុនា ឆ្នាំ២០១៨	
	ដុល្លារអាមេរិក	ពាន់រៀល (សំគាល់ ៤.២)	ដុល្លារអាមេរិក	ពាន់រៀល (សំគាល់ ៤.២)
ក្នុងកំឡុងពេល ១ ឆ្នាំ	**៦៦.០០០**	**២៦៧.៦៩៦**	៦៦.០០០	២៦៧.៦២៨
ក្នុងកំឡុងពេល២ ដល់ ៥ ឆ្នាំ	**១៣.២៦៧**	**៦៣.៩៤៤**	៧៤.១១៨	៣០១.១៤១
	៦៩.២៦៧	**២៨១.៦៤០**	១៣០.១១៨	៦២៨.៦៦៩

២៧ បំណុលយថាភាព

នៅក្នុងឆ្នាំ២០១១ អគ្គនាយកដ្ឋានពន្ធដារកម្ពុជាបានចេញសេចក្តីជូនដំណឹងដល់ក្រុមហ៊ុន ដើម្បីទាមទារឲ្យបង់នូវប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអាករលើតម្លៃបន្ថែមដែលមិនបានប្រកាសក្នុងចំនួនទឹកប្រាក់ ៥៤៦.៩៧១ ដុល្លារអាមេរិក ដែលត្រូវនឹង ២.២២២.៣៨៤.០១១រៀល ក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០១១ ដល់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១១។

នៅក្នុងឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារកម្ពុជាបានចេញសេចក្តីជូនដំណឹងដល់ក្រុមហ៊ុនដើម្បីទាមទារឲ្យបង់នូវប្រាក់រំដោះពន្ធលើប្រាក់ចំណេញនិងពន្ធអាករលើតម្លៃបន្ថែមដែលមិនបានប្រកាសក្នុងចំនួនទឹកប្រាក់៤៩០.៩១២ ដុល្លារអាមេរិក ដែលត្រូវនឹង ១.៩៩៤.៥៧៥.៧៨៥ រៀល ក្នុងអំឡុងពេលចាប់ពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ ដល់ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣។

នៅក្នុងឆ្នាំ២០១៧ អគ្គនាយកដ្ឋានពន្ធដារកម្ពុជាបានចេញសេចក្តីជូនដំណឹងដល់ក្រុមហ៊ុន ដើម្បីទាមទារឲ្យបង់នូវប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធអាករលើតម្លៃបន្ថែម និងពន្ធកាត់ទុកលើសេវាកម្ម ១៤% ដែលមិនបានប្រកាសក្នុងចំនួនទឹកប្រាក់ ២៦៧.៨៥៦ ដុល្លារអាមេរិក ដែលត្រូវនឹង ១.០៨៨.៧០៤.៨៣៩ រៀល សម្រាប់សវនកម្មពេញលេញក្នុងឆ្នាំ២០១០។

ឆ្លើយតបនឹងសេចក្តីជូនដំណឹងនេះ ក្រុមហ៊ុនបានដាក់លិខិតតវ៉ាទៅអគ្គនាយកដ្ឋានពន្ធដារវិញដើម្បីតវ៉ាពីការខុសឆ្គងនៃការវាយតម្លៃឡើងវិញ។ ថ្នាក់គ្រប់គ្រងបានចាត់ទុកសេចក្តីជូនដំណឹងនេះថាមិនមានមូលដ្ឋាននិងមិនសមហេតុផល និងប្រូបាបដែលក្រុមហ៊ុនទូទាត់ពន្ធដែលវាយតម្លៃរួចគឺមានភាពតិចតួចណាស់។ ការតវ៉ានេះនៅតែបន្ត រហូតដល់ចុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុ។

២៨ ការគ្រប់គ្រងមូលធន

កម្មវត្ថុបឋមរបស់សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនក្នុងការគ្របគ្រងមូលធនគឺ ដើម្បីធានាបានថា សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនអាចបន្តប្រតិបត្តិការរបស់ខ្លួនដោយឈរលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម ហើយស្របពេលជាមួយគ្នានេះ ធ្វើអោយមានកំណើនផលលាភដល់ភាគហ៊ុននិក។

សម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនបានរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងធ្វើនិយ័តកម្មលើមូលធនរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃលក្ខខណ្ឌសេដ្ឋកិច្ច។ ដើម្បីរក្សា និងធ្វើនិយ័តកម្មហេដ្ឋារចនាសម្ព័ន្ធលើមូលធនសម្ព័ន្ធក្រុមហ៊ុន និងក្រុមហ៊ុនអាចធ្វើនិយ័តកម្មលើការចំណាយភាគលាភទៅលើភាគហ៊ុននិក បង្វិលភាគហ៊ុនអោយទៅភាគហ៊ុននិក ឬចេញផ្សាយភាគហ៊ុនថ្មី។ ពុំមានការប្រែប្រួលលើកម្មវត្ថុ គោលនយោបាយ ឬដំណើរការផ្សេងៗទេ នៅក្នុងការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ និង ថ្ងៃទី៣០ ខែមិថុនាឆ្នាំ២០១៨។

២៩ ព្រឹត្តិការណ៍បន្ទាប់ពីចុងគ្រារាយការណ៍

មិនមានព្រឹត្តិការណ៍កែសម្រួល និងព្រឹត្តិការណ៍មិនកែសម្រួលសំខាន់ៗណាមួយ បានកើតឡើងចន្លោះ រវាងថ្ងៃបរិច្ឆេទរបាយការណ៍ និងថ្ងៃបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ។

៣១ ការអនុម័តនៃរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី១៧ ខែវិច្ឆិការ ឆ្នាំ២០១៩។

១០. ព័ត៌មានផ្សេងៗ

១០.១ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងរយៈពេលពីរ (២) ឆ្នាំចុងក្រោយមុនពេលដាក់ពាក្យស្នើសុំ

ល.រ	កាលបរិច្ឆេទ	រឿងរ៉ាវ	លទ្ធផល
១	០៦ តុលា ២០១៧	ចុះកិច្ចសន្យាដោយផ្ទាល់ជាមួយនឹងអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអាឡិច	អនុម័ត
២	២២ ធ្នូ ២០១៧	ផ្តល់ព័ត៌មានក្នុងឯកសារផ្តល់ព័ត៌មាន និងរបាយការពាក់ព័ន្ធ	អនុម័ត
៣	២២ ធ្នូ ២០១៧	ដាក់សំណើរបោះផ្សាយមូលបត្រជាលើកដំបូង	អនុម័ត
៤	២២ ធ្នូ ២០១៧	តែងតាំងអ្នកតំណាងមានសិទ្ធិសម្រាប់ដាក់សំណើរ IPO	អនុម័ត
៥	០២ កុម្ភៈ ២០១៨	កិច្ចព្រមព្រៀងកម្ចីជាមួយនឹងស្ថាប័នហិរញ្ញវត្ថុនានា	អនុម័ត
៦	០៨ កុម្ភៈ ២០១៨	ទទួលយកកម្ចី Syndicated Commodity Murabahah Term Financing Facility	អនុម័ត
៧	០៨ កុម្ភៈ ២០១៨	កិច្ចព្រមព្រៀងប្រតិបត្តិការរវើវេសម្រាប់ការប្តូរអត្រាការប្រាក់ជាមួយ OCBC Bank (Malaysia) Berhad	អនុម័ត
៨	២៣ មីនា ២០១៨	ការផ្ទេរប្រាក់បង់មុន និងការធ្វើមូលធនីយកម្មនៃប្រាក់ចំណេញរក្សាទុក	អនុម័ត
៩	២៣ មីនា ២០១៨	ការប្រើប្រាស់កិច្ចសន្យា Foreign Exchange Contract Limit 2 and Derivative Facility	អនុម័ត
១០	២៩ មីនា ២០១៨	តែងតាំងកញ្ញាគាន់ សុចាន់ ជាលេខាធិការ	អនុម័ត
១១	៣០ មីនា ២០១៨	ព័ត៌មានដែលត្រូវបង្ហាញក្នុងឯកសារផ្តល់ពត៌មាន និងរបាយការណ៍ពាក់ព័ន្ធផ្សេងៗ	អនុម័ត
១២	១៧ មេសា ២០១៨	បើកគណនីដែលបានរៀបចំ	អនុម័ត
១៣	២៣ ឧសភា ២០១៨	ការផ្ទេរប្រាក់បង់មុន និងការធ្វើមូលធនីយកម្មនៃប្រាក់ចំណេញរក្សាទុក	អនុម័ត
១៤	១២ មិថុនា ២០១៨	បើកគណនីជាមួយ CIMB Bank Labuan Offshore Branch	អនុម័ត
១៥	៣០ មិថុនា ២០១៨	កំណត់អត្រាការប្តូរប្រាក់	អនុម័ត
១៦	២៩ សីហា២០១៨	តែងតាំងប្រធាន និងសមាជិកនៃគណៈកម្មការសវនកម្ម និងគណៈកម្មការគ្រប់គ្រងហានិភ័យ	អនុម័ត
១៧	០៨ តុលា ២០១៨	ស្នើសុំគម្រោងហិរញ្ញវត្ថុ ឬគម្រោងកម្ចីរួម	អនុម័ត
១៨	២១ ធ្នូ ២០១៨	កម្ចីរវើវេដែលផ្តល់ដោយធនាគារ OCBC Bank (Malaysia) Berhad	អនុម័ត
១៩	០៧ កុម្ភៈ ២០១៩	លក់ឃានយន្ត	អនុម័ត
២០	២៦ កុម្ភៈ ២០១៩	ការប្រើប្រាស់ Multi Option Line-i (MOL-i) ចំនួន ៤០ លានរីងហ្គីត ដោយក្រុមហ៊ុន ផេសធិក (ខេមបូឌា)	អនុម័ត

១០. ព័ត៌មានផ្សេងៗ (ត)

ល.រ	កាលបរិច្ឆេទ	របៀបវារៈ	លទ្ធផល
២១	១២ មីនា ២០១៩	លក់ឃានយន្ត	អនុម័ត
២២	១៤ មីនា ២០១៩	ការប្រើប្រាស់កិច្ចសន្យា Third-party Foreign Exchange Contract Limit (FECL)/Derivative Facility ទទួលបានពី CIMB Bank Berhad	អនុម័ត
២៣	១០ ឧសភា ២០១៩	បើកគណនីធនាគារជាមួយនឹងធនាគារ អេស៊ីលីដា ម.ក	អនុម័ត
២៤	២២ សីហា ២០១៩	ទទួលយកកម្ចីចំនួន ១២ លានដុល្លាអាមេរិក ពីធនាគារ ហុង លីអុង (ខេមបូឌា) ម.ក	អនុម័ត
២៥	៣០ សីហា ២០១៩	ការផ្លាស់ប្តូរហត្ថលេខីធនាគារ ជាមួយនឹងធនគារ ស៊ីអាយអីមប៊ី ម.ក	អនុម័ត
២៦	០៩ កញ្ញា ២០១៩	ទទួលយកកម្ចីចំនួន ១២ លានដុល្លាអាមេរិក ពីធនាគារ ហុង លីអុង (ខេមបូឌា) ម.ក (លិខិតផ្តល់ជូននៅថ្ងៃទី០៩ កញ្ញា ឆ្នាំ២០១៩)	អនុម័ត
២៧	១៨ កញ្ញា ២០១៩	កិច្ចព្រមព្រៀង 2002 ISDA Master ជាមួយ OCBC Bank (Malaysia) Berhad	អនុម័ត
២៨	០៣ តុលា ២០១៩	កិច្ចព្រមព្រៀង International Swaps & Derivatives Association Master ជាមួយ CIMB Bank Berhad	អនុម័ត
២៩	០៣ តុលា ២០១៩	បើកគណនីធនាគារជាមួយនឹងធនាគារ ហុង លីអុង (ខេមបូឌា) ម.ក	អនុម័ត
៣០	១២ កុម្ភៈ ២០២០	បើកគណនីប្រាក់បញ្ញើមានកាលកំណត់ជាមួយធនាគារ ហុង លីអុង (ខេមបូឌា) ម.ក	អនុម័ត

១០.២. ប្រាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករផ្ទៃក្នុងសម្រាប់រយៈពេលពីរ (២) ឆ្នាំចុងក្រោយ

គ្មាន

១០. ព័ត៌មានផ្សេងៗ (ត)

១០.៣. សេចក្តីសម្រេចរបស់ភាគហ៊ុនិកពីរ (២) ឆ្នាំចុងក្រោយ មុនពេលដាក់ពាក្យស្នើសុំ

ល.រ	កាលបរិច្ឆេទ	រៀបរាប់:	លទ្ធផល
១	២៣ ឧសភា ២០១៨	(i) ការផ្តល់ចំនួន ៥,០ លានដុល្លារអាមេរិក និងការទទួលយកមូលធនីយកម្មចំនួនទឹកប្រាក់ដដែល (ii) ការទទួលយកមូលធនីយកម្មនៃប្រាក់ចំណេញរក្សាទុកចំនួន ២,១ លានដុល្លារអាមេរិក	អនុម័ត
២	៣០ ឧសភា ២០១៨	(i) បង្កើនមូលធនដល់ ៧,១ លានដុល្លារអាមេរិក (ii) បង្កើនចំនួនភាគហ៊ុន ៧១ លានភាគហ៊ុន, ដែលក្នុងមួយភាគហ៊ុនមានតំលៃចារឹក ៤០០ រៀល (iii) បន្ថែមចំនួនអភិបាលថ្មីចំនួនពីររូប (iv) ផ្លាស់ប្តូរទម្រង់ក្រុមហ៊ុនទៅជា មហាជនទទួលខុសត្រូវមានកម្រិត (v) វិសោធនកម្មលក្ខន្តិក:ក្រុមហ៊ុន	អនុម័ត
៣	២៧ មិថុនា ២០១៨	ការតែងតាំងលោក Han Fatt Juan និងលោក Tan Pui Hooi ជាអភិបាល	អនុម័ត
៤	០៣ កក្កដា ២០១៨	ការតែងតាំង Teh Bee Choo ជានាយកហិរញ្ញវត្ថុ	អនុម័ត
៥	០៣ កក្កដា ២០១៨	ការតែងតាំងឯកឧត្តម ងាវ អានសាន ជាអភិបាលឯករាជ្យ	អនុម័ត
៦.	៣០ ឧសភា ២០២០	ការតែងតាំងឡើងវិញអភិបាល និងអភិបាលឯករាជ្យ	អនុម័ត

១០.៤. រង្វាយការណ៍ភាគលាភពីរ (២) ឆ្នាំចុងក្រោយ មុនពេលដាក់ពាក្យស្នើសុំ

មិនមានភាគលាភណាមួយត្រូវមានបែងចែកអំឡុងពេលពីរ (២) ឆ្នាំចុងក្រោយ មុនឯកសារផ្តល់ព័ត៌មាននេះឡើយ។

១០.៥. រង្វាយការណ៍ពាក់ព័ន្ធដំណើរការផ្លូវច្បាប់ពីរ(២) ឆ្នាំចុងក្រោយមុនពេលដាក់ពាក្យស្នើសុំ

គិតត្រឹមកាលបរិច្ឆេទអនុវត្តចុងក្រោយ ក្រុមហ៊ុនមិនមានពាក់ព័ន្ធក្នុង វិវាទ និង/ឬមជ្ឈត្តកម្មណាមួយ (ក្នុងនាមជាដើមបណ្តឹង ឬចុងចម្លើយ) ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហើយមិនមានព័ត៌មានណាមួយដែលអភិបាលរបស់យើងបានដឹងពាក់ពន្ធ័នឹងនីតិវិធីបណ្តឹងណាមួយមិនទាន់ចប់ ឬអាចនឹងកើតមាន ឬព្រឹត្តិការណ៍ណាមួយដែលអាចបណ្តាលឱ្យមានបណ្តឹង ដែលអាចជះឥទ្ធិពលអវិជ្ជមាន ដល់ស្ថានភាពហិរញ្ញវត្ថុ ឬធុរកិច្ចរបស់ក្រុមហ៊ុនឡើយ។

១០. ព័ត៌មានផ្សេងៗ (ត)

១០.៦. តម្រូវការសម្រាប់ការអនុម័ត

ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិគឺជាកម្មវត្ថុទៅនឹងការអនុញ្ញាតដូចខាងក្រោម៖



១. ការអនុម័តរបស់ភាគហ៊ុនិករបស់ PIB សម្រាប់ការចុះបញ្ជីលក់មូលលត្រកម្មសិទ្ធិ ដែលធ្វើឡើងនៅក្នុងមហាសន្និបាតវិសាមញ្ញ នៅប្រទេសម៉ាឡេស៊ី ទទួលបាននៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០

២. ការអនុម័តរបស់ គ.ម.ក សម្រាប់ការចុះបញ្ជីលក់មូលលត្រកម្មសិទ្ធិ និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

៣. ការអនុម័តរបស់ ធ.ម.ក សម្រាប់ការចុះបញ្ជីលក់មូលលត្រកម្មសិទ្ធិ និង

៤. ការអនុម័តរបស់អាជ្ញាធរ/ដៃគូពាក់ព័ន្ធ ប្រសិនបើតម្រូវ៕

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា



១១. ការព្រមព្រៀងរបស់អ្នកជំនាញ



១. កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរពីសំណាក់ សវនករ និងគណនេយ្យករវាយការណ៍ សម្រាប់ការដាក់បញ្ចូលឈ្មោះរបស់ខ្លួន របាយការណ៍គណនេយ្យ និងរាល់អំណះអំណាងទាំងអស់ដែលភ្ជាប់មកជាមួយទម្រង់ និងខ្លឹមសារដែលមាននៅក្នុងឯកសារផ្តល់ពត៌មាននេះ ត្រូវបានផ្តល់ឱ្យមុនពេលឯកសារផ្តល់ពត៌មាននេះត្រូវបានបោះផ្សាយ និងមិនមានការលុបចោលកិច្ចព្រមព្រៀងនាពេលក្រោយ។

២. កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរពីសំណាក់ អ្នកស្រាវជ្រាវទីផ្សារឯករាជ្យ សម្រាប់ការដាក់បញ្ចូលឈ្មោះរបស់ខ្លួន របាយការណ៍ស្រាវជ្រាវទីផ្សារឯករាជ្យរបស់ខ្លួនក្នុងសេចក្តីសង្ខេប និងការដកស្រង់របាយការណ៍ក្នុងទម្រង់ និងខ្លឹមសារខាងលើដែលមាននៅក្នុងឯកសារផ្តល់ពត៌មាននេះ ត្រូវបានផ្តល់ឱ្យមុនពេលឯកសារផ្តល់ព័ត៌មាននេះត្រូវបានបោះផ្សាយ និងមិនមានការលុបចោលកិច្ចព្រមព្រៀងនាពេលក្រោយ៕

ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា



១២. ហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល នាយកប្រតិបត្តិ និងនាយកផ្នែកហិរញ្ញវត្ថុ

លោក Lim Pay Chuan ប្រធានក្រុមប្រឹក្សាភិបាលប្រតិបត្តិ	ហត្ថលេខា	០៦-កក្កដា-២០២០ កាលបរិច្ឆេទ
លោក Lim Ah Hock អភិបាលប្រតិបត្តិ	ហត្ថលេខា	០៦-កក្កដា-២០២០ កាលបរិច្ឆេទ
លោក Han Fatt Juan អភិបាលប្រតិបត្តិ/នាយកប្រតិបត្តិ	ហត្ថលេខា	០៦-កក្កដា-២០២០ កាលបរិច្ឆេទ
លោក Tan Pu Hooi អភិបាលប្រតិបត្តិ	ហត្ថលេខា	០៦-កក្កដា-២០២០ កាលបរិច្ឆេទ
ឯកឧត្តម ងាវ អានសាន អភិបាលឯករាជ្យ	ហត្ថលេខា	០៦-កក្កដា-២០២០ កាលបរិច្ឆេទ
លោកស្រី Teh Bee Choo នាយកផ្នែកហិរញ្ញវត្ថុ	ហត្ថលេខា	០៦-កក្កដា-២០២០ កាលបរិច្ឆេទ

ឧបសម្ព័ន្ធ

១. ក្រមសីលធម៌វិជ្ជាជីវៈ

២. សេចក្តីសង្ខេបប្រតិបត្តិនៃរបាយការណ៍ស្រាវជ្រាវទីផ្សារឯករាជ្យ

៣. របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩

៤. របាយការណ៍ហិរញ្ញវត្ថុត្រួតពិនិត្យក្នុងគ្រាសម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

៥. លិខិតបញ្ជាក់ពីភាពត្រឹមត្រូវនៃព័ត៌មាន

ក្រមសីលធម៌វិជ្ជាជីវៈ
ក្រុមហ៊ុន ផេសថិក (ខេមបូឌា)

គុណតម្លៃរួម

ក្នុងនាមជាបុគ្គលិកនៃសម្ព័ន្ធក្រុមហ៊ុន ផេសថិក (ខេមបូឌា) យើងប្តេជ្ញាក្នុងការធ្វើអ្វីដែលប្រកបទៅដោយភាពត្រឹមត្រូវ និងប្រកបដោយភាពផ្តែផ្តួរចំពោះរាល់ទិដ្ឋភាពទាំងអស់នៃការរស់នៅរបស់យើង មិនថានៅកន្លែងធ្វើការ នៅផ្ទះ និងកន្លែងផ្សេងទៀត។

យើងជឿជាក់ថា ក្រមសីលធម៌ ត្រូវតែផ្អែកទៅលើគុណតម្លៃដែលមានភាពចាំបាច់សម្រាប់ភាពជាអ្នកដឹកនាំផ្ទាល់ខ្លួន ដោយមិនគិតត្រឹម ការដឹកនាំ ការប្រព្រឹត្តិចំពោះ និងការបម្រើដល់អ្នកដទៃ។ យើងជឿជាក់ថា យើងចែករំលែកនូវគុណតម្លៃជារួម ដូចដែលបានបញ្ជាក់ខាងក្រោម :

ភាពត្រឹមត្រូវ/សេចក្តីស្មោះត្រង់	យើងជឿជាក់ថា សេចក្តីស្មោះត្រង់គឺជាលក្ខណៈសម្បត្តិ សីលធម៌ និងអធិប្បាយអំពីភាពវិជ្ជមាន និង គុណធម៌ផ្សេងទៀតដូចជា ភាពស្មោះត្រង់ សេចក្តីទុកចិត្ត និង សុចរិតភាព ដែលជាផ្នែកសំខាន់នៃចរិតលក្ខណៈរបស់យើង។
ទំនុកចិត្ត	យើងជឿជាក់ថា ទំនុកចិត្តគឺជា ការកំណត់សម្រាប់រង្វង់នៃទំនាក់ទំនង និងអន្តរកម្ម ឥទ្ធិពលសង្គម (ដែលបង្ហាញ ការទុកចិត្តនិង ភាពដែលគួរឱ្យទុកចិត្តបាន) ហេតុដូច្នេះភាពជា អ្នកដឹកនាំគឺជាការប្តេជ្ញាចិត្តដើម្បីផ្តល់នូវការគោរពពាក្យសន្យា។
សុចរិតភាព	យើងជឿជាក់ថា សុចរិតភាពគឺ ជាការប្តេជ្ញាចិត្តដែលមិនមានភាពសម្រុះសម្រួល និងជាការប្តេជ្ញាចិត្តដែលមិនមានការផ្លាស់ប្តូរ ប្រែប្រួល ដែលអាចទាយទុកជាមុន ដើម្បីគោរពទៅតាមគុណតម្លៃ និងគោលការណ៍សីលធម៌។ វាគឺជាផ្នែកធំមួយនៃចរិតលក្ខណៈល្អ ក្នុងការធ្វើអ្វីដែលល្អ និងត្រឹមត្រូវ ទោះបីជានៅពេលដែលគ្មាននរណាម្នាក់អង្កេតក៏ដោយ។
សមភាព	យើងជឿជាក់ថា សមភាពធ្វើឱ្យលើកកំរិតនូវ ឋានៈ តំណែង និងលក្ខខណ្ឌសម្រាប់ការអនុវត្តន៍ច្បាប់ បទបញ្ញា និងយុត្តិធម៌។

យុត្តធម៌	យើងជឿជាក់ថា យុត្តិធម៌គឺជា សម្មតិកម្ម ឬ ការសំរេចបាននូវការកែប្រែសីលធម៌ សនិទានភាព ច្បាប់ សមធម៌ និងភាពស្មើគ្នា។
ភាពស្មើគ្នា	យើងជឿជាក់ថា ភាពស្មើគ្នាគឺជា ភាពសមស្របមួយនៃការអនុវត្តន៍នូវការប្រព្រឹត្តរវាងអន្តរបុគ្គល ច្បាប់ និងនីតិវិធី។
ការមើលថែអ្នកដទៃ	យើងជឿជាក់ថា ការមើលថែអ្នកដទៃគឺជាសមត្ថភាពក្នុងការគិតគូរ ពីអ្នកដទៃមុនខ្លួនឯងនិងប្រព្រឹត្តទៅលើអ្នកដទៃតាមដែល យើងចង់ ឱ្យគេប្រព្រឹត្តិមកលើខ្លួន ដែលមិនបណ្តាយឱ្យមានមហិច្ឆតា អាត្មានិយម ការបោកបញ្ឆោត និងការសងសឹក។

ហេតុដូច្នេះហើយ យើងបានកំណត់យកចរិកលក្ខណៈដែលមានបទដ្ឋានខ្ពស់។ នៅទីបំផុត យើងប្រើតម្លៃទាំងនេះដើម្បីបង្កើតជាសារធាតុនៅក្នុងចរិតលក្ខណៈរបស់យើង និងដើម្បីកសាងភាពជឿជាក់ និងកេរ្តិ៍ឈ្មោះរបស់យើង ដែលអាចងាយសង្កេតបានតាមរយៈអាកប្បកិរិយាជាបុគ្គល និងជាក្រុម ហើយនិងជាក្រុមហ៊ុនមួយ។

ក្នុងការបម្រើអតិថិជនរបស់យើង និងទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ ឈ្មួញ និងអ្នកម៉ៅការ យើងខិតខំយកចិត្តទុកដាក់ពីផលប្រយោជន៍របស់ពួកគេជាជាងផលប្រយោជន៍ដ៏ទៃផ្សេងទៀតផ្ទាល់របស់ពួកយើង និងដើម្បីលើកកម្ពស់កេរ្តិ៍ឈ្មោះ និងទំនុកចិត្តរបស់ពួកគេមកលើយើង។ យើងប្តេជ្ញាចិត្តក្នុងការផ្តល់ជូននូវផលិតផល និងសេវាកម្មដ៏មានផលល្អ មានប្រសិទ្ធភាព និងល្អឥតខ្ចោះដោយគ្មានភាពលំអៀង។

ក្រមសីលធម៌

គ្រប់បុគ្គលិកទាំងអស់នៃ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ត្រូវ៖

- ប្រកាន់ខ្ជាប់ទៅនឹងច្បាប់ បទប្បញ្ញត្តិ និង សេចក្តីណែនាំដែលបានកំណត់។
- បដិសេធក្នុងការបង្ក ទទួលយក ឬផ្តល់សំណូក និង លើកទឹកចិត្តអ្នកដទៃឱ្យធ្វើទង្វើទាំងនេះ។
- បង្ហាញការទុកចិត្ត និង គួរឱ្យទុកចិត្តបាន។
- ត្រៀមខ្លួនដើម្បីពន្យល់ណែនាំអំពីការងាររបស់យើង និង ហេតុផលដែលនៅពីក្រោយការងារទាំងនោះ។
- ធ្វើការសម្រេចចិត្ត និង ធ្វើសកម្មភាពមិនលំអៀងនិងច្បាស់លាស់។
- គោរពការសម្ងាត់ ទាំងការសម្ងាត់ដែលបានចែង និង មិនបានចែង។
- មិនចូលរួមប្រព្រឹត្តអំពើបោកប្រាស់ក្លែងបន្លំ អំពើពុករលួយ ឬ បទឧក្រិដ្ឋ។
- រាប់អានអ្នកដទៃដោយការគោរព និង ភាពថ្លៃថ្នូរដោយគ្មានការរើសអើង ឬ ការបៀតបៀន។
- ទទួលយកឥរិយាបថបើកចំហ និង ស្មោះត្រង់ក្នុងគ្រប់ទិដ្ឋភាពទាំងអស់។

ព្រះរាជាណាចក្រកម្ពុជា
ផេសថិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA)
PLC
KINGDOM OF CAMBODIA

- បញ្ចេញសមត្ថភាពដ៏ល្អបំផុតរបស់យើងជាមួយនឹងស្តង់ដារខ្ពស់បំផុតក្នុងខណៈពេលដែលបន្តធ្វើឱ្យគុណភាពនៃផលិតផល និង សេវាកម្មរបស់យើងកាន់តែប្រសើរឡើង។
- ធ្វើកិច្ចការដោយស្មោះអស់ពីចិត្ត ហើយប្តេជ្ញាចិត្តដើម្បីប្រគល់កិច្ចការតាមការសន្យា។
- ស្មោះត្រង់រាល់កិច្ចការដែលខ្ញុំនិយាយ និង ធ្វើ។
- មិនត្រូវប្រកបមុខរបរ ឬ ធ្វើការងារផ្សេងទៀត ឬ ការងារឯករាជ្យណាមួយ ដោយគ្មានការយល់ព្រមពីក្រុមហ៊ុនឡើយ។



SMITH ZANDER INTERNATIONAL SDN BHD (1058128-V)
Suite 23-3, Level 23, Office Suite
Menara IMK
1 Jalan Kiara, Mont Kiara
50480 Kuala Lumpur, Malaysia
T +603 6211 2121

SMITH ZANDER

ក្រុមប្រឹក្សាភិបាល
ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក
ផ្ទះលេខ០៦ ផ្លូវ៥៨៨ សង្កាត់បឹងកក់២
ខណ្ឌទួលគោក រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

សូមគោរពជូន ៖

របាយការណ៍សង្ខេបនៃការស្រាវជ្រាវទីផ្សារឯករាជ្យ លើឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាជនឡាវ ពាក់ព័ន្ធនឹងការចុះបញ្ជីលក់ មូលបត្ររបស់ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក នៅក្នុង ផ្សារមូលបត្រកម្ពុជា ។

របាយការណ៍សង្ខេបនៃការស្រាវជ្រាវទីផ្សារឯករាជ្យលើឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាជនឡាវ ត្រូវបានរៀបចំឡើងដោយក្រុមហ៊ុន SMITH ZANDER INTERNATIONAL SDN BHD (ឥទៅកាត់ថា "ក្រុមហ៊ុន SMITH ZANDER") សម្រាប់បញ្ចូលក្នុងឯកសារផ្តល់ពត៌មាន នៃ **ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក**។

ជំនួស និងក្នុងនាមឱ្យក្រុមហ៊ុន SMITH ZANDER៖

DENNIS TAN
នាយកប្រតិបត្តិ

ផេសថិក (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

សេចក្តីសន្មតប្រតិបត្តិនៃរបាយការណ៍ស្រាវជ្រាវទីផ្សារឯករាជ្យ

សេចក្តីជូនដំណឹងអំពីកម្មសិទ្ធិបញ្ញា

មិនមានផ្នែកណាមួយនៃ**របាយការណ៍** ការស្រាវជ្រាវទីផ្សារឯករាជ្យនេះអាចត្រូវបានប្រគល់ ជួល លក់បន្ត ឬបង្ហាញដល់ភាគីមិនមែនអតិថិជន ឬភាគីផ្សេងទៀត ក្នុងទម្រង់ណាមួយក៏ដោយ សម្រាប់ហេតុផលពាណិជ្ជកម្ម ឬមិនមែនពាណិជ្ជកម្ម ដោយគ្មានការយល់ព្រមដោយផ្ទាល់ពី SMITH ZANDER។ បន្ថែមពីលើនេះទៅទៀត មិនមានផ្នែកណាមួយនៃរបាយការណ៍ការស្រាវជ្រាវទីផ្សារឯករាជ្យនេះ អាចត្រូវបានដកស្រង់ បង្កើតឡើងវិញ កែប្រែ សង្ខេប កែសម្រួល ផ្លាស់ប្តូរ ឬបំផ្លែង រក្សាទុកក្នុងប្រព័ន្ធដែលអាចទាញយក ឬបញ្ជូន ក្នុងទម្រង់ណាមួយ ឬដោយមធ្យោបាយណាមួយ តាមរយៈអេឡិចត្រូនិក គ្រឿងម៉ាស៊ីន ការថតចម្លង ការថតទុក ឬផ្សេងពីនេះ សម្រាប់គោលបំណងផ្សេងក្រៅពីការបោះផ្សាយរបស់ក្រុមហ៊ុន ផេសទិក (ខេមបូឌា) ម.ក ក្នុងផ្សារមូលបត្រកម្ពុជា ដោយមិនមានការយល់ព្រមដោយផ្ទាល់ពី SMITH ZANDER។

គ្រប់ផ្នែកនៃរបាយការណ៍ការស្រាវជ្រាវទីផ្សារឯករាជ្យនេះ ដែលប្រើប្រាស់ក្នុងការបោះផ្សាយរបស់តតីយជន ដែលការបោះផ្សាយនោះផ្អែកទៅលើខ្លឹមសារ ទោះជាទាំងស្រុង ឬដោយផ្នែក នៃរបាយការណ៍ការស្រាវជ្រាវ ទីផ្សារឯករាជ្យនេះក៏ដោយ ឬដែលខ្លឹមសារនៃរបាយការណ៍ការស្រាវជ្រាវទីផ្សារឯករាជ្យនេះត្រូវបានបញ្ចូលជាមួយអ្វីផ្សេង ត្រូវដកស្រង់ និងផ្តល់នូវប្រភពដល់ SMITH ZANDER។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់៖

SMITH ZANDER INTERNATIONAL SDN BHD
Suite 23-3, Level 23, Office Suite
Menara 1MK
1 Jalan Kiara, Mont' Kiara
50480 Kuala Lumpur
Tel: + 603 6211 2121
www.smith-zander.com

©17 December 2019, All rights reserved, **SMITH ZANDER INTERNATIONAL SDN BHD**

១ ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

រចនាសម្ព័ន្ធឧស្សាហកម្ម និងខ្សែច្រវាក់តម្លៃ

ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនី ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងរ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា។ ក្រសួងរ៉ែ និងថាមពល ទទួលខុសត្រូវជាចម្បងលើវិស័យថាមពលទាំងមូល និងទទួលបន្ទុកបង្កើត និងអនុវត្តគោលនយោបាយថាមពលយុទ្ធសាស្ត្រ ថាមពលអគ្គិសនី និងផែនការអភិវឌ្ឍន៍ថាមពលនានា។ បន្ថែមពីលើនេះ ក្រសួងរ៉ែ និងថាមពល ក៏ទទួលខុសត្រូវលើ ស្តង់ដារបច្ចេកទេស សុវត្ថិភាព និងបរិស្ថាន សម្រាប់វិស័យថាមពលដែរ។ អាជ្ញាធរអគ្គិសនីកម្ពុជា ទទួលខុសត្រូវលើការគ្រប់គ្រងទូទៅលើផ្នែកសេវាកម្ម និងការប្រើប្រាស់អគ្គិសនី។ ភ្នាក់ងារមួយនេះ ទទួលខុសត្រូវលើការត្រួតពិនិត្យ ណែនាំ និងសម្របសម្រួលប្រតិបត្តិករនៅក្នុងវិស័យថាមពល ដើម្បីអនុលោមតាមគោលនយោបាយ សេចក្តីណែនាំ និងស្តង់ដារបច្ចេកទេសដែលចេញដោយក្រសួងរ៉ែ និងថាមពល។ អាជ្ញាធរអគ្គិសនីកម្ពុជាក៏មានតួនាទី ផ្តល់ កែប្រែ ដកហូត ឬព្យួរ អាជ្ញាប័ណ្ណនានាសម្រាប់សេវាកម្មថាមពលអគ្គិសនី អនុម័តលើបញ្ហីផ្តែលក់អគ្គិសនី ចេញគោលការណ៍សម្រាប់គ្រប់គ្រង ដាក់ពិន័យ និងដោះស្រាយវិវាទពាក់ព័ន្ធនឹងសេវាកម្មថាមពលអគ្គិសនី និងការប្រើប្រាស់អគ្គិសនី។ អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញ និងអនុវត្តប្រភេទអាជ្ញាប័ណ្ណចំនួន ប្រាំបី (៨) ប្រភេទ ដូចខាងក្រោម៖

- **អាជ្ញាប័ណ្ណផលិតកម្ម**

  អាជ្ញាប័ណ្ណផលិតកម្ម ផ្តល់សិទ្ធិធ្វើសេវាកម្មផលិតអគ្គិសនីដោយមធ្យោបាយផលិតកម្មជាកំណត់មួយ។

- **អាជ្ញាប័ណ្ណបញ្ជូន**

  អាជ្ញាប័ណ្ណបញ្ជូន ផ្តល់សិទ្ធិធ្វើសេវាកម្មបញ្ជូនអគ្គិសនី។ អាជ្ញាប័ណ្ណបញ្ជូន ចែកចេញជា ពីរ (២) ប្រភេទ ដូចជា អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី និងអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស។

  អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី អាចផ្តល់ឱ្យចំពោះតែក្រុមហ៊ុនធ្វើសេវាកម្មបញ្ជូនអគ្គិសនីមួយដែលរដ្ឋទទួលខុសត្រូវ និងស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ។ អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ផ្តល់ឱ្យក្រុមហ៊ុនទាំងនោះនូវសិទ្ធិសម្រាប់ការបញ្ជូនអគ្គិសនីដល់ក្រុមហ៊ុនចែកចាយអគ្គិសនី និងដល់អ្នកប្រើប្រាស់ធំៗក្នុងព្រះរាជាណាចក្រកម្ពុជា។

  អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសផ្តល់ឱ្យនូវសិទ្ធិសម្រាប់សាងសង់ធ្វើជាម្ចាស់ និងដំណើរការមធ្យោបាយបញ្ជូនអគ្គិសនីដែលបានកំណត់ជាក់លាក់ក្នុងព្រះរាជាណាក្រកម្ពុជា សម្រាប់គោលដៅច្បាស់លាស់។

- **អាជ្ញាប័ណ្ណចែកចាយ**

  អាជ្ញាប័ណ្ណចែកចាយ ផ្តល់នូវសិទ្ធិសម្រាប់ធ្វើសេវាកម្មចែកចាយអគ្គិសនីក្នុងតំបន់ជាកំណត់មួយ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

- **អាជ្ញាប័ណ្ណរួម**

  អាជ្ញាប័ណ្ណរួម រួមបញ្ចូលនូវអាជ្ញាប័ណ្ណលើសពីមួយ (១) ប្រភេទ។ អាជ្ញាប័ណ្ណរួម អាចត្រូវបានចេញជូនចំពោះអគ្គិសនីកម្ពុជា និងប្រព័ន្ធទោល។ អាជ្ញាប័ណ្ណរួម ផ្តល់សិទ្ធសម្រាប់ផលិត បញ្ជូន បែងចែក ចែកចាយ និងលក់អគ្គិសនីឱ្យអ្នកប្រើប្រាស់។

- **អាជ្ញាប័ណ្ណបែងចែក**

  អាជ្ញាប័ណ្ណបែងចែក ផ្តល់សិទ្ធិក្នុងការចាត់ចែង គ្រប់គ្រង និងប្រតិបត្តិការលើមធ្យោបាយបែងចែកអគ្គិសនី ដើម្បីសម្របសម្រួល ការប្រគល់ និងការទទួលអគ្គិសនីពីប្រព័ន្ធផលិតកម្ម ប្រព័ន្ធបញ្ជូន និងប្រព័ន្ធចែកចាយ។

- **អាជ្ញាប័ណ្ណលក់ដុំ**

  អាជ្ញាប័ណ្ណលក់ដុំ ផ្តល់សិទ្ធិសម្រាប់ទិញអគ្គិសនីពីអ្នកកាន់អាជ្ញាប័ណ្ណផលិតកម្ម ឬ ពីប្រព័ន្ធអគ្គិសនីនៃប្រទេសជិតខាងណាមួយ ដើម្បីលក់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ ឬអ្នកប្រើប្រាស់ធំៗ នៅក្នុងប្រព័ន្ធអគ្គិសនីជាប់គ្នាមួយ។

- **អាជ្ញាប័ណ្ណលក់រាយ**

  អាជ្ញាប័ណ្ណលក់រាយ ផ្តល់ឱ្យនូវសិទ្ធិក្នុងការលក់អគ្គិសនីឱ្យអ្នកប្រើប្រាស់ក្នុងតំបន់ជាកំណត់មួយ។

- **អាជ្ញាប័ណ្ណសេវាកម្មបន្ត**

  អាជ្ញាប័ណ្ណសេវាកម្មបន្ត ផ្តល់ឱ្យនូវសិទ្ធិក្នុងការផ្គត់ផ្គង់សេវាកម្មអគ្គិសនីស្របតាមកិច្ចសន្យាបន្តជាមួយអ្នកដែលមានអាជ្ញាប័ណ្ណស្រាប់។

រចនាសម្ព័ន្ធឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា



ប្រភព៖ ក្រសួងរ៉ែ និងថាមពល និងការវិភាគរបស់ SMITH ZANDER

ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា (ប្រទេសកម្ពុជា) រួមមាន សកម្មភាពផលិត បញ្ជូន និងចែកចាយអគ្គិសនី។ អគ្គិសនីកម្ពុជា គឺជាក្រុមហ៊ុនផលិតអគ្គិសនី ដែលក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាម្ចាស់ទាំងស្រុង។ អគ្គិសនីកម្ពុជា ទទួលខុសត្រូវលើការផលិត បញ្ជូន និងចែកចាយអគ្គិសនីនៅក្នុងប្រទេសកម្ពុជា។ ក្រៅពីអគ្គិសនីកម្ពុជា ក្រុមហ៊ុនផលិតថាមពលឯករាជ្យ ("IPPs") ក្រុមហ៊ុនអគ្គិសនីឯកជន និងសហគ្រាសអគ្គិសនីជនបទដូចជា ក្រុមហ៊ុន ផៅវែរ ប្លែនមីសិន ឡាញ ក៏បានចូលរួមក្នុងអាជីវកម្មផ្គត់ផ្គង់អគ្គិសនីផងដែរ។

ខ្សែចង្វាក់ផ្គត់ផ្គង់អគ្គិសនី រួមបញ្ចូល ការផ្គត់ផ្គង់ប្រេងឥន្ធនៈ ការផលិតថាមពល ការបញ្ជូនទៅបណ្តាញអគ្គិសនី និងចែកចាយទៅកាន់អតិថិជន នៅពេលដែល៖

- **ការផ្គត់ផ្គង់ឥន្ធនៈ**

  ឥន្ធនៈ គឺជាវត្ថុធាតុដើមមួយដ៏សំខាន់ក្នុងការផលិតអគ្គិសនី។ ប្រទេសកម្ពុជាបានប្រើប្រាស់ថាមពលវារីអគ្គិសនីជាចម្បងក្នុងការផលិតអគ្គិសនី។ ប្រភពឥន្ធនៈដទៃទៀតរួមមាន ធ្យូងថ្ម ប្រេងម៉ាស៊ូត ប្រេងម៉ាស៊ីន ប្រេងជីវសាស្ត្រ និងពន្លឺព្រះអាទិត្យ។

- **ការផលិតថាមពល**

  នៅក្នុងប្រទេសកម្ពុជា ការផលិតថាមពលសម្រាប់ធ្វើការបញ្ជូនលើបណ្តាញជាតិបញ្ជូនអគ្គិសនីគឺត្រូវបាន ផលិតជាចម្បងដោយក្រុមហ៊ុនផលិតថាមពលឯករាជ្យ។ អគ្គិសនីកម្ពុជា និងអ្នកកាន់អាជ្ញាប័ណ្ណរួម ក៏ផលិតអគ្គិសនីផងដែរ។ ក្រុមហ៊ុនផលិតថាមពលឯករាជ្យ គឺជាក្រុមហ៊ុនឯកជនដែលទទួលបានសម្បទានសម្រាប់អភិវឌ្ឍន៍ ផ្តល់ហិរញ្ញប្បទានសាងសង់ ទទួលបានកម្មសិទ្ធិ និងប្រតិបត្តិរោងចក្រអគ្គិសនី។ ក្រុមហ៊ុនផលិតថាមពលឯករាជ្យផលិតអគ្គិសនីដែលត្រូវបានលក់ទៅឱ្យក្រុមហ៊ុនសេវាកម្មអគ្គិសនី និងអ្នកប្រើប្រាស់ចុងក្រោយមួយចំនួនធំដែលបានកំណត់។

PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ក្រុមហ៊ុនផលិតថាមពលឯករាជ្យចូលរួមតែក្នុងការផលិតអគ្គិសនីតែប៉ុណ្ណោះ។ ក្រុមហ៊ុនផលិតថាមពលឯករាជ្យ មិនទទួលបានអាជ្ញាប័ណ្ណពីរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ជូន ឬចែកចាយអគ្គិសនីដល់ប្រជាជនឡើយ។
ផ្ទុយពីនេះវិញ ក្រុមហ៊ុនផលិតថាមពលឯករាជ្យ ត្រូវបានអនុញ្ញាតឱ្យផលិត និងលក់អគ្គិសនីទៅឱ្យ អគ្គិសនីកម្ពុជា ស្របតាមកិច្ចព្រមព្រៀងទិញលក់ថាមពលនានា។ ប៉ុន្តែ អ្នកកាន់អាជ្ញាប័ណ្ណរួម ដែលរួមទាំងអគ្គិសនីកម្ពុជាផងដែរ អាចផលិតអគ្គិសនីដើម្បីផ្គត់ផ្គង់ឱ្យអតិថិជន តាមរយៈប្រព័ន្ធចែកចាយរបស់ខ្លួន។

- **ការបញ្ជូនទៅកាន់បណ្តាញអគ្គិសនី**

ការបញ្ជូន សំដៅដល់ការផ្ទេរអគ្គិសនីក្នុងទំហំធំពីរោងចក្រថាមអគ្គិសនី ទៅកាន់អនុស្ថានីយ៍អគ្គិសនី ដោយឆ្លងកាត់បណ្តាញបញ្ជូនដែលមានកម្រិតវ៉ុលខ្ពស់។ បណ្តាញបញ្ជូនដែលមានកម្រិតវ៉ុលខ្ពស់ទាំងនេះ ត្រូវបានដំណើរការដោយអគ្គិសនីកម្ពុជា ក្រុមហ៊ុន ស៊ីណូហាយដ្រូ កំចាយ ហាយដ្រូអេឡិកទ្រីក ប្រជេក ក្រុមហ៊ុន ខេមបូឌាន ផៅវ័រ ប្រ៊ីត ក្រុមហ៊ុន (ខេមបូឌា) ផៅវ័រ ទ្រែនមីសិន ឡាញ ក្រុមហ៊ុន ឆាយណា ហ៊ីរទាន ឡូវើរ ស្តឹងឫស្សីជ្រុំ ហាដ្រូ-អេឡិចទ្រីក ប្រជេក (ខេមបូឌា) ខមភេនី លីមីធីត ក្រុមហ៊ុន ខេមបូឌាន ទ្រែនមីសិន លីមីធីត ក្រុមហ៊ុន ស៊ីធីក អ៊ិនធើណេសិនណល ហាយដ្រូផៅវ័រ ឌីវេឡុបមេន ខមភេនី និង ក្រុមហ៊ុន ស៊ី.អេច.ឌី (ខេមបូឌា) ហាយដ្រូផៅវ័រ ឌីវេឡុបមេន។

- **ការចែកចាយទៅកាន់អតិថិជន**

អគ្គិសនីត្រូវបានចែកចាយតាមរយៈបណ្តាញប្រព័ន្ធចែកចាយមួយ ឱ្យទៅអតិថិជនជាចម្បងទៅក្នុងតំបន់ឧស្សាហកម្ម ពាណិជ្ជកម្ម និងលំនៅដ្ឋាន ដោយអ្នកកាន់អាជ្ញាប័ណ្ណចែកចាយនានា ដែលរួមមានអគ្គិសនីកម្ពុជាផងដែរ។
ប្រទេសកម្ពុជា ពឹងផ្អែកមួយផ្នែកលើការនាំចូលអគ្គិសនីពីប្រទេសវៀតណាម ថៃ និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាជនឡាវ ដែលថាមពលត្រូវបាននាំចូលក្នុងកម្រិតវ៉ុលមធ្យម។ ដូចនេះ អគ្គិសនីត្រូវបានផលិត បញ្ជូន និងចែកចាយពីប្រភពថាមពលជាច្រើន ឱ្យទៅអតិថិជន តាមរយៈប្រព័ន្ធផ្គត់ផ្គង់នានា រួមមានបណ្តាញថាមពលតភ្ជាប់ទៅកាន់ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅក្នុងប្រទេសវៀតណាម ថៃ និងឡាវ។ បណ្តាញចរន្តក្នុងប្រទេសកម្ពុជាមានដូចខាងក្រោម៖

- **បណ្តាញជាតិបញ្ជូនអគ្គិសនី**

បណ្តាញជាតិបញ្ជូនអគ្គិសនី ផ្តល់នូវការផ្គត់ផ្គង់ថាមពលអគ្គិសនី ទៅកាន់តំបន់នានាជុំវិញអនុស្ថានីយ៍បណ្តាញ។ ការផ្គត់ផ្គង់អគ្គិសនីតាមរយៈបណ្តាញជាតិបញ្ជូនអគ្គិសនី មាននៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត កណ្តាល កំពង់ស្ពឺ តាកែវ កំពត ព្រះសីហនុ កំពង់ចាម កំពង់ធំ ព្រៃវែង បន្ទាយមានជ័យ បាត់ដំបង សៀមរាប ពោធិ៍សាត់ និង កំពង់ឆ្នាំង។

- **បណ្តាញចរន្តប្រទេសវៀតណាម**

ការនាំចូលអគ្គិសនីពីប្រទេសវៀតណាម មានកំលាំង ២២ គីឡូវ៉ុល កាត់តាម ១៦ ទីតាំង នៅក្នុងខេត្តកំពង់ចាម ស្វាយរៀង កំពត មណ្ឌលគិរី កណ្តាល តាកែវ ប្រចេះ ព្រៃវែង និងរតនៈគីរី។ អគ្គិសនីក៏ត្រូវបាននាំចូលពីប្រទេសវៀតណាម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ក្នុងកំលាំង ២៣០ គីឡូវ៉ាត់ កាត់តាមបណ្តាញចរន្ត ប្រទេសវៀតណាម-តាកែវ-ភ្នំពេញ។ ការផ្គត់ផ្គង់អគ្គិសនីក្រោយមក ក៏ត្រូវបានពង្រីកដល់អ្នកកាន់អាជ្ញាប័ណ្ណ ដទៃទៀត។

- **បណ្តាញចរន្តប្រទេសថៃ**

  ការនាំចូលអគ្គិសនីពីប្រទេសថៃ មានកំលាំង ២២ គីឡូវ៉ុល កាត់តាម ប្រាំបី (៨) ទីតាំង នៅក្នុងខេត្តបាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ កោះកុង និងឧត្តរមានជ័យ។ អគ្គិសនីក៏ត្រូវបាននាំចូលពីប្រទេសថៃ ក្នុងកំលាំង ១១៥ គីឡូវ៉ុល កាត់តាម បណ្តាញចរន្តប្រទេសថៃ-បន្ទាយមានជ័យ-បាត់ដំបង និងសៀមរាប។ ក្រសួងរ៉ែ និងថាមពល ក៏បានផ្តល់ឱ្យក្រុមហ៊ុនឯកជនមួយចំនួន នូវសិទ្ធិក្នុងការទិញអគ្គិសនីពីអាជ្ញាធរអគ្គិសនីខេត្តនៃប្រទេសថៃសម្រាប់ផ្គត់ផ្គង់ក្នុងតំបន់ផ្សេងៗជិតព្រំប្រទល់ប្រទេសកម្ពុជា-ថៃផងដែរ។

- **បណ្តាញចរន្តប្រទេសឡាវ**

  ការនាំចូលអគ្គិសនីពីប្រទេសឡាវ មានកម្រិត ២២ គីឡូវ៉ុល ទៅកាន់តំបន់ខេត្តស្ទឹងត្រែង។

- **ប្រព័ន្ធផ្គត់ផ្គង់ទោល**

  ការផ្គត់ផ្គង់អគ្គិសនីនៃផ្នែកមួយចំនួនក្នុងប្រទេសកម្ពុជា គឺតាមរយៈប្រព័ន្ធផ្គត់ផ្គង់ទោល។ ប្រព័ន្ធផ្គត់ផ្គង់ទោលនីមួយៗ ផលិត និងផ្គត់ផ្គង់អគ្គិសនីផ្ទាល់ខ្លួន ឱ្យទៅតំបន់តូចៗ។ តំបន់ដែលត្រូវបាន ផ្គត់ផ្គង់អគ្គិសនី តាមរយៈប្រព័ន្ធផ្គត់ផ្គង់ទោល ស្ថិតនៅតាមបណ្តាខេត្តមួយចំនួនក្នុងប្រទេសកម្ពុជា រួមមានជាអាទិ៍ ខេត្តកំពង់ធំ ព្រះវិហារ សៀមរាប ក្រចេះ ឧត្តរមានជ័យ និងកំពង់ចាម។

អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន និងចែកចាយ ជាធម្មតាពឹងពាក់ក្រុមហ៊ុនវិស្វកម្មតតិយជន ដូចជា ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក សម្រាប់ដំណោះស្រាយលើបញ្ហាបច្ចេកទេស និងវិស្វកម្មប្រព័ន្ធថាមពល ដែលក្រុមហ៊ុនទាំងនេះមានភារៈកិច្ចរចនា អភិវឌ្ឍន៍ និង/ឬ ផ្គត់ផ្គង់ បញ្ជូន និងចែកចាយហេដ្ឋារចនាសម្ព័ន្ធ តភ្ជាប់អតិថិជន លំនៅដ្ឋាន ពាណិជ្ជកម្ម និងឧស្សាហកម្មទៅកាន់បណ្តាញជាតិបញ្ជូនអគ្គិសនី។ អ្នកប្រើប្រាស់ដែលជាឧស្សាហកម្មធំៗ ក៏ពឹងពាក់ក្រុមហ៊ុនវិស្វកម្មតតិយជនទាំងនេះផងដែរក្នុងការតំឡើងអនុស្ថានីយ៍អគ្គិសនីក្នុងទីតាំងប្រតិបត្តិការរបស់ខ្លួន។

ផេសថិក (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

ខ្សែចង្វាក់តម្លៃខស្សាហកម្ម នៃផ្នែកដំណោះស្រាយបច្ចេកទេស និងវិស្វកម្មប្រព័ន្ធថាមពល នៃខស្សាហកម្មផ្គត់ផ្គង់ អគ្គិសនីក្នុងប្រទេសកម្ពុជា



[a] *រួមបញ្ចូលអតិថិជនផ្នែកខស្សាហកម្មធំៗមានដូចជា ប្រតិបត្តិការរុករករ៉ែ រោងចក្រផលិតស៊ីម៉ង់ត៍ រោងចក្រផលិតដែក និងរោងចក្រចម្រាញ់*

ប្រភព៖ ក្រុមហ៊ុន SMITH ZANDER

សមត្ថភាពក្នុងការផលិត

ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងប្រទេសកម្ពុជា ទាញយកជាចម្បងពី រោងចក្រថាមពលវារីអគ្គិសនី ធ្យូងថ្ម និងប្រេងម៉ាស៊ូត ឬប្រេងម៉ាស៊ុន។ ប្រទេសកម្ពុជាក៏នាំចូលអគ្គិសនីពី ប្រទេសថៃ វៀតណាម និងឡាវផងដែរ។ ការផ្គត់ផ្គង់ថាមពលក្នុងប្រទេសកម្ពុជា ដូចដែលបានកម្រិតត្រឹមទំហំផលិតកម្មសរុប កើនឡើងពី ៥៦៩,០៤ ម៉ែកាវ៉ាត់ ក្នុងឆ្នាំ២០១១ ទៅ ២.១៨៦,៩៩ ម៉ែកាវ៉ាត់ ក្នុងឆ្នាំ២០១៨ ក្នុងអត្រាកំណើនប្រចាំឆ្នាំ (“អត្រាកំណើនប្រចាំឆ្នាំ”) ចំនួន ២១,២១% កើតឡើងពីកំណើននៃសមត្ថភាពផលិតរបស់រោងចក្រថាមពលធ្យូងថ្ម និងវារីអគ្គិសនី។ ចន្លោះឆ្នាំ២០១១ និង២០១៧ សមត្ថភាពផលិតរបស់រោងចក្រថាមពលធ្យូងថ្ម កើនឡើងពី ១៣,០០ ម៉ែកាវ៉ាត់ ទៅ ៥៥១,២០ ម៉ែកាវ៉ាត់ ក្នុងអត្រាកំណើនប្រចាំឆ្នាំដ៏ខ្លាំងក្លា ចំនួន ៧០,៨០%។ ស្របពេលជាមួយគ្នានេះ សមត្ថភាពផលិតរបស់រោងចក្រវារីអគ្គិសនី បានកើនឡើងពី ២០៧,០៦ ម៉ែកាវ៉ាត់ ទៅ ១,៣២៩,៧០ ម៉ែកាវ៉ាត់ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ៣០,៤៣%។ ប្រទេសកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងទៅលើវារីអគ្គិសនី ធ្យូងថ្ម និងប្រេងម៉ាស៊ូត/ប្រេងម៉ាស៊ុន សម្រាប់ផលិតថាមពល ដែលស្មើនឹង ៦០,៨០% ២៥,២០% និង១២,២០% រៀងគ្នានៃទំហំផលិតកម្មសរុបក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៨។

ដោយហេតុថាប្រទេសកម្ពុជានាំចូលនូវប្រេងម៉ាស៊ូត និងប្រេងម៉ាស៊ុនពីប្រទេសជិតខាង បញ្ជីថ្លៃលក់អគ្គិសនី ដែលផលិតពីប្រេងម៉ាស៊ូត និងប្រេងម៉ាស៊ុន គឺជាកម្មវត្ថុនៃការឡើងចុះតម្លៃ។ ដូចនេះហើយ វារីអគ្គិសនី និងធ្យូងថ្ម គឺជាប្រភពថ្មីសម្រាប់ការផលិតថាមពលនៅក្នុងប្រទេសកម្ពុជា។ គិតត្រឹមចុងឆ្នាំ២០១៨ ប្រទេសកម្ពុជាមាន រោងចក្រវារីអគ្គិសនីកំពុងដំណើរការសរុបចំនួន ដប់ (១០) និងរោងចក្រថាមពលធ្យូងថ្ម ចំនួន ពី (០២) កំពុងដំណើការ។

ក្រុមហ៊ុនឆាបក្រកម្ពុជា
ផេសធិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA)
PLC
KINGDOM OF CAMBODIA

សមត្ថភាពផលិតនៃវិស័យផ្គត់ផ្គង់អគ្គិសនីក្នុងប្រទេសកម្ពុជា [a]

ប្រភព	សមត្ថភាពផលិត (មេ៉ាវ៉ាត់)								អត្រាកំណើនប្រចាំឆ្នាំ (%)
	២០១១	២០១២	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨	
វារីអគ្គិសនី	២០៧,០៦	២២៥,៤៣	៦៨៣,៤៣	៩២៩,៤៣	៩២៩,៧០	៩៣០,០០	៩៧៩,៧០	១.៣២៩,៧០	៣០,៤៣
ប្រេងម៉ាស៊ូត និងប្រេងម៉ាស៊ីន	៣៤២,៤៨	៣២១,០១	៣២៣,៩៩	២៩១,២៧	៣០៤,៦៣	៣០៤,២២	២៩៥,១៤	២៦៦,៨២	-៣,៥០
ប្រេងជីវសាស្ត្រ	៦,៥០	២២,៥០	១៤,៥៧	២២,៦៤	១៩,៩៥	១៧,៥៧	២៨,៥៧	២៩,២៧	២៣,៩៨
ធ្យូងថ្ម	១៣,០០	១៣,០០	១៣៣,០០	២៦៨,០០	៤០៣,០០	៤២៩,២០	៥៦៤,២០	៥៥១,២០	៧០,៨០
ពន្លឺព្រះអាទិត្រ	-	-	-	-	-	-	១០,០០	១០,០០	-
សរុប	**៥៦៩,០៤**	**៥៨១,៩៤**	**១.១៥៤,៩៩**	**១.៥១១,៣៤**	**១.៦៥៧,២៧**	**១,៦៨០.៩៩**	**១,៨៧៧.៦១**	**២.១៨៦,៩៩**	**២១,២១**

[a] គិតត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

ប្រភព៖ អាជ្ញាធរអគ្គិសនីកម្ពុជា ការវិភាគរបស់ក្រុមហ៊ុន SMITH ZANDER

នៅចន្លោះឆ្នាំ២០១១ និង២០១៨ ទំហំនៃការផលិតក្នុងប្រទេសកម្ពុជាបានកើនឡើងពី ១.០១៨,៥៤ ជីកាវ៉ាត់ម៉ោង ទៅ ៨.១៧២,២៧ ជីកាវ៉ាត់ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ៣៤,៦៥%។ ដើម្បីបន្តបង្កើនការផ្គត់ផ្គង់ អគ្គិសនីនៅក្នុងប្រទេសកម្ពុជាបាននាំចូលអគ្គិសនីពីប្រទេសវៀតណាម ថៃ និងឡាវ។ ក្នុងឆ្នាំ២០១៨ អគ្គិសនី ពីប្រទេសវៀតណាមមានចំនួន ៦៩,៦៤% នៃការនាំចូលអគ្គិសនីក្នុងប្រទេសកម្ពុជា ខណៈដែលប្រទេសថៃ និងឡាវ មានចំនួន ២៦,១៧% និង ៤,១៨% ។ ស្របពេលដែលប្រទេសកម្ពុជានៅតែពឹងផ្អែកលើការនាំចូលអគ្គិសនីពីប្រទេសវៀតណាម ថៃ និងឡាវ ការពឹងផ្អែកនេះបាននឹងកំពុងថយចុះ ដោយការនាំចូល បានថយចុះពី ១.៨២៩,៧៨ ជីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០១១ ទៅ ១.៥៦៦,៥១ ជីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០១៨។ ក្នុងឆ្នាំ២០១៨ អគ្គិសនីនាំចូលមានចំនួនប្រហែល ១៦,០៩% នៃការផ្គត់ផ្គង់អគ្គិសនីសរុបក្នុងប្រទេសកម្ពុជា បើធៀបទៅនឹងឆ្នាំ២០១១ ដែលចំនួនអគ្គិសនីនាំចូលមានចំនួនប្រហែល ៦៤,២៤% នៃការផ្គត់ផ្គង់អគ្គិសនីសរុបក្នុងប្រទេសកម្ពុជា។

ការនាំចូលអគ្គិសនីរបស់ប្រទេសកម្ពុជា [a]

ឆ្នាំ	ទំហំនៃការផលិតរបស់ប្រទេសកម្ពុជា (ជីកាវ៉ាត់)	នាំចូល (ជីកាវ៉ាត់ម៉ោង)			សរុប (ជីកាវ៉ាត់ម៉ោង)
		វៀតណាម	ថៃ	ឡាវ	
២០១១	១.០១៨,៥៤	១.៣៩២,៣៩	៤៣០,៧៩	៦,៦០	២.៨៤៨,៣២
២០១២	១.៤២៣,១០	១.៥៦០,២៣	៥៣៥,០៨	៩,០១	៣.៥២៧,៤២
២០១៣	១.៧៦៩,៩៦	១.៦៩១,៣១	៥៧៩,៥៩	១០,៧៣	៤.០៥១,៥៩
២០១៤	៣.០៥៨,៣៦	១.២៦៥,៧២	៥២៣,៥៥	១៣,៧៧	៤.៨៦១,៤០
២០១៥	៤.៤៨៩,២៧	១.២០០,៣៩	៣០៧,៣៩	១៨,៣១	៦.០១៥,៣៦
២០១៦	៥.៤៨២,៩៦	១.១៧៧,១២	៣៣៥,៦៦	៣៧,៤១	៧.០៣៣,១៥
២០១៧	៦.៦៣៣,៦៩	១.០៩៤,៦៦	២៩០,៩៣	៥៣,៥៦	៨.០៧២,៨៤
២០១៨	៨.១៧២,២៧	១.០៩០,៩៨	៤០៩,៩៨	៦៥,៦៦	៩.៧៣៨,៧៨
អត្រាកំណើនប្រចាំឆ្នាំ (%)	**៣៤,៦៥%**	**-៣,៤២%**	**-0,៧0%**	**៣៨,៨១%**	**១៩,២0%**

[a] *គិតត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩*

ប្រភព៖ អាជ្ញាធរអគ្គិសនីកម្ពុជា ការវិភាគរបស់ ក្រុមហ៊ុន SMITH ZANDER

ចលការនៃការវិកចម្រើន និងផែនការពង្រីកសមត្ថភាពផលិតនាពេលអនាគត

ផែនការអភិវឌ្ឍថាមពល (២០០៨-២០២១) រៀបរាប់នូវយុទ្ធសាស្ត្រជាតិសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍន៍ លទ្ធភាពនៃការផលិត បញ្ជូន និងជួញដូរថាមពលជាមួយនឹងប្រទេសជិតខាង។ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តក្នុងការបង្កើន តំណភ្ជាប់អគ្គិសនី នៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា។ ហេតុដូចនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ ទិសដៅចំនួន ពីរ (២) ដំណាក់កាល ក្នុងការធ្វើអគ្គិសនីភាវូបនីយកម្មក្នុងតំបន់ជនបទតាមរយៈក្រសួងរ៉ែ និងថាមពល។ ដំណាក់កាលទីមួយ រាជរដ្ឋាភិបាលបានចេញនូវដាក់ទិសដៅថា ភូមិទាំងអស់ក្នុងប្រទេសកម្ពុជា នឹងមានការផ្គត់ផ្គង់អគ្គិសនីត្រឹមឆ្នាំ២០២០។ ដំណាក់កាលទីពីរ រាជរដ្ឋាភិបាលបានដាក់ចេញនូវទិសដៅថា យ៉ាងតិច ៧0% នៃលំនៅដ្ឋានទាំងអស់ មានការផ្គត់ផ្គង់នូវបណ្តាញអគ្គិសនីដែលមានគុណភាពត្រឹមឆ្នាំ២០៣0។

ប្រទេសកម្ពុជាប្រឈមនឹងឧបសគ្គលើការផ្គត់ផ្គង់ថាមពលដែលមានទំនុកចិត្ត។ ប្រទេសកម្ពុជាស្ថិតនៅក្នុងចំណុចមួយដែលតម្លៃ និងការទទួលបានអគ្គិសនីប្រើប្រាស់ បាននឹងកំពុងរាំងស្ទះដល់ការរីកលូតលាស់នៃវិស័យផលិតកម្មរបស់ជាតិ។ ក្រសួងរ៉ែ និងថាមពល ព្យាករថា តម្រូវការថាមពលនឹងកើនឡើងជាងពីរ (២) ដង រវាងឆ្នាំ២០១២ និង២០២0។ យោងទៅលើ បច្ចុប្បន្នភាពផែនការនៃការអភិវឌ្ឍន៍អគ្គិសនី អោងចក្រអគ្គិសនីពន្លឺព្រះអាទិត្រចំនួនពីរ (២) ស្មើនឹងកំលាំងសរុប ១២0 ម៉ែកាវ៉ាត់ ព្រមទាំង អោងចក្រថាមពលធ្យូងថ្ម ចំនួនប្រាំមួយ (៦) ជាមួយនឹង លទ្ធភាពផលិតស្មើនឹង ១.៩៥0 ម៉ែកា

PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

វ៉ាត់ និងរោងចក្រវារីអគ្គិសនីចំនួនពីរ (២) ជាមួយនឹងលទ្ធភាពផលិតស្មើនឹង ៣៤០ ម៉េកាវ៉ាត់ ដែលកំពុងស្ថិតក្រោមការសាងសង់ និងរំពឹងថានឹងត្រូវដាក់ឱ្យដំណើរការ នៅចន្លោះឆ្នាំ២០២០ និង២០៣០។

ផែនការពង្រីកការផលិតថាមពលរបស់រដ្ឋាភិបាលសម្រាប់ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីនៅក្នុងប្រទេសកម្ពុជា ដែលរំពឹងថានឹងត្រូវដាក់ឱ្យដំណើរការនៅចន្លោះឆ្នាំ២០២០ និង២០៣០

ឈ្មោះគម្រោង	ប្រភេទឥន្ធនៈ	សមត្ថភាពផលិត (ម៉េកាវ៉ាត់)	គោលដៅឆ្នាំប្រតិបត្តិការ
ឧទ្យានថាមពលអគ្គិសនីពន្លឺព្រះអាទិត្យ	ពន្លឺព្រះអាទិត្យ	៦០	២០២០
ឧទ្យានថាមពលអគ្គិសនីពន្លឺព្រះអាទិត្យ	ពន្លឺព្រះអាទិត្យ	៦០	២០២០
រោងចក្រថាមពលធ្យូងថ្ម ខេមបូឌា អ៊ិនធើរណេសិ្សណល អ៊ិនវេស្តមែន ឌីវើឡុបមែន គ្រុប	ធ្យូងថ្ម	៣៥០	២០២៣
ពោធិសាត់១	វារីអគ្គិសនី	៨០	២០២៣
រោងចក្រថាមពលធ្យូងថ្ម ខេមបូឌា អ៊ិនធើរណេសិ្សណល អ៊ិនវេស្តមែន ឌីវើឡុបមែន គ្រុប	ធ្យូងថ្ម	៣៥០	២០២៤
សេសានក្រោម៣	វារីអគ្គិសនី	២៦០	២០២៥
រោងចក្រថាមពលធ្យូងថ្ម	ធ្យូងថ្ម	២០០	២០២៧
រោងចក្រថាមពលធ្យូងថ្ម២	ធ្យូងថ្ម	១២០	២០២៨
រោងចក្រថាមពលធ្យូងថ្ម៣	ធ្យូងថ្ម	២៥០	២០២៩
រោងចក្រថាមពលធ្យូងថ្ម៤	ធ្យូងថ្ម	២៥០	២០៣០

ប្រភព៖ អគ្គិសនីកម្ពុជា

សមត្ថភាពបញ្ជូន និងចែកចាយចរន្ត

ការរីកចម្រើនផ្នែកដំណោះស្រាយបច្ចេកទេស និងវិស្វកម្មប្រព័ន្ធថាមពល នៃឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីក្នុងប្រទេសកម្ពុជា គឺពឹងផ្អែកលើការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយចរន្តនៅក្នុងប្រទេស។ ក្នុងប្រទេសកម្ពុជា អគ្គិសនីត្រូវបានផលិត បញ្ជូន និងចែកចាយ ពីប្រភពថាមពលជាច្រើនទៅកាន់អតិថិជនតាមរយៈបណ្តាញជាតិ បញ្ជូនអគ្គិសនីដែលមានវ៉ុលខ្ពស់ បណ្តាញបញ្ជូនអគ្គិសនីប្រទេសវៀតណាមដែលមានវ៉ុលមធ្យម បណ្តាញបញ្ជូនអគ្គិសនីប្រទេសថៃដែលមានវ៉ុលមធ្យម បណ្តាញបញ្ជូនអគ្គិសនីប្រទេសឡាវដែលមានវ៉ុលមធ្យម និងប្រព័ន្ធផ្គត់ផ្គង់ទោលផ្សេងៗទៀត។

បណ្តាញបញ្ជូនត្រូវបានប្រើប្រាស់សម្រាប់ការផ្ទេរអគ្គិសនី ដែលផលិតចេញពីរោងចក្រថាមពលអគ្គិសនីទៅកាន់អនុស្ថានីយ៍។ បន្ទាប់មកទៀត អគ្គិសនីត្រូវបានផ្ទេរពីប្រព័ន្ធបញ្ជូនទៅកាន់អ្នកប្រើប្រាស់ចុងក្រោយតាមរយៈបណ្តាញចែកចាយ។ ការរីកចម្រើននៃបណ្តាញបញ្ជូន និងចែកចាយក្នុងប្រទេសកម្ពុជា ជួយទ្រទ្រង់ដល់ការរីកចម្រើននៃហេដ្ឋារចនាសម្ព័ន្ធ

ផែនទីដោយក្រុមហ៊ុន
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ផលិតថាមពលនៅក្នុងប្រទេស។ ការរីកចម្រើននៃឧស្សាហកម្មចែកចាយថាមពលក្នុងប្រទេសកម្ពុជា ត្រូវបានតំណាងដោយការរីកចម្រើនរបស់ប្រទេសទៅលើសមត្ថភាពប្រព័ន្ធបញ្ជូននៅចន្លោះឆ្នាំ២០១១ និង ២០១៨។ ប្រវែងសរុបនៃបណ្តាញបញ្ជូនក្នុងប្រទេសកម្ពុជាបានកើនឡើងពី ៥៥៧,០៣ គីឡូម៉ែត្រ ក្នុងឆ្នាំ២០១១ ទៅ ២.០៣១,០៤ គីឡូម៉ែត្រ ក្នុងឆ្នាំ២០១៨ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ២០.៣០%។ ក្នុងរយៈពេលដដែលគ្នានោះ បណ្តាញបញ្ជូនមានកម្រិត ២៣០ គីឡូវ៉ុល ដែលត្រូវបានចាត់ទុកថាជាអត្រារីកចម្រើនខ្លាំងបំផុត បានកើនឡើងពី ១៨១.០០ គីឡូម៉ែត្រ ទៅ ១.២២៣,៨៨ គីឡូម៉ែត្រ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ៣១.៤០%។ ក្នុងឆ្នាំ ២០១៨ ប្រទេសកម្ពុជា មានអនុស្ថានីយ៍បញ្ជូនចរន្តសរុប ៦១ ជាមួយនឹងសមត្ថភាព ២.៦៨៦,៣០ ម៉ែកាវ៉ុលអំពែរ (“MVA”)។ ចំនួនអនុស្ថានីយ៍ផ្ទេរចរន្តក្នុងប្រទេសកម្ពុជា បានកើនឡើងពី ៦៧២,៣០ ម៉ែកាវ៉ុលអំពែរ ក្នុងឆ្នាំ២០១១ ទៅ ២.៦៨៦,៣០ មេកាវ៉ុលអំពែរ ក្នុងឆ្នាំ២០១៨ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ២១,៨៨%។

សមត្ថភាពនៃប្រព័ន្ធបញ្ជូនចរន្តក្នុងប្រទេសកម្ពុជា[a]

	២០១១	២០១២	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨	អត្រាកំណើនប្រចាំឆ្នាំ (%)
	បណ្តាញបញ្ជូនថាមពលអគ្គិសនី (គីឡូម៉ែត)								
១១៥ គីឡូវ៉ុល	៣៧៦,០៣	៣៩៥,៤២	៤៣២,៦៧	៤៣២,៦៧	៤៩៧,៦៧	៤៩៧,៦៧	៧៧៧,៦៧	៨០៧,១៦	១១,៥៣
២៣០ គីឡូវ៉ុល	១៨១,០០	៦០៦,៣៨	៨៦៤,១៨	៨៦៤,១៨	៩៥០,១៨	៩៥០,១៨	១.១៩២,១៨	១.២២៣,០៤	៣១,៤០
សរុប	**៥៥៧,០៣**	**១.០០១,៨០**	**១.២៩៦,៨៥**	**១.២៩៦,៨៥**	**១.៤៤៧,៨៥**	**១.៤៤៧,៨៥**	**១.៩៦៩.៨៥**	**២.០៣១,០៤**	**២០,៣០**
	អនុស្ថានីយ៍បញ្ជូនថាមពលអគ្គិសនី								
ចំនួន	១៦	២០	៣១	៣៣	៤១	៤៥	៤៥	៦១	២១,០៧
សមត្ថភាពបញ្ជូន (ម៉ែកាវ៉ុលអំពែរ)	៦៧២,៣០	៩៦២,៣០	១.៣៣៧,៣០	១.៥៦៥,០០	២.១២២,៣០	២.៣២២,៣០	២.៥៥០,០០	២.៦៨៦,៣០	២១,៨៨

[a] គិតត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

ប្រភព៖ អជ្ញាធរអគ្គិសនីកម្ពុជា ការវិភាគរបស់ ក្រុមហ៊ុន SMITH ZANDER

បណ្តាញចែកចាយអគ្គិសនី ជាទូទៅមានកម្រិតវ៉ុលមធ្យម ២២ គីឡូវ៉ុល និងកម្រិតវ៉ុលទាប ០,៤ គីឡូវ៉ុល ឬ ០,២២ គីឡូវ៉ុល។ ការរីកចម្រើននៃឧស្សាហកម្មចែកចាយថាមពលក្នុងប្រទេសកម្ពុជា តំណាងដោយការពង្រីកប្រវែងនៃបណ្តាញចែកចាយចន្លោះឆ្នាំ២០១១ និងឆ្នាំ២០១៧។ ប្រវែងសរុបរបស់បណ្តាញចែកចាយអគ្គិសនីកម្ពុជា បានកើនឡើងពី ៥.៧៨៤ សឺឃីតគីឡូម៉ែត្រ (“cct km”) ក្នុងឆ្នាំ២០១១ ទៅ ១៨.៨៣៩ cct km ក្នុងឆ្នាំ២០១៧ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ២១,៧៥%។ ស្របពេលគ្នានោះ ខេត្តក្រចេះជាខេត្តដែលមានអត្រារីកចម្រើនខ្ពស់ជាងគេ ដែលបណ្តាញចែកចាយក្នុងខេត្តមួយនេះបានកើនឡើងពី ៤៧ cct km ទៅ ៥៥២ cct km ក្នុងអត្រាកំណើនប្រចាំឆ្នាំ ៥០,៧៧%។ តារាងខាងក្រោមបង្ហាញទីតាំងកំពូលចំនួន ប្រាំ (៥) ដែលមានប្រវែងសរុបនៃបណ្តាញចែកចាយខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៧។

បរិក្ខារចែកចាយរបស់ប្រព័ន្ធអគ្គិសនីកម្ពុជា នៅក្នុងប្រទេសកម្ពុជា[a]

តំបន់	បណ្តាញចែកចាយ (cct km)							អត្រាកំណើនប្រចាំឆ្នាំ (%)
	២០១១	២០១២	២០១៣	២០១៤	២០១៥	២០១៦	២០១៧	
រាជធានីភ្នំពេញ និងខេត្តកណ្តាល	២.០៥៨	២.៥៧៣	៣.៥៨៦	៣.៧៧៩	៤.១៨៧	៤.៤២១	៤.៦៤៧	១៤,៥៤
ខេត្តបាត់ដំបង	៦៤៣	៦៤៣	៦៩២	៦៩១	៦៩៦	២.២៧៦	២.៤៦៥	២៥,១០
ខេត្តសៀមរាប	៦២៦	៦៥៨	៧៣៦	៨០៨	១.១២៩	១.៣០៩	២.៣៥៦	២៤,៧២
ខេត្តកំពង់ចាម	១៤៤	១៤៥	១៥០	៦៦៧	៧៣២	៨៤៥	១.០២៤	៣៨,៦៧
ក្រុងព្រះស៊ីហនុ	២៩៨	២៩៨	៣០៤	៣៦២	៥០៣	៨៨៩	៩៨៤	២២,០៣
ផ្សេងៗ [b]	១.៧៥៣	២.២១១	៣.៤៨០	៤.៥៩៥	៤.៧៤០	៦.៣៤២	៧.៣៦៣	២៤,១១
សរុប [c]	**៥.៧៨៥**	**៦.៨០០**	**៩.២១៦**	**១០.៨៣៨**	**១១.៦២២**	**១៦.១២៧**	**១៨.៨៣៩**	**២១,៧៥**

[a] *ព័ត៌មានផ្សព្វផ្សាយត្រឹមថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ (ទិន្នន័យសម្រាប់ឆ្នាំ ២០១៨ មិនទាន់មានជាសាធារណៈនៅឡើយ)*

[b] *ផ្សេងៗរួមមានខេត្តកំពង់ស្ពឺ កំពង់ចាម ពញាក្រែក មេមត់ កំពត កំពង់ត្រាច បន្ទាយមានជ័យ មង្គលបុរី ស្ទឹងត្រែង រតនគីរី ព្រៃវែង បាវិត កែវសីមា ក្រចេះ និងស្វាយ*

[c] *តួរលេខទាំងនេះអាចនឹងមិនបូកបញ្ចូលគ្នា ដោយសារការបង្គត់*

ប្រភព៖ អគ្គិសនីកម្ពុជា ការវិភាគរបស់ ក្រុមហ៊ុន SMITH ZANDER



ចលកវង្វៃការរីកចម្រើន និងផែនការពង្រីកសមត្ថភាពបញ្ជូន និងចែកចាយថាមពលនាពេលអនាគត

រាជរដ្ឋាភិបាលបានអនុវត្តផែនការ និងការផ្តួចផ្តើមមួយចំនួនដើម្បីបង្កើនការអភិវឌ្ឍន៍វិស័យថាមពលនៅក្នុងប្រទេសកម្ពុជា។ ផែនការ និងការផ្តួចផ្តើមទាំងនេះ រួមមានផែនការតំណាញ់អគ្គិសនីក្នុងតំបន់ជនបទ និងផែនការអភិវឌ្ឍន៍ថាមពល។ ក្រោមទិសដៅជាតិ រាជរដ្ឋាភិបាលមានគោលបំណងពង្រីងប្រព័ន្ធបញ្ជូនក្នុងប្រទេសកម្ពុជាក្នុងចំនួន ២០ ដង នៃចំនួន ពី ១២០ គីឡូម៉ែត្រ ក្នុងឆ្នាំ២០០១ ទៅ ២.៥៨២ គីឡូម៉ែត្រ ត្រឹមឆ្នាំ២០២០។ គិតត្រឹមចុងឆ្នាំ២០១៨ ប្រវែងសរុបនៃបណ្តាញបញ្ជូនៅក្នុងប្រទេសកម្ពុជា មានចំនួន ២.០៣១,០៤ គីឡូម៉ែត្រ។ ដើម្បីបំពេញតម្រូវការគោលដៅជាតិ ក្នុងការពង្រីងប្រព័ន្ធបញ្ជូនចរន្តក្នុងប្រទេសកម្ពុជា ប្រព័ន្ធបញ្ជូនប្រវែង ៥៥០,៩៦ គីឡូម៉ែត្រ គួរត្រូវបានសាងសង់បន្ថែមទៀត ដើម្បីឱ្យប្រព័ន្ធបញ្ជូនចរន្តរបស់ប្រទេសកម្ពុជា ឈានដល់ប្រវែង ២.៥៨២ គីឡូម៉ែត្រ ត្រឹមឆ្នាំ២០២០។

គោលដៅថ្នាក់ជាតិសម្រាប់ការពង្រីកសមត្ថភាពបញ្ជូនក្នុងប្រទេសកម្ពុជា



ប្រភព៖ ក្រសួងរ៉ែ និងថាមពល និង ការវិភាគរបស់ ក្រុមហ៊ុន SMITH ZANDER

ផែនការតំណាញ់អគ្គិសនីក្នុងតំបន់ជនបទ មានគោលដៅលើកកំពស់ការគ្រប់ដណ្តប់តំណាញ់អគ្គិសនីក្នុងតំបន់ជនបទ។ ប្រជាជនកម្ពុជានឹងមានអគ្គិសនីប្រើប្រាស់ក្នុងតម្លៃសមរម្យ សម្រាប់ការប្រើប្រាស់ជាលក្ខណៈ សេដ្ឋកិច្ច សង្គមកិច្ច និងគ្រួសារ។ វាត្រូវបានរំពឹងថានឹងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើក ទឹកចិត្តដល់វិស័យឯកជន ឱ្យចូលរួមផ្តល់សេវាកម្មតំណាញ់អគ្គិសនីប្រកបដោយចីរភាព ហើយជាពិសេស តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មី និងបច្ចេកវិទ្យាថាមពលកកើតឡើងវិញ។ ដើម្បីសម្រួលដល់កិច្ចការនេះ មូលនិធិតំណាញ់អគ្គិសនីត្រូវបានបង្កើតឡើង ដើម្បីបង្កើនការអភិវឌ្ឍន៍តំណាញ់អគ្គិសនីក្នុងប្រទេសកម្ពុជា។ មូលនិធិតំណាញ់អគ្គិសនីក្នុងតំបន់ជនបទ បច្ចុប្បន្នស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា។ ព្រះរាជក្រឹត្យបានចែងថា អាណត្តិរបស់មូលនិធិតំណាញ់អគ្គិសនីក្នុងតំបន់ជនបទ គឺមានរហូតដល់មូលនិធិតំណាញ់អគ្គិសនីក្នុងតំបន់ជនបទ សម្រេចបានគោលដៅ ដូចមានចែងក្នុងគោលនយោបាយរដ្ឋាភិបាលស្តីអំពីតំណាញ់អគ្គិសនី។ ប្រភពនៃមូលនិធិនៃតំណាញ់អគ្គិសនីក្នុងតំបន់ជនបទ ទទួលបានពី៖

ក្រុមហ៊ុនសាងសង់ក្រុងភ្នំពេញ
ផែនដីក
(ខេមបូឌា) ខ.ក
PESTECH (CAMBODIA)
PLC
KINGDOM OF CAMBODIA

- កញ្ចប់ថវិកាសង្គម ផ្តល់នៅក្នុងបញ្ជីផ្ទៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា និងការបរិច្ចាគនានារបស់ អគ្គិសនីកម្ពុជា
- ការបរិច្ចាគ និងអំណោយហិរញ្ញវត្ថុ ដែលត្រូវសន្មតថាអាចទទួលយកបានដោយ ក្រសួងរ៉ែ និងថាមពល និងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង
- ប្រភពផ្សេងៗពីរដ្ឋាភិបាលកម្ពុជា។

ឧទាហរណ៍នៃកម្មវិធីដែលត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជា ក្រោមមូលនិធិតំណភ្ជាប់អគ្គិសនីក្នុងតំបន់ជនបទ ក្នុងឆ្នាំ ២០១៨ មាន៖

- **ការផ្តល់ថាមពលសម្រាប់ប្រជាជនក្រីក្រ**

  កម្មវិធីផ្តល់ថាមពលសម្រាប់ប្រជាជនក្រីក្រ មានគោលដៅជួយដល់ក្រុមគ្រួសារក្រីក្រនៅតាមតំបន់ជនបទ ដោយ ផ្តល់ឱ្យ និងមានការប្រើប្រាស់អគ្គិសនីពីបណ្តាញផ្គត់ផ្គង់។ កម្មវិធីនេះនឹងផ្តល់ឱ្យនូវប្រាក់កម្ចីដែលគ្មានការប្រាក់ សម្រាប់ការចំណាយនានា រួមមាន តម្លៃតភ្ជាប់បណ្តាញរបស់អ្នកផ្គត់ផ្គង់អគ្គិសនី ប្រាក់កក់ សម្រាប់អ្នកផ្គត់ផ្គង់ អគ្គិសនី ការទិញសម្ភារៈ និងកំលាំងពលកម្មសម្រាប់តំឡើងខ្សែភ្លើង ពីចំនុចភ្ជាប់ទៅកាន់លំនៅដ្ឋាន និងការទិញ សម្ភារៈ និងកំលាំងពលកម្មសម្រាប់តំឡើងខ្សែភ្លើងនៅក្នុងលំនៅដ្ឋាន។ ហើយប្រាក់កម្ចី គឺមិនឱ្យលើសពី ៤៨0.000 ខ្មែរ រៀល (“KHR”) ក្នុងមួយលំនៅដ្ឋានឡើយ។ ក្នុងកំឡុងឆ្នាំ២០១៨ គ្រួសារនៅជនបទចំនួន ២៥៧គ្រួសារ នៅក្នុងខេត្ត កោះកុង និងខេត្តតាកែវបានទទួលអត្ថប្រយោជន៍ដោយផ្ទាល់ពីកម្មវិធីនេះ។
- **កម្មវិធីសម្រាប់ផ្តល់ជំនួយដល់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីនៅក្នុងតំបន់ជនបទ**

  កម្មវិធីផ្តល់ជំនួយសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីក្នុងតំបន់ជនបទ មានគោលដៅជួយដល់អ្នកផ្គត់ផ្គង់ អគ្គិសនីឯកជននៅក្នុងតំបន់ជនបទ ក្នុងការទទួលបានអាជ្ញាប័ណ្ណស្របច្បាប់ដើម្បីទទួលបានមូលនិធិ សម្រាប់ពង្រីក ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីដើម្បីគ្របដណ្តប់ដល់តំបន់ ដែលត្រូវបានអនុញ្ញាតឱ្យចែកចាយនានា។ ទាំងនេះនឹង អនុញ្ញាតឱ្យក្រុមគ្រួសារនៅតំបន់ជនបទទាំងអស់ទទួល បានអគ្គិសនីប្រើប្រាស់។ ក្នុងកំឡុងឆ្នាំ២០១៨ អ្នកកាន់អាជ្ញាប័ណ្ណចំនួន ១0៦ (ស្មើនឹងប្រវែង ១.៦៨៩,៤៥ គីឡូម៉ែត្រ) បានទទួលផលប្រយោជន៍ដោយផ្ទាល់ពីកម្មវិធីនេះ។

នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីគឺជាចំណុចផ្តោតសំខាន់ ហើយដែលការ អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាក់ស្តែងត្រូវបានចាត់ទុកថាជាចំណុចគួរយកចិត្តទុកដាក់។ ផែនការអភិវឌ្ឍយុទ្ធសាស្ត្រថ្នាក់ជាតិ (២០១៤-២០១៨) ក៏ត្រូវបានកំណត់យកឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនី ជាអាទិភាពចម្បងដែរ។ រដ្ឋាភិបាលកម្ពុជា កំពុងផ្តល់អាទិភាពលើការពង្រីកបន្ថែមនៃ ការអភិវឌ្ឍន៍ថាមពលកម្រិតខ្ពស់ និងការធ្វើប្រសើរឡើងនៃប្រព័ន្ធបញ្ជូន និង ចែកចាយថាមពល ដែលមានតម្លៃទាប។ រាជធានីភ្នំពេញគឺជាតំបន់សំខាន់ដោយហេតុថាវាជាមជ្ឈមណ្ឌលសេដ្ឋកិច្ចនៃ ប្រទេសកម្ពុជា។ រដ្ឋាភិបាលដាក់ចេញនូវគោលដៅថ្នាក់ជាតិ សម្រាប់បង្កើនសមត្ថភាពប្រព័ន្ធបញ្ជូនថាមពលនៅក្នុង ប្រទេសកម្ពុជា ទៅដល់ ២.៦៧១ គីឡូម៉ែត្រ ត្រឹមឆ្នាំ២០២៥ រួមមាន បណ្តាញបញ្ជូនថាមពលកម្រិត ១១៥ គីឡូវ៉ុល ប្រវែង ៨២៧ គីឡូម៉ែត្រ បណ្តាញបញ្ជូនថាមពលកម្រិត ២៣0 គីឡូវ៉ុល ប្រវែង ១.៤២៦ គីឡូម៉ែត្រ និងបណ្តាញបញ្ជូនថាមពល កម្រិត ៥00 គីឡូវ៉ុល ប្រវែង ៣៨៨ គីឡូម៉ែត្រ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ផែនការពង្រីកការបញ្ជូនថាមពលរបស់រដ្ឋាភិបាលសម្រាប់ឧស្សាហកម្មផ្តល់ផ្តង់អគ្គិសនីនៅក្នុងប្រទេសកម្ពុជា

គម្រោង	ប្រវែង (គីឡូម៉ែត)	គោលដៅឆ្នាំប្រតិបត្តិការ
បណ្តាញបញ្ជូនថាមពលអគ្គិសនី ១១៥ គីឡូវ៉ុល		
ស្ថានីយ៍បណ្តាញបញ្ជូនទី ២ - ស្ថានីយ៍បណ្តាញសួនច្បារសម្តេចហ៊ុន សែន និងអនុស្ថានីយ៍	៥	២០១៩
ស្ថានីយ៍បណ្តាញរតនៈ មណ្ឌល - ស្ថានីយ៍នបណ្តាញប៉ៃលិន	៤៥	២០១៩
ស្ថានីយ៍បណ្តាញបញ្ជូនទី ៣ - ស្ថានីយ៍បណ្តាញទួលគោក	៥	២០១៩
ស្ថានីយ៍បណ្តាញបញ្ជូនទី ៥ - ស្ថានីយ៍បណ្តាញជ្រោយចង្វារ	១៨	២០១៩
ស្ថានីយ៍បណ្តាញខេត្តកំពង់ចាម - ស្ថានីយ៍បណ្តាញព្រែកប្រសប់(ខេត្តក្រចេះ)	៩១	២០១៩
ស្ថានីយ៍បណ្តាញស្វាយអន្ទរ - ស្ថានីយ៍កំពង់សៀង	៥៦	២០១៩
ស្ថានីយ៍បណ្តាញក្រុងព្រះស៊ីហនុ - ស្ថានីយ៍រាម	១២	២០១៩
ស្ថានីយ៍បណ្តាញរាម - ស្ថានីយ៍ចំការលួង	៦០	២០១៩
ស្ថានីយ៍បណ្តាញខេត្តកំពង់ធំ - ស្ថានីយ៍បណ្តាញខេត្តព្រះវិហា	១៤០	២០១៩
បណ្តាញបញ្ជូនក្រោមដីពី បណ្តាញបញ្ជូនទី ១ - ស្ថានីយ៍បណ្តាញការិយាល័យកណ្តាលអគ្គិសនីកម្ពុជា - ស្ថានីយ៍បណ្តាញសួនច្បារសម្តេចហ៊ុនសែន - ស្ថានីយ៍បណ្តាញកីឡារដ្ឋានអូឡាំពិក - ស្ថានីយ៍បណ្តាញ NCC - ស្ថានីយ៍បណ្តាញទី ៣	១៤	២០២០
ស្ថានីយ៍បណ្តាញព្រែកប្រសព្វ - ស្ថានីយ៍បណ្តាញខេត្តក្រចេះ	៣០	២០២១
ស្ថានីយ៍បណ្តាញក្រលាញ់ - ស្ថានីយ៍បណ្តាញខេត្តឧត្តរមានជ័យ	៨០	២០២២
ស្ថានីយ៍បណ្តាញចំការលួង - រោងចក្រភារីអគ្គិសនីគិរីរម្យ III	៣០	២០២៤
ស្ថានីយ៍បណ្តាញកំពត - ស្ថានីយ៍បណ្តាញជីប ម៉ុង	៤៦	២០២៤
ស្ថានីយ៍បណ្តាញច្រកម្ទេស - ស្ថានីយ៍បណ្តាញពញ្ញាក្រែក	៧៥	២០២៥
ស្ថានីយ៍បណ្តាញពញ្ញាក្រែក - ស្ថានីយ៍បណ្តាញសួង	៤៥	២០២៥
ស្ថានីយ៍បណ្តាញ ៧ - ស្ថានីយ៍បណ្តាញកោះធំ	៤០	២០២៥
ស្ថានីយ៍បណ្តាញកោះធំ - ស្ថានីយ៍បណ្តាញតាកែវ	៤៥	២០២៥
Total	**៨២៧**	
បណ្តាញបញ្ជូនថាមពលអគ្គិសនី ២៣០ គីឡូវ៉ុល		
ស្ថានីយ៍បណ្តាញខេត្តបាត់ដំបង - ស្ថានីយ៍បណ្តាញខេត្តសៀមរាបភាគខាងកើត - ស្ថានីយ៍បណ្តាញខេត្តកំពង់ធំ - ស្ថានីយ៍បណ្តាញខេត្តកំពង់ចាម	៣៥០	២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ខ្សែបណ្តាញភ្នំពេញ (ដំណាក់កាលទី២) (ភ្នំពេញខាងជើង - ជ្រោយចង្វារ - ភ្នំពេញខាងកើត - ភ្នំពេញខាងជើង)	៩៦	២០១៩
រោងចក្រវារីអគ្គិសនីតាតៃ - រាជធានីភ្នំពេញ	១៨២	២០១៩
ស្ថានីយ៍បណ្តាញខេត្តកោះកុង - ស្ថានីយ៍បណ្តាញក្រុងកោះកុង	២០	២០១៩
ស្ថានីយ៍បណ្តាញចំការលួង - ស្ថានីយ៍បណ្តាញបទុមសារគរ	៥៤	២០១៩
ស្ថានីយ៍បណ្តាញបទុមសារគរ - រោងចក្រវារីអគ្គិសនីតាតៃ	៧០	២០១៩
ស្ថានីយ៍បណ្តាញខេត្តក្រចេះ - ស្ថានីយ៍បណ្តាញខេត្តមណ្ឌលគីរី	១៧០	២០១៩
ស្ថានីយ៍បណ្តាញខេត្តរតនគីរី - ស្ថានីយ៍បណ្តាញខេត្តស្ទឹងត្រែង	១២០	២០១៩
ស្ថានីយ៍បណ្តាញបែកចាន - ស្ថានីយ៍បណ្តាញទី៥ - NCC	២០	២០២១
ស្ថានីយ៍បណ្តាញ ៤ - ស្ថានីយ៍បណ្តាញកំពង់ស្ពឺ (ថ្មី) - ស្ថានីយ៍បណ្តាញកំពង់ស្ពឺ	៤៨	២០២១
ស្ថានីយ៍បណ្តាញស្ទឹងហាវ - ស្ថានីយ៍បណ្តាញអូរត្រែស	១៦	២០២១
ស្ថានីយ៍បណ្តាញសួង - ស្ថានីយ៍បណ្តាញស្វាយអន្ទរ	៤៥	២០២១
ស្ថានីយ៍បណ្តាញ ២ - ស្ថានីយ៍បណ្តាញព្រែកហូរ	១៥	២០២១
ស្ថានីយ៍បណ្តាញ ៥ - ស្ថានីយ៍បណ្តាញសែនសុខ	៦	២០២២
ស្ថានីយ៍បណ្តាញស្ទឹងត្រែង - ស្ថានីយ៍បណ្តាញខេត្តសៀមរាបខាងជើង	២០០	២០២៥
ស្ថានីយ៍បណ្តាញខ្តេត្តសៀមរាបខាងជើង - ស្ថានីយ៍បណ្តាញខេត្តសៀមរាបខាងកើត	៤៤	២០២៥
សរុប	**១.៤៥៦**	
បណ្តាញបញ្ជូនថាមពលអគ្គិសនី ៥០០ គីឡូវ៉ុល		
ស្ថានីយ៍បណ្តាញចំការលួង - ស្ថានីយ៍បណ្តាញបែកចាន	១៩៨	២០១៩
ស្ថានីយ៍បណ្តាញស្ទឹងត្រែង - ស្ថានីយ៍បណ្តាញព្រំដែនប្រទេសឡាវ	៥៥	២០២១
ស្ថានីយ៍បណ្តាញបែកចាន - ស្ថានីយ៍បណ្តាញភ្នំពេញខាងកើត	៤៥	២០២១
ស្ថានីយ៍បណ្តាញភ្នំពេញខាងកើត - ស្ថានីយ៍បណ្តាញសួង	៩០	២០២២
សរុប	**៣៨៨**	

ប្រភព៖ អគ្គិសនីកម្ពុជា និងក្រសួងរ៉ែ និងថាមពល

ធនាគារពិភពលោក ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី និងដៃគូរអភិវឌ្ឍន៍នានា បាននឹងកំពុងសម្របសម្រួលការជួយទ្រទ្រង់របស់ខ្លួនចំពោះការនាំមកនូវថាមពល ដែលមានតម្លៃសមរម្យទៅកាន់ក្រុមគ្រួសារនៅក្នុងតំបន់ជនបទដើម្បីលើកតម្កើនកំណើនសេដ្ឋកិច្ច។ ចំណុចយកចិត្តទុកដាក់នៃការជួយទ្រទ្រង់ផ្នែកតំណាភ្ជាប់អគ្គិសនីក្នុងតំបន់ជនបទរបស់ធនាគារពិភពលោកនៅក្នុងប្រទេសកម្ពុជា រួមមាន៖

- ធ្វើឱ្យប្រសើរឡើងវិញនូវប្រសិទ្ធភាព និងចំនុកចិត្តនៃវិស័យថាមពល
- កាត់បន្ថយតម្លៃអគ្គិសនី ធ្វើឱ្យប្រសើរឡើងនៃជីវភាពរស់នៅ និង
- លើកតម្កើនកំណើនសេដ្ឋកិច្ច។

ទាំងនេះអាចទទួលជោគជ័យបានដោយការពង្រីកតំណាភ្ជាប់អគ្គិសនីនៅតំបន់ជនបទ និងអ្នកផ្គត់ផ្គង់ថាមពលឯទៃទៀត និងពង្រឹងស្ថាប័នអគ្គិសនីនានា ខណៈជំរុញក្របខណ្ឌបទប្បញ្ញត្តិ និង “លក្ខខណ្ឌបរិស្ថាន” សម្រាប់ពាណិជ្ជភាវូបនីយកម្ម វិស័យថាមពល។

រាជរដ្ឋាភិបាលកម្ពុជា មានគោលដៅពង្រីកយុទ្ធសាស្ត្រតំណាភ្ជាប់អគ្គិសនីក្នុងតំបន់ជនបទរបស់ខ្លួន ដើម្បីធានាថា គ្រប់ភូមិទាំងអស់ទទួលបានអគ្គិសនីប្រើប្រាស់ត្រឹមឆ្នាំ២០២០ រួមមាន ការទទួលបានពីបណ្តាញថាមពលតូចៗ និងអគ្គិសនីក្រៅពីបណ្តាញថាមពល ហើយ ៧០% នៃរាល់ក្រុមគ្រួសារនឹងមានអគ្គិសនីប្រើប្រាស់ត្រឹមឆ្នាំ២០៣០។ បច្ចុប្បន្ន ធនាគារពិភពលោក កំពុងគាំទ្រគម្រោង ពីរ (២) មានដូចជា គម្រោងតំណាភ្ជាប់អគ្គិសនី និងការបញ្ជូនចរន្តថាមពលក្នុងតំបន់ជនបទ និងគម្រោងពាណិជ្ជកម្មថាមពលនៃអនុតំបន់មេគង្គ។

ធនាគារពិភពលោកបានប្តេជ្ញាផ្តល់ឱ្យនូវឥណទានចំនួន ៤០ លានដុល្លារអាមេរិក សម្រាប់គម្រោងតំណាភ្ជាប់អគ្គិសនី និងការបញ្ជូនចរន្តថាមពលក្នុងតំបន់ជនបទ។ គម្រោងតំណាភ្ជាប់អគ្គិសនី និងការបញ្ជូនចរន្តថាមពលក្នុងតំបន់ជនបទ គឺជាគម្រោងរួមគ្នានៃម្ចាស់ជំនួយនានាដូចជា ធនាគារពិភពលោក ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងធនាគារអភិវឌ្ឍន៍អាស៊ី។ បន្ថែមពីលើគម្រោងតំណាភ្ជាប់អគ្គិសនី និងការបញ្ជូនចរន្តថាមពលក្នុងតំបន់ជនបទ ធនាគារពិភពលោកបានជួយគាំទ្ររដល់គម្រោងពាណិជ្ជកម្មថាមពលនៃអនុតំបន់ មេគង្គ ជាមួយនឹងទឹកប្រាក់ចំនួន ១៨,៥ លានដុល្លារអាមេរិក សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដើម្បីការបញ្ជូនចរន្តអគ្គិសនីពីប្រទេសឡាវ មកខេត្តស្ទឹងត្រែងនៃប្រទេសកម្ពុជា។ គម្រោងនេះនឹងអាចផ្គត់ផ្គង់អគ្គិសនីទៅកាន់មជ្ឈមណ្ឌលផ្ទុកថាមពលសំខាន់ក្នុងរាជធានីភ្នំពេញ នៅពេលដែលបណ្តាញ បញ្ជូនចរន្តគោលត្រូវបានបញ្ចប់។ នៅក្នុងខែមីនា ឆ្នាំ២០១១ រដ្ឋាភិបាលកម្ពុជាបន្តប្តេជ្ញាវិនិយោគ នូវទឹកប្រាក់ចំនួន ៥០០ លានដុល្លារ អាមេរិក សម្រាប់រយៈពេលប្រាំ (៥) ឆ្នាំបន្ទាប់ក្នុងការអភិវឌ្ឍន៍បណ្តាញបញ្ជូនចរន្តថាមពល ដើម្បីបញ្ជូនថាមពលពីរោងចក្រវារីអគ្គិសនី និងរោងចក្រអគ្គិសនីដទៃទៀត ទៅកាន់អ្នកប្រើប្រាស់តាមលំនៅដ្ឋាន នៅក្នុងប្រទេស។ ផ្អែកលើពត៌មានដែលមានជាសាធារណៈ ទឹកប្រាក់វិនិយោគសរុបចំនួន ២៧៨,៦០ លានដុល្លារអាមេរិកត្រូវបានប្រើប្រាស់សម្រាប់គម្រោង ពង្រីកសមត្ថភាពនៃការបញ្ជូន និងចែកចាយថាមពលនៅក្នុងប្រទេសកម្ពុជា។

ក្រសួងរ៉ែ និងថាមពល
(ផែនដី) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

យន្តការសម្រាប់ផ្តល់អគ្គិសនីគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការអគ្គិសនី ដែលរំពឹងថានឹងកើនឡើងក្នុងរយៈពេលវែង រួមមាន៖

- ការអភិវឌ្ឍន៍ផែនការពង្រីកការផលិត និងបញ្ជូន
- ការជួញដូរបន្តនៃថាមពលជាមួយនឹងប្រទេសជិតខាងនានា និង
- ការអនុវត្តកម្មវិធីតំណភ្ជាប់អគ្គិសនីនៅក្នុងខេត្ត និងតំបន់ជនបទ។

ដើម្បីទ្រទ្រង់យន្តការទាំងនេះ ហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយថាមពលក្នុងប្រទេសកម្ពុជា ត្រូវតែពង្រីកឱ្យបានគ្រប់គ្រាន់។ ទាំងនេះនឹងធ្វើឱ្យមានការកើនឡើងយ៉ាងខ្លាំងលើការចំណាយលើការបញ្ជូន និងចែកចាយថាមពល ដែលជាបន្ទុករបស់រដ្ឋាភិបាល ប៉ុន្តែនឹងផ្តល់អត្តប្រយោជន៍ដល់តួអង្គខស្សាហកម្មនានា ដែលផ្តល់ដំណោះស្រាយផ្នែកវិស្វកម្មប្រព័ន្ធថាមពល និងបច្ចេកទេស ។

គោលដៅវិនិយោគដែលត្រូវបានជ្រើសរើសនៅក្នុងខស្សាហកម្មផ្គត់ផ្គង់អគ្គិសនីក្នុងប្រទេសកម្ពុជា [a]

ប្រភេទគម្រោង	គោលដៅវិនិយោគ (លានដុល្លារអាមេរិក)
គម្រោងថាមពលអគ្គិសនីក្នុងតំបន់ជនបទ (ពីមុនជា គម្រោងថាមពលអគ្គិសនីសាកល្បងក្នុងតំបន់ជនបទ)	៦,១
វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ	២៤,៤
គម្រោងពង្រីកប្រព័ន្ធបញ្ជូន និងចែកចាយក្រុងភ្នំពេញ ដំណាក់កាលទី ២ (i)	៣៤,0
គម្រោងតំណភ្ជាប់អគ្គិសនី និងការបញ្ជូនចរន្តថាមពលក្នុងតំបន់ជនបទ	៤0,0
គម្រោងវិស័យពង្រីកអនុបញ្ជូនវ៉ុលខ្នាតមធ្យម (ពីមុនជា គម្រោងតំណភ្ជាប់អគ្គិសនីក្នុងតំបន់ជនបទ)	៥៥,0
ការអភិវឌ្ឍន៍បណ្តាញបញ្ជូនអគ្គិសនី ២៣0 គីឡូវ៉ុល ពីខេត្តព្រះសីហនុ តាកែវ និងកំពត ទៅរាជធានីភ្នំពេញ	១១៩,១
សរុប	**២៧៨,៦0**

[a] *តារាងគម្រោងនេះមិនមានលក្ខណៈពេញលេញទេ ប៉ុន្តែបានកំណត់យកនូវការវិនិយោគធំៗក្នុងវិស័យខស្សាហកម្មផ្គត់ផ្គង់អគ្គិសនីកាលបរិច្ឆេទវិនិយោគមិនមានជាសារធារណៈនៅឡើយ*

ប្រភព៖ ធនាគារពិភពលោក Cambodian Business Review និងការវិភាគរបស់ ក្រុមហ៊ុន SMITH ZANDER

ឆ្លាតាជាណាបម្រុកម្ពុជា
ផេសទីក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ការប្រើប្រាស់ថាមពលអគ្គិសនី

អគ្គិសនីគឺជាធាតុផ្សំហេដ្ឋារចនាសម្ព័ន្ធសំខាន់មួយសម្រាប់កំណើនសេដ្ឋកិច្ច និងជាធាតុផ្សំសំខាន់សម្រាប់សកម្មភាព ផលិតកម្ម។ អគ្គិសនីជួយដល់បណ្តាសេវាកម្ម និងផលិតផលជាច្រើន ដែលធ្វើឱ្យជីវិតប្រសើរឡើង បង្កើនផលិតកម្ម និងលើកតម្កើនសកម្មភាពជំនួញ។ ដូចនេះហើយ ការប្រើប្រាស់អគ្គិសនីមានទំនាក់ទំនងវិជ្ជមានយ៉ាងខ្លាំងជាមួយនឹងផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ (“GDP”) ។ ការរីកចម្រើនសេដ្ឋកិច្ចនៃប្រទេសមួយ នាំមកនូវការកើនឡើងនៃការប្រើប្រាស់ អគ្គិសនីក្នុងមនុស្សម្នាក់។

ផលិតផលក្នុងស្រុកសរុបនៃប្រទេសកម្ពុជាកើនឡើង ៦២.៧៦% ពី ៣២,៥៥ ទ្រីលានរៀល ក្នុងឆ្នាំ២០១១ ទៅ ៥២,៩៨ ទ្រីលានរៀល ក្នុងឆ្នាំ២០១៨។ មូលនីធិហិរញ្ញវត្ថុអន្តរជាតិ ប៉ាន់ប្រមាណថាផលិតផលក្នុងស្រុកសរុប នៃប្រទេសកម្ពុជានឹងកើនឡើងដល់ ៥៦,៥៧ ទ្រីលានរៀល ក្នុងឆ្នាំ២០១៩។ ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ នៃប្រទេសកម្ពុជាកើនឡើង ៤៧,១៦% ពី ២,២៩ លានរៀល ក្នុងឆ្នាំ២០១១ ទៅ ៣,៣៧ លានរៀល ក្នុងឆ្នាំ២០១៨។ ចន្លោះឆ្នាំ២០១១ និង ២០១៨ តម្រូវការអគ្គិសនីក្នុង មនុស្សម្នាក់ នៃប្រទេសកម្ពុជា កើនឡើងពី ១៧៦,១៥គីឡូវ៉ាត់ក្នុងមួយម៉ោង (“kWh”) ទៅ ៥៣២,៣១ kWh កើតចេញពីលទ្ធផលនៃនិន្នាការកំណើនប្រជាជន នគរូបនីយកម្ម និង ស្តានភាពសកលភាវូបនីយកម្ម។

ព្រះរាជាណាចក្រកម្ពុជា
ផេសធិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ការប្រើប្រាស់អគ្គិសនីក្នុងមនុស្សម្នាក់ និងផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់នៃប្រទេសកម្ពុជា [a]



[a] គិតត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

ប្រភព៖ អាជ្ញាធរអគ្គិសនីកម្ពុជា ស្ថាប័នជាតិស្ថិតិនៃប្រទេសកម្ពុជា មូលនិធិរូបិយវត្ថុអន្តរជាតិ ការវិភាគរបស់ SMITH ZANDER

ប្រទេសកម្ពុជាមានសកម្មភាពសេដ្ឋកិច្ចសំខាន់ៗចំនួនបី (៣) ដូចជា វិស័យឧស្សាហកម្ម សេវាកម្ម និងកសិកម្ម។ ចន្លោះឆ្នាំ២០១១ និងឆ្នាំ២០១៨ វិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ក្នុងប្រទេសកម្ពុជា មានអត្រាកំណើនមធ្យមប្រចាំឆ្នាំ ១,៤៩% ១០,៦១% និង៧,៥៩% រៀងគ្នា។ វិស័យឧស្សាហកម្ម មានកំណើនខ្ពស់ជាងគេ កើនឡើងពី ៩,២៦ ទ្រីលានរៀល ក្នុងឆ្នាំ២០១១ ទៅ ១៨,៧៦ ទ្រីលានរៀល ក្នុងឆ្នាំ២០១៨។ វិស័យឧស្សាហកម្ម រំពឹងថានឹងប្រើប្រាស់អគ្គិសនីច្រើនជាងគេបើធៀបនឹងវិស័យកសិកម្ម។ ហេតុដូចនេះ កំណើនវិស័យឧស្សាហកម្ម ត្រូវបានរំពឹងថានឹងបង្កើនតម្រូវការអគ្គិសនីនៅក្នុងប្រទេសទាំងមូល។

ក្រុមហ៊ុនវិស្វកម្មប៉ែស្ទិច (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

ផលិតផលក្នុងស្រុកសរុបផ្អែកលើសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា[a]

ឆ្នាំ	កសិកម្ម (ពាន់លានរៀល)	ឧស្សាហកម្ម (ពាន់លានរៀល)	សេវាកម្ម (ពាន់លានរៀល)
២០១១	៨.៥៦៧,០	៩.២៥៩,៣	១២.៤៤៩,០
២០១២	៨.៩៣៥,៩	១០.១២៣,៨	១៣.៤៥៧,៨
២០១៣	៩.០៧៥,៩	១១.២៣០៩,៧	១៤.៦២៥,៩
២០១៤	៩.១០១,៤	១២.៣៤០,៦	១៥.៩០៣,៣
២០១៥	៩.១១៩,៩	១៣.៧៨៧,៨	១៧.០២៦,៦
២០១៦	៩.២៤០,៦	១៥.២៨៥,១	១៨.១៨១,៦
២០១៧	៩.៤០១,២	១៦.៧៨១,៥	១៩.៤៥៧,២
២០១៨	៩.៥០៤,៥	១៨.៧៥៩,១	២០.៧៧២,៥
អត្រាកំណើនប្រចាំឆ្នាំ (%)	**១,៤៩**	**១០,៦១**	**៧,៥៩**

[a] គិតត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

ប្រភព៖ ស្ថាប័នជាតិស្ថិតិ និងការវិភាគរបស់ ក្រុមហ៊ុន SMITH ZANDER

ចន្លោះឆ្នាំ២០១១ និង២០១៨ តម្រូវការអគ្គិសនីក្នុងប្រទេសកម្ពុជា តាមរយៈរង្វាស់កម្រិតនៃការលក់ បានកើនឡើងពី ២.៥៧២,៧៤ (“GWh”) ទៅ ៨.៦៤៩,៩៨ ជីកាវ៉ាត់ម៉ោង ក្នុងអត្រាកំណើនប្រចាំឆ្នាំ ១៨,៩១%។ ការកើនឡើងនៃតម្រូវការថាមពលសម្រាប់ខេត្តនីមួយៗក្នុងប្រទេសកម្ពុជា មានទំនាក់ទំនងទៅនឹងចំនួននៃអ្នកប្រើប្រាស់ក្នុងខេត្តនីមួយៗនោះ។ ចំនួនអ្នកប្រើប្រាស់សរុបក្នុងប្រទេសកម្ពុជា បានកើនឡើងពី ៨១០.៩៨៤ ក្នុងឆ្នាំ២០១១ ទៅ ២.៧០៥.៥០៥ ក្នុងឆ្នាំ២០១៨ ក្នុងអត្រាកំណើនមធ្យមប្រចាំឆ្នាំ ១៨,៧៨%។

PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ការប្រើប្រាស់អគ្គិសនីនៅក្នុងប្រទេសកម្ពុជា [a]

ឆ្នាំ	ការលក់អគ្គិសនី (ជីកាវ៉ាត់ម៉ោង)	ចំនួនអតិថិជន
២០១១	២.៥៧២,៧៤	៨១០.៩៨៤
២០១២	៣.២៦៥,៨១	៩៩២.៥៩៧
២០១៣	៣.៥៥២,៥៩	១.១៩៨.៨៤៤
២០១៤	៤.១៤៤,១២	១.៤២៤.៧៣៥
២០១៥	៥.២០៥,៣៤	១.៨៥៩.២០៤
២០១៦	៦.២២៩,៦៧	២.១៧០.៦៨២
២០១៧	៧.០៣៨,៥៣	២.៤១២.៧៥៩
២០១៨	៨.៦៤៩,៩៨	២.៧០៥.៥០៥
អត្រាកំណើនប្រចាំឆ្នាំ (%)	**១៨,៩១**	**១៨,៧៨**

[a] *គិតត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩*

ប្រភព៖ អាជ្ញាធរអគ្គិសនីកម្ពុជា និងការវិភាគរបស់ ក្រុមហ៊ុន SMITH ZANDER

ចលករនៃកំណើន និងការព្យាករណ៍ការកើនឡើងនៃការប្រើប្រាស់ថាមពលអគ្គិសនី

ការប្រើប្រាស់ ឬតម្រូវការអគ្គិសនី គឺជាចលករចម្បងមួយសម្រាប់ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនី និងជាចលករក្នុងការទាមទារឱ្យមានដំណោះស្រាយបច្ចេកទេស និងវិស្វកម្មនៃប្រព័ន្ធថាមពល។ តម្រូវការអគ្គិសនី ត្រូវបានរំពឹងថានឹងកើនឡើងស្របពេលជាមួយនឹងកំណើនសេដ្ឋកិច្ច។ ដោយហេតុថាអគ្គិសនីមានតួនាទីយ៉ាងសំខាន់ លើកំណើនថាមពល ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីក្នុងប្រទេសកម្ពុជា រំពឹងថានឹងកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំ ខាងមុខនេះ ស្របតាម លទ្ធផលជាក់ស្តែងនៃកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេស។

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ចាប់ផ្តើមពីឆ្នាំ២០០៤។ យុទ្ធសាស្ត្រចតុកោណ មានគោលដៅលើកកម្ពស់កំណើនសេដ្ឋកិច្ច ផ្តល់ការងារពេញលេញសម្រាប់និយោជិត កម្ពុជា និងភាពស្មើគ្នា និងយុត្តិធម៌សង្គម។ ក្រោមយុទ្ធសាស្ត្រចតុកោណ រដ្ឋាភិបាលមានបំណងទទួលបានន្ទូវ មជ្ឈដ្ឋាន ម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដ៏ល្អប្រសើរសម្រាប់ប្រទេសដែលមានកំណើនសេដ្ឋកិច្ច ៦% ទៅ ៧% ក្នុងមួយឆ្នាំ។ រាជរដ្ឋាភិបាល ក៏មានគោលដៅរួមបញ្ចូលប្រទេសកម្ពុជាទាំងថ្នាក់តំបន់ និងថ្នាក់សកលលោក ដើម្បីលើកកម្ពស់ពាណិជ្ជកម្មសេរី និងផ្តល់ឱកាសទាក់ទាញដល់ការវិនិយោគ បង្កើតការងារ បង្កើនចំណូល និងបង្កើនកំណើនសេដ្ឋកិច្ចដើម្បីកាត់បន្ថយភាពក្រីក្រ។ ក្រោមយុទ្ធសាស្ត្រចតុកោណ កំណើនសេដ្ឋកិច្ចនៃ ប្រទេសកម្ពុជា នឹងត្រូវកើតមានឡើងតាមរយៈការអនុវត្តន៍នូវយន្តការដូចខាងក្រោម៖

- **ការធ្វើឱ្យប្រសើរឡើងនៃវិស័យកសិកម្ម**

  វិស័យកសិកម្មរបស់ជាតិនឹងត្រូវអភិវឌ្ឍន៍ដោយធ្វើឱ្យប្រសើរឡើងនូវផលិតកម្មកសិកម្ម និងកសិកម្មចំរុះ កំណែទម្រង់ដីធ្លី និងការសម្អាតមីន កំណែទម្រង់រុក្ខាប្រមាញ់ និងព្រៃឈើ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

- **ការបន្តការស្តារឡើងវិញ និងសាងសង់នៃហេដ្ឋារចនាសម្ព័ន្ធ**

ទាំងនេះទាក់ទិននឹងការបន្តការស្តារឡើងវិញ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការគ្រប់គ្រងធនធាន ទឹក និងស្រោចស្រព ការអភិវឌ្ឍន៍ថាមពល និងបណ្តាញថាមពលអគ្គិសនី និងការអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង។ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនក្នុងប្រទេសកម្ពុជា នឹងសម្រប សម្រួលដល់ការផ្លាស់ប្តូរ របស់ប្រទេសឱ្យក្លាយទៅជាសេដ្ឋកិច្ចរួមមួយ។ ទាំងនេះ នឹងកើតមានឡើង តាមរយៈ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវគោក ទឹក និងអាកាស។

- **ការរីកចម្រើននៃវិស័យឯកជន និងភាពមានការងារធ្វើ**

វិស័យឯកជន គឺជាគ្រឿងម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និងជាចំណុចស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃ ប្រទេសកម្ពុជា។ ដូចនេះ រាជរដ្ឋាភិបាលមានគោលបំណងពង្រឹងវិស័យឯកជន តាមរយៈការអនុវត្ត គោលនយោបាយសមាហរន្តកម្ម សេដ្ឋកិច្ចនៃប្រទេសកម្ពុជា ឱ្យទៅជាសេដ្ឋកិច្ចតំបន់ និងសកលលោក។ រដ្ឋាភិបាលក៏មានបំណងសម្របសម្រួលការរីកចម្រើននៃវិស័យឯកជននៅក្នុងប្រទេស តាមរយៈ៖

- ការអភិវឌ្ឍន៍បណ្តាញហេដ្ឋារចនាសម្ព័ន្ធ software និង hardware
- ពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់សហគ្រាស
- ពង្រឹងការអភិបាលកិច្ចសាធារណៈ និងក្រុមហ៊ុន
- សម្របសម្រួលពាណិជ្ជកម្ម និងធ្វើឱ្យប្រសើរឡើងនៃលក្ខខណ្ឌវិនិយោគ
- លើកកំពស់ការអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់បំពេញតម្រូវការទីផ្សារ
- លើកកំពស់សហគ្រាសធនតូច និងមធ្យម
- ការអនុវត្តគោលនយោបាយបង្កើតការងារ និងធានាលក្ខខណ្ឌការងារល្អប្រសើរសម្រាប់នយោជិត និងកម្មករ និង
- ការបង្កើតឡើងនូវបណ្តាញសុវត្ថិភាពសង្គម សម្រាប់និយោជិត និងកម្មករ រួមបញ្ចូលទាំងមន្ត្រីរាជការសាធារណៈ។

- **ការអភិវឌ្ឍន៍សមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្ស**

ទាំងនេះនឹងត្រូវធ្វើឡើងតាមរយៈការបង្កើនគុណភាពអប់រំ សេវាសុខាភិបាល សមភាពយេនឌ័ និងការអនុវត្តគោលនយោបាយប្រជាជន។

ក្រោមគម្រោងអភិវឌ្ឍន៍ថាមពលនៃព្រះរាជាណាចក្រកម្ពុជា តម្រូវការអគ្គិសនីត្រូវបានរំពឹងថានឹងកើនឡើងជាគំហុក រហូតដល់ឆ្នាំ២០២០។ ការប្រើប្រាស់អគ្គិសនីក្នុង ប្រទេសកម្ពុជាកើនឡើងពី ២.៥៧២,៧៤ ជីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ ២០១១ ដល់ ៨.៦៤៩,៩៨ ជីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០១៨ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ១៨,៩១%។ SMITH ZANDER ប៉ាន់ប្រមាណថាតម្រូវការអគ្គិសនី នឹងកើនឡើងពី ៨.៦៤៩,៩៨ ជីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០១៨ ទៅ ១២.០១៩,៧៥ ជីកាវ៉ាត់ម៉ោង ក្នុងឆ្នាំ២០២០[1] ក្នុងអត្រាកំណើនប្រចាំឆ្នាំ ១៧,៨៨% ពីក្រោយកំណើនសេដ្ឋកិច្ច និងការផ្តួចផ្តើមដោយរដ្ឋាភិបាលកម្ពុជា សម្រាប់ធ្វើឱ្យប្រសើរឡើងនូវអត្រាអគ្គិសនីភាវូបនីយកម្មនៅក្នុងប្រទេស។

[1] *ការព្យាករណ៍របស់ក្រុមហ៊ុន SMITH ZANDER ដោយផ្អែកលើប្រវត្តិនៃការប្រើប្រាស់អគ្គិសនីនិងការស្រាវជ្រាវអំពីចលករនៃការប្រើប្រាស់អគ្គិសនីដែលមាន*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
(ខេមបូឌា) ខ.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

លទ្ធផលក្នុងផ្នែកដំណោះស្រាយលើបញ្ហាបច្ចេកទេស និងវិស្វកម្មប្រព័ន្ធថាមពលនៃឧស្សាហកម្មផ្គត់ផ្គង់ថាមពលនៅក្នុងប្រទេសកម្ពុជា គឺជាអនុគមន៍នៃកំណើននៅក្នុងហេដ្ឋារចនាសម្ព័ន្ធនៃការបញ្ជូន និង ចែកចាយថាមពលនៅក្នុងប្រទេស។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា អគ្គិសនីគឺផលិត បញ្ជូន និងចែកចាយពីប្រភពថាមពលផ្សេងៗ ទៅដល់អ្នកប្រើប្រាស់តាមរយៈបណ្តាញជាតិបញ្ជូនអគ្គិសនីវ៉ុលខ្ពស់ បណ្តាញថាមពលប្រទេសវៀតណាមវ៉ុលមធ្យម បណ្តាញថាមពលប្រទេសថៃវ៉ុលមធ្យម បណ្តាញថាមពលប្រទេសឡាវវ៉ុលមធ្យម និងប្រព័ន្ធផ្គត់ផ្គង់ទោល ។

តួអង្គឧស្សាហកម្មដែលផ្គត់ផ្គង់ដំណោះស្រាយលើបញ្ហាបច្ចេកទេស និងវិស្វកម្មប្រព័ន្ធថាមពល សម្រាប់ប្រព័ន្ធបញ្ជូន ចូលរួមក្នុងការរៀបចំ អភិវឌ្ឍ និង/ឬ ផ្គត់ផ្គង់ ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនអគ្គិសនីដូចជា បណ្តាញបញ្ជូន បង្គោលបញ្ជូន និងអនុស្ថានីយ៍បញ្ជូន។ តួអង្គឧស្សាហកម្មទាំងនោះរួមមាន ក្រុមហ៊ុន អេប៊ីប៊ី លីមីធីត, ក្រុមហ៊ុន China Datang, ក្រុមហ៊ុន China Heavy Machinery, ក្រុមហ៊ុនផេសថិក (ខេមបូឌា) ម.ក និងក្រុមហ៊ុនហ្ស៊ីមិនស៍ លីមីធីត ។

ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក គឺជាក្រុមហ៊ុនបច្ចេកវិទ្យាថាមពលអគ្គិសនីរួមបញ្ចូល ដែលចូលរួមជាចំបងក្នុង ផ្គត់ផ្គង់ដំណោះស្រាយលើបញ្ហាបច្ចេកទេស និងវិស្វកម្មប្រព័ន្ធថាមពលដ៏ទូលំទូលាយ សម្រាប់ការរចនា លទ្ធកម្ម សាងសង់ តម្លើង និងដាក់ឱ្យដំណើរការអនុស្ថានីយ៍វ៉ុលខ្ពស់ និង វ៉ុលខ្ពស់ខ្លាំង បង្គោលបញ្ជូន និងបណ្តាញបញ្ជូន ក៏ដូចជាប្រព័ន្ធ ខ្សែកាបអគ្គិសនីសម្រាប់ការបញ្ជូន និងចែកចាយអគ្គិសនី និងធ្វើការចែកចាយគ្រឿងបរិក្ខារ និងបង្កុំប្រព័ន្ធថាមពលអគ្គិសនី។ ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក បានបញ្ចប់គម្រោងបញ្ជូនថាមពលបី (៣) នៅក្នុងប្រទេសកម្ពុជា ដែលគម្រោងនេះមានឈ្មោះថា៖

- គម្រោងបញ្ជូនភ្នំពេញភាគខាងជើង - ខេត្តកំពង់ចាម ដែលរួមមានការរចនា សាងសង់ ធ្វើតេស្ត និងដាក់ឱ្យដំណើរការ នៃ បណ្តាញបញ្ជូនសៀគ្វីទ្វេ ប្រវែង ៩៧,១៨ គីឡូម៉ែត ទំហំ ២៣០ គីឡូវ៉ុល ពីភ្នំពេញខាងភាគខាងជើងរហូតដល់ខេត្តកំពង់ចាម រួមជានឹងការសាងសង់ និងធ្វើឱ្យប្រសើរឡើងនូវអនុស្ថានីយ៍ពីរ (២)។
- គម្រោងខេត្តបាត់ដំបង ដែលរួមមានការរចនា វិស្វកម្ម លទ្ធកម្ម និងតម្លើង បណ្តាញបញ្ជូនអគ្គិសនីប្រវែង ០,៩៧ គីឡូម៉ែត ទំហំ ១១៥ គីឡូវ៉ុល ភ្ជាប់ពី អនុស្ថានីយ៍ ២៣០/១១៥ គីឡូវ៉ុល របស់ក្រុមហ៊ុនខេមបូឌាន ផៅវ៉ែរ ប្រ៊ីត ដល់អនុស្ថានីយ៍ ១១៥/២២ គីឡូវ៉ុលរបស់ក្រុមហ៊ុន ខេមបូឌា ផៅវ៉ែរ ប្រែនមីសិន ឡាញ ក្នុងខេត្តបាត់ដំបង។ និង
- គ្រោងខេត្តកំពង់ចាម - ក្រចេះ ដែលរួមមានការរចនា សាងសង់ វិស្វកម្ម ធ្វើតេស្ត និងតម្លើង ទីធ្លាភ្ជាប់ផ្តាច់ចរន្ត ដែលមានទំហំ ២៣០ kV ក្នុង អនុស្ថានីយ៍ខេត្តកំពង់ចាមដែលមានស្រាប់ អនុស្ថានីយ៍ខេត្តក្រចេះថ្មីដែលមានទំហំ ២៣០/២២ kV និង ខ្សែបញ្ជូនប្រវែង ១២៥ គីឡូម៉ែតពីអនុស្ថានីយ៍ខេត្តកំពង់ចាមដល់អនុស្ថានីយ៍ខេត្តក្រចេះ។

ផេសថិក (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

២ឧស្សាហកម្មផ្គត់ផ្គង់អគ្គសនីនៅក្នុងប្រទេសមីយ៉ាន់ម៉ា

ប្រតិបត្តិការឧស្សាហកម្ម ទស្សនៈវិស័យ និងការវំពឹងទុក

សមត្ថភាពនៃការផលិត

ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងសាធារណរដ្ឋសហភាពយ៉ាន់ម៉ា មានប្រភពចម្បងចេញពីរោងចក្រវារីអគ្គិសនី និងឧស្ម័ន។ ការផ្គត់ផ្គង់ថាមពលនៅក្នុងប្រទេសមីយ៉ាន់ម៉ា ផ្អែកតាមរង្វាស់ទំហំផលិតកម្មសរុប បានកើនឡើងពី ៣.៤១៣ ម៉ែកាវ៉ាត់ នៅក្នុងឆ្នាំ២០១១ រហូតដល់ ៦.៦៤២ មេកាវ៉ាត់ នៅក្នុងឆ្នាំ ២០១៨ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ៧,៤៤% ដែលជម្រុញយ៉ាងខ្លាំងដោយកំណើនសមត្ថភាពផលិតពីរោងច្រកថាមពលម៉ាស្ទ៊ីត និងឧស្ម័ន។ នៅចន្លោះឆ្នាំ ២០១១ និង ២០១៨ សមត្ថភាពផលិត របស់រោងចក្រថាមពលប្រើប្រាស់ឧស្ម័ន កើនឡើងពី ៥៥០ មេកាវ៉ាត់ រហូតដល់ ១.៨៨១មេកាវ៉ាត់ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ១៩,២០%។

ប្រទេសមីយ៉ាន់ម៉ាមានធនធានទឹក និង ឧស្ម័នធម្មជាតិដ៏សម្បូរបែប។ ដូចនេះ ប្រទេសមីយ៉ាន់ម៉ាពឹងផ្អែក យ៉ាងខ្លាំង ទៅលើផលិតកម្មដោយប្រើប្រាស់ វារីអគ្គិសនី និងឧស្ម័ន ដែលតំណាងឱ្យ ៥៧,៦៩% និង ៣៣,៣៤% នៃទំហំផលិតកម្មសរុប ក្នុងឆ្នាំ ២០១៨។

សមត្ថភាពផលិតនៃឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីក្នុងប្រទេសមីយ៉ាន់ម៉ា[a,b]

ប្រភព		សមត្ថភាពផលិត (**មេកាវ៉ាត់**)							អត្រាកំណើន
ថាមពល	២០១១	២០១២	២០១៣	២០១៤	២០១៥	២០១៦	២០១៧	២០១៨	ប្រចាំឆ្នាំ (%)
កំដៅ	២៨៥	២៨៥	២៨៥	២៨៥	២៨៥	៣០០	៣៧៨	៤១៤	៥,៤៨
ប្រេងម៉ាស្ទ៊ីត	៥៦	៦០	៧៨	៨៥	៨៩	៩៥	៩៤	៩២	៧,៣៥
វារីអគ្គិសនី	២.៥២២	២.៦៩៣	២.៨១៣	៣.០០៥	៣.១៨៥	៣.២១៥	៣.២៥៥	៣.២៥៥	៣,៧១
ឧស្ម័ន	៥៥០	៥៥០	៥៥០	៧៧១	១.២៤៦	១.៥១៥	១.៦៦៣	១.៨៨១	១៩,២០
សរុប	**៣.៤១៣**	**៣.៥៨៨**	**៣.៧២៦**	**៤.១៤៦**	**៤.៨០៥**	**៥.១២៥**	**៥.៣៩០**	**៥.៦៤២**	**៧,៤៤**

[a] *គិតត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩*

[b] *ទន្និន័យត្រូវបានបញ្ជាប់នៅថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ*

ប្រភព: Central Statistical Organisation, ការវិភាគរបស់ក្រុមហ៊ុន SMITH ZANDER

ចលករនៃការវីកចម្រើន និងផែនការពង្រីកទំហំផលិតកម្មនាពេលអនាគត

រាជរដ្ឋាភិបាលនៃប្រទេសមីយ៉ាន់ម៉ា បានអនុវត្តគម្រោងអភិវឌ្ឍន៍ថាមពលរយៈពេល១៥ឆ្នាំ (២០១៦-២០៣១) ដែលមានគោលដៅបង្កើតរោងចក្រផលិតថាមពលថ្មីចំនួន ៤១ បង្កើនសមត្ថភាពផលិតរហូតដល់ជាង ២៩ ជីកាវ៉ាត់ (“GW”) ធ្វើទំនើបកម្មបណ្តាញដើម្បីកាត់បន្ថយការបាត់បង់តាមរយៈការបញ្ជូន និង ចែកចាយ និង ពង្រីកនូវការទទួលបានអគ្គិសនីនៅឆ្នាំ ២០៣១។

ក្រសាទាណាបក្រកម្ពុជា
ផេសធីក
(ខេមុជា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ក្នុងចំណោមរោងចក្រផលិតអគ្គិសនីចំនួន ៤១ រោងចក្រចំនួន ១២ ប្រើប្រាស់ធ្យូងថ្ម និង រោងចក្រចំនួន ២០ ទៀតនឹងប្រើប្រាស់វារីអគ្គិសនី។ រោងចក្រអគ្គិសនីដែលប្រើប្រាស់ធ្យូងថ្មចំនួន ១២ នឹងត្រូវមានទំហំផលិកម្ម សរុប ១២.៧៨០ មេកាវ៉ាត់ ខណៈពេលដែលរោងចក្រវារីអគ្គិសនីចំនួន ២០ នឹងត្រូវមានទំហំផលិកម្មសរុប ៦.៧២០ មេកាវ៉ាត់។ ក្រៅពីផលិតកម្មអគ្គិសនីធ្យូងថ្ម និងវារីអគ្គិសនី រដ្ឋាភិបាលប្រទេសមីយ៉ាន់ម៉ា ក៏មានគម្រោងក្នុងការផលិត អគ្គិសនីពីប្រភពថាមពលផ្សេងទៀតដូចជា ឧស្ម័នធម្មជាតិ ពន្លឺព្រះអាទិត្យ និងដោយកម្លាំងខ្យល់។ រដ្ឋាភិបាលប្រទេសមីយ៉ាន់ម៉ា មានបំណងផលិតថាមពលចំនួន ១.៣០១ មេកាវ៉ាត់ ៥២០ មេកាវ៉ាត់ និង ៤.០៣២ មេកាវ៉ាត់ពី ឧស្ម័នធម្មជាតិ ពន្លឺព្រះអាទិត្យ និងដោយកម្លាំងខ្យល់ រៀងគ្នា។ ការវិនិយោគទៅលើការសាងសង់រោងចក្រថាមពលថ្មីទាំង ៤១ រោងចក្រទាំងអស់នេះអាចធ្វើទៅបានតាមរយៈ មធ្យោបាយ ៣ មានដូចជា តាមរយៈការសហការវិនិយោគជាមួយក្រសួងថាមពលអគ្គិសនី(“MOEE”) ដែលជាម្ចាស់ការ វិនិយោគដោយសហគ្រាសក្នុងស្រុកដែលស្ថិតនៅក្រោមផែនការសាងសង់ ប្រតិបត្តិការ និងបញ្ជូន ឬ វិនិយោគដោយក្រុមហ៊ុនបរទេសតាមរយៈទម្រង់សាងសង់ ប្រតិបត្តិការ និងផ្ទេរ និងក្នុងទម្រង់ជាការសហការអាជីវកម្ម។ បច្ចុប្បន្នរោងចក្រផលិតថាមពលអគ្គិសនីចំនួនប្រាំពីរ (០៧) កំពុងសាងសង់នៅក្នុងប្រទេសមីយ៉ាន់ម៉ា ជាមួយទំហំផលិតកម្មសរុប ១.១៦៥,៥៤ ម៉េកាវ៉ាត់ និងត្រូវបានរំពឹងថានឹងចាប់ផ្តើមដំណើការក្នុងឆ្នាំ២០២០។ រោងចក្រផលិតថាមពល Thanlyin ត្រូវបានរំពឹងទុកជា រោងចក្រ ផលិតថាមពលធំជាងគេបង្អស់នៅក្នុងប្រទេសមីយ៉ាន់ម៉ាក្រោយបញ្ចប់ការសាងសង់ ដែលរោងចក្រនេះមានទំហំផលិតកម្មសរុប ៤០០ មេកាវ៉ាត់។

សមត្ថភាពបញ្ជូន និងចែកចាយ

នៅក្នុងប្រទេសមីយ៉ាន់ម៉ា អគ្គិសនីដែលផលិតចេញពីរោងចក្រថាមពលអគ្គិសនី ត្រូវបានបញ្ជូនទៅអនុស្ថានីយ៍តាមរយៈ បណ្តាញបញ្ជូន ២៣០ គីឡូវ៉ុល ១៣២ គីឡូវ៉ុល និង ៦៦ គីឡូវ៉ុល។ ជាទូទៅ បណ្តាញបញ្ជូនក្នុងប្រទេសមីយ៉ាន់ម៉ា ជា បណ្តាញបញ្ជូនសៀគ្វីទោល។ ការកើនឡើងនៃបណ្តាញបញ្ជូន និងចែកចាយអគ្គិសនី នៅក្នុងប្រទេសមីយ៉ាន់ម៉ា ជួយទ្រទ្រង់ដល់កំណើននៃហេដ្ឋារចនាសម្ព័ន្ធនៃការផលិតនៅក្នុងប្រទេសទាំងមូល។ កំណើននៃឧស្សាហកម្មបញ្ជូនថាមពលក្នុងប្រទេសមីយ៉ាន់ម៉ា គឺតំណាងដោយកំណើនជាតិក្នុងទំហំប្រព័ន្ធបញ្ជូន ដូចដែលបានកំណត់តាមរយៈប្រវែងបណ្តាញបញ្ជូន និងចំនួនអនុស្ថានីយ៍នៅក្នុងប្រទេស។

គិតត្រឹមខែមិថុនា ឆ្នាំ២០១៧ ប្រវែងសរុបនៃបណ្តាញបញ្ជូននៅក្នុងប្រទេសមីយ៉ាន់ម៉ាមានប្រវែង ១១.៣៦៦,៨៣ គីឡូម៉ែត។ ក្នុងនោះ បណ្តាញបញ្ជូន ៦៦ គីឡូវ៉ុល ស្មើនឹង ៤១,៣៩% (៤.៧០៤,៩៤ គីឡូម៉ែត) ខណៈពេលដែលបណ្តាញ បញ្ជូន ១៣២ គីឡូវ៉ុល និង ២៣០ គីឡូវ៉ុល ស្មើនឹង ១៩,២៨% (២.១៩១,៣៦ គីឡូម៉ែត) និង ៣៩,៣៣% (៤.៤៧០,៥៣ គីឡូម៉ែត) រៀងគ្នា។ នៅក្នុងប្រទេសមីយ៉ាន់ម៉ា មានអនុស្ថានីយ៍ន៍បញ្ជូនថាមពលសរុបចំនួន ២៧៧ គិតត្រឹមខែមិថុនា ឆ្នាំ២០១៧ ជាមួយនឹងទំហំផលិតកម្ម ១០.៣០៨,០៥ ម៉េកាវ៉ុលអំពែរ។

ក្រុមហ៊ុនបរទេសតាមរយៈ ឆេសទិក (ខេមបូឌា) ម.ក PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

ទំហំនៃប្រព័ន្ធបញ្ជូនក្នុងប្រទេសមីយ៉ាន់ម៉ា [a]

	គិតត្រឹមខែមិថុនា ឆ្នាំ២០១៧
បណ្តាញបញ្ជូនថាមពល (គីឡូម៉ែត)	
៦៦ គីឡូវ៉ុល	៤.៧០៤,៩៤
១៣២ គីឡូវ៉ុល	២.១៩១,៣៦
២៣០ គីឡូវ៉ុល	៤.៤៧០,៥៣
សរុប	**១១.៣៦៦,៨៣**
អនុស្ថានីយ៍បញ្ជូនថាមពល	
ចំនួន	២៧៧
ទំហំ (ម៉ែកាវ៉ុលអំពែរ)	១០.៣០៨,០៥

[a] *គិតត្រឹមថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៩*

ប្រភព៖ MOEE

កំណើនឧស្សាហកម្មចែកចាយអគ្គិសនីនៅក្នុងប្រទេសមីយ៉ាន់ម៉ា តំណាងដោយប្រវែងជាតិនៃបណ្តាញចែកចាយ នៅក្នុងប្រទេស។ នៅក្នុងឆ្នាំ ២០១៦ ប្រវែងសរុបនៃបណ្តាញចែកចាយនៅក្នុងប្រទេសមីយ៉ាន់ម៉ា មានកំណត់ត្រាប្រវែង ៥៨.៨០១,៦០ គីឡូម៉ែត។ ក្នុងនោះ បណ្តាញចែកចាយ ០,៤ គីឡូវ៉ុល គិតជាភាគរយប្រមាណ ៤៦,២៧% (២៧.២០៥,៣០គីឡូម៉ែត) ស្របពេលដែលបណ្តាញចែកចាយ ៦,៦ គីឡូវ៉ុល ១១ គីឡូវ៉ុល និង៣៣ គីឡូវ៉ុល គិតជាភាគរយប្រមាណ ២,៣៦% (១.៣៩០,៥០ គីឡូម៉ែត), ៣៦,១៦% (២១.២៦០,០០ គីឡូម៉ែត) និង ១៥,២១%(៨.៩៤៥,៨០ គីឡូម៉ែត)។ ក្នុងខែមិថុនាឆ្នាំ ២០១៧ MOEE បានប្រកាសថានឹងមានផែនការណ៍ពង្រីកខ្សែចែកចាយប្រវែង ១៥.៨៦១,០០ គីឡូម៉ែត ដែលនឹងអនុវត្តអំឡុងឆ្នាំ២០១៧ ដល់ ឆ្នាំ២០២១។

PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ទំហំប្រព័ន្ធចែកចាយនៅក្នុងប្រទេសមីយ៉ាន់ម៉ា[a]

	ឆ្នាំ ២០១៣
បណ្តាញចែកចាយថាមពល (គីឡូម៉ែត)	
០,៤ គីឡូវ៉ុល	២៧.២០៥,៣០
៦,៦ គីឡូវ៉ុល	១.៣៩០,៥០
១១ គីឡូវ៉ុល	២១.២៦០,០០
៣៣ គីឡូវ៉ុល	៨.៩៤៥,៨០
សរុប	**៥៨.៨០១,៦០**

[a] *គិតត្រឹមថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៩ (ទិន្នន័យសម្រាប់ឆ្នាំ២០១៧ ឆ្នាំ២០១៨ មិនទាន់មានជាសាធារណៈនៅឡើយ)*

ប្រភព៖ MOEE

ចលកវនៃការវីកចម្រើន និងផែនការពង្រីកសមត្ថភាពផ្គេរ និងចែកចាយចរន្តនាពេលអនាគត

ក្រសួងថាមពលអគ្គិសនី ("MOEE") បានអនុម័តគម្រោង និង ការផ្តួចផ្តើមមួយចំនួន ដើម្បីបន្តអភិវឌ្ឍវិស័យ ថាមពលនៅក្នុងប្រទេសមីយ៉ាន់ម៉ា ដែលផែនការនេះមានឈ្មោះថា ផែនការតំណភ្ជាប់អគ្គិសនីថ្នាក់ជាតិ និង ផែនការអភិវឌ្ឍថាមពល ១៥ ឆ្នាំ (២០១៦-២០៣១)។ ក្រោមផែនការតំណភ្ជាប់អគ្គិសនីថ្នាក់ជាតិ រាជរដ្ឋាភិបាលនៃប្រទេសមីយ៉ាន់ម៉ាគ្រោងនឹងសម្រេចឱ្យបាននូវការភ្ជាប់ចរន្តអគ្គិសនីទៅដល់អ្នកប្រើប្រាស់ ឱ្យបានទូទាំងប្រទេសនៅក្នុងឆ្នាំ ២០៣០។ ការពង្រីកសេវាកម្មអគ្គិសនីនៅក្នុងប្រទេសមីយ៉ាន់ម៉ានឹងសម្រេច បានតាមរយៈដំណោះស្រាយតាមបណ្តាញ ឬក្រៅ បណ្តាញដូចជាការតភ្ជាប់តាមរយៈថាមពលពន្លឺព្រះអាទិត្យ និងបណ្តាញ តូចៗ។ ផែនការតំណភ្ជាប់អគ្គិសនីថ្នាក់ជាតិ នឹងត្រូវអនុវត្តតាមរយៈបី (៣) ដំណាក់កាល ខណៈដំណាក់កាល ទីមួយ នឹងមានគោលដៅផ្តត់ផ្គង់ការទទួលបានអគ្គិសនីប្រើប្រាស់ដល់ប្រជាពលរដ្ឋចំនួន ៥០% នៅក្នុងប្រទេស មីយ៉ាន់ម៉ាក្នុងឆ្នាំ២០២០ ដែលមានកំណើនកើនឡើងដល់ ៧៥% នៅក្នុងឆ្នាំ ២០២៥ និង ១០០% ក្នុងឆ្នាំ២០៣០។

នៅខែកញ្ញា ឆ្នាំ២០១៥ ធនាគារពិភពលោកបានអនុម័តកម្ចី ៤០០ លានដុល្លារអាមេរិក ដើម្បីទ្រទ្រង់ផែនការ តំណភ្ជាប់អគ្គិសនីថ្នាក់ជាតិរបស់រដ្ឋាភិបាលមីយ៉ាន់ម៉ា។ ផែនការតំណភ្ជាប់អគ្គិសនីថ្នាក់ជាតិ នឹងត្រូវអនុម័ត ដោយ MOEE និងក្រសួងបសុសត្ថ នេសាទ និងអភិវឌ្ឍជនបទ។ ផែនការតំណភ្ជាប់អគ្គិសនី ថ្នាក់ជាតិនេះមានសមាសភាគបួន (៤) ដូចជា ការពង្រីកបណ្តាញបញ្ជូនថាមពល តំណភ្ជាប់អគ្គិសនីក្រៅ បណ្តាញ ជំនួយផ្នែកបច្ចេកទេស និងការគ្រប់គ្រងគម្រោង និងការងារសង្ក្រោះបន្ទាន់។

ក្រុមហ៊ុនឆាមក្រកម្ពុជា
ផេសទិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

- **ការពង្រីកបណ្តាញថាមពល**

ក្រោមគម្រោងតំណភ្ជាប់អគ្គិសនីថ្នាក់ជាតិ ចំនួនទឹកប្រាក់ ៣០០ លានដុល្លារអាមេរិក នឹងត្រូវបានផ្តល់ សម្រាប់ការពង្រីកថាមពលបន្ថែមនៅក្នុងប្រទេសមីយ៉ាន់ម៉ា ដែលការប្រើប្រាស់អគ្គិសនី នឹងត្រូវផ្តល់ទៅដល់ សហគមន៍ និងគេហដ្ឋានដែលនៅជិតបណ្តាញជាតិបំផុត។ នៅក្នុងគម្រោងនេះ ទឹកប្រាក់ចំណាយរួមមាន ការពង្រីកអនុស្ថានីយ៍វ៉ុលមធ្យមដែលមានស្រាប់ និងការសាងសង់អនុស្ថានីយ៍វ៉ុលមធ្យមថ្មី ការសាងសង់ បណ្តាញវ៉ុលទាបនិងមធ្យមដែលមានប្រវែងប្រមាណ ១២.៩០០ ម៉ាយ (ប្រម៉ាណ ២០.៧៦០,០០គីឡូម៉ែត) នៃបណ្តាញវ៉ុលមធ្យមនិង ទាបចំនួន ៧៧២ ម៉ែកាវ៉ុលអំពែរ និងការផ្តល់នូវតំណភ្ជាប់ចរន្តក្នុង សហគមន៍ចំនួន ១១.៦០០ (មន្ទីរពេទ្យ សាលារៀន និងអគារ សាធារណៈ) តំណភ្ជាប់ទៅគេហដ្ឋានចំនួន ៧៥០.០០០ និង ភ្លឺងបំភ្លឺសាធារណៈចំនួន ១៣២.០០០។

- **តំណភ្ជាប់អគ្គិសនីក្រៅបណ្តាញ**

ក្រោមគម្រោងតំណភ្ជាប់អគ្គិសនីថ្នាក់ជាតិ ទឹកប្រាក់ចំនួន ៨០ លានដុល្លារអាមេរិក នឹងត្រូវយកទៅប្រើប្រាស់ក្នុងតំណភ្ជាប់អគ្គិសនីក្រៅបណ្តាញនៅក្នុងប្រទេសមីយ៉ាន់ម៉ា ដែលការទទួលបានការប្រើប្រាស់អគ្គិសនីនឹងផ្តល់ទៅដល់សហគមន៍ដែលមានទីតាំងឆ្ងាយពីបណ្តាញជាតិដែលមានស្រាប់ ដូច្នេះហើយសហគមន៍ដែលនៅក្រៅបណ្តាញមិនអាចទទួលបានការតភ្ជាប់បណ្តាញនៅក្នុងរយៈពេល១០ឆ្នាំ ឬ លើសនេះ។ បច្ចេកវិទ្យាដែលប្រើប្រាស់សម្រាប់តំណភ្ជាប់អគ្គិសនីក្រៅបណ្តាញ នឹងត្រូវពឹងផ្អែកលើ បច្ចេកវិទ្យារវាយតម្លៃដែលនឹងត្រូវប្រើប្រាស់សម្រាប់គោលដៅ សហគមន៍ដែលបានកំណត់។ បច្ចេកវិទ្យាទាំងអស់នេះរួមមាន ថាមពលពីពន្លឺព្រះអាទិត្យ ថាមពលពីវារីអគ្គិសនីខ្នាតតូច ថាមពលពីខ្យល់ ថាមពេលពីប្រេងម៉ាស៊ូត ក៏ដូចជាបច្ចេកវិទ្យាកូនកាត់ដូចជា ថាមពលពីពន្លឺព្រះអាទិត្យ និងប្រេងម៉ាស៊ូត។

- **ជំនួយការបច្ចេកទេស និង ការគ្រប់គ្រងគម្រោង**

ក្រោមគម្រោងតំណភ្ជាប់អគ្គិសនីថ្នាក់ជាតិ ទឹកប្រាក់ចំនួន ២០ លានដុល្លារអាមេរិក នឹងត្រូវយកទៅ ប្រើប្រាស់ក្នុងជំនួយបច្ចេកទេស និងការគ្រប់គ្រងគម្រោង សម្រាប់ឧស្សាហកម្មអគ្គិសនី នៅក្នុងប្រទេស មីយ៉ាន់ម៉ា។ ជំនួយ បច្ចេកទេស និងការគ្រប់គ្រប់គម្រោងនេះ រួមមាន ការបង្កើនសមត្ថភាព ការបណ្តុះ បណ្តាល ពង្រឹងក្របខ័ណ្ឌគោលនយោបាយ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងអគ្គិសនី ការអភិវឌ្ឍក្របខ័ណ្ឌ ប្រព័ន្ធព័ត៌មានភូមិសាស្ត្ររួមបញ្ចូលសម្រាប់ផែនការតំណភ្ជាប់អគ្គិសនិ ពិនិត្យនិងវិភាគ ផ្តល់យោបល់ បច្ចេកទេស និង សេវាប្រឹក្សាយោបល់ និងការគ្រប់គ្រងគម្រោង។

- **ការងារសង្គ្រោះបន្ទាន់**

ក្នុងគម្រោងនេះមិនមានការកំណត់ជាមុននូវថវិកា នោះឡើយ ដូចនេះវាអនុញ្ញាតឱ្យមានការបង្វិល ឥណទានភ្លាមៗ ពីសមាសភាគផ្សេងទៀតសម្រាប់ការទ្រទ្រង់ផ្នែកសង្គ្រោះបន្ទាន់ និងការស្រោចស្រង់ឡើង វិញនៅក្នុងព្រឹត្តិការណ៍ដែលមានការប្រកាសអាសន្ន។ សមាសភាគនេះនឹងផ្តល់ហិរញ្ញប្បទានលើការចំណាយចំពោះវិស័យសាធារណៈ និងវិស័យ

PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ឯកជនទៅលើ បញ្ហើចំនិញវិជ្ជមាន និង/ឬ កិច្ចការជាក់លាក់ ចំនិញ សេវាកម្ម និងការចំណាយលើកិច្ចការសង្គ្រោះបន្ទាន់ ដែលតម្រូវការសម្រាប់ការស្រោចស្រង់ឡើងវិញ។

ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់ជំនួយដល់ប្រទេសមីយ៉ាន់ម៉ាជាមួយនឹងការស្តារបណ្តាញបញ្ជូន និងបណ្តាញចែកចាយដែលមានស្រាប់ ដើម្បីបង្កើនការផ្គត់ផ្គង់ និងអត្រាតំណភ្ជាប់អគ្គិសនីនៅក្នុងប្រទេស។ នៅក្នុងខែធ្នូ ឆ្នាំ២០១៣ ធនាគារអភិវឌ្ឍន៍អាស៊ី បានអនុម័តផ្តល់កម្ចីចំនួន ៦០ លានដុល្លារអាមេរិក សម្រាប់គម្រោងបង្កើនការចែកចាយថាមពល នៅក្នុងប្រទេសមីយ៉ាន់ម៉ា។ រាជរដ្ឋាភិបាលប្រទេសមីយ៉ាន់ម៉ា ក៏បានផ្តល់មូលនិធិបន្ថែមចំនួន ១៣,៧ លានដុល្លារអាមេរិកសម្រាប់គម្រោងនេះផងដែរ។ ក្រោមគម្រោងបង្កើនការចែកចាយថាមពលនេះ ការស្តារឡើងវិញនូវបណ្តាញចែកចាយនៅក្នុងប្រទេសមីយ៉ាន់ម៉ា រួមមាន ការធ្វើឱ្យប្រសើរឡើងវិញនូវអនុស្ថានីយ៍ ៦៦/១១ គីឡូវ៉ុល និង ៣៣/១១ គីឡូវ៉ុល ជំនួសនូវបណ្តាញចែកចាយ ដែលមានស្រាប់ ៣៣ គីឡូវ៉ុល និង ១១ គីឡូវ៉ុល ផ្លាស់ប្តូរឧបករណ៍ បំប្លែងថាមពល ១១/០,៤ គីឡូវ៉ុល ដែលមានស្រាប់ ធ្វើការផ្លាស់ប្តូរបណ្តាញចែកចាយវ៉ុលទាប ដែលមានស្រាប់ជាមួយនឹងបណ្តុំឧបករណ៍ ចម្លងចែកចាយអគ្គិសនីយ លើអាកាសដែលមានប្រសិទ្ធិភាពជាងមុន និងធ្វើការផ្លាស់ប្តូរកុងទ័រវាស់ម៉ែត្រ ចាស់ដែលមានស្រាប់ជំនួសដោយកុងទ័រវាស់ម៉ែត្រឌីជីថលវិញ។ គម្រោងបង្កើនការចែកចាយថាមពលនឹងផ្តល់នូវលទ្ធផលក្នុងការកាត់បន្ថយការបាត់បង់អគ្គិសនីអំឡុងពេលចែកចាយ បង្កើននូវប្រសិទ្ធភាពថាមពល និងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការផ្គត់ផ្គង់អគ្គិសនីដែលទុកចិត្ត និងមាននិរន្តភាព ទៅដល់តំបន់ដែលស្ថិតនៅក្នុងគម្រោងនេះ ។ តំបន់ដែលស្ថិតនៅក្នុងគម្រោងនេះ មានទីប្រជុំជនចំនួន ៥ នៅក្នុងតំបន់ Yangon ខណ្ឌចំនួន ៤ នៅក្នុងតំបន់ Mandalay ខណ្ឌចំនួន ៥ នៅក្នុងតំបន់ Sagaing និងទីប្រជុំជនចំនួន ០២ នៅក្នុងតំបន់ Magway។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ ធនាគាររអភិវឌ្ឍន៍អាស៊ី ក៏បានអនុម័តកម្ចីដែលមានទឹកប្រាក់ចំនួន ៨០ លានដុល្លារអាមេរិក សម្រាប់គម្រោងបង្កើនការបញ្ជូនថាមពលនៅក្នុងប្រទេសមីយ៉ាន់ម៉ា។ រាជរដ្ឋាភិបាលប្រទេសមីយ៉ាន់ម៉ា ក៏បានផ្តល់មូលនិធិបន្ថែមចំនួន ៣,៣ លានដុល្លារអាមេរិក នៅក្នុងគម្រោងនេះ ផងដែរ។ គម្រោងបង្កើនការបញ្ជូនថាមពល រួមបញ្ចូលការសាងសង់ដូចជា៖

- ការសាងសង់បណ្តាញបញ្ជូនរវាងអនុស្ថានីយ៍ Thida និង អនុស្ថានីយ៍ Thaketa ប្រវែង ៨,២ គីឡូម៉ែត ទំហំ ២៣០ គីឡូវ៉ុល
- ការសាងសង់បណ្តាញបញ្ជូនរវាងអនុស្ថានីយ៍ Thaketa និង អនុស្ថានីយ៍ Kyaikasan ប្រវែង ៨,៦ គីឡូម៉ែត ទំហំ ២៣០ គីឡូវ៉ុល;
- ការពង្រីក ទីធ្លាភ្ជាប់ផ្តាច់ចរន្ត របស់អនុស្ថានីយ៍ Thaketa ដែលមានស្រាប់ទំហំ ២៣០ គីឡូវ៉ុល;
- ធ្វើឱ្យប្រសើរឡើងនូវអនុស្ថានីយ៍ Kyaikasan ដែលមានស្រាប់ ពីទំហំ ៦៦ គីឡូវ៉ុល ទៅ ២៣០ គីឡូវ៉ុល និង;
- ការសាងសង់អនុស្ថានីយ៍ថ្មីទំហំ ២៣០ គីឡូវ៉ុល នៅ Okkalapa និង សាកលវិទ្យាល័យ West។

PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

គម្រោងបង្កើនការបញ្ជូនថាមពល គ្រោងនឹងបញ្ចប់នៅខែមិថុនា ឆ្នាំ២០១៩។ គម្រោងបង្កើនការបញ្ជូនថាមពល នឹងជួយបំពេញវង្វង់នៃការបញ្ជូនទំហំ ២៣០ គីឡូវ៉ុល ដែលផ្គត់ផ្គង់អគ្គិសនីទៅតំបន់ Yangon ដែលធ្វើឱ្យប្រព័ន្ធ ថាមពលបញ្ជូននៅតំបន់ Yangon ទទួលបានការជឿជាក់កាន់តែខ្លាំង ។

គម្រោងអភិវឌ្ឍន៍បណ្តាញបញ្ជូនថាមពលថ្នាក់ជាតិ រំពឹងទុកថានឹងបង្កើនសមត្ថភាពបញ្ជូន និងធ្វើឱ្យប្រសើរ ឡើងនូវភាពជឿជាក់លើបណ្តាញជាតិនៅក្នុងប្រទេសមីយ៉ាន់ម៉ា តាមរយៈការសាងសង់អនុស្ថានីយ៍ និងបណ្តាញបញ្ជូន ៥០០ គីឡូវ៉ុល។ ដោយសារតែការចំណាយខ្ពស់ គម្រោងអភិវឌ្ឍន៍បណ្តាញបញ្ជូនថាមពល នឹងត្រូវធ្វើឡើងក្នុងបី (៣) ដំណាក់កាល។ នៅក្នុងខែមីនា ឆ្នាំ២០១៥ ក្រុមហ៊ុន Japan International Cooperation Agency បានអនុម័តប្រាក់កម្ចីចំនួន ២៤.៦៧៨ លានយ៉េនជប៉ុន សម្រាប់ដំណាក់កាលទីមួយ (១)។ ក្រោមគម្រោងអភិវឌ្ឍន៍បណ្តាញបញ្ជូនថាមពលថ្នាក់ជាតិ ដំណាក់កាលទី (១) មានការសាងសង់នូវអនុស្ថានីយ៍ ពីរ (២) នៅ Meikhtila និង Taungoo នៅក្នុងតំបន់ Mandalay និង តំបន់ Bago ដែលរំពឹងថានឹងបញ្ចប់នៅខែកញ្ញា ឆ្នាំ២០២០។

នៅក្នុងខែតុលា ឆ្នាំ២០១៦ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន បានអនុម័តប្រាក់កម្ចីចំនួន ៤១.១១៥ លានយ៉េនជប៉ុន សម្រាប់គម្រោងអភិវឌ្ឍន៍បណ្តាញបញ្ជូនថាមពលថ្នាក់ជាតិ ដំណាក់កាលទីពីរ (២) ដើម្បីសាងសង់អនុស្ថានីយ៍ទំហំ ៥០០ គីឡូវ៉ុល ចំនួនពីរ (២) នៅក្នុង Phayargi និង Hlaingthayar និងបណ្តាញបញ្ជូនដែលមានប្រវែង ៩៥ គីឡូម៉ែត និងទំហំ ៥០០ គីឡូវ៉ុល រវាង Phayargi និង Hlaingthayar។ គម្រោងអភិវឌ្ឍបណ្តាញបញ្ជូនថាមពលជាតិ ដំណាក់កាលទីពីរ (២) នេះ រំពឹងទុកថានឹងបញ្ចប់នៅក្នុងខែមករា ឆ្នាំ២០២១។ ដើម្បីបង្កើនសមត្ថភាពបញ្ជូនអគ្គិសនីនៅក្នុងប្រទេសមីយ៉ាន់ម៉ាបន្ថែមទៀត ក្រុមហ៊ុនឯកជន Serbian បានផ្តល់គ្រឿងបរិក្ខារ និងសម្ភារៈ សម្រាប់ការសាងសង់បណ្តាញបញ្ជូនដែលមានប្រវែង ២៣៥ គីឡូម៉ែត និង ទំហំ៥០០ គីឡូវ៉ុល ពីMeikhtila ទៅ Taungoo ដែលត្រូវបានបញ្ចាប់ការសាងសង់ និងចាប់ផ្តើមដំណើរការក្នុងឆ្នាំ២០១៩។

ការប្រើប្រាស់ថាមពលអគ្គិសនី

ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសមីយ៉ាន់ម៉ា កើនឡើង ៦០,៤៦% ពី ៣៩,៧៨ ទ្រីលានគីតមីយ៉ាន់ម៉ា (“MMK”) នៅក្នុងឆ្នាំ២០១១ ទៅ ៦៣,៨៣ MMK ទ្រីលានគីត នៅក្នុងឆ្នាំ២០១៨។ មូលនិធិរូបិយវត្ថុអន្តរជាតិ បានប៉ាន់ប្រមាណថាផលិតផលក្នុងស្រុកសរុបរបស់ប្រទេសមីយ៉ាន់ម៉ា នឹងឈានទៅដល់ចំនួន ៦៩,៣០ ទ្រីលានគីត នៅក្នុងឆ្នាំ២០១៩។ រវាងឆ្នាំ២០១១ និង ឆ្នាំ២០១៨ ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ នៅក្នុងប្រទេសមីយ៉ាន់ម៉ាបានកើនឡើងក្នុងអត្រា ៥៣,១៦% ពី ០,៧៩ MMK លានគីត ទៅ ១,២១ MMK លានគីត។ តម្រូវការប្រើប្រាស់អគ្គិសនីក្នុងមនុស្សម្នាក់នៅក្នុងប្រទេសមីយ៉ាន់ម៉ា បានកើនឡើងពី ១២៩,០៦ គីឡូវ៉ាត់ម៉ោង នៅក្នុងឆ្នាំ ២០១១ ទៅ ៣២៦,៥៤ គីឡូវ៉ាត់ម៉ោង ក្នុងឆ្នាំ ២០១៨ ដែលការកើនឡើងនេះកើតចេញពីលទ្ធផល នៃការរីកចម្រើននិន្នាការ នគរូបនីយកម្ម និង សាកលភាវូបនីយកម្មក្រុងប្រទេស។

PESTECH (CAMBODIA) PLC KINGDOM OF CAMBODIA

ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសមីយ៉ាន់ម៉ា អាចចែកចេញជាវិស័យសេដ្ឋកិច្ចសំខាន់ៗបី (៣) រួមមានវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ ក្នុងចន្លោះឆ្នាំ២០១១ និង ២០១៨ វិស័យកសិកម្ម ឧស្សាហកម្ម និង សេវាកម្ម នៅក្នុងប្រទេសមីយ៉ាន់ម៉ាបានចុះអត្រាកំណើនប្រចាំឆ្នាំចំនួន ១,៦៥% ៩,៧៧% និង ៩,២៩%។ វិស័យឧស្សាហកម្ម មានកំណើនខ្ពស់ជាងគេ ដោយវិស័យសេវាកម្មមានកំណើនខ្ពស់លំដាប់បន្ទាប់។ វិស័យ ឧស្សាហកម្ម និង សេវាកម្ម ប្រើប្រាស់អគ្គិសនីច្រើនជាងគេ ធៀបទៅនឹងវិស័យកសិកម្ម។ ហេតុដូច្នេះ ការកើនឡើងខ្ពស់នៃវិស័យទាំងពីរនេះ ត្រូវបានរំពឹងថានឹងបង្កើនតម្រូវការថាមពលអគ្គិសនីបន្ថែមនៅក្នុងប្រទេសទាំងមូល។

យោងតាមធនាគារអភិវឌ្ឍអាស៊ី ការប្រើប្រាស់អគ្គិសនីក្នុងមនុស្សម្នាក់ក្នុងប្រទេសមីយ៉ាន់ម៉ា គឺស្ថិតនៅក្នុងចំណោម ដែលទាបជាងគេនៅក្នុងប្រទេសនៃសមាគម៉ប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលការប្រើប្រាស់អគ្គិសនីក្នុងកម្រិតទាប ជាមធ្យមក្នុងមនុស្សម្នាក់នេះ គឺដោយសារអត្រាតំណភ្ជាប់អគ្គិសនីទាប ការអភិវឌ្ឍវិស័យឧស្សាហកម្មទាប និងកង្វះខាតការវិនិយោគ។ តំណភ្ជាប់អគ្គិសនី សំដៅដល់ចំនួនលំនៅដ្ឋានដែលមានតំណភ្ជាប់អគ្គិសនីទៅនឹងបណ្តាញ ធៀបនឹងចំនួនលំនៅដ្ឋានសរុប។ នៅក្នុងប្រទេសមីយ៉ាន់ម៉ា ចំនួននៃអត្រាតំណភ្ជាប់អគ្គិសនីនៅក្នុងទីក្រុង និងភូមិក្នុងប្រទេសទាំងមូល កើនឡើងក្នុងអត្រា ៣៤១,៨៩% ពី ២.៧៣៦ ទីក្រុង និង ភូមិ ក្នុងឆ្នាំ ២០១១ រហូតដល់ ១២.០៩០ ទីក្រុង និងភូមិនៅក្នុងឆ្នាំ ២០១៨។ សម្រាប់ចន្លោះឆ្នាំ២០១១ និង ២០១៨ តម្រូវការអគ្គិសនីនៅក្នុងប្រទេសមីយ៉ាន់ម៉ា យោងតាមរង្វាស់នៃការលក់ថាមពលអគ្គិសនី បានកើនឡើងពី ៦.៣១២,០៨ ជីកាវ៉ាត់ម៉ោង ទៅ ១៧.១១៥,៤៧ ជីកាវ៉ាត់ម៉ោង ជាមួយអត្រាកំណើនប្រចាំឆ្នាំ ១៥,៣២%។ ការលក់ថាមពលអគ្គិសនីនៅក្នុងប្រទេសមីយ៉ាន់ម៉ា អាចបែងចែកជាបួន (៤) ប្រភេទទៅតាមអ្នកប្រើប្រាស់ចុងក្រោយ ដែលមានដូចជា៖

- ប្រភេទប្រើប្រាស់ទូទៅ សំដៅដល់ការប្រើប្រាស់អគ្គិសនីតាមលំនៅដ្ឋាន
- ប្រភេទថាមពលឧស្សាហកម្ម សំដៅដល់ការប្រើប្រាស់អគ្គិសនីពីវិស័យឧស្សាហកម្ម
- ប្រើប្រាស់អគ្គិសនីជាដុំ សំដៅដល់ការប្រើប្រាស់អគ្គិសនីពីវិស័យពាណិជ្ជកម្ម និង
- ការប្រើប្រាស់ផ្សេងទៀត រួមមានការប្រើប្រាស់អគ្គិសនីសម្រាប់សេវាកម្មសាធារណៈដូចជាភ្លើងបំភ្លឺផ្លូវ និងភ្លើងបំភ្លឺបណ្តោះអាសន្ន។

ចាប់តាំងពីឆ្នាំ២០១១ រហូតដល់ឆ្នាំ២០១៨ ការលក់ថាមពលអគ្គិសនីមានចំនួនច្រើនលើសលុបនៅក្នុងប្រភេទផ្សេងៗទៀត ដែលកើនឡើងពី ៦៥,៦០ ជីកាវ៉ាត់ម៉ោង នៅក្នុងឆ្នាំ២០១១ ទៅ ៨.១២៩,៧៤ ជីកាវ៉ាត់ម៉ោង នៅក្នុងឆ្នាំ២០១៨ ក្នុងអត្រាកំណើនប្រចាំឆ្នាំខ្ពស់ដល់ទៅ ៩៩,០៨%។

ក្រុះវាជាណាចក្រកម្ពុជា
ផេសទិក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA)
PLC
KINGDOM OF CAMBODIA

ការលក់អគ្គិសនីនៅក្នុងប្រទេសមីយ៉ាន់ម៉ា [a, b]

ឆ្នាំ	ការលក់ថាមពលអគ្គិសនី (ជីកាវ៉ាត់ម៉ោង)				
	គោលដៅទូទៅ	អគ្គិសនីសម្រាប់វិស័យឧស្សាហកម្ម	អគ្គិសនីជាដុំ	អគ្គិសនីផ្សេងៗទៀត	ចំនួនសរុប
២០១១	២.៦៥៣,៣៣	២.២៨៦,៧៧	១.៣០៦,៣៨	៦៥,៦០	៦.៣១២,០៨
២០១២	៣.៣៨០,៩៧	២.៧២៧,៣៧	១.៥៣១,៧១	៧៦,៨១	៧.៧១៦,៨៦
២០១៣	៣.៦៥៥,១៨	២.៦៧៦,៥៧	១.៦៥២,៨១	២៨០,៦៣	៨.២៥៥,១៩
២០១៤	៣.៧៦៤,០០	២.៦៦៩,០០	១.៦៩២,១២	១.៤៥៧,៥២	៩.៦១២,៦៤
២០១៥	៤.១១២,៨៣	២.៩៨៤,៦០	១.៧៥៤,៥៨	២.៤០២,៩៤	១១.២៥៤,៩៦
២០១៦	៣.៥៦៧,១៥	២.១៤៤,៨៥	១.៤៦៣,៧៥	៦.២២០,៨០	១៣.៣៩៦,៥៥
២០១៧	៣.៤៥១,០៧	២.១១៩,៧៥	១.៣៧៧,៩២	៨.៤០៦,៣៥	១៥.៣៥៥,០៩
២០១៨	៤.៥០៩,៨២	២.៧៧២,៨២	១.៧០៣,០៤	៨.១២៩,៧៤	១៧.១១៥,៧៤
អត្រាកំណើនប្រចាំឆ្នាំ (%)	**៧,៨៧**	**២,៧៩**	**៣,៨៦**	**៩៩,៨០**	**១៥,៣២**

[a] *ទន្និន័យត្រូវបានបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ*

[a] *គិតត្រឹមថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៩*

ប្រភព: Central Statistical Organisation, ការវិភាគរបស់ក្រុមហ៊ុន SMITH ZANDER

ចលករធំការរីកចម្រើនសម្រាប់ការប្រើប្រាស់ថាមពលអគ្គិសនី

ការប្រើប្រាស់ ឬតម្រូវការក្នុងការប្រើប្រាស់ថាមពលអគ្គិសនី គឺជាចលករដ៏សំខាន់មួយសម្រាប់ការផ្គត់ផ្គង់អគ្គិសនី និងជាចលករក្នុងការទាមទារឱ្យមានដំណោះស្រាយបច្ចេកទេស និងវិស្វកម្មប្រព័ន្ធថាមពល។ តម្រូវការអគ្គិសនី ត្រូវបានរំពឹងថានឹងមានការកើនឡើង ស្របពេលជាមួយនឹងកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសមីយ៉ាន់ម៉ា។ ដោយសារថាមពល អគ្គិសនីដើរតួនាទីសំខាន់ក្នុងការជំរុញឱ្យមានការរីកចម្រើន ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីនៅក្នុងប្រទេសមីយ៉ាន់ម៉ា ត្រូវបានរំពឹងទុកថានឹងមានការកើនឡើងនៅក្នុងឆ្នាំបន្តបន្ទាប់ទៅតាមលទ្ធផលជាក់ស្តែង នៃកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេស។ រដ្ឋាភិបាលប្រទេសមីយ៉ាន់ម៉ា បានអនុវត្តផែនការអភិវឌ្ឍទូលំទូលាយថ្នាក់ជាតិ (២០១១-២០៣១) ដែលជាគម្រោង មានរយៈពេល ២០ ឆ្នាំ មានគោលដៅក្នុងការបង្កើនផលិតផលក្នុងស្រុកសរុបរបស់ប្រទេស ដល់ចំនួន ១៨០ ពាន់លានដុល្លារអាមេរិក និងផលិតផលក្នុងស្រុកក្នុងមនុស្សម្នាក់ចំនួន ៣០០០ ដុល្លារអាមេរិកក្នុងឆ្នាំ ២០៣០។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ផែនការអភិវឌ្ឍទូលំទូលាយថ្នាក់ជាតិ នឹងត្រូវអនុវត្តតាមផែនការបួន (៤) ឆ្នាំ ដែលរាល់ផែនការប្រាំ (៥) ឆ្នាំម្តង ផ្តោតទៅលើការអនុវត្តចំណុចយុទ្ធសាស្ត្រមួយចំនួន។ រាជរដ្ឋាភិបាលប្រទេសមីយ៉ាន់ម៉ា បានអនុវត្តផែនការប្រាំ (៥) ឆ្នាំ លើកដំបូង (២០១១-១២ ទៅ ២០១៥-១៦) ដែលអាទិភាពផ្តោតសំខាន់ទៅលើផ្នែកចំណីអាហារ សំលៀកបំពាក់ និង ទីជំរកសម្រាប់សាធារណៈជន ស្របទៅនឹងនិន្នាការផ្លាស់ប្តូរក្នុងប្រទេស។ ផែនការប្រាំ (៥) ឆ្នាំ លើកទីពីរ (២០១៦-១៧ ទៅ ២០២០-២១) នឹងត្រូវអនុវត្តនៅក្នុងខែមេសា ឆ្នាំ២០១៦ និងមានគោលដៅដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ច ដោយលើកទឹកចិត្តការវិនិយោគនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជនតាមរយៈដំណើរការឧស្សាហូបនីយកម្ម។

[ផ្នែកដែលនៅសល់ខាងក្រោមត្រូវបានទុកឱ្យនៅទំនេរដោយចេតនា]

៣ ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីនៅក្នុងប្រទេសឡាវ

ប្រតិបត្តិការឧស្សាហកម្ម ទស្សនៈវិស័យ និង ការវិនិយោគ

សមត្ថភាពនៃការផលិត

ការផ្គត់ផ្គង់អគ្គិសនីនៅប្រទេសឡាវ កើតចេញពីរោងចក្រវារីអគ្គិសនី។ អគ្គិសនីដែលផ្គត់ផ្គង់នៅក្នុងប្រទេសឡាវ ផ្អែកតាមរង្វាស់ទំហំផលិតកម្មសរុប កើនឡើងពី២.៥៦៩,៧០ មេកាវ៉ាត់ នៅក្នុងឆ្នាំ២០១១ ទៅដល់ ៦.៦១៤,១៤ មេកាវ៉ាត់ នៅក្នុងឆ្នាំ២០១៧ ក្នុងអត្រាកំណើនប្រចាំឆ្នាំ ១៧,០៧% ក្នុងឆ្នាំ២០១៧ ប្រទេសឡាវមានរោងចក្រវារីអគ្គិសនីសរុបចំនួន ៦១ រោងចក្រ។

ប្រទេសឡាវស្ថិតនៅតំបន់ ឆ្លងកាត់ដោយមូសុងពីរ (២) ទិសដៅ ដែលចេញពីឈូងសមុទ្រថៃ និងឈូងសមុទ្រតុងកាំង។ គួបផ្សំជាមួយនឹងអនុតំបន់ទន្លេមេគង្គនៅក្នុងប្រទេស ប្រទេសឡាវមានវារីអគ្គិសនីដែលមានសក្តានុពលយ៉ាងខ្លាំង។ អគ្គិសនីដែលផលិតឡើងដោយរោងចក្រវារីអគ្គិសនីនៅក្នុងប្រទេសគឺប្រើប្រាស់សម្រាប់ផ្គត់ផ្គង់អគ្គិសនីទៅដល់អ្នកប្រើប្រាស់ក្នុងស្រុក ក៏ដូចជាការនាំចេញទៅប្រទេសជិតខាងដែលរួមមានប្រទេសថៃ ប្រទេសវៀតណាម សាធារណរដ្ឋប្រជាមានិតចិន ប្រទេសកម្ពុជា និងប្រទេសមីយ៉ាន់ម៉ា។

សមត្ថភាពផលិតនៃឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីនៅក្នុងប្រទេសឡាវ[a]

ឆ្នាំ	សមត្ថភាពផលិត (មេកាវ៉ាត់)
២០១១	២.៥៦៩,៧០
២០១២	២.៩៧៣,១៥
២០១៣	២.៩៨០,២៤
២០១៤	៣.០៥៨,៤៨
២០១៥	៦.២៦៤,៨០
២០១៦	៦.៣៧៣,១៨
២០១៧	៦.៦១៤,១៤
អត្រាកំណើនប្រចាំឆ្នាំ (%)	**១៧,០៧**

[a] *ត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ (ទិន្នន័យសម្រាប់ឆ្នាំ២០១៨ មិនទាន់មានជាសាធារណៈនៅឡើយ)*

ប្រភព៖ អគ្គីសនីឡាវ និង ការវិភាគរបស់ក្រុមហ៊ុន SMITH ZANDER

តាមច្រឹស្តី ប្រទេសឡាវមានសក្តានុពលខាងអគ្គិសនីដែលផលិតចេញពីវារីអគ្គិសនីមានទំហំប្រមាណ ២៦.៥០០ មេកាវ៉ាត់ ដែលអគ្គិសនីទំហំ ១៨.០០០ មេកាវ៉ាត់ នៃទំហំនេះអាចយកជាអត្ថប្រយោជន៍បាន។ នៅក្នុងឆ្នាំ ២០១៧ ទំហំផលិតកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

របស់រោងចក្រវារីអគ្គិសនីនៅប្រទេសឡាវ មានទំហំ ៦.៦១៤,១៤ មេកាវ៉ាត់ តំណាងឱ្យប្រមាណ ៣៦,៧៥% នៃទំហំ ទ្រឹស្តីដែលប្រទេសអាចយកជាអត្ថប្រយោជន៍បាន (theoretically exploitable capacity)។

ក្រៅពីសក្តានុពលវារីអគ្គិសនីនេះ ធ្យូងថ្មក៏ជាធនធានសំខាន់សម្រាប់ការផលិតអគ្គិសនីនៅក្នុងប្រទេសឡាវដែរ។ ប៉ុន្តែការប្រើប្រាស់ធ្យូងថ្មដើម្បីជាធនធានសម្រាប់ផលិតអគ្គិសនី គឺស្ថិតនៅក្នុងដំណាក់កាលកំពុងតែចាប់ផ្តើម។ រោងចក្រថាមពល Hongsa ដែលជារោងចក្រផលិតអគ្គិសនីចេញពីធ្យូងថ្ម lignite ជាមួយនឹងមានម៉ាស៊ីន ភ្លើងចំនួនបី (៣) និងមានទំហំ ១.៨៧៨ មេកាវ៉ាត់ កំពុងស្ថិតនៅក្នុងដំណាក់កាលសាងសង់។ គម្រោងទាំងមូលនេះនឹងត្រូវបាន បញ្ចប់នៅចុងឆ្នាំ២០១៥។ អគ្គិសនីដែលផលិតចេញពីរោងចក្រថាមពល Hongsa ភាគច្រើនត្រូវបាននាំចេញទៅប្រទេសថៃ។ នៅពេលដែលរាល់ម៉ាស៊ីនផលិតទាំងបី (៣) ដាក់ឱ្យដំណើរការ វានឹងក្លាយជារោងចក្រផលិតអគ្គិសនីដែលមានទំហំធំជាងគេនៅក្នុងប្រទេសឡាវ។ រោងចក្រផលិតថាមពលអគ្គិសនី Hongsa នឹងផ្តល់និរន្តរភាពថាមពលសម្រាប់ប្រទេសឡាវនិងប្រទេសថៃ។ រោងចក្រផលិតថាមពលអគ្គិសនី Hongsa នឹងផលិតអគ្គិសនី ១.៤៧៣ មេកាវ៉ាត់ ដើម្បីលក់ឱ្យអាជ្ញាធរអគ្គិសនី នៃប្រទេសថៃ សម្រាប់រយៈពេល ២៥ ឆ្នាំ ខណៈដែលថាមពលនៅសេសសល់ទុកសម្រាប់ប្រើប្រាស់នៅក្នុងស្រុក។

បន្ថែមពីនេះ ដោយសារប្រទេសឡាវ ជាប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ជីវម៉ាសក៏អាចជាជម្រើសធនធានថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីផងដែរ។ ធនធានជីវម៉ាសដែលមានសក្តានុពលរួមមាន កាកសំណល់ពីឈើ អង្កាមស្រូវ និងកាកសំណល់អំពៅ។ យោងតាមធនាគារអភិវឌ្ឍអាស៊ី អង្កាមស្រូវប្រមាណ ៣៣ តោន អាចផលិតអគ្គិសនីបាន ១ មេកាវ៉ាត់។

ចលកវនៃការរីកចម្រើន និងផែនការពង្រីកការសមត្ថភាពផលិតនាពេលអនាគត

ផែនការអភិវឌ្ឍប្រព័ន្ធថាមពល (២០០៥-២០២០) ផ្តល់នូវផែនការសម្រាប់ការអភិវឌ្ឍវិស័យអគ្គិសនីនៅក្នុង ប្រទេសឡាវ សម្រាប់គោលបំណងនៃការប្រើប្រាស់ក្នុងស្រុក និងនាំចេញ។ ក្នុងគម្រោងអភិវឌ្ឍប្រព័ន្ធថាមពលនេះ រដ្ឋាភិបាលប្រទេសឡាវ ដាក់ទិសដៅបង្កើតឱ្យមានតំណភ្ជាប់ថាមពលអគ្គិសនីនៅតាមលំនៅដ្ឋាន ៩០% ក្នុងប្រទេសត្រឹមឆ្នាំ ២០២០ តាមរយៈការអភិវឌ្ឍតំណភ្ជាប់ក្រៅបណ្តាញ និងការពង្រីកបណ្តាញ។ រាជរដ្ឋាភិបាលប្រទេសឡាវ ក៏មានគោលដៅប្រើប្រាស់តំបន់ភូមិសាស្ត្រ និងសក្តានុពល នៃការផ្គត់ផ្គង់អគ្គិសនីរបស់ខ្លួន ដើម្បីធ្វើឱ្យប្រទេសក្លាយជាតួអង្គសំខាន់ក្នុងការលើកកម្ពស់ការធ្វើពាណិជ្ជកម្ម ថាមពលអគ្គិសនីក្នុងតំបន់ នៅក្នុងអនុតំបន់ទន្លេមេគង្គផងដែរ។

ផែនការអភិវឌ្ឍការផ្គត់ផ្គង់អគ្គិសនីរបស់ក្រសួងរ៉ែ និងថាមពលរបស់ប្រទេសឡាវ (“MEM”) ពឹងផ្អែកលើការពង្រីកសមត្ថភាព ផលិតអគ្គិសនីនៅក្នុងប្រទេសឡាវ។ បច្ចុប្បន្ន នៅក្នុងប្រទេសឡាវ មានរោងចក្រវារីអគ្គិសនីចំនួន ៥ ដែលមានទំហំផលិតអគ្គិសនីសរុបចំនួន ២.១៦០ មេកាវ៉ាត់ ដែលកំពុងសាងសង់ និងរំពឹងដាក់ឱ្យ ដំណើរការក្នុងចន្លោះឆ្នាំ២០១៩ និង ២០២០។ លើសពីនេះ រោងចក្រវារីអគ្គិសនីពីរ (២) ទៀត ដែលមានសមត្ថភាពផលិតអគ្គិសនីសរុបចំនួន ៩៧២ មេកាវ៉ាត់

ប្រាះរាជាណាចក្រកម្ពុជា
ផេសទិក
(ខេបបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

កំពុងស្ថិតក្នុងដំណាក់កាលសាងសង់ ខណៈការកំណត់កាលបរិច្ឆេទដាក់ឱ្យដំណើរការមិនទាន់ប្រកាសជាសាធារណៈនៅឡើយ។

ផែនការពង្រីកការផលិតសម្រាប់ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីក្នុងប្រទេសឡាវជាមួយនឹងគោលដៅប្រតិបត្តិការសម្រាប់ឆ្នាំ២០១៩ និងឆ្នាំទៅមុខ

គម្រោង	ប្រភេទរោងចក្រ	សមត្ថភាពផលិត (មេកាវ៉ាត់)	គោលដៅដាក់ឱ្យដំណើរការ
Xayaboury (Mekong)	វារីអគ្គិសនី	១.២៨៥	២០១៩
Xepian-Xenamnoy	វារីអគ្គិសនី	៤១០	២០១៩
Nam Ngiep 1	វារីអគ្គិសនី	២៩០	២០១៩
Nam Pha	វារីអគ្គិសនី	១៣០	២០១៩
Nam Phak	វារីអគ្គិសនី	៤៥	២០២០
Don Sahong	វារីអគ្គិសនី	២៤០	មិនទាន់មានកំណត់កាលបរិច្ឆេទ
Nam Ou 1,3,4 and 7	វារីអគ្គិសនី	៧៣២	មិនទាន់មានកំណត់កាលបរិច្ឆេទ
	សរុប	**៣.១៣២**	

ប្រភព: Department of Energy Business ("DEB"), ការវិភាគរបស់ក្រុមហ៊ុន SMITH ZANDER

សមត្ថភាពបញ្ជូន និងចែកចាយថាមពលអគ្គិសនី

នៅក្នុងប្រទេសឡាវ អគ្គិសនីដែលផលិតបានដោយរោងចក្រផលិតអគ្គិសនី គឺត្រូវបានបញ្ជូនទៅអនុស្ថានីយ៍ក្នុងស្រុកតាមរយៈបណ្តាញបញ្ជូន ១១៥ គីឡូវ៉ុល។ ប្រព័ន្ធបញ្ជូននៅក្នុងប្រទេសឡាវបែងចែកជាបួន (៤) ដែលប្រព័ន្ធនីមួយៗបញ្ជូនអគ្គិសនីទៅតំបន់មួយនៃតំបន់បួន (៤) នៅក្នុងប្រទេស។ ប្រព័ន្ធបញ្ជូនទាំងបួន (៤) ស្ថិតនៅ តំបន់ភាគខាងជើង តំបន់ភាគកណ្តាល១ តំបន់ភាគកណ្តាល២ និង តំបន់ភាគខាងត្បូង។

កំណើននៃបណ្តាញបញ្ជូន និងចែកចាយ នៅប្រទេសឡាវ ទ្រទ្រង់ទៅដល់កំណើននៃហេដ្ឋារចនាសម្ព័ន្ធ ផលិតកម្មអគ្គិសនីនៅក្នុងប្រទេស។ កំណើនឧស្សាហកម្មបញ្ជូនថាមពលអគ្គិសនីនៅប្រទេសឡាវ តំណាងដោយការកើនឡើងនៃកំណើនសមត្ថភាពប្រព័ន្ធបញ្ជូនរបស់ជាតិ ចន្លោះឆ្នាំ២០១១ និង២០១៧។ ប្រវែងសរុបនៃបណ្តាញបញ្ជូន ១១៥ គីឡូវ៉ុល នៅប្រទេសឡាវបានកើនឡើងពីប្រវែង ៣.៣៤២,៧៦ គីឡូម៉ែត នៅក្នុងឆ្នាំ២០១១ រហូតដល់ ៦.៦៤៦,៥០ គីឡូម៉ែត ក្នុងឆ្នាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

២០១៦ នៅអត្រាកំណើនប្រចាំឆ្នាំ ១២,១៤%។ សមត្ថភាពរបស់អនុស្ថានីយ៍បញ្ជូននៅប្រទេសឡាវ កើនឡើងពី ២.៤៦៧,៤០ ម៉េកាវ៉ុលអំពែរ នៅក្នុងឆ្នាំ ២០១១ ទៅ ៤.៥៥០,១០ ម៉េកាវ៉ុលអំពែរ នៅក្នុងឆ្នាំ ២០១៧ នៅអត្រាកំណើនប្រចាំឆ្នាំ ១០,៧៤%។

អគ្គិសនីផលិតចេញពីរោងចក្រអគ្គិសនីដែលត្រូវបានបញ្ជូនទៅប្រទេសថៃ និងប្រទេសវៀតណាម ប្រើប្រាស់បណ្តាញបញ្ជូន ១១០ គីឡូវ៉ុល ១១៥ គីឡូវ៉ុល ២៣០ គីឡូវ៉ុល និង ៥០០ គីឡូវ៉ុល។ បណ្តាញបញ្ជូនទាំងនេះមានប្រវែងសរុបថេរ ៧៩៣,៦៧ គីឡូម៉ែត នៅចន្លោះឆ្នាំ២០១១ និង ២០១៧។

សមត្ថភាពប្រព័ន្ធបញ្ជូនប្រទេសឡាវ[a]

	២០១១	២០១២	២០១៣	២០១៤	២០១៥	២០១៦	២០១៧	អត្រាកំណើនប្រចាំឆ្នាំ (%)
បណ្តាញបញ្ជូន (គីឡូម៉ែត)								
១១៥ គីឡូវ៉ុល	៣.៣៤២,៧៦	៤.៥៥៣,៥៣	៤.៣៥៦,៦៦	៤.៥៣៨,៥៣	៥.២៥៧,១៨	៦.៩៦៨,២៣	៦.៦៤៦,៦០	១២,១៤
២៣០គីឡូវ៉ុល	៧៣៦,៤៤	៧៣៦,៤៤	៧៣៦,៤៤	៧៣៦,៤៤	១.៣៧១,១៤	មិនមាន	មិនមាន	១៦,៨១ [b]
៥០០គីឡូវ៉ុល	៣៣០,០០	៣៣០,០០	៣៣០,០០	៣៣០,០០	៣៤០,០០	មិនមាន	មិនមាន	០,៧៥ [b]
អនុស្ថានីយ៍បញ្ជូន								
ចំហាំ (ម៉េកាវ៉ុលអំពែរ)	២.៤៦៧,៤០	២.៨៥៥,៧០	៣.១៧៥,៥០	៣.៥០៦,៧៤	៣.៨៣៧,៤៦	៤.១៣៦,៩៣	៤.៥៥០,១០	១០,៧៤

[a] *ត្រឹមថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៩ (ទិន្នន័យសម្រាប់ឆ្នាំ ២០១៨ មិនទាន់មានជាសាធារណៈនៅឡើយ)*

[b] អត្រាកំណើនប្រចាំឆ្នាំ ត្រូវបានគណនាសម្រាប់ចន្លោះឆ្នាំ២០១១ ទៅឆ្នាំ២០១៥ ទិន្នន័យសម្រាប់ឆ្នាំ២០១៦ និង២០១៧ មិនទាន់មានជាសាធារណៈនៅឡើយ

ប្រភព: EDL, ការវិភាគរបស់ក្រុមហ៊ុន SMITH ZANDER

បណ្តាញចែកចាយនៅប្រទេសឡាវ មានខ្សែបណ្តាញចែកចាយ ៣៥ គីឡូវ៉ុល ២៥ គីឡូវ៉ុល ២២ គីឡូវ៉ុល ១២,៧ គីឡូវ៉ុល និង ០,២២ គីឡូវ៉ុល។ កំណើនឧស្សាហកម្មចែកចាយថាមពលអគ្គិសនីនៅប្រទេសឡាវ តំណាងដោយការកើនឡើងនៃប្រវែងខ្សែបណ្តាញចែកចាយជាតិ ក្នុងចន្លោះឆ្នាំ២០១១ និង ឆ្នាំ២០១៦។ ប្រវែងសរុបបណ្តាញចែកចាយនៅក្នុង ប្រទេសឡាវ កើនឡើងពី ៣១.៦២៣ គីឡូម៉ែត នៅក្នុងឆ្នាំ២០១១ ទៅ ៤៩.២៥០,៣៥ គីឡូម៉ែត ក្នុងឆ្នាំ២០១៧ ក្នុងអត្រាកំណើនមធ្យមប្រចាំឆ្នាំ ៧,៦៦%។

ក្រុមហ៊ុនសាយសាច្រកកម្ពុជា
ភេសេទិក
(ខេមបូឌា) ប.ក
PESTECH (CAMBODIA)
PLC
KINGDOM OF CAMBODIA

សមត្ថភាពប្រព័ន្ធចែកចាយនៅប្រទេសឡាវ [a]

	២០១១	២០១២	២០១៣	២០១៤	២០១៥	២០១៦	២០១៧	អត្រាកំណើនប្រចាំឆ្នាំ (%)
ម៉ែត្របណ្តាញចែកចាយ (គីឡូម៉ែត)								
៣៥ គីឡូវ៉ុល	១៨៨	១៥២	១៩៩	២២០	២៣៧	២៦០០	២៨៨	៧,៣៧
២៥ គីឡូវ៉ុល	១៦៧	១៥៨	១០៥	៩,៦៥	០	០	០	-១០០,០០
២២ គីឡូវ៉ុល	១៧.១២៧	២០.៦១៣	២២.៤៧៥	២៥.៦៨៨	២៦.៤៥០	២៨.២៦៥	២៩.៧២០	៩,៦២
១២,៧ គីឡូវ៉ុល	២៦៨	២៧៩	២៩០	២៩៦,២៥	២៩៥	២៣៦.៦៥	៣១៥,៤៥	២,៥៩
០,៤ គីឡូវ៉ុល	១៣.៨១៣	១៥.១៧២	១៥.៩៧១	១៧.១២៨	១៧.៧៦៦,៤៧	១៨.៣៧៦	១៨.៩០៣	៥,៣៧
០,២២ គីឡូវ៉ុល	៦០	៧៧	១១៩	៦៨,៧៥	៤៧,៦៥	៤៧,២៧	២៦,៩១	-១២,៥១
សរុប	**៣១.៦២៣**	**៣៦.៤៥១**	**៣៩.១៥៨**	**៤២.៤១០,៦២**	**៤៥.៧៩៥,១១**	**៤៧.១៨៣,៩១**	**៤៩.២៥០,៣៥**	**៧,៦៦**

[a] *ត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ (ទិន្នន័យសម្រាប់ឆ្នាំ ២០១៨ មិនទាន់មានជាសាធារណៈនៅឡើយ)*

ប្រភព: EDL, ការវិភាគរបស់ក្រុមហ៊ុន SMITH ZANDER

ចលករនៃការរីកចម្រើន និងផែនការពង្រីកលទ្ធភាពបញ្ជូន និងចែកចាយថាមពលអគ្គិសនីនាពេលអនាគត

រដ្ឋាភិបាលប្រទេសឡាវ មានគោលដៅភ្ជាប់ចរន្តអគ្គិសនី ៩០% ដល់លំនៅដ្ឋាន នៅក្នុងប្រទេសត្រឹមឆ្នាំ២០២០។ គោលដៅនេះនឹងត្រូវសម្រេចបានតាមរយៈ ការអភិវឌ្ឍតំណភ្ជាប់អគ្គិសនីក្រៅបណ្តាញ ឬការពង្រីកបណ្តាញ។ តំណភ្ជាប់អគ្គិសនីក្រៅបណ្តាញ នឹងត្រូវផ្តល់ដល់លំនៅដ្ឋាន ដោយមិនចាំបាច់ភ្ជាប់អគ្គិសនីពីបណ្តាញឡើយ។ រដ្ឋាភិបាលប្រទេសឡាវ មានគោលដៅផ្តល់ជូនការតភ្ជាប់អគ្គិសនីក្រៅបណ្តាញ ដល់ ១៥០.០០០ លំនៅដ្ឋាន ត្រឹមឆ្នាំ២០២០។ ការពង្រីកបណ្តាញ ក៏ត្រូវធ្វើឡើងដើម្បីតភ្ជាប់អគ្គិសនីដល់លំនៅដ្ឋានប្រជាពលរដ្ឋនៅក្នុងប្រទេសទាំងអស់ ដើម្បីឆ្លើយតបទៅនឹងគោលដៅរបស់រដ្ឋាភិបាលប្រទេសឡាវ ក្នុងការតភ្ជាប់អគ្គិសនីឱ្យ បាន ៩០% ដល់លំនៅដ្ឋាន ទូទាំងផ្ទៃប្រទេស ត្រឹមឆ្នាំ២០២០។ ក្នុងឆ្នាំ ២០១៧ អត្រានៃការតភ្ជាប់អគ្គិសនីនៅ តាមសង្កាត់ ភូមិ និងលំនៅដ្ឋាន ក្នុងប្រទេសឡាវមាន ១០០% ៩០,១៥% និង ៩៤,២៣%។ ភាគរយនៃ លំនៅដ្ឋានដែលទទួលបានការតភ្ជាប់ថាមពលអគ្គិសនីកើនឡើងពី ៧៨,៥៣% ក្នុងឆ្នាំ២០១១ ដល់៩៤,២៣% ក្នុងឆ្នាំ២០១៧ ដែលគោលដៅ ៩០% នៃការតភ្ជាប់ថាមពលអគ្គិសនីដល់លំនៅដ្ឋានត្រូវបានសម្រេចត្រឹមឆ្នាំ២០២០។

ក្រោយសាលាក្រុងកំពង់ឆ្នាំង
ផែនដីក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

អត្រាតំណភ្ជាប់អគ្គិសនីនៅក្នុងប្រទេសឡាវ [a]

ឆ្នាំ	ខណ្ឌដែលមានអគ្គិសនីតភ្ជាប់	តំណភ្ជាប់អគ្គិសនី (%)	ភូមិដែលមានអគ្គិសនីតភ្ជាប់	តំណភ្ជាប់អគ្គិសនី (%)	លំនៅដ្ឋានដែលមានអគ្គិសនីតភ្ជាប់	តំណភ្ជាប់អគ្គិសនី (%)
២០១១	១៣៩	៩៧,២	៦.០១០	៦៨,៩៩	៨២១.២៩៥	៧៨,៥៣
២០១២	១៤៥	១០០	៦.៤៤៨	៧៤,៤៩	៨៧៦.៧៦២	៨២,២៥
២០១៣	១៤៣	៩៨,៦២	៦.៩២៤	៨០,៣២	៩៣៤.៥៩៩	៨៧,៣៤
២០១៤	១៤៥	៩៩,៣២	៧.២០៣	៨៤,០៤	៩៨៦.៤៣៥	៨៨,៧០
២០១៥	១៤៨	១០០	៧.៣៧៣	៨៥,៩	១.០៣៨,២៤៨	៩០,៥១
២០១៦	១៤៨	១០០	៧.៥៥៤	៨៨,៤១	១.០៧៨,៧១២	៩២,៣៩
២០១៧	១៤៨	១០០	៧,៦៦៧	៩០,១៥	១.០៩២,៦១១	៩៤,២៣

[a] ត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ (ទិន្នន័យសម្រាប់ឆ្នាំ២០១៨ មិនទាន់មានជាសាធារណៈនៅឡើយ)

ប្រភព: EDL, ការវិភាគរបស់ក្រុមហ៊ុន SMITH ZANDER

គម្រោងបណ្តាញបញ្ជូនមួយចំនួន ត្រូវបានកំណត់ក្នុងផែនការអភិវឌ្ឍអគ្គិសនីរយៈពេលវែង (២០១២ - ២០២២)។ គម្រោងបណ្តាញបញ្ជូននៅក្នុងប្រទេសរួមមាន ការសាងសង់បណ្តាញបញ្ជូន នៅតំបន់ភាគខាងជើង និងភាគកណ្តាល១ តំបន់ភាគកណ្តាល២ និង ភាគខាងជើង បណ្តាញបញ្ជូន ៥០០ គីឡូវ៉ុល នៅតំបន់ភាគខាងជើង និងភាគកណ្តាល១ និង បណ្តាញបញ្ជូន ២៣០ គីឡូវ៉ុល ទៅ ៥០០ គីឡូវ៉ុល នៅក្នុងតំបន់ភាគកណ្តាល២ និងភាគខាងត្បូង។ លើសពីនេះ ការតភ្ជាប់បណ្តាញជាមួយប្រទេសថៃ និងប្រទេសវៀតណាមក៏នឹងត្រូវពង្រីកផងដែរ ជាមួយនឹងផែនការតំណភ្ជាប់ឆ្លងប្រទេសដែលនឹងត្រូវអនុវត្តនៅក្នុងឆ្នាំ២០២០។

បន្ថែមពីលើនេះ EDL គ្រោងនឹងពង្រីកបណ្តាញបញ្ជូននៅក្នុងប្រទេសឡាវ តាមរយៈការសាងសង់អនុស្ថានីយ៍ចំនួន ៣៨ និងការតម្លើងបណ្តាញអគ្គិសនីតង់ស្យុងខ្ពស់យ៉ាងហោចណាស់ប្រវែង ៦.០០០ គីឡូម៉ែតនៅក្នុងឆ្នាំ២០២៥។ ការពង្រីកបណ្តាញបញ្ជូននៅក្នុងប្រទេស នឹងជួយទ្រទ្រង់ដល់ការអភិវឌ្ឍវិស័យអគ្គិសនីនៅក្នុងប្រទេសឡាវ ក៏ដូចជាជួយសម្រួលដល់ការនាំចេញអគ្គិសនីទៅដល់ប្រទេសថៃ និងប្រទេសវៀតណាមដែលបម្រើដល់ការហូរចូលនៃចំណូលរូបិយប័ណ្ណបរទេសសម្រាប់ប្រទេស។

ការប្រើប្រាស់ថាមពលអគ្គិសនី

ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសឡាវ បានកើនឡើងត្រឹម ៥១,៥៧% ពី ឡាវគីប ("LAK") ៨១,៦១ទ្រីលានគីប ក្នុងឆ្នាំ២០១២ ទៅ LAK ១២៣,៧០ទ្រីលានគីប នៅក្នុងឆ្នាំ ២០១៨។ អង្គការ IMF រំពឹងថាផលិតផលក្នុងស្រុកសរុប របស់ប្រទេសឡាវនឹងកើនដល់ ១៣១,៦៦ ទ្រីលានគីប នៅក្នុងឆ្នាំ ២០១៩។ រវាងឆ្នាំ ២០១២ និង ២០១៨ ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់នៅប្រទេសឡាវបានកើនឡើងត្រឹម ៣៨,៣៩% ពី ១២,៦៦ លានគីប ទៅដល់ ១៧,៥២ លានគីប។

ក្រុមហ៊ុនសាធារណៈចំកាត់ដីស្ងួត
ផេសទីក
(ខេមបូឌា) ម.ក
PESTECH (CAMBODIA)
PLC
KINGDOM OF CAMBODIA

តម្រូវការអគ្គិសនីក្នុងមនុស្សម្នាក់នៅប្រទេសឡាវ បានកើនឡើងពី ៣៧៧,៩៧ គីឡូវ៉ាត់ម៉ោង នៅក្នុងឆ្នាំ ២០១១ ដល់ ៧១៤,២៧ គីឡូវ៉ាត់ម៉ោង ក្នុងឆ្នាំ២០១៧ ដែលជាលទ្ធផលកើតចេញពី ការរីកចម្រើន និន្នាការនគរូបនីយកម្ម និងសាកលភាវូបនីយកម្ម។

ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសឡាវ អាចបែងចែកជាសកម្មភាពសេដ្ឋកិច្ចចម្បងបី (៣) ដែលមានដូចជា កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ នៅចន្លោះឆ្នាំ ២០១២ និង ឆ្នាំ២០១៧ វិស័យកសិកម្ម វិស័យឧស្សាហកម្ម និង វិស័យសេវាកម្ម នៅក្នុងប្រទេសឡាវ មានអត្រាកំណើនប្រចាំឆ្នាំ ២,៩០% ៨,៨៩% និង ៦,៩៥% រៀងគ្នា។ វិស័យឧស្សាហកម្មគឺជាវិស័យដែលមានកំណើនខ្ពស់ជាងគេ តាមពីក្រោយដោយវិស័យសេវាកម្ម ដែលមានអត្រាកំណើនខ្ពស់ប្រហាក់ ប្រហែល។ វិស័យឧស្សាហកម្ម និងសេវាកម្ម ប្រើប្រាស់អគ្គិសនីច្រើនជាងបើប្រៀបធៀប ទៅនឹងវិស័យកសិកម្ម ដូចនេះ កំណើនដ៏ខ្ពស់របស់វិស័យទាំងពីរនេះ រំពឹងថានឹងបន្តបង្កើនតម្រូវការអគ្គិសនីនៅក្នុងប្រទេស។

សម្រាប់អំឡុងឆ្នាំ ២០១១ និង ២០១៧ ការប្រើប្រាស់អគ្គិសនីនៅក្នុងប្រទេសឡាវ បានកើនឡើងពី ២.៣៩៩,៣៦ ជីកាវ៉ាត់ម៉ោង ដល់ ៤.៩៦៦,៣២ ជីកាវ៉ាត់ម៉ោង នៅក្នុងអត្រាកំណើនប្រចាំឆ្នាំ ១២,៨៩%។ ប្រភេទអ្នកប្រើប្រាស់អគ្គិសនីចុងក្រោយក្នុងវិស័យឧស្សាហកម្ម និងលំនៅដ្ឋាន មានចំនួនច្រើនក្នុងឆ្នាំ២០១៦ បង្កើតជាភាគរយប្រហែល ៤១,០១% និង ៣៦,៥៤%។

ការប្រើប្រាស់អគ្គិសនីនៅក្នុងប្រទេសឡាវ [a] [b]

ប្រភេទ	ការប្រើប្រាស់អគ្គិសនី (ជីកាវ៉ាត់ម៉ោង)							
	២០១១	២០១២	២០១៣	២០១៤	២០១៥	២០១៦	២០១៧	អត្រាកំណើនប្រចាំឆ្នាំ (%)
លំនៅដ្ឋាន	១.០០៤,០៧	១.១៦០,៩៨	១.២៧៨,៤២	១.៤២៤,១៥	១.៥៩៤,៦៥	១.៧៣៥,១៧	១.៨១៤,៤៦	១០,៣៦
ពាណិជ្ជកម្ម វិស័យអប់រំ និង អាជីវកម្មកីឡា	៥៩៨,៧៤	៧៩៩,៧៣	៧៤០,៣៣	៥៤០,៤៤	៦១៥,៥៥	៦៩៧,៩៧	៧៥៨,២៦	៤,០២
ការកំសាន្ត	៧,៧៨	៨,៨៣	៩,១៦	៩,៤៩	១០,៦៤	១១,៣១	១១,៦៤	៦,៩៦
ការិយាល័យរដ្ឋាភិបាល	១៤៩,០៧	១៧៣,៩២	១៨៩,១៥	២០៤,២៤	២២៨,០៦	២៥២,២១	២៥៥,៩៣	៩,៤៣
កសិកម្ម	៤៦,១៩	៣៩,៤៥	៣៥,២២	៣៥,៦១	៣២,៥៩	៣៤,២៤	២៧,៤៦	-៨,៣០
ស្ថានទូត	៩,៤៣	១០,៤៣	១០,៤៧	១២,៩៩	១២,៣៤	១២,៨១	១២,០៧	៤,២០
រោងចក្រ	៥៨៤,០៩	៦៨០,៨៧	១.១១៨,២១	១.៥៦៤,៤១	១.៧៤៥,៣២	១.៩១៦,៣៨	២.០៨៦,៥១	២៣,៦៤
សរុប	**២.៣៩៩,៣៦**	**២.៨៧៤,២១**	**៣.៣៨០,៩៦**	**៣.៧៩១,៣៣**	**៤.២៣៩,១៦**	**៤.៦៦០,១១**	**៤.៩៦៦,៣២**	**១២,៨៩**

[a] *ត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ (ទិន្នន័យសម្រាប់ឆ្នាំ ២០១៨ មិនទាន់មានជាសាធារណៈនៅឡើយ)*

[b] *តួរលេខទាំងនេះអាចនឹងមិនបូកបញ្ចូលគ្នា ដោយសារការបង្គត់* *ប្រភព: EDL, ការវិភាគរបស់ក្រុមហ៊ុន SMITH ZANDER*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
(ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

ការកើនឡើងនូវតម្រូវការថាមពលអគ្គិសនីនៅប្រទេសឡាវ ជាប់ទាក់ទងជាមួយនឹងចំនួនអ្នកប្រើប្រាស់នៅក្នុងប្រទេស។ ចំនួនអ្នកប្រើប្រាស់សរុបនៅក្នុងប្រទេសឡាវ បានកើនឡើងពី ៨៦៥.៥២៨ នាក់ ក្នុងឆ្នាំ២០១១ ទៅ ១,៣៦៥,៧២២ នាក់ ក្នុងឆ្នាំ២០១៧ នៅអត្រាកំណើនប្រចាំឆ្នាំ ៧,៩៤%។

ចលកវនៃការរីកចម្រើននៃការប្រើប្រាស់ថាមពលអគ្គិសនី

ការប្រើប្រាស់ ឬតម្រូវការថាមពលអគ្គិសនី គឺជាចលកវដ៏សំខាន់មួយសម្រាប់ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនី និងជាចលកវ ក្នុងការទាមទារឱ្យមានដំណោះស្រាយបច្ចេកទេស និងវិស្វកម្មប្រព័ន្ធថាមពល។ តម្រូវការអគ្គិសនី រំពឹងទុកថានឹងមានការ ពង្រីកស្របជាមួយនឹងកំណើនសេដ្ឋកិច្ចនៃប្រទេសឡាវ។ ដោយសារថាមពលអគ្គិសនីដើរតួនាទីសំខាន់ក្នុងការជំរុញឱ្យ មានការរីកចម្រើន ឧស្សាហកម្មផ្គត់ផ្គង់អគ្គិសនីនៅប្រទេសឡាវ ត្រូវបានរំពឹងទុកថានឹងមានការកើនឡើងនៅក្នុងឆ្នាំបន្ត បន្ទាប់ ទៅតាមលទ្ធផលជាក់ស្តែងនៃកំណើនសេដ្ឋកិច្ច នៅក្នុងប្រទេស។

